Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

32784

# កម្ពុជា

## ឯកសារយុទ្ធសាស្ត្រវិស័យជនបទរបស់កម្ពុជា



### ឆ្ពោះទៅកាន់យុទ្ធសាស្ត្រកំណើន
### និងការកាត់បន្ថយភាពក្រីក្រនៅជនបទ

ខែ មិថុនា ឆ្នាំ២០០៥

ធនាគារពិភពលោក

# របាយការណ៍លេខ...~KH

# ឯកសារយុទ្ធសាស្ត្រវិស័យជនបទរបស់កម្ពុជា :

# ឆ្ពោះទៅកាន់វឌ្ឍនភាពនៅជនបទ និង ការកាត់បន្ថយភាពក្រីក្រ

**រៀបចំដោយក្រុមធនាគារពិភពលោកសំរាប់រាជរដ្ឋាភិបាលកម្ពុជា**

ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥

ផ្នែកអភិវឌ្ឍន៏ជនបទ និង ធនធានធម្មជាតិ
តំបន់អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក

**រូបិយវត្ថុ និង អត្រាប្តូរប្រាក់**

ឯកត្តារូបិយវត្ថុ- ប្រាក់រៀលកម្ពុជា

អត្រាប្តូរប្រាក់ (គិតត្រឹមខែមិថុនា ឆ្នាំ ២០០៥) : ៤.២៨៥ រៀល

ឆ្នាំសារពើពន្ធ

( ថ្ងៃទី ១ ខែ មករា ដល់ ៣១ ខែ ធ្នូ)

| | |
|---|---|
| អនុប្រធានប្រចាំតំបន់ | Jemal-ud-Din Kassum |
| នាយកប្រចាំប្រទេស | Ian C. Porter |
| នាយយកគ្រប់គ្រងប្រចាំប្រទេស | Nisha Agrawal |
| នាយកតាមផ្នែក | Mark D. Wilson |
| នាយកគ្រប់គ្រងតាមផ្នែក | Hoonae Kim |
| ប្រធានក្រុមការងារ | Marianne Grosclaude |

# ពាក្យបំព្រួញ

| | | |
|---|---|---|
| **AAA** | - | សេវាវិភាគ និង ផ្តល់ប្រឹក្សា |
| **ADB** | - | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **AEW** | - | បុគ្គលិកផ្សព្វផ្សាយកសិកម្ម |
| **AFD** | - | ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ |
| **AQIP** | - | គំរោងលើកកំពស់គុណភាពកសិកម្ម |
| **APIP** | - | គំរោងលើកកំពស់ផលិតភាពកសិកម្ម |
| **ARD** | - | ការអភិវឌ្ឍន៍កសិកម្ម និង ជនបទ |
| **AusAID** | - | ទីភ្នាក់ងារអូស្ត្រាលីអភិវឌ្ឍន៍អន្តរជាតិ |
| **ASDL** | - | ឥណទានអភិវឌ្ឍន៍វិស័យកសិកម្ម (ADB) |
| **ASEAN** | - | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ |
| **CAEEP** | - | គំរោងផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី |
| **CAS** | - | យុទ្ធសាស្ត្រជំនួយប្រចាំប្រទេស |
| **CIAP** | - | គំរោងអ៊ីរីកម្ពុជា-អូស្ត្រាលី |
| **CIDA** | - | ទីភ្នាក់ងារកាណាដាដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| **CLP** | - | ក្រុមប្រឹក្សាគោលនយោបាយដីធ្លី |
| **CSES** | - | អង្កេតសេដ្ឋកិច្ចនិងសង្គមកិច្ចកម្ពុជា |
| **C/SF** | - | មូលនិធិឃុំ/សង្កាត់ |
| **DANIDA** | - | ជំនួយដាណឺម៉ាកសំរាប់អភិវឌ្ឍន៍អន្តរជាតិ |
| **DAO** | - | ការិយាល័យកសិកម្មស្រុក |
| **DFID** | - | ក្រសួងអភិវឌ្ឍន៍អន្តរជាតិ (UK) |
| **DoF** | - | នាយកដ្ឋានជលផល |
| **EBA** | - | គំរោង "អ្វីៗទាំងអស់ក្រៅពីអាវុធ" របស់សហភាពអឺរ៉ុប |
| **EC** | - | សហគមន៍អឺរ៉ុប |
| **ECHO** | - | ការិយាល័យមនុស្សធម៌នៃគណៈកម្មការសហគមន៍អឺរ៉ុប |
| **FAO** | - | អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ |
| **FDI** | - | វិនិយោគក្នុងស្រុកពីបរទេស |
| **FWUC** | - | សហគមន៍កសិករប្រើប្រាស់ទឹក |
| **GDP** | - | ផលិតផលក្នុងស្រុកសរុប |

| | | |
|---|---|---|
| **IMF** | - | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **IFAD** | - | មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍន៍កសិកម្ម |
| **IFAPER** | - | ការវាយតំលៃទំនុកចិត្ត និង ចំណាយសាធារណៈ |
| **JICA** | - | ទីភ្នាក់ងារសហប្រត្តិបត្តិការអន្តរជាតិជប៉ុន |
| **LIL** | - | ឥណទានសំរាប់ការសិក្សានិងនវានុវត្តន៍ |
| **LMAP** | - | គំរោងគ្រប់គ្រងនិងរដ្ឋបាលដីធ្លី |
| **MLMUPC** | - | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |
| **MAFF** | - | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| **MEF** | - | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| **MDG** | - | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| **MFI** | - | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| **MFO** | - | អង្គការមីក្រូហិរញ្ញវត្ថុ |
| **MIME** | - | ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| **MOC** | - | ក្រសួងពាណិជ្ជកម្ម |
| **MOE** | - | ក្រសួងបរិស្ថាន |
| **MOEY** | - | ក្រសួងអប់រំ យុវជន និង កីឡា |
| **MOI** | - | ក្រសួងមហាផ្ទៃ |
| **MOWVA** | - | ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន |
| **MOWRAM** | - | ក្រសួងធនធានទឹក និង ឧតុនិយម |
| **MRC** | - | គណៈកម្មការទន្លេមេគង្គ |
| **MRD** | - | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **MTEF** | - | ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម |
| **NBC** | - | ធនាគារជាតិនៃកម្ពុជា |
| **NGO** | - | អង្គការក្រៅរដ្ឋាភិបាល |
| **NPRS** | - | យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ |
| **O&M** | - | ប្រតិបត្តិការ និង ការថែទាំ |
| **PDAFF** | - | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត |
| **PRASAC II** | - | កម្មវិធីស្តារនិងគាំទ្រវិស័យកសិកម្មនៅកម្ពុជា |
| **PRDC** | - | គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត |
| **PRIP** | - | គំរោងហេដ្ឋារចនាសម្ព័ន្ធខេត្តនិងជនបទ |

| | | |
|---|---|---|
| **PSIA** | - | ការប៉ាន់ប្រមាណផលប៉ះពាល់នៃភាពក្រីក្រនិងសង្គម |
| **RDB** | - | ធនាគារអភិវឌ្ឍន៍ជនបទ |
| **RGC** | - | រាជរដ្ឋាភិបាលកម្ពុជា |
| **RSSN** | - | ឯកសារយុទ្ធសាស្ត្រវិស័យជនបទ |
| **SEDP** | - | គំរោងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច |
| **SIDA** | - | ទីភ្នាក់ងារស៊ុយអែតដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| **SME** | - | សហគ្រាសខ្នាតតូចនិងមធ្យម |
| **TA** | - | ជំនួយបច្ចេកទេស |
| **UNDP** | - | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **VAHW** | - | បសុពេទ្យភូមិ |
| **WHO** | - | អង្គការសុខភាពពិភពលោក |
| **WTO** | - | អង្គការពាណិជ្ជកម្មពិភពលោក |

# មាតិកា


**អារម្ភកថា** x

**សេចក្តីថ្លែងអំណរគុណ** ខ

**ខ្លឹមសារសង្ខេប** ១

**ផ្នែក I: ការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្ន និងកំណើន: ចំណុចស្នូលនៃការអភិវឌ្ឍន៍ជនបទ** ១

កំណើនកន្លងមកមិនបាននាំមកនូវការកាត់បន្ថយភាពក្រីក្រជាធំដុំទេ ១

ជីវភាពរស់នៅ នៅតំបន់ជនបទ នៅមានកម្រិតដោយសារការខ្វះនូវកាលានុវត្តភាព និងភាពងាយរងគ្រោះ ៤

ការគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិកំពុងមានការប្រែប្រួលយ៉ាងខ្លាំង ៩

ការអនុវត្តនីការងារវិស័យកសិកម្មមានការខកចិត្ត ១២

សេវាជាមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធមានការខ្វះខាតយ៉ាងខ្លាំង ១៨

**ផ្នែក II : ការបន្តកិច្ចអភិវឌ្ឍន៍ជនបទ ~ ធាតុសំខាន់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ កសិកម្ម និងអភិវឌ្ឍន៍វិស័យជនបទឆ្ពោះទៅរកអ្នកក្រ** ២៤

ការកែលំអការគ្រប់គ្រងនិងបង្កើនលទ្ធភាពបានទទួលបាននូវសម្បត្តិធម្មជាតិដែលមាន ផលិតភាព ២៦

*កំណែទំរង់រដ្ឋបាលដីធ្លី និងកំណែទំរង់ការគ្រប់គ្រងដីធ្លី* *២៧*

*កំណែទំរង់លើការគ្រប់គ្រងព្រៃឈើ* *៤០*

*កំណែទំរង់ការគ្រប់គ្រងជលផល* *៥៣*

*កំណែទំរង់លើការគ្រប់គ្រងទឹក និងលើការគ្រប់គ្រងទឹកជំនន់* *៦១*

ការបង្កើនប្រាក់ចំណូលកសិកម្ម ៧៣

*ការពង្រឹង និងគ្រប់គ្រងតាមវិស័យ* *៧៦*

*ការសម្រួលសេវាគាំទ្របច្ចេកទេស និងសេវាគាំទ្រទីផ្សារ* *៨៣*

*កំណត់កម្មវិធីសំរាប់លើកកំពស់លទ្ធផលអនុវត្តន៍នៃអនុវិស័យសំខាន់ផ្នែកកសិកម្ម* *៩០*

ផ្សារភ្ជាប់គំលាតលើលទ្ធភាពទទួលបានសេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធ ១០៥

*អភិវឌ្ឍន៍សេវាហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទ* *១០៥*

*ការពង្រីកសេវាហិរញ្ញវត្ថុនៅតំបន់ជនបទ* *១១១*

**ផ្នែកទី III : ការផ្តល់លទ្ធផល និងជំហានបន្ទាប់** **១២០**
ពង្រឹងចំណងទាក់ទងចំពោះរបៀបវារៈ គាំទ្រតាមវិស័យ
១២៣
*ការគ្រប់គ្រងធនធានសាធារណៈ* *១២៤*
*វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន* *១២៦*
*ការប្រឆាំងអំពើពុករលួយ និងកំណែទំរង់ប្រព័ន្ធច្បាប់និងតុលាការ* *១៣០*
*ការអភិវឌ្ឍន៍ផ្នែកឯកជន និងសេដ្ឋកិច្ចជនបទមិនមែនកសិកម្ម* *១៣៤*
ការប្រមូលផ្តុំទៅលើតួនាទីផ្នែកសាធារណៈសំខាន់ៗ ១៣៩
តំរូវការសំរបសំរួល រួមមានការគាំទ្រពីអ្នកផ្តល់ជំនួយ ១៤២
ជំហានបន្ទាប់ ១៤៦

**ឯកសារយោងសំខាន់ៗ** **១៩៤**
**ឧបសម្ព័ន្ធ ១: គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា** **១៩៨**
**ឧបសម្ព័ន្ធទី ២: ប្រព័ន្ធជាំដុះ** **២០០**
**ឧបសម្ព័ន្ធទី ៣: ផែនទី** **២០៦**

## តារាង

តារាង ១: ការរួមចំណែកតាមវិស័យចំពោះ អឌុភ និងការងារ (ប្រភព: ក្រសួងពាណិជ្ជកម្ម) ២
តារាង ២: សមាមាត្រភាគរយមធ្យមនៃប្រភពផ្សេងៗគ្នានៃចំណូល ធៀបនឹងចំណូលគ្រួសារសរុបនៅជនបទ តាមបញ្ចភាគ ៥
តារាង ៣: កម្ពុជា - ការប៉ាន់ស្មាននៃសិទ្ធិកាន់កាប់/ប្រើប្រាស់ដីធ្លី , ២០០៤ ១២
តារាង ៤: ការគ្រប់ដណ្តប់សេវាហេដ្ឋារចនាសម្ព័ន្ធ-ការប្រៀបធៀបជាមួយប្រទេសជិតខាង ២០
តារាង ៥: វិនិយោគដែលបានអនុម័ត[ក/] (ដុល្លារអាមេរិក - តួលេខប៉ាន់ស្មាន) ២២
តារាងទី៦ : លក្ខណៈស្តីពីបច្ចេកវិទ្យាកសិកម្ម និងកត្តាលើកទឹកចិត្តវិស័យឯកជនក្នុងការផ្តល់បច្ចេកវិទ្យា ៨៣
តារាងទី ៧: ផលចំណូលនៃការធ្វើវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម និងផលប៉ះពាល់ទៅលើការកាត់

បន្ថយភាពក្រីក្រនៅប្រទេសចិន និងឥណ្ឌា ១២៣

តារាងទី ៨: វិស័យដែលកំណែទំរង់អន្តរផ្នែកមានឥទ្ធិពលទៅលើសេដ្ឋកិច្ចជនបទ-ឧទាហរណ៍ជ្រើសរើស ១៣៥

## ប្រអប់

ប្រអប់១: លទ្ធផលសង្ខេប និងអនុសាសន៍ដកស្រង់ពី ការសិក្សាវាយតំលៃស្ថានភាពយេនឌ័រ នៅកម្ពុជា ៨

ប្រអប់ ២: លទ្ធផលនៃការវិភាគតំបន់សេដ្ឋកិច្ចស្បៀង របស់កម្មវិធីស្បៀងអាហារពិភពលោក ១០

ប្រអប់ ៣: ស្ថានភាពនៃសេវាហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចនៅតំបន់ជនបទ ១៩

ប្រអប់ទី៤ : បញ្ហាប្រឈមនៃការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតធំនៅកម្ពុជា ៦៣

ប្រអប់ទី ៥ : បញ្ហាគន្លឹះនៃ ភកី នៅក្នុងវិស័យកសិកម្ម ៧៦

ប្រអប់ទី៦ : ឧបសគ្គសំខាន់ៗចំពោះកិច្ចអភិវឌ្ឍន៍ពាណិជ្ជកម្ម ៨៧

ប្រអប់ទី ៧: កែលំអភាពដែលអាចព្យាករណ៍បាននៃកិច្ចសន្យា ១៣០

ប្រអប់ទី ៨: មេរៀនបទពិសោធន៍ខ្លះដែលបានមកពីការពិនិត្យឡើងវិញនាពេលថ្មីៗនៃជំនួយបរទេស ១៤០

# អារម្ភកថា

ក្រោយពេលងើបចេញពីសង្គ្រាមរយៈពេល ៣ ទសវត្សរ៍ កម្ពុជា បានឆ្លងកាត់ដំណាក់កាលអន្តរកាលផ្នែក សេដ្ឋកិច្ច នយោបាយ និង សង្គម អស់រយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ។ កម្ពុជា បានធ្វើឱ្យមានការប្រែប្រួលយ៉ាងលឿន លើផ្នែកស្ថាប័ន ការស្តារឡើងវិញនូវសន្តិភាព និង ការផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការបែបមជ្ឈការ ទៅជាសេដ្ឋកិច្ចទីផ្សារ និង ពីភាពឯកោទៅការធ្វើសមាហរណកម្មចូលក្នុងសហគមន៍តំបន់និងពិភពលោក ។ សមិទ្ធផលសំខាន់ៗដែលសំរេចបានរហូតមកដល់ពេលនេះ មានដូចជា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ ២០០២ និង ការបោះឆ្នោតជ្រើសរើសសមាជិកសភាអាណត្តិទី ៣ ឆ្នាំ ២០០៣ កំណើនសេដ្ឋកិច្ចថេរ ៦% ក្នុងអំឡុងទសវត្សរ៍កន្លងមក និង ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (**WTO**) ។ ទោះបីជា ស្ថានភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាព ហើយ កំណែទំរង់រចនាសម្ព័ន្ធសំខាន់ៗត្រូវបានអនុវត្តហើយក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅតែងាយទទួលរងគ្រោះ ហើយកំណើនសេដ្ឋកិច្ចមិនទាន់បានកាត់បន្ថយភាពក្រីក្រឱ្យ បានទូលំទូលាយនៅឡើយ ។ ដោយសារផលិតផលក្នុងស្រុកសរុប (**GDP**) សំរាប់មនុស្សម្នាក់មាន ២៨០ ដុល្លាអាមេរិក និង សូចនាករសង្គមដែលបង្ហាញឱ្យឃើញថា មានការរីកចំរើនតិចតួច ចាប់តាំងពីទសវត្សរ៍ឆ្នាំ ៦០ មក កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតនៅក្នុងពិភពលោក ។ ផលវិបាកនៃសង្គ្រាម ការបាត់បង់មូលធនរូបវ័ន្តនិងសង្គម ការបាត់បង់ធនធានមនុស្ស និង គ្រាប់មីនដែលនៅសេសសល់ នៅតែជាឧបសគ្គចំពោះការអភិវឌ្ឍន៍ប្រទេសជាតិ ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង ។ លើសពីនេះទៀត សេដ្ឋកិច្ចទ្រង់ទ្រាយតូចនិង បើកចំហរបស់កម្ពុជា ក៏ជួបប្រទះនឹងបញ្ហាប្រឈម ដូចជា ការបង្កើតស្ថាប័ន និង ហេដ្ឋារចនាសម្ព័ន្ធ ដែលជួយឱ្យ សេដ្ឋកិច្ចទទួលបាននូវផលប្រយោជន៍ និងកាត់បន្ថយហានិភ័យដែលកើតចេញពីការធ្វើសមាហរណកម្មចូលក្នុង សហគមន៍តំបន់និងពិភពលោក ក្នុងបរិយាកាសមួយដែលមានការប្រកួតប្រជែងកាន់តែខ្លាំងក្លានៅក្នុងតំបន់ ។

ការរីកចំរើន ពឹងផ្អែកយ៉ាងខ្លាំងទៅលើសមិទ្ធផលដែលសំរេចបាននៅជនបទ ។ ដោយសារ ៩០ ភាគរយ នៃប្រជាជនក្រីក្ររស់នៅជនបទ គំលាតរវាងតំបន់ជនបទនិងទីក្រុងកាន់តែធំ ហើយ ការកាត់បន្ថយភាពក្រីក្រ ក្នុងអំឡុងជាងមួយទសវត្សរ៍កន្លងមកនេះមានការរីកចំរើនតិចតួច មានការឯកភាពជាទូទៅថា កំណើនសេដ្ឋកិច្ច និងការរីកចំរើនក្នុងការកាត់បន្ថយភាពក្រីក្រ ត្រូវពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើដំណោះស្រាយបញ្ហាចំបងៗ ដែលសេដ្ឋកិច្ចជនបទ កំពុងតែប្រឈមមុខ ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥ របស់ រាជរដ្ឋាភិបាល បានទទួលស្គាល់ពីតំរូវការឱ្យពង្រឹង និង ពង្រីកការធ្វើកំណែទំរង់ ដោយផ្តោតធនធានដ៏តិចតួចទៅ លើសរសរទ្រូងទាំង ៤ គឺ ការអភិវឌ្ឍន៍កសិកម្មនិងជនបទ ការអប់រំ សុខាភិបាល និង ហេដ្ឋារចនាសម្ព័ន្ធ ។ ទោះបីជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចប្រាំឆ្នាំលើកទីពីរ និងយុទ្ធសាស្ត្រ-ជាតិកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល បានកំណត់នូវអាទិភាពទូទៅសំរាប់វិស័យជនបទក៏ដោយ ក៏នៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីរៀបចំឱ្យមានកម្មវិធីច្បាស់លាស់សំរាប់ស្តារសេដ្ឋកិច្ចជនបទឡើងវិញ ដោយចាប់ផ្តើមពីការផ្សព្វផ្សាយសកម្មភាពជាអាទិភាពឱ្យបានច្បាស់លាស់និងមានយុទ្ធសាស្ត្រល្អជាងមុន ការផ្សារភ្ជាប់កំណែទំរង់និង ការវិនិយោគ

ជាមួយនឹងធនធានដែលមានស្រាប់ ការបង្កើនការយកចិត្តទុកដាក់ទៅលើទិន្នផលនិងលទ្ធផល និង ការពង្រឹង កិច្ចសហការនៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសំរេចឱ្យបានលទ្ធផលជាអតិបរមា ។

ធនាគារពិភពលោក ត្រូវបានស្នើសុំឱ្យចូលរួមក្នុងដំណើរការនេះ ដោយបន្តធ្វើការងារវិភាគ ជាពិសេសបញ្ចូលសំណើរបស់ខ្លួនទៅក្នុងឯកសារយុទ្ធសាស្ត្រវិស័យជនបទ (**RSSN**) នេះ ។ ដំណាក់កាលទីមួយនៃការងារ នេះបាននាំឱ្យមានឯកសារព្រាងខែ មិនា ២០០៣-មិនា ២០០៤ ។ ដំណាក់កាលទីពីរ មិនា ២០០៤-ឧសភា ២០០៥ បានអនុញ្ញាតអោយរដ្ឋាភិបាល ម្ចាស់ជំនួយ និង ដៃគូដទៃទៀតពិភាក្សាឯកសារព្រាងនេះ និងបាននាំដល់ការរៀបចំឯកសារនេះ ដែលជាការរួមចំណែកចំពោះកិច្ចពិភាក្សាកំពុងប្រព្រឹត្តទៅជុំវិញអាទិភាពជាយុទ្ធសាស្ត្រ សំរាប់កិច្ចអភិវឌ្ឍន៍តំបន់ជនបទ និងសកម្មភាពជាក់លាក់ សំរាប់ឈានដល់សំរេចលទ្ធផលដែលបានឯកភាពគ្នា ។ គឺការរៀបចំឯកសារយុទ្ធសាស្ត្រវិស័យជនបទនេះ ។ ដំណាក់កាលទីពីរ គឺ ជំរុញឱ្យ រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងដៃគូដទៃទៀត មានការឯកភាពគ្នា ជាទូទៅលើអាទិភាពជាយុទ្ធសាស្ត្រ និងសកម្មភាពជាក់លាក់មួយចំនួន ដើម្បីសំរេច ឱ្យបាននូវលទ្ធផលដែលអាចទទួលយកបានទាំងអស់គ្នា ។

ឯកសារនេះ មានគោលបំណងផ្តល់នូវក្របខ័ណ្ឌដ៏ទូលំទូលាយមួយសំរាប់ការពិភាក្សាលើជំរើសទិសដៅនាពេលអនាគតរបស់កម្ពុជា ក្នុងការអភិវឌ្ឍន៍ជនបទ ជាមួយនឹង រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និង ដៃគូដទៃទៀត ។ លើសពីនេះទៀត ឯកសារនេះ ក៏មានគោលបំណងផ្តល់នូវពត៌មានទាក់ទងនឹងការរៀបចំយុទ្ធសាស្ត្រជំនួយប្រចាំ ប្រទេសថ្មី (**Country Assistance Strategy**) របស់ធនាគារពិភពលោក ដែលកំពុងតែដំណើរការ ដោយមានការចូលរួមសហការពី ធនាគារអភិវឌ្ឍន៍អាស៊ី និង ក្រសួងអភិវឌ្ឍន៍អន្តរជាតិ **(DFID)** ។ ឯកសារនេះ បានផ្តល់នូវរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ននៅក្នុងវិស័យជនបទនិងផ្នែកជាអាទិភាព ដើម្បីសំរេចឱ្យបាននូវអត្រាកំណើនដ៏ទូលំ-ទូលាយនិងមានការីតខ្ពស់សំរាប់ជួយឱ្យវិស័យជនបទ បន្តចូលរួមចំណែកបង្កើនចំណូលនៅជនបទ និង ទីក្រុង/ទីប្រជុំជន និងការងារ ។

ឯកសារនេះ មាន ៣ ផ្នែកធំៗ : ផ្នែកទី **I** បង្ហាញពីទិដ្ឋភាពទូទៅទាក់ទងនឹងសេដ្ឋកិច្ចជនបទ ។ ផ្នែកទី **II** ពិនិត្យមើលឡើងវិញលើបញ្ហាចំបងៗ ដែលមានផលប៉ះពាល់ដល់វិស័យជនបទ និងស្នើឡើងនូវកត្តាមួយចំនួននៃយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មនិងជនបទដែលជួយដល់ប្រជាជនក្រីក្រ និងផ្នែកទី **III** ពិភាក្សាលើបញ្ហារួម ដែលមានផលប៉ះពាល់លើលទ្ធផល ក៏ដូចជា សំណើសុំឱ្យមានសកម្មភាពបន្តពីឯកសារនេះ ។

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះរៀបចំដោយក្រុមមួយដែលដឹកនាំដោយ Marianne Grosclaude និង Louise Scura និង Stephen Mink ដោយមានការរួមវិភាគទានពី Wael Zakout Malcolm Childress និង Keith Bell (ដីធ្លី) William B. Magrath និង Peter Jipp (ព្រៃឈើ) Douglas Olson (គ្រប់គ្រងធនធានទឹក) Idah Pswarayi-Riddihough (គ្រប់គ្រងគ្រោះថ្នាក់ដោយធម្មជាតិ) Ronald Zweig (ជលផល) Steven Schonberger (គ្រប់គ្រងធនធានធម្មជាតិ) Andrew Goodland (អាជីវកម្មកសិកម្ម ឱកាសការងារក្រៅពីកសិកម្ម) Philippe Boyer (កសិកម្ម) Christina Malmberg Calvo (ហេដ្ឋារចនាសម្ព័ន្ធជនបទ) និង Richard Burcroff ។ Steven Schonberger និង ចំរើន មុទិតា បានសំរួលដំណើរការប្រឹក្សានៅកម្ពុជា ដោយមានជំនួយ ពី James Brew ទាក់ទង នឹងវិស័យឯកជន ។ ក្រុមនេះបានទទួលការគាំទ្រពីសំណាក់ Bautista-Laguidao និង Cecilia B. Tan-Yap នៅទីក្រុងវ៉ាស៊ីនតោន DC និង ខៀវ អមរា នៅភ្នំពេញ ។

ឯកសារសាវតារពាក់ព័ន្ធចំពោះរបាយការណ៍នេះត្រូវបានរៀបរៀងដោយ Kent Helmers, John Gibson និង Pia Wallgren (ប្រភពប្រាក់ចំណូលនៃគ្រួសារនៅជនបទ) Olga Torres (ហិរញ្ញវត្ថុជនបទ) Peter Millington (គ្រប់គ្រងធនធានទឹក) Joseph Ernstberger និង Liu Xueming (ប្រភពនៃកំណើន) Christian Castellanet (ផ្សព្វផ្សាយកសិកម្ម) Bruno Vindel និង Emmanuel Pousse (វិសហមជ្ឈការនៃ សេវាកសិកម្ម) ។

របាយការណ៍នេះបានទទួលមតិយោបល់ពីសហសេវិកពិនិត្យសារឡើងវិញរបស់ខ្លួន រួមមាន : Gershon Feder (នាយករបស់ DECRG) Dina Umali-Deininger (SASAR) និង Louise Bevan (ទីប្រឹក្សា) និង បានទទួលមតិពិគ្រោះពីការ Kazi Mahbub Al-Matin, Chorching Goh (EASPR), Magdi Amin (EASFP), Imogene Jensen (EASTR), Luiz Tavares (EASUR), Gillian Brown (EACTF), Glen Morgan (EASES), Rebecca Sekse (EASEG), Chandrasekar Govindarajalu (ENV), Rohit Khanna (ENVGC), Eric Haythorne (LEGPS), Zhi Liu (EASIN), និង James Brew (IFC) ។ ជាមួយ គ្នានេះផងដែរ ក៏បានទទួលការណែនាំ ដែលមានសារៈប្រយោជន៍ពី Nisha Agrawal (នាយកគ្រប់គ្រងប្រចាំប្រទេស EACSF) Homi Kharas (នាយកតាមវិស័យ EASPR) Mark D. Wilson (នាយកតាមវិស័យ EASRD) និង Hoonae Kim (នាយកគ្រប់គ្រងតាមវិស័យ EASRD) ។

ក្រុមការងារសូមថ្លែងអំណរគុណចំពោះ ឯ.ឧ. គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ឯ.ឧ. ហង់ជួន ណារ៉ុន អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានគាំទ្រ និងសំរបសំរួល

ដំណើរការប្រឹក្សាជាមួយស្ថាប័ននានារបស់រដ្ឋាភិបាល និង ភាគីពាក់ព័ន្ធដទៃទៀត និង ចំពោះ ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឯ.ឧ. អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងគ្រប់គ្រង ដែនដី នគ្ររូបនីយកម្ម និងសំណង់ ឯ.ឧ. សុក ស៊ីផាន់ណា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ឯ.ឧ. វ៉េង សាខុន រដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម និង ឯ.ឧ. លី ធុច អតីតរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ចំពោះ ពេលវេលាដែលឯកឧត្តមទាំងអស់គ្នាបានចំណាយពេលវេលា ក្នុងការសំរបសំរួល និង ផ្តល់មតិយោបល់ ចំពោះ ក្រសួងនីមួយៗរបស់ខ្លួន ។ យើងក៏សូមថ្លែងអំណរគុណផងដែរ ចំពោះមតិយោបល់ និងការរួមវិភាគទាន ដ៏មាន តំលៃពីស្ថាប័ននានារបស់រដ្ឋាភិបាលនៅភ្នំពេញ និងនៅបណ្តាខេត្ត ក៏ដូចជាពីសហគមន៍ម្ចាស់ជំនួយ រួមមានបណ្តា ប្រទេសផ្តល់ជំនួយដែលបានផ្តល់មតិយោបល់ តាមរយៈក្រុមការងារបច្ចេកទេសរួមគ្នា រវាងរដ្ឋាភិបាល និង ម្ចាស់ជំនួយ ព្រមទាំងសូមថ្លែងអំណរគុណចំពោះតំណាងជាច្រើននៃវិស័យឯកជន វិទ្យាស្ថានស្រាវជ្រាវ និង អង្គការក្រៅរដ្ឋាភិបាល ដែលបានរួមវិភាគទាន ទស្សនៈ និងមតិយោបល់របស់ខ្លួន ចំពោះសេចក្តីព្រាងពីដំបូង ។

ឯកសារនេះត្រូវបានកែសំរួលដោយ Alicia Hertzner ហើយឯកសារបកប្រែជាភាសាខ្មែរមាននៅក្នុងគេហទំព័រ របស់ក្រុមធនាគារពិភពលោក (http://www.worldbank.org/easrd) ដែលរៀបចំដោយលោក ទា សាវ៉ា(?) ។

# ខ្លឹមសារសង្ខេប

# របាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្ន និង ទស្សនៈវិស័យសំរាប់ការអភិវឌ្ឍន៍ជនបទ

កំណើនសេដ្ឋកិច្ចកម្ពុជា មានកំរិតខ្ពស់មធ្យមក្នុងអំឡុងទសវត្សរ៍កន្លងមកនេះក៏ពិតមែន ប៉ុន្តែកំណើននេះ មានតែនៅក្នុងតំបន់ទីក្រុង និងក្នុងសកម្មភាពងាយទទួលរងគ្រោះមួយចំនួនតូចប៉ុណ្ណោះ : មានសញ្ញាមួយចំនួន ដែលបង្ហាញឃើញថាសេដ្ឋកិច្ចកម្ពុជានៅទន់ខ្សោយ : ចាប់តាំងពីឆ្នាំ ១៩៩៣ មក មូលដ្ឋានកំណើនសេដ្ឋកិច្ច តូចចង្អៀត ហើយមួយភាគធំនៃកំណើននេះបានមកពីវិស័យផលិតកម្ម និងទេសចរណ៍ ។ គំលាតចំណូលរវាងទីក្រុង និងជនបទ មានទំហំធំណាស់ ដោយសារកំណើនសេដ្ឋកិច្ចរហូតមកដល់ពេលនេះ មានច្រើននៅតែតំបន់ទីក្រុង ចំណែកនៅតំបន់ជនបទ កំណើនសេដ្ឋកិច្ចមានការថយចុះ ។ វិស័យកសិកម្មដែលផ្តោតខ្លាំងតែទៅលើកសិកម្មដែលជាលក្ខណៈគ្រួសារ មានកំណើនតិចបំផុត ដោយសារផលិតភាពដីធ្លី និងកំលាំងពលកម្មមានកំរិតទាបជាងផលិតភាព និងកំលាំងពលកម្មរបស់ប្រទេសផ្សេងទៀតនៅក្នុងតំបន់ ។ ទោះជាយ៉ាងនេះក្តី វិស័យកសិកម្មដែលមានវិសាលភាព ទូលំទូលាយ រួមទាំង ការប្រើប្រាស់ធនធានធម្មជាតិដោយផ្ទាល់ ដូចជា ត្រី និង ផលិតផលព្រៃឈើ គឺ នៅតែជា ប្រភពសំខាន់បំផុតតែមួយគត់ ដែលផ្តល់នូវការងារ និង របរចិញ្ចឹមជីវិត ដល់ប្រជាជនខ្មែរប្រមាណ ៧០ ភាគរយ ប៉ុន្តែ តាមលទ្ធផលនៃការអង្កេតនាពេលបច្ចុប្បន្នបានបង្ហាញឱ្យឃើញថា សមត្ថភាពរបស់វិស័យកសិកម្មក្នុងការបន្ត រួមចំណែកដោះស្រាយបញ្ហាទាំងនេះ គឺ មានកំរិត ហើយ ចំនួនការងារថ្មីក្រៅពីកសិកម្មដែលបង្កើតឡើងដោយ កំណើនសេដ្ឋកិច្ច ដូចជា នៅក្នុងវិស័យផលិតកម្ម និង ទេសចរណ៍ មានតិចតួចណាស់ ។

ការរីកចំរើនផ្នែកសេដ្ឋកិច្ចជនបទ និងកំណើនចំណូល ព្រមទាំងការងារដែលកើតចេញពីកំណើននេះ មានសារៈសំខាន់ណាស់ក្នុងការសំរេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចនៅកម្ពុជា : ដោយសារកំណើន ប្រជាជននៅតែបន្តយ៉ាងលឿន ហើយការស្រូបទាញកំលាំងពលកម្មចូលក្នុងវិស័យសេដ្ឋកិច្ចផ្សេងទៀតក្រៅពីវិស័យកសិកម្មបានតិចតួច ដូច្នេះ កំលាំងពលកម្មនៅជនបទ នឹងនៅតែបន្តកើនឡើងយ៉ាងច្រើនក្នុងរយៈពេលខ្លី និង មធ្យម ដែលត្រូវស្វែងរកការងារនៅក្នុងផ្នែកផលិតកម្មនៅជនបទ ។ ប្រសិនបើចំនួនប្រជាជនបន្តកើន ឡើងក្នុង អត្រាប្រហែល ២,៥ ភាគរយក្នុងមួយឆ្នាំ ហើយ ឱកាសការងារក្រៅពីវិស័យកសិកម្មកើនឡើងមិនទាន់កំណើននេះទេនោះ មនុស្សពេញកំលាំងពលកម្មជាច្រើនដែលចេញពីក្នុងចំណោមមនុស្ស ២៥០.០០០នាក់ ចូលបន្ថែមទៅ លើកំលាំងពលកម្មដែលមានស្រាប់ជារៀងរាល់ឆ្នាំ នឹងត្រូវហូរចូលទៅក្នុងវិស័យកសិកម្ម ។ ផលវិបាកជាចំបងមួយ ដែលនឹងកើតមានឡើង គឺ ការបង្កើនសំពាធទៅលើធនធានធម្មជាតិ ដូចជា មូលដ្ឋានដីធ្លី ព្រៃឈើ និង ធនធាន ជលផល ដោយសារកាលានុវត្តសេដ្ឋកិច្ច មានតិចតួច ហើយ គ្រួសារនៅជនបទ ត្រូវប្រកបរបរចិញ្ចឹមជីវិត ។

កម្ពុជា ស្ថិតក្នុងចំណោមប្រទេសពីរនៅក្នុងតំបន់ ( មួយទៀត គឺ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ) ដែលវិស័យកសិកម្ម មានចំណែកធំបំផុតនៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) និងការងារ ។ ទោះជាយ៉ាងណាក៏ដោយ វិស័យ

កសិកម្មមិនទាន់មានការរីកចំរើននៅឡើយ ។ កំណើនវិស័យកសិកម្មតាមមិនទាន់កំណើន វិស័យកសិកម្មរបស់ប្រទេសជិតខាង ហើយគំលាតដ៏ធំនៃផលិតភាពកសិកម្មនិងកំលាំងពលកម្ម បានធ្វើឱ្យកម្ពុជា ស្ថិតនៅដាច់ឆ្ងាយពីប្រទេសកសិកម្ម និង ប្រទេសនាំចេញផលិតផលកសិកម្មសំខាន់ៗនៅក្នុងតំបន់ ។ ក្នុងខណៈ ពេលដែលរាជរដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់វិនិយោគក្នុងវិស័យឯកជននិង កសិកម្ម ជាក្បាលម៉ាស៊ីន សំរាប់ជំរុញ កំណើនសេដ្ឋកិច្ច កម្ពុជាត្រូវរៀបចំខ្លួនចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក - **WTO** គឺចំពេលដែលការ នាំចេញផលិតផលកសិកម្ម និង វិនិយោគរបស់វិស័យឯកជន ទៅលើវិស័យកសិ-ឧស្សាហកម្មធ្លាក់ចុះ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ។

របរចិញ្ចឹមជីវិតនៅជនបទ ប្រឈមមុខនឹងហានិភ័យខ្ពស់ ដែលបានកំរិតទៅលើចំណូលនៅជនបទនិងនាំ ឱ្យមានកសិកម្មជាលក្ខណៈគ្រួសារដ៏ច្រើនលើសលុប ហើយ ពឹងផ្អែកទៅលើធនធានធម្មជាតិរួម ជាពិសេសគ្រួសារក្រីក្របំផុត ។ គ្រួសារក្រីក្រប្រកបរបរចិញ្ចឹមជីវិត ក្នុងបរិយាកាសពោរពេញទៅដោយហានិភ័យ និង មានគ្រោះមហន្តរាយខ្ពស់ ដូចជា ទឹកជំនន់ ការខូចខាតផលដំណាំ និង ការស្លាប់សត្វ បណ្តាលមកពីជំងឺរាតត្បាត បញ្ហាសុខភាព ក៏ដូចជាការដណ្តើមយកដីធ្លីពីសំណាក់ក្រុម ឬបុគ្គលមានអំណាច ។ កសិកម្មជាលក្ខណៈគ្រួសារ នៅតែមានជាទូទៅ ហើយការប្រើប្រាស់ធនធានធម្មជាតិសំរាប់ជាមុខរបរចិញ្ចឹមជីវិត នៅតែជាមុខរបរសំខាន់ របស់គ្រួសារក្រីក្រ ។ ដោយសារចំណូលពីកសិកម្ម មានកំរិតទាបនិងមានទៅតាមរដូវ គ្រួសារនៅជនបទត្រូវស្វែងរកការងារផ្សេងទៀតធ្វើ ដែលភាគច្រើនមានលក្ខណៈបណ្តោះអាសន្ន និង មានប្រាក់កំរៃទាប ។

ការកែលំអការងារគ្រប់គ្រងធនធានធម្មជាតិមានសារៈសំខាន់ណាស់ ដែលជួយគាំទ្រដល់កំណើន សេដ្ឋកិច្ច ជនបទដែលពឹងផ្អែកលើការពង្រីកតំបន់ផលិតកម្មកសិកម្ម ទន្ទឹមនឹងនេះធានាឱ្យមានការ ប្រើប្រាស់ ធនធានធម្មជាតិដោយនិរន្តរភាព ។ ក្របខ័ណ្ឌគ្រប់គ្រងធនធានធម្មជាតិបច្ចុប្បន្ន ផ្តល់នូវផលប្រយោជន៍តិចតួចណាស់ ចំពោះកំណើនសេដ្ឋកិច្ចជនបទ និង ការកាត់បន្ថយភាពក្រីក្រ ហើយ មានកត្តាមួយចំនួនដែលបង្ហាញឱ្យ ឃើញពីការថយ ចុះនៃធនធានធម្មជាតិ ។ ការពង្រឹងនិងពង្រីកសកម្មភាពកសិកម្ម ទំនងជាបន្តដាក់សំពាធទៅ លើមូលដ្ឋានធនធានធម្មជាតិ ។ ទោះបីជាវិធានការមួយចំនួនត្រូវបានអនុវត្ត ដើម្បីផ្ទេរសិទ្ធិប្រើប្រាស់ ពីការធ្វើពាណិជ្ជកម្មជាទ្រង់ទ្រាយធំ ទៅការត្រួតពិនិត្យដោយផ្ទាល់ពីរាជរដ្ឋាភិបាលនិងសហគមន៍ក៏ដោយ ក៏ប្រព័ន្ធគ្រប់គ្រង ដែលមានប្រសិទ្ធិភាព មិនទាន់ត្រូវបានបង្កើតឡើង និង អនុវត្តដើម្បីធានាឱ្យគ្រួសារនៅជនបទមានលទ្ធភាពប្រើប្រាស់ធនធានទាំងនេះនៅឡើយ ។ លើសពីនេះទៀត ការគៀងគរដីធ្លីសំរាប់អ្នកគ្មានដីធ្លី និងអ្នកមានដីធ្លីបន្តិចបន្តួចប្រើប្រាស់ តំរូវឱ្យមានដំណើរការស្មុគស្មាញ ដូចជាការកាត់បន្ថយដី ពីអ្នកមានដីធ្លីច្រើន ក៏ដូចជាការកែប្រែដីព្រៃឈើដែលហិនហោច ទំនាបលិចទឹក និងដីរួម ។ ដើម្បីគ្រប់គ្រងមូលដ្ឋានធនធានឱ្យមានប្រសិទ្ធិភាព រួមទាំង ការកែប្រែដីធ្លីឱ្យ មាននិរន្តរភាពផង រាជរដ្ឋាភិបាល ត្រូវតែកែលំអមូលដ្ឋានពត៌មានធនធានបង្កើតឱ្យមានយន្តការធ្វើផែនការប្រើប្រាស់ដីធ្លី និងបង្កើតយន្តការមួយដែលសង្គមអាចទទួលយកបាន សំរាប់ផ្ទេរសិទ្ធិប្រើប្រាស់ឱ្យទៅគ្រួសារកសិករ ។ លើសពីនេះទៀត ការធានាឱ្យមានលទ្ធភាពប្រើប្រាស់ ធនធានធម្មជាតិគឺជាមូលដ្ឋានមួយដ៏ចាំបាច់សំរាប់រក្សា ស្ថិរភាពកំណើនសេដ្ឋកិច្ចជនបទឱ្យបានទូលំទូលាយ និង ការកាត់បន្ថយភាពងាយទទួលរងគ្រោះ ។

ការជំរុញការកែប្រែវិស័យកសិកម្ម ពីកសិកម្មជាលក្ខណៈគ្រួសារ ទៅកសិកម្មទីផ្សារដែលមានទ្រង់ទ្រាយធំ រួមទាំងឯកទេសកម្មក្នុងតំបន់ផង មានសារៈសំខាន់ណាស់ក្នុងការបង្កើនផលិតភាពកសិកម្ម និងចំណូលដល់កសិករ ហើយតាមរយៈនេះ បង្កើនល្បឿនកំណើនកសិកម្ម និង ការកាត់បន្ថយភាពក្រីក្រ ។ កម្ពុជាអាចផលិតស្រូវបានគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ខ្លួនឯង ទោះបីជាតំបន់មួយចំនួន នៅជួបប្រទះការខ្វះខាតក៏ដោយ ។ ទោះបីជាការយកចិត្តទុកដាក ចំពោះតំរូវការសន្តិសុខស្បៀង នៅតែមានសារៈសំខាន់នៅក្នុងផ្នែកខ្លះ ជាពិសេសតុល្យភាពអាហារូបត្ថម្ភ ក៏ត្រូវមានការផ្លាស់ប្តូរទៅរកឯកទេសកម្មដែលខ្ពស់ជាងមុន និងការតំរង់ទិសទីផ្សារ ។ ទោះជាយ៉ាងណាក៏ដោយ ល្បឿននៃការផ្លាស់ប្តូរនេះអាស្រ័យទៅលើការយល់ដឹងរបស់គ្រួសារនៅតំបន់ជនបទ ចំពោះដំណើរការដោះស្រាយបញ្ហាហានិភ័យទាក់ទងនឹងការពឹងផ្អែកលើទីផ្សារចំពោះតំរូវការជាមូលដ្ឋាន និងចំណូល ។ ដំណើរការកាត់បន្ថយភាពងាយទទួលរងគ្រោះ របស់គ្រួសារនៅជនបទ មានកត្តាមួយចំនួន ដូចជាការបង្កើនការ ធានាសិទ្ធិកាន់កាប់ដីធ្លី ការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិឱ្យមានប្រសិទ្ធិភាព (ដូចជា ទឹកជំនន់ ជាដើម) ការ កាត់បន្ថយបន្ទុកលើអ្នកផលិត ដូចជា ថ្លៃធ្វើដំណើរតាមផ្លូវថ្នល់ក្រៅផ្លូវការ និងថ្លៃចេញចូលផ្សារ និងការពង្រឹង ទីផ្សារ តាមរយៈវិធានការមួយចំនួន ដូចជា ការកាត់បន្ថយទុនវិនិយោគលើហេដ្ឋារចនា-សម្ព័ន្ធ និង ការសំរបសំរួលឱ្យមានការប្រកួតប្រជែងនៅក្នុងខ្សែសង្វាក់ទីផ្សារ ។

ការបង្កើនផលិតភាពកសិកម្ម និង ឯកទេសកម្ម ក៏នឹងជួយឱ្យអ្នកផលិតនៅជនបទ មានលទ្ធភាព ទទួលបាន ពត៌មាន និងបច្ចេកវិទ្យាផងដែរ ។ លទ្ធភាពរបស់អ្នកផលិតនៅជនបទ ក្នុងការទទួល បានពត៌មាន និង បច្ចេកវិទ្យា មានសារៈសំខាន់ចំពោះឯកទេសកម្មក្នុងតំបន់លើការ ដាំដុះដំណាំ កសិកម្ម និង ក្នុងការសំរេចឱ្យបាន នូវសក្តានុពល ក្នុងការដាំដុះកសិកម្ម ដែលដឹងបានតាមរយៈ ទិន្នផលដ៏ទាបនៃ ផលដំណាំនិងបសុសត្វក្នុង រដូវកន្លងមក ។ ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម ដែលបាន ចាប់ផ្តើមអនុវត្ត តាំងពី ១៥ ឆ្នាំមុន នៅតែពឹងផ្អែកលើថវិកា ជំនួយដដែល ។ បើពិចារណាទៅលើសមត្ថភាព និង បញ្ហាកង្វះថវិកានៅ ក្នុងវិស័យសាធារណៈ ជាការចាំបាច់ រដ្ឋាភិបាល គួរតែយកចិត្តទុកដាក់ទៅលើតួនាទីសំខាន់ របស់វិស័យ សាធារណៈ និងបង្កើនការចូលរួមពីវិស័យឯកជន ។ ដោយប្រឈមមុខនឹងបញ្ហារួម ទាក់ទងនឹងការធ្វើប្រពលវប្បកម្ម ការបង្កើតនានាភាព និង ឯកទេសកម្ម ក្នុងតំបន់ យុទ្ធវិធីមួយដែលទទួលបាន ពីអ្នកផ្តល់ សេវាជាច្រើនគឺការសំរេចលទ្ធផលឱ្យបានលឿននិងមាននិរន្តរភាព ជាងការពង្រឹងសមត្ថភាព ផ្សព្វផ្សាយកសិកម្ម ជាសាធារណៈ ។ លើសពីនេះទៀត ក្រៅពីការផ្តល់សេវាផ្តល់ប្រឹក្សា ចាំបាច់ត្រូវមានការបង្កើន លទ្ធភាព ទទួលបានសេវាហិរញ្ញវត្ថុ និងទុនសំភារៈប្រកបដោយគុណភាព ដល់កសិករផងដែរ ។

ទោះបីជាមានការរីកចំរើនក៏ដោយ ក៏សេវា និង ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន នៅតែមិនទាន់មានគ្រប់ គ្រាន់នៅឡើយ : លទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ មានទំនាក់ទំនងជិតស្និទ្ធទៅនឹងកំណើនសេដ្ឋកិច្ចជនបទ ដោយផ្សារភ្ជាប់អ្នកផលិតជាមួយនឹងទីផ្សារ កាត់បន្ថយចំណាយលើទុនសំភារៈបំរើឱ្យការដាំដុះកសិកម្ម បង្កើនការ ប្រកួតប្រជែងលើការនាំចេញរបស់កម្ពុជា និង ជំរុញឱ្យវិស័យឯកជនធ្វើការវិនិយោគនៅតំបន់ជនបទ ។ ទោះបីជា មានការវិនិយោគច្រើនក្នុងអំឡុងទសវត្សរ៍កន្លងមកនេះក៏ដោយ ក៏តំបន់ជនបទ នៅជួបប្រទះកង្វះ សេវាសង្គម សេដ្ឋកិច្ច និង ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាននៅឡើយ

ហើយ ផ្អែកជាច្រើនទៀត តាមមិនទាន់ប្រទេសជិតខាង ។ សេវាហិរញ្ញវត្ថុផ្លូវការ ឬ ពាក់កណ្តាលផ្លូវការ មិនអាចប្រើការបាននៅតាមបណ្តាតំបន់ជាច្រើន នៅជនបទ ។ ហេដ្ឋារចនាសម្ព័ន្ធអប់រំនិងសុខាភិបាល និង សេវាកម្ម ក៏ស្ថិតនៅក្រោមកំរិតស្តង់ដារក្នុងតំបន់ ដោយបង្កើនភាព ងាយទទួលរងគ្រោះដល់គ្រួសារនៅជនបទ និង កំរិតទៅលើលទ្ធភាពរបស់គ្រួសារទាំងនេះក្នុងការទទួលបាន កាលានុវត្តសេដ្ឋកិច្ច ។

ការកែលំអសេវាសង្គមនិងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានក៏ដូចជា ការកែលំអបរិយាកាសអាជីវកម្មឱ្យបាន កាន់តែទូលំទូលាយ ក៏នឹងជួយបង្កើតឱ្យមានសកម្មភាពក្រៅពីកសិកម្មដែលរួមចំណែកជំរុញឱ្យមានកំណើនសេដ្ឋកិច្ចជនបទដែរ ។ សកម្មភាពសេដ្ឋកិច្ចជនបទក្រៅពីកសិកម្ម ដែលភាគច្រើនមិនផ្លូវការបានរួមចំណែកយ៉ាងច្រើនក្នុង ការបង្កើនចំណូលដល់គ្រួសារនៅជនបទ ។ ការបង្កើតនានាភាពចំណូល មានតួនាទីក្នុងការគ្រប់គ្រងហានិភ័យផង និងបង្កើតចំណូលសំរាប់គ្រួសារផង ។ គ្រួសារនៅជនបទ ធ្វើការងារជាច្រើន ដូចជា កសិកម្ម សំណង់ ការដឹក ជញ្ជូន ការងាររោងចក្រ សេវាកម្ម និង ការងាររាជការ ដែលជា ការងារមានប្រាក់កំរៃ ឬ មីក្រូអាជីវកម្ម រួមបញ្ចូលទាំងការកែច្នៃស្បៀងសំរាប់លក់ ការផ្តល់សេវា ការជួញដូរផលិតផលកសិកម្មតិចតួច ដូចជា ត្រីនិងសត្វ ព្រមទាំង ការផលិតនិងការជួញដូរផលិតផលនានា ផងដែរ ។

ទស្សនៈវិស័យសំរាប់ការអភិវឌ្ឍន៍តំបន់ជនបទ : ឯកសារនេះ ផ្តល់អនុសាសន៍សំរាប់កំណែទំរង់ជា យុទ្ធសាស្ត្រ ដូចជា គោលនយោបាយ សមត្ថភាពស្ថាប័ននៅថ្នាក់ជាតិនិងមូលដ្ឋាន និង ការបង្វែរទិសដៅវិនិយោគ សាធារណៈ ដែលត្រូវរៀបចំឡើង ដើម្បីជំរុញឱ្យមានការអភិវឌ្ឍន៍វិស័យកសិកម្ម និងវិស័យផ្សេងទៀតក្រៅពី កសិកម្មនៅតំបន់ជនបទនៃប្រទេសកម្ពុជា ។ យុទ្ធសាស្ត្រនេះ កើតចេញពីទស្សនវិស័យទាក់ទងនឹងអ្វីដែលជា បំណងប្រាថ្នា និង អ្វីដែលអាចធ្វើបាន : វិស័យជនបទនៅកម្ពុជា ដែលក្នុងនោះ មានអភិបាលកិច្ចមូលដ្ឋានល្អ និង សហគមន៍មូលដ្ឋាន បានចូលរួមក្នុងការធ្វើសេចក្តីសំរេចលើការអភិវឌ្ឍន៍ និងការវិភាជធនធានសំខាន់ៗ ។ លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិសំរាប់ផលិតកម្ម មានលក្ខណៈសមស្រប និងមានតម្លាភាព ។ សកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ មាននិរន្តរភាព ។ ឥណទាន មានគ្រប់គ្រាន់សំរាប់វិនិយោគលើសកម្មភាពកសិកម្ម និងសកម្មភាពក្រៅពីកសិកម្ម ហើយអាចធានាដោយអចលនទ្រព្យ ដូចជា ដីធ្លី ជាដើម ។ ការបង្កើតឱ្យមានសកម្មភាពគ្រប់គ្រាន់សំរាប់ស្រូបទាញកំលាំងពលកម្ម នៅក្នុងវិស័យឧស្សាហកម្ម និង សេវាកម្ម បង្កើនចំណូលដល់គ្រួសារកសិករ តាមរយៈឱកាសការងារក្រៅពីកសិកម្មពេញពេល និងកន្លះពេល ។ ចំនួនមនុស្សដែលធ្វើការងារស្រែចំការ និងពឹងផ្អែកទាំងស្រុងទៅលើកសិកម្មជាលក្ខណៈគ្រួសារ និង សកម្មភាពក្រៅផ្លូវការបានថយចុះ ។ ផលិតភាពកសិកម្ម និង ចំណូលពីកសិកម្ម មានការកើនឡើង ។ វិបត្តិនៅក្នុងគ្រួសារ ត្រូវបានកាត់បន្ថយ ដោយគ្រួសារមានសមត្ថភាពកាត់បន្ថយ និង គ្រប់គ្រង ហានិភ័យ ។ ការបង្កើតនានាភាពដំណាំ និង ផលិតផលត្រូវបានធ្វើឡើង ដោយសារកសិករ ឆ្លើយតបដោយសេរី ទៅនឹងការប្រែប្រួលតំលៃទីផ្សារ និងការលើកទឹកចិត្តដោយមិនលំអៀង ។ កសិកម្មនៅតាមតំបន់នានានៅក្នុងប្រទេស មានការវិវឌ្ឍន៍ទៅតាមសក្តានុពលភាពខុសៗគ្នានៃតំបន់ ទាំងនោះ ។ លើសពីនេះទៀត ការអភិវឌ្ឍន៍សេដ្ឋកិច្ច មានការរីកចំរើននៅទូទាំងប្រទេស ហើយ គំលាតចំណូលរវាងតំបន់ជនបទ និងទីក្រុងកាន់តែតូច ។

# កត្តាសំខាន់ៗនៃយុទ្ធសាស្ត្រ

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចប្រាំឆ្នាំលើកទី ២ ឆ្នាំ ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយ ភាពក្រីក្រឆ្នាំ ២០០៣-២០០៥ និង យុទ្ធសាស្ត្រចតុកោណថ្មីរបស់រាជរដ្ឋាភិបាល បានផ្តល់នូវទិសដៅទូទៅដល់ ស្ថាប័ននានា ដែលធ្វើការងារខាងអភិវឌ្ឍន៍ជនបទ ។ សំរាប់ការអភិវឌ្ឍន៍ជនបទ គេត្រូវយកទិសដៅទូទៅទាំង នេះទៅរៀបចំជាយុទ្ធសាស្ត្រមួយទៀត ឱ្យមានលក្ខណៈពិស្តារពេញលេញ និង មានទំនាក់ទំនងគ្នា ។ ដើម្បីរួម ចំណែកដល់ការសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និង ដើម្បីធានាឱ្យកំណើនសេដ្ឋកិច្ចមាននិរន្តរភាព ទន្ទឹម នឹងនេះ ធានាបានថា គ្រួសារនៅជនបទ ជាពិសេស គ្រួសារក្រីក្របំផុត ទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍ កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ ការតំរង់ទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗ ខាងក្រោមនេះ ត្រូវបានស្នើឡើង ។ សកម្មភាពជាអាទិភាព នៅក្នុងភាគទី II នៃឯកសារនេះ ក៏មានសង្ខេបជូននៅក្នុង ម៉ាទ្រីសជូនភ្ជាប់ បន្ទាប់ពីខ្លឹមសារសង្ខេបនេះ ។

ការពង្រឹងក្របខ័ណ្ឌច្បាប់ និង ប្រព័ន្ធគ្រប់គ្រងបច្ចេកទេស សំរាប់គ្រប់គ្រងធនធានធម្មជាតិឱ្យមាន និរន្តរភាព ត្រូវតែសំរេចឱ្យបាន ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ។ ក្របខ័ណ្ឌច្បាប់គ្រប់គ្រងដីធ្លី ព្រៃឈើ ជលផល និងធនធានទឹក នៅមិនទាន់មានគ្រប់គ្រាន់ គួបផ្សំជាមួយនឹងភាពទន់ខ្សោយក្នុងការអនុវត្តន៍ច្បាប់និងបទដ្ឋាន គតិយុត្តិដែលនៅជាធរមាន បានក៏រិតទៅលើការធានាឱ្យគ្រួសារនៅជនបទមានលទ្ធភាពប្រើប្រាស់ធនធាន បន្ថែមភាពមិនច្បាស់លាស់ទៅលើបរិយាកាសអាជីវកម្ម និង បង្កើតឱ្យមានបរិយាកាសជំរុញឱ្យអ្នកគ្រប់គ្រងនិងអ្នកប្រើ ប្រាស់ធនធានធម្មជាតិចង់បានកំរៃ ។ ការបង្កើតឱ្យមានជាបន្ទាន់នូវប្រព័ន្ធគ្រប់គ្រងដែលពង្រឹងការទទួលខុសត្រូវ នៅមូលដ្ឋាន ទន្ទឹមនឹងនេះ ធានាឱ្យមានការគោរពចំពោះនិរន្តរភាពទូលំទូលាយ ត្រូវតែធ្វើឡើងជាបន្ទាន់ ដើម្បីពង្រឹងការគ្រប់គ្រងធនធានដែលកំពុងត្រូវបានធ្វើអាជីវកម្មនាពេលបច្ចុប្បន្ន ជាតំបន់បើកចំហការប្រើប្រាស់ ដោយមានការពារតិចតួច ឬគ្មានការពារសោះចំពោះសិទ្ធិប្រើប្រាស់ជាធម្មតា និងជាលក្ខណៈគ្រួសារ ។ អាទិភាព រួមមាន :

បង្កើនការធានាសិទ្ធិកាន់កាប់ដីធ្លី ជាពិសេស សំរាប់ប្រជាជនក្រីក្រ និង ដែលស្ថិតក្នុងស្ថានភាព លំបាកតោកយ៉ាក តាមរយៈការផ្តល់សិទ្ធិកាន់កាប់ដីធ្លី ទន្ទឹមនឹងនេះ ក៏បង្កើននូវលទ្ធភាពប្រើប្រាស់ ដីធ្លីដល់ប្រជាពលរដ្ឋដែលគ្មានដីធ្លី និងប្រជាពលរដ្ឋដែលមានដីធ្លីតិច ព្រមទាំង ដោះស្រាយបញ្ហា ដែលជាឫសគល់នៃការបាត់បង់ដីធ្លី ។

អនុវត្តប្រព័ន្ធគ្រប់គ្រងជលផលទឹកប្រៃនិងទឹកសាប ដែលបង្កើនលទ្ធភាពប្រើប្រាស់ ដល់សហគមន៍ ដែលពឹងផ្អែកលើធនធានជលផលនេះ ទន្ទឹមនឹងនេះ រក្សាបាននូវនិរន្តរភាពផលស្តុក ។

អនុវត្តប្រព័ន្ធគ្រប់គ្រងព្រៃឈើរួម ដែលជំរុញឱ្យមាន ការចូលរួមពីសហគមន៍មូលដ្ឋាន កំណើន សេដ្ឋកិច្ចកាន់តែទូលំទូលាយ និងជីវចំរុះ ព្រមទាំង ផលប្រយោជន៍ផ្សេងទៀតនៃការអភិរក្ស ដោយ ផ្តោតទៅលើយន្តការអនុវត្តន៍ច្បាប់ ដែលផ្អែកទៅលើ តម្លាភាព និង ការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន និង ថ្នាក់លើ ។

បង្កើត និងអនុវត្តសាកល្បង ប្រព័ន្ធគ្រប់គ្រងធនធានទឹកនៅតាមតំបន់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ បណ្តាលមកពី គ្រោះទឹកជំនន់និងរាំងស្ងួត បញ្ចូលការពង្រឹងប្រព័ន្ធកសិកម្ម និង ធានាឱ្យមានសេវា ផ្គត់ផ្គង់ទឹកដែលមានគុណភាពល្អ និង មាននិរន្តរភាព ។

*ការកែលំអជាបន្តបន្ទាប់នូវទីផ្សារផលិតផលនិងទុនសំភារៈ ក៏ដូចជា គោលនយោបាយ និង ការវិនិយោគ ដើម្បីគាំទ្រ ដល់ការពង្រីកនិងពង្រឹងការដាំដុះដំណាំគ្រប់មុខ ជាតំរូវការចាំបាច់សំរាប់ជំរុញឱ្យកំណើនសេដ្ឋកិច្ច ជនបទឡើងដល់ពី ៥ ទៅ ៦ ភាគរយជាអប្បបរមា ក្នុងមួយឆ្នាំ និង ឆ្លើយតបទៅនឹងតំរូវការនៃកំលាំងពលកម្មនៅ ជនបទ ដែលចេះតែកើនឡើង ជាលំដាប់* ។ នេះគឺជាអត្រាកំណើនសេដ្ឋកិច្ចដ៏ខ្ពស់មួយ បើប្រៀបធៀបជាមួយនឹង ការងារដែលបានអនុវត្តនាពេលបច្ចុប្បន្ន នៅក្នុងវិស័យនេះ ហើយការបង្កើនទិន្នផលស្រូវ នឹងគ្រាន់តែឈាន ឆ្ពោះទៅសំរេចគោលដៅនេះប៉ុណ្ណោះ ។ ការសំរេច ឱ្យបាននូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ តំរូវឱ្យមានការ បង្កើនការ ដាំដុះដំណាំចំរុះ ក្រៅពីស្រូវ ដែលភាគច្រើន មានតំរូវការ ពីទីផ្សារ និងលើសពីនេះគឺសំរាប់នាំចេញ ។ ការប្រកួតប្រជែងរបស់កសិករនិងគ្រឹះស្ថានកសិ-ពាណិជ្ជកម្ម និងការធ្វើ សមាហរណកម្ម ចូលក្នុងទីផ្សារ ពិភពលោក នៅមានកំរិត ដោយសារកត្តាមួយចំនួន ដូចជា ផលិតភាពទាប ហេដ្ឋារចនាសម្ព័ន្ធ ផលិតកម្មនិង ទីផ្សារខ្សោយ និងស្ថាប័ន (ដូចជាអំពើពុករលួយជាដើម) ដែលធ្វើឱ្យទុនសំរាប់ដំណើរការអាជីវកម្ម ឡើងខ្ពស់ និងរារាំងដល់ការផ្ទេរពត៌មានពីទីផ្សារទៅអ្នកផលិតនៅជនបទ អ្នកដឹកជញ្ជូន អ្នកកែច្នៃ និងទីផ្សារហិរញ្ញវត្ថុដែលកំពុង ចាប់កំណើតនៅជនបទនៃប្រទេសកម្ពុជា ។ ដើម្បីដោះស្រាយបញ្ហាទាំងនោះ ឯកសារនេះ បានអះអាងថា ការគ្រប់គ្រងវិស័យ កសិកម្ម ត្រូវការកែទំរង់ជាចាំបាច់ ដោយចាប់ផ្តើមផ្សព្វផ្សាយ អំពីកម្មវិធីអភិវឌ្ឍន៍កសិកម្មមួយច្បាស់លាស់ ដែល ផ្តោតទៅលើការផ្តល់សេវាកសិកម្មប្រកប ដោយគុណភាព បំពេញទៅតាមតំរូវការ និង ការដោះស្រាយចំណាយប្រតិបត្តិការ ខ្ពស់នៅក្នុងខ្សែសង្វាក់ទីផ្សារ ។

*ការរៀបចំគោលនយោបាយ និង ការលើកទឹកចិត្ត ត្រូវតែបន្តធ្វើឡើង ដោយពិគ្រោះយោបល់ ជាមួយកសិករ និង វិស័យឯកជន ដើម្បីបង្កើនការឆ្លើយតបទៅនឹង ទិន្នផល ដូចជា ស្រូវ ដំណាំ និង ព្រៃឈើ និង ដើម្បីសំរបសំរួល ឱ្យមាន ការបង្កើតនានាភាព* ទាំងលើការដាំដុះ កសិកម្ម និង ការកែច្នៃដើម្បីតំលៃបន្ថែម ក៏ដូចជា ការកំណត់អំពីកត្តាដែល ជួយធ្វើឱ្យប្រជាពលរដ្ឋក្រីក្រនៅជនបទ ទទួលបានតំលៃបន្ថែមមួយផ្នែកធំ ពីការដាំដុះកសិកម្មនៅជនបទ ។ ជំរើសនានា និង ឧទាហរណ៍មួយចំនួនមាននៅកម្ពុជា សំរាប់អនុវត្តយុទ្ធសាស្ត្រ កំណើនសេដ្ឋកិច្ចជនបទដែលជួយដល់ប្រជាពលរដ្ឋក្រីក្រ តាមរយៈ ការបង្កើតនានាភាពនាំមុខទីផ្សារ រួមទាំង ការធ្វើកិច្ចសន្យាសំរាប់កសិកម្ម សមាគមទីផ្សារ ។ល។ ប៉ុន្តែ

ទាំងនេះតំរូវឱ្យមានការផ្លាស់ប្តូរជាច្រើនលើ បរិយាកាសវិនិយោគនៅជនបទ និង រចនាសម្ព័ន្ធចាត់តាំង ដែលផ្សារភ្ជាប់អ្នកផលិតនៅជនបទ ជាមួយនឹងអ្នកកែច្នៃ និង ទីផ្សារ ។

ការវិនិយោគបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងសេវាសង្គមកិច្ច ក៏ដូចជាការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ មានសារៈសំខាន់ក្នុងការជំរុញឱ្យមានកំណើនសេដ្ឋកិច្ចជនបទ :

វិនិយោគបន្ថែមទៅលើការអប់រំជាមូលដ្ឋាន ជាពិសេស ដើម្បីបង្កើនអត្រាក្មេងស្រីរៀន ចប់កំរិតសិក្សា នីមួយៗ នៅតំបន់ជនបទ គឺជាតំរូវការចាំបាច់ ។ ការវិនិយោគ ដែលលើក កំពស់សុខភាពជាទូទៅ ជា ពិសេស សុខភាពស្ត្រី ដែលមានជាង ៥០ ភាគរយ នៃកំលាំង ពលកម្មកសិកម្ម និង កាត់បន្ថយតំលៃ សេវាសុខភាព អាចកាត់បន្ថយប្រភពចំបងនៃភាពងាយទទួលរងគ្រោះរបស់គ្រួសារ ។

ការបង្កើនលទ្ធភាពទទួលបានផ្លូវថ្នល់ អគ្គិសនី និង ទឹកស្អាតប្រើប្រាស់ នឹងជួយបង្កើនឱកាសចេញ ចូលទីផ្សារ ហើយផ្តល់នូវឱកាសសំរាប់បង្កើតសកម្មភាពក្រៅពីកសិកម្ម ។

ការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុច្រើនប្រភេទ នឹងកាត់បន្ថយភាពងាយទទួលរងគ្រោះ របស់គ្រួសារនៅជនបទ ហើយ ជាតំរូវការចាំបាច់សំរាប់គាំទ្រដល់ការធ្វើនានាភាពសេដ្ឋកិច្ចជនបទ។

ការបង្កើតនានាភាពប្រភពចំនូល និង ការផ្លាស់ប្តូរសំខាន់ៗ នៅចន្លោះ និង នៅក្នុង តំបន់ ស្រុក/ខ័ណ្ឌ និង ឃុំ/សង្កាត់ បានបង្ហាញយ៉ាងច្បាស់ថា គ្មានដំណោះស្រាយទូទៅចំពោះការអភិវឌ្ឍន៍ជនបទទេ ។ ផ្ទុយទៅវិញ ដំណើរការនេះ ត្រូវមានលក្ខណៈជាក់លាក់ ហើយ ឆ្លើយតបទៅនឹងស្ថានភាពនិងកាលៈទេសៈនៅក្នុងមូលដ្ឋាន ព្រមទាំង បង្កើនឱ្យបានជាអតិបរមានូវការចូលរួមពីសំណាក់អង្គការនិងប្រជាជនក្នុងមូលដ្ឋាន ។ ការបង្កើនការ ចូលរួមពីណាក់អង្គការ និងប្រជាជនក្នុងមូលដ្ឋាន នៅក្នុងដំណើរការធ្វើផែនការនិងរៀបចំតាក់តែងគោលនយោបាយ នឹងរួមចំណែកដល់ការកំណត់អាទិភាពវិនិយោគសាធារណៈឱ្យបានល្អប្រសើរ ។ លើសពីនេះទៀត ដំណើរការធ្វើផែនការ និងអភិបាលកិច្ចមូលដ្ឋាន ត្រូវការការគាំទ្រពីថ្នាក់ជាតិ តាមរយៈការដោះស្រាយបញ្ហាគោល- នយោបាយនិងស្ថាប័ន ដែលមានផលប៉ះពាល់លើវិស័យជនបទ ។

## ការសំរេចឱ្យបានលទ្ធផលល្អ និង ដំណាក់កាលបន្តបន្ទាប់

ដើម្បីសំរេចឱ្យបានលទ្ធផលល្អ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទដែលមានប្រសិទ្ធិភាព ត្រូវតែពិចារណាទៅលើ ទិដ្ឋភាពបន្ថែមមួយចំនួន ដែលមានឥទ្ធិពលល្អដល់តំបន់ជនបទ និង ផ្សារភ្ជាប់យុទ្ធសាស្ត្រនេះទៅនឹងផ្នែកផ្សេងទៀតនៃសេដ្ឋកិច្ចជាតិ ។

ទិដ្ឋភាពទាំងនេះ មានដូចជា ទំនាក់ទំនងខ្សែទទឹងជាមួយនឹងរបៀបវារៈជាតិ បញ្ហា សមត្ថភាពស្ថាប័នដែលផ្តោតទៅលើតួនាទីសំខាន់របស់វិស័យសាធារណៈ និង ការដោះស្រាយតំរូវការសំរបសំរួល មួយចំនួន រួមទាំង ការគាំទ្រពីម្ចាស់ជំនួយផង ។

*ពង្រឹងទំនាក់ទំនងជាមួយនឹងរបៀបវារៈរួម* : ការរីកចំរើនខាងផ្នែកអភិវឌ្ឍន៍កសិកម្មនិងអភិវឌ្ឍន៍ជនបទ មិនគ្រាន់តែពឹងផ្អែកលើដំណោះស្រាយបញ្ហានៅក្នុងផ្នែកទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ពឹងផ្អែកលើ ដំណើការអនុវត្តន៍របៀបវារៈសំខាន់ៗ ដែលមានទំនាក់ទំនងតាមខ្សែទទឹងជាមួយនឹងវិស័យផ្សេងទៀតផងដែរ ។ យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥ និង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចប្រាំឆ្នាំលើក ទី ២ ឆ្នាំ ២០០១-២០០៥ បានបង្ហាញនូវសារៈសំខាន់នៃសកម្មភាពទាំងនេះ ។ ការរីកចំរើនតាមវិស័យ ត្រូវបានទទួលស្គាល់ថា ត្រូវពឹងផ្អែកទៅលើការរីកចំរើនស្របគ្នានៃទិដ្ឋភាពទាំង ៣ របស់អភិបាលកិច្ច ដែលតែកំពុងមាន ភាពល្អប្រសើរឡើង ដូចជា កំណែទំរង់មន្ត្រីរាជការ វិមជ្ឈការនិងអភិបាលកិច្ចមូលដ្ឋាន និង ការប្រឆាំងនឹងអំពើ ពុករលួយ ។ លើសពីនេះទៅទៀត មានរបៀបវារៈតាមខ្សែទទឹងទាក់ទងនឹងការអភិវឌ្ឍន៍វិស័យឯកជន ដែលគាំទ្រ ដល់ខ្សែសង្វាក់តំលៃកែច្នៃកសិកម្ម និង សេដ្ឋកិច្ចជនបទក្រៅពីវិស័យកសិកម្មយ៉ាងទូលំទូលាយ ។ បញ្ហានេះ បានបង្ហាញឱ្យឃើញនូវបរិយាកាសដែលមានការអនុគ្រោះដល់ការអភិវឌ្ឍន៍ជនបទ និងជាកត្តាសំខាន់សំរាប់តំរង់ទិស ដៅការអភិវឌ្ឍន៍ជនបទឱ្យដំណើរការទៅក្នុងល្បឿនមួយដែលអាចនាំមក នូវការរីកចំរើនផ្នែកសុខុមាលភាពដល់ប្រជាជននៅជនបទ ។ ការដោះស្រាយបញ្ហាទាំងនេះ ភាគច្រើន គឺមិនមែនជាទទួលខុសត្រូវរបស់ស្ថាប័ន ដែលមានភារកិច្ចអភិវឌ្ឍន៍កសិកម្មនិងអភិវឌ្ឍន៍ជនបទទេ ហើយករណីដែលស្ថាប័នទាំងនេះមិនបាន ចូលរួមឱ្យបានសកម្មក្នុង ការដោះស្រាយបញ្ហាទាំងនេះ នាំឱ្យមានកំហុសឆ្គងកើតឡើង ។ ជាដំបូង ទិសដៅដ៏ទូលំទូលាយនៃកំណែទំរង់ ចាំបាច់ត្រូវតែមានឫសគល់នៅក្នុងរបៀបវារៈតាមវិស័យទើបមានប្រសិទ្ធិភាព ហើយការរៀបចំរបៀបវារៈតាមវិស័យនេះឱ្យស៊ីសង្វាក់គ្នា នឹងធ្វើឱ្យស្ថាប័នដែលមាន ភារកិច្ចអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ជនបទនេះ ក្លាយជាអ្នកទទួលបានផលប្រយោជន៍មុនគេពីការផ្លាស់ប្តូរ ។ បន្ទាប់មក នៅក្នុងតំបន់ខ្លះ ស្ថាប័នអភិវឌ្ឍន៍ជនបទកំពុងតែរកដំណោះស្រាយសំរាប់របៀបវារៈ ដ៏ទូលំទូលាយនេះ (ឧទាហរណ៍ : ការកែលំអប្រព័ន្ធផ្ទេរហិរញ្ញវត្ថុអន្តររដ្ឋាភិបាល ក៏ដូចជាការធ្វើផែនការ និងការអនុវត្តន៍គំរោងអភិវឌ្ឍន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌកំណែទំរង់វិមជ្ឈការនាពេលថ្មីៗនេះ) ។ ស្ថាប័នតាមវិស័យ អាចទទួលបានផលប្រយោជន៍ តាមរយៈការចូលរួមយ៉ាងសកម្ម ប៉ុន្តែចាំបាច់ត្រូវពង្រឹង សមត្ថភាព ស្ថាបន័របស់ខ្លួនជាមុនសិន ។

ផ្តោតការយកចិត្តទុកដាក់ទៅលើតួនាទីសំខាន់ៗរបស់វិស័យសាធារណៈ : បញ្ហាប្រឈមមួយ ដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយ គឺ ការពង្រឹងសម្ថភាពសំរាប់បំពេញឱ្យតួនាទីដឹកនាំការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បី ជំរុញឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយសមធម៌ ។ លើសពីនេះទៀត រាជរដ្ឋាភិបាល បានបោះបង់ ចោលសកម្មភាព ដែលបន្តដាក់បន្ទុកទៅលើវិស័យសាធារណៈរបស់ប្រទេសជិតខាង ដូចជា ការចូលរួមផ្ទាល់ក្នុង ផលិតកម្ម និង ការគាបសង្កត់ពីរដ្ឋលើស្ថាប័នទីផ្សារ ។ រាជរដ្ឋាភិបាល នៅមានកិច្ចជាច្រើនទៀតត្រូវធ្វើ ដូចជា ការផ្តល់ផលិតផលសាធារណៈ ការដោះស្រាយបញ្ហាក្ស័យធនផ្នែកទីផ្សារ និងការផ្តល់សេវាសំខាន់ៗ ដែលវិស័យឯកជន ទំនងជាយល់ឃើញថាមិនទទួលបានផលចំណេញ ។

តួនាទីមួយចំនួនទៀត រួមមាន ការជំរុញឱ្យមានការ ឯកភាពគ្នាលើ ការអនុវត្តន៍ និង ការសំរបសំរួលឱ្យមានគោលនយោបាយតាមវិស័យ ដែលពាក់ព័ន្ធនឹងគោលដៅជាន់គ្នា ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល មានតួនាទីសំខាន់ក្នុងការអនុវត្តន៍គោលការណ៍អភិបាលកិច្ចល្អ និង អនុវត្តន៍វិធានការប្រឆាំងនឹងអំពើពុករលួយ ។ ទាក់ទងនឹងការផ្តល់មូលនិធិជំនួយសំរាប់វិនិយោគសាធារណៈ មាន បញ្ហាប្រឈមមួយទៀតទាក់ទងនឹងការសំរបសំរួលសកម្មភាពរបស់ម្ចាស់ជំនួយ ដើម្បីធ្វើយ៉ាងណាជំនួយទាំងនេះត្រូវគ្នាជាមួយនឹងអាទិភាពជាតិ ។ កង្វះសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាល ជាបញ្ហាបន្ថែមមួយទៀត សូម្បីតែសមត្ថភាពផ្តល់សេវានានា ដែលមានសារៈសំខាន់ចំពោះអ្នកផលិតនៅជនបទ នៅពេលដែលពួកគេ ព្យាយាម បង្កើតនានាភាពសំរាប់សកម្មភាព និងតំរង់ទិសដៅទៅឱកាសទីផ្សារ ។ ការបង្កើតលក្ខខ័ណ្ឌទាំងនោះសំរាប់ អោយមានកិច្ចអភិវឌ្ឍន៍វិស័យឯកជន និងលើកកំពស់សមត្ថភាព និងធនធានជាបន្តនៃវិស័យឯកជន ដើម្បីផ្តល់ ធាតុចូល និង ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដើម្បីពង្រឹងការកសាងសេដ្ឋកិច្ចជនបទ ចាំបាច់ត្រូវឋិតនៅត្រង់ចំណុច ស្នូលនៃរបៀបវារៈអភិវឌ្ឍន៍ជនបទ ។

*ការផ្តោតការយកចិត្តទុកដាក់ទៅលើតួរីការសំរបសំរួល រួមទាំង ជំនួយគាំទ្រពីម្ចាស់ជំនួយ* : មានបញ្ហា ប្រឈមមួយទៀតដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយ គឺតួរីការសំរបសំរួល បើពិចារណាទៅលើចំនួនដ៏ច្រើននៃស្ថាប័នរាជរដ្ឋាភិបាល ដែលចូលរួមក្នុងការអភិវឌ្ឍន៍កសិកម្មនិងជនបទ ចំនួនដៃគូខាងក្រៅដែលបានផ្តល់ ហិរញ្ញប្បទានដល់កិច្ចអភិវឌ្ឍន៍ និង សមត្ថភាពសំខាន់ៗដែលមាននៅក្នុងមុខងារសាធារណៈ។ កិច្ចខិតខំប្រឹងប្រែង សំរបសំរួលដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន នឹងទទួលបានជោគជ័យធំធេង ប្រសិនបើមានការចូលរួមខ្លាំងក្លាពី ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ។ គំរោងមួយដែលបានអនុវត្តនៅឆ្នាំ ២០០៣ ដើម្បីសំរបសំរួលគោលនយោបាយ និង ជំនួយគាំទ្រពីម្ចាស់ជំនួយ ដែលនាំទៅដល់ការបង្កើតក្រុមការងារបច្ចេកទេសរួមមួយចំនួនរវាងរាជរដ្ឋាភិបាល និង ម្ចាស់ជំនួយ (**TWG**) គឺជាការចាប់ផ្តើមមួយដ៏ល្អ ។ លើសពីនេះទៀត គេគួរតែពិចារណាទៅលើមធ្យោបាយបង្រួប បង្រួមបញ្ចូលគ្នា និង សំរបសំរួលរបៀបវារៈរបស់ក្រុមទាំងនេះ ដោយជំរុញឱ្យមានទស្សនៈវិស័យមួយទាក់ទងនឹង ទំហំជំនួយដែលម្ចាស់ជំនួយសន្យាផ្តល់ឱ្យផ្នែកអភិវឌ្ឍន៍កសិកម្មនិងជនបទ រួមទាំងសមាសភាពវិស័យរួមផ្សំផង និង ជាកន្លែងមួយសំរាប់តំរង់ទិសដៅជំនួយឱ្យត្រូវនឹងរបៀបវារៈកំណែទំរង់សំរាប់ការអភិវឌ្ឍន៍កសិកម្មនិងជនបទ នៅ កម្ពុជា ។

*ដំណាក់កាលបន្តបន្ទាប់ : ការផ្លាស់ប្តូរឆ្ពោះទៅរកក្របខ័ណ្ឌរួមមួយសំរាប់ការអភិវឌ្ឍន៍ជនបទ* : ឯកសារនេះ អាចជាជំនួយសំរាប់ការពិភាក្សាគោលនយោបាយ រវាង រាជរដ្ឋាភិបាល និងដៃគូ លើការកំណត់អាទិភាព កំណែទំរង់សេដ្ឋកិច្ច និងការវិនិយោគនៅតំបន់ជនបទ ដោយផ្តោតទៅលើដំណើរការឆ្ពោះទៅកំណត់របៀបវារៈ រួមសំរាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ នៅតំបន់ជនបទនៃប្រទេសកម្ពុជា ។ កិច្ចពិគ្រោះ យោបល់លើឯកសារនេះបានប្រព្រឹត្តទៅជាមួយរដ្ឋាភិបាល និងជាមួយភាគីពាក់ព័ន្ធដទៃទៀត រួមមានម្ចាស់ជំនួយដទៃទៀត អ្នកតំណាងនៃវិស័យឯកជនវិទ្យាស្ថានស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាអោយមានតុល្យភាព និងភាពត្រឹមត្រូវ ។ ឯកសារនេះពុំមានបំណងបញ្ហាញយុទ្ធសាស្ត្រពេញលេញឡើយ ព្រោះថា គំលាតពតិមានសំខាន់ៗ និង ការចូលរួមតិចតួចជាមួយរដ្ឋាភិបាលរហូតមកដល់ពេលនេះ បន្សល់ទុកកិច្ចការជា ច្រើនសំរាប់ដំណាក់កាលជាបន្តបន្ទាប់ ។ ការពិគ្រោះយោបល់ លើឯកសារ

នឹងត្រូវធ្វើឡើងជាមួយនឹង រាជរដ្ឋាភិបាល និង ភាគីពាក់ព័ន្ធដទៃទៀត រួមទាំង ម្ចាស់ជំនួយដទៃទៀត ផង ដើម្បីធ្វើយ៉ាងណាឱ្យមានតុល្យភាព និងភាពត្រឹមត្រូវ ។ ឯកសារនេះ មិនទាន់មានយុទ្ធសាស្ត្រទូលំទូលាយ គ្រប់ជ្រុងជ្រោយនៅឡើយ ដោយសារកង្វះពត៌មានសំខាន់ៗ ហើយទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលរហូតមកដល់ពេលនេះមានតិចតួច ដូច្នេះការងារសំខាន់ នឹងធ្វើនៅដំណាក់កាលបន្តបន្ទាប់ទៀត ។ ការពិគ្រោះយោបល់ មានគោលបំណងផ្ទៀងផ្ទាត់ បញ្ជាក់ទិសដៅជាយុទ្ធសាស្ត្រជាមួយនឹងរាជរដ្ឋាភិបាល និងកំណត់អំពីវិស័យរួមផ្សំជាអាទិភាព ពត៌មានដែលត្រូវការចាំបាច់សំរាប់វាយតំលៃបន្ថែម និង ផ្នែកជាក់លាក់ដែលស្ថាប័នឬបុគ្គលមួយចំនួនបានដឹងច្បាស់លាស់រួចជាស្រេច សំរាប់ ចាប់ផ្តើមអនុវត្តរបៀបវារៈច្បាស់លាស់ ដែលនាំឱ្យទទួលបានលទ្ធផលជាក់ ស្តែងជាមូលដ្ឋាន ។ ធនាគារពិភពលោកត្រៀមខ្លួនជាស្រេច ដើម្បីឧបត្ថម្ភគាំទ្រដល់ការងារជាបន្តបន្ទាប់ ដែលបានព្រមព្រៀង និងសំរបសំរួល ជាមួយនឹងរាជរដ្ឋាភិបាល និង ដៃគូរបស់រាជរដ្ឋាភិបាល ។

# តារាងម៉ាទ្រីសអនុសាសន៍ស្តីពីផែនការសកម្មភាពជាអាទិភាព ៖
# ក្របខណ្ឌពេលវេលា និង ធនធាន

**របៀបបកស្រាយតារាងម៉ាទ្រីស ៖**

- តារាងម៉ាទ្រីស មិនរៀបរាប់ពិស្តារទេ គឺផ្តោតតែទៅលើ សកម្មភាពសំខាន់ៗប៉ុណ្ណោះ ។
- កម្មវិធី គំរោង និង ដៃគូ មិនត្រូវបានលើកយកមកពិភាក្សាទាំងអស់ទេ ។ តារាងម៉ាទ្រីសនេះ គឺជា "ឯកសាររស់" ហើយអាចធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ដើម្បីឆ្លុះបញ្ចាំងវឌ្ឍនភាព ដើម្បីឆ្ពោះទៅរករបៀបវារៈកំណែទំរង់ និង ការកៀងគរធនធានបន្ថែមទៀតដែលបានឯកភាព ។
- ឃ្លាប្រយោគពណ៌ខៀវ គឺជាសកម្មភាព ដែលត្រូវការធនធានបន្ថែម (ឬ ធនធានមានស្រាប់ ដែលមិនទាន់បានកំណត់យកមកប្រើប្រាស់នៅដំណាក់កាលនេះ) និង ការយកចិត្តទុកដាក់ខ្លាំងក្លាពី រដ្ឋាភិបាល និង ដៃគូរបស់ខ្លួន ។ ឃ្លាប្រយោគពណ៌ខ្មៅ គឺជាសកម្មភាព ដែលកំពុងតែអនុវត្ត ក្រោមកម្មវិធីនានា ដែលទទួលបានថវិកាឧបត្ថម្ភពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ ផ្នែកឯកជន ឬ ភាគីពាក់ព័ន្ធផ្សេងទៀត ។
- តារាងម៉ាទ្រីស ក៏បង្ហាញអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលមានការចូលរួមចំណែក *ច្រើនបំផុត និង ដោយផ្ទាល់* ពីរបៀបវារៈដែលបានស្នើឡើង ។
- សកម្មភាពទាំងនេះ មានប្រភេទ និង វិសាលភាពខុសៗគ្នា (ដូចជា សេចក្តីសំរេចលើគោលនយោបាយ កំណែទំរង់ស្ថាប័ន វិនិយោគ ការសិក្សាស្រាវជ្រាវ ឬ សកម្មភាពទាំងនេះពីរឬច្រើនបញ្ចូលគ្នា) អាស្រ័យទៅលើតំរូវការនៅតាមផ្នែក និងស្ថានភាពរីកចំរើននៃវិស័យនានា ។ ហេតុដូច្នេះ សកម្មភាពនៅក្នុងតារាងម៉ាទ្រីសមានកំរិតមិនដូចគ្នាទេ។
- ចំពោះពាក្យបំព្រួញ សូមអានទំព័រខាងដើមនៃឯកសារនេះ ។

កំណែទំរង់ដីធ្លី [គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ : លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ - គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៧ : ធានាចីរភាពបរិស្ថាន]

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយ ២០១០)** | **ធនធាន** | **ដៃគូ** |
| **ពង្រឹងការគ្រប់គ្រងដីធ្លី :**<br>- ធ្វើសនិទានកម្មប្រព័ន្ធចាត់ថ្នាក់ដីធ្លី<br>- ធ្វើសនិទានកម្មប្រព័ន្ធសេដ្ឋកិច្ច ជលផល និង ព្រៃសម្បទាន<br>- ពង្រឹងការធ្វើផែនការប្រើប្រាស់ដីធ្លី<br>- រៀបចំនិងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច | • រៀបចំបង្កើយអនុក្រឹត្យស្តីពី ដីរដ្ឋ (កំពុងដំណើរការ)<br>• រៀបចំបង្កើយអនុក្រឹត្យស្តីពី សម្បទានសេដ្ឋកិច្ច (កំពុង ដំណើរការ)<br>• អនុវត្តអនុក្រឹត្យស្តីពីសម្បទាន សេដ្ឋកិច្ច<br>• រៀបចំបង្កើយអនុក្រឹត្យស្តីពីសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋាន (កំពុងដំណើរការ)<br>• អនុវត្តអនុក្រឹត្យស្តីពីដីរដ្ឋ<br>• អនុវត្តអនុក្រឹត្យស្តីពីសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន<br>• ការរៀបចំកម្មវិធីបែងចែកដីធ្លី ដោយផ្អែកលើលទ្ធផលនៃការវាយតំលៃផលប៉ះពាល់ភាពក្រីក្រ និងសង្គម និង គំរោងសាកល្បង (កំពុងដំណើរការ)<br>• អនុវត្តកម្មវិធីដីសម្បទានដីសង្គមកិច្ច | • អនុវត្តអនុក្រឹត្យស្តីពីដីរដ្ឋ<br>• អនុវត្តអនុក្រឹត្តស្តីពីសម្បទានសេដ្ឋកិច្ច<br>• អនុវត្តអនុក្រឹត្យស្តីពីសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន<br>• អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច | • អនុវត្តអនុក្រឹត្យស្តីពីដីរដ្ឋ<br>• អនុវត្តអនុក្រឹត្យស្តីពីសម្បទានសេដ្ឋកិច្ច<br>• អនុវត្តអនុក្រឹត្យស្តីពីសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន<br>• អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច | LMAP<br>ASDL (ADB)<br>(LASED) | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ CLP និង ស្ថាប័នជាសមាជិករបស់ខ្លួន<br>CC រដ្ឋអំណាចខេត្ត<br>ADB, WB, GTZ, FINNIDA, CIDA, NGOs |

| | | | | | |
|---|---|---|---|---|---|
| **ពង្រឹងរដ្ឋបាលដីធ្លី :**<br>- ពង្រឹងការដោះស្រាយជំលោះដីធ្លី ។<br>- បង្កើនការផ្តល់កម្មសិទ្ធិ និងការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ<br>- ពិនិត្យកែសំរួលមុខងារការិយាល័យសុរិយោដី<br>- បង្កើតនិងអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ<br>- កែសំរួលរចនាសម្ព័ន្ធផ្ទេរដីធ្លី ពន្ធដារ និងធ្វើការវាយតំលៃទ្រព្យសម្បត្តិ ។ | • កសាងសមត្ថភាពដល់គណៈកម្មការសុរិយោដី និង ពិនិត្យតាមដានលទ្ធផលការងាររបស់គណៈកម្មការនេះ (កំពុងដំណើរការ នៅទូទាំង ២៤ ខេត្ត-ក្រុង)<br>• ផ្តល់កម្មសិទ្ធិដីធ្លីចំនួន ១ លាន ច្បាប់ ដល់ខេត្ត-ក្រុងចំនួន ១០ និង រាជធានីភ្នំពេញ (កំពុង ដំណើរការ)<br>• ពង្រឹងការិយាល័យសុរិយោដី នៅក្នុងខេត្ត-ក្រុងចំនួន ១០ (កំពុងដំណើរការ)<br>• បង្កើតនិងអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ | • ផ្តល់កម្មសិទ្ធិដីធ្លីចំនួន ១ លាន ច្បាប់ ដល់ខេត្ត-ក្រុងចំនួន ១០ និង រាជធានីភ្នំពេញ (កំពុងដំណើរការ)<br>• ពង្រីកការផ្តល់ប័ណ្ណកម្មសិទ្ធទៅខេត្ត-ក្រុងដទៃទៀត<br>• ពង្រឹងការចុះបញ្ជីដីធ្លីនៅខេត្ត-ក្រុងដទៃទៀត<br>• អនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើ ពុករលួយ | • ពង្រីកការចុះផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី ទៅ ខេត្ត-ក្រុងដទៃទៀត<br>• ពង្រឹងការចុះបញ្ជីដីធ្លីនៅខេត្ត-ក្រុងដទៃទៀត<br><br>(នៅទូទាំងប្រទេស ប័ណ្ណកម្មសិទ្ធិដីធ្លី ប្រហែល ៥ ទៅ ៦ លានច្បាប់ ) | **LMAP**<br><br>**(LMAP 2)** | |
| | **កំណែទំរង់សំខាន់ៗ និង ការវិនិយោគស្របពេលជាមួយគ្នា :** ការពង្រឹងការអនុវត្តន៍កិច្ចសន្យា ការពង្រឹងប្រព័ន្ធតុលាការ ការបង្កើតសេវាហិរញ្ញវត្ថុជនបទ និង សេវាគាំទ្រហេដ្ឋារចនាសម្ព័ន្ធនិងកសិកម្ម | | | | |

## កំណែទំរង់ការគ្រប់គ្រងវិស័យព្រៃឈើ

(គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ : លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និង ភាពអត់ឃ្លាន - គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៧ : ធានាចីរភាពបរិស្ថាន)

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **ពង្រឹងកំណែទំរង់គ្រប់គ្រងសម្បទានព្រៃឈើ:**<br>-បញ្ចប់ការរៀបចំប្រព័ន្ធព្រៃសម្បទានឡើងវិញ<br>- ធ្វើសនិទានភាពចំពោះការប្រើប្រាស់ដីព្រៃ<br>-បង្កើនការគ្រប់គ្រងតំបន់ព្រៃក្រៅឧទ្យាននិងក្រៅតំបន់ការពារ<br>-ពង្រឹងសមត្ថភាពដើម្បីត្រួតពិនិត្យការអនុវត្តន៍តាមល័ក្ខខ័ណ្ឌសម្បទានព្រៃឈើ | • បញ្ចើ្ចយការរៀបចំកែសំរួល កិច្ចសន្យាឡើងវិញ និង លុបចោលកិច្ចសន្យាដែលមិនគោរពតាមល័ក្ខខ័ណ្ឌសម្បទាន<br>• កសាងបញ្ចប់/អនុម័ត និង អនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងជីវឌ្ឍ<br>• ***បង្កើនល្បឿនការកសាងផែនទី ការបោះបង្គោល អង្កេត និងសារពើភ័ណ្ឌដីព្រៃ***<br>• ***សិក្សាជំរើសសំរាប់គ្រប់គ្រងតំបន់ព្រៃក្រៅឧទ្យាន និងក្រៅតំបន់ការពារ អោយមាននិរន្តរភាព***<br>• ***អនុវត្តសាកល្បងការរៀបចំគ្រប់គ្រងថ្មី***<br>• ***ពង្រឹងសមត្ថភាពរបស់រដ្ឋបាលព្រៃឈើនៅថ្នាក់ខុសៗគ្នា*** | • អនុវត្តអនុក្រឹត្យស្តីពីជីវឌ្ឍ<br>• បន្តកសាងផែនទី ការបោះបង្គោល អង្កេត និង សារពើភ័ណ្ឌដីព្រៃ<br>• ពង្រីកការអនុវត្តន៍សាកល្បងជាបណ្តើៗ<br>• ពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនៅថ្នាក់ខុសៗគ្នា | • ***អនុវត្តអនុក្រឹត្យស្តីពីជីវឌ្ឍ***<br>• ***បន្តកសាងផែនទី ការបោះបង្គោល អង្កេត និង សារពើភ័ណ្ឌដីព្រៃ***<br>• ***ពង្រីកការអនុវត្តន៍សាកល្បងជាបណ្តើៗ***<br>• ***ពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនៅថ្នាក់ខុសៗគ្នា*** | **WB LIL**<br>**WB SAC**<br>**LMAP** | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ COMTWG ស្តីពីព្រៃឈើ ម្ចាស់ជំនួយ (WB SIDA ។ល។)<br>**MLMUPC, CLP,** ស្ថាប័នតាមវិស័យ អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល |

| | | | | | |
|---|---|---|---|---|---|
| **ពិនិត្យមើលសាឡើងវិញនូវរចនាសម្ព័ន្ធនៃវិស័យព្រៃឈើ :**<br>-ផ្តោតលើការរៀបចំ "ខែបញ្ញារតែមួយ"<br>- ធ្វើសមាហរណកម្មអភិវឌ្ឍជនបទនៅបណ្តាខេត្ត<br>- ពង្រឹកការរាយការណ៍ អំពីឧក្រិដ្ឋកម្មព្រៃឈើ និងរៀបចំចោទប្រកាន់ | • បន្តពិភាសក្សា និង សិក្សាជំរើសរកមតិយោបល់សាធារណៈនៅមូលដ្ឋាន អំពីការគ្រប់គ្រងព្រៃឈើ និង ការបែងចែកប្រាក់ចំណូល<br>• បន្តសិក្សាជំរើសផ្សេងៗ ចំពោះការគ្រប់គ្រងព្រៃឈើសំរាប់អភិវឌ្ឍន៍ជីវភាពរស់នៅ និង អភិវឌ្ឍន៍កសិរុក្ខកម្ម<br>• សិក្សាជំរើសនានានៅក្នុងស្ថាប័នដទៃទៀត អាជ្ញាធរមូលដ្ឋាន និង សង្គមស៊ីវិល ចំពោះការត្រួតពិនិត្យ ការកាប់ឈើដោយខុសច្បាប់ និង ឧក្រិដ្ឋកម្មព្រៃឈើដទៃទៀត | • *អនុវត្តសាកល្បង និង ពង្រីកគំនិតផ្តួចផ្តើមដែលកំពុងទទួលជោគជ័យ*<br>• *ពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ ដើម្បីអនុវត្តមុខងារសេវាថ្មី*<br>• *ពង្រឹងសមត្ថភាពនៅមូលដ្ឋានសំរាប់គ្រប់គ្រងព្រៃឈើ*<br>• *តាមដានផលប៉ះពាល់នៃកំណែទំរង់* | • *បន្តកសាងសមត្ថភាពរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន និង សហគមន៍*<br>• *តាមដានផលប៉ះពាល់នៃកំណែទំរង់* | **WB LIL**<br>គំនិតផ្តួចផ្តើមនៃសហគមន៍ព្រៃឈើមួយចំនួន | ក្រសួងកសិកម្ម<br>ស្ថាប័នរដ្ឋាភិបាលដទៃទៀតពាក់ព័ន្ធ នឹងការអនុវត្តន៍ច្បាប់<br>ម្ចាស់ជំនួយ ( DFID GTZ DANIDA SIDA WB .។ល។)<br>អង្គការក្រៅរដ្ឋាភិបាល<br>អាជ្ញាធរមូលដ្ឋាន និង សហគមន៍ |
| **សំរួលការរៀបចំឧស្សាហកម្មកែច្នៃឈើសារឡើងវិញ** | • *ធ្វើជំរឿនរោងចក្រអារឈើ និង អង្កេតសមត្ថភាព*<br>• *សិក្សាជំរើស/កត្តាលើកទឹកចិត្ត ដើម្បីអោយមានសមត្ថភាពវិស័យឯកជនដែលមានទំហំសមស្រប*<br>• *សិក្សាសក្តានុពលសំរាប់នាំចេញផលិតផលឈើដែលមានគុណភាពខ្ពស់* | • *តាមដានបំរែបំរួលរចនាសម្ព័ន្ធនៅក្នុងឧស្សាហកម្មកែច្នៃឈើ កែសំរួលគោលនយោបាយ និង កត្តាលើកទឹកចិត្តតាមការចាំបាច់* | • *តាមដានបំរែបំរួលរចនាសម្ព័ន្ធនៅក្នុងឧស្សាហកម្មកែច្នៃឈើ កែសំរួលគោលនយោបាយ និង កត្តាលើកទឹកចិត្តតាមការចាំបាច់* | | ក្រសួងពាណិជ្ជកម្ម<br>ក្រសួងកសិកម្ម |
| | **កំណែទំរង់សំខាន់ៗ និង ការវិនិយោគស្របពេលជាមួយគ្នា :** ការពង្រឹងប្រព័ន្ធតុលាការ និង ក្របខ័ណ្ឌគ្រប់គ្រងដីធ្លី ។ | | | | |

## **កំណែទំរង់ការគ្រប់គ្រងវិស័យជលផល**

[គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ : លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និង ភាពអត់ឃ្លាន - គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៧ : ធានាចីរភាពបរិស្ថាន]

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **ពង្រឹងក្របខ័ណ្ឌស្ថាប័ន : សំរាប់ការគ្រប់គ្រងជលផល**<br>- ពង្រឹងស្ថាប័ន និង សំរបសំរួលស្ថាប័ន<br>- បន្តពង្រឹងក្របខ័ណ្ឌច្បាប់តាមរយៈកិច្ចពិគ្រោះយោបល់ និង ការសិក្សានានា<br>- តាមដានផលប៉ះពាល់នៃកំណែទំរង់<br>- ពង្រឹងសមត្ថភាពអនុវត្ត<br>- ពង្រឹងសមត្ថភាពវាយតំលៃបរិមាណស្តុក | • ***បង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីជួយសំរបសំរួលការប្រើប្រាស់ធនធានវារីជាតិ*** ពង្រឹងក្រុមការងារបច្ចេកទេរវាងរដ្ឋាភិបាលនិងម្ចាស់ជំនួយ<br>• ***កសាងបញ្ចប់ អនុម័តច្បាប់ជលផល*** និង កែសំរួលទៀងទាត់តាមការចាំបាច់<br>• ***កសាងបញ្ចប់អនុក្រឹត្យស្តីពីសហគមន៍នេសាទ និងបទប្បញ្ញត្តិសំខាន់ៗដទៃទៀត***<br>• ***បណ្តុះបណ្តាលបុគ្គលិកនាយកដ្ឋានជលផល (រាប់ទាំងបុគ្គលិកនៅ ថ្នាក់ខេត្ត និងថ្នាក់ស្រុក)អំពីកម្មវិធីគ្រប់គ្រងថ្មី***<br>• ***កសាងសមត្ថភាពវាយតំលៃផលលផល ទឹកសាប និង ទឹកប្រៃ ដើម្បីផ្តល់ដំណឹងចំពោះការរៀបចំ គោលនយោបាយ*** | • ***បណ្តុះបណ្តាលបុគ្គលិកនាយកដ្ឋានជលផល (រាប់ទាំងបុគ្គលិកនៅ ថ្នាក់ខេត្ត និងថ្នាក់ស្រុក) អំពីប្រព័ន្ធគ្រប់គ្រងថ្មី***<br>• ***អនុវត្តអនុក្រឹត្យ ស្តីពីសហគមន៍ព្រៃឈើ និង បទប្បញ្ញត្តិដទៃទៀត***<br>• ***បង្កើតប្រព័ន្ធតាមដានទៀតទាត់ចំពោះបរិមាណស្តុកជលផល ដើម្បីផ្តល់ដំណឹងចំពោះសេចក្តីសំរេចគោលនយោបាយ និងវិនិយោគ*** | • ***បណ្តុះបណ្តាលបុគ្គលិកនាយក ដ្ឋានជលផល (រាប់ទាំងបុគ្គលិកនៅ ថ្នាក់ខេត្ត និងថ្នាក់ស្រុក) អំពីប្រព័ន្ធគ្រប់គ្រងថ្មី***<br>• ***អនុវត្តអនុក្រឹត្យ ស្តីពីសហគមន៍ ព្រៃឈើ និង បទប្បញ្ញត្តិដទៃ ទៀត***<br>• ***តាមដានបរិមាណស្តុកជលផល*** | APIP (2004) | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>- ម្ចាស់ជំនួយ (TWG ស្តីពីជលផល)<br>- អង្គការក្រៅរដ្ឋាភិបាល និង ស្ថាប័នពាក់ព័ន្ធដទៃ<br><br>-ក្រសួងកសិកម្ម MRC ម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាល សហគមន៍មូលដ្ឋាន |

| | | | | | |
|---|---|---|---|---|---|
| **ពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងធនធានជលផល**<br>-ធ្វើសនិទានភាពប្រព័ន្ធសម្បទាន<br>-ពិនិត្យមើលការអនុវត្តន៍សាកល្បងនៃសហគមន៍នេសាទ<br>-ស្វែងរកជំរើសគ្រប់គ្រងផ្សេងទៀត | • វាយតំលៃផលប៉ះពាល់នៃកំណែទំរង់វិស័យជលផលនាពេលបច្ចុប្បន្ន (កំពុងដំណើរការ)<br>• ពិនិត្យមើលមេរៀនពីគំរោងសាកល្បង<br>• ***រៀបចំឱ្យមានកម្មវិធីសហគមន៍នេសាទមួយប្រកបដោយនិរន្តរភាព***<br>• ***សិក្សាអំពីលទ្ធភាពកែលំអ និង/ឬ សិក្សាអំពីជំរើសដទៃជំនួសឱ្យប្រព័ន្ធសម្បទានបច្ចុប្បន្ន*** | • ***អនុវត្តកម្មវិធីគ្រប់គ្រងសហគមន៍នេសាទឱ្យមាននិរន្តរភាព***<br>• ***អនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងតាមជំរើសដទៃបន្ទាប់មកពង្រីកប្រព័ន្ធនោះលើមូលដ្ឋាននៃការពិនិត្យមើលសាឡើងវិញ*** | • ***អនុវត្តកម្មវិធីគ្រប់គ្រងសហគមន៍នេសាទឱ្យមាននិរន្តរភាព*** | **PSIA** - ជលផល (**DFID**) | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **DFID DANIDA** អង្គការក្រៅរដ្ឋាភិបាល សហគមន៍ ម្ចាស់ជំនួយដទៃទៀត អាជ្ញាធរមូលដ្ឋាន ក្រសួងកសិកម្ម វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ |

## **កំណែទម្រង់ការគ្រប់គ្រងធនធានទឹក**

(គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ : លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និង ភាពអត់ឃ្លាន - គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៧ : ធានាចីរភាពបរិស្ថាន)

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **ពង្រឹងក្របខ័ណ្ឌស្ថាប័ន និង គោលនយោបាយ :**<br>- ពង្រឹងការសំរបសំរួលតាមវិស័យ<br><br>- បន្តអភិវឌ្ឍក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងទឹក | • ពង្រឹងការសំរបសំរួលរបស់ម្ចាស់ជំនួយ (TWG)<br>• ***បង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីលើកកំពស់ការសំរបសំរួលបញ្ហាទឹក និង តាមដានសហប្រតិបត្តិការរបស់ស្ថាប័ននានា***<br>• ***បង្កើតផែនការសកម្មភាព ដើម្បីណែនាំស្ថាប័នពាក់ព័ន្ធ ដោយមានការតាមដានជាទៀងទាត់របស់អន្តរក្រសួង***<br>• ***ពិនិត្យមុខងារស្ថាប័នទឹកសំខាន់ៗ សារជាថ្មីឡើងវិញ (MOWRAM MIME MRD)***<br>• អនុម័តច្បាប់ស្តីពីទឹក<br>• បោះផ្សាយច្បាប់ បណ្តុះបណ្តាលបុគ្គលិកអនុវត្តច្បាប់<br>• កសាងបញ្ចប់ និង អនុម័តអនុក្រឹត្យសំខាន់ៗ | • ***ការសំរបសំរួល និង គោលនយោបាយគ្រប់គ្រងទឹក និង វិនិយោគ ព្រមទាំងតាមដានវឌ្ឍនភាព និង ផលប៉ះពាល់ជាទៀងទាត់***<br>• ***អនុវត្តអនុសាសន៍ ស្តីពីការពិនិត្យមុខងារសារឡើងវិញនៅថ្នាក់កណ្តាល និង ថ្នាក់មូលដ្ឋាន***<br>• ***អនុវត្តច្បាប់ និង អនុក្រឹត្យស្តីពីទឹក ហើយកែសំរួលជាទៀងទាត់***<br>• ***បោះផ្សាយ បណ្តុះបណ្តាលបុគ្គលិកនៅគ្រប់ថ្នាក់ អនុវត្តអនុក្រឹត្យ និង តាមដាន*** | • ***ការសំរបសំរួល និង គោលនយោបាយគ្រប់គ្រងទឹក និង វិនិយោគ ព្រមទាំងតាមដានវឌ្ឍនភាព និង ផលប៉ះពាល់ជាទៀងទាត់***<br>• ***អនុវត្តច្បាប់ និង អនុក្រឹត្យស្តីពីទឹក ហើយកែសំរួលជាទៀងទាត់***<br>• ***អនុវត្តដោយតាមដានជាទៀងទាត់នូវវឌ្ឍនភាព និង ផលប៉ះពាល់ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់*** | WB APIP EFRP ADB AFD JICA | ម្ចាស់ជំនួយ ស្ថាប័នគ្រប់គ្រងធនធានទឹកសំខាន់ៗ<br>MOWRAM<br>MIME<br>MRD<br>ការគាំទ្ររបស់ម្ចាស់ជំនួយម្ចាស់ជំនួយ (ADB បារាំង ជប៉ុន WB ) |

| | | | | | |
|---|---|---|---|---|---|
| -ពង្រឹងភាពស៊ីសង្វាក់គ្នាជាមួយវិសហមជ្ឈការ និង វិមជ្ឈការ<br>-លើកកំពស់ការចូលរួមនៅក្នុង MRC | តាមរយៈការពិគ្រោះយោបល់<br>• បោះផ្សាយអនុក្រឹត្យ និង បណ្តុះបណ្តាលបុគ្គលិក<br>• ***ពិនិត្យមើលភាពស៊ីសង្វាក់គ្នា រវាងការរៀបចំគោលនយោបាយ ការកសាងផែនការ និង កសារសំរេចចិត្ត ស្តីពីការវិនិយោគនៅក្នុងស្ថាប័នទឹកសំខាន់ៗ និង ក្របខ័ណ្ឌអភិបាលកិច្ចនៅមូលដ្ឋាន***<br>• ពង្រឹងការចូលរួមអំពីគំនិតផ្តួចផ្តើមរបស់គណកម្មការទន្លេមេគង្គ នៅក្នុងប្រទេសពាក់ព័ន្ធ (រាប់ទាំងយុទ្ធសាស្រ្តធនធានទឹក ទន្លេមេគង្គ) | ***ផលប៉ះពាល់***<br>• ***អនុវត្តដោយតានដានជាទៀងទាត់នូវវឌ្ឍនភាព និង ផលប៉ះពាល់ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់***<br>• ***ពង្រឹងការសំរបសំរួល និង ភាពស៊ីសង្វាក់គ្នាជាមួយក្របខ័ណ្ឌអភិបាលកិច្ចនៅមូលដ្ឋាន***<br>• ***លើកកំពស់ការសំរបសំរួលកម្មវិធីកម្ពុជាជាមួយកម្មវិធីគណៈកម្មការទន្លេមេគង្គប្រចាំតំបន់*** | • ***បន្តការសំរបសំរួល កម្មវិធីកម្ពុជាជាមួយកម្មវិធីគណៈកម្មការទន្លេមេគង្គប្រចាំតំបន់*** | | |
| **លើកកំពស់ការកសាងផែនការវិនិយោគជាយុទ្ធសាស្រ្ត**<br>-ធ្វើសនិទានកម្មចំពោះការផ្តល់អាទិភាពវិនិយោគ<br>-ចាប់ផ្តើមធ្វើការនៅកំរិតអាង និង ពង្រឹងសមាហរណកម្ម ជាមួយផែន | • បញ្ជាក់ច្បាស់លាស់ នូវលក្ខណៈវិនិច្ឆ័យជ្រើសរើស ចំពោះវិនិយោគជាអាទិភាព<br>• អនុវត្តសាកល្បងនូវផែនការអាងទន្លេមេគង្គនៅតំបន់អាទិភាពមួយ (គំរោងគ្រប់គ្រងធនធានទឹកនៅតំបន់ពាយ័ព្យ) | • ***ពង្រីកទៅកាន់អាង/ អនុអាងដទៃទៀត បន្ទាប់ពីបានពិនិត្យមេរៀនពីបទពិសោធន៍នានាសារជាថ្មី***<br>• ***ដាក់បញ្ចូល និង អនុវត្តសកម្មភាពរបស់ WRM នៅកំរិតមូលដ្ឋាន ក្នុងបរិបទនៃ*** | • ***ពង្រីកទៅកាន់អាង/ អនុអាងដទៃទៀត បន្ទាប់ពីបានពិនិត្យមេរៀនពីបទពិសោធន៍នានាសារជាថ្មី*** | ធនាគារអភិវឌ្ឍន៍អាស៊ី (ប្រព័ន្ធធារាសាស្រ្តនៅតំបន់ពាយ័ព្យ) | - ក្រសួងធនធានទឹក និងឧតុនិយម<br>-ធនាគារអភិវឌ្ឍន៍អាស៊ី<br>-ភាគីពាក់ព័ន្ធដទៃទៀត |

| | | | | | |
|---|---|---|---|---|---|
| ការអភិវឌ្ឍន៍សេដ្ឋកិច្ចទូទៅ:<br>-កសាងផែនការអាង និង អនុអាង<br>សំរាប់អាង/អនុអាង<br>អាទិភាព | • ***ពង្រឹងសមត្ថភាព ដើម្បីវាយតំលៃ អត្ថប្រយោជន៍ចំពោះពលរដ្ឋក្រីក្រ និង រៀបចំ គោលនយោបាយ និង វិនិយោគផ្តោតការ យកចិត្តទុកដាក់ចំពោះពលរដ្ឋក្រីក្រ*** | ***គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ ជនបទទូទៅ*** | | | |
| **បញ្ជ្រាបការត្រៀមលក្ខណ: និង ការបញ្ចៀសគ្រោះ មហន្តរាយ** | • ***ពិនិត្យនិងសំរេច NDMP***<br>• ***បណ្តុះបណ្តាល NCDM នៅក្នុងការ វាយតំលៃ វាយការណ៍ អំពីការខូចខាត***<br>• ***ពិនិត្យមើលបទពិសោធន៍ជាមួយការ គ្រប់គ្រងគ្រោះថ្នាក់នៅមូលដ្ឋាន***<br>• ***ធ្វើសមាហរណកម្មការលក្ខណៈត្រៀម និង ការបញ្ចៀសកម្មភាពនានាក្នុងវិស័យ ដូចជាការប្រើប្រាស់ដីធ្លី និង ការរៀបចំ ហេដ្ឋារចនាសម្ព័ន្ធ*** | • ***បែងចែកធនធានសមស្រប ដើម្បី អនុវត្តNDPM***<br>• ***អនុវត្តNDPM***<br>• ***អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រង ហានិភ័យ*** | • ***បែងចែកធនធានសមស្រប ដើម្បី អនុវត្តNDPM***<br>• ***អនុវត្តNDPM***<br>• ***អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រង ហានិភ័យ*** | | គណ:កម្មាធិការជាតិ គប់គ្រងគ្រោះ មហន្តរាយ ម្ចាស់ជំនួយ |
| **កៀងគរធនធានសំរាប់ ផ្គត់ផ្គង់ទឹក និង អនាម័យ នៅជនបទ :** | • លើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យ ឯកជន តាមរយ: ក្របខ័ណ្ឌច្បាប់និង និយ័តកម្ម (កំពុងដំណើរការ)<br>• ***បង្កើនការវិនិយោគនៅតំបន់ដាច់ស្រយាល ដែលគ្មានការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់*** | • ***ជំរុញការវិនិយោគឯកជន***<br>• ***បង្កើនការវិនិយោគនៅតំបន់ ដាច់ស្រយាលដែលគ្មាន ការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់*** | • ***ជំរុញការវិនិយោគឯកជន***<br>• ***បង្កើនការវិនិយោគនៅតំបន់ ដាច់ស្រយាលដែលគ្មាន ការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់*** | - ធនាគារពិភពលោក | -ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល<br>-ក្រសួងអភិវឌ្ឍន៍ ជនបទ<br>-អាជ្ញាធរមូលដ្ឋាន<br>- វិស័យឯកជន |

# គំណែនំរបស់ការលើកកំពស់លទ្ធផលអនុវត្តន៍ការងារក្នុងវិស័យកសិកម្ម

(គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ : លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និង ភាពអត់ឃ្លាន - គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៧ : ធានាចីរភាពបរិស្ថាន)

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **ពង្រឹងការគ្រប់គ្រងវិស័យកសិកម្ម និង ប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធាន :**<br>- កសាងកម្មវិធីអភិវឌ្ឍន៍កសិកម្ម<br>- រៀបចំធនធានស្របតាមអាទិភាពកម្មវិធី<br>- ពិនិត្យមើលតួនាទីរបស់ស្ថាប័នសាធារណៈ | • ***ដោយមានការគាំទ្រពីជំនួយបច្ចេកទេស បង្កើតកម្មវិធីអភិវឌ្ឍន៍ទូទាំងវិស័យកសិកម្ម ដើម្បីណែនាំការរៀបចំគោលនយោបាយ និង អភិវឌ្ឍន៍***<br>• ***រៀបចំធនធានឱ្យស្របទៅនឹងអាទិភាពកម្មវិធី (ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម)***<br>• ***ពិនិត្យមើលមុខងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ***<br>• ***អនុវត្តការរៀបចំចាត់តាំងមុខងារថ្មីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ)***<br>• បង្កើយការធ្វើឯកជនភាវូប-នីយកម្មសហគ្រាសរដ្ឋនៅក្នុង | • ***អនុវត្តកម្មវិធីកសិកម្ម និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់***<br>• ***រៀបចំធនធានឱ្យស្របទៅនឹងអាទិភាពកម្មវិធី (ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម)***<br>• ***រៀបចំការចាត់តាំងមុខងារថ្មីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ)***<br>• ***ពង្រីកទៅកាន់គ្រប់ខេត្តទាំងអស់*** | • ***អនុវត្តកម្មវិធីកសិកម្ម និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់***<br>• ***ពង្រីកទៅកាន់គ្រប់ខេត្តទាំងអស់*** | ASDL (ADB)<br>(APIP WB)<br>ADESS,<br>RPRP (IFAD)<br>CAAEP II<br>(AusAID) | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>- ម្ចាស់ជំនួយ<br>- ភាគីពាក់ព័ន្ធផ្សេងទៀត<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br><br>**ADB, IFAD, WB FAO GTZ, AFB, AusAID,**<br>**JICA, SIDA** ។ល។ |

| | | | | | |
|---|---|---|---|---|---|
| | វិស័យកសិកម្ម<br>• សិក្សាអំពីជំរើសសំរាប់ការធ្វើសហវិមជ្ឈការសេវាកសិកម្ម (កំពុងដំណើរការ)<br>• អនុវត្តសាកល្បង (សេវាកសិកម្មបែបសហវិមជ្ឈការ) | | | | |
| **ពង្រឹងការគាំទ្រសេវាសំខាន់ៗ រាប់ទាំងការចូលរួមរបស់វិស័យឯកជនផងដែរ**<br>- ប្រព័ន្ធស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មចំរុះ<br>- ជំរុញឱ្យមានអង្គការរបស់ផលិតករ<br>- សុវត្ថិភាពស្បៀង និងស្តង់ដារស្បៀង<br>- ប្រព័ន្ធតាមដានអេពីដេមីសាស្ត្រ<br>- សេវាគាំទ្រកសិ-ពាណិជ្ជកម្ម<br>- ប្រព័ន្ធផ្តល់ពត៌មានជាមុន | • កសាងសមត្ថភាពផ្សព្វផ្សាយកសិកម្មនៅក្នុងខេត្តចំនួន ១៣ (កំពុងដំណើរការ)<br>• ពិនិត្យមើលការផ្សព្វផ្សាយកសិកម្មការគ្រប់គ្រងសត្វល្អិតចង្រៃ (កំពុងដំណើរការ)<br>• ផែនការមេសំរាប់ការស្រាវជ្រាវកសិកម្ម<br>• ***ការសិក្សាស្រាវជ្រាវពីសេវាកសិកម្ម***<br>• ***សិក្សាអត្តសញ្ញាណ/តំរូវការ/ការវាយតំលៃ RPO***<br>• រៀបចំឱ្យមានស្តង់ដារស្បៀង បទប្បញ្ញត្តិ បង្កើតស្ថាប័ន និងផ្សព្វផ្សាយ (កំពុងដំណើរការ)<br>• ***កសាងសមត្ថភាព ពត៌មាន សាធារណៈ និងការអនុវត្តន៍*** | • ***ពង្រឹងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម និង ពង្រីកឱ្យបានគ្រប់ខេត្តទាំងអស់***<br>• ***ពង្រឹងការផ្តល់សេវាកសិកម្មស្នូល ដោយធ្វើសនិទានកម្មការចូលរួមរបស់វិស័យសាធារណៈ និង វិស័យឯកជន***<br>• ***អនុវត្តសាកល្បងគំរោងគាំទ្រ RPO***<br>• ***ពង្រឹងនិងពង្រីកសមត្ថភាព និងការអនុវត្តន៍នៅថ្នាក់មូលដ្ឋាន***<br>• ***ពង្រឹងនិងពង្រីកប្រព័ន្ធតាមដានសត្វនិងរុក្ខជាតិ***<br>• ***បង្កើតប្រព័ន្ធពត៌មានកសិ-ពាណិជ្ជកម្ម***<br>• ***ពង្រឹងប្រព័ន្ធផ្តល់ពត៌មាន*** | • ***ពង្រឹងប្រព័ន្ធផ្សព្វផ្សាយ កសិកម្ម និង ពង្រីកឱ្យបានគ្រប់ខេត្តទាំងអស់***<br>• ***ពង្រឹងការផ្តល់សេវាកសិកម្ម ស្នូល ដោយធ្វើសនិទានកម្មការចូលរួមរបស់វិស័យសាធារណៈ និង វិស័យឯកជន***<br>• ***អនុវត្តសាកល្បងគំរោងគាំទ្រ RPO***<br>• ***ពង្រឹងនិងពង្រីកសមត្ថភាព និងការអនុវត្តន៍នៅថ្នាក់មូលដ្ឋាន*** | **CAAEP II**<br>**ADESS**<br>**APIP**<br>**WB (AAA)**<br>**ASLD**<br><br>***បស្សុសត្វ EU*** | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- **CARDI**<br>- **NDMC**<br>- **AusAID**<br>-**IFAD**<br>- ធនាគារអភិវឌ្ឍន៍អាស៊ី<br>**- FAO WB WFP**<br>- **EU**<br>- ម្ចាស់ជំនួយដទៃទៀត |

| | | | | | |
|---|---|---|---|---|---|
| | • បង្កើតប្រព័ន្ធតាមដានអេពីដេមី-សាស្ត្រសត្វ (កំពុងដំណើរការ)<br>• បង្កើតប្រព័ន្ធចត្តាឡីស័ក/តាមដានរុក្ខជាតិ (ក្របខ័ណ្ឌច្បាប់ ស្ថាប័ន ការកសាងសមត្ថភាព)<br>• ***បង្កើតប្រព័ន្ធពត៌មានកសិ-ពាណិជ្ជកម្ម***<br>• ***ពង្រឹងប្រព័ន្ធផ្តល់ពត៌មានជាមុនដែលមានស្រាប់ (សូមអាន យុទ្ធសាស្ត្របញ្ជៀសគ្រោះមហន្តរាយធម្មជាតិ)*** | ***ជាមុនដែលមានស្រាប់ (សូមអាន យុទ្ធសាស្ត្រកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ)*** | | | |
| - **ដោះស្រាយឧបសគ្គឱ្យបានជាក់លាក់ទាក់ទងនឹងផលិតផល** តាមរយៈកម្មវិធីសមាហរណកម្ម និង ភាពជាដៃគូនៃវិស័យសាធារណៈ និង ឯកជន<br>- បញ្ជាក់ឱ្យបានច្បាស់ពីយុទ្ធសាស្ត្រវិស័យដំណាំស្រូវ<br>- ពង្រឹងសេវាគាំទ្រ បសុសត្វ<br>- សំរបសំរួលឱ្យមានការតំរង់ទិសវិស័យកៅស៊ូ | • ***រៀបចំឱ្យមានយុទ្ធសាស្ត្រ វិស័យស្រូវ ដោយមានការគាំទ្រទីប្រឹក្សាបច្ចេកទេស***<br>• ពង្រឹង និង ពង្រីក ប្រព័ន្ធ **VAHW** (**APIP** កំពុង ដំណើរការនៅក្នុងខេត្ត ៤ -គំរោងបសុសត្វរបស់ **EU** នៅក្នុងខេត្ត ៥ នាពេលខាងមុខ)<br>• *ការសិក្សាលើខ្សែសង្វាក់តំលៃបសុសត្វ*<br>• ការបញ្ចប់ការធ្វើឯកជនភាវូប-នីយកម្មសហគ្រាសកៅស៊ូ (កំពុងដំណើរការ)<br>• ការរកទីផ្សារ/ការសិក្សាអំពីការផ្តល់ | • អនុវត្តសកម្មភាពជាក់លាក់ (ប្រភេទ និង កំរិត ទៅតាមសេចក្តីសំរេចលើយុទ្ធសាស្ត្រ និងគោលនយោបាយស្តីពីដំណាំស្រូវ)<br>• ពង្រឹង និង ពង្រីកប្រព័ន្ធ VAHW ឱ្យបានគ្រប់ខេត្ត-ក្រុងទាំងអស់<br>• ដោះស្រាយបញ្ហាចំបងៗមួយចំនួន ដែលត្រូវបានកំណត់នៅក្នុងលទ្ធផលនៃការសិក្សាលើខ្សែសង្វាក់ | • ***ពង្រឹង និង ពង្រីកប្រព័ន្ធ VAHW ឱ្យបានគ្រប់ខេត្ត-ក្រុងទាំងអស់*** | **APIP**<br>-គំរោងបសុសត្វរបស់ **EU**<br>**ASDP**<br>**AFD** | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>- ភាគីពាក់ព័ន្ធ<br>- ធនាគារពិភពលោក<br>- **EU**<br>- អង្គការក្រៅរដ្ឋាភិបាល<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ធនាគារអភិវឌ្ឍន៍អាស៊ី<br>- **ADB/AFD** |

| | | | | | |
|---|---|---|---|---|---|
| - ការគាំទ្រឱ្យមានការធ្វើពាណិជ្ជកម្មផលផល<br>- ការអភិវឌ្ឍន៍ដំណាំសំរាប់លក់/មូលដ្ឋានរឹងមាំសំរាប់ផលិតផល | វិញ្ញាបនប័ត្រកៅស៊ូ (កំពុងដំណើរការ)<br>• កម្មវិធីគាំទ្រការផលិតកៅស៊ូគ្រួសារ<br>• ***ធ្វើសេរីភាវូបនីយកម្មទីផ្សារកៅស៊ូ/ អនុញ្ញាតឱ្យបង្កើត សហគ្រាសកែច្នៃឯកជន***<br>• ***ពិនិត្យមើលបទពិសោធន៍ទាក់ទងប្រព័ន្ធចិញ្ចឹមត្រីក្នុងស្រែ***<br>• ***ដោះស្រាយឧបសគ្គមួយចំនួនទាក់ទងនឹងទីផ្សារនិងការនាំចេញត្រី***<br>• ***សិក្សាអំពីឧបសគ្គឬសក្តានុពលសំរាប់ធ្វើពិពិធកម្ម និងរកជំរើសដែលអាចមានសំរាប់គាំទ្រដល់កិច្ចអភិវឌ្ឍន៍*** | តំលៃបសុសត្វ<br>ដាក់បញ្ចូលវិធីសាស្រ្តប្រព័ន្ធដាំដុះរួមទាំងប្រព័ន្ធចិញ្ចឹមត្រីក្នុងស្រែទៅក្នុងកម្មវិធីផ្សព្វផ្សាយផងដែរ<br>• ពង្រីកកម្មវិធីគាំទ្រដល់អ្នកផលិតកៅស៊ូក្នុងលក្ខណៈគ្រួសារ<br>• ដោះស្រាយឧបសគ្គមួយចំនួនចំពោះការរកទីផ្សារ និង ការនាំចេញត្រី | | | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ម្ចាស់ជំនួយ |
| | **កំណែទំរង់សំខាន់ៗ និង ការវិនិយោគស្របពេលជាមួយគ្នា :** កំណែទំរង់មុខងារសាធារណៈ រដ្ឋបាលនិងការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ ការអភិវឌ្ឍន៍វិស័យឯកជន ។ | | | | |

# ការអភិវឌ្ឍន៍មីក្រូហិរញ្ញវត្ថុ និង ហិរញ្ញវត្ថុជនបទ

(គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ : លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និង ភាពអត់ឃ្លាន)

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **ធ្វើបច្ចុប្បន្នភាពគោលនយោបាយហិរញ្ញវត្ថុជនបទ :** | • ***លើកកំពស់ការយល់ដឹង អំពីប្រភពប្រាក់ចំណូលគ្រួសារនៅជនបទ និង យុទ្ធសាស្ត្រសំរបតាមស្ថានការ : សិក្សាតំរូវការសេវា និង ការផ្គត់ផ្គង់បច្ចុប្បន្ន យុទ្ធសាស្ត្រសំរបតាមស្ថានការ និង យុទ្ធសាស្ត្រលំហូរសាច់ប្រាក់***<br>• ***ពិនិត្យសឡើងវិញ និង ធ្វើបច្ចុប្បន្នភាពគោលនយោបាយជនបទ និង មីក្រូហិរហញ្ញវត្ថុ តាមរយៈ ការសិក្សាស្រាវជ្រាវ និង កិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធទាំងអស់*** | • តាមដានការអនុវត្តគោលនយោបាយ និង ការធ្វើបច្ចុប្បន្នភាព រួមមានតាមរយៈកិច្ចពិភាក្សាជាទៀងទាត់ជាមួយ MFI/MFO | • តាមដានការអនុវត្តគោលនយោបាយ និង ការធ្វើបច្ចុប្បន្នភាព រួមមានតាមរយៈកិច្ចពិភាក្សាជាទៀងទាត់ជាមួយ MFI/MFO | | MEF NBC RDB MFI/MFO ស្ថាប័ន តាមវិស័យ ម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន |

| | | | | | |
|---|---|---|---|---|---|
| **សំរួលដល់ការបង្កើតសេវាហិរញ្ញវត្ថុឱ្យបានច្រើន :** | • កែសំរួលបន្ទុកពន្ធដាររបស់ MFI អោយមានលក្ខណៈសាមញ្ញ<br>• សិក្សាគំរូផ្សេងៗសំរាប់បង្កើតមូលនិធិធានាប្រាក់បញ្ញើរ ឬ គ្រឹះស្ថានផ្តល់ការធានា | • អនុវត្តអនុសាសន៍ស្តីពីការសិក្សាមូលនិធិធានា ឬ ស្ថាប័នធានា | | | - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ធនាគារជាតិនៃកម្ពុជា<br>-ធនាគារអភិវឌ្ឍន៍ជនបទ<br>-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ<br>-ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ<br>- ម្ចាស់ជំនួយ |
| កាត់បន្ថយចំណាយប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ | សិក្សារកជំរើសសំរាប់បង្កើតការិយាល័យព័តមានឥណទាន<br>កាត់បន្ថយហានិភ័យប្តូរប្រាក់សំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ<br>ជំរុញផែនការរបស់ធនាគារជាតិនៃកម្ពុជាក្នុងការផ្ទេរប្រាក់រវាងបណ្តាខេត្តនិងដើម្បីពង្រីកសភាផាត់ទាត់មូលប្បទានប័ត្រនៅតាមបណ្តាខេត្ត<br>ជំរុញការបង្កើតសមាគមន៍នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ<br>កែសំរួលកាតព្វកិច្ចទទួលខុសត្រូវរបស់ភាគទុនិក<br>ពង្រឹងកិច្ចប្រឹងប្រែង ចំពោះការកសាងសមត្ថភាពរបស់ | បង្កើតការិយាល័យព័ត៌មានឥណទាន?<br>បន្តប្រឹងប្រែងកសាងសមត្ថភាពរបស់ធនាគារជាតិនៃកម្ពុជា និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ | | | MEF<br>ម្ចាស់ជំនួយ MFI<br><br>MEF NBC MFI MFO<br><br>NBC MEF<br>NBC<br>ម្ចាស់ជំនួយ<br><br>MFI MFO |

| | | | | | |
|---|---|---|---|---|---|
| | ធនាគារជាតិនៃកម្ពុជានិង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ | | | | |
| **បង្កើនលក្ខណៈវិជ្ជាជីវៈចំពោះអ្នកផ្តល់ឥណទានខ្នាតតូច** | • *ពង្រឹងសមត្ថភាពត្រួតពិនិត្យរបស់ធនាគារជាតិ*<br>• *បង្កើនលទ្ធភាពយល់ដឹងរបស់សាធារណៈជន រដ្ឋាភិបាល ម្ចាស់ជំនួយ អំពីកិច្ចប្រតិបត្តិល្អនៅក្នុងមីក្រូហិរញ្ញវត្ថុ* | | | | ធនាគារជាតិ<br>ម្ចាស់ជំនួយ<br>MEF សមាគមន៍ MFI<br>ស្ថាប័នតាមវិស័យ |
| | **កំណែទំរង់សំខាន់ៗ និង ការវិនិយោគស្របពេលជាមួយគ្នា** : លើហេដ្ឋារចនាសម្ព័ន្ធ ការកែលំអបរិយាកាសវិនិយោគឱ្យល្អប្រសើរឡើង ការអនុវត្តន៍កិច្ចសន្យា និង ការពង្រឹងវិស័យច្បាប់ និង ប្រព័ន្ធតុលាការ ។ | | | | |

## ការបង្កើតសេវាហេដ្ឋារចនាសម្ព័ន្ធជនបទ

(គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ១ : លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និង ភាពអត់ឃ្លាន)

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **ពង្រឹងការណែនាំជាយុទ្ធសាស្ត្រ :** | • ***ពិនិត្យមើលគោលនយោបាយ និងយុទ្ធសាស្ត្រដែលកំពុងអនុវត្ត ការរៀបចំផ្នែកស្ថាប័ន សំរាប់គ្រប់គ្រង និង ការផ្តល់ហិរញ្ញប្បទានដល់សេវាហេដ្ឋារចនាសម្ព័ន្ធជនបទ កំណត់រកភាពខុសគ្នា និងភាពមិនស៊ីសង្វាក់គ្នា ព្រមទាំងបង្កើតផែនការចង្អុលបង្ហាញ សំរាប់ដោះស្រាយបញ្ហាទាំងនោះ***<br>• ***ពង្រឹងភាពស៊ីសង្វាក់គ្នានៃការកសាងផែនការ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ជាមួយការកសាងផែនការអនុវត្ត នៅមូលដ្ឋាន និង*** | • ***ការកំណត់គោលដៅនិង វិនិយោគអាទិភាពឱ្យកាន់តែប្រសើរ***<br>• ***ពង្រឹងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋាន ដើម្បីកំណត់អាទិភាព ធ្វើផែនការ និង គ្រប់គ្រងហេដ្ឋារចនា-សម្ព័ន្ធនិងការផ្តល់សេវា នៅក្នុងមូលដ្ឋាន***<br>• ***ជំរុញឱ្យវិស័យឯកជនឱ្យរួមចំណែកក្នុងការផ្តល់សេវា (តាមរយៈលទ្ធភាពទទួលបានឥណទាន ការធានារ៉ាប់រង ការបង្កលក្ខណៈងាយស្រួលដល់ការសុំលិខិតអនុញ្ញាត)*** | • ***ការកំណត់គោលដៅនិង អាទិភាពវិនិយោគឱ្យបានកាន់តែប្រសើរ*** | | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល<br>- ក្រសួងធនធានទឹក និង ឧត្តុនិយម<br>- ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- អាជ្ញាធរមូលដ្ឋាន<br>- ម្ចាស់ជំនួយ<br>- វិស័យឯកជន |

| | | | | | |
|---|---|---|---|---|---|
| | ***នៅក្នុងតំបន់***<br>• ពង្រឹងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋាន ដើម្បីកំណត់អាទិភាព ធ្វើផែនការ និង គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវានៅមូលដ្ឋាន<br>• ***ជំរុញឱ្យវិស័យឯកជនឱ្យរួមចំណែកក្នុងការផ្តល់សេវា (តាមរយៈលទ្ធភាពទទួលបានឥណទាន ការធានារ៉ាប់រង ការបង្កលក្ខណៈងាយស្រួលដល់ការសុំលិខិតអនុញ្ញាត)***<br>• ***លើកកំពស់ការស្តារចំណាយនៅក្នុងសេវាហេដ្ឋារចនា-សម្ព័ន្ធជនបទ*** | • ***លើកកំពស់ការស្តារចំណាយនៅក្នុងសេវាហេដ្ឋារចនា-សម្ព័ន្ធជនបទ*** | | | |
| **ធានាឱ្យគោលនយោបាយដឹកជញ្ជូន គាំទ្រគោលដៅកាត់បន្ថយភាពក្រីក្រ :** | • ***រៀបចំ អនុម័ត និង អនុវត្តគោលនយោបាយជាតិស្តីពីការដឹកជញ្ជូន ដែលដោះស្រាយតំរូវការផ្លាស់ប្តូរទីកន្លែងនៅជនបទ***<br>• ***រៀបចំគោលនយោបាយជាតិ*** | • ***អនុវត្តគោលនយោបាយជាតិស្តីពីការដឹកជញ្ជូន*** | • ***អនុវត្តគោលនយោបាយជាតិស្តីពីការដឹកជញ្ជូន*** | **- ADB**<br>**- IDA**<br>**- PRIP** និង **PRIP- II**<br>**- KfW (LBAT)** | - ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |

| | | | | | |
|---|---|---|---|---|---|
| | ***ឱ្យស្របជាមួយនឹងយុទ្ធសាស្ត្រផ្លូវថ្នល់នៅជនបទ***<br>• ***អាចចាត់ទុកជាមុនបាន***<br>• ***បង្កើតមូលដ្ឋានទិន្នន័យរបស់អាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្ទេរសារពើពន្ធ*** | | | | |
| **ការផ្គត់ផ្គង់ថាមពលនិងភ្លើងអគ្គិសនីនៅតំបន់ជនបទ :** | • រៀបចំឱ្យមានផែនការមេស្តីពីការផ្គត់ផ្គង់ភ្លើងអគ្គិសនីនៅជនបទ ដើម្បីដឹកនាំការវិនិយោគក្នុងការផ្គត់ផ្គង់អគ្គិសនីទៅជនបទតាមបែបបរិមជ្ឈការ<br>• បង្កើនលទ្ធភាពបានទទួលហិរញ្ញប្បទាន ជាពិសេសសំរាប់សេវាផ្គត់ផ្គង់ឯកជននៅជនបទ<br>• បង្កើតឱ្យមានទស្សនាទានស្តីពីតម្លាភាព និងការបំពេញខាតផ្អែកលើលទ្ធផលអនុវត្តន៍ | • អនុវត្តផែនការមេ<br>• បង្កើនលទ្ធភាពបានទទួលហិរញ្ញប្បទាន ជាពិសេសសំរាប់សេវាផ្គត់ផ្គង់ឯកជននៅជនបទ<br>• បង្កើតឱ្យមានទស្សនាទានស្តីពីតម្លាភាព និងការបំពេញខាតផ្អែកលើលទ្ធផលអនុវត្តន៍ | • អនុវត្តផែនការមេ | | - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- វិស័យឯកជន<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| **-លើកកំពស់លទ្ធភាពទៅកាន់ជនបទតាមរយៈការថែទាំផ្លូវថ្នល់ដែលមានស្រាប់និងបង្កើនលទ្ធភាពផ្លាស់ទីនៅ** | • ***រៀបចំការធ្វើបញ្ជីសារពើភណ្ឌ និង ផែនទីផ្លូវថ្នល់ជនបទ***<br>• ***ធានាឱ្យមានទំនាក់ទំនងពេញលេញរវាងបណ្តាញផ្លូវថ្នល់*** | • ***រៀបចំការធ្វើបញ្ជីសារពើភណ្ឌ និង ផែនទីផ្លូវថ្នល់ជនបទ***<br>• ***ធានាឱ្យមានទំនាក់ទំនងពេញលេញរវាងបណ្តាញផ្លូវថ្នល់*** | • | | - ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | | | |
|---|---|---|---|---|---|
| **ជនបទ** | ***សំខាន់ៗ និងផ្លូវថ្នល់នៅ មូលដ្ឋាន***<br>• ***ប្រើប្រាស់បច្ចេកវិទ្យាសមស្រប ផ្អែកលើកំលាំងពលកម្ម សំរាប់ការថែទាំផ្លូវថ្នល់***<br>• ***ពិនិត្យមើលអត្ថិភាព លទ្ធភាព និងសុវត្ថិភាពនៃសេវាដឹក ជញ្ជូននៅជនបទ កំណត់រកភាព ខុសគ្នា និង បង្កើតអនុសាសន៍ សំរាប់លុបបំបាត់ភាពខុសគ្នា ទាំងនោះ***<br>• ***ជំរុញឱ្យវិស័យឯកជន ចូលរួម ផ្តល់សេវាផ្នែកផ្លូវថ្នល់ និង ដឹកជញ្ជូន*** | ***សំខាន់ៗ និងផ្លូវថ្នល់នៅ មូលដ្ឋាន***<br>• ***ប្រើប្រាស់បច្ចេកវិទ្យាសមស្រប ផ្អែកលើកំលាំងពលកម្ម សំរាប់ការថែទាំផ្លូវថ្នល់***<br>• អនុវត្តអនុសាសន៍នៃការពិនិត្យសេវា នៅជនបទ<br>• ***ជំរុញឱ្យវិស័យឯកជនចូលរួម ផ្តល់សេវាផ្នែកផ្លូវថ្នល់ និង ដឹកជញ្ជូន*** | | | |
| **-ផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ សំរាប់ថែទាំផ្លូវនិងសំរាប់ ជួសជុលកែលំអផ្លូវនៅ មូលដ្ឋាន** | • ***ធ្វើកំណែទំរង់ FMRR ដើម្បីធានា ឱ្យមានការផ្តល់មូលនិធិសំរាប់ ថែទាំផ្លូវថ្នល់បានគ្រប់គ្រាន់ អាចព៉ាន់ស្មានជាមុនបាន***<br>• បង្កើតមូលដ្ឋានធនធានរបស់ អាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្ទេរ សារពើពន្ធ | • ***បង្កើតមូលដ្ឋានធនធានរបស់ អាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្ទេរ សារពើពន្ធ*** | | **IFAPER**<br>តាមពិនិត្យ មើល | **MEF** |

| | | | | | |
|---|---|---|---|---|---|
| **ការផ្តត់ផ្គង់ថាមពល/អគ្គិសនីនៅតំបន់ជនបទកាន់តែប្រសើរ** | • ***រៀបចំឱ្យមានផែនការមេស្តីពីការផ្គត់ផ្គង់ភ្លើងអគ្គិសនីនៅជនបទ ដើម្បីដឹកនាំការវិនិយោគក្នុងការផ្គត់ផ្គង់អគ្គិសនីទៅជនបទតាមបែបវិមជ្ឈការ***<br>• ***បង្កើនលទ្ធភាពបានទទួលហិរញ្ញប្បទាន ជាពិសេសសំរាប់ក្រុមហ៊ុនផ្គត់ផ្គង់ឯកជននៅជនបទ***<br>• ***បង្កើតឱ្យមានទស្សនទានស្តីពីតម្លាភាព និងការបំពេញខាតផ្អែកលើលទ្ធផលអនុវត្ត*** | • ***បង្កើនលទ្ធភាពបានទទួលហិរញ្ញប្បទាន ជាពិសេសសំរាប់ក្រុមហ៊ុនផ្គត់ផ្គង់ឯកជននៅជនបទ***<br>• ***បង្កើតឱ្យមានទស្សនទានស្តីពីតម្លាភាព និងការបំពេញខាតផ្អែកលើលទ្ធផលអនុវត្តន៍*** | | | - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- វិស័យឯកជន<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| | **កំណែទំរង់សំខាន់ៗ និង ការវិនិយោគស្របពេលជាមួយគ្នា :** វិមជ្ឈការ ការអភិវឌ្ឍន៍វិស័យឯកជន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ: ។ | | | | |

## ការអប់រំនៅជនបទ

(គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី២: សំរេចឱ្យបានជាទូទៅការអប់រំមូលដ្ឋាន-គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៣: លើកកំពស់សមភាពយេនឌ័រនិងផ្តល់សិទ្ធិអំណាចដល់ស្ត្រី)

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **បង្កលក្ខណៈអោយមានលទ្ធភាពទទួល ការអប់រំនៅជនបទប្រកបដោយសមធម៌ :** | • បង្កើនការវិនិយោគនៅក្នុងតំបន់ក្រីក្រ និង តំបន់ដែលគ្មានសេវាអប់រំគ្រប់គ្រាន់<br>• រៀបចំគោលនយោបាយដើម្បីបង្កើនការចុះឈ្មោះចូលរៀនដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាយេនឌ័រ | • ***បង្កើនការវិនិយោគ នៅក្នុងតំបន់ក្រីក្រ និង តំបន់ដែលគ្មានសេវាអប់រំគ្រប់គ្រាន់***<br>• ***អនុវត្ត និងពិនិត្យគោលនយោបាយ*** | • បង្កើនការវិនិយោគ នៅក្នុងតំបន់ក្រីក្រ និង តំបន់ដែលគ្មានសេវាអប់រំគ្រប់គ្រាន់ | កំពុងអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន | - ក្រសួងអប់រំ យុវជន និង កីឡា<br>- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន<br>- ម្ចាស់ជំនួយ<br>- អង្គការក្រៅរដ្ឋាភិបាល<br>- អ្នកប្រើប្រាស់<br>- អាជ្ញាធរមូលដ្ឋាន |
| **លើកកំពស់គុណភាពអប់រំនៅជនបទ :** | • បន្តធ្វើវិមជ្ឈការការធ្វើផែនការ និង ការគ្រប់គ្រងការអប់រំ<br>• បង្កើនការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន (ប្រាក់បៀវត្សរ៍ ផ្ទះសម្បែង ទិសដៅអាជីព)<br>• លើកកំពស់គុណភាពនៃការ | • ***ពិនិត្យតាមដានគុណភាពនៃសេវាអប់រំនៅជនបទ*** | • ***ពិនិត្យតាមដានគុណភាពសេវាអប់រំនៅជនបទ*** | កំពុងអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន | - ក្រសួងអប់រំ យុវជន និង កីឡា<br>- ម្ចាស់ជំនួយ<br>- អង្គការក្រៅរដ្ឋាភិបាល<br>- អ្នកប្រើប្រាស់<br>- អាជ្ញាធរមូលដ្ឋាន |

| | | | | | |
|---|---|---|---|---|---|
| | បណ្តុះបណ្តាលគ្រូបង្រៀន<br>• ***បង្កើតប្រព័ន្ធធានានិងតាមដានគុណភាព***<br>• ***ពិនិត្យមើលកម្មវិធីសិក្សាឡើងវិញដើម្បីបញ្ចូលប្រធានបទទាក់ទងនឹងសហគមន៍ជនបទ*** | | | | |
| **កែសំរួលកម្មវិធីអក្ខរកម្ម :** | • ***បន្ថែមខ្លឹមសារសំខាន់ៗនៅក្នុងកម្មវិធីអក្ខរកម្ម ដោយធ្វើយ៉ាងណាឱ្យកម្មវិធីនេះ មានទំនាក់ទំនងកាន់តែច្រើនទៅនឹងសហគមន៍នៅជនបទ*** | | | | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ស្ថាប័នដែលធ្វើការងារខាងវិស័យជនបទ<br>- អ្នកប្រើប្រាស់<br>- ម្ចាស់ជំនួយ<br>- អង្គការក្រៅរដ្ឋាភិបាល |
| **កំណត់គោលដៅឱ្យកាន់តែប្រសើរចំពោះក្រុមពលរដ្ឋងាយរងគ្រោះ :** | • រៀបចំកម្មវិធីវិនិយោគលើការអប់រំដែលដោះស្រាយបញ្ហាឬ តំរូវការជាក់លាក់របស់ក្រុមពលរដ្ឋងាយរងគ្រោះ : ក្មេងស្រី គ្រួសារក្រីក្រ ជនជាតិភាគតិច<br>• បណ្តុះបណ្តាលគ្រូបង្រៀនដែលចេះនិយាយភាសានៅមូលដ្ឋាន | • ***រៀបចំកម្មវិធីវិនិយោគលើការអប់រំដែលដោះស្រាយបញ្ហាឬ តំរូវការជាក់លាក់របស់ក្រុមពលរដ្ឋងាយរងគ្រោះ : ក្មេងស្រី គ្រួសារក្រីក្រ ជនជាតិ ភាគតិច***<br>• ***បណ្តុះបណ្តាលគ្រូបង្រៀនដែលចេះនិយាយភាសាមូលដ្ឋាន*** | • ***រៀបចំកម្មវិធីវិនិយោគលើការអប់រំដែលដោះស្រាយបញ្ហាឬ តំរូវការជាក់លាក់របស់ក្រុមពលរដ្ឋងាយរងគ្រោះ: ក្មេងស្រី គ្រួសារក្រីក្រ ជនជាតិ ភាគតិច***<br>• ***បណ្តុះបណ្តាលគ្រូបង្រៀនដែលចេះនិយាយភាសាមូលដ្ឋាន*** | កំពុងអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន | - ក្រសួងអប់រំ យុវជន និងកីឡា<br>- អង្គការក្រៅរដ្ឋាភិបាល<br>- ម្ចាស់ជំនួយ<br>- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |

## ការថែទាំសុខភាពនៅជនបទ

(គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៤ : កាត់បន្ថយអត្រាមរណភាពកុមារ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៥ : លើកកំពស់សុខភាពមាតា។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៦ : ប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និង ជំងឺដទៃទៀត)

| | **ក្របខ័ណ្ឌពេលវេលា** | | | | |
|---|---|---|---|---|---|
| | **រយៈពេលខ្លី (២០០៤-២០០៦)** | **រយៈពេលមធ្យម (២០០៧-២០១០)** | **រយៈពេលវែង (ក្រោយឆ្នាំ ២០១០)** | **ធនធាន** | **ដៃគូ** |
| **បង្កើនលទ្ធភាពទទួលបាន និងលើកកំពស់គុណភាព សេវាថែទាំសុខភាព :** | • កែលំអការធ្វើផែនការ និង ការចំណាយសាធារណៈ ទៅលើមូលដ្ឋានសំភារៈបំរើឱ្យការថែទាំសុខភាព ជាពិសេសតាមរយៈ ការវិភាគកាន់តែប្រសើរអំពីតំរូវការតាមតំបន់<br>• បន្តអភិវឌ្ឍន៍មធ្យោបាយថែទាំសុខភាពបឋម បន្តកសាងមន្ទីរពេទ្យបង្អែកទីពីរ | • កែលំអការធ្វើផែនការ និង ការចំណាយសាធារណៈ ទៅលើមូលដ្ឋានសំភារៈបំរើឱ្យការថែទាំសុខភាព ជាពិសេសតាមរយៈ ការវិភាគកាន់តែប្រសើរអំពីតំរូវការតាមតំបន់<br>• ***បន្តអភិវឌ្ឍន៍មធ្យោបាយថែទាំសុខភាពបឋម បន្តកសាងមន្ទីរពេទ្យបង្អែកទីពីរ*** | • ***បន្តអភិវឌ្ឍន៍មធ្យោបាយថែទាំសុខភាពបឋម បន្តកសាងមន្ទីរពេទ្យបង្អែកទីពីរ*** | កំពុងអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន | - ក្រសួងសុខាភិបាល<br>- អាជ្ញាធរមូលដ្ឋាន<br>- អ្នកប្រើប្រាស់<br>- វិស័យឯកជន<br>- អង្គការក្រៅរដ្ឋាភិបាល<br>- ម្ចាស់ជំនួយ |

| | | | | | |
|---|---|---|---|---|---|
| **បង្កើនលទ្ធភាពរ៉ាប់រង ប្រើប្រាស់ សេវាថែទាំសុខភាព ដល់ប្រជាពលរដ្ឋក្រីក្រ :** | • ពង្រឹងសមត្ថភាពគ្រប់គ្រងនៅមូលដ្ឋាន<br>• ជំរុញឱ្យមានមូលនិធិដែលមាននិរន្តរភាពនៅមូលដ្ឋាន<br>• ពិនិត្យមើលគោលនយោបាយកំណត់ថ្លៃឡើងវិញ ដោយផ្តោតទៅលើការបង្កើតយន្តការកំណត់គោលដៅឱ្យមានប្រសិទ្ធិភាពចំពោះប្រជាពលរដ្ឋក្រីក្រ<br>• ផ្តោតការយកចិត្តទុកសារជាថ្មីលើសុខភាពសាធារណៈ និងការបង្ការ | • ***ពង្រឹងសមត្ថភាពគ្រប់គ្រងនៅមូលដ្ឋាន ។***<br>• ***ជំរុញឱ្យមានមូលនិធិដែលមាននិរន្តរភាពនៅមូលដ្ឋាន ។***<br>• ***កែសំរួលគោលនយោបាយកំណត់ថ្លៃឡើងវិញ ។*** | | កំពុងអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន | |
| **ជំរុញឱ្យមានការចូលរួមពីវិស័យឯកជន :** | • ***ពិនិត្យមើលបទពិសោធន៍ទាក់ទងនឹងការផ្តល់សេវាឯកជនក្នុងការថែទាំសុខភាព*** | • ***ពិនិត្យមើលក្របខ័ណ្ឌគោលនយោបាយសំរាប់ការផ្តល់ការថែទាំសុខភាពឯកជន*** | • ***ផ្តោតទៅលើវិនិយោគសាធារណៈនៅតំបន់ដាច់ស្រយាលបន្ថែមទៀត*** | | - ក្រសួងសុខាភិបាល<br>- វិស័យឯកជន<br>- ម្ចាស់ជំនួយ |

## បញ្ជារួម

| | **ទិដ្ឋភាពសំខាន់ៗសំរាប់វិស័យជនបទ** |
|---|---|
| **ការគ្រប់គ្រងវិស័យសាធារណៈ** | • កំណែទំរង់មុខងារសាធារណៈ រួមទាំង ការផ្តល់ប្រាក់បៀវត្សរ៍សមរម្យ ដើម្បីទប់ស្កាត់បុគ្គលិកដែលមានសមត្ថភាពកុំឱ្យរត់ចោលជួរ និង លើកកំពស់គុណភាពនៃការផ្តល់សេវាសាធារណៈ<br>• កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំង ការរៀបចំធនធានសាធារណៈដែលមានស៊ីសង្វាក់គ្នាជាមួយនឹងសកម្មភាពជាអាទិភាពនៅជនបទ ដែលបានឯកភាពគ្នា (ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម) តម្លាភាព និង លទ្ធភាពព្យាករណ៍លើការបែងចែកធនធាន |
| **អំពើពុករលួយ** | • កំណែទំរង់ប្រព័ន្ធតុលាការ និង ការអនុវត្តន៍ច្បាប់និងបទដ្ឋានគតិយុត្តិ ដែលនៅជាធរមាន<br>• ការកាត់បន្ថយចំណាយប្រតិបត្តិការនៅតាមខ្សែសង្វាក់ទីផ្សារ<br>• ការកែលំអលទ្ធភាពព្យាករណ៍នៃកិច្ចសន្យាឱ្យបានកាន់តែល្អប្រសើរឡើង |
| **វិមជ្ឈការ និង សហវិមជ្ឈការ** | • ការរីកចំរើននៅក្នុងដំណើរការកែទំរង់វិមជ្ឈការ និង សហវិមជ្ឈការ<br>• ការចូលរួមនៃស្ថាប័នវិស័យជនបទកាន់តែច្រើននៅក្នុងកិច្ចពិភាក្សាលើគោលនយោបាយវិសហមជ្ឈការ<br>• ការបន្តអនុវត្តគំរោងសាកល្បងវិសហមជ្ឈការនៅក្នុងស្ថាប័នវិស័យជនបទ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ - ក្រសួងធនធានទឹក និង ឧតុនិយម - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់) |
| **ការអភិវឌ្ឍន៍វិស័យឯកជន** | • ការអនុវត្តន៍កំណែទំរង់បរិយាកាសវិនិយោគ រួមទាំង ការដោះស្រាយបញ្ហាបរិយាកាសវិនិយោគនៅជនបទផងដែរ<br>• ការបង្កើតយុទ្ធសាស្ត្រវិស័យឯកជន ដែលយកចិត្តទុកដាក់ទៅលើសហគ្រាសខ្នាតតូចនិងមធ្យមនៅជនបទ និង តំរូវការផ្នែកកសិ-ពាណិជ្ជកម្ម |

# ផ្នែក I: ការអភិវឌ្ឍន៍ប្រកបដោយទីរក្រោ និងកំណើនៈ ចំណុចស្នូលនៃការអភិវឌ្ឍន៍ជនបទ

## *កំណើនកន្លងមកមិនបាននាំមកនូវការកាត់បន្ថយភាពក្រីក្រជាធំដុំទេ*

១. *មូលដ្ឋានគ្រឹះម៉ាក្រូសេដ្ឋកិច្ចដែលមានលក្ខណៈអំណោយផលអនុញ្ញាតឱ្យមានអត្រាកំណើនខ្ពស់នៅក្នុងរយៈពេលក្រោយជំលោះផ្ទៃក្នុង*។ កំណើនសេដ្ឋកិច្ចមានភាពរឹងមាំ ជាមធ្យមស្មើនឹង ៦% នៅក្នុងកំឡុងឆ្នាំ ១៩៩៤-២០០១ លើកលែងនៅក្នុងឆ្នាំ ១៩៩៨ បន្ទាប់ពីព្រឹត្តិការណ៍វិបត្តិនយោបាយនាពាក់កណ្តាលឆ្នាំ ១៩៩៧។ ការងើបឡើងវិញនៃសេដ្ឋកិច្ចមានល្បឿនលឿននៅក្នុងអំឡុងឆ្នាំ ១៩៩៩-២០០១ ដោយមានកំណើនផលិតផលក្នុងស្រុកសរុប (GDP) ប្រចាំឆ្នាំជាមធ្យម ៧ភាគរយ។ ចំណូលសារពើពន្ធមានការកើនឡើង អត្រាអតិផរណាត្រូវបានកាត់បន្ថយ (ក្រោម ៤%) ហើយអត្រាប្តូរប្រាក់មានស្ថេរភាព។ ភាពឿនលឿននៃរចនាសម្ព័ន្ធសំខាន់ៗត្រូវបានសំរេចបាន ដោយមានការអនុវត្តន៍នូវកម្មវិធីផ្តល់អាជ្ញាប័ណ្ណសារជាថ្មីចំពោះធនាគារពាណិជ្ជ ការបន្តពង្រឹងរដ្ឋបាលពន្ធដារនិងគយ និងការរៀបចំសេចក្តីព្រាងនូវច្បាប់ពាណិជ្ជកម្មសំខាន់ៗ ដែលចាំបាច់ដើម្បីបំពេញលក្ខខណ្ឌនៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO)។

២. *ប៉ុន្តែសេដ្ឋកិច្ចប្រទេសកម្ពុជានៅតែមានភាពងាយរងគ្រោះ ដោយមានកំណើនមានមូលដ្ឋានតូចចង្អៀត និងលំអៀងទៅរកតំបន់ទីប្រជុំជន និងមានបរិស្ថានធ្វើអាជីវកម្មមិនសូវអំណោយផល*។ ការទទួលបាននូវកំណើនគួរឱ្យកត់សំគាល់នាទសវត្សកន្លងមក ភាគច្រើនឆ្លុះបញ្ចាំងពីការងើបឡើងវិញពីអតីតកាល ហើយពឹងផ្អែកទៅលើមូលដ្ឋានដែលតំរង់ទិសទៅទីប្រជុំជនដែលមានលក្ខណៈតូចចង្អៀត។ កំណើននៃផ្នែកកម្មន្តសាលមានស្ថេរភាពនៅក្នុងកំរិតជាមធ្យមស្មើនឹង ១៤,៧% ក្នុងមួយឆ្នាំនៅក្នុងអំឡុងឆ្នាំ ១៩៩៣-២០០១ ប៉ុន្តែភាគច្រើនផ្អែកលើឧស្សាហកម្មកាត់ដេរ។ សេចក្តីរំពឹងនាពេលអនាគតគឺមានភាពមិនប្រាកដប្រជាដោយសារការផុតកំណត់នៃកិច្ចព្រមព្រៀងវាយនភណ្ឌទ្វេភាគីរវាងសហរដ្ឋអាមេរិក និងកម្ពុជា នៅចុង ឆ្នាំ២០០៤ និងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសចិន។ កំណើននៅក្នុងវិស័យសេវាកម្មដែលរួមចំណែក ៣៦% ដល់ GDP មានកំរិតនៅឡើយ ហើយពឹងផ្អែកយ៉ាងខ្លាំងទៅលើផ្នែកទេសចរណ៍ (សូមអានតារាងទី១)។ ទំនុកចិត្តរបស់អ្នកវិនិយោគទុននៅមានកំរិត ហើយបរិយាកាសអាជីវកម្មជាទូទៅសហគ្រិន

គិតថាមានភាពមិនល្អ ដោយសារមានអំពើពុករលួយជាបញ្ហាចំបង[១]។ កសិកម្ម[២] ដែលជាវិស័យសំខាន់ជាងគេគិតទាំងសមាមាត្រនៃ GDP (៣៧% នៅឆ្នាំ២០០១) និងសមាមាត្រនៃកំលាំងពលកម្ម (៧៤%, អង្កេតកំលាំងពលកម្ម, ២០០២) មានការកើនឡើងប្រហែល ៣.៥% ប្រចាំឆ្នាំ ក្នុងអត្រាពិត ក្នុង អំឡុងឆ្នាំ ១៩៩៣-២០០១ ប៉ុន្តែបានជួបប្រទះនូវការប្រែប្រួលឡើងចុះយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ហើយរួមចំណែកតិចតួចក្នុងការបង្កើតការងារ។

*តារាង ១: ការរួមចំណែកតាមវិស័យចំពោះ GDP និងការងារ (ប្រភព: ក្រសួងពាណិជ្ជកម្ម)*

| វិស័យ | សមាមាត្រនៃ GDP / ២០០១ (%) | អត្រាកំណើន ១៩៩៣-២០០១ | សមាមាត្រនៃការងារ ២០០១ (%) | អត្រាកំណើនការងារ, ១៩៩៨-២០០០ | សន្ទស្សន៍ភាពក្រីក្រតាមប្រភពចំណូលសំខាន់ៗ (១៩៩៩ CSES) % |
|---|---|---|---|---|---|
| កសិកម្ម | 37 | 3.5% | 73.7 | 1.55 | 78.9 |
| ឧស្សាហកម្ម | 27 | 14.7% | 8.4 | 43.29 | 3.8 |
| សេវាកម្ម | 36 | 1.9% | 17.9 | 1.08 | 11 |

៣. *ការងារផ្លូវការក្រៅពីធ្វើស្រែមានកំរិតតិចតួច ជាពិសេសនៅតំបន់ជនបទ។* កំណើនការងារនៅក្នុងផ្នែកកម្មន្តសាលមានកំរិតខ្លាំង ប៉ុន្តែចាប់ផ្ដើមពីមូលដ្ឋានដ៏តូច។ កម្មករប្រហែល ២២០.០០០ (ស្ត្រីមានសមាមាត្រខ្ពស់) - ៨% នៃកំលាំងពលកម្ម - ឥឡូវកំពុងបំរើការងារនៅក្នុងឧស្សាហកម្មកាត់ដេរ។ ការបង្កើតការងារនៅក្នុងវិស័យសេវាកម្មក៏មានកំរិតតិចតួចដែរនៅក្នុងទសវត្សកន្លងមក។ ពេលអវត្តមាននៃកាលានុវត្តភាពផ្សេងៗទៀត ភាគច្រើននៃអ្នកដែលចូលក្នុងទីផ្សារពលកម្មនៅតែស្ថិតនៅក្នុងតំបន់ជនបទ ហើយត្រូវបានរាប់ថាជាផ្នែកមួយនៃកំលាំងពលកម្មកសិកម្ម ដោយមានកំរិតខ្ពស់នៃការងារមិនពេញលេញ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈប្រាក់បៀវត្សរ៍ជនបទទាប[៣]។ កំរិតទាបនៃជំនាញរារាំងបន្ថែមទៀតដល់កសិករជនបទវ័យក្មេងនូវលទ្ធភាពទទួលបានកាលានុវត្តភាពសេដ្ឋកិច្ចនានា។

---

[១] កម្ពុជា: ការច្បាមយកកាលានុវត្តភាពពិភពលោក - ការវាយតំលៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកំណែទំរង់, ធនាគារពិភពលោក, ២០០៤

[២] កសិកម្ម ឬវិស័យកសិកម្មគឺសំដៅទៅលើសកម្មភាពដាំដំណាំគ្រប់ប្រភេទ បសុសត្វ ព្រៃឈើ និងជលផល។

[៣] ៣៥០០-៤០០០ រៀលក្នុងមួយថ្ងៃសំរាប់បៀវត្សរ៍កសិកម្ម និង ៣៨០០-៤២០០ រៀលសំរាប់បៀវត្សរ៍មិនមែនកសិកម្ម (Helmers et al., 2003)។

៤. *អត្រាកំណើនប្រជាជនខ្ពស់ (២,៥% ក្នុងមួយឆ្នាំ) មានសំពាធយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចក្នុងការបង្កើតការងារ ហើយវិស័យកសិកម្មកំពុងតែស្រូបយកភាគច្រើននៃអ្នកចំណូលថ្មីក្នុងទីផ្សារការងារ។* តួលេខមួយក្នុងចំណោមតួលេខជាច្រើនដែលគួរឱ្យកត់សំគាល់ គឺសមាមាត្រខ្ពស់ (៥៥%) នៃប្រជាជនអាយុក្រោម ២០ឆ្នាំ។ កំណើនដ៏ច្រើននៃប្រជាជនក្មេង រួមទាំងចំនួនដ៏ច្រើន (១៥០ ០០០) នៃអតីតយោធិន គឺកំពុងចូលទៅក្នុងទីផ្សារការងារ ដោយមានកាលានុវត្តភាពតិចតួចក្នុងការរកបាននូវការងារដែលទទួលបានផលកំរៃ។ ប្រជាជនប្រហែលពី ២២០.០០០ ទៅ ២៥០.០០០ នាក់ចូលទៅក្នុងទីផ្សារការងារក្នុងមួយឆ្នាំៗ ភាគច្រើននៃពួកគេទាំងនោះរស់នៅតំបន់ជនបទ ទន្ទឹមនឹងនោះដែរមានចំនួនតិចតួចទេដែលចូលនិវត្តន៍។ បញ្ហាប្រឈមដ៏ធំមួយក្នុងចំណោមបញ្ហាប្រឈមដ៏ធំនានា គឺការផ្តល់នូវការងារប្រកបដោយផលិតភាពចំពោះកំលាំងពលកម្មដែលចេះតែកើនឡើងយ៉ាងឆាប់រហ័សនេះ។ កំណើនដ៏ឆាប់រហ័សនៅជនបទ នឹងដើរតួនាទីដ៏សំខាន់ក្នុងការបង្កើតការងារ បង្កើនចំណូលជនបទ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ទិន្នផល និងចំណូលកសិកម្មគួរតែកើនឡើងប្រកបដោយនិរន្តរភាព យ៉ាងហោចណាស់ក៏មានល្បឿនស្មើនឹងកំណើនកំលាំងពលកម្ម ដែលក្នុងអត្រាពិតគឺយ៉ាងហោចណាស់កើនឡើងពី ៥% ទៅ ៦% ក្នុងមួយឆ្នាំ ដើម្បីបន្តស្រូបយកអ្នកចំណូលថ្មីទាំងនោះនៅក្នុងទីផ្សារពលកម្ម។ អត្រាកំណើនខ្ពស់គួរតែទទួលបានដើម្បីបង្កើនផងដែរនូវប្រៀវត្សរ៍ពិត។ ប៉ុន្តែបន្ទុកនៃដំណោះស្រាយបញ្ហាការងារ មិនមែនឋិតនៅតែទៅលើវិស័យកសិកម្មតែមួយមុខប៉ុណ្ណោះទេ។ ការបន្តផ្តោតទៅលើការបង្កើតបរិស្ថានអំណោយផលសំរាប់កំណើនដ៏ឆាប់រហ័សនៃវិស័យឧស្សាហកម្ម និងសេវាកម្មក៏តំរូវឱ្យមានផងដែរ។

៥. *កំណើនភាគច្រើនផ្តល់ផលប្រយោជន៍ដល់តំបន់ទីប្រជុំជន និងមិនបាននាំមកនូវការកាត់បន្ថយភាពក្រីក្រដ៏ទូលំទូលាយនៅក្នុងតំបន់ជនបទដែលមានប្រជាជនភាគច្រើនរស់នៅ។* យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា (NPRS) ប៉ាន់ស្មានថា សន្ទស្សន៍នៃភាពក្រីក្របានថយចុះពី ៣៩% នៃប្រជាជនទាំងអស់ នៅឆ្នាំ ១៩៩៣-៩៤ មក ៣៦% នៅឆ្នាំ ១៩៩៧[៤]។ NPRS ក៏បានរកឃើញផងដែរ ជាមធ្យម អ្នកក្ររស់នៅជិតបន្ទាត់ភាពក្រីក្រ ហើយហេតុដូច្នេះគឺមានសក្តានុពលជាច្រើនសំរាប់ការកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនដោយមានសមធម៌។ ផ្ទុយមកវិញ និន្នាការអាចបញ្ច្រាសមកវិញ ហើយភាពក្រីក្រកាន់តែធ្ងន់ធ្ងរជាងមុនជាមួយនឹងកំណើនយឺត ឬជាមួយការបែងចែកនូវផលប្រយោជន៍កាន់តែមានកំរិត។ ការកាត់បន្ថយភាពក្រីក្រ និងភាពជឿនលឿនឆ្ពោះទៅសំរេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ - ទាំងនៅទីប្រជុំជន និងទីជនបទ -

[៤] ប៉ុន្តែ ជាមួយនឹងចំនួនប្រជាជនប៉ាន់ស្មាន ១០លាននាក់នៅឆ្នាំ ១៩៩៣-៩៤ និង ១១,៤លាននាក់នៅឆ្នាំ១៩៩៧ បើគិតជាតួលេខដាច់ខាត ចំនួនអ្នកក្រីក្រមានការកើនឡើងនៅក្នុងទសវត្សរ៍កន្លងមក ពី ៣,៩លាននាក់ ទៅ៤,១លាននាក់ (ឬកើន៥%ជាតួលេខដាច់ខាត)

បង្ហាញថា កំណើនសេដ្ឋកិច្ចកន្លងមកភាគច្រើនផ្តល់ផលប្រយោជន៍ដល់តំបន់ទីប្រជុំជន ដែលមានប្រជាជន ១៥% រស់នៅ ដោយមានផ្លែផ្កាពីកំណើនសេដ្ឋកិច្ចជ្រាបចុះមកក្រោមដល់សេដ្ឋកិច្ចជនបទតិចតួចប៉ុណ្ណោះ ហើយពុំមានការចង្អុលបង្ហាញពីភាពជឿនលឿនក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទឡើយ។ ផលិតផលក្នុងស្រុកសរុបសំរាប់មនុស្សម្នាក់នៅតំបន់ជនបទត្រូវបានប៉ាន់ស្មានថាមាន ១១៩ ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹង ២៨០ដុល្លារសំរាប់ប្រទេសទាំងមូល។ ដោយមាន ៩០% នៃប្រជាជនរស់នៅជនបទ និង ៧៩% នៃអ្នកក្រដែលពឹងផ្អែកទៅលើផ្នែកកសិកម្មដ៏ទូលំទូលាយសំរាប់ជីវភាពរស់នៅរបស់ពួកគាត់ ភាពជឿនលឿនក្នុងការសំរេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល នឹងមិនអាចសំរេចបានឡើយ ប្រសិនបើមិនដោះស្រាយ ដោយហ្មត់ចត់ និងដោយផ្ទាល់នូវបញ្ហាសំខាន់ៗមួយចំនួនដែលត្រូវបានជួបប្រទះដោយសេដ្ឋកិច្ចជនបទ។

## ជីវភាពរស់នៅ នៅតំបន់ជនបទ នៅមានកំរិតដោយសារការខ្វះនូវកាលានុវត្តភាព និងភាពងាយរងគ្រោះ[៥]

៦. *ការពឹងផ្អែកទៅលើកសិកម្មជីវព្រឹត្តិមានកំរិតខ្ពស់។* កម្ពុជានៅតែជាប្រទេសកសិកម្មនៅឡើយទេ ដោយមាន ៧០% នៃប្រជាជន និងភាគរយនៃអ្នកក្រីក្រច្រើន (៧៩%) ប្រកបមុខរបរកសិកម្ម ហើយការប្រើប្រាស់ជីវព្រឹត្តិស្រូបយក ៦០-៦៥% នៃទិន្នផលកសិកម្ម (FAO, ២០០៣)។ ជាមួយនឹងបន្ទាត់ភាពក្រីក្រដែលត្រូវបានកំណត់ដោយផ្អែកលើបរិមាណហូបចុកគិតជាកាឡូរី អសន្តិសុខស្បៀងនៅតែជាទិដ្ឋភាពមួយដ៏សំខាន់នៃភាពក្រីក្រនៅជនបទ។ នៅពេលដែលចំណីអាហារ និងអង្ករជាទូទៅមានការកើនឡើងនៅក្នុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ និងអតិរេកអង្ករបានកើតមានឡើង គ្រួសារនៅតំបន់ជនបទជាច្រើនពុំមានលទ្ធភាពគ្រប់គ្រាន់ឬគួរឱ្យទុកចិត្តបានក្នុងការទទួលបាននូវការផ្គត់ផ្គង់ស្បៀងអាហារ។ រហូតដល់ ២ភាគ៣ នៃ ១,៦លានគ្រួសារ ដែលរស់នៅជនបទ ជួបប្រទះនូវការខ្វះស្បៀងអាហារតាមរដូវក្នុងមួយឆ្នាំៗ ហើយ ៥០% នៃកុមារអាយុក្រោម ៥ឆ្នាំ មានទំងន់មិនគ្រប់ (NPRS)។ អង្ករតែមួយមុខមានពី ២៥% ទៅ ៣០% នៃការចំណាយសរុបរបស់គ្រួសារក្រីក្រ។ នេះបង្ហាញប្រាប់ថា ការបង្កើននូវផលិតភាពកសិកម្មសំដៅចំពោះកសិករជីវព្រឹត្តិ អាចមានផលប៉ះពាល់ដ៏ខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ (ជាពិសេសការហូបចុកគិតជាកាឡូរី) និងសំរួលដល់ការផ្លាស់ប្តូរពីកសិកម្មជីវព្រឹត្តិទៅជាសកម្មភាពកសិកម្មដែលតំរង់ទិសទៅរកលក្ខណៈពាណិជ្ជកម្ម។ ភាពខុសៗគ្នា

---

[៥] លទ្ធផលនៅក្នុងផ្នែកនេះត្រូវបានដកស្រង់ចេញពី " ប្រភពចំណូលនៅតំបន់ជនបទ " សិក្សាដោយ Helmers, Gibson, និង Wallgren (2003), លុះណាតែបញ្ជាក់ប្រាប់ខុសពីនេះ។

ខ្លាំងនៃតំបន់ភូមិសាស្ត្រ បង្ហាញប្រាប់ថា បញ្ហាការខ្វះខាត បញ្ហាការដឹកជញ្ជូន និងបញ្ហាកាលានុវត្តភាពរកចំណូលផ្សេងទៀតក៏កើតមានឡើងដែរ ។

៧. *ការធ្វើអាជីវកម្មលើធនធានធម្មជាតិ (ធនធានរួម) គឺជាយុទ្ធសាស្ត្ររមមួយដើម្បីបំពេញគ្នាជាមួយនឹងចំណូលពីការធ្វើស្រែពីដីធ្លីដែលកាន់កាប់បន្តិចបន្តួច។* នៅពេលដែលសេដ្ឋកិច្ចរបស់ប្រទេសជាតិមិនទាន់ត្រូវបានធ្វើពិពិធកម្មនៅឡើយ ទ្រព្យសម្បត្តិជាដីធ្លី និងធនធានធម្មជាតិនៅតែដើរតួនាទីដ៏សំខាន់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារនៅជនបទ។ ដូច្នេះការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងការកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ប្រជាជនជនបទ គឺពឹងផ្អែកយ៉ាងខ្លាំងទៅនឹងគំរូនៃភាពជាម្ចាស់កម្មសិទ្ធិ និងលទ្ធភាពទទួលបានដីធ្លី និងធនធានធម្មជាតិ។ ទោះបីជាមានភាពខុសគ្នាតាមតំបន់ក៏ដោយ ជាទូទៅការកាន់កាប់ដីធ្លីមានទំហំតូច គិតជាមធ្យម ១,៥ ហិកតាក្នុងមួយគ្រួសារ ដោយមានគ្រួសារប្រហែលពាក់កណ្តាលមានដីធ្វើស្រែតិចជាង 0,៧៥ ហិកតា (CSES, ១៩៩៩)។ ទំហំនៃការកាន់កាប់ដីជាមធ្យមមានការរួញថយចុះជាមួយនឹងកំណើនប្រជាជន ដែលបណ្តាលឱ្យមានការធ្វើចំណាកស្រុកពីជនបទមកទីក្រុង និងមកតំបន់ដែលមានប្រជាជនតិច ជាលក្ខណៈអចិន្ត្រៃយ៍ ឬតាមរដូវ ហើយពឹងផ្អែកយ៉ាងខ្លាំងទៅលើការងារក្រៅពីធ្វើស្រែនៅពេលដែលការងារនោះមាន។ គ្រួសារក្រីក្រជាងគេបំផុត គឺជាគ្រួសារដែលមានលទ្ធភាពតិចតួច ឬគ្មានសោះក្នុងការទទួលបាននូវដីធ្លីសំរាប់ធ្វើកសិកម្ម (តិចជាង ២ហិកតានៅក្នុងទីតាំងដែលមិនអំណោយផល) ហើយជាលទ្ធផល គឺពួកគាត់ពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានទ្រព្យសម្បត្តិរួម ដើម្បីបំពេញសេចក្តីត្រូវការជាលក្ខណៈជីវព្រឹត្តិរបស់ពួកគាត់។ គ្រួសារដែលក្រីក្រជាងគេជាទូទៅក៏ពុំមានការជួយឧបត្ថម្ភពីសាច់ញាតិរបស់ខ្លួនទេ ជាគ្រួសារក្មេងដែលមានកូនច្រើនពី ៥-១២នាក់ មានទ្រព្យសម្បត្តិតិចតួច (គ្មាន ឬសត្វពាហនៈសំរាប់ធ្វើស្រែមួយ សំភារៈឧបករណ៍សំរាប់ធ្វើស្រែតិចតួច) ជួបប្រទះនូវកង្វះស្បៀងអាហាររវាង ៣ទៅ៨ខែក្នុងមួយឆ្នាំ ជំពាក់បំណុលគេច្រើន ហើយជាទូទៅគឺពុំមានលទ្ធភាពសងបំណុលគេវិញ ឬខ្ចីគេបន្ថែមទៀតបាន (ADB, ២00១)។

***តារាង ២:*** **សមាមាត្រភាគរយមធ្យមនៃប្រភពផ្សេងៗគ្នានៃចំណូល ធៀបនឹងចំណូលគ្រួសារសរុបនៅជនបទតាមបញ្ចភាគ**

| ប្រភពចំណូល | ប្រភពចំណូលគ្រួសារនៅជនបទ តាមបញ្ចភាគនៃការចំណាយ, ភាគរយ | | | | | |
|---|---|---|---|---|---|---|
| | ក្រជាងគេបំផុត | បញ្ចភាគទី 2 | បញ្ចភាគទី 3 | បញ្ចភាគទី 4 | មានជាងគេបំផុត | សរុប |
| កសិកម្ម | **50%** | **54%** | **54%** | **55%** | 37% | 50% |

| | | | | | | |
|---|---|---|---|---|---|---|
| *ដែលក្នុងនោះ ស្រូវ* | **26%** | **29%** | **28%** | **31%** | 17% | 26% |
| *បសុសត្វ* | **19%** | **19%** | **18%** | 16% | 11% | 17% |
| ធនធានរួម | **21%** | **16%** | **15%** | 12% | 6% | 14% |
| បៀវត្សរ៏ | 9% | 9% | 11% | 10% | **23%** | 13% |
| មិនមែនធ្វើស្រែ | 8% | 12% | 10% | **14%** | **25%** | 14% |
| ការផ្ទេរប្រាក់មកឱ្យ ការផ្ញើប្រាក់មកឱ្យ ផ្សេងៗ | **12%** | 9% | **10%** | 9% | 9% | 9% |
| | | | | | | |
| ចំណូលគ្រួសារ គិតជាមធ្យម (១000រៀល/១ឆ្នាំ) | 2,553 | 3,057 | 3,351 | 3,875 | 5,616 | 3,689 |

ប្រភពCSES 1999 (ពិណប្រផេះគឺជាតួលេខធំជាងតួលេខមធ្យម)

៨. *ការងារក្រៅពីធ្វើស្រែមិនរៀបរយគឺជាប្រភពដ៏សំខាន់នៃចំណូលសំរាប់គ្រួសារនៅជនបទ។* គ្រួសារជនបទដោះស្រាយបាននឹងការខ្វះខាត នៃកាលានុវត្តភាពក្នុងការរកកំរៃដែលមានលក្ខណៈសេដ្ឋកិច្ចនិងពេញម៉ោងដោយធ្វើពិពិធកម្មនៃប្រភពចំណូល[៦] ។ ការសិក្សាដែលព្យាយាមគណនាជាបរិមាណនូវសារៈសំខាន់នៃប្រភពទាំងនោះបានរកឃើញថា ២៩% ទៅ ៥0% នៃចំណូល (សាច់ប្រាក់ និងជារបស់) គឺមកពីកសិកម្ម ១៤% ទៅ ២២% មកពីសកម្មភាពជលផលនិងព្រៃឈើ និង ៣៦% ទៅ ៥៧% មកពីអាជីវិកម្ម និងបៀវត្សនៃពលកម្ម។ ភាគច្រើននៃបៀវត្សរ៏ និងចំណូលអាជីវកម្ម គឺមកពីបៀវត្សរ៏នៃពលកម្មក្នុងផ្នែកកសិកម្មតាមរដូវ និងធម្មតា និងមិនមែនកសិកម្ម និងក្នុងសកម្មភាពមីក្រូអាជីវកម្មតាមរដូវ។ លទ្ធភាពទទួលបានការងារក្រៅពីធ្វើស្រែដែលមានលក្ខណៈស្ថេរភាព និងទទួលបានកំរៃ ជាធម្មតាអាចអនុវត្តបានតែចំពោះអ្នកដែលមានធនធានច្រើន

[៦] ការស្រាវជ្រាវអំពីប្រភពចំណូលនៅកម្ពុជាគឺ និយាយយ៉ាងល្អបំផុត មិនទាន់ពេញលេញ ដោយមានការសិក្សាទូទាំងប្រទេសតិចតួច និងពុំសូវលំអិត ទៅលើបញ្ហាយ៉ាងច្រើនដែលមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការកំណត់នូវគោលនយោបាយនឹងគំរោងនានាដើម្បីទ្រទ្រង់ ការអភិវឌ្ឍន៍ ជនបទ។ ការសិក្សាដែលមានលក្ខណៈទូលំទូលាយបំផុតនោះគឺការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ ១៩៩៩ ទោះបីជាមានគុណវិបត្តិខ្លះ ដែលពាក់ព័ន្ធបទពិសោធន៏ការងាររបស់មន្ត្រីធ្វើសំភាសន៍ និងទំហំសំណាកគំរូតូច (ទោះបីជាអង្កេតទូទាំងប្រទេសក៏ដោយ)។ មានការ ខ្វះចន្លោះជាពិសេសពាក់ព័ន្ធនឹងការស្រាវជ្រាវចំពោះប្រជាជននៅតំបន់ខ្ពង់រាបនិងមាត់សមុទ្រ ហើយជាទូទៅចំពោះតួនាទីរបស់ស្រូវ និងដំណាំផ្សេងៗទៀត ចំណូលមិនមែនបានមកពីការធ្វើស្រែ និងធនធានរួមចំពោះចំណូលរបស់គ្រួសារក្រីក្រនៅជនបទ។ ប៉ុន្តែជាទូទៅ មានភាពស៊ីសង្វាក់គ្នានៃលទ្ធផលដ៏ទូលំទូលាយនៅក្នុងការធ្វើអង្កេតជាច្រើនអំពីចំណូលនៅជនបទដែលបង្ហាញប្រាប់ថាលទ្ធផលស្រាវជ្រាវអាចជឿទុកចិត្តបាន ទោះបីជាមានវិសាលភាព និងភាពគ្របដណ្តប់តូចក៏ដោយ (Helmers et al., 2003)។

បំផុតប៉ុណ្ណោះ។ សមាជិកគ្រួសារជនបទ ដែលជួបប្រទះនឹងចំណូលកសិកម្មទាបនិងប្រែប្រួលតាមរដូវ កំពុងតែរកការងារធ្វើជាប្រចាំ ឬធ្វើសកម្មភាពផ្សេងៗដែលអាចបង្កើតនូវចំណូល ដែលភាគច្រើនមានលក្ខណៈបណ្តោះអាសន្ន និងទទួលបានផលតិចតួច។

៩. *ដូច្នេះ ការច្របាច់បញ្ចូលគ្នាជាទូទៅនៃសកម្មភាពដែលផ្តល់ផលដែលរួមចំណែកដល់ចំណូលគ្រួសារជនបទគឺមានភាពខុសៗគ្នានៅគ្រប់គ្រួសារ និងតំបន់*។ តំបន់កសិ-អេកូឡូហ្ស៊ី និងលទ្ធភាពចូលដល់ និងក្បែរទីផ្សារគឺមានទំនាក់ទំនងទៅវិញទៅមកជាមួយប្រភពចំណូលនៃគ្រួសារជនបទ។ ភាពនៅក្បែរ និងលទ្ធភាពទទួលបាននូវធនធានព្រៃឈើនិងជលផល កំណត់នូវការរួមចំណែកដល់ជីវភាពរស់នៅនៅជនបទ។ ការស្រាវជ្រាវបាន រកឃើញនូវទំនាក់ទំនងយ៉ាងខ្លាំងនិងវិជ្ជមានរវាងភាពនៅក្បែរផ្លូវ និងសារៈសំខាន់នៃសកម្មភាពសេដ្ឋកិច្ចក្រៅពីធ្វើស្រែចំការ។ កាលានុវត្តភាពសំរាប់ការងារ ក្រៅពីធ្វើស្រែចំការ គឺល្អប្រសើរនៅភាគខាងត្បូង និងអាគ្នេយ៍ ដែលនៅទីនោះបណ្តាញផ្លូវថ្នល់បានទទួលការអភិវឌ្ឍន៍។ ទាំងសំរាប់ចូលដល់ទីផ្សារដើម្បីលក់ទំនិញ និងសេវាកម្មផលិតក្នុងស្រុក និងសំរាប់លទ្ធភាពទទួលបានការងារដែលមានប្រៀវត្សរ៍មានផ្លូវថ្នល់ និងក្នុងកំរិត តិចតួចមួយអាចដឹកជញ្ជូនទឹក គឺក៏ជាកត្តាមួយសំខាន់ក្នុងការកំណត់នូវកំរិតចំណូលផងដែរ។ ស្ត្រី ដែលជាអ្នកចូលរួមចំណែកភាគច្រើនក្នុងកំលាំងពលកម្មកសិកម្ម (៥៤%) ចូលរួមតិចតួចក្នុងសកម្មភាពរកចំណូល ក្រៅពីធ្វើស្រែចំការ ទោះបីជាមានភាគច្រើនប្រកបរបរអាជីវកម្មតូចតាចក្តី។ ជនជាតិភាគតិច ដែលប្រមូលផ្តុំគ្នារស់នៅក្នុងតំបន់ដាច់ឆ្ងាយពីគេ និងមានដង់ស៊ីតេទាបនៃតំបន់ភាគឦសានពឹងផ្អែកយ៉ាងច្រើនទៅលើកសិកម្ម និងធនធានធម្មជាតិសំរាប់ជីវភាពរស់នៅរបស់ពួកគេ។

១០. *ការកើតឡើងនូវភាពចលាចល និងវិបត្តិគឺជាធម្មតាមាននៅគ្រប់កន្លែង* ដោយមាន ៩០% នៃគ្រួសារជាមធ្យមជួបប្រទះ នូវវិបត្តិដែលបណ្តាលឱ្យបាត់បង់នូវចំណូលនៅក្នុងរយៈពេលមួយឆ្នាំ។ ការបាត់ចំណូលគឺមានទំហំធំ - ជិត ៣០%នៃចំណូលគ្រួសារជនបទសរុបបានបាត់បង់រៀងរាល់ឆ្នាំដោយសារភាពចលាចល និង វិបត្តិគ្រួសារ ( Helmers et al, 2003)។ ការខូចខាតដំណាំ (ភាគច្រើនបណ្តាលមកពីទឹកជំនន់ និង/ឬ សត្វល្អិតបំផ្លាញ) ការឈឺនៃសមាជិកគ្រួសារ និងអត្រាស្លាប់ខ្ពស់នៃបសុសត្វ គឺជាមូលហេតុដ៏ចំបងនៃការបាត់បង់ដ៏ខ្លាំងនេះ។ ជាលទ្ធផលនៃវិបត្តិតតយប់ឈរ ការជំពាក់បំណុលនៃគ្រួសារជនបទមានកំរិតខ្ពស់[៧] ដែលរួមចំណែកឱ្យមានការលក់ដីធ្លីដើម្បីដោះស្រាយទុក្ខលំបាក និងការកើនឡើងនូវភាពគ្មានដីធ្លី។ ការសិក្សាពិភាព

---

[៧] ការស្រាវជ្រាវក៏បានបង្ហាញផងដែរថាលក្ខខណ្ឌឥណទានមានលក្ខណៈអាក្រក់សំរាប់អ្នកក្រ ដែលធ្វើឱ្យពួកគាត់ពឹងផ្អែកយ៉ាងខ្លាំងទៅលើអ្នករកស៊ីចងការប្រាក់ក្រៅប្រព័ន្ធដែលយកអត្រាការប្រាក់ខ្ពស់។

គ្មានដីធ្លីបង្ហាញថា ១៣-១៧% នៃគ្រួសារជនបទនៅកម្ពុជាមិនមានដីធ្លីទេ ទោះបីជាតួលេខនេះប្រែប្រួលយ៉ាងខ្លាំងរវាងខេត្ត ស្រុក និងឃុំ។ ស្ត្រីជាមេគ្រួសារទទួលរងខ្លាំងនូវការពុំមានដីធ្លី។

១១. *ដូច្នេះ លទ្ធផលទាំងនោះបង្ហាញប្រាប់ថា យុទ្ធសាស្ត្រដើម្បីកែលំអជីវភាពរស់នៅតំបន់ជនបទត្រូវទាមទារឱ្យមានកញ្ចប់នៃសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងស្មុគស្មាញ ដោយទទួលស្គាល់នូវការពឹងផ្អែករបស់គ្រួសារជនបទទៅលើពហុសកម្មភាព* និងសេចក្តីត្រូវការដើម្បីឆ្លើយតបដែលត្រូវបានតំរឹមឱ្យស្របទៅនឹងពហុភាពនៃស្ថានភាពនៅមូលដ្ឋាន និងគ្រួសារជនបទ។ សេចក្តីសង្ឃឹមទៅអនាគតសំរាប់ការប្រើប្រាស់ប្រកបដោយនិរន្តភាពនូវដីធ្លី និងធនធានធម្មជាតិ ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅជនបទនឹងត្រូវបានកែប្រែដោយកត្តាសំខាន់បីៈ (១) ក្របខ័ណ្ឌគោលនយោបាយនិងបទប្បញ្ញត្តិដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបាន និងការគ្រប់គ្រងនូវធនធានសំខាន់ៗដូចជា ដីធ្លី ព្រៃឈើ ជលផល និងទឹក (២) (២) យុទ្ធសាស្ត្រលូនមួយសំរាប់ការអភិវឌ្ឍន៏កសិកម្ម និងជនបទ និង (៣) កាលានុវត្តភាពសំរាប់ការងារក្រៅពីធ្វើស្រែជាពិសេសនៅតំបន់ជនបទ។ នៅពេលដែលផ្តោតការយកចិត្តទុកដាក់ទៅលើមធ្យោបាយដើម្បីបង្កើនកាលានុវត្តភាពសេដ្ឋកិច្ចនៅតំបន់ជនបទ ឬមួយចំពោះកសិកម្ម ឬមួយមិនចំពោះកសិកម្ម ជម្រើសគួរតែត្រូវបាននាំមុខ ដោយសេចក្តីត្រូវការដើម្បីកាត់បន្ថយភាពងាយរងគ្រោះ នៃគ្រួសារជនបទចំពោះវិបត្តិចំណូលរួមមាន តាមរយៈសំណាញ់សុវត្ថិភាព។ ដោយមានការចូលរួមយ៉ាងច្រើននៅក្នុងសេដ្ឋកិច្ចជនបទ និងភាពងាយរងគ្រោះ និងកង្វះលទ្ធភាពទទួលបានកាលានុវត្តភាព គោលនយោបាយ និងកម្មវិធីសំរាប់ការអភិវឌ្ឍន៏តំបន់ជនបទគួរធានាថា តំរូវការចាំបាច់ជាក់លាក់របស់ស្ត្រីត្រូវបានដោះស្រាយ (សូមអានប្រអប់ ១)។

*ប្រអប់១: លទ្ធផលសង្ខេប និងអនុសាសន៏ដកស្រង់ពី ការសិក្សាវាយតំលៃស្ថានភាពយេនឌ័រ នៅកម្ពុជា*

*បញ្ហាគន្លឹះ:* ស្ត្រីជួបប្រទះនូវឧបសគ្គជាច្រើនដោយសារមានលទ្ធភាពពុំស្មើគ្នាក្នុងការទទួលបាននូវធនធានធម្មជាតិ និងសេវា។ ស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងផលិតកម្មកសិកម្ម និងមានតួនាទីសំខាន់ជាសក្តានុពលក្នុងការកាត់បន្ថយអសន្តិ-សុខស្បៀង។ ស្ត្រីគឺជាក្រុមភាគតិចក្នុងចំណោមអ្នកទទួលផលនៃជីវភាពរស់នៅប្រកបកសិកម្មនិងជនបទដែលទាក់ទងនឹងសេវាកម្ម និងទ្រព្យសកម្ម។ អត្រាអនក្ខរភាពខ្ពស់និងខ្ចីមសារ និងទីតាំងនៃការពង្រីកសេវា គឺជាឧបសគ្គចំបង២យ៉ាងក្នុងការកែលំអលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាផ្សព្វផ្សាយកសិកម្ម។ ទោះបីជាមានច្បាប់ដីធ្លីដែលឆ្លើយតបបញ្ហាយេនឌ័រ ស្ត្រីក៏នៅតែមានភាពងាយរងគ្រោះចំពោះការមិនអើពើនូវសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគាត់។ ការដឹកជញ្ជូននិងផ្លូវជនបទ ក៏ដូចជាការផ្គត់ផ្គង់ទឹក និងការផ្តល់សេវាហិរញ្ញវត្ថុ គឺជាអាទិភាពសំរាប់ស្ត្រី។ ស្ត្រីមានតំណាងតិចនៅក្នុងការធ្វើសេចក្តីសំរេចចិត្តលើផ្នែកកសិកម្ម និងនៅក្នុងសេវាស៊ីវិល។ ប៉ុន្តែ កម្មវិធីដែលទ្រទ្រង់ដោយអ្នកផ្តល់ជំនួយ និង

របស់រដ្ឋាភិបាលមានការឆ្លើយតបកាន់តែខ្លាំងចំពោះការព្រួយបារម្ភទាំងនោះ។ ផ្នែកអភិវឌ្ឍវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទនៅក្នុង NPRS រួមមាន ចំណុចដៅនិងសូចនាករ ជាក់លាក់អំពីយេនឌ័រ។

*អនុសាសន៍:* (១) ជំរុញវិមជ្ឈការកំណើន និងពង្រីកកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតកាលានុវត្តភាពការងារ នៅតំបន់ជនបទ ដើម្បីកំរិតនូវផលប៉ះពាល់សង្គមជាអវិជ្ជមាននៃការធ្វើចំណាកស្រុកមកកាន់តំបន់ទីប្រជុំជនរបស់ស្ត្រីក្មេងៗ (២) គាំទ្រការអភិវឌ្ឍន៍សហគ្រាសធុនតូច ដែលអាចធ្វើបានក្នុងរយៈពេលខ្លីដើម្បីផ្ដល់ការងារដល់ស្ត្រី (៣) បង្កើតយុទ្ធសាស្ត្រសំរាប់លើកកំពស់អក្ខរភាព និងកំរិតជំនាញរបស់ស្ត្រី (៤) ដោះស្រាយសេចក្ដីត្រូវការបង្ការសង្គមកិច្ចចំពោះកម្មករចំណាកស្រុកជាស្ត្រី (៥) អភិវឌ្ឍការផ្ទេរប្រឌិតថ្មីដើម្បីផ្ដល់ពត៌មានកសិកម្ម និងសេវាផ្សព្វផ្សាយកសិកម្មដល់ស្ត្រី (៦) ធានាកែលំអ និងរក្សាឱ្យបាននូវលទ្ធភាពទទួលបានដីធ្លី និងធនធានធម្មជាតិសំរាប់ស្ត្រី (៧) បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទដែលបានរៀបចំនៅមូលដ្ឋាន ដើម្បីឱ្យសេចក្ដីត្រូវការរបស់បុរសនិងស្ត្រីត្រូវបានទទួលស្គាល់និងដោះស្រាយ (៨) ធ្វើឱ្យសេវាសុខភាពអាចមានលទ្ធភាពទិញបានដោយស្ត្រីក្រីក្រ និង (៩) បង្កើនការចូលរួមរបស់ស្ត្រីនៅកំរិតថ្នាក់ភូមិ។

## *ការគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិកំពុងមានការប្រែប្រួលយ៉ាងខ្លាំង*

១២. *ប្រជាសាស្ត្រនិងលក្ខណៈសម្បត្តិធនធានធម្មជាតិបង្កើតនូវការប្រឈមជាក់លាក់ចំពោះតំបន់ផ្សេងៗគ្នា។* កម្ពុជាបានទទួលអំណោយផលពីធម្មជាតិយ៉ាងច្រើន គឺដី ក៏ដូចជាធនធានធម្មជាតិដ៏ច្រើនសន្ធឹកសន្ធាប់ ជាពិសេស ព្រៃឈើ និងជលផល និងប្រភេទផ្សេងៗគ្នាជាច្រើននៃជំរកធម្មជាតិនិងប្រព័ន្ធអេកូឡូហ្ស៊ី រួមមានព្រៃតំបន់ខ្ពង់រាប និងទំនាប តំបន់ដីសើមទឹកសាប និងតំបន់ដែលមានផ្លូវទឹកហូរកាត់ជាច្រើន។ ប៉ុន្តែ ៧០% នៃប្រជាជន គឺរស់នៅប្រមូលផ្ដុំលើ ៣០% នៃផ្ទៃដីនៅតាមរបៀងទំនាបពីព្រំដែនថៃនៅភាគពាយ័ព្យ រហូតដល់ព្រំដែនវៀតណាមនៅភាគអាគ្នេយ៍។ ផ្ទៃដីភាគច្រើនត្រូវបានប្រើប្រាស់សំរាប់ដំណាំស្រូវ និងធ្វើនេសាទនៅតំបន់ទំនាបលិចទឹក និងតំបន់មានផ្លូវទឹកហូរកាត់ ដោយមានសម្ពាធប្រជាជនកាន់តែកំពុងគំរាមកំហែងដល់ប្រព័ន្ធអេកូឡូហ្ស៊ីបឹងទន្លេសាប (ព្រៃលិចទឹក និងបឹងនេសាទ)។ ផ្ទុយទៅវិញ ព្រៃក្រាស់ និងដង់ស៊ីតេប្រជាជនទាបបង្ហាញអំពីតំបន់ភាគខាងជើង ឰសាន និងនិរតី នៃប្រទេស (សូមអានផែនទី ឧបសម្ព័ន្ធទី១)។ តំបន់ចន្លោះ រវាងទំនាបនិងខ្ពង់រាប កំពុងជួបប្រទះការកើនឡើងនៃចំណូលស្រុក និងការទន្ទ្រានយករបស់កសិករនូវតំបន់ព្រៃដុះ។ យុទ្ធសាស្ត្រនិងគោលនយោបាយសំរាប់ការគ្រប់គ្រងធនធានព្រៃឈើចាំបាច់ត្រូវតែទទួលស្គាល់នូវភាពខុសគ្នាទាំងនេះ និងផ្ដល់ការឆ្លើយតបដែលត្រូវបានតំរឹមឱ្យស្របតាម ស្ថានភាពតំបន់និងមូលដ្ឋាន - ភាពខុសគ្នានៃដង់ស៊ីតេប្រជាជន និងភាពខុសគ្នានៃកសិ-ប្រព័ន្ធអេកូឡូហ្ស៊ី។

១៣. ការសិក្សាលើកមុនដែលបានធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក បានវាយតំលៃនូវសារៈសំខាន់នៃកសិ-ប្រព័ន្ធអេកូឡូហ្ស៊ីខុសៗគ្នា ដូចដែលបានបង្ហាញនៅក្នុងប្រអប់ទី២ខាងក្រោម។ វិធីប្រៀបធៀបគ្នាដ៏លឿន នៃការធ្វើចំណាត់ថ្នាក់នេះដោយមានប្រើផែនទីប្រើប្រាស់ដី និងផែនទីនៃភាពក្រីក្រ (សូមអានផែនទី ក្នុងឧបសម្ព័នទី ១) បង្ហាញថាសន្ទស្សន៍នៃភាពក្រីក្រមានកំរិតខ្ពស់នៅតំបន់ទំនាបដែលមានភ្លៀងធ្លាក់និងដែលហិនហោចព្រៃឈើ ដែលនៅទីនោះមានប្រជាជនភាគច្រើនរស់នៅផ្តុំគ្នា។ ប៉ុន្តែ ផែនទីនៃភាពជឿនលឿនរបស់ UNDP ឆ្ពោះទៅសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (សូមអានឧបសម្ព័ន្ធ ១) បង្ហាញពីស្ថានភាពផ្សេងទៅវិញ ដោយមានការបែងចែកយ៉ាងច្បាស់រវាងបណ្តាខេត្តភាគខាងជើង ដែលអាចមានការយឺតយ៉ាវក្នុងការសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ភាគច្រើន និងតំបន់ដ៏ទៃទៀតនៃប្រទេសដែលភាពជឿនលឿនច្រើនកំពុងត្រូវបានធ្វើឡើង អាចសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ខ្លះឬទាំងអស់។ ទោះបីជាគុណភាពនៃទិន្នន័យដែលយកមកប្រើដើម្បីធ្វើផែនទីអាចត្រូវបានប្រឈមនឹងការវាយតំលៃក៏ដោយ ក៏ផែនទីទាំងនោះគាំទ្រនូវគំនិតនៃអាទិភាព និងអត្ថប្រយោជន៍ធៀបខុសៗគ្នាតាមតំបន់ផងដែរ។

**ប្រអប់ ២: លទ្ធផលនៃការវិភាគតំបន់សេដ្ឋកិច្ចស្បៀង របស់កម្មវិធីស្បៀងអាហារពិភពលោក**

**តំបន់ទំនាបមានភ្លៀងធ្លាក់:** ៤៥ ស្រុក ប្រជាជន ២,៩ លាននាក់

ប្រជាជនភាគច្រើនពឹងផ្អែកទៅលើតែការដាំស្រូវមួយមុខនៅរដូវវស្សាដោយពុំមានប្រព័ន្ធធារាសាស្ត្រ ដែលជាប្រភពចំណូលនិងស្បៀងអាហារដ៏សំខាន់ ការកាន់កាប់ដីធ្លីទំហំតូចដោយឯករាជ្យ ចំណូលត្រូវបានបំពេញបន្ថែមដោយសកម្មភាពតាមរដូវផ្សេងៗ។ ផ្ទៃដីមានលក្ខណៈរាបស្មើ និងប្រើប្រាស់យ៉ាងខ្លាំងក្នុងការដាំដុះ។

**តំបន់ដែលមានផ្លូវទឹកហូរកាត់:** ២៨ ស្រុក ប្រជាជន ១,៧ លាននាក់

ប្រជាជនភាគច្រើនពឹងផ្អែកលើការដាំដំណាំសំរាប់ធ្វើពាណិជ្ជកម្ម ដាំស្រូវឡើងទឹក ឬស្រូវប្រាំង ហើយនេសាទត្រី សំរាប់សន្តិសុខស្បៀងនិងចំណូល។ តាំងទីលំនៅជាប់នឹងទន្លេសំខាន់ៗ ឬក៏នៅក្នុងឃុំជាប់នឹងបឹងទន្លេសាប។

**តំបន់ទីប្រជុំជន/ទីផ្សារ:** ១៧ ស្រុក ប្រជាជនប៉ាន់ស្មាន ១,៣ លាននាក់

ពឹងផ្អែកទៅលើការងារដែលបានចំណូលជាប្រាក់ និងធ្វើអាជីវកម្មតូចនៅមជ្ឈមណ្ឌលទីប្រជុំជនរបស់រដ្ឋាភិបាល។

តំបន់ព្រៃរបស់/ពលកម្មជាប់កិច្ចសន្យា: ២៤ ស្រុក ប្រជាជន ១,២ លាននាក់រស់នៅតំបន់ទាំងនោះ

ប្រជាជនពឹងផ្អែកភាគច្រើនទៅលើធនធានព្រៃឈើដែលចេះតែរិចរិលទៅ និងពលកម្មដែលទទួលបានបៀវត្សរ៍សំរាប់ចំណូល។ ការដាំស្រូវដែលមានកំរិតតិចតួច មិនគ្រប់គ្រាន់ដើម្បីបំពេញតំរូវការប្រចាំឆ្នាំបានឡើយ។ គ្រួសារដែលពុំមានដី

ធ្លីជាធម្មតាតែងតែឃើញនៅតំបន់ទាំងនោះ ។ ពួកគេទាំងនោះងាយទទួលរងគ្រោះចំពោះការថយចុះនៃធនធានព្រៃឈើ ដោយការធ្វើអាជីវកម្ម និងនៅដាច់ឆ្ងាយពីទីផ្សារ និងផ្លូវសំខាន់ៗ ។

**ព្រៃឈើ:** ៣៧ ស្រុក ប្រជាជន ៤៥០.០០០ នាក់
ពឹងផ្អែកភាគច្រើនទៅលើផលិតផលព្រៃឈើ សំរាប់ស្បៀងអាហារ និងចំណូល ។ ពួកគេមានភាពងាយទទួលរងគ្រោះក្នុងការចូលទៅដល់តំបន់ដែលមានព្រៃឈើ ។ មានដង់ស៊ីតេប្រជាជនទាប តិចជាង ៨នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ។

**តំបន់ចំរុះ:** ព្រៃឈើ/ស្រែ (៤ ស្រុក ប្រជាជន ២២៩.០០០ នាក់), ព្រៃឈើ/ផ្លូវទឹកហូរកាត់ (៣ ស្រុក ប្រជាជន ១២២.០០០ នាក់), ព្រៃឈើ/ព្រៃរបស់ (៩ ស្រុក ប្រជាជន ២៣០.៩០០ នាក់), ស្រែ/ព្រៃរបស់/ព្រៃឈើ (៣ ស្រុក ប្រជាជនចំនួន ១០៤.៥០០ នាក់), មិនច្បាស់/ច្រើនប្រភេទ (៧ ស្រុក ប្រជាជន ៥៦៥.០០០ នាក់)

១៤. *ការផ្លាស់ប្តូរថ្មីៗនៃគោលនយោបាយគ្រប់គ្រងធនធានធម្មជាតិបានទុកចោលនូវតំបន់ដ៏ធំធេងនៃប្រទេស (៣០% ទៅ ៤០%នៃតំបន់ទាំងមូល) ដោយពុំមានវិធានការគ្រប់គ្រងច្បាស់លាស់ ។* បន្ទាប់ពីការលុបចោលនូវព្រៃសម្បទានដែលមិនបានធ្វើអាជីវកម្ម ប្រហែល ១,៦ លានហិកតា ឬតំបន់ព្រៃឈើបានប្រែក្លាយទៅជា "ព្រៃបំរុងទុក" ដែលវិធានការគ្រប់គ្រងនៅតែត្រូវបានកំណត់ ។ ការលុបចោលនូវព្រៃសម្បទានដែលមិនបានធ្វើអាជីវកម្ម ប្រមាណ ១៨៦ លានហិកតា ក៏កំពុងត្រូវបានពិចារណាផងដែរ ។ ផ្ទៃដីទំហំ ១,៧៣ លានហិកតាបន្ថែមទៀត ហាក់បីដូចជាដីដែលមានព្រៃរបស់ មានកំណើនមិនគ្រប់គ្រាន់ ដីពុំមានឈើធំៗ និងតំបន់មិនប្រើប្រាស់ដូចគ្នាដែលមិនទាន់ប្រកាសថាជាកម្មសិទ្ធជាក់លាក់ណាមួយ មានការគ្រប់គ្រង ឬប្រើប្រាស់នៅឡើយ ។ ការលុបបំបាត់បន្ថែមទៀតនៃសម្បទានសេដ្ឋកិច្ចខាងលើ ទំហំដែលបានអនុញ្ញាតិតាមច្បាប់ភូមិបាលថ្មី នឹងបន្តបង្កើននូវដីបំរុងដែលមានសំរាប់ការអភិវឌ្ឍន៍កសិកម្ម ។ ប៉ុន្តែ ការប្រើប្រាស់ជាក់ស្តែងនៃតំបន់ទាំងនេះ និងសក្តានុពលសំរាប់ការអភិវឌ្ឍន៍តាមប្រព័ន្ធកសិកម្ម ឬប្រព័ន្ធកសិ-ឧស្សាហកម្ម នៅមិនទាន់បានវាយតំលៃ នៅឡើយទេ (សូមអាន ផ្នែកទី II) ។ នៅក្នុងវិស័យជលផល ទំហំពាក់កណ្តាលកាលពីមុនដែល ស្ថិតនៅក្រោមទំរង់ បែបបទសម្បទាន (ប្រហែល ៥០០,០០០ ហិកតា) ត្រូវបានលុបចោលនៅឆ្នាំ ២០០១ ប៉ុន្តែ ការគ្រប់គ្រងរួម ដែលពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋានត្រូវតែអភិវឌ្ឍន៍បន្ថែមទៀត ។ នៅក្នុងរយៈពេលខ្លី ការគ្រប់គ្រងប្រកបដោយចិរភាព និងតម្លាភាពត្រូវតែរៀបចំឡើង ដើម្បីជៀសវាងការប្រើប្រាស់មិនចំទិស និងការធ្វើអាជីវកម្មហួសក៏រិតនៃធនធានទាំងនេះ ។

*តារាង ៣: កម្ពុជា - ការប៉ាន់ស្មាននៃសិទ្ធិកាន់កាប់/ប្រើប្រាស់ដីធ្លី , ២០០៤*

| **ប្រភេទ** | **ផ្ទៃដី (លានហិកតា)** | **សមាមាត្រ %** |
|---|---|---|
| ព្រៃមិនមែនសម្បទាន | 4.7 | 26.1 |
| តំបន់/ព្រៃឈើ ការពារ | 3.3 | 18.3 |
| តំបន់ដាំដុះ | 2.7 | 15.0 |
| ព្រៃសម្បទាន | 3.1 | 17.2 |
| ដីព្រៃរបស់ ដីពុំមានឈើធំៗ ។ល។ | 1.7 | 9.4 |
| ទីក្រុងតូច ហេដ្ឋារចនាសម្ព័ន្ធ ។ល។ | 1.1 | 6.1 |
| សម្បទានឡូត៍នេសាទ | 0.5 | 2.8 |
| សម្បទានកសិកម្ម | 0.8 | 4.4 |
| តំបន់ដីដែលមានគ្រាប់មីន | 0.1 | 0.6 |
| សរុប | 18.0 | 100.00 |

*ប្រភព:សិទ្ធិកាន់កាប់ដីនៅកម្ពុជា - ទិន្នន័យកែសំរួលថ្មី, CDRI,2001, IFSR 2004, MAFF 2004*

## ***ការអនុវត្តន៍ការងារវិស័យកសិកម្មមានការខកចិត្ត***

១៥. *នៅពេលដែលការរួមចំណែករបស់វិស័យកសិកម្មចំពោះសេដ្ឋកិច្ចមានកំរិតខ្ពស់ផ្អែកលើស្តង់ដារតំបន់ ភាពទន់ខ្សោយនៃការអនុវត្តន៍ការងារកសិកម្ម និងសក្តានុពលកំណើនគឺមានភាពមិនច្បាស់លាស់។* ការរួមចំណែកដ៏ធំនៃវិស័យកសិកម្មចំពោះ GDP (៣៧% នៅឆ្នាំ ២០០១)[៨] ហើយសារៈសំខាន់របស់វាដែលជាប្រភពចំណូល និងជីវភាពរស់នៅ គឺជាលទ្ធផលនៃលក្ខណៈអពិពិធកម្មនៃសេដ្ឋកិច្ច ជាជាងលទ្ធផលនៃកំណើនដ៏ខ្លាំងនៅក្នុងវិស័យកសិកម្ម។ កំណើនវិស័យកសិកម្មនៅកម្ពុជាគឺមានកំរិតទាបជាងគេបំផុតនៅក្នុងតំបន់នៅក្នុងទសវត្សឆ្នាំ៩0 (សូមមើល រូបភាព ១) ទោះបីជាការអនុវត្តន៍មានលក្ខណៈប្រសើរនៅប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ។ ភាពរឹករវរផ្នែកនយោបាយ វិបត្តិហិរញ្ញវត្ថុក្នុងតំបន់ក្នុងឆ្នាំ ១៩៩៨ និងទឹកជំនន់ដ៏ធ្ងន់ធ្ងរក្នុងឆ្នាំ២០00 ទាំងអស់នេះ បានរួមចំណែកធ្វើឱ្យកំណើនធ្លាក់ចុះ។ លក្ខណៈសំគាល់មួយទៀតនៃកំណើនពីការអនុវត្តន៍វិស័យកសិកម្មគឺមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ដែលឆ្លុះបញ្ចាំងពីភាពងាយរងគ្រោះចំពោះ

[៨] តួលេខនេះខ្ពស់នៅក្នុងតំបន់ ហើយប្រៀបធៀបជាមួយ ឡាវ ៥១%នៃ GDP វៀតណាម ២៣% ចិន ១៦% ឥណ្ឌូណេស៊ី ១៧% ហ្វីលីពីន ១៥% ថៃឡង់ដ៍ ៨.៥% និងម៉ាឡេស៊ី ៨.១% ក្នុងឆ្នាំ២០០១។

លក្ខខណ្ឌអាកាសធាតុ និងបង្ហាញប្រាប់ពីការធ្វើវិនិយោគមិនគ្រប់គ្រាន់នៅក្នុងវិស័យនេះ និងការធ្វើអាជីវកម្មហួសហេតុនៃធនធានធម្មជាតិ ។

រូបភាព ១:អត្រាកំណើនពិតជាមធ្យមនៃវិស័យកសិកម្ម (តំលៃគោល ឆ្នាំ១៩៩៥, ប្រភព: FAO




១៦. *កំណើននៃផ្នែកកសិកម្មត្រូវបាននាំមុខដោយ ផលិតកម្មដំណាំ និងជលផល ។* នៅក្នុងវិស័យកសិកម្ម ផលិតកម្មដំណាំ ជាពិសេសផលិតកម្មដំណាំស្រូវ មានកំណើនលឿនជាងកំណើនប្រជាជន នៅក្នុងកំរិត ៤,៨% ក្នុងមួយឆ្នាំ រវាងឆ្នាំ ១៩៩៣ និងឆ្នាំ ២០០១ (ថ្លៃថេរ ឆ្នាំ ២០០០) ។ ការវាយតំលៃកំណើនក្នុងផ្នែកជលផល គឺមានការលំបាក ពីព្រោះការខ្វះខាតនូវទិន្នន័យដែលគួរឱ្យទុកចិត្តបាន ប៉ុន្តែប្រភពនានាឯកភាពធ្វើការប៉ាន់ស្មានថា ការរួមចំណែកនៃផ្នែកជលផលចំពោះកំណើនវិស័យកសិកម្មទាំងមូល គឺដូចគ្នាទៅនឹងការរួមចំណែកនៃផ្នែកដំណាំស្រូវ ។ តំលៃទិន្នផលជលផលត្រូវបានប៉ាន់ស្មានថាកើនឡើង ៦%ក្នុងមួយឆ្នាំក្នុងអំឡុង ១៩៩៣-២០០១[៩] ។ ទោះបីជាមានសារសំខាន់នៅក្នុងប្រព័ន្ធ[១០]នៃការធ្វើស្រែចំការនៅកម្ពុជាក៏ដោយ ក៏តំលៃនៃទិន្នផលបសុសត្វបានកើនឡើងទាបជាងយ៉ាងខ្លាំងក្នុងកំរិត ២,៤% ក្នុងមួយឆ្នាំ ដោយមានការប្រែប្រួលខ្លាំងនៅក្នុងឆ្នាំ ដោយសារភាពងាយរងគ្រោះទៅនឹងជំងឺ និងទឹកជំនន់ ។ នៅក្នុងអំឡុងឆ្នាំ ១៩៩៣-២០០១ ផលដំណាំរួមចំណែកជាមធ្យម ១៩% នៃកំណើន GDP សរុប ឯជលផល ១២% បសុសត្វ ៤% និងព្រៃឈើថយចុះ ៦%

[៩] ទិន្នន័យចុងក្រោយបំផុតនេះ គួរតែត្រូវបានពិចារណាដោយមានការប្រុងប្រយ័ត្ន ដោយសារតែមានការបញ្ចូលទិន្នន័យនេសាទត្រីខ្នាតតូចតែនៅចុងទសវត្សឆ្នាំ ៩០ ។

[១០] បសុសត្វរួមចំណែក ១៧% នៃចំណូលគ្រួសារជនបទ គិតជាមធ្យម(Helmers et al., 2003) ។

បន្ទាប់ពីការផ្អាក ការកាប់ឈើជាលក្ខណៈពាណិជ្ជកម្មនៅក្នុងតំបន់សម្បទាន និងការលុបចោលនូវព្រៃសម្បទានមួយចំនួន[១១] ។

១៧. *ផលិតភាពកសិកម្មនៅកម្ពុជាមានកំរិតទាប* ទាំងកំលាំងពលកម្ម ទាំងដីធ្លី ដោយមានតំលៃទិន្នផលសរុបប៉ាន់ស្មានក្នុងកំរិត ២០០ដុល្លារអាមេរិកក្នុងកម្មករម្នាក់ និង ២៨០ដុល្លារអាមេរិកក្នុងមួយហិកតា។ ទោះបីជាមានកំណើនផលិតភាពក៏ដោយ - ដោយការប៉ាន់ស្មានពី ១,៣ តោនក្នុងមួយហិកតានៅដើមទសវត្សឆ្នាំ៩០ ទៅ ២តោនក្នុងមួយហិកតាចាប់តាំងពីឆ្នាំ២០០០ - ទិន្នផលស្រូវនៅតែមានកំរិតទាប បើប្រៀបធៀបទៅនឹងការអនុវត្តន៏នៅប្រទេសជិតខាង[១២] នេះបង្ហាញប្រាប់ថានៅមានកាលានុវត្តភាពច្រើនសំរាប់បង្កើនផលិតភាពថែមទៀត។ បញ្ហារចនាសម្ព័ន្ធដ៏សំខាន់មួយគឺ ជីជាតិដីមានកំរិតទាប ក្នុងទំហំ ៥០%នៃផ្ទៃដីដាំស្រូវ (Nesbitt, 1997), ដែលភាគច្រើននៃកសិករប្រមូលផ្ដុំនៅទីនោះ។ បញ្ហាដ៏ទៃទៀតគឺការប្រើប្រាស់ជីតិចតួច ហានិភ័យដែលពាក់ព័ន្ធនឹងទឹកជំនន់ និងការតំរង់ទិសទៅរកលក្ខណៈជិវព្រឹត្តិនៃប្រព័ន្ធធ្វើកសិកម្មដែលមាននៅគ្រប់ទីកន្លែង ដែលរួមចំណែកដល់កំរិតទាបនៃការវិនិយោគលើធាតុចូលនៃវិស័យកសិកម្ម។ ជាងនេះទៅទៀត គួរកត់សំគាល់ថា ផលិតភាពទាបនៃការផលិតស្រូវគឺក៏ជាការឆ្លុះបញ្ចាំងពីសារៈសំខាន់នៃប្រព័ន្ធកសិកម្មដែលពឹងផ្អែកទៅលើទឹកភ្លៀងនៅតំបន់ទំនាប ដែលកំពុងតែអនុវត្តដោយកសិករប្រមាណ ៨០%: គេប៉ាន់ស្មានថាមានតែ ១៧%ប៉ុណ្ណោះនៃផ្ទៃដីធ្វើស្រែទទួលបានអត្ថប្រយោជន៍ពីរចនាសម្ព័ន្ធត្រួតពិនិត្យទឹក។ ផលិតភាពនៃដំណាំសំខាន់ៗផ្សេងទៀត (ពោត ដំឡូងឈើ ។ល។) ហាក់បីដូចជាទាបជាងគេទាំងអស់បើធៀបទៅនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់ (សូមមើលរូបភាពទី ២: ទិន្នផលមធ្យមសំរាប់ដំណាំសំខាន់ៗនៅកម្ពុជា)។

---

[១១] តួលេខនេះប្រៀបធៀបជាមួយនឹង ការរួមចំណែក ១៥% របស់វិស័យសេវាកម្ម ចំពោះកំណើន GDP និង ៥៦%របស់វិស័យឧស្សាហកម្ម នៅក្នុងអំឡុងពេលដូចគ្នា។

[១២] ក្នុងឆ្នាំ២០០២ បាន ២,៦តោនក្នុងមួយហិកតានៅប្រទេសថៃ ៣,៣តោន នៅហ្វីលីពីន ៣,៥ តោននៅឡាវ ៤,៤ តោន នៅឥណ្ឌូនេស៊ី ៤,៦ តោន នៅវៀតណាម និង ៦,៣ តោននៅប្រទេសចិន (FAO)។

រូបភាព ២:ទិន្នផលមធ្យមក្នុងឆ្នាំ ២០០១ ជា តោន/ហិកតា ( ប្រភព: FAO




| | Rice | Maize | Cassava | Soybeans |
|---|---|---|---|---|
| Cambodia | 2.07 | 2.76 | 10.5 | 0.85 |
| Vietnam | 4.29 | 2.96 | 12 | 1.24 |
| Thailand | 2.62 | 3.73 | 17.5 | 1.42 |
| Lao PDR | 3.13 | 2.55 | 4 | 0.9 |
| China | 6.15 | 4.7 | 16 | 1.62 |
| Indonesia | 4.39 | 2.84 | 12.9 | 1.22 |
| Malaysia | 3.14 | 3.05 | 10 | |

១៨. *កសិកម្មកម្ពុជាគឺមិនមានលក្ខណ:ពិពិធកម្ម ដោយមាន ៩០% នៃផ្ទៃដីសរុបសំរាប់ដាំស្រូវ*[១៣] (២,៣ លានហិកតា)។ ស្រូវដើរតួនាទីដ៏សំខាន់សំរាប់សន្តិសុខស្បៀងដែលជាអាហារចាំបាច់ដំបូងបង្អស់ ក៏ដូចជារួមចំណែកទៅនឹងអតិរេកតិចតួចល្មមសំរាប់ការនាំចេញ។ ការដាំដំណាំផ្សេងទៀតគឺត្រូវធ្វើឡើងនៅក្នុងកំរិតគ្រួសារ និងមានការកើនឡើងលឿន ប៉ុន្តែពីមូលដ្ឋានដំបូងដែលមានកំរិតទាប ដែលគ្របដណ្តប់ ៨% នៃតំបន់ដាំដំណាំ។ នៅសល់ ២% គឺសំរាប់ដាំដំណាំឧស្សាហកម្ម រួមមាន កៅស៊ូ និងថ្នាំជក់។ កៅស៊ូនៅតែជាមុខទំនិញនាំចេញរបស់កម្ពុជា ដែលឈរនៅចំណាត់ថ្នាក់លេខមួយក្នុងចំណោមការនាំចេញផលិតផលកសិកម្ម។ បសុសត្វគឺជាប្រភពរួមមួយនៃចំណូលដែលបំពេញឱ្យគ្នាថែមទៀតសំរាប់គ្រួសារជនបទ។ សារៈសំខាន់នៃស្រូវក្នុងចំណោមដំណាំនានាធៀបទៅនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់ គឺមិនមែនជាការឆ្លុះបញ្ចាំងនៃការខ្វះសក្តានុពលក្នុងការធ្វើពិពិធកម្មដំណាំឡើយ ប៉ុន្តែគឺជាលទ្ធផលមកពីការតំរង់ទិសទៅរកលក្ខណៈជីវព្រឹត្តនៃកសិកម្ម។ សក្តានុពលសំរាប់ការធ្វើពិពិធកម្មនៃប្រព័ន្ធកសិកម្មដែលកំពុងមានអត្ថិភាព គឺមានសារៈសំខាន់លុះត្រាតែបញ្ហាសំខាន់ៗ ដូចជា កង្វះនូវហេដ្ឋារចនាសម្ព័ន្ធ ទំនុកចិត្តទីផ្សារ និងពតិមានបច្ចេកទេស លទ្ធភាពទទួល បានសេវាហិរញ្ញវត្ថុ លទ្ធភាពទទួលបាននូវកត្តាផលិតកម្ម អសន្តិសុខនៃសិទ្ធិកាន់កាប់ ជាដើម

[១៣] តួលេខនេះប្រៀបធៀបជាមួយឡាវ ៨០% វៀតណាម ៦២% ថៃឡង់ដ៏ ៥៧% ឥណ្ឌូនេស៊ី ៣៨% ហ្វីលីពីន ៣២% និងម៉ាឡេស៊ី ១២% (IRRI, 2001)។

ត្រូវបានដោះស្រាយ ហើយកសិករមានទឹកចិត្តគ្រប់គ្រាន់សំរាប់ការវិនិយោគថ្មីក្នុងទំរង់ផលិតកម្ម ប្រពល-វប្បកម្ម និងធ្វើពិពិធកម្មដំណាំផ្សេងៗទៀតក្រៅពីស្រូវ ។

១៩. *ការធ្វើឯកទេសកម្មតាមតំបន់កំពុងដំណើរការ ទោះបីជាមានកំរិតតិចតួចក៏ដោយ ។* ការកើតមាននៅគ្រប់ទីកន្លែងនៃកសិកម្មជីវព្រឹត្តិ មានន័យថាការធ្វើស្រែចំការជាទូទៅមិនមានលក្ខណៈឯកទេសកម្ម ដោយមានការលើកលែងចំពោះតំបន់ខ្លះដែលមានផលិតភាពខ្ពស់និងអាចូលដល់ទីផ្សារបានប្រសើរជាង ។ ប៉ុន្តែតំបន់ផលិតកម្មជាលក្ខណៈប្រពៃណីនៅតែមាននៅឡើយ (ឧទាហរណ៍ ការដាំកៅស៊ូនៅតំបន់ដីក្រហម ៥០%នៃផលិតកម្មស្រូវបានមកពីខេត្តចំនួនប្រាំ) ហើយឯកទេសកម្មតាមតំបន់កំពុងតែលេចមុខជាបន្តបន្ទាប់ ។ ដោយសារតែរដ្ឋាភិបាលបំភ្លឺកាន់តែច្បាស់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៏កសិកម្មរបស់ខ្លួន នោះការគិតគូរពិចារណារគួរតែធ្វើឡើងដើម្បីលើកកំពស់ឯកទេសកម្មដោយផ្អែកលើអត្ថប្រយោជន៏ធៀបនៃតំបន់និងមូលដ្ឋាននានា។ នេះនឹងទាមទារនូវការអភិវឌ្ឍន៏សមត្ថភាពដើម្បីវិភាគពីសក្តានុពលកសិកម្មនៅថ្នាក់មូលដ្ឋាន ដើម្បីផ្តល់ពត៌មានអំពីជំរើសគោលនយោបាយ និងការវិនិយោគនៅថ្នាក់មូលដ្ឋាន និងជាតិ ។

២០. *ទោះបីជាមានភាពជឿនលឿនក្នុងការធ្វើសេរីភាវូបនីយកម្មគោលនយោបាយពាណិជ្ជកម្ម ការនាំចេញកសិផលផ្លូវការនៅមានកំរិតទាប ហើយការធ្វើពាណិជ្ជកម្មក្រៅផ្លូវការគឺមានការកើនឡើង។* ជាលក្ខណៈតំបន់ កម្ពុជាឈរក្នុងតារាងក្រោមគេបំផុតចំពោះលទ្ធភាពធ្វើពាណិជ្ជកម្មកសិកម្ម[១៤] និង សមត្ថភាពនាំចូលស្បៀងអាហារ[១៥] ។ បច្ចុប្បន្ន ការនាំចេញផលិតផលកសិកម្មតំណាងឱ្យតែ ៦%នៃទំនិញនាំចេញទាំងអស់ ដែលទំនិញភាគច្រើនបានមកពីផ្នែកផលិតផលរោងចក្រកាត់ដេរ (៧៧%) ។ ការធ្វើពាណិជ្ជកម្មផលិតផលកសិកម្មរុក្ខកម្ម និងជលផលបានធ្លាក់ចុះនៅប៉ុន្មានឆ្នាំថ្មីៗនេះ-ពី ២៥២ លានដុល្លាអាមេរិកនៅឆ្នាំ ១៩៩៩ មកត្រឹម ៨៩ លានដុល្លារអាមេរិកនៅឆ្នាំ ២០០១ (មូលនិធិរូបិយវត្ថុអន្តរជាតិ ២០០៣) ជាចំបងដោយសារការធ្លាក់ចុះការនាំចេញនៃផលិតផលព្រៃឈើបន្ទាប់ពីមានការហាមឃាត់ការកាប់ឈើ ។ ការកើនឡើងនូវការនាំចេញក្រៅផ្លូវការនៃផលិតផលស្រូវ (ប៉ាន់ស្មាន ៤៥០.០០០ តោននៅឆ្នាំ ២០០១) ត្រីស្រស់ និងពាហានៈរស់ទៅប្រទេសវៀតណាម និងប្រទេសថៃគឺជាសញ្ញានៃបរាជ័យ និងអប្រសិទ្ធភាពនៅក្នុងទីផ្សារនិងការសំរួលពាណិជ្ជកម្ម ។

---

[១៤] លទ្ធភាពធ្វើពាណិជ្ជកម្មកសិកម្ម (អត្រានៃការនាំចូលផលិតផលកសិកម្មសរុបបូកនឹងការនាំចេញ ទៅនឹង GDP កសិកម្ម) គឺជារង្វាស់នៃការបើកចំហនៃវិស័យពាណិជ្ជកម្ម ។

[១៥] សមត្ថភាពនាំចូលស្បៀងអាហារ (អត្រានៃតំលៃការនាំចូលស្បៀង ទៅនឹងការនាំចេញមិនមែនស្បៀងសរុប) វាស់នូវសមត្ថភាពរបស់ប្រទេសមួយដែលមានរូបិយបណ្ណ័បរទេសដើម្បីនាំចូលស្បៀងអាហារ ។

២១. *របាំងដ៏ធំបងចំពោះការធ្វើពាណិជ្ជកម្មកសិកម្ម ហាក់បីដូចជាអប្រសិទ្ធិភាពដ៏សំខាន់នៅក្នុងការរកទីផ្សារ និងច្រកពាណិជ្ជកម្ម។* ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ ៨០ ប្រទេសកម្ពុជាបានអនុវត្តបន្តិចម្តងៗនូវសេរីភាវូបនីយកម្មសេដ្ឋកិច្ច រួមមាន អត្រាការប្រាក់អណ្តែត ការលុបបំបាត់នូវការដាក់កំហិតជាបរិមាណក្នុងការធ្វើពាណិជ្ជកម្ម កាត់បន្ថយអត្រាពន្ធនាំចូល បំបែកសិទ្ធិផ្តាច់មុខរបស់រដ្ឋក្នុងទីផ្សារធាតុចូលនិងធាតុចេញសំខាន់ៗមួយចំនួន។ ទោះបីជា អត្រាពន្ធនាំចូលនៅតែមាន ដែលមានកំរិតខ្ពស់ចំពោះទំនិញខ្លះ ការចូលថ្មីៗនេះជាលើកដំបូងជាសមាជិកអាស៊ាន (១៩៩៩) និងរឹតតែថ្មីៗនេះទៀត ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (២០០៣) បានដាក់ប្រទេសកម្ពុជាទៅក្នុងដំណើរការនៃការធ្វើវិចារណកម្មបន្ថែមទៀតនៃគោលនយោបាយពាណិជ្ជកម្ម និងការកាត់បន្ថយជាបណ្តើរៗនៃអត្រាពន្ធនាំចូល។ បញ្ហាស្ថាប័ន និងអភិបាលកិច្ច ដែលបណ្តាលឱ្យមានលំហូរការធ្វើពាណិជ្ជកម្មក្រៅផ្លូវការដ៏ច្រើន ហើយស្ថាប័នទីផ្សារ និងបញ្ហាហិរញ្ញប្បទាន និងហេដ្ឋារចនាសម្ព័ន្ធដែលជះឥទ្ធិពលដល់ការរកទីផ្សារ និងការធ្វើពាណិជ្ជកម្មនៃទំនិញសំខាន់ៗត្រូវបានកត់ត្រាបញ្ចូលយ៉ាងល្អនៅក្នុងឯកសារ (ក្របខ័ណ្ឌសមាហរណកម្ម និងការងារថ្មីអំពីការវិភាគខ្សែសង្វាក់តំលៃ)។

២២. *ដូច្នេះ កម្ពុជានៅពុំទាន់មានលទ្ធភាពច្បាមយកកាលនុវត្តភាព ពីសាកលភាវូបនីយកម្ម នៃទីផ្សារ និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដូចជាកាលានុវត្តភាពដែលបានមកពីការចូលជាសមាជិក WTO ថ្មីៗ ឬ កម្មវិធីឆាប់ទទួលផលរវាងចិន និង អាស៊ាន*[១៦] *ដែលធ្វើអោយបាត់បង់សក្តានុពលប្រាក់ចំណូល ចំពោះសហគមន៍ជនបទ និងសេដ្ឋកិច្ចជាតិទូទៅ* ។ កម្ពុជាគឺជា នឹងនៅតែជាសេដ្ឋកិច្ចតូចមួយ ហើយកំណើនទៅអនាគតនៃវិស័យកសិកម្មនឹងពឹងផ្អែកទៅលើសមត្ថភាពរបស់ខ្លួនក្នុងការចូលដល់ទីផ្សារ តំបន់និងអន្តរជាតិ ដែលចាំបាច់ជាផ្នែកមួយដើម្បីទូទាត់កំណើននៃការនាំចូលស្បៀង។ ការនាំចូលរបស់ ប្រទេសកម្ពុជានូវអង្ករ ប្រេងបន្លែ ផ្លែឈើនិងបន្លែ បក្សីនិងជ្រូក មានការកើនឡើងនៅក្នុងទសវត្ស ចុងក្រោយនេះ។ ផលប៉ះពាល់ក្នុង រយៈពេលខ្លីនៃសេរីភាវូបនីយកម្ម ចំពោះចំណូលជនបទ និងភាពក្រីក្រ នៅជនបទ នៅមិនទាន់ត្រូវបានវាយតំលៃច្បាស់លាស់នៅឡើយទេ។ ជាគោលការណ៍ ការថយចុះនូវអត្រា ពន្ធនាំចូល អាចត្រូវបានគេរំពឹងថានឹងបង្កើតនូវសម្ពាធប្រកួតប្រជែងបន្ថែមទៀត ទៅលើវិស័យកសិកម្ម និងផ្នែកការងារជនបទក្រៅពីស្រែចំការ ដោយបង្កើនទូវការហូរចូលនៃទំនិញបរទេស និងផលិតផលកសិកម្ម។ ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែង

[១៦] នៅខែវិច្ឆិកា ឆ្នាំ ២០០២ ចិន និង សមាជិកអាស៊ាន (សមាគមន៍នៃប្រជាជាតិនៅអាស៊ីអាគ្នេយ៍) រួមមានកម្ពុជាផងដែរ បានចុះហត្ថលេខាលើកម្មវិធីទទួលផលដើមរដូវ (EHP) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចពេញលេញនៅភ្នំពេញ ប្រទេសកម្ពុជា ។ គោលដៅ គឺជំរុញពាណិជ្ជកម្មទំនិញកសិកម្ម និង ស្បៀងអាហារជាមួយប្រទេសចិន តាមរយៈកម្មវិធីកាត់បន្ថយពន្ធនាំចូល "ដើមរដូវ" ។

របាំងពន្ធគយមាន ប្រសិទ្ធភាពតែក៏រិតតិចតួចទេ ដោយគិតទៅដល់បញ្ហា ពង្រឹងការអនុវត្តច្បាប់ និងការកើនឡើងនៃពាណិជ្ជកម្មក្រៅផ្លូវការ ។ ថាតើផ្នែកជនបទអាចងើបឈរ ប្រឈមនឹងការប្រកួតប្រជែងជាសកលនៅក្នុងរយៈពេលមធ្យម និងវែងបានគឺជាបញ្ហាលំបាក់មិនអាចព្យាករណ៍បាន ទោះបីជារបៀបវារៈកំណែទំរង់ដែលបានស្នើឡើង ខាងក្រោមនេះអាចសំរាលនូវវិបាកធ្ងន់ធ្ងរបានខ្លះ ។

## *សេវាជាមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធមានការខ្វះខាតយ៉ាងខ្លាំង*

២៣. *ការអភិវឌ្ឍន៏សេដ្ឋកិច្ចជនបទទាមទារនូវការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គមជាមូលដ្ឋាន ។* លទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធគឺមានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងកំណើនសេដ្ឋកិច្ចជនបទ ។ ផ្លូវសំរាប់ដឹកជញ្ជូនគឺសំខាន់ណាស់សំរាប់សកម្មភាពសេដ្ឋកិច្ចជាច្រើននៅតំបន់ជនបទ ផ្សារភ្ជាប់អ្នកផលិតទៅនឹងទីផ្សារ និងបន្ថយចំណាយពាណិជ្ជកម្ម ដូច្នេះកាត់បន្ថយចំណាយធាតុចូលសំរាប់កសិកម្ម និងបង្កើនថ្លៃផលិតផលកសិកម្មដែលឈ្មួញទិញដល់កន្លែង[១៧] ។ លទ្ធភាពទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន មានផលប៉ះពាល់ច្បាស់ទៅលើការអភិវឌ្ឍន៏នៃកាលានុវត្តភាពបង្កើតចំណូលក្រៅពីរបរធ្វើស្រែចំការ (Helmers et al., 2003) ហើយវត្តមាននៃទីផ្សារនៅតាមភូមិជាអចិន្ត្រៃយ៏មានទំនាក់ទំនងទៅវិញទៅមកជាមួយក៏រិតចំណូលខ្ពស់របស់គ្រួសារ (Auffret, 2003) ។ ការធ្វើពាណិជ្ជកម្មសាមញ្ញនៃទំនិញនិងសេវាកម្មគឺត្រូវបានបន្ទុចបង្អាក់ដោយហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទន់ខ្សោយ និងអសមត្ថភាពក្នុងការធ្វើគមនាគមន៏នៅលើផ្លូវដ៏ឆ្ងាយ ។ អវត្តមាននៃថាមពល និងបណ្តាញទូរគមនាគមន៏ខាយាំងដល់ការធ្វើវិនិយោគឯកជននៅតំបន់ជនបទ ។ ទីបំផុត ការអភិវឌ្ឍន៏នូវចំណេះដឹងនិងជំនាញធនធានមនុស្សគឺត្រូវបានរារាំងដោយលទ្ធភាពតិចតួចក្នុងការទទួលបាននូវមូលដ្ឋានសំភារៈអប់រំ និងសុខាភិបាល និងគុណភាពអនាម័យនិងការផ្គត់ផ្គង់ទឹកទន់ខ្សោយ ។

២៤. *តំបន់ជនបទមិនទទួលបានសេវាគ្រប់គ្រាន់ខាងផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ។* ហេដ្ឋារចនាសម្ព័ន្ធជនបទត្រូវបានបំផ្លិចបំផ្លាញយ៉ាងដំណំ និង/ឬមិនអើពើក្នុងកំឡុងឆ្នាំនៃចំបាំងរាំងជល ហើយទោះបីជាទទួលបានការកែលំអខ្លះៗក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ គឺនៅមានផ្លូវវែងឆ្ងាយណាស់សំរាប់ធ្វើដំណើរទៅមុខទៀតដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានរបស់អ្នករស់នៅជនបទនូវហេដ្ឋារចនាសម្ព័ន្ធ ។ ករណីនេះពិតប្រាកដចំពោះតំបន់ដែលមាប្រជាជនតិចនៅក្នុងភាគខាងពាយ័ព្យ និងព្យសានដែលនៅទីនោះ

---

[១៧] ប៉ុន្តែ នេះប្រហែលជាមិនគ្រប់គ្រាន់ ហើយផលចំណេញអាចត្រូវបានប្រមូលយកដោយអ្នកជំនួញនៅពេលដែលភាពផ្តាប់មុខកើតមាន ឧទាហរណ៍ ការផ្តល់ឥណទាន ។

គេបានឃើញនូវលំហូរចូលនៃប្រជាជន។ កម្ពុជាស្ថិតនៅពីក្រោយប្រទេសផ្សេងៗនៅក្នុងតំបន់សំរាប់សូចនាករមួយចំនួន (ប្រអប់ទី ៣ និងតារាងទី ៤)។ ជាងនេះទៅទៀត ស្ថាប័នដែលបំរើឱ្យតំបន់ជនបទត្រូវបានប្រឈមមុខដោយ បញ្ហានៃសមត្ថភាព ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបែងចែកធនធាន និងអំពើពុករលួយ។ វិមជ្ឈការ និងការផ្ទេរកិច្ចសន្យាអនុវត្តការងារទៅផ្នែកឯកជន មានសក្តានុពលក្នុងការពង្រឹងការចែកចាយសេវាជនបទ ប៉ុន្តែបញ្ហាប្រឈមដ៏ខ្លាំងចំពោះអភិបាលកិច្ច និងសមត្ថភាពនៅតែមានដដែល។

**ប្រអប់ ៣: ស្ថានភាពនៃសេវាហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចនៅតំបន់ជនបទ**

**ការផ្គត់ផ្គង់ទឹក និងអនាម័យ:** គ្រួសារតិចជាង ២៥%មានលទ្ធភាពទទួលបានទឹកស្អាតសំរាប់បរិភោគ ដែលក្នុងនោះមាន ៤%ក្នុងចំណោមគ្រួសារក្រីក្របំផុតនៃបញ្ចភាគ ហើយគ្រួសារជនបទតិចជាង ១៦% ទទួលបានមូលដ្ឋានសំភារៈអនាម័យ ស្ថិតនៅក្រោមចំណុចដៅឆ្នាំ ២០០៥ នៃ ៤០% និង ២០% រៀងគ្នា។ ពុំមានប្រព័ន្ធលូទឹកនៅខាងក្រៅទីក្រុងសំខាន់ៗមួយចំនួន ហើយកម្ពុជាស្ថិតក្នុងចំណោមអត្រាខ្ពស់បំផុតនៃជំងឺដែលបណ្តាលមកពីទឹកក្រខ្វក់នៅលើពិភពលោក។

**ការដឹកជញ្ជូន:** ប្រហែល ៦%នៃបញ្ចភាគក្របំផុតរស់នៅ ប្រមាណ ៥គ.ម. ឆ្ងាយពីផ្លូវដែលនៅជិតជាងគេបំផុត។ ភូមិប្រមាណតិចជាង ៣០% អាចទៅដល់តាមចរាចរយានយន្តនៅរដូវវស្សា។ បណ្តាញផ្លូវមានលក្ខណៈអន់ខ្សោយដោយមាន ៥២%នៃផ្លូវ ត្រូវបានរាយការណ៍ថាមានលក្ខណៈអន់ថយ ហើយ ៨%មានលក្ខណៈអាក្រក់ នៅក្នុងឆ្នាំ ២០០៣។

**សេវាថាមពល និងទូរគមនាគមន៍** មានតែនៅតំបន់ទីប្រជុំជនធំនិងប្រជាជនរស់នៅច្រើន។ កម្ពុជាមានអត្រាប្រើប្រាស់អគ្គិសនីទាបបំផុតនៅក្នុងចំណោមប្រទេសអាស៊ីបូព៌ា ក្នុងកំរិត ៥% នៅតំបន់ជនបទ។ ចំពោះទូរគមនាគមន៍ ខ្សែភ្ជាប់បណ្តាញទូរស័ព្ទអចល័តសំរាប់ទូទាំងប្រទេសមានតែ ០,២៧ ក្នុង ១០០គ្រួសារ ចំណែកឯបណ្តាញទូរស័ព្ទចល័តមាន ១,២៧ ក្នុង១០០គ្រួសារ នៅឆ្នាំ ២០០០។ វិសាលភាពខ្សែភ្ជាប់អចល័ត គឺរឹតតែទាបនៅតំបន់ជនបទ ដែលការពង្រីកវិសាលភាពនឹងទាមទារនូវការវិនិយោគដ៏ធំ ចំណែកឯសេវាទូរស័ព្ទចល័តបានពង្រីកទៅតំបន់ជនបទខ្លះៗ ដោយមានអត្រាខ្ពស់។

**សុខាភិបាល:** ភាគច្រើននៃអ្នកក្រីក្ររស់នៅឆ្ងាយពីមណ្ឌលសុខភាព-អត្រាស្លាប់របស់ទារក និងមាតាមានកំរិតខ្ពស់។ មូលដ្ឋានសំភារៈថែទាំសុខភាពភាគច្រើនផ្តុំនៅតែមណ្ឌលទីប្រជុំជនធំៗ ទុកចោលតំបន់ជនបទស្ទើរតែទាំងអស់ដោយមិនបានផ្តល់សេវាគ្រប់គ្រាន់។

**អប់រំ:** មានតែ ៤៦%នៃភូមិទាំងអស់មានសាលាបឋមសិក្សា។

**តារាង ៤: ការគ្រប់ដណ្តប់សេវាហេដ្ឋារចនាសម្ព័ន្ធ-ការប្រៀបធៀបជាមួយប្រទេសជិតខាង**

| **សូចនាករ** | **កម្ពុជា** | **វៀតណាម** | **ថៃ** | **ឡាវ** | **ចិន** |
|---|---|---|---|---|---|
| ភាគរយនៃផ្លូវដែលបានឈូសឆាយ, ១៩៩៩ ក/ | 16% | 25% | 97% | 44% | 22% |
| បណ្តាញខ្សែទូរស័ព្ទសំខាន់ៗ ក្នុង ១០០ នាក់ ២០០១ ក/ | 0.24 | 3.75 | 9.39 | 0.93 | 13.8 |
| ភាគរយនៃប្រជាជនដែលមានលទ្ធទទួលបានអគ្គីសនី ២០០០ ខ/ | 16% | 76% | 82% | > 22% | |
| ប្រភពទឹកដែលបានកែលំអ (%ប្រជាជនជនបទដែលមាន លទ្ធភាពទទួលបាន, ២០០០) ក/ | 26% | 72% | 81% | 29% | 66% |
| មូលដ្ឋានសំភារៈអនាម័យដែលបានកែលំអ (%ប្រជាជន ជនបទ ដែលមានលទ្ធភាពទទួលបាន ២០០០) ក/ | 10% | 38% | 96% | 19% | 24% |

ប្រភព: ក/ World Bank SIMA database; ខ/ ADB “Electric Utilities Data Book”, IEA “World Energy Outlook 2002”

២៥. *ប្រព័ន្ធធនាគារដែលមានលក្ខណៈទន់ខ្សោយ មិនទាន់បំរើអ្នកក្រជនបទ និងវិស័យកសិកម្មនៅឡើយទេ។* លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុគឺជាកត្តាមួយដ៏សំខាន់ដើម្បីជួយដល់គ្រួសារឱ្យអាចដោះស្រាយបាននឹងការប្រែប្រួលនៃចំណូលភាពងាយទទួលរងគ្រោះ និងអាចឱ្យឆ្លើយតបបានទៅនឹងកាលានុវត្តភាពសេដ្ឋកិច្ចដែលមានស្រាប់។ ផ្នែកហិរញ្ញវត្ថុទទួលផលប្រយោជន៍ពីក្របខ័ណ្ឌល្អនៃច្បាប់និងបទប្បញ្ញត្តិ។ បន្ទាប់ពីការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីស្ថាប័នធនាគារនិងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩ ដំណើរការនៃការកែប្រែរចនាសម្ព័ន្ធធនាគារដែលបានបញ្ចប់នៅក្នុងឆ្នាំ ២០០២ បានបង្ហាញពីជោគជ័យក្នុងការធ្វើឱ្យប្រសើរឡើងនូវការទុកចិត្តពីសាធារណៈក្នុងវិស័យធនាគារ។ ប៉ុន្តែ សកម្មភាពឱ្យខ្ចីរបស់ធនាគារ បន្តនៅនឹងមួយកន្លែង[១៨] ហើយកំណើនក្នុងការផ្តល់ឥណទានដល់ផ្នែកឯកជនស្ទើរតែគ្មានក្នុងអំឡុងពេលពីរឆ្នាំកន្លងមកនេះ[១៩] ទោះបីជាមានតំរូវការ

---

[១៨] ហេតុផលសំខាន់ដែលបានរកឃើញគឺ: (១) កម្ចីភាគច្រើនមានរយៈពេលខ្លី ដោយមានការប្រាក់ខ្ពស់ ជាសំខាន់ផ្តល់ការធ្វើហិរញ្ញ-ប្បទានដល់ការនាំចេញ/នាំចូល និងសំរាប់ជាទុនបង្វិលចំពោះផ្នែកពាណិជ្ជកម្មនិងសេវាកម្ម (ទេសចរណ៍), (២) ធនាគារភាគច្រើនមានម្ចាស់ជាជនបរទេស ហើយផ្តោតទៅលើការផ្តល់សេវាដល់អតិថិជននៅស្រុកខ្មែរដែលមកពីប្រទេសដូចខ្លួនដែរ (៣) ធនាគារប្រមូលផ្តុំ តែនៅតំបន់ទីប្រជុំជន ដោយមានតែធនាគារមួយចំនួនតូចមានសាខានៅក្រៅទីក្រុងសំខាន់ៗ ទុកឱ្យប្រជាជនជនបទភាគច្រើនពុំមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ (ADB, 2002)។

[១៩] ឥណទានសំរាប់ផ្នែកឯកជន គឺ ៧%នៃ GDP មានកំរិតទាបជាងយ៉ាងខ្លាំងនៃប្រទេសអាស៊ីផ្សេងទៀត នៅក្នុងដំណាក់កាលអភិវឌ្ឍន៍ដូចគ្នា (IMF, 2003)។

ខ្លាំងពី សហគ្រាសធុនតូចនិងមធ្យមក៏ដោយ។ ការប៉ាន់ស្មានថ្មីៗនៃលទ្ធភាពទទួលបានមីក្រូឥណទាន បង្ហាញថា មានតែ ១៥%នៃប្រជាជនជនបទរបស់ប្រទេសកម្ពុជា មានលទ្ធភាពទទួលបានឥណទាន ពីស្ថាប័នរៀបរយ និងពាក់កណ្តាលរៀបរយ (ធនាគា ឬស្ថាប័នចុះបញ្ជីមីក្រូហិរញ្ញវត្ថុ) - បន្សល់ទុក ៨៥%នៃប្រជាជនជនបទ ពឹងផ្អែកទាំងស្រុងទៅលើប្រភពក្រៅផ្លូវការ ដូចជា មិត្រភ័ក្ត សាច់ញាតិ អ្នកចងការប្រាក់ឬឈ្មួញកណ្តាល។ ប្រភពផ្សេងៗប៉ាន់ស្មានអំពីសេចក្តីត្រូវការឥណទានដោយគ្រួសារជនបទ រវាងពី ៤០លានដុល្លារអាមេរិក និង ១២៥លានដុល្លារអាមេរិកក្នុងមួយឆ្នាំ[២០]។ ការសិក្សាបង្ហាញថា វិស័យរៀបរយមានការស្ទាក់ស្ទើរក្នុងការឱ្យខ្ចី នៅតំបន់ជនបទ ពីព្រោះមានការចំណាយខ្ពស់ មានកាលានុវត្តភាពតិចតួច និងអសមត្ថភាពក្នុងការវាយតំលៃ ហានិភ័យឥណទានប្រកបដោយប្រសិទ្ធិភាព។ ផ្ទុយមកវិញ កសិករ និងសហគ្រាសធុនតូចនិងមធ្យមជនបទ គឺពុំមានលទ្ធភាពចូលដល់ធនាគារ ដែល នៅក្រៅទីក្រុងសំខាន់ៗបានឡើយ ហើយដូច្នេះ ប្រាថ្នាងាកទៅរកទីផ្សារ ឥណទានមិនរៀបរយ (Torres, 2004)។ លទ្ធភាពទទួលបានសេវាសន្សំ គឺរឹតតែមានកំរិតថែមទៀត។

២៦. *បរិយាកាសអាជីវកម្មជនបទ ដោយយល់ដឹងថាអំពើពុករលួយគឺជាឧបសគ្គដ៏ចំបង។* លទ្ធផលនៃ ការវាយតំលៃបរិយាកាសវិនិយោគ[២១] បង្ហាញថា ទស្សនៈរបស់សហគ្រិននៅក្នុងនិងក្រៅប្រទេសកម្ពុជា គឺថា អំពើពុករលួយគឺមាននៅគ្រប់ទីកន្លែង ហើយថាប្រទេសនៅតែមានភាពងាយទទួលរងអស្ថេរភាព។ ភាពទន់ ខ្សោយនៃវិធានច្បាប់ បន្ទុកការិយាធិបតេយ្យ និងអំពើពុករលួយ ត្រូវបានយល់ដឹងថាជាឧបសគ្គចំបងចំពោះ ការធ្វើអាជីវកម្មនៅប្រទេសកម្ពុជា។ អត្ថិភាពនៃកត្តាកត្តាផលិតកម្ម - ហិរញ្ញវត្ថុ ជំនាញ និងហេដ្ឋារចនា- សម្ព័ន្ធ - ត្រូវបានរកឃើញថាជាឧបសគ្គទីពីរ ប្រហែលមកពីលទ្ធផលនៃកំណើនដែលមានមូលដ្ឋានតូច និង ចរិតលក្ខណៈ នៃមីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម។ ប៉ុន្តែ បើប្រៀបធៀបទៅនឹង ក្រុមហ៊ុន នៅទីប្រជុំជន ក្រុមហ៊ុននៅជនបទមានការព្រួយបារម្ភនឹងអស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចដែលអាច កើតមាន ការចំណាយ ហិរញ្ញប្បទាន ការដឹកជញ្ជូន និងអគ្គិសនី។

២៧. *ការវិនិយោគនៅតំបន់ជនបទហាក់បីដូចជាមានការថយចុះ។* "ការវាយតំលៃនៃស្ថានភាពកសិ- ឧស្សាហកម្ម នៅកម្ពុជា " ដែលធ្វើឡើងដោយគរោង PRASAC II របស់គណកម្មការអឺរុប បញ្ជាក់អំពី

---

[២០] ADB បានប៉ាន់ស្មានពីតំរូវការហិរញ្ញវត្ថុសរុបប្រហែល ១២០-១៣០ដុល្លារអាមេរិកក្នុងមួយឆ្នាំ ដែលក្នុងនោះ មួយភាគបីសំរាប់ មីក្រូឥណទាន ក្នុងទំរង់ជាកម្ចីពី ៥០ ទៅ ៣០០ដុល្លារអាមេរិក។

[២១] កម្ពុជាៈ ការច្បាមយកកាលានុវត្តភាពពិភពលោក -ការវាយតំលៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកំណែទំរង់សំរាប់កម្ពុជា. ធនាគារពិភពលោក ២០០៤។

និន្នាការថយចុះនៃការវិនិយោគដែលបានចុះបញ្ជីទៅលើវិស័យកសិ-ឧស្សាហកម្ម។ ការអនុម័តការវិនិយោគជារួមបានថយចុះយ៉ាងខ្លាំង ហើយរឹតតែជាងនេះទៀតគឺចំពោះការអនុម័តអំពីឧស្សាហកម្មដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម។ សមាមាត្រនៃឧស្សាហកម្មដែលពាក់ព័ន្ធនឹងវិស័យកសិកម្មបានថយចុះពី ២២% មកនៅត្រឹម ៣% តាំងពីឆ្នាំ ១៩៩៨។ និន្នាការថយចុះដូចគ្នានេះដែរ គឺត្រូវបានគេសង្កេតឃើញនូវចំនួនច្រើននៃសហគ្រាសថ្មីធុនតូចនិងមធ្យមដែលបានចុះបញ្ជី។ លើសពីនេះទៀត ការវិនិយោគក្នុងវិស័យកសិកម្មមានលក្ខណៈច្រើនជាប្រពលកម្មដើមទុន និងទ្រទ្រង់នូវទំរង់កសិកម្មដែលមានលក្ខណៈវិបុលកម្មជាជាងប្រពលវប្បកម្ម ដោយមានការចូលរួមតិចតួចទៅនឹងការបង្កើតការងារនៅជនបទ (Van Acker, 1999)។ និន្នាការទាំងនេះនាំឱ្យមានការព្រួយបារម្ភ ដោយគិតដល់ការរំពឹងទុកថា វិស័យកសិកម្ម និងផ្នែកឯកជននឹងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច (SEDP II, NPRS) ។

**តារាង ៥: វិនិយោគដែលបានអនុម័ត**[ក/] (ដុល្លារអាមេរិក - តួលេខបាន់ស្មាន)

| | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|
| កសិ-ឧស្សាហកម្ម | 2,023 | 29,558 | 5,929 | - |
| ការកែច្នៃម្ហូបអាហារ | 7,972 | 11,913 | - | 2,016 |
| ការកែច្នៃស្បែក (សំលាប់ស្បែក) | - | - | 1,116 | - |
| ថ្នាំជក់ | 7,195 | - | - | 3,652 |
| ការកែច្នៃឈើ | 164,464 | 14,148 | - | 1,236 |
| **សរុប** | **181,653** | **55,619** | **7,044** | **6,904** |
| វិនិយោគដែលបានអនុម័តសរុប | 832,531 | 482,240 | 226,014 | 197,710 |
| ភាគរយនៃកសិ-ឧស្សាហកម្ម | 22% | 12% | 3% | 3% |

[ក/] តួលេខពាក់ព័ន្ធនឹងវិនិយោគដែលបានអនុម័ត ការវិនិយោគជាក់ស្តែងអាចមានកំរិតទាបជាងនេះខ្លាំង។ ប្រភព: *PRASAC II (2003)*

២៨. *កសិ-ឧស្សាហកម្មមានការអភិវឌ្ឍន៍កំរិតទាប ហើយជាទូទៅ អនុវត្តមិនទាន់បានល្អ។* ជាតួលេខភាគច្រើននៃផ្នែកឯកជនរួមមានក្រុមហ៊ុនកសិ-ឧស្សាហកម្មខ្នាតតូច។ ទោះបីជាវាអាចមានលក្ខណៈ អត្ថ-ប្រយោជន៍ធៀបដែលបណ្តាលមកពីចំណាយពលកម្មទាប និងសំបូរដោយដីទំនេរក៏ដោយ ក៏តំលៃបន្ថែមនៅក្នុងផ្នែកកសិ-ឧស្សាហកម្មក៏នៅមានកំរិតទាបបើធៀបទៅនឹងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ ឬក៏វិស័យផ្សេងៗទៀតដូចជា ឧស្សាហកម្មកាត់ដេរ[២២]។ កង្វះខាតនូវអតិរេកដែលគួរឱ្យទុកចិត្ត បានបង្អាក់ការ

[២២] កម្ពុជា: ការច្បាមយកកាលានុវត្តភាពពិភពលោក -ការវាយតំលៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកំណែទំរង់សំរាប់កម្ពុជា, ធនាគារពិភពលោក ២០០៤។

អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម។ លើសពីនេះទៅទៀត ការនេះបង្ហាញថា ការលើកកំពស់បច្ចេកវិជ្ជានៅដំណាក់កាលបន្ទាប់ពីការច្រូតកាត់ និងការកែច្នៃ បច្ចុប្បន្ននេះនៅមានកំរិតនៅឡើយ ដោយការខ្វះខាតនូវសេវាឥណទានសំរាប់វិស័យនេះ (FAO, 2003)។ ប៉ុន្តែ ការស្រាវជ្រាវគឺត្រូវការបន្ថែមទៀត ដើម្បីវិភាគអំពីឧបសគ្គចំបងៗដែលជួបប្រទះដោយក្រុមហ៊ុនកសិ-អាជីវកម្ម និងរៀបចំនូវការឆ្លើយតបដ៏សមស្រប។

## ផ្នែក II : ការបន្ស៊ីកិច្ចអភិវឌ្ឍន៍ជនបទ ~ ធាតុសំខាន់នៃយុទ្ធសាស្រ្តអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍វិស័យជនបទឆ្ពោះទៅរកអ្នកក្រ

២៩. ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទីពីរ (SEDP II, 2001-2005) យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ (NPRS, 2003-2005) និង MDGs របស់កម្ពុជា (សូមអានឧបសម្ព័ន្ធ ១) ផ្តល់នូវក្របខ័ណ្ឌទូទៅមួយ សំរាប់នាំផ្លូវទីភ្នាក់ងារនានាដែលពាក់ព័ន្ធនៅក្នុងកិច្ចអភិវឌ្ឍន៍តំបន់ជនបទ។ កាលពីពេលថ្មីៗកន្លងទៅនេះ "យុទ្ធសាស្រ្តចតុកោណ " ថ្មីរបស់រដ្ឋាភិបាលបានលើកសំណើទិសដៅគោលនយោបាយសេដ្ឋកិច្ចមួយចំនួន ដើម្បីសំរេចគោលដៅកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ទាំងអស់នេះ ចាំបាច់ត្រូវប្រែក្លាយទៅជាយុទ្ធសាស្រ្តពេញលេញសំរាប់អភិវឌ្ឍន៍តំបន់ជនបទដោយទីភ្នាក់ងារនានានៃវិស័យជនបទ។ ភាពស្មុគស្មាញនិងភាពទាក់ទងទៅពីមួយទៅមួយនៃបញ្ហាជនបទដែលបានពិណនានៅក្នុងផ្នែកទី I នៃឯកសារនេះ តំរូវឱ្យមានយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទសំរាប់ប្រទេសកម្ពុជា ឱ្យមានការប្រើប្រាស់ប្រកបដោយតុល្យភាពនូវគោលនយោបាយ វិនិយោគ និងវិធានការស្ថាប័នសមស្រប ដែលពុំមែនគ្រាន់តែមានឥទ្ធិពលមកលើកសិកម្មតែប៉ុណ្ណោះទេ ប៉ុន្តែក៏មានឥទ្ធិពលទូទៅលើសកម្មភាពជនបទផងដែរ។ វិធានការទាំងនេះរួមមានវិធានការទាំងឡាយណាដែលមានលក្ខណៈជាក់លាក់ចំពោះវិស័យជនបទ ដូចជាការគ្រប់គ្រងដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ កសិកម្ម និងស្ថាប័ននានានៅជនបទ។ ជាងនេះទៅទៀត គោលនយោបាយដែលមានសារៈសំខាន់ចំពោះសេដ្ឋកិច្ចទាំងមូល ដូចជាគោលនយោបាយសំរាប់ហេដ្ឋារចនាសម្ព័ន្ធ គោលនយោបាយសំរាប់វិស័យហិរញ្ញវត្ថុ និងគោលនយោបាយសំរាប់កំណែទំរង់វិស័យសាធារណៈទូទៅ ក៏មានឥទ្ធិពលយ៉ាងច្រើនមកលើការអភិវឌ្ឍន៍ជនបទផងដែរ។

៣០. *គោលដៅរួមរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនឹងសំរេចបានតាមរយៈការជំរុញកំណើនកសិកម្មឱ្យកាន់តែរហ័សនិងមាននិរន្តរភាព រួមមានការគ្រប់គ្រងវិស័យព្រៃឈើ បសុសត្វ និងជលផល និងជំរុញកំណើនក្រៅពីសកម្មភាពកសិកម្មនៅជនបទ។* ការជំរុញកំណើនកសិកម្ម និងការលើកកំពស់ប្រាក់ចំណូលផ្នែកកសិកម្ម ចាំបាច់ត្រូវរួមបញ្ចូលនូវការបង្កលក្ខណៈឱ្យកសិករមួយចំនួនធំងាកពីកសិកម្មជីវព្រឹត្តិមកកសិកម្មដែលឆ្ពោះទៅរកទីផ្សារ។ ក្នុងរយៈពេលខ្លី ប្រការនេះមានន័យថាជាការដោះស្រាយអំពីភាពខុសគ្នា និងការដោះស្រាយបញ្ហាអប្រសិទ្ធភាពនៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ ដើម្បីធានាឱ្យមានសុវត្ថិភាពអំពីកម្មសិទ្ធដីធ្លី លទ្ធភាពអាចបានទទួលធនធានធម្មជាតិ និងការប្រើប្រាស់ធនធានទាំងនោះប្រកបដោយនិរន្តរភាព ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃកសិកម្ម និងជា

ប្រភពមួយនៃប្រាក់ចំណូលបំពេញបន្ថែមសំរាប់គ្រួសារជនបទភាគច្រើន។ ប្រការនេះក៏តំរូវឱ្យមានការតភ្ជាប់កាន់តែប្រសើររវាងកសិករចំពោះទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិផងដែរ ហើយបង្កើតល័ក្ខខ័ណ្ឌសំរាប់ធ្វើពិពិធភាពចំពោះដំណាំ បសុសត្វ និងជលផលដែលផ្តល់តំលៃខ្ពស់ ដើម្បីឆ្លើយតបនឹងតំរូវការក្នុងស្រុក និងតំរូវការអន្តរជាតិ។ ការងារនេះតំរូវឱ្យមានការិនិយោគនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័នពាក់ព័ន្ធនឹងទីផ្សារសំខាន់ៗ ដើម្បីលើកកំពស់ភាពប្រកួតប្រជែងនៃផលិតផលកសិកម្មរបស់កម្ពុជា។ គេឃើញមានភស្តុតាងកាន់តែច្រើន ដែលបង្ហាញថាឧបសគ្គផ្នែកអភិបាលកិច្ចធ្ងន់ធ្ងរ ធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងនៃផលិតផលជនបទរបស់កម្ពុជា។ ហេតុនេះ វឌ្ឍនភាពអំពីកំណែទំរង់គោលនយោបាយ និងកំណែទំរង់ស្ថាប័នក្នុងការដោះស្រាយបញ្ហាទាំងនេះនឹងនាំមកនូវការវិនិយោគបន្ថែមទៀត។ ការជំរុញឱ្យមានការឆ្លើយតបពីកសិករ ក្នុងការផ្គត់ផ្គង់ផ្នែកកសិកម្មដែលមាននិរន្តរភាព ឱ្យឆ្លើយតបនឹងតំរូវការរបស់ទីផ្សារ ក៏ទាមទារឱ្យមានគោលនយោបាយនិងការវិនិយោគ ដែលធានាឱ្យមានលទ្ធភាពបានទទួលកត្តាផលិតកម្មដទៃទៀតផងដែរ ដូចជាសេវាបច្ចេកវិទ្យា សេវាហិរញ្ញវត្ថុ និងសេវាសុខភាពសត្វដែលត្រូវបានលើកកំពស់។ ការលើកកំពស់គុណភាពសេវាជនបទ (អប់រំ និងសុខាភិបាល) ដើម្បីពង្រឹងមូលធនមនុស្សនៅតំបន់ជនបទ ក៏មានសារៈសំខាន់ផងដែរ ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមមុខថ្មីៗរបស់ទីផ្សារ និងជួយសំរួលប្រជាពលរដ្ឋនៅជនបទឱ្យងាកពីវិស័យកសិកម្ម មកកាន់វិស័យឧស្សាហកម្ម និងសេវាកម្ម ទោះបីជានៅតំបន់ជនបទ ឬនៅតំបន់ទីប្រជុំជនក្តី។

៣១. *ផ្នែកនេះពិភាក្សាអំពីវិស័យសំខាន់ៗដើម្បីចាត់វិធានការចាំបាច់សំរាប់ផ្តល់ដង្ហើមចំពោះកិច្ចអភិវឌ្ឍន៍នៅជនបទ។* វិធានការទាំងនោះរួមមានៈ

- *បង្កើនលទ្ធភាពទទួលបានការគ្រប់គ្រងធនធានធម្មជាតិដែលមានផលិតភាព*- ការងារនេះមានសារៈ-សំខាន់ខ្លាំងណាស់សំរាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ។ បញ្ហាសំខាន់គឺការធ្វើឱ្យមាន តុល្យភាពលើអាទិភាពនានាចំពោះការប្រកួតប្រជែងក្នុងការប្រើប្រាស់ដីធ្លី ត្រី ជលផល និងទឹក បង្កើត ឱ្យមានលទ្ធភាពទទួលបានប្រកបដោយសមធម៌ចំពោះកម្មសិទ្ធដែលមានស្ថេរភាព និងដែលអាចផ្ទេរបាន ដោយរួមបញ្ចូលសហគមន៍មូលដ្ឋាន នឹងកាត់បន្ថយការកើតមានវិបត្តិនានា តាមរយៈការលើកកំពស់ការគ្រប់គ្រង ទឹក*ក្នុងចំណោមការងារដទៃទៀត* ។
- *បង្កើនប្រាក់ចំណូលកសិកម្ម*-ងាកចេញពីការធ្វើឯកវប្បកម្មចំពោះដំណាំស្រូវសំរាប់ស្វ័យផ្គត់ផ្គង់ និងផ្តល់នូវការលើកទឹកចិត្តចំពោះការធ្វើពិពិធកម្មកសិកម្ម។ វិធានការក្នុងការបង្កើនកត្តាផលិតភាពចំពោះដីធ្លី និងពលកម្ម អាចមានឥទ្ធិពលយ៉ាងច្រើនមកលើភាពក្រីក្រ (ការបរិភោគគិតជាកាឡូរី)នឹង ជួយសំរួល

អន្តរកាលឆ្ពោះទៅរកប្រព័ន្ធដែលផ្តោតលើការធ្វើពាណិជ្ជកម្ម។ ការលើកកំពស់សេវាទ្រទ្រង់កសិកម្មនិង ដំណើរការទីផ្សារ នឹងជំរុញឱ្យមានផលិតភាពបន្ថែមទៀត។ ចាំបាច់ត្រូវមានការគាំទ្រចំពោះការធ្វើ ពិពិធកម្មកសិកម្ម និងសេដ្ឋកិច្ចជនបទ តាមរយៈការកំណត់អត្តសញ្ញាណនិងការដោះស្រាយឧបសគ្គ ចំបងៗចំពោះការធ្វើពិពិធកម្មនៃប្រព័ន្ធដាំដុះ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទក្រៅពីកសិកម្ម។

- *លុបបំបាត់ឧបសគ្គក្នុងការទទួលបានហេដ្ឋារចនាសម្ព័ន្ធនិងសេវាទ្រទ្រង់នៅជនបទ*-កែលំអការបែងចែក វិនិយោគសាធារណៈតាមវិស័យ ឱ្យមានតុល្យភាពតាមភូមិសាស្ត្រ។ ដោយសារមានប្រភពប្រាក់ចំណូល ផ្សេងៗនិងមានភាពខុសគ្នាៗរវាងតំបន់និងក្នុងតំបន់ រវាងស្រុកនិងឃុំ ជាក់ច្បាស់ណាស់ដែលថា គ្មាន ដំណោះស្រាយទូទៅណាមួយសំរាប់ការអភិវឌ្ឍន៍ជនបទឡើយ។ ផ្ទុយទៅវិញ ដំណើរការនេះចាំបាច់ ត្រូវមានលក្ខណៈជាក់លាក់ទៅតាមមូលដ្ឋាន ឆ្លើយតបនឹងល័ក្ខខ័ណ្ឌ ឆ្លើយតបនឹងបរិយាកាសមូលដ្ឋាន និងលើកកំពស់ឱ្យបានជាអតិបរមានូវការចូលរួមរបស់អង្គការ និងប្រជាពលរដ្ឋនានានៅមូលដ្ឋាន ជាសំខាន់គឺតាមរយៈការធ្វើវិសហមជ្ឈការ និងវិមជ្ឈការ។

## *ការកែលំអការគ្រប់គ្រងនិងបង្កើនលទ្ធភាពបានទទួលបាននូវសម្បត្តិធម្មជាតិដែលមានផលិតភាព*

៣២. ដោយហេតុថាសេដ្ឋកិច្ចរបស់ប្រទេសនៅមិនទាន់ធ្វើពិពិធកម្មហើយកសិកម្ម និងការប្រមូលផល ដោយផ្ទាល់នៃធនធានធម្មជាតិមានលក្ខណៈជាមូលដ្ឋាន ដីធ្លី និងសម្បត្តិធម្មជាតិមានតួនាទីសំខាន់នៅក្នុង ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចរបស់កម្ពុជា។ ជាទូទៅខណៈដែលការអភិឌ្ឍន៍ជនបទ និងការអភិវឌ្ឍន៍ សេដ្ឋកិច្ចតំរូវឱ្យសេដ្ឋកិច្ចកម្ពុជាធ្វើពិពិធកម្មពីសកម្មភាពផលិតកម្ម ដែលមានលក្ខណៈបឋម ក្នុងរយៈពេល ខ្លី និងរយៈពេលមធ្យម ការលើកកំពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជា-ពលរដ្ឋនៅជនបទពឹងផ្អែកយ៉ាងខ្លាំងលើនិន្នាការវិវត្តន៍នៃភាពជាកម្មសិទ្ធ និងលទ្ធភាពបានទទួលដី និងសម្បត្តិ ធម្មជាតិដទៃទៀត។

៣៣. ការប្រមើលមើលទៅអនាគតអំពីការប្រើប្រាស់ដីនិងធនធានធម្មជាតិដែលមាននិរន្តរភាព និងការ លើកកំពស់ជីវភាពនៅជនបទ នឹងពឹងផ្អែកលើគោលនយោបាយនិងបទប្បញ្ញត្តិនានាដែលមានផលប៉ះពាល់ ដល់លទ្ធភាពបានទទួលនិងការគ្រប់គ្រងធនធានសំខាន់ៗ (ដី ព្រៃឈើ ជលផល និងទឹក) ការកំណត់ ទិសដៅជាយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍកសិកម្មនិងឱកាសធ្វើការងារក្រៅពីកសិកម្ម។ ក្នុងចំណោមធនធាន ធម្មជាតិសំខាន់ៗ ទាំង ៤ គឺ ដី ព្រៃឈើ ត្រី និងទឹក គេចាំបាច់ត្រូវមានប្រព័ន្ធគ្រប់គ្រងធនធាននីមួយៗ

ដែលមានលក្ខណៈគន្លឹះ គ្របដណ្តប់លើការវាយតំលៃធនធាន ការបែងចែក និង លទ្ធភាពបានទទួល ការតាមដាន និងការអនុវត្តន៍។ ចំពោះធនធានធម្មជាតិទាំងអស់ ជាទូទៅ ត្រូវមានការវាយតំលៃដែលកាន់តែអាចជឿទុកចិត្តបានអំពីស្ថានភាពធនធានទាំងនោះ ធ្វើជាមូលដ្ឋានគ្រឹះរឹងមាំសំរាប់ធ្វើសេចក្តីសំរេចចិត្តផ្នែកគោលនយោបាយនិងសេចក្តីសំរេចចិត្តផ្នែកគ្រប់គ្រង។ នៅគ្រប់ករណីទាំងអស់ ចំណុចចាប់ផ្តើមសមស្រប ចំពោះការវាយតំលៃបែបនេះគឺការវិភាគអំពីសមត្ថភាពធនធាននោះក្នុងការទ្រទ្រង់ប្រភេទ និងទំហំនៃការប្រើប្រាស់ខុសៗគ្នា ក៏ដូចជាការវាយតំលៃអំពីសមត្ថភាពស្ថាប័ននៅក្នុង អនុវិស័យធនធានធម្មជាតិ ដើម្បីគ្រប់គ្រងការប្រើប្រាស់ទាំងនោះ។

## កំណែទំរង់រដ្ឋបាលដីធ្លី និងកំណែទំរង់ការគ្រប់គ្រងដីធ្លី

៣៤. *វិធាននានាអំពីសិទ្ធិចំពោះដីធ្លីមានការប្រែប្រួលកាលពីពេលថ្មីៗនេះ។* ខ្មែរក្រហមដែលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានធ្វើសមូហកម្មដីធ្លីទាំងអស់ និងបានបំផ្លាញទិន្នន័យដីធ្លី ដោយរាប់ទាំងផែនទីសុរិយោដីនិងកម្មសិទ្ធិដីធ្លីផងដែរ ។របបនេះបានធ្វើឱ្យប្រជាពលរដ្ឋផ្លាស់ទីយ៉ាងខ្លាំងនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដោយបង្ខំឱ្យប្រជាពលរដ្ឋរាប់លាននាក់ ឱ្យចាកចេញពីទីក្រុងនិងទីប្រជុំជន នានាទៅកាន់ជនបទ និងបង្ខំឱ្យចាកចេញពីកន្លែងមួយនៃប្រទេសកម្ពុជាទៅកាន់កន្លែងមួយផ្សេងទៀត។ ប្រជាពលរដ្ឋរាប់ពាន់នាក់ក៏បានឆ្លងកាត់ព្រំដែនផងដែរ ។សិទ្ធិក្នុងការកាន់កាប់ដី ដែលត្រូវបានបង្កើតឡើងវិញនៅឆ្នាំ ១៩៨៩ អនុញ្ញាតឱ្យកសិករកាន់កាប់សិទ្ធិដីស្រែរហូតដល់៥ហិកតា បន្ទាប់ពីការដាំដុះជាបន្តបន្ទាប់ក្នុងរយៈពេល ៥ ឆ្នាំ ហើយផ្តល់ឱ្យគ្រួសារនូវប័ណ្ណកម្មសិទ្ធិលើដីស្នាក់នៅ ដែលមានទំហំរហូតដល់ ២000 ម៉ែត្រការ៉េ។ សិទ្ធិផ្នែកសម្បទានត្រូវបានផ្តល់ចំពោះដីដាំដុះដែលមានទំហំលើស៥ហិកតា។ ដីដែលទុកចោលទំនេរលើសពីបីឆ្នាំត្រូវក្លាយជាកម្មសិទ្ធរបស់រដ្ឋ ។ បន្ទាប់ពីមានការអនុម័តច្បាប់ភូមិបាល គេបានរៀបចំកម្មវិធីមួយសំរាប់ដាក់ពាក្យសុំវិញ្ញាបនប័ត្រកម្មសិទ្ធិដីធ្លី ដើម្បីបញ្ជាក់អំពីសិទ្ធិកាន់កាប់សិទ្ធិ និងសិទ្ធិប្រើប្រាស់។ គេបានដាក់ពាក្យសុំជាង ៤ លានច្បាប់ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ មានតែវិញ្ញាបនប័ត្រកម្មសិទ្ធិដីធ្លីមួយចំនួនតូចតែប៉ុណ្ណោះ ដែលគេបានផ្តល់ ដោយសារសមត្ថភាពមានកំរិតរបស់រដ្ឋាភិបាល។

៣៥. *ក្រសួងគ្រប់គ្រងដែនដីនគរូបនីយកម្មនិងសំណង់ (MLMUPC) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ មានមុខងារចំបងក្នុងការគ្រប់គ្រងដីធ្លី*មមានការដឹកនាំបង្កើតក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគ្រប់គ្រង នឹងការសម្របសម្រួលនូវការកសាងផែនការប្រើប្រាស់ដី ការធ្វើអង្កេតលើការវាស់វែងដីធ្លី និងសុរិយោដី ហើយ ក៏ទទួលខុសត្រូវផងដែរក្នុងការសម្របសម្រួលការចុះបញ្ជី និងការគ្រប់គ្រងដីធ្លីព្រមទាំងការវាយតំលៃ

អចលន វត្ថុផងដែរ។ ការអនុវត្តន៏ជាក់ស្តែងអំពីការចុះបញ្ជីដីធ្លី ការគ្រប់គ្រងលើការទិញលក់ដីធ្លី និងការកសាង ផែនការប្រើប្រាស់ដីធ្លីគឺជាការទទួលខុសត្រូវរបស់មន្ទីរ MLMUPC ខេត្ត-ក្រុង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) មានភារកិច្ចគ្រប់គ្រងដីព្រៃនឹងដីសើម ព្រមទាំងគ្រប់គ្រងសម្បទានកសិកម្ម សម្បទានព្រៃឈើ និងសម្បទានជលផលផងដែរ។

៣៦. *ការវាយតំលៃមួយរបស់ធនាគារពិភពលោកនៅឆ្នាំ ១៩៩៨ បានកំណត់បញ្ហាចំបងចំនួនប្រាំពីរ នៅក្នុងវិស័យដីធ្លី :* (i) មានក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលដីធ្លី និងការគ្រប់គ្រងដីធ្លីមិនគ្រប់គ្រាន់ (ii) កង្វះសមត្ថភាពផ្នែកស្ថាប័ននិងខ្វះធនធានមនុស្សក្នុងការអនុវត្តន៏កម្មវិធីកំណែទំរង់ (iii) កង្វះសុវត្ថិភាព ផ្នែកកម្មសិទ្ធិចំពោះប្រជាពលរដ្ឋភាគច្រើន ដែលធ្វើឱ្យមានការរំលោភយកដីធ្លីពីសំណាក់អ្នកមានអំណាច និងមានវិវាទដីធ្លីយ៉ាងច្រើន (iv) មានក្របខ័ណ្ឌគ្រប់គ្រងមិនគ្រប់គ្រាន់ និងការទទួលខុសត្រូវផ្នែកស្ថាប័ន មិនច្បាស់លាស់ ចំពោះចំណាត់ថ្នាក់និងចំណាត់ថ្នាក់សារឡើងវិញនៃដីធ្លី រួមទាំងនិយមន័យមិនច្បាស់លាស់ អំពីព្រំដែនដីព្រៃ តំបន់ទទួលការការពារ ដីរដ្ឋដទៃទៀត និងដីកសិកម្មផងដែរ-ព្រំដែននៃប្រភេទដីទាំងអស់នេះ ត្រូវបានគេកំណត់លើមូលដ្ឋានដែលគ្មានលក្ខណៈជាប្រព័ន្ធ (v) ការកើនឡើងនូវភាពគ្មានដី ដែលគេប៉ាន់ស្មានថាមានចំនួន១២ទៅ១៣ភាគរយ[២៣] នៃប្រជាពលរដ្ឋនៅជនបទ (vi) គ្មានការរៀបចំគ្រប់គ្រងដោយច្បាប់ទំលាប់និងគ្មានភាពប្រាកដប្រជា អំពីលទ្ធភាពរបស់ប្រជាពលរដ្ឋក្រីក្រក្នុងការទទួលបានសម្បត្តិធម្មជាតិលើដីរបស់រដ្ឋ (vii) ខ្វះបទប្បញ្ញត្តិនិងខ្វះតម្លាភាពនៅក្នុងការផ្តល់សម្បទានសេដ្ឋកិច្ច។

៣៧. *បច្ចុប្បន្ន បញ្ហាទាំងនេះនៅតែជាបញ្ហាកង្វល់ចំបងនៅឡើយ ។ ទោះជាយ៉ាងណាក៏ដោយប្រទេសកម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពយ៉ាងច្រើនក្នុងការដោះស្រាយបញ្ហាមួយចំនួននៃបញ្ហាទាំងអស់នេះ* ជាពិសេស គឺ ការបង្កើតក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគ្រប់គ្រង មុខងារនិងការទទួលខុសត្រូវចំពោះរដ្ឋបាល ដីធ្លីនិងការ

---

[23] CSES–ឆ្នាំ១៩៩៧បងាញថា១៣ភាគរយនៃគ្រួសារនៅជនបទគ្មានដីកសិកម្ម CSES ឆ្នាំ ១៩៩៩ បងាញថាគ្រួសារនៅជនបទដែលគ្មានដីកសិកម្មមានចំនួន ១៥.៨ភាគរយ តាមរយៈប្រើប្រាស់វិធានធ្វើសំណាកអង្កេត LADIT របស់ Oxfam នៅឆ្នាំ២០០០បងាញថា អ្នកគ្មានដីធីមានចំនួន ១២ភាគរយ។ ពតិមានបញ្ជាក់ថ្មីៗដែលគេបានធ្វើសំរាប់ការវាយតំលៃអំពីផលប៉ះពាល់នៃសក្តានុពល សម្បទានដីសង្គមកិច្ច( PSIA 2004 )បានរកឃើញថាអត្រាគ្មានដីធី មានចំនួន១២ភាគរយក្នុងចំណោមក្រុមគ្រួសារនៅជនបទ ។

គ្រប់គ្រងដីធ្លី[២៤] ។ ជាពិសេសគេសង្កេតឃើញវិឌ្ឍនភាពតាមរយៈ : (i) ការបង្កើតក្រសួង គ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់នៅឆ្នាំ ១៩៩៨ ដើម្បីដឹកនាំកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ចំពោះរបៀបវារៈ កំណែទំរង់ដីធ្លី (ii) ការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លីនៅឆ្នាំ ២០០០ ដែលមាន សមាជិកភាព មកពីក្រសួងចំនួន ១៣ ក្នុងការដឹកនាំរៀបចំការបង្កើតគោលនយោបាយដីធ្លី (iii) អនុម័តគោល-នយោបាយ ជាតិស ្តីពីដីធ្លីដោយក្រុមប្រឹក្សារដ្ឋមន្រ ្តីនៅខែ ឧសភា ឆ្នាំ ២០០១ (iv) ការអនុម័តច្បាប់ភូមិបាលថ្មីនៅខែ សីហា ឆ្នាំ ២០០១ និង (v) អនុម័តអនុក្រឹត្យជាច្រើននៅក្រោមច្បាប់ភូមិបាល រួមមាន ការផ ្តល់ប័ណ្ណ កម្មសិទ្ធិដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំ ការចុះបញ្ជីដីធ្លី គណៈកម្មការសុរិយោដីសំរាប់ដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ និងសម្បទានសង្គមកិច្ចសំរាប់ បែងចែកដី ។ នៅមានអនុក្រឹត្យជាច្រើនទៀតដែលគេកំពុងរៀបចំ ហើយរំពឹងថានឹងអនុម័តនៅចុងឆ្នាំ ២០០៤/២០០៥ រួមមានការគ្រប់គ្រងសម្បទានសេដ្ឋកិច្ច ការគ្រប់គ្រងដីរដ្ឋ និងការទទួលស្គាល់ និងការ ចុះបញ្ជីស ិ ្តសិទ្ធិដីធ្លី របស់ជនជាតិដើមភាគតិច ។

៣៨. *ការពង្រឹងសុវត្ថិភាពកម្មសិទ្ធិដីធ្លី និងការពង្រីកការផ ្តល់ប័ណ្ណកម្មសិទ្ធិ* ។ សុវត ្ថិភាពផ្នែកកម្មសិទ្ធិ មានចែងនៅក្នុងបញ្ញត ្តិនៃច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលចែងអំពីការបង្កើតសិទ្ធិផ្នែកកម្មសិទ្ធិ និងបង្កើត មូលដ្ឋាន សំរាប់ប្រព័ន្ធចុះបញ្ជីដីធ្លីទំនើប ។ បញ្ញត ្តិនេះចែងថាសិទ្ធិស ្តីពីកម្មសិទ្ធិអាចទទួលមកដោយផ្ទាល់ពីការ កាន់កាប់ មុនពេលច្បាប់ភូមិបាលត្រូវបានអនុម័ត អាស្រ័យហេតុនេះផ ្តល់ឱ្យអ្នកកាន់កាប់ភាគច្រើន ទទួលបាននូវការការពារតាមផ្លូវច្បាប់ ។ ទន្ទឹមនឹងនេះផងដែរក៏មានការកសាងសមត្ថភាពបន្ថែមសំរាប់ រដ្ឋាភិបាលដីធ្លីដោយមានជំនួយពីប្រទេសផ ្តល់ជំនួយ និងមានវឌ្ឍនភាពមួយចំនួនអំពីការផ ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ព្រមទាំងបានពង្រីកការរៀបចំផែនទីភូមិសាស្រ ្ត និងការផ ្តល់ប័ណ្ណកម្មសិទ្ធិដែលមានលក្ខណៈជាប្រព័ន្ធនៅ ទូទាំងប្រទេសក្នុងរយៈពេល១០ឆ្នាំក្រោយ ប៉ុន្តែ ្តការរីកចំរើនត្រូវបានគេរំពឹងទុកថាមានល្បឿនយឺតក្នុងការ

---

[24] នៅឆ្នាំ ២០០១រដ្ឋាភិបាលបានផ ្តួចផ ្តើម*គំរោងគ្រប់គ្រងដីធ្លី និង រដ្ឋាបាលដីធ្លី* ដែលគាំទ្រដោយធានាគារពិភពលោក ADB និង រដ្ឋាភិបាលហ្វាំងឡង់ និង រដ្ឋាភិបាលអាល្លឺម៉ង់ក្នុងគោលដៅបញ្ចប់នូវក្របខ័ណ្ឌបទបញ្ញត ្តិ បង្កើតស្ថាប័នចុះបញ្ជីដីធ្លីដែលមាននិរន ្តរ — ភាព និង ចេញប័ណ្ណកម្មសិទ្ធប្រហែលមួយលានសន្លឹកនៅឆ្នាំ ២០០៧ ។

ផ ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីចំនួនមួយលានសន្លឹកនៅក្នុងខេត ្តចំនួន ១០ និងនៅរាជធានីភ្នំពេញនៅឆ្នាំ ២០០៧ ជា គោលដៅបច្ចុប្បន្ន។ ការលើកកំពស់ជាក់ស្តែងអំពីសិទ្ធិផ្នែកកម្មសិទ្ធិបន្ថែមទៀត ទាមទារពេលវេលាក្នុងការ បង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត ្តិ រចនាសម្ព័ន្ធស្ថាប័ន និងយន ្តការដោះស្រាយវិវាទ ។ ទោះជា យ៉ាងណាក៏ដោយ ដើម្បីឱ្យទទួលបាននូវផលប្រយោជន៍ពេញលេញពីកំណែទំរង់ទាំងនោះ គេអាចអនុវត្ត អន ្តរាគមន៍ស្របគ្នាដើម្បីសម្រួលកិច្ចអភិវឌ្ឍន៍ទីផ្សារដីធ្លី និងលើកកំពស់លទ្ធភាពបានទទួលឥណទាន ដែល ការធ្វើបែបនេះមានសារៈសំខាន់ណាស់ ។ ប្រការនេះរួមមានការលើកកំពស់បរិយាកាសគោលនយោបាយ ចំពោះទីផ្សារលក់ និងទីផ្សារជួល ដូចជាអនុញ្ញាតឱ្យមានការចុះបញ្ជីអំពីការជួលនៅការិយាល័យសុរិយោដី ការអនុវត្តន៍រចនាសម្ព័ន្ធពន្ធលើកម្មសិទ្ធិ ដើម្បីបន្ថុចបង្អាក់ការទុកដីចោលសំរាប់លក់តម្លើងថ្លៃ ការអនុម័ត ច្បាប់ស ្តីពីប្រត ិបត្តិការដែលមានការធានា និងពង្រឹងវិស័យហិរញ្ញវត្ថុនៅតំបន់ជនបទ ។ នៅពេលដែលគេ មិនអាចទទួលបានឥណទានជាទូទៅ និងនៅពេលគ្មានបណ ្តាញសុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាពនៅ តំបន់ជនបទ អាចមានហានិភ័យដែលថាការផ ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើឱ្យមានបណ្តុំដីធ្លីកាន់តែច្រើន ឡើងៗ ។ វត្តមាននៃទីផ្សារដីធ្លីអនុញ្ញាតឱ្យប្រជាពលរដ្ឋលក់ដីក្នុងករណីដែលគេត្រូវការប្រាក់បន្ទាន់ ករណីនេះក៏អាច ធ្វើឱ្យមានបណ្តុំដីធ្លី ព្រោះថាអ្នកមានលទ្ធភាពបានទទួលឥណទានផ្តល់តំលៃដីកាន់តែ ខ្ពស់ ។

៣៩. ច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងអំពីលទ្ធកម្មដី ។ នៅពេលអនុវត ្តន៍ចំណុចនេះ ម្ចាស់ដីដែលបាន ចុះបញ្ជី ត្រូវមានសិទ្ធនៅក្នុងការបានទទួលសំណង"ដោយត្រឹមត្រូវនិងយុត ្តិធម៌" ។ ក៏ប៉ុន្តែ ្តគេពុំឃើញមាន អនុក្រឹត្យ ឬបទប្បញ្ញត ្តិជាក់លាក់ណាទាក់ទងនឹងលទ្ធកម្មដីធ្លី ឬការតាំងទីលំនៅសារជាថ្មីឡើយ ។ ក្នុងការ អនុវត្តន៍ ជាក់សែ ្តង រដ្ឋច្រើនបានទទួលដីដោយមិនចាំបាច់ផ្តល់សំណង ឬបានទទួលដីតាមរយៈការចរចានៅ មូលដ្ឋាន ដែលគ្មានលក្ខណៈជាប្រព័ន្ធ ។

៤០. *ពង្រឹងការដោះស្រាយវិវាទដីធ្លី ។* ដោយសារភាពកំសោយផ្នែកសមត្ថភាពរបស់តុលាការក្នុងការ ដោះស្រាយបណ្តឹងដីធ្លី គណៈកម្មការជាតិដោះស្រាយវិវាទដីធ្លី និងគណៈកម្មការនានារបស់ខេត ្តត្រូវបាន បង្កើតឡើងនៅចុងឆ្នាំ ១៩៩៩ ដើម្បីដោះស្រាយវិវាទដីធ្លីនៅក្រៅប្រព័ន្ធតុលាការ ។ ច្បាប់ភូមិបាលឆ្នាំ

២០០១ ស្វែងរកការដោះស្រាយចំណុចខ្វះខាតដែលនៅសេសសល់នៅក្នុងប្រព័ន្ធដោះស្រាយវិវាទតាមរយៈការអនុញ្ញាតិឱ្យបង្កើតគណៈកម្មការសុរិយោដីដែលជាប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីដោះស្រាយវិវាទអំពីដីដែលគ្មានកម្មសិទ្ធិ និងផ ្តល់ការការពារចំពោះគ្រួសារនានាដែលពាក់ព័ន្ធជាមួយនឹងករណីរំលោភយកដីធ្លីក្នុងពេលបច្ចុប្បន្ន នៅថ្នាក់ស្រុក ថ្នាក់ខេត ្ត និងថ្នាក់ជាតិ ។ នៅឆ្នាំ ២០០២ គណៈកម្មការសុរិយោដីត្រូវបានបង្កើតដោយអនុក្រឹត្យ ហើយនៅឆ្នាំ ២០០៤ ការិយាល័យគណៈកម្មការសុរិយោដីបានបើកទ្វារ និងមានការបណ ្តុះបណ ្តាលបុគ្គលិកជាច្រើន ។ ទោះបីជាមានការរីកចំរើនអំពីយន ្តការដោះស្រាយវិវាទក ្តី គេមិនអាចកាត់បន្ថយទំនាស់ដីធ្លីឱ្យបានច្រើនដោយគ្មានពត៌មានច្បាស់លាស់ស ្តីពីការប្រើប្រាស់ដី ដោយគ្មានពត៌មានច្បាស់លាស់ស ្តីពីគោលនយោបាយ និងដោយគ្មានពត៌មានច្បាស់លាស់ស ្តីពីបទប្បញ្ញត ្តិស្តីពីការ ចាត់ថ្នាក់ដីធ្លី ដោយកង្វះសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយវិវាទនោះឡើយ ហើយសំខាន់បំផុតគឺការ បោះបង្គោលព្រំដីដែលទាំងអស់គ្នាទទួលស្គាល់ ។

៤១. *ការធ្វើសនិទានកម្មអំពីការចាត់ថ្នាក់ដីធ្លីដើម្បីធ្វើឱ្យការប្រើប្រាស់ធនធានដីធ្លីកាន់តែមានប្រសិទ្ធភាព* **។** ដីនៅប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាដីរដ្ឋ ឬដីឯកជន ដែលដីឯកជនមានត្រឹមតែ ២០% ប៉ុណ្ណោះ ។ ប៉ុន្តែ ្តការបែងចែកដីជាផ្លូវការរវាងឯកជន និងសាធារណៈមានទំនាក់ទំនងតិចតួចប៉ុណ្ណោះចំពោះការប្រើប្រាស់ ដីក្នុងពេលបច្ចុប្បន្ន ឬ មានទំនាក់ទំនងតិចតួចប៉ុណ្ណោះស្របជាមួយដីសំរាប់ការប្រើប្រាស់ជាក់លាក់ផ្សេងៗ ។ ជាលទ្ធផលធ្វើឱ្យមានតំបន់ធំៗជាច្រើនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ទុកដីចោលទំនេរ ប៉ុន្តែដីទាំងនោះមានលក្ខណៈសមស្របសំរាប់ការប្រើប្រាស់របស់ឯកជនហើយមួយចំណែកធំនៃដីសាធារណៈរបស់រដ្ឋដែលស្ថិតនៅក្នុងការការពារ ឬដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋត្រូវបានគេរានដី តាំងទីលំនៅ និងកំពុងត្រូវបានគេប្រើប្រាស់សំរាប់សកម្មភាពកសិកម្ម ។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវធ្វើសនិទានកម្មជាបន្ទាន់អំពីបរិមាណ និងប្រភេទដីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ។ ជាងនេះទៅទៀតគេពុំបានដឹងច្បាស់លាស់អំពីតំបន់ជាក់សែ ្តង ទីតាំង និងព្រំដែនដីរបស់រដ្ឋឡើយ ហើយក៏គ្មានកិច្ចព្រមព្រៀង បច្ចុប្បន្នណាមួយស្តីពីការទទួលខុសត្រូវផ្នែកស្ថាប័នក្នុងការកំណត់ អង្កេត និងបោះបង្គោលកំណត់បរិវេណ ដីរបស់រដ្ឋឡើយ ។ ដីរដ្ឋចែកចេញជាពីរប្រភេទ : "ដីសាធារណៈរបស់រដ្ឋ" និង "ដីឯកជនរបស់រដ្ឋ" ។ ដីសាធារណៈរបស់រដ្ឋគឺគ្រាន់តែជាដីសំរាប់អភិរក្ស និងគ្រប់គ្រង

ដូច្នេះរដ្ឋមិនអាចផ្តល់ឱ្យប្រើប្រាស់ ក្នុង លក្ខណៈជាឯកជនឡើយ ។ ផ្ទុយទៅវិញ ដីឯកជនរបស់រដ្ឋៗអាចធ្វើការបែងចែកឱ្យឯកជនប្រើប្រាស់ និងច្រើនតែផ្តល់ក្នុងរូបភាពជាសម្បទាន ជាជាងការបែងចែកដោយផ្ទាល់តាមរយៈការលក់ ឬការផ្តល់ឱ្យ ត្រង់ៗ ។ អនុក្រឹត្យក្នុងពេលខាងមុខស្តីពី ការគ្រប់គ្រងដីរដ្ឋនឹងផ្តល់ក្របខ័ណ្ឌគ្រប់គ្រងចំពោះការចាត់ថ្នាក់សារជាថ្មី និងការទទួលខុសត្រូវគ្រប់គ្រងដីរដ្ឋ និងបង្កើតជាក្របខ័ណ្ឌច្បាប់ដើម្បីឱ្យមានការទទួលខុសត្រូវផ្នែកស្ថាប័ន សំរាប់អនុវត្តភារកិច្ចទាំងអស់នេះ ។ គេរំពឹងថារដ្ឋាភិបាលរៀបចំនិងអនុម័តអនុក្រឹត្យនេះនៅពាក់កណ្តាលឆ្នាំ ២០០៥ ។ អនុក្រឹត្យនោះនឹងអនុញ្ញាតឱ្យមានការបញ្ជាក់អំពីប្រភេទផ្សេងៗនៃដីឯកជនរបស់រដ្ឋ និងដីសាធារណៈរបស់រដ្ឋ រួមមានដីព្រៃ និងតំបន់ដែលបានទទួលការការពារ ។ ការងារសំខាន់គឺអនុក្រឹត្យនោះនឹងអនុញ្ញាតឱ្យ មានការធ្វើសនិទានកម្មលើបរិមាណនៅក្នុងក្របខ័ណ្ឌសាធារណៈរបស់រដ្ឋ និងការធ្វើចំណាត់ថ្នាក់សារជាថ្មីនៃដី ដែលមិនត្រូវការ ឱ្យមានការគ្រប់គ្រងដែលមានប្រសិទ្ធភាពដោយផ្តល់ដីសំរាប់ការប្រើប្រាស់ដទៃទៀត ។

៤២. *ការផ្តល់សនិទានកម្មចំពោះសម្បទានសេដ្ឋកិច្ច ។* ច្បាប់ភូមិបាលឆ្នាំ ២០០១ អនុញ្ញាតឱ្យមានសម្បទានដីកសិកម្ម ដែលនៅកម្ពុជាគេស្គាល់ជាទូទៅថាជាសម្បទានសេដ្ឋកិច្ច ដែលត្រូវផ្តល់សំរាប់ធ្វើកសិកម្ម ដើម្បីយកផលិតផលលក់ឱ្យទីផ្សារអន្តរជាតិ និងទីផ្សារក្នុងស្រុក ។ ចាប់តាំងពីការចាប់ផ្តើមកម្មវិធីនេះមក បរិមាណដីសរុបចំនួន ៨២៧, ២៨៦ ហិកតា ត្រូវបានគេផ្តល់ជាដីសម្បទានកសិកម្ម ។ ទោះជាយ៉ាងនេះក្តី គិតត្រឹមខែសីហា ឆ្នាំ ២០០២ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទបានដកយកមកវិញនូវដីសម្បទាន សរុបចំនួន ១០៣,៦៨០ ហិកតា ដោយរក្សាទុកនូវដីសម្បទានចំនួន ២៦ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ៧២៣,៦០៦ ហិកតា ជាដីសម្បទាន ក្នុងខណៈដែលក៏រឹតកំណត់តាមផ្លូវច្បាប់ ចំពោះដីសម្បទានកសិកម្ម មានទំហំ ១០,០០០ ហិកតាក្តី ជាងពាក់កណ្តាលផ្ទៃដីសម្បទានដែលមានទំហំ ៤៦៣,៦០៦ ហិកតា មានទំហំលើសពីក៏រឹតកំណត់ដោយច្បាប់។ អាស្រ័យហេតុនេះ តំរូវឱ្យមានការធ្វើសនិទានកម្មជាបន្ទាន់បរិមាណ និងប្រភេទដីសម្បទានសេដ្ឋកិច្ច ។

៤៣. *ក្នុងការអនុវត្តន៍ជាក់ស្តែងសម្បទានសេដ្ឋកិច្ចមួយផ្នែកធំត្រូវបានផ្តល់ជាដីព្រៃ* ហើយទោះបីជាការព្យួរសម្បទានលើការកាប់ឈើបានចូលជាធរមានចាប់តាំងពីឆ្នាំ២០០២លើដីព្រៃដទៃទៀតក្តី ល័ក្ខខ័ណ្ឌ

សម្បទាន សេដ្ឋកិច្ចអនុញ្ញាតឱ្យកាប់ដើមឈើនៅក្នុងតំបន់សម្បទាន។ ជាងនេះទៅទៀតនៅលើដីសម្បទានមួយចំនួន ការកាប់ដើមឈើធម្មជាតិនៅក្នុងតំបន់សម្បទានគឺជាសកម្មភាពតែមួយគត់ ដែលគេអនុវត្តន៍នៅក្នុងសម្បទាន ធ្វើឱ្យមានការព្រួយបារម្ភថាសម្បទានសេដ្ឋកិច្ចត្រូវបានគេប្រើប្រាស់សំរាប់ជៀសវាងការហាមឃាត់ចំពោះការកាប់ឈើនិងការការពារថ្មីៗ និងការការពារថ្មីៗសំរាប់ពិនិត្យមើលសារឡើងវិញនិងសំរាប់បែងចែកព្រៃសម្បទាន[២៥]។ មានតំរូវការជាបន្ទាន់ឱ្យដំណើរការនេះមានលក្ខណៈជាប្រព័ន្ធ និង មានតម្លាភាព លើរបៀបវាយតំលៃនិងផ្តល់សម្បទានសេដ្ឋកិច្ច ដោយអនុវត្តន៍នូវប្រព័ន្ធពិនិត្យមើលសារឡើងវិញម៉ត់ចត់នឹងបើកចំហដែលមានលក្ខណៈដូចគ្នានឹងប្រព័ន្ធដែលគេកំពុងប្រើប្រាស់ចំពោះសម្បទានព្រៃឈើ។

៤៤. *ទន្ទឹមនិងនេះផងដែរទោះបីជាសនិទានភាពមួយ ក្នុងចំណោមសនិទានភាពនានាចំពោះសម្បទានដីកសិកម្មគឺបង្កើតប្រាក់ចំណូលចំពោះរដ្ឋក្តី ក្នុងការអនុវត្តន៍ជាក់ស្តែង សម្បទានសេដ្ឋកិច្ចពុំបានផ្តល់ប្រាក់ចំណូលច្រើនដល់រដ្ឋាភិបាលឡើយ* ។មានមូលហេតុជាច្រើនចំពោះបញ្ហានេះ។ ទី ១ ទោះបីជាពន្ធសួយសារត្រូវយកពីការកាប់ឈើដែលទាក់ទងនឹងការរានដីក្តី មានទឹកប្រាក់តិចតួចតែប៉ុណ្ណោះដែលបានប្រមូលព្រោះថាមូលនិធិដើមឈើឈរនៅក្នុងតំបន់សម្បទានពុំមានការរៀបចំជាឯកសារ ហើយបរិមាណដើមឈើដែលគេកាប់ក៏មិនត្រូវបានគេតាមដានប្រកបដោយប្រសិទ្ធភាពឡើយ។ ទី ២ ដោយហេតុថាពន្ធសួយសារចំពោះសម្បទានសេដ្ឋកិច្ចត្រូវបានគេគណនាលើមូលដ្ឋាននៃផលិតកម្ម ហើយដីសម្បទានភាគច្រើនដែលគេមិនបានប្រើប្រាស់សំរាប់កសិកម្ម ត្រូវបានគេប៉ាន់ស្មានថាមានចំនួន ៦៤១.៥០០ ហិកតា ធ្វើឱ្យគេអាចប្រមូលប្រាក់ចំណូលបានតិចតួចប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវពិនិត្យមើលមូលដ្ឋាននៃការគណនាប្រាក់ចំណូលសារជាថ្មី និងពង្រឹងប្រព័ន្ធប្រមូលចំណូលនឹងគណនេយ្យកម្ម។

៤៥. *បញ្ហាសំខាន់មួយក្នុងចំណោមបញ្ហាសំខាន់នានាគឺគំរូសំរាប់កាត់បន្ថយសម្បទាន។* ការងារនេះកំពុងប្រព្រឹត្តទៅ គឺជាផ្នែកមួយនៃការរៀបចំអនុក្រឹត្យសម្បទានសេដ្ឋកិច្ច ដើម្បីបញ្ជាក់អំពីវិធីកាត់បន្ថយសម្បទាន ដែលទទួលការគាំទ្រពី ADB ។

៤៦. *ការដោះស្រាយបញ្ហាគ្មានដីធ្លី តាមរយៈការបែងចែកដី ។* ទោះបីជាមានការបែងចែកដីនៅឆ្នាំ ១៩៨៩ ក្តី ចំនួនគ្រួសារនៅជនបទដែលគេមិនទទួលស្គាល់លទ្ធភាពក្នុងការប្រើប្រាស់ដីធ្លី បានកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ។ តាមន័យសេដ្ឋកិច្ច នៅកម្ពុជាភាពគ្មានដីធ្លីមានលក្ខណៈគួរឱ្យកត់សំគាល់ ដោយសារគេមិនបានធ្វើពិពិធកម្មសេដ្ឋកិច្ច។ នៅជនបទដោយមានជំរើសតិចតួចអំពីឱកាស

---

[25] កំណត់សំគាល់របស់អ្នកបកប្រែៈ ឃ្លាដើមទំនងជាបាត់កិរិយាស័ព្ទ Require

ការងារក្រៅពីកសិកម្ម លទ្ធភាពនៅក្នុងការមានដីសំរាប់ផលិតកម្មកសិកម្មជីវព្រឹត្ត និងលទ្ធភាពក្នុងការបានទទួលធនធាន ដទៃទៀតសំរាប់ប្រមូលផលដោយផ្ទាល់*ក្នុងពេលបច្ចុប្បន្ននេះ* គឺបណ្តាញសុវត្ថិភាពសង្គមតែមួយគត់ ចំពោះគ្រួសារនៅជនបទក្នុងរយៈពេលខ្លី។ មូលហេតុមួយផ្នែកនៃការកើតឡើងនូវហេតុការណ៍នៃភាពគ្មានដីធ្លីគឺបណ្តាលមកពីការបង្ខំចិត្តលក់ដី ឬការលក់ដីដោយសារការរងសំពាធនានា និងដោយសារការដកហូតកម្មសិទ្ធិ ពីផ្នែកយោធានឹងពីអ្នកដែលមានទំនាក់ទំនងផ្នែកនយោបាយ[26]។ សមាមាត្រគួរឱ្យកត់សំគាល់នៃគ្រួសារ ដែលពុំដែលមានដីធ្លី ឆ្លុះបញ្ចាំងឱ្យឃើញនូវការកើនឡើងនៃសំពាធប្រជាសាស្ត្រមកលើដីធ្លីនៅតំបន់ដែល មានដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់។ ភាពគ្មានដីធ្លីកើតមានច្រើនបំផុតក្នុងចំណោមគ្រួសារដែលមានស្ត្រីជា មេគ្រួសារតែម្នាក់ (២១.២%)។ ភាពគ្មានដីធ្លីនេះ បានជំរុញឱ្យចំនួនគ្រួសារជាច្រើនចាកចេញពីភូមិស្ថាន របស់ខ្លួន[27]។

៤៧. *ដើម្បីដោះស្រាយបញ្ហាគ្មានដីធ្លី ច្បាប់ភូមិបាលឆ្នាំ២០០១ មានបញ្ញត្តិចែងអំពី "សម្បទានសង្គមកិច្ច"* គឺថាផ្តល់អំណោយដីឯកជនរបស់រដ្ឋចំពោះគ្រួសារនានាក្នុងគោលបំណងសង្គមកិច្ច ដែលគេអាចប្រើប្រាស់សំរាប់ដាំដុះ ឬស្នាក់នៅ (ជំពូកទី២ មាត្រា១៧ ជំពូកទី៥ មាត្រា៤៨-៦២ )។ អនុក្រឹត្យដែលលំអិតអំពី ការធ្វើសម្បទានសង្គមកិច្ចបានទទួការឯកភាពពីក្រុមប្រឹក្សារដ្ឋមន្ត្រី ក្នុងខែ មិនា ឆ្នាំ ២០០៣។ មាន សនិទានភាពផ្នែកសង្គមយ៉ាងច្រើន ក្នុងការផ្ទេរសិទ្ធអាស្រ័យផលនិង/ឬការផ្ទេរកម្មសិទ្ធិដីមិនប្រើប្រាស់ ទាំងនេះទៅឱ្យគ្រួសារគ្មានដី ហើយគេបានប៉ាន់ស្មានថាជាមធ្យោបាយមួយមានសារៈសំខាន់ក្នុងការកាត់បន្ថយ ភាពក្រីក្រ។ កម្មវិធីនេះនឹងអនុញ្ញាតឱ្យប្រែក្លាយដីដែលគេមិនប្រើប្រាស់ជាច្រើនឱ្យទៅជាដីផលិតកម្ម ដែលនឹងធ្វើឱ្យប្រជាពលរដ្ឋក្រីប្រានទទួលអត្ថប្រយោជន៍ដោយផ្ទាល់។ ប៉ុន្តែដូចដែលការបែងចែកដីនៅកម្ពុជា មុននេះបានបង្ហាញយ៉ាងដូច្នេះថា ការបែងចែកដីតែមួយមុខគឺគ្រាន់តែជាដំណោះស្រាយប្រសើរបំផុតដែល មានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ។ ប្រទេសកម្ពុជាមានមានប្រជាជនក្មេងយ៉ាងច្រើនដែលរង់ចាំចូលទៅក្នុងកំលាំងពលកម្ម ដែលនឹងកើនឡើងយ៉ាងរហ័សហើយដែលដំណោះស្រាយបែបនេះមិនអាចរ៉ាប់រងបាន។ អាស្រ័យហេតុនេះ ដើម្បីឱ្យកម្មវិធីសម្បទានមានសនិទានភាពសង្គមកិច្ចរឹងមាំ នឹងឱ្យមានលក្ខណៈប្រសើរជាងបណ្តាញសុវត្ថិភាពសង្គមបណ្តោះអាសន្ន កម្មវិធីនេះចាំបាច់ត្រូវជួយអ្នកទទួលផល ឱ្យចាកផុតពី អាជីវកម្មកសិកម្មជីវព្រឹត្ត និងប្រែក្លាយដីរដ្ឋដែលនៅទំនេរ ឱ្យទៅជាដីដែលមានផលិតភាពខ្ពស់ បង្កើន

---

[26] ក្នុងចំណោមដីដែលគេបានដកហូត ភាគីនានាដែលទទួលខុសត្រូវមានជាអាទិ៍ : យោធា (៣៦ % ) អាជ្ញាធរខេត្ត (៣៦%) កម្មសិទ្ធិករដើម(១៣%) អាជ្ញាធរមូលដ្ឋាន(១២%) សាច់ញាតិ(២%) និងអ្នកដទៃទៀត (LADIT, 2002)

[27] ភាពគ្មានដីធី និងមធ្យោបាយអភិវឌ្ឍន៍ពតិមាន ( LADIT ) ឆ្នាំ២០០០

ផលិតកម្មនិងផលិតភាពជាតិនិងផ្តល់ជាចលករសំរាប់ឱ្យមានកំណើននៅជនបទទូទៅ និងដើម្បីបង្កើតឱកាសការងារ។

៤៨. *គេមិនរំពឹងថាដីឯកជនរបស់រដ្ឋទាំងអស់នឹងត្រូវបែងចែកទៅឱ្យអ្នកកាន់កាប់ដីតូចៗឡើយ ប៉ុន្តែជាការរួមបន្សំនៃសម្បទានសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចដែលគ្រប់គ្រងបានល្អគឺជាប្រការសមស្រប។* មុខងារសមស្របរបស់សម្បទានសេដ្ឋកិច្ច កំពុងត្រូវបានគេពិនិត្យម៉ត់ចត់ គឺជាផ្នែកមួយនៃឯកសារសាវតារពាក់ព័ន្ធសំរាប់រៀបចំគោលនយោបាយ កំពុងស្ថិតនៅក្នុងដំណាក់កាលនៃការរៀបចំអនុក្រឹត្យសម្បទានសេដ្ឋកិច្ច។ ការងារថ្មីៗដែលគេបានធ្វើដើម្បីវាយតំលៃភាពក្រីក្រ និងវាយតំលៃផលប៉ះពាល់សង្គមនៃសំណើកម្មវិធីសម្បទានដីសង្គមកិច្ច បានបង្ហាញថាកាលពីពេលថ្មីៗ ដីកសិកម្មល្អមួយចំនួនតូច ត្រូវបានគេទុកចោលទំនេរ និងអាចយកមកបែងចែកបាន[28] ។ ប្រភពដីដែលអាចយកមកបែងចែកនៅក្នុងសម្បទានសង្គមកិច្ច រួមមាន : សម្បទានព្រៃដែលគេបានលុបចោល នឹងតំបន់ដទៃទៀតនៃដីព្រៃដែលគ្មានការគ្រប់គ្រង ដែលមិនទាមទារឱ្យមានការគ្រប់គ្រងព្រៃ ឬមិនតំរូវឱ្យមានការការពារផ្នែកបរិស្ថាន ហើយមានលក្ខណៈសមស្របសំរាប់ផលិកម្ម សម្បទានសេដ្ឋកិច្ចដែលគេលុបចោល ចំណែកដីតូចៗរបស់រដ្ឋនៅក្នុងឃុំនានា តំបន់សាធារណៈដទៃទៀតរបស់រដ្ឋ ដែលថ្មីៗនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងាររដ្ឋាភិបាល រួមមាន កងទ័ព និងដីដែលបានមកតាមរយៈការអនុវត្តន៍មាត្រាទី ១៨ នៃច្បាប់ភូមិបាល ។ ដោយហេតុថាដីដែលត្រូវធ្វើការបែងចែក ចាំបាច់ត្រូវធ្វើចំណាត់ថ្នាក់ជាមុនទៅជាដីកសិកម្ម ឬដីនៅតំបន់ទីប្រជុំជន ជាដំបូងរដ្ឋាភិបាលចាំបាច់ត្រូវអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ដែលបង្កលក្ខណៈឱ្យមានការធ្វើចំណាត់ថ្នាក់ដីសារជាថ្មី នឹងចែងអំពីការផ្តល់ដី ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋផ្សេងៗ។ ទន្ទឹមនឹងនេះដោយហេតុថា ផ្ទៃដីជាច្រើនដែលមាលក្ខណៈសមស្របសំរាប់ការបែងចែកក្នុងពេលបច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុងសម្បទានសេដ្ឋកិច្ច អំពីទំហំតាមច្បាប់ និង/ឬ សម្បទានសេដ្ឋកិច្ចដែលមិនដំណើរការ ជាការសំខាន់ណាស់ដែលរដ្ឋាភិបាលត្រូវអនុម័តអនុក្រឹត្យស្តីពីសម្បទានសេដ្ឋកិច្ច ដើម្បីសំរួលការលុបចោលសម្បទានទាំងនេះ និងបង្កលក្ខណៈក្នុងការបែងចែកដីធ្លី ដែលបានមកពីការលុបចោលសម្បទាន។ អាស្រ័យហេតុនេះអនុក្រឹត្យពីរដែលបំរុងចេញ ស្តីពីសម្បទានសេដ្ឋកិច្ច និងស្តីពីការគ្រប់គ្រងដីរដ្ឋ មានសារៈ-សំខាន់ដើម្បីធានាឱ្យការអនុវត្តន៍កម្មវិធីសម្បទានដីសង្គមកិច្ចទទួលជោគជ័យ។ ភាពដំណើរការបាននៃកម្មវិធីសម្បទានដីសង្គមកិច្ចអាស្រ័យលើឆន្ទៈនយោបាយរបស់រដ្ឋាភិបាលក្នុងការអនុម័តនិងអនុវត្តន៍អនុក្រឹត្យទាំងនេះក៏ដូចជាអនុវត្តន៍ច្បាប់ភូមិបាលឱ្យមានប្រសិទ្ធភាពផងដែរ។

---

[28] សេចក្តីព្រាងស្តីពីការវាយតំលៃសក្តានុពលផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ច ( PSIA ឆ្នាំ 2004 ) ធនាគារពិភពលោក

៤៩. *នៅក្នុងវិសាលភាពទូទៅ សម្បទានសង្គមកិច្ចត្រូវបានគ្រោងលើមូលដ្ឋាននៃការបែងចែកដីរដ្ឋដែលទំនេរ ដូច្នេះកម្មវិធីនេះមិនប្រឈមមុខនឹងបញ្ហាលទ្ធកម្មដីធ្លីដែលត្រូវចំណាយច្រើននោះឡើយ។* ទោះជាយ៉ាងនេះក្តី ដើម្បីឱ្យការបែងចែកដីតាមរយៈសម្បទានសង្គមកិច្ចផ្តល់ជីវភាព ដែលមាននិរន្តរភាពដល់អ្នកទទួលផល និងបង្កើនផលិតផលកសិកម្ម ចាំបាច់ត្រូវមានការវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់ ផលិតភាព (ការគ្រប់គ្រងទឹក ផ្លូវថ្នល់) ការផ្ទេរបច្ចេកវិទ្យា ការលើកកំពស់ការចូលទៅកាន់ទីផ្សារ និង ហេដ្ឋារចនាសម្ព័ន្ធសង្គម។ ការវិភាគជំហានដំបូងអំពីសក្តានុពលផលប៉ះពាល់មកលើភាពក្រីក្រនៃនៃការបែងចែកដីធ្លី អះអាងចំពោះការសង្កេតពីបណ្តាប្រទេសដទៃ ដែលថាផលប៉ះពាល់ទាំងអស់លើភាពក្រីក្រ នៃការបែងចែកដីមួយមុខមានកំរិតតិចតួចទេ (Auffret ឆ្នាំ 2003)។ ទោះជាយ៉ាងនេះក្តី ការវិនិយោគបំពេញបន្ថែមចំពោះហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងសេវាគាំទ្រផ្នែកបច្ចេកទេសជួយបង្កើនឥទ្ធិពលមកលើភាពក្រីក្រ។ ដើម្បីវាយតំលៃអំពីភាពធ្វើបាន និងវាយតំលៃអំពីនិរន្តរភាពសំរាប់រយៈពេលវែងនៃកម្មវិធីមួយ ការវាយតំលៃអំពីការចំណាយ និងផលដែលបានទទួលនៃកញ្ចប់គាំទ្រខុសគ្នាៗ មានសារៈសំខាន់ណាស់។ ជាងនេះទៅទៀត កត្តាដែលមានសារៈប្រយោជន៏មួយទៀតសំរាប់ធានាឱ្យកម្មវិធីបែងចែកដីសង្គមកិច្ចមានជោគជ័យ គឺការដាក់បញ្ចូលនូវវិធានការជាក់លាក់ដើម្បីដោះស្រាយហានិភ័យអភិបាលកិច្ចបច្ចុប្បន្ន និងឧបសគ្គផ្នែកសមត្ថភាព។ ការវាយតំលៃផលប៉ះពាល់មកលីភាពក្រីក្រនឹងមកលើសង្គមនៃកម្មវិធីបែងចែកដីធ្លីដែលកំពុងដំណើរការជាការសិក្សាមានដៃគូចំរុះ គប្បីផ្តល់នូវការយល់ដឹងបន្ថែមទៀតអំពីភាពធ្វើបាន និងគំរូនានានៃកម្មវិធីបែបនេះ។ ការងារកំពុងអនុវត្តចំពោះការរៀបចំ ការសិក្សារចនាសម្ព័ន្ធដីធ្លីនៅឆ្នាំ ២០០៥-២០០៦ (ធនាគារពិភពលោក) នឹងផ្តល់ពត៌មានបន្ថែម ចំពោះការរៀបចំសំណើកម្មវិធីបែងចែកដីសង្គមកិច្ច។

## អនុសាសន៏ស្តីពីសកម្មភាពអាទិភាពសំរាប់កំណែទំរង់រដ្ឋបាល និងការគ្រប់គ្រងដីធ្លី

៥០. សកម្មភាពជាអាទិភាពខាងក្រោមនេះជាអនុសាសន៏សំរាប់ផ្តល់សនិទានភាពអំពីលទ្ធភាព និងការបែងចែកដី លើកកំពស់សុវត្ថិភាពកម្មសិទ្ធដីធ្លី និងជំរុញកិច្ចអភិវឌ្ឍន៏ជនបទ:

### អាទិភាពទី ១ ពង្រឹងការគ្រប់គ្រងដីធ្លីតាមរយៈកិច្ចប្រឹងប្រែងសម្របសម្រួលអន្តរក្រសួង

ការគ្រប់គ្រងដីធ្លីរួមមានការធ្វើចំណាត់ថ្នាក់ និងចំណាត់ថ្នាក់ដីសារឡើងវិញរវាងដីប្រភេទផ្សេងៗគ្នា ការកសាងផែនការប្រើប្រាស់ដី ការបែងចែកជាតំបន់ និងការត្រួតពិនិត្យលើការគ្រប់គ្រងលើការប្រើប្រាស់ដី ។ ធាតុសំខាន់ៗនៃការគ្រប់គ្រងដីធ្លីដែលត្រូវការសំរេចបាននូវគោលដៅជាបន្ទាន់ទាំងនេះរួមមានៈ

- *បង្កើនល្បឿនការអនុវត្តន៍បញ្ចប់អនុក្រឹត្យសំរាប់អនុវត្ត ច្បាប់ភូមិបាលឆ្នាំ ២០០១ ។* អនុក្រឹត្យទាំងនេះ រួមមានៈ (ក) ត្រូវអនុម័តនៅពាក់កណ្តាលឆ្នាំ ២០០៥: (i) អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និង (ii) ការគ្រប់គ្រងសម្បទានសេដ្ឋកិច្ច និង (ខ) ត្រូវអនុម័តចុងឆ្នាំ ២០០៥: អនុក្រឹត្យស្តីពី ការទទួលស្គាល់ និងការចុះបញ្ជីសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ។
- *ធ្វើសនិទានភាពប្រព័ន្ធចំណាត់ថ្នាក់ដីធ្លី ។* អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរបស់រដ្ឋដែលចេញក្នុងពេលខាងមុខស្ថិតនៅក្រោមច្បាប់ភូមិបាលឆ្នាំ ២០០១ និងផ្តល់នូវក្របខ័ណ្ឌគ្រប់គ្រងសំរាប់ការធ្វើចំណាត់ថ្នាក់ នឹងធ្វើចំណាត់ថ្នាក់សារឡើងវិញនៃដីរដ្ឋរវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ និងដាក់ចេញនូវ និតិវិធីចំពោះការផ្ទេរសិទ្ធ និងការបញ្ចេញដីរបស់រដ្ឋ ។ នេះគ្រាន់តែជាជំហ៊ានទីមួយ និងជាការអនុវត្តន៍អនុក្រឹត្យនេះតែប៉ុណ្ណោះដែលតំរូវឱ្យមានការផ្តោតការយកចិត្តទុកដាក់ និងត្រូវការជំនួយឧបត្ថមគាំទ្រយ៉ាងច្រើន ។
- *ពង្រឹងការកសាងផែនការប្រើប្រាស់ដី ។* ប្រការនេះរួមមានការសម្របសម្រួលការកសាងផែនការស្តីពី ការប្រើប្រាស់ដីជាមួយនឹងផែនការអភិវឌ្ឍន៍សង្គមកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិ វិមជ្ឈការនៃការគ្រប់គ្រងដីនិងសមត្ថកិច្ចកសាងផែនការ កិច្ចអភិវឌ្ឍន៍ផែនការប្រើប្រាស់ដីសំរាប់តំបន់អាទិភាព ។ ការកសាងផែនការប្រើប្រាស់ដីគប្បីស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលមានការគាំទ្រពី MLMUPC និងការគាំទ្រពីភ្នាក់ងារដទៃទៀត ។
- *ការអនុវត្តន៍សាកល្បងនូវសម្បទានសង្គមកិច្ច និងវាយតំលៃភាពដែលអាចធ្វើបាន ដើម្បីដំណើរការអនុវត្តកម្មវិធីសម្បទានសង្គមកិច្ចពេញលេញ រួមមានការបែងចែកដី និងសេវាគាំទ្រពាក់ព័ន្ធដទៃទៀត ។* ការអនុវត្តន៍គំរោងសាកល្បងចាប់ផ្តើមនៅក្នុងស្រុកបួនខុសៗគ្នានៅចុងឆ្នាំ ២០០៣ ។

កម្មវិធីបែងចែកដី នឹងធ្វើការបែងចែកដីឯកជនរបស់រដ្ឋដែលនៅទំនេរឱ្យគ្រួសារដែលត្រូវបានកំណត់ថាមានតំរូវការជា អាទិភាពចំពោះសម្បទានដីសង្គមកិច្ច ។ ដើម្បីសំរេចបាននូវអត្ថប្រយោជន៍នៃសម្បទានដីសង្គមកិច្ច គេចាំបាច់ត្រូវផ ្តល់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមកិច្ច ការបណ ្តុះបណ ្តាល និងកិច្ចអភិវឌ្ឍន៍សហគ្រាស ដល់អ្នកទទួលផលពីការបែងចែកដី[២៩] ។ ការងារនេះតំរូវឱ្យមានវិធីសាស្រ ្តដែលមានការសម្របសម្រួល និងមានធនធានច្រើនពីរដ្ឋាភិបាល និងពីអ្នកផ ្តល់ជំនួយ។ ការបែងចែកដីនៅក្នុងកម្មវិធីសម្បទាន សង្គមកិច្ច តំរូវឱ្យអនុវត ្តមាត្រាទី ១៨ នៃច្បាប់ភូមិបាល និងអនុវត ្តអនុក្រឹត្យស ្តីពីការគ្រប់គ្រងដីរដ្ឋ និងសម្បទានសេដ្ឋកិច្ចផងដែរ ។

- *ការធ្វើសនិទានកម្មនៃប្រព័ន្ធសម្បទានសេដ្ឋកិច្ច ជលផល និងព្រៃឈើ ។* ជាវិធីសាស្រ ្តមួយដែលមានការសម្របសម្រួល និតិវិធីវាយតំលៃ និងផ ្តល់ការឯកភាពជាស ្តង់ដារ និងបង្កើនការប្រមូលប្រាក់ចំណូល ព្រមទាំងលើកកំពស់កិច្ចប្រតិបត ្តិលើការងារគ្រប់គ្រង ដែលគប្បីអនុវត ្តនៅក្នុងប្រភេទសម្បទាន ផ្សេងៗ ។

## អាទិភាពទី ២ ពង្រឹងរដ្ឋបាលដីធ្លីដើម្បីបង្កើនសុវត្ថិភាពកម្មសិទ្ធដីធ្លី និងគាំទ្រកិច្ចអភិវឌ្ឍន៍ទីផ្សារដីធ្លីឱ្យមានប្រសិទ្ធភាព

គោលដៅគោលនយោបាយរួមគឺការបញ្ជាក់ឱ្យបានច្បាស់ និងកត់ត្រាកម្មសិទ្ធ និងសិទ្ធិដទៃទៀតអំពីកម្មសិទ្ធិទាំងអស់(សាធារណៈ និងឯកជន) ស្របតាមច្បាប់ភូមិបាល ។

- *ពង្រីកតំបន់ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការផ ្តល់ប័ណ្ណកម្មសិទ្ធ និងការចុះបញ្ជីដីធ្លីឱ្យមានលក្ខណៈជាប្រព័ន្ធ ។* ចំណុចនេះគប្បីរួមមានការចេញប័ណ្ណកម្មសិទ្ធចំនួន ១ លានសន្លឹកគ្រោងផ្តល់ឱ្យរហូតដល់ឆ្នាំ ២០០៧ ក៏ដូចជាការទទួលស្គាល់សិទ្ធប្រើប្រាស់ដីឃុំដែលមានលក្ខណៈជាពិសេសចំពោះតំបន់ខ្ពង់រាប ។
- *ពង្រឹង និងរៀបចំមុខងារនៃការិយាល័យចុះបញ្ជីដីធ្លី* ដើម្បីបង្កលក្ខណៈឱ្យមានការចុះបញ្ជីការទិញលក់ដីធ្លីឱ្យមានតម្លាភាព និងមានប្រសិទ្ធភាព ។

---

[29] កំណត់សំគាល់របស់អ្នកបកប្រែៈ អ្នកបកប្រែបកតាមការយល់ឃើញរបស់ខ្លួន ព្រោះគិតថាសំណៅដើមសរសេរខុសក្បួនវេយ្យាករណ៍

- *បង្កើត និងអនុវត្តយុទ្ធសាស្រ្តប្រឆាំងអំពើពុករលួយ* ដោយផ្តោតការយកចិត្តទុកដាក់លើការរៀបចំផ្តល់ ប័ណ្ណកម្មសិទ្ធដីក្នុងលក្ខណៈដាច់ដោយដុំដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធតាមតំរូវការ និងលុបបំបាត់ការបង់ប្រាក់ ក្រៅផ្លូវការ បង្កើត អនុវត្ត និងតាមដានស្តង់ដារសេវាអប្បបរមា និងពង្រឹងការតាមដានផ្ទៃក្នុងអំពី អំពើពុករលួយ និងការប្រព្រឹត្តខុសឆ្គងផ្សេងៗ ។
- *ពង្រឹងការដោះស្រាយវិវាទដីធ្លី* ។ គាំទ្រការអនុវត្តន៍ និងតាមដានលទ្ធផលអនុវត្តន៍នៃគណៈកម្មការ សុរិយោដីនានា ។
- *ពិនិត្យមើលសារឡើងវិញ និងកែសម្រួលការផ្ទេរបចេទាសម្ព័ន្ធដីនិងពន្ធដីធ្លី* លើការផ្តល់កម្មសិទ្ធដីក្នុង លក្ខណៈដាច់ដោយដុំ លៃយ៉ាងណាឱ្យមានការចូលរួមពេញលេញក្នុងការចុះបញ្ជីដីធ្លី ។

- ក៏មានតំរូវឱ្យមានផងដែរនូវសកម្មភាពបំពេញបន្ថែមនៅក្នុងផ្នែកបីដទៃទៀត លៃយ៉ាងណាឱ្យ អត្ថប្រយោជន៍នៃការផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លីអាចអនុវត្តបាន ។ ប្រការទាំងនេះរួមមានៈ (i) គាំទ្រចំពោះ ការរៀបចំបទប្បញ្ញត្តិស្តីពីប្រតិបត្តិការដែលមានកាធានា (ii) ពង្រឹងវិស័យហិរញ្ញវត្ថុដើម្បីបង្កលក្ខណៈ ឱ្យប្រើប្រាស់ប័ណ្ណកម្មសិទ្ធដីធ្លីធ្វើជាវត្ថុបញ្ចាំ និង (iii) កំណែទំរង់តុលាការដើម្បីបង្កលក្ខណៈឱ្យមាន ដំណោះស្រាយវិវាទដីធ្លីនៅក្នុងប្រព័ន្ធតុលាការដែលកាន់តែមានលក្ខណៈសមស្រប ។

## កំណែទំរង់លើការគ្រប់គ្រងព្រៃឈើ

៥១. *គេបានប៉ាន់ស្មានថាព្រៃរបស់កម្ពុជាមានទំហំប្រហែល ១១,១ លានហិកតា*[30] ត្រូវជា ៦១% នៃផ្ទៃដីសរុប(សូមអានផែនទីនៅក្នុងឧបសម្ព័ន្ធទី២)។សួនឧទ្យាននិងតំបន់ដែលទទួលការការពារមានទំហំ ៣.៣ លានហិកតា ត្រូវជាមួយភាគប្រាំនៃផ្ទៃដីសរុប ផ្ទៃដីនេះភាគច្រើនជាព្រៃ ប៉ុន្តែគុណភាពនៅក្នុងការគ្រប់គ្រង និងកំរិតនៃការការពារធនធាននៅមានកំរិតទាប។ កាលពីឆ្នាំ ១៩៩៩ ពីទំហំផ្ទៃដីព្រៃសម្បទានចំនួន ៦,៨ លានហិកតា រដ្ឋាភិបាលបានកាត់បន្ថយមកត្រឹមប្រមាណជា ៣,១ លានហិកតា។ អង្កេតឆ្នាំ២០០២របស់ GTZ បានរកឃើញថានៅទូទាំងប្រទេស មាននៅសល់ព្រៃឈើតិចតួច និងមានប្រភេទឈើគុណភាពមិនល្អ គ្រប់ដណ្តប់លើផ្ទៃដីប្រហែល ៨០.០០០ហិកតា ដែលគេទទួលស្គាល់ថាជាព្រៃសហគមន៍ ។ ដីព្រៃនៅសល់ប្រមាណជា ៥ លានហិកតា ស្ថិតនៅក្នុងក្របខ័ណ្ឌសាធារណៈ ជាដីព្រៃដែលគ្មានការគ្រប់គ្រង ឬគ្មានការការពារប្រកបដោយប្រសិទ្ធភាពឡើយ។

៥២. *វិស័យព្រៃឈើមានសក្តានុពលយ៉ាងច្រើន ក្នុងការរួមវិភាគទានប្រកបដោយនិរន្តរភាពចំពោះកិច្ចអភិវឌ្ឍន៍ជនបទនិងជីវភាពរស់នៅជនបទនៅប្រទេសកម្ពុជា* ដោយផ្ទាល់និងប្រយោល ។ ការរួមវិភាគទានដោយផ្ទាល់រួមមានៈការបង្កើនចំណូលសាធារណៈអំពីការធ្វើអាជីវកម្មព្រៃឈើ និងធនធានដទៃទៀតដែលមានការគ្រប់គ្រង ការបង្កើនប្រាក់ចំនូលនិងការប្រើប្រាស់របស់គ្រួសារដែលមានប្រភពមកពីផលិតផលដើមឈើនិងអនុផលព្រៃឈើ(NTFPs)[31] និងការបង្កើនឱកាសការងារនិងប្រាល់ចំណូលពី ការកែច្នៃផលិតផលព្រៃឈើ ។ ដីព្រៃក៏អាចរួមវិភាគទានចំពោះកិច្ចអភិវឌ្ឍន៍ជនបទតាមរយៈ ការបំលែងដីដោយមានផែនការច្បាស់លាស់ទៅជាការប្រើប្រាស់ដទៃទៀតដែលផ្តល់ផលិតភាព លើសពីតំរូវការឱ្យមានការគ្រប់គ្រងព្រៃឈើឱ្យមានប្រសិទ្ធភាព ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយក្នុងពេលបច្ចុប្បន្ន ការរៀបចំបទប្បញ្ញត្តិនិងការរៀបចំគ្រប់គ្រងមានកំរិតខ្សោយ តំរូវឱ្យមានការពង្រឹងឱ្យបានខ្លាំងក្លាដើម្បីបង្កលក្ខណៈ

---

[30] ការពិនិត្យមើលវិស័តព្រៃឈើ ក្នុងលក្ខណៈឯករាជ្យ ឆ្នាំ២០០៤ ។

[31] ស្របជាមួយនិងប្រទេសនានាដែលមានកំរិតអភិវឌ្ឍន៍ដូចគ្នា គឺចូលរួមវិភាគទានជាចំណែកមួយយ៉ាងធំនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជនបទដែលរស់នៅជិតតំបន់ព្រៃឈើ ។ អុស និងធ្យូង គឺ ជាប្រភពផ្គត់ផ្គង់ថាមពលដល់គ្រួសារនៅជនបទ ការប្រម៉ាញ់ និងនេសាទនៅតាមដងព្រៃជាសកម្មភាពចំពោះគ្រួសារទូទៅនៅជនបទនៅតាបតំបន់ដងទនេហើយការដងជ័រត្រូវបានគេគិតថាជាប្រភពប្រាក់ចំណូលចំបង(គេប៉ាន់ស្មានថាជ័រចំនួន២០.០០០តោនត្រូវបានគេដងជារៀងរាល់ឆ្នាំដែលមានតំលៃប្រហែលជា៦លាដុលា)ចំពោះប្រមាណជា ១០០.០០០គ្រួសារដែលរស់នៅតាមដងព្រៃ។

:(i) បង្កើនការរួមវិភាគទាននៃវិស័យនេះចំពោះចំណូលសាធារណៈនិងជីវភាពជនបទតាមបែបមួយ ដែលមាននិរន្តភាព (ii) រក្សានូវតំលៃអេកូឡូស៊ី[32]និងតំលៃវប្បធម៌នៃសម្បត្តិព្រៃឈើ ។

៥៣. *ការបំលែងព្រៃឈើនិងកិច្ចអភិវឌ្ឍន៍ដីធ្លី ភាគច្រើនគ្មានការកសាងផែនការនិងគ្មានការគ្រប់គ្រង* ។ របកគំហើញនៃឯកសារឯករាជ្យអំពីពិនិត្យមើលសារឡើងវិញលើវិស័យព្រៃឈើ[33] ប៉ាន់ស្មានថាការកាប់ព្រៃឈើ ប្រចាំឆ្នាំមានអត្រា១% ដែលការខាតបង់ប្រមូលផ្តុំនៅតំបន់សំខាន់៧មួយចំនួន( នៅតំបន់ពាយ័ព្យក្បែរព្រំដែន ថៃ នៅរតនៈគីរី នៅតាមផ្លូវជាតិលេខ៤ នៅតាមមាត់សមុទ្រ នៅតាមព្រៃលិចទឹក នឹងនៅជុំវិញបឹងទន្លេសាប) ដែលបណ្តាលមកពីការការកាប់ឈើដោយខុសច្បាប់ និងគ្មានការហាមឃាត់ ក៏ដូចជាការប្រែក្លាយដីព្រៃជាបន្តបន្ទាប់មកជាការប្រើប្រាស់សំរាប់វិស័យកសិកម្មរាប់ទាំងខុសច្បាប់ និងស្របច្បាប់ ។ តំបន់ព្រៃរបស់កម្ពុជាគឺជាសំណល់ដែលគ្មានការ គ្រោងទុកនៃមរតកធម្មជាតិរបស់កម្ពុជា ការកាប់ឈើដោយខុសច្បាប់ និងការកើនឡើងឥតឈប់ឈរនូវការ តាំងទីលំនៅផ្នែកកសិកម្ម។ ការរំលោភបំពានជាច្រើនរបស់កសិករច្រើនកើតមានបន្ទាប់ពីការកាប់ឈើដោយខុសច្បាប់ ដែលស្ថានភាពនេះជាទូទៅ គឺជាការគំរាមគំហែងធំបំផុតចំពោះធនធានព្រៃឈើ ប៉ុន្តែការបំលែងនេះក៏មានទំរង់ជាការអភិវឌ្ឍន៍ដាំដំណាំឧស្សាហកម្ម ដែលរដ្ឋាភិបាលបានអនុញ្ញាត តាមរយៈសម្បទានដីធ្លី សេដ្ឋកិច្ចដែលមានទំហំធំល្វឹងល្វើយ។ ក្នុងខណៈដែលដីព្រៃជាច្រើនទំនងជាមានសក្តានុពលសំរាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាពសំរាប់កសិកម្ម និងសំរាប់ប្រើប្រាស់ក្នុងគោលដៅដទៃទៀត ក្នុងពេលបច្ចុប្បន្នការប្រែក្លាយដីបែបនេះកំពុងបង្កើតជាបញ្ហា ព្រោះថាតំបន់ដែលមានសក្តានុពលសមស្របចំពោះកសិកម្មមិនត្រូវបានគេវាយតំលៃ ឬគ្មានការកំណត់អត្តសញ្ញាណ ហើយ

---

[32] សេវាបរិស្ថានជាពិសេសការគ្រប់គ្រងផ្លូវទឹកនិងការអភិរក្សដីនិងទឹកជាផ្នែកមួយនៃភាពស្មុគស្មាញនៃអត្ថប្រយោជន៍ផ្សេងៗ ដែលមានប្រភពមកពីព្រៃ ។ទោះបីជាមានសំណើរនៅក្នុងសារពត៌មានដែលមានប្រជាប្រិយនិងសំណើរមកពីប្រភពដទៃដែលថាការកាប់ព្រៃឈើគឺ ជាការបំផ្លាញប្រភពធនធានទឹកនៅកម្ពុជាក្តី ជាពិសេសទន្លេសាបការវិភាគរបស់គណៈកម្មាការទន្លេមេគង្គការកកដីមិនធ្វើអោយ ផ្ទៃបឹងខូចខាតឡើយ ហើយផ្ទៃបឹងក៏មិនកាយជារាក់ដែរ។

[33] នៅក្នុងឆ្នាំ ២០០៣គណៈកម្មាការចំរុះរបស់រដ្ឋាភិបាល ទីភ្នាក់ងារផ្តល់ជំនួយនិងអង្គការ ក្រៅរដ្ឋាភិបាលបានបង្កើត ក្រុមអ្នកជំនាញការឯករាជមួយដើម្បីពិនិត្យមើលបទពិសោធអំពីវិស័យព្រៃឈើនៅកម្ពុជានិងជាពិសេសពិនិត្យមើលមុខងារដែលមានលក្ខណៈផ្ទុយគ្នា អំពីមុខងាររបស់ធនាគារពិភពលោកក្នុងការគាំទ្រការធ្វើកំណែទំរង់សម្បទានព្រៃឈើ និង ក្នុងការអនុវត្តន៍ច្បាប់ព្រៃឈើ។ "ការពិនិត្យមើលឡើងវិញនៃវិស័យព្រៃឈើក្នុងលក្ខណៈឯករាជ " មានបំណងផ្តល់នូវយថាទស្សន៍អំពីបញ្ហាប្រឈមចំពោះវិស័យនេះនឹង ភាពគ្រប់គ្រាន់នៃតុល្យភាព និង ទំហំកម្មវិធីកំណែទំរងប្ញ្ញូក្រាមដែលបានអនុវត្តន៍ដោយរដ្ឋាភិបាល ។ការពិនិត្យមើលឡើងវិញនេះដែលបានបញ្ចប់ នៅឆ្នាំ២០០៤ ត្រូវបានគេរំពឹងថាផ្តល់ជាចំនុចចាប់ផ្តើមមួយសំរាប់ការពិភាក្សាគោលនយោបាយ នៅវិស័យព្រៃឈើបន្ថែមទៀត។

គ្មាននីតិវិធី ឬគ្មានការបង្កើតផែនការណាមួយសំរាប់គ្រប់គ្រងការបំលែងដីព្រៃទៅរកការប្រើប្រាស់ដទៃទៀត ដែលធានាបំរើផលប្រយោជន៍សាធារណៈ ត្រូវបានគេអនុវត្តន៍ប្រកបដោយតម្លាភាព និងតាមរយៈបែបបទគ្រប់គ្រងដីធ្លីល្អប្រសើរនោះឡើយ ។

៥៤. *ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចគ្រប់គ្រងដីព្រៃ ព្រមទាំងគ្រប់គ្រងសម្បទានកសិកម្ម និងគ្រប់គ្រងព្រៃឈើ* ។ ច្បាប់ព្រៃឈើឆ្នាំ ២០០២ ចែងអំពីរដ្ឋបាលព្រៃឈើនៅក្នុង (ក្រសួងកសិកម្ម) រួមមានរចនាសម្ព័ន្ធផ្ទាល់ តាមខ្សែបណ្ដោយចែកជាថ្នាក់កណ្ដាល អគ្គារធិការដ្ឋានប្រចាំតំបន់ អង្គភាព ផ្នែក និង ពូក ។ គំរូនេះមានមូលដ្ឋានលើគំរូនៃបទពិសោធន៍ក្រោយអាណានិគម ហើយមានបំណងអនុញ្ញាតអោយ មានការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពនៃដែនដីព្រៃរបស់ជាតិ ដោយមានការជ្រៀតជ្រែកក្នុងកំរិត អប្បបរមាពីសំណាក់អាជ្ញាធរមូលដ្ឋាន ។ ខ្សែបន្ទាត់រចនាសម្ព័ន្ធគ្រប់គ្រងតែមួយនេះត្រូវបានបង្កើតនៅក្នុង សេចក្ដីប្រកាសរបស់ក្រសួងកសិកម្ម សំរាប់អនុវត្តលំអិតនៅឆ្នាំ ២០០៣ ។ រដ្ឋបាលព្រៃឈើក៏ជាទីភ្នាក់ងារ ចំបងមួយដែលមានភារៈកិច្ចរកអោយឃើញ និងតាមដានការកាប់ឈើដោយខុសច្បាប់ ។នេះគឺជាការពង្រឹកការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានរបស់ខ្លួន ហើយដែលអនុលោមតាមកិច្ចប្រតិបត្តិអន្តរជាតិ ។

៥៥. *បញ្ហាអភិបាលកិច្ចដែលទាក់ទងនឹងការកាប់ឈើដោយខុសច្បាប់នៅកម្ពុជាបានបង្កើនការទាក់ទាញការយកចិត្តទុកដាក់ជាងការយកចិត្តទុកដាក់លើលក្ខណៈដទៃទៀតនៃវិស័យនេះ* ។ ខណៈដែលវិស័យព្រៃឈើប្រឈមមុខនឹងបញ្ហាអភិបាលកិច្ចជាច្រើន ដូចជាលាភការផ្នែកមុខងារសាធារណៈ គណនេយ្យភាព និងលទ្ធផលអនុវត្តន៍ គឺជាកត្តាដូចគ្នាដែលវិស័យដទៃទៀតប្រឈមមុខដូច្នោះដែរ បញ្ហាដទៃទៀតមានលក្ខណៈពិសេសចំពោះវិស័យព្រៃឈើ ឧទាហរណ៍បញ្ហាស្ដីពីការអនុវត្តន៍ច្បាប់ ការយល់ដឹងអំពីអន្តរវិស័យ និងបញ្ហា ជាក់លាក់អំពីការតាមដានដែលមានលក្ខណៈឯករាជ្យ ។ ការកាប់ឈើខុសច្បាប់ដែលកើតមាននៅគ្រប់កន្លែងដោយមានល្បិចកលយ៉ាងច្បាស់ពីមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល នៅពាក់កណ្ដាលទសវត្សរ៍ ១៩៩០ ធ្វើឱ្យវិស័យព្រៃឈើរបស់កម្ពុជាស្ថិតក្រោមការគ្រប់គ្រងជាចំបងរបស់សហគមន៍អន្តរជាតិ ហើយដាក់បញ្ហាព្រៃឈើជាចំណុចស្នូលនៃការពិភាក្សាអំពីអភិបាលកិច្ចនិងកិច្ចអភិវឌ្ឍន៍ ។ តួលេខប៉ាន់ស្មានអំពីអត្រាកាប់ឈើដោយខុសច្បាប់នៅទសវត្សរ៍ ១៩៩០ បង្កការភ័យខ្លាចអំពីលទ្ធភាពនៃការបាត់បង់សក្តានុពលភាពពាណិជ្ជកម្មនៃមូលដ្ឋានធនធានក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ ។ វិធានការក្ដៅនៅចុងទសវត្សរ៍

១៩៩០ និង ដើមទសវត្សរ៍នេះទំនងជាបានទទួលជោគជ័យមួយផ្នែក ប៉ុន្តែទំហំនៃបញ្ហាដែលនៅសេសសល់ពុំមានការវាស់ស្ទង់ឡើយ ។

៥៦. *វត្តមាននៃអ្នកតាមដានឯករាជ្យ ជាមុខងារថ្មីមួយដែលបំពេញ ដោយអ្នកម៉ៅការឯកជន (SGS ) ជួយធ្វើឱ្យរដ្ឋបាលព្រៃឈើមានវិន័យនៅក្នុងមុខងារមួយដែលពោរពេញទៅដោយគ្រោះថ្នាក់ផ្នែកស្មារតី* ។ ជាគោលការណ៍ការកាប់ឈើខុសច្បាប់ក៏ចំណុះលើបញ្ញត្តិច្បាប់ដទៃទៀតរបស់កម្ពុជាផងដែរ (ឧទាហរណ៍ បញ្ញត្តិស្តីពីការលួចកម្មសិទ្ធអ្នកដទៃ) ដែលស្ថិតនៅក្នុងសមត្ថកិច្ចឯករាជ្យរបស់ស្ថាប័នដទៃទៀត ដូចជា ក្រសួង មហាផ្ទៃជាដើម ។ អាជ្ញាធរយោធានិងនគរបាលបានចូលរួមក្នុងការបង្ក្រាប ការដកហូតបរិក្ខារបំរើឱ្យការកាប់ឈើ និង សកម្មភាពដទៃទៀត ប៉ុន្តែការសម្របសម្រួលរវាងក្រសួងអំពីការអនុវត្តន៍ច្បាប់ព្រៃឈើប្រព្រឹត្តទៅដោយគ្មានលក្ខណៈជាប្រព័ន្ធ ហើយមានអប្រសិទ្ធភាពយ៉ាងខ្លាំង ។

៥៧. *កំណែទំរង់សម្បទានព្រៃឈើចាំបាច់ត្រូវរំពឹងគិតអំពីភាពខុសគ្នានិងបញ្ហាផ្សេងៗ រវាងការរៀបចំ និង ការអនុវត្តន៍ ។* នៅពាក់កណ្តាលទសវត្សរ៍ ១៩៩០ ដោយមានការរៀបចំមិនបានគ្រប់គ្រាន់ ប្រទេសកម្ពុជាបានប្រកាសអនុវត្តន៍យុទ្ធសាស្ត្រសម្បទានព្រៃឈើ លើមូលដ្ឋាននៃការយល់ដឹងមិនបានត្រឹមត្រូវ គ្មានវិន័យដែលសម្បទានឡើងដល់កំរិតខ្ពស់អតិបរមាគ្របដណ្តប់លើផ្ទៃព្រៃ ៦,៨ លានហិកតា ដែលរួមមានធនធានដើមឈើដែលមានតំលៃពាណិជ្ជកម្ម និងរួមមានផងដែរនូវដីដទៃទៀតដែលពុំមានលក្ខណៈសមស្របសំរាប់ធ្វើអាជីវកម្មពាណិជ្ជកម្ម ។ ដោយមានការផ្តល់ការឧបត្ថម្ភគាំទ្រពីអ្នកផ្តល់ជំនួយ ប្រព័ន្ធនេះបានកាត់បន្ថយជាបណ្តើរៗ ហើយបច្ចុប្បន្ននេះមានសម្បទានចំនួនប្រហែល១២ គ្របដណ្តប់លើផ្ទៃដីតិចជាង ៣,១៤ លានហិកតា ។ ទន្ទឹមជាមួយគ្នានេះ រដ្ឋាភិបាលបានចាប់ផ្តើមដាក់ឱ្យមានប្រព័ន្ធគ្រប់ជ្រុងជ្រោយមួយសំរាប់រៀបចំការកសាងផែនការនិងប្រតិបត្តិការសម្បទាន ។ ដូចដែលបានគ្រោង បញ្ញត្តិទាំងនេះដោះស្រាយនូវវិសាលភាពពេញលេញនៃកិច្ចប្រតិបត្តិទំនើបអំពីការដាំដុះព្រៃឈើ រួមមានវិធីសាស្ត្រដាំដុះ និងគ្រប់គ្រងព្រៃឈើ សារពើភ័ណ្ឌ និងការវាយតំលៃធនធាន ការរៀបចំប្លង់វិស្វកម្ម និងការការពារសង្គមនិងបរិស្ថាន ។ កាលពីពេលថ្មីនេះ ប្រតិបត្តិការសម្បទានស្របច្បាប់ត្រូវបានផ្អាក ក្នុងខណៈដែលផែនការ និងដំណើការផ្តល់ការ ឯកភាពកំពុងត្រូវបានអនុវត្តន៍សាកល្បង ។ តាមពិតប្រព័ន្ធថ្មីទាំងនេះបានរួមវិភាគទានក្នុងការធ្វើឱ្យប្រព័ន្ធសម្បទានចុះថយ ជាលទ្ធផលល្អស្របតាមការចំណាយ និងផ្តល់គុណភាពចំពោះការអនុវត្តន៍ ។ ប៉ុន្តែនៅពេលដែលប្រតិបត្តិការចាប់ដំណើរការ ហើយភាពចំរុះបែបនៃការត្រួតពិនិត្យបញ្ហាកើនឡើង បុគ្គលិកនៅមូលដ្ឋានមួយចំនួនធំចូលរួមនៅក្នុងការត្រួតពិនិត្យសម្បទាន ហើយលទ្ធផលជាដុំកំភួននៃប្រព័ន្ធសម្បទានកើនឡើង ។ នៅត្រង់នេះ ជាការត្រឹមត្រូវក្នុងការរំពឹងថាមានបញ្ហា និងកង្វះខាតបន្ថែមរវាងគំរោងនិងការ

អនុវត្តន៍ ។ គេចាំបាច់ត្រូវរំពឹងទុកជាមុននូវបញ្ហាទាំងអស់នេះ ហើយដោះស្រាយវាតាមរយៈជំនួយបច្ចេកទេសដែលកំពុងដំណើរការ លៃយ៉ាងណាឱ្យមានតម្លាភាពកាន់តែច្រើន និង ប្រឹងប្រែងបោះផ្សាយស្តង់ដារ ដំណើរការផ្តល់ការឯកភាព និង ល័ក្ខខ័ណ្ឌផ្តល់ការអនុញ្ញាតិ ។

៥៨. *ការគ្រប់គ្រងសម្បត្តិព្រៃឈើទូទៅ ចាំបាច់ត្រូវឱ្យមានលក្ខណៈទំនើបបន្ថែមទៀត ហើយត្រូវញែកពីគ្នាវវាងដីព្រៃដែលមានអត្ថប្រយោជន៍ចំពោះជាតិនិងតំបន់ដទៃទៀត* ។ ជាទូទៅ ការគ្រប់គ្រងដីព្រៃជាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងដំណើរការអភិវឌ្ឍន៍គោលនយោបាយជាតិដែលមានប្រសិទ្ធភាពស្តីពីដីធ្លី និងបរិមាណសម្បត្តិព្រៃឈើដែលចាំបាច់ត្រូវធ្វើសនិទានភាព ដោយពិចារណាអំពីសមត្ថភាពធនធានដែលមាននិងសមត្ថភាពគ្រប់គ្រងស្ថាប័ន។ ការគ្រប់គងធនធានព្រៃនៅកម្ពុជា ចាំបាច់ត្រូវមានលក្ខណៈកាន់តែទំនើបចាំបាច់ត្រូវត្រួតពិនិត្យ និងរៀបចំជាឯកសារ ។ ដោយមិនទាក់ទងជាមួយទិសដៅនិងផលិតផលនៃការគ្រប់គ្រង ( ដើមឈើ ជ័រចុង សត្វព្រៃ បរិស្ថាន ។ល ។) ឬមិនទាក់ទងនឹងបែបផែននៃការគ្រប់គ្រង( សម្បទានសហគមន៏ ស្ថាប័នសាធារណៈ) រដ្ឋាភិបាលចាំបាច់ត្រូវកំណត់ស្តង់ដារសំរាប់ *អធិប្បាយ ពិគ្រោះ ដោះស្រាយព្យាករណ៏ វាយតំលៃ និងរៀបចំជាឯកសារ*) ហើយនាយកគ្រប់គ្រងនីមួយៗត្រូវអនុវត្តន៏។ ការបំលែងដីព្រៃដែលនៅសេសសល់ឱ្យទៅជាការប្រើប្រាស់សមស្របដទៃទៀត គឺជាអត្ថប្រយោជន៍សាធារណៈ។ ភាគច្រើននៃសម្បត្តិព្រៃឈើសាធារណៈផ្លូវការ មិនត្រូវបានអង្កេត នឹងមិនបានចុះបញ្ជីសារពើភ័ណ្ឌឡើយ ប៉ុន្តែតាមការពិតមានព្រៃឈើតែមួយផ្នែកតូចប៉ុណ្ណោះដែលតំណាងអត្ថប្រយោជន៍ជាតិពិតប្រាកដ និងមានលទ្ធភាពក្នុងការគ្រប់គ្រងលើសពីគោលដៅគ្រប់គ្រងនៅមូលដ្ឋាន។ ជាងនេះទៅទៀតដីព្រៃភាគច្រើនពុំមាននៅក្នុងផែនការសមស្របណាមួយឡើយក្នុងខណៈដែលរដ្ឋបាលព្រៃឈើបានដាក់វិធានការដើម្បីលៃយ៉ាងណាឱ្យសម្បត្តិសម្បទានដែលនៅសេសសល់បានទទួលការគ្រប់គ្រងសមស្រប គេសឹងតែមានចន្លោះប្រហោងអំពីគោលនយោបាយនិងការគ្រប់គ្រងតំបន់ព្រៃដទៃទៀត ជាពិសេសតំបន់ព្រៃដែលស្ថិតនៅក្រៅដែនការពារ ។ រដ្ឋបាលព្រៃឈើ ដែលត្រូវបានរៀបចំជារចនាសម្ព័ន្ធកាលពីពេលថ្មីៗនេះ មិនទំនងជាមានលទ្ធភាពគ្រប់គ្រងប្រកបដោយ ប្រសិទ្ធភាពចំពោះផ្ទៃដីធំទូលាយនេះឡើយ ហេតុនេះធនធាននិងសមត្ថភាពតិចតួច ដែលរដ្ឋបាលព្រៃឈើមាន គប្បីផ្តោតទៅលើដីព្រៃតូចៗតាមអនុផ្នែកដែលមានសារៈសំខាន់សំរាប់ប្រយោជន៍ជាតិជាពិសេសគឺតំបន់សម្បទាន និងតំបន់មួយចំនួនដែលមានព្រៃឈើមានតំលៃខ្ពស់។

៥៩. *តំបន់ព្រៃដែលពុំមានលក្ខណៈសមស្របសំរាប់ការបំលែងទៅជាការប្រើប្រាស់ដទៃ ការរៀបចំផ្នែករដ្ឋបាលលើវិស័យព្រៃឈើ ចាំបាច់ត្រូវអភិវឌ្ឍន៍បន្ថែមទៀតដើម្បីអនុញ្ញាតឱ្យមានការចូលរួមពីមូលដ្ឋាន*

*ឱ្យបានកាន់តែទូលាយក្នុងការងារគ្រប់គ្រងព្រៃឈើ* ។ មានតំរូវការអោយបង្កើតយន្តការគ្រប់គ្រងព្រៃឈើតាមជំរើសដទៃដោយផ្តល់អោយសហគមន៍ នូវលទ្ធភាពគ្រប់គ្រងព្រៃឈើកាន់តែធំ រាប់ទាំងឈើដែលមានតំលៃខ្ពស់ផងដែរ ។ ក្នុងករណីនេះរដ្ឋបាលព្រៃឈើមានអាណត្តិស្របច្បាប់ ពេញលេញអាចធ្វើសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន លើការងាររៀបចំចាត់ចែងគ្រប់គ្រងប្រកប ដោយគំនិតច្នៃប្រឌិតដែលផ្តល់ឱកាសដល់អាជ្ញាធរមូលដ្ឋានផ្តួចផ្តើមគំនិត និងទទួលស្គាល់ផលប្រយោជន៍ នៃបែបបទគ្រប់គ្រងដោយនិរន្តរភាព ។ ជំរើសមួយត្រូវបានផ្តល់ តាមរយៈអនុក្រឹត្យសហគមន៍ព្រៃឈើ ដែលក្រុមប្រឹក្សារដ្ឋមន្ត្រីបានឯកភាពកាលពីខែធ្នូឆ្នាំ២០០៣ បង្កើតជានិតិវិធីផ្តល់ឱ្យសហគមន៍មូលដ្ឋានមានសិទ្ធក្នុងការត្រួតពិនិត្យគ្រប់គ្រងនិងមានភារកិច្ចត្រួតពិនិត្យ តាមរយៈការដាក់បទប្បញ្ញត្តិស្តីលើព្រៃឈើដែល ពួកគេពឹងអាស្រ័យនិងមានលទ្ធភាពក្នុងការបង្ហាញនូវការត្រួតពិនិត្យនិងសមត្ថភាពរបស់ខ្លួន ។ ការអភិវឌ្ឍន៍ បន្ថែមទៀតនៃការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន និងការសំរេចចិត្ត តំរូវឱ្យមានការធ្វើប្រតិភូកម្មនៃសមត្ថកិច្ច និងការកំណត់ន័យនៃប្រព័ន្ធត្រួតពិនិត្យនិងថ្លឹងថ្លែងរវាងអាជ្ញាធរមូលដ្ឋាននិងអាជ្ញាធរជាតិ ។ ក្នុងពេលបច្ចុប្បន្នច្បាប់កម្ពុជាស្តីពីព្រៃឈើពុំមានមូលដ្ឋានច្បាស់លាស់សំរាប់បង្កើតចំណងទាក់ទងបែបនេះឡើយ ។ ប៉ុន្តែ នៅក្នុងក្របខ័ណ្ឌនៃគោលការណ៏និងបុព្វសិទ្ធិដែលបានបង្កើទនៅក្នុងច្បាប់ស្តីពីរដ្ឋបាលនិងការគ្រប់គ្រងឃុំសង្កាត់[34] មានការអនុញ្ញាតិឱ្យធ្វើដូច្នេះ ។

៦០. *ការរៀបចំសហគមន៍ព្រៃឈើតាមរយៈសហគមន៍មូលដ្ឋាន បានទទួលការពង្រឹងផ្នែកសិទ្ធិអំណាចក្នុងការគ្រប់គ្រងដីព្រៃ ដែលជាសម្បត្តិសាធារណៈ ទទួលបាននូវការលើកទឹកចិត្តតាមរយៈសិទ្ធិរក្សាទុកនូវព្រៃឈើដែលជាប្រភពប្រាក់ចំណូលមួយផ្នែកធំ បានអនុវត្តនៅប្រទេសកម្ពុជា* ។ តួលេខប៉ាន់ស្មានអំពីចំណងទាក់ទង នៃការគ្រប់គ្រងសហគមន៍ចំពោះធនធានព្រៃឈើរបស់កម្ពុជាមានភាព ខុសគ្នាៗយ៉ាងខ្លាំង ។ ថ្មីៗនេះផ្ទៃដីតិចជាង ១០០.០០០ ហិកតា ( ប្រមាណជា ៨០.០០០ ហិកតា នៅចុងឆ្នាំ ២០០២) ស្ថិតនៅក្នុងការគ្រប់គ្រងជាផ្លូវការរបស់សហគមន៍ ។ ក្នុងខណៈដែលវិសាលភាពសំរាប់ពង្រីកមានទំហំធំ ហើយទំហំនៃសហគមន៍ព្រៃឈើគប្បីពង្រីកផ្អែកលើនិតិវិធីដែលមានលក្ខណៈសាមញ្ញតាមដែលអាចធ្វើបាន និងគំរោងទទួលការគាំទ្រពីម្ចាស់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាល តាមពិតទៅ តាមបញ្ញត្តិនៃអនុក្រឹត្យឆ្នាំ ២០០៣

---

[34] ជំពូកនៃច្បាប់នេះ( ជាពិសេសមាត្រា៤២-៤៧) ចែងថាប្រតិភូកម្មនៃមុខងារ ឬ ក៏ធ្វើប្រតិភូកម្មនៃសមត្ថកិច្ចចំពោះមុខងារ ជាក់លាក់ពីសំណាក់អាជ្ញាធររបស់រដ្ឋទៅកាន់ក្រុមប្រឹក្សាឃុំ ។រីឯមាត្រា៤៥ ចែងថាក្រុមប្រឹក្សាឃុំពុំមានសមត្ថកិច្ចក្នុងការសំរេចចិត្តចំពោះបញ្ហា ព្រៃឈើដោយខ្លួនឯងឡើយ មាត្រា៤២និង៤៣អនុញ្ញាត្តិអោយមានការផ្តល់អោយ ឬក៏ធ្វើប្រតិភូកម្មទៅអោយ ក្រុមប្រឹក្សាឃុំពីសំណាក់រដ្ឋបាលព្រៃឈើ ។ទន្ទឹមនិងនេះដែរមាត្រា៤៧ចែងថាក្រសួងមហាផ្ទៃអាចចេញអនុក្រឹត្យ ប្រសិនបើការបញ្ជាក់អំពីមុខងារស្នូល ឬ មុខងារដែលបានធ្វើប្រតិភូកម្មចំពោះក្រុមប្រឹក្សាឃុំមានការចាំបាច់ ។

ស្តីពីសហគមន៍ព្រៃឈើ មានតែធនធានមួយផ្នែកតូចនៃធនធានព្រៃឈើសរុបប៉ុណ្ណោះ ដែលអាចដាក់ឱ្យសហគមន៍គ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពនៅក្នុងអនាគតដ៏ខ្លីខាងមុខ។ ពេលវេលាចាំបាច់សំរាប់បង្កើតសមាគមសហគមន៍ព្រៃឈើឱ្យបានត្រឹមត្រូវ ចំណាយនៃការផ្តល់សេវានិងជំនួយបច្ចេកទេស និងភាពបន្ទាន់នៃការគំរាមគំហែងដែលតំបន់ទាំងនេះប្រឈមមុខ តំរូវឱ្យចាត់វិធានការបន្ទាន់ ដើម្បីផ្តល់នូវការការពារនិងរគ្រប់គ្រង។ ការអនុវត្តន៍សាកល្បងរបស់សហគមន៍ព្រៃឈើក្នុងពេលបច្ចុប្បន្ន (ជាង៤០០សហគមន៍) ការអនុម័តអនុក្រឹត្យស្តីពីព្រៃឈើ និងការរំពឹងអំពីការលុបចោលនូវសម្បទានព្រៃឈើជិត២លានហិកតា បង្កើតឱ្យមានដំណាក់មួយសំរាប់សក្តានុពលភាពនៃការពង្រីកផ្ទៃព្រៃ ដែលគ្រប់គ្រងដោយសហគមន៍នៅកម្ពុជា។ មកទល់នឹងបច្ចុប្បន្ននេះ សហគមន៍ព្រៃឈើត្រូវបានបង្កើតនៅក្នុងតំបន់ដែលមានព្រៃរិចរិល និងបង្កើទនៅក្នុងតំបន់ដែលមានដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់ ជុំវិញតំបន់ទន្លេសាបនឹងទៅតាមតំបន់ទន្លេមេគង្គផ្នែកខាងក្រោម។ សក្តានុពលក្នុងការដាក់បញ្ចូលតំបន់ដែលមានបរិមាណដើមឈើច្រើនបន្ថែមទៀត គឺតំបន់ដែលមានប្រជាពលរដ្ឋតិច ដែលទើបតែចាប់ផ្តើមពិនិត្យស្រាវជ្រាវនៅខេត្តរតនៈគីរី ។ ប្រការនេះបង្ហាញថារដ្ឋបាលព្រៃឈើគប្បីត្រៀមលក្ខណៈក្នុងការកសាងសមត្ថភាពនិងរចនាសម្ព័ន្ធសំរាប់ផ្តល់សេវា ផ្តល់ការសិក្សាផ្នែកបច្ចេកទេស និងផ្តល់ការគាំទ្រខាងផ្នែកសំភារៈ តាមរយៈរចនាសម្ព័ន្ធដែលតំរង់ទិសទៅរកមូលដ្ឋានរួមមានព្រៃឈើនៅកំរិតឃុំ និងអង្គភាពកសិកម្មព្រមទាំងសមាគនសហគមន៍ព្រៃឈើ។

៦១. *ក្នុងចំណោមលទ្ធភាពដទៃទៀតដែលអាចពិចារណាគឺការបង្កើតភាពជាដៃគូរវាងសាធារណៈ និងឯកជននៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត សំរាប់កិច្ចសន្យាគ្រប់គ្រង ។* កិច្ចការទាំងនេះសំដៅទាក់ទាញវិនិយោគឯកជនឱ្យធ្វើសកម្មភាពលើដីសាធារណៈស្ថិតនៅក្រោមការត្រួតពិនិត្យនៃអាជ្ញាធរ និងសហគមន៍មូលដ្ឋានស្ថិតក្រោមការណែនាំរបស់ជាតិដើម្បីឱ្យមានការគ្រប់គ្រងប្រកបដោយនិរន្តរភាព ។ ការចាត់ចែងផ្នែកហិរញ្ញវត្ថុតំរូវឱ្យមានការលើកកំពស់ការគ្រប់គ្រងដែលមានការទទួលខុសត្រូវ និងការត្រួតពិនិត្យគុណភាពពីសំណាក់អាជ្ញាធរមូលដ្ឋាន ។

៦២. *ចាំបាច់ត្រូវពង្រឹងការរៀបចំឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងព្រៃឈើ ។* ទោះបី ជាតំបន់ព្រៃដែលត្រូវគ្រប់គ្រងជាសំខាន់ដោយរដ្ឋបាលព្រៃឈើទាក់ទងទៅនឹងកិច្ចការរបស់ជាតិក្តី (ប្រាក់ចំណូល ការព្រួយបារម្ភផ្នែកបរិស្ថាន ។ល។) គេឃើញមានសារៈសំខាន់អំពីផលវិបាកនៅមូលដ្ឋានអំពីការគ្រប់គ្រង ។ ផលប៉ះពាល់បែបនេះអាចរួមមានការបាត់បង់លទ្ធភាពបានទទួលធនធាន ដោយសារការកាប់ឈើ ការការពារ មានផ្លូវថ្នល់ ឬកិច្ចអភិវឌ្ឍន៍អមដោយការគ្រប់គ្រងព្រៃឈើ ។ ការការពារ

សុខុមាលភាពនៅមូលដ្ឋាន និងលៃយ៉ាងណាឱ្យទំនាស់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានមិនសម្របសម្រួលតាមរយៈការ កាត់បន្ថយប្រសិទ្ធភាពនៃការគ្រប់គ្រង និងតំរូវឱ្យមានកិច្ចប្រឹងប្រែងនិងនិតិវិធីត្រឹមត្រូវដើម្បីពិចារណាអំពីកង្វល់នៅមូលដ្ឋាន ទោះបីជាមានវិធីសាស្រ្តត្រួតពិនិត្យតាមបន្ទាត់ដឹកនាំតែមួយក្តី ។ កាលពីពេលថ្មី១នេះ យន្តការសំរាប់ពិគ្រោះក្នុងកិរិតនៅមូលដ្ឋានប្រព្រឹត្តទៅដោយគ្មានការគ្រោងទុកឱ្យបាន ច្បាស់លាស់ហើយ តាមការពិគ្រោះមានចរិតបុគ្គលយ៉ាងខ្លាំង បង្កើតជាឱកាសសំរាប់ការស្វែងរកផលចំណេញនិងអំពើពុករលួយ ដោយមិនគិត ឬមិនយកចិត្តទុកដាក់អំពីផលប្រយោជន៍នៃក្រុមពលរដ្ឋងាយរងគ្រោះ និង ធ្វើសេចក្តីសំរេចចិត្ត ដែលមានចរិតនយោបាយ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ រដ្ឋាភិបាលចាំបាច់ ត្រូវបង្កើន និងពង្រីកដំណើរការរបស់ខ្លួនក្នុងពេលបច្ចុប្បន្នលើកិច្ចអភិវឌ្ឍន៍និងកំណែទំរង់រដ្ឋបាលព្រៃឈើ ។ ការរៀបចំច្បាស់លាស់ដើម្បីឱ្យមានការពិគ្រោះនៅមូលដ្ឋាន ស្តីពីប្រតិបត្តិការគ្រប់គ្រងព្រៃឈើជាប្រចាំ ចាំបាច់ត្រូវប្រកាសឱ្យបានដឹងជាមុនក្នុងរយៈពេលមួយសមស្រប មុនពេលចាប់ផ្តើមប្រតិបត្តិការ និងគប្បីរៀបចំលើមូលដ្ឋាននៃ បទពិសោធន៍កន្លងមក ។ ការអភិវឌ្ឍន៍ប្រព័ន្ធតាមដានដែលមានការចូលរួម អាចជួយឱ្យមានតម្លាភាព និង ប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន ។ វិធីសាស្រ្តសិក្សារៀនសូត្រច្បាស់លាស់អាចអនុម័តដោយគំរោង សាកល្បងនៅតាមតំបន់មួយចំនួនដែលជ្រើសរើសដែលតំបន់ទាំងនោះមានព្រៃ និងលក្ខណៈសង្គមខុស១គ្នា ។ ការធ្វើបែបនេះអាចធ្វើឱ្យមានស្តង់ដារនិងការរៀបចំសមស្របដែល អាចអនុវត្តបាន ។

៦៣. *ការប្រមូលពន្ធសួយសារគ្មានលក្ខណៈជាប្រព័ន្ធហើយក៏គ្មានការតាមដានគ្រប់គ្រាន់ ។* បន្ទាប់ពីមានការព្យួរសម្បទានលើការកាប់ឈើ ប្រាក់ចំណូលព្រៃឈើសរុបបានចុះថយជាមធ្យមពី ៨ ទៅ ១២ លានដុល្លារ នៅក្នុងទសវត្សរ៍ ១៩៩០ មកត្រឹមប្រមាណជា ២ លានដុល្លារ នៅឆ្នាំ ២០០២ ។ លើមូលដ្ឋាននៃការប៉ាន់ស្មានដ៏ប្រសើរបំផុតអំពីបរិមាណព្រៃឈើដែលអនុញ្ញាតឱ្យកាប់ប្រចាំឆ្នាំ (AAC) លើមូលដ្ឋានប្រព័ន្ធសម្បទាន(បច្ចុប្បន្នមានទំហំ ៣,១ លានហិកតា)ក្នុងកំរិតប្រហែល ២៥០,០០០ ម៉ែត្រគូបការបន្តកាប់ព្រៃ តទៅទៀតអាចរំពឹងថាបានប្រាក់ចំណូលចំនួនប្រមាណជា ១៥ លានដុល្លារ ក្នុងមួយឆ្នាំ

[35] ។ ប្រសិនត្រូវ ដោះស្រាយបញ្ហាអភិបាលបច្ចុប្បន្ន និង បញ្ចូបមូលប្រាក់ចំណូល បន្ថែមលើប្រាក់ចំណូលគ្រោងទុក ដែលប្រាថ្នាឱ្យមានការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃសម្បទានព្រៃឈើពន្ធ សួយសារក៏ត្រូវយកពីការកាប់ឈើដែលពាក់ពន្ធនឹងការរានដី និងយកពីការធ្វើពាណិជ្ជកម្មខ្នាតតូចនៃ ផលិតផល និងអនុផលព្រៃឈើផងដែរ(រួមមាន ជ័រចុង សរសរ និងអុស) ។ ប្រាក់ចំណូលដែលបានមក ពីប្រភពទាំងនេះ ទំនងជាមានចំនួនតិច ហើយត្រូវបានបាត់បង់ដោយសារការត្រួតពិនិត្យមិនបានល្អក្នុងការប្រមូល និងការគ្រប់គ្រងចំណូល ។

៦៤. *ចាំបាច់ត្រូវពិនិត្យសារឡើងវិញនូវគោលនយោបាយឧស្សាហកម្ម រួមមានការវាយតំលៃសមត្ថភាពកែច្នៃបច្ចុប្បន្ន ។* យុទ្ធសាស្រ្តអភិវឌ្ឍន៏វិស័យព្រៃឈើនៅពាក់កណ្តាលទសវត្សរ៍ ១៩៩០ មានគោលដៅក្នុងការបង្កើតឧស្សាហកម្មកែច្នៃឈើខ្នាតធំ ។ សមត្ថភាពដែលអាចកើតមាន អាចមានសមត្ថភាពលើសពីសក្តានុពលនៃមូលដ្ឋានធនធាន ទោះជាប្រការនេះចាំបាច់ត្រូវធ្វើការវាយតំលៃក្តី ។ ផ្អែកលើការប៉ាន់ស្មាន សមហេតុសមផលអំពីសមត្ថភាពផលិតនៃមូលដ្ឋានធនធាន ប្រទេសកម្ពុជាមិនអាចទ្រទ្រង់ឧស្សាហកម្មឈើ ខ្នាតធំដែល រដ្ឋាភិបាលបានគ្រោងទុកនៅក្នុងទសវត្សរ៍ ១៩៩០ ឡើយ ។ ថ្មីៗនេះ សមត្ថភាពកែច្នៃដែល គេបានតម្លើងដោយស្របច្បាប់ ភាគច្រើននៅទុកចោលទំនេរ ប្រាក់ឈ្នួល និងពន្ធដារពីការកែច្នៃឈើ មានកំរិតតិចតួច ។ បន្ថែមលើសមត្ថភាពនៃរោងចក្រនៅនឹងកន្លែង មានរោងចក្រអារឈើតូចៗជាច្រើន ហើយជួនកាលជារោងចក្រអារឈើខុសច្បាប់ និងរោងចក្រអារឈើចល័ត ដែលធ្វើឱ្យមានសម្ពាធមកលើមូលដ្ឋានធនធាន ប៉ុន្តែបរិមាណ និងសមាសភាពនៃសមត្ថភាពនេះគេមិនបានដឹងថាមានទំហំប៉ុណ្ណាឡើយ ។ ការកាត់បន្ថយផ្ទៃដីសម្បទានព្រៃឈើ ចាំបាច់ត្រូវតំរឹមតាមរយៈការបញ្ចុះទំហំ

---

[35] តួលេខនេះមានលក្ខណៈផ្ទុយគ្នាជាមួយនឹងការប៉ាន់ស្មានកាលពីពេលមុនរបស់ធនាគារពិភពលោក/FAO/UNDP ដែលមានបរិមាណស្មើរនឹង ១០០លានដុល្លាក្នុងមួយឆ្នាំ ។ តួលេខផ្លាស់ប្តូរនេះមួយផ្នែកធំបណ្តាលមកពីការចុះថយតំបន់សម្បទានប្រមាណជា ៦០ភាគរយ និងការធ្លាក់ចុះនៃថ្លៃប្រថាប់ត្រាដែលគេបានប៉ាន់ស្មានថាក្នុងកំរិតខ្ពស់ប្រមាណជា ៨០ដុល្លាក្នុង ១ម៉ែត្រគូបនៅឆ្នាំ ១៩៩៦ ។ ក្រៅពីនេះនៅក្នុងរយៈពេលអនុវត្តមន៏ ៨ឆ្នាំការកាប់ឈើដោយខុសច្បាប់បានកាត់បន្ថយសក្តានុពលទិន្នផលដែលមាននិរន្តរភាពហើយតំរូវអោយមានរយៈពេលវែងក្នុងការស្តារស្ថានភាពមុនពេលអនុញ្ញាតអោយកំរិតនៃការប្រមូលផលអាចវិលត្រលប់ ទៅរកសក្តានុពលភាពរបស់ខ្លួនវិញ ។

និង/ឬរៀបចំសារឡើងវិញនូវ តម្លើងសមត្ថភាពរោងចក្រ (និងការត្រួតពិនិត្យឱ្យបានប្រសើរលើសមត្ថភាពរោងចក្រចល័ត) ពីព្រោះថា តំរូវការលើសកំរិតនេះធ្វើឱ្យមានសម្ពាធដល់ការកាប់ឈើដោយខុសច្បាប់ និងធ្វើឱ្យអាជីវកម្មមានកំរិតច្រើនហួសហេតុ ។

៦៥. ខណៈដែលការអភិវឌ្ឍន៍ឧស្សាហកម្មកែច្នៃឈើមានគោលបំណងក្នុងការផលិតឈើអារ និងក្តារបន្ទះ ប្រទេសកម្ពុជាគួរជាប្រទេសមួយផលិតនូវសង្ហារឹមដែលធ្វើអំពីឈើប្រណីត ។ ប្រការនេះអាចឆ្លើយតបនឹងតំរូវការក្នុងការអភិវឌ្ឍន៍យុទ្ធសាស្រ្តគ្រប់គ្រងទូទៅផ្អែកលើអាត្រាប្រមូលផលយឺត នៅក្នុងតំបន់ព្រៃលាស់ ស្លឹក ហើយអាចអភិវឌ្ឍន៍តាមរយៈភាពជាដៃគូជាមួយផលិតករអន្តរជាតិ ។ ជាជំហានដំបូង ចាំបាច់ត្រូវមាន ការសិក្សាស្រាវជ្រាវអំពីសមត្ថភាពនៃទំនិញប្រណិតដើម្បីទ្រទ្រង់ការប្រមូលផលពាណិជ្ជកម្ម ។

៦៦. *ដើម្បីជួយនាំមកនូវការកាត់បន្ថយទំហំ និងការរៀបចំទិសដៅចាំបាច់នៅក្នុងអនុវិស័យឧស្សាហកម្មឈើ រដ្ឋាភិបាលគប្បីដាក់អាទិភាពទី ១ ចំពោះការយកពន្ធឈើ និងប្រព័ន្ធប្រាក់ចំណូលព្រៃឈើ ដើម្បីផ្តល់ដំណឹងទីផ្សារសមស្របដល់ឧស្សាហកម្មនេះ ។* ដូចដែលបានកំណត់ន័យក្នុងពេលថ្មីៗនេះ ការកសាងផែនការធនធានព្រៃឈើ យ៉ាងហោចណាស់ទាក់ទងនឹងប្រព័ន្ធសម្បទាន រួមមានការប៉ាន់ស្មានអំពីបរិមាណឈើដែលអនុញ្ញាតឱ្យកាប់ដើម្បីធានាឱ្យមាននិរន្តរភាព ។ ជំហររបស់រដ្ឋាភិបាលក្នុងការចចារឡើងវិញអំពីកិច្ចសន្យាសម្បទាន ជាពិសេសគឺបញ្ញត្តិស្តីពីពន្ធសួយសារកំណត់យកពីអាជីវកម្មឈើ ចាំបាច់ត្រូវឆ្លុះបញ្ចាំងការប៉ាន់ស្មានសមស្របអំពីឆន្ទៈក្នុងការទូទាត់របស់ឧស្សាហកម្មដែលបានកសាងមូលដ្ឋានសំភារៈ ក៏ដូចជា ថ្លៃបំរុងទុករបស់រដ្ឋាភិបាល (ក្នុងចំណោមកត្តាដទៃទៀត ថ្លៃនោះគប្បីពិចារណាអំពីតំលៃសង្គម និងតំលៃបរិស្ថាននៃព្រៃឈើសម្បទានបច្ចុប្បន្ន) ។ របបថ្លៃឈើសមស្របមិនធ្វើឱ្យឈើមានតំលៃថោក តាមបែបសិប្បនិម្មិត ដើម្បីឱ្យរោងចក្រអារឈើបន្តប្រតិបត្តិការនោះឡើយ ប៉ុន្តែថ្លៃនឹងជំរុញការលើកទឹកចិត្ត សំរាបបិទរោងចក្រអារឈើមិនឱ្យធ្វើអាជីវកម្មនេះ ។ ការបង្កើតឱ្យមានប្រព័ន្ធល្អប្រសើរអំពីការកាប់ឈើ ប្រចាំឆ្នាំ សឹងតែអាចផ្តល់ពតិមានស្តីពីថ្លៃដែលមិនអាចកាត់តំលៃបាន ដែលអាចដាក់បញ្ចូលយ៉ាងស្រួលទៅក្នុងការរៀបចំរចនាសម្ព័ន្ធសមទានសារឡើងវិញ ។ ទោះជាយ៉ាងណាក៏ដោយការងារនេះអាចបង្ហាញនូវ

ទិដ្ឋភាពដែលកាន់តែមានលក្ខណៈប្រឈមចំពោះការតាមដាន និងការត្រួតពិនិត្យឧក្រិដ្ឋកម្មព្រៃឈើ និងគំរូជាក់លាក់ចាំបាច់ត្រូវធ្វើការសិក្សាឱ្យបានម៉ត់ចត់ ។ គេសង្កេតឃើញមានហានិភ័យខ្ពស់មួយចំនួន ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធកាប់ឈើ រួមមានការលំបាកក្នុងការរកអោយឃើញ និង ការចោទប្រកាន់អំពីឧក្រិដ្ឋកម្មព្រៃឈើ ដែលធ្វើអោយសហគមន៍នានាប្រឈមមុខ នឹង ការបាត់បង់សិទ្ធិជាប្រពៃណី ធ្វើអោយប៉ះពាល់អវិជ្ជមានចំពោះកិច្ចប្រឹងប្រែងក្នុងការអភិវឌ្ឍន៍វិនិយោគវិស័យឯកជន នៅក្នុងវិស័យព្រៃឈើ ហើយធ្វើអោយការប្រមូលចំណូលឈើកាប់កាន់តែជួបការលំបាក ក្នុងស្ថានភាពដែលអាចមានបរិមាណឈើកាប់ដេញថ្លៃប្រចាំឆ្នាំជាច្រើន ។

៦៧. *អាត្រាដែលការកែតំរូវនេះនឹងប្រព្រឹត្តទៅ អាចនឹងបង្កើនល្បឿន តាមរយៈបន្ធូរបន្ថយ កាតព្វកិច្ចឮរកិច្ចសន្យាចំពោះការវិនិយោគកែច្នៃបន្ថែម* (ជាជាងការសន្យាដទៃរបស់ ក្រុមហ៊ុន) និងតាមរយៈ ការធានាថាមានឧបសគ្គតិចតួចការរៀបចំសារជាថ្មី និងការផ្ទេរសមត្ថភាពរោងចក្រអារឈើក្នុងចំណោមសម្បទានដែលនៅសេសសល់ ។ ការអនុវត្តន៍កាតព្វកិច្ចផ្តល់អញ្ញាប័ណ្ណ បញ្ញត្តិច្បាប់អំពីទីតាំងរោងចក្រអារឈើ និងការត្រួតពិនិត្យដទៃទៀតគប្បីបន្តធ្វើជាជំហានបន្ទាប់ក្នុងការលុបបំបាត់នូវសមត្ថភាពលើសពីភាពចាំបាច់ ។ ស្ថិតលើមូលដ្ឋាននៃសមត្ថភាពដែលនៅសេសសល់បន្ទាប់ពីមានវិធានការទាំងនេះ ចាំបាច់ត្រូវមានកម្មវិធីរយៈពេលវែង សំរាប់តាមដាន និងត្រួតពិនិត្យកិច្ចអភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ អំពីសមត្ថភាពធនធាន។

## អនុសាសន៍ស្តីពីសកម្មភាពជាអាទិភាពសំរាប់កំណែទំរង់ការគ្រប់គ្រងព្រៃឈើ

៦៨. សកម្មភាពជាអាទិភាពខាងក្រោមនេះជាអនុសាសន៍សំរាប់ធ្វើសនិទានកម្មលើការបែងចែកដីព្រៃការ ត្រួតពិនិត្យការបំលែងដីព្រៃដែលមិនបានគ្រោងទុក ការបាត់បង់ព្រៃឈើ និងការពារតំលៃអេកូឡូស៊ីតំលៃសេដ្ឋកិច្ច និងតំលៃដាំដុះព្រៃឈើ និងបង្កើនការរួមវិភាគទានដែលមាននិរន្តរភាពលើជីវភាពរស់នៅនិងកិច្ចអភិវឌ្ឍន៍ជនបទ។ អនុសាសន៍ស្តីពីសកម្មភាពទាំងនេះគប្បីទទួលការពិនិត្យសារឡើងវិញនៅក្នុងបរិបទនៃកិច្ចពិភាក្សាខាងមុខអំពីលទ្ធផលនៃ *ការពិនិត្យឡើងវិញនូវវិស័យព្រៃឈើក្នុងលក្ខណៈឯករាជ្យ*។

## អាទិភាពទី ១ ពង្រឹងកំណែទំរង់ការគ្រប់គ្រងសម្បទានព្រៃឈើ

- *ការរៀបចំរចនាសម្ព័ន្ធនៃប្រព័ន្ធសម្បទានព្រៃឈើពេញលេញសារជាថ្មី* ការពិនិត្យសារឡើងវិញរបស់រដ្ឋាភិបាលចំពោះផែនការគ្រប់គ្រងព្រៃឈើ សម្បទានជាយុទ្ធសាស្ត្រ បង្កើតអោយមានអនុសាសន៍មួយ

ចំនួន ដែលបង្កើតបានជាសំណើរ ក្នុងការបញ្ឈប់សម្បទានបន្ថែមចំនួន ៦ ។ ក្នុងខណៈដែលមានភាពផ្ទុយគ្នា អំពីសម្បទានចំនួន ៦ ដែលនៅសេសសល់ រដ្ឋាភិបាលមិនត្រូវអូសបន្លាយបន្ថែមទៀត ក្នុងការបញ្ឈប់សម្បទានដែលមិនអាចដំណើរការបាន ។ សម្បទានដែលឋិតនៅក្រោមការពិចារណា គប្បីស្នើសុំអោយមានការផ្តល់ពេលវេលាក្នុងការអនុវត្តន៍ សំរាប់ឆ្លើយតបជាមួយកាតព្វកិច្ចផ្នែកបទប្បញ្ញត្តិ។ វឌ្ឍនភាពដែលសំរេចបាននៅក្នុងការធ្វើសនិទានភាព ចំពោះប្រព័ន្ធសម្បទាន ព្រៃឈេអាចផ្តល់មេរៀនមានតំលៃ ដើម្បីបានទទួលការចាត់ចែងកាន់តែប្រសើរ លើប្រភេទសម្បទាន ដទៃទៀត ។

- *ការធ្វើសនិទានភាវូបនីយកម្មប្រើប្រាស់ដីព្រៃ* **។** បន្ទាប់ពីការអនុម័តអនុក្រឹត្យ ស្តីពីការគ្រប់គ្រងដីរដ្ឋ ចូរធ្វើការវាយតំលៃដីព្រៃ រាប់ទាំងតំបន់ទទួលការការពារ ដើម្បីកំណត់ផ្នែកសំខាន់ៗនៃដីព្រៃ ដែលចាំបាច់ត្រូវរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ដើម្បីធានាអោយមានការការពារប្រកបដោយប្រសិទ្ធិភាព នៃជីវចំរុះ និង ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ព្រមទាំងការគ្រប់គ្រងព្រៃឈើ ក៏ដូចជាការកំណត់ថាតើតំបន់នៅសេសសល់មានលក្ខណៈសមស្របសំរាប់ជួលសារជាថ្មី ចំពោះការបំលែង សំរាប់កសិកម្ម និង ការប្រើប្រាស់ដទៃទៀត ។
    - *ជំរុញល្បឿនការកសាងផែនទីដីធ្លី ការបោះបង្គោល អង្កេត និង ការធ្វើសារពើភ័ណ្ឌដីព្រៃ*
    - *សិក្សាជំរើសនានាចំពោះការគ្រប់គ្រងតំបន់ព្រៃក្រៅឧទ្យាន និង តំបន់ទទួលការការពារ* អោយមាននិរន្តរភាព រាប់ទាំងលទ្ធភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និង ការពិនិត្យមើលសារឡើងវិញ អំពីការសាកល្បងសហគមន៍ព្រៃឈើដែលកំពុងដំណើរការ ដើម្បីវាយតំលៃមេរៀនដែលបានដកពិសោធន៍រហូតមកដល់ពេលបច្ចុប្បន្ន និង សក្តានុពលសំរាប់ពង្រីកបន្ថែម ។

- *ពង្រឹងសមត្ថភាពរដ្ឋាលព្រៃឈើនៅថ្នាក់ផ្សេងៗគ្នា* រាប់ទាំងសមត្ថភាពសំរាប់ត្រួតពិនិត្យការអនុវត្តន៍តាមសម្បទានព្រៃឈើ ។
- *បង្កើនប្រាក់ចំណូលនិងពង្រឹងការគ្រប់គ្រង ។* ពិនិត្យមើលសារឡើងវិញនូវបទពិសោធន៍អំពីការប្រមូលពន្ធសួយសារ ថ្លៃប្រថាប់ត្រានិងថ្លៃប្រើប្រាស់ រៀបចំនឹងអនុវត្តន៍កម្មវិធីមួយ ដើម្បីលើកកំពស់ការគ្រប់គ្រងប្រាក់ចំណូលនិងលើកកំពស់ការត្រួតពិនិត្យការប្រមូលប្រាក់ចំណូល។

**អាទិភាពទី ២ ពិនិត្យមើលឡើងវិញរចនាសម្ព័ន្ធវិស័យព្រៃឈើ**

- *ផ្តោតការរៀបចំ "បន្ទាត់បញ្ចារតែមួយ" ចំពោះតំបន់ព្រៃដែលមានសារៈសំខាន់ចំពោះជាតិ* សម្បទានដែលនៅសេសសល់ ព្រៃដែលមានក្រលាផ្ទៃធំ អាចធ្វើពាណិជ្ជកម្មបាន ដែលមានតំរូវការតិចតួចនៅសហគមន៍ និង ជាតំបន់ត្រូវទទួលការការពារ និងគ្រប់គ្រង សំរាប់គោលដៅជាតិស្តីពីព្រៃឈើ ។ គប្បីអនុវត្តសាកល្បង ចំពោះបទប្បញ្ញត្តិជាក់លាក់ ដែលបានរៀបចំជាឯកសារ ហើយបានផ្សព្វផ្សាយទូលំទូលាយ ដើម្បីទទួលមតិកែលំអពីសាធារណៈជននៅមូលដ្ឋាន ចំពោះការសំរេចចិត្តគ្រប់គ្រង និងការចែករំលែកប្រាក់ចំណូល ។
- *បង្កើតដំណោះស្រាយតាមបែបដទៃ ក្នុងការធ្វើសមាហរណកម្មពតិមានរដ្ឋបាលព្រៃឈើអោយមានការគាំទ្រអភិវឌ្ឍន៍ជនបទនៅថ្នាក់ខេត្ត ។ នៅទីកន្លែងដែលធនធានព្រៃឈើមានលក្ខណៈដាច់ដោយដុំដាច់ៗពីគ្នា ឬជួនកាលមានទំនាក់ទំនងជិតស្និទ្ធជាមួយជីវភាពរស់នៅ និងកិច្ចអភិវឌ្ឍន៍ជនបទ សេវាព្រៃឈើមិនត្រូវចាត់តាំងលើមូលដ្ឋានដែនដីឡើយ ។ ផ្ទុយទៅវិញ ឋិតនៅក្នុងបញ្ញត្តិនៃច្បាប់ ព្រៃឈើ រដ្ឋបាលព្រៃឈើអាចត្រូវបានរៀបចំសាជាថ្មី លើមូលដ្ឋានផ្តោតទៅរកសេវា ដើម្បីផ្តោតលើការទទួលខុសត្រូវនៅមូលដ្ឋានក្នុងការទ្រទ្រង់ចំពោះការដាំដើមឈើ ការគ្រប់គ្រងដីព្រៃសំរាប់ជីវភាពរស់នៅមូលដ្ឋាន និង សំរាប់កិច្ចអភិវឌ្ឍន៍កសិរុក្ខកម្ម ។*
- *ពង្រីកមូលដ្ឋានរាយការណ៍បទឧក្រិដ្ឋព្រៃឈើ និងចោទប្រកាន់ដើម្បីនាំមកនូវទស្សនវិស័យទូលំទូលាយកាត់បន្ថយទំនាស់ផលប្រយោជន៍ និង បង្កើនការទទួលខុសត្រូវ និងតំលាភាព* ខណៈដែលការអនុវត្តន៍ច្បាប់គឺជាផ្នែកមួយនៃមុខងារគ្រប់គ្រងព្រៃឈើរបស់រដ្ឋបាលព្រៃឈើ ស្ថាប័នសាធារណៈមួយចំនួនធំ អាជ្ញាធរមូលដ្ឋាន និង សង្គមស៊ីវិលអាចត្រួតពិនិត្យមើលការកាប់ឈើដែលខុសច្បាប់ និងការរំលោភយកដីធ្លី និង ឧក្រិដ្ឋកម្មព្រៃឈើដទៃទៀត ។

## អាទិភាពទី ៣ សំរួលការរៀបចំរចនាសម្ព័ន្ធនៃឧស្សាហកម្មកែច្នៃឈើ

- *សំរួលការរៀបចំរចនាសម្ព័ន្ធនៃឧស្សាហកម្មកែច្នៃឈើសារជាថ្មី ។* សំរួលការរៀបចំទំហំសមស្របនៃសមត្ថភាពខ្នាតធំដែលគេបានតម្លើងនៅក្នុងឧស្សាហកម្មកែច្នៃឈើ ធ្វើអន្តរកម្មមកទៅជារោងចក្រកែច្នៃឈើដែលមានកំលាំងផលិតទាបផលិតផលិតផលឈើមានគុណភាពខ្ពស់សំរាប់ទីផ្សារនាំចេញ និងរក្សាទុកសមត្ថភាពអប្បរមាក្នុងការកែច្នៃឈើសំណង់ សំរាប់ទីផ្សារក្នុងស្រុក ។
- *ធ្វើជំរឿនរោងចក្រអារឈើនិងអង្កេតសមត្ថភាពរបស់រោងចក្រ ។* ដើម្បីឱ្យដឹងច្បាស់អំពីសមត្ថភាពរបស់រោងចក្រអារឈើសរុប រាប់ទាំងសមាសភាពនិងបរិមាណកែច្នៃដែលមាននៅក្នុងរោងចក្រអារឈើនៅនឹងកន្លែងនិងរោងចក្រអារឈើចល័តផងដែរ ។

## កំណែទំរង់ការគ្រប់គ្រងជលផល

៦៩. *ធនធានជលផលរបស់កម្ពុជាមានប្រភពមកពីទន្លេ ដីសើម និងជំរកតាមឆ្នេរសមុទ្រ ផ្ដល់ជាអាហារ ប្រាក់ចំណូល និងទ្រទ្រង់ជីវភាពរស់នៅដល់ប្រជាពលរដ្ឋរាប់លាននាក់* ។ វិស័យនេះក៏ជាប្រភពសក្ដានុពលសំខាន់មួយនៃពន្ធសួយសារសំរាប់រដ្ឋាភិបាលផងដែរ[36]ដែលមានចំណែកស្មើនឹង ១០% នៃ GDP[37]កសិកម្ម និងជាទំនិញនាំចេញដែលមានសារៈសំខាន់។ ធនធានជលផលរួមមានត្រី សត្វ និងរុក្ខជាតិដទៃទៀត ព្រៃលិចទឹកក៏មានសារៈសំខាន់ផងដែរសំរាប់ការអភិរក្សផ្នែកអេកូឡូស៊ី អភិរក្សជំរកធម្មជាតិ ទេសចរណ៍-សេដ្ឋកិច្ច និងវប្បធម៌ផងដែរ។ នេសាទទឹកសាបដែលមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ចបំផុតមានកំរិតស្មើនឹង ៨០%នៃ GDPជលផល ជាពិសេសគឺជលផលដែលបានមកពីបឹងទន្លេសាប និងតំបន់ទន្លេ[38] តំបន់ទន្លេមេគង្គ និងទន្លេបាសាក់[39] និងតំបន់ទន្លេមេគង្គផ្នែកខាងលើ[40] ។ ទន្លេសាបនៅរដូវប្រាំងមានទំហំ ២.៥០០ ទៅ ៣.០០០គីឡូម៉ែត្រការ៉េ ហើយទំហំនេះនឹង កើនឡើងដល់ ១០.០០០ ទៅ ១៥.០០០ គីឡូម៉ែត្រការ៉េ នៅរដូវវស្សា ។ ការនេសាទគឺជាប្រភពចំណូលចំបងមួយ សំរាប់គ្រួសាររស់នៅតាមបណ្ដោយខេត្តអមទន្លេមេគង្គ ប្រហែល៤៥%[41] ។ តួលេខស្ថិតិជលផលមិនអាចជឿទុកចិត្តបានឡើយ ប៉ុន្តែតួលេខប៉ាន់ស្មានសរុបផ្អែកលើពត៌មានបច្ចុប្បន្នបង្ហាញថាប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ទីមួយធៀបនឹងតំបន់នេះ និងស្ថិតនៅលំដាប់ទី ៤ ធៀបនឹងផលនេសាទត្រីទឹកសាបរបស់ពិភពលោក ដែលមានផលនេសាទប្រចាំឆ្នាំប្រហែល ៣០០.០០០ ទៅ ៤៥០.០០០ តោន ក្នុងមួយឆ្នាំ។

---

[36] ទោះជាយ៉ាងណាក៏ដោយគេមិនអាចមាននេះក្ដីតួលេខប៉ាន់ស្មានត្រឹមត្រូវ អំពីចំណូលសរុបដែលគេបានប្រមូល ពីការដេញថ្លៃសម្បទាន និងការនេសាទចំណូលពីអាជ្ញាប័ណ្ណឡើយ ។

[37]តួលេខនេះទំនងជាប៉ាន់ស្មានមិនគ្រប់ចំនួនព្រោះគេមិនបានគិតអំពីការនេសាទត្រីតាមស្រែ ដូជាមិនបានគិតផងដែរនូវតំលៃនៃសត្វ និង ផលិផលរុក្ខជាតិដែលគេបានប្រមូល

[38] គឺជាតំបន់នេសាទទឹកសាបដែលសំបូរត្រីបំផុត និងរួមមានខេត្តកំពុងឆ្នាំង ពោធិសាត់ បន្ទាយមានជ័យ សៀមរាប កំពង់ធំ និងប៉ែកខាងជើងនៃខេត្តកណ្ដាល ។

[39] ជាតំបន់នេសាទទឹកសាបសំបូរណ៍ត្រីបំផុត រួមមានខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ និងភាគខាងជើងនៃខេត្តកណ្ដាល។

[40] មានសារៈសំខាន់ចំពោះការនេសាទជីវព្រឹត្តលក្ខណៈគ្រួសារ រួមមានខេត្តក្រចេះ និងស្ទឹងត្រែង

[41]យោងតាមការអង្កេតមួយនៅក្នុងខេត្តចំនួន៨ដែលគេបានធ្វើនៅឆ្នាំ១៩៩៨១០%នៃគ្រួសារចាត់ទុកថាប្រភពប្រាក់ចំណូលជាមូលដ្ឋាន និង៣៥%ទៀតជាប្រភពប្រាក់ចំណូលបន្ទាប់បន្សំ ។តួលេខមានកំរិតទាបនៅថ្នាក់ជាតិដោយប្រើប្រាស់ទិន្នន័យCSESឆ្នាំ១៩៩៩ប្រាក់ចំណូលដែលបានមកពីជលផលមានចំនួនសរុបស្មើនិង៦%នៃប្រាក់ចំណូលគ្រួសារ（Source:Helmersetal.,2003）។

៧០. ជាងនេះទៅទៀត ឆ្នេរ[42]សមុទ្ររបស់កម្ពុជាមានប្រវែង៤៣៥គីឡូម៉ែត្រ រួមមានឈូងសមុទ្រសំខាន់ៗចំនួន ៣ គឺ កំពង់សោម កោះកុង និងកំពត នឹងមានតំបន់សេដ្ឋកិច្ចផ្តាច់មុខតាមមាត់សមុទ្ទ (EEZ)[43] មានទំហំ ៥៥.៦០០ គីឡូម៉ែត្រការ៉េដែលមានចំងាយ ២០០ម៉ៃល៍[44] ពីឆ្នេរសមុទ្រ ដែលផ្តល់ផលិតភាពចំពោះការនេសាទ។ ដែនសមុទ្ទតាមឆ្នេរ និងដែនសមុទ្ទនៅឯនាយ នៃសមុទ្រកម្ពុជាមានមច្ឆាជាតិប្រហែល ៤៧៤ មុខ ក្នុងនោះ មានមច្ឆាជាតិប្រហែល៣០មុខដែលមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ។ គេប៉ាន់ស្មានថាមានអ្នកនេសាទតិចជាង ១០.០០០ គ្រួសារ ។ តួលេខផលត្រីទឹកប្រៃដែលនេសាទបានជាផ្លូវការដែលកំណត់ប្រចាំឆ្នាំប្រហែល ៣០.០០០ តោន ជាតួលេខដែលមានកំរិតទាបជាង ផលចាប់ជាក់ស្តែងព្រោះថាតួលេខទាំងនោះគ្រាន់តែពឹងផ្អែកទៅលើផលនេសាទនៃឧបករណ៍នេសាទដែលមានអាជ្ញាប័ណ្ណតែប៉ុណ្ណោះ ហើយគេមិនបានគិតបញ្ចូលនូវតួលេខប៉ាន់ស្មាននៃផលចាប់ជាច្រើនរបស់ទូកនេសាទដែលគ្មានអាជ្ញាប័ណ្ណឡើយ ក្នុងនោះមានទូកនេសាទគ្មានអាជ្ញាប័ណ្ណរបស់បរទេស ដែលផ្ទេរផលចាប់នៅក្រៅប្រទេសកម្ពុជា ទូកពាណិជ្ជកម្មក្នុងស្រុក និងអ្នកនេសាទខ្នាតតូចដែលគ្មានអាជ្ញាប័ណ្ណ។

៧១. *តាមច្បាប់ ក្របខ័ណ្ឌនៃការនេសាទជារបស់រដ្ឋ* ហើយនាយកដ្ឋានជលផល (នាយកដ្ឋានព្រៃឈើនៅក្នុងក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ - MAFF) មានសមត្ថកិច្ចក្នុងការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍ ធនធានជលផល ។ ជាពិសេសនាយកដ្ឋានជលផលទទួលខុសត្រូវក្នុងការអនុវត្តនីបទប្បញ្ញត ្តិ ផ ្តល់ សម្បទាន ចេញអាជ្ញាប័ណ្ណ និងប្រមូលប្រាក់បន្ទុក ប៉ុន្តែ ្តសមត្ថភាពគ្រប់គ្រងខ្សោយ ការគ្រប់គ្រងជាក់សែ ្តង មានអប្រសិទ្ធិភាពយ៉ាងខ្លាំង ហើយវិស័យនេះសំបូរណ៏ដោយទំនាស់ផ្ទៃក្នុង ទំនាស់អន ្តរវិស័យ និងទំនាស់ អន ្តរជាតិ ។

៧២. *ទោះបីជាមានជំហ៊ាននានាកាលពីពេលថ្មីៗក្នុងការដោះស្រាយបញ្ហាអភិបាលកិច្ចនៅក្នុងការនេសាទទឹកសាបក ្តី ភាពកំសោយក្នុងពេលបច្ចុប្បន្នអំពីក្របខ័ណ្ឌគោលនយោបាយ និងការអនុវត្តន៏ច្បាប់ចាំបាច់ត្រូវដោះស្រាយ* ។ អស់រយៈពេលជាងមួយទសវត ្សរ៍នៃកម្មវិធីគ្រប់គ្រងដោយសមូហភាពនៅក្នុងអំឡុងពេលកាន់កាប់របស់ខ្មែរក្រហម និងវៀតណាម នៅចុងទសវត្សរ៍ ១៩៨០ ប្រព័ន្ធសម្បទាននេសាទមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រព័ន្ធដែលគេប្រើប្រាស់ក្នុងសម័យអនានិគមនិយមបារាំង ត្រូវបានដាក់ឱ្យប្រើ-

---

[42]នៅតាមខេត្តក្រុងនានានៃកោះកុង ក្រុងព្រះស៊ីហនុ និងក្រុងកែប ។

[43] ការបោះបង្គោលកំណត់ EEZ ដែរបស់កម្ពុជាមានជំលោះជាមួយប្រទេសវៀតណាមនិងប្រទេសថៃ។

[44] កំណត់សំគាល់របស់អ្នកបកប្រែ: ចំងាយ ២០០ ម៉ៃល៍ = ២០០ x ១,៨៥២ គ.ម. = ៣៧០,៤ គ.ម.

ប្រាស់ចំពោះការនេសាទទឹកសាបធ្វើជាមធ្យោបាយគ្រប់គ្រង និងជាប្រភពប្រាក់ចំណូលសំរាប់រដ្ឋាភិបាល ។ សម្បទានដែលមានរយៈពេលពីរឆ្នាំចំពោះឡូត៍នេសាទត្រូវបានរដ្ឋផ្តល់ឱ្យអ្នកហ៊ានដេញថ្លៃខ្ពស់បំផុតនៅក្នុង ការដេញថ្លៃជាសាធារណៈ[45] ។ ប្រតិបត្តិករឡូត៍នេសាទចាំបាច់ត្រូវអនុវត្តតាមវិធានគ្រប់គ្រង ដែលមានចែងនៅក្នុងសៀវភៅ"បន្ទុក"របស់សម្បទាន ដែលចែងអំពី (i) តំបន់ឡូត៍នេសាទដែលផ្តល់ឱ្យសម្បទានិកប្រើប្រាស់ផ្តាច់មុខ និង"តំបន់រក្សាទុកសំរាប់ប្រជាពលរដ្ឋ" នៅក្នុងឡូត៍នេសាទដែលគេអនុញ្ញាតឱ្យប្រជា-ពលរដ្ឋនេសាទ (ii) អំឡុងពេលបើករដូវនេសាទ (គឺពីខែ តុលា ដល់ខែឧសភាសំរាប់តំបន់ភាគខាងជើងទីក្រុងភ្នំពេញ ពីខែវិច្ឆិកា ដល់ខែមិថុនាសំរាប់តំបន់ខាងត្បូងទីក្រុងភ្នំពេញ) (iii) ប្រភេទនិងចំនួននៃឧបករណ៍នេសាទដែលច្បាប់អនុញ្ញាត ។ ទោះជាយ៉ាងណាក៏ដោយ ការនេសាទដោយខុសច្បាប់កើតមានជាទូទៅ ហើយចាំបាច់ត្រូវធ្វើការវាយតំលៃសារឡើងវិញនូវប្រសិទ្ធិភាពនៃប្រព័ន្ធសម្បទានពាណិជ្ជកម្មរាប់ទាំងវិសាលភាពនៃប្រព័ន្ធសម្បទានដែលមានរយៈពេលពីរឆ្នាំ ក្នុងការផ្តល់ការលើកទឹកចិត្តឱ្យមានការ គ្រប់គ្រងធនធាន ដែលមាននិរន្តរភាពផងដែរ ។

៧៣. បន្ថែមលើការនេសាទក្នុងឡូត៍នេសាទដែលមានខ្នាតធំ នៅក្នុងច្បាប់ជលផលបច្ចុប្បន្ន ការនេសាទទឹកសាបក៏រួមមានផងដែរនូវប្រតិបត្តិករខ្នាតមធ្យម ដែលបានទទួលអាជ្ញាប័ណ្ណឱ្យនេសាទនៅក្នុងតំបន់នេសាទ-សាធារណៈ(ក្រៅឡូត៍នេសាទ តំបន់បំរុងទុក និងតំបន់ការពារ) នៅក្នុងអំឡុងពេលជាក់លាក់ ក៏ដូចជាប្រតិបត្តិករខ្នាតតូចដែលមិនតំរូវឱ្យមានអាជ្ញាប័ណ្ណ និងដែលទទួលបានការអនុញ្ញាតិឱ្យនេសាទគ្រប់ពេលវេលាក្នុងតំបន់នេសាទសាធារណៈក៏ដូចជានៅក្នុងតំបន់សាធារណៈក្នុងឡូត៍នេសាទផងដែរ ។ ត្រីទឹកសាបដែលខកខ្លួននៅតាមទីផ្សេងៗក្រោយពេលទឹកស្រក ក៏ត្រូវបានគេនេសាទពីវាលស្រែ សំរាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃផងដែរ ។ ទាំងប្រតិបត្តិករខ្នាតមធ្យម និងខ្នាតតូចត្រូវគោរពតាមបទប្បញ្ញត្តិជលផល ទូទៅរាប់ទាំងការគោរពតាមបទប្បញ្ញត្តិស្តីពីប្រភេទឧបករណ៍នេសាទផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ការនេសាទត្រីដែលមានចរិតបំផ្លិចបំផ្លាញ និងនេសាទដោយខុសច្បាប់កើតមានជាទូទៅ ។

---

[45] ដែលមានបញ្ហាចោទអំពីតម្លាភាព និងនិយ័តភាព ។

៧៤. *ប្រព័ន្ធគ្រប់គ្រងដែលមានមូលដ្ឋានលើប្រព័ន្ធមួយស្មុគស្មាញសំរាប់ការញែកចេញពីគ្នានូវអាជីវកម្ម ដែលមានចរិតពាណិជ្ជកម្មខ្នាតមធ្យម និងខ្នាតតូច ពិសេសគឺការនេសាទជីវព្រឹត្ត បានបង្កើនសក្តានុពល ទំនាស់ពីផ្នែកផ្សេងៗនៃការនេសាទទឹកសាប ។* បញ្ហាអភិបាលកិច្ចមានលក្ខណៈធ្ងន់ធ្ងរ ហើយចំណាយសង្គម មានកំរិតខ្ពស់ ។ ការធ្វើឯកជនភាវូបនីយកម្មនៃឡូត៍នេសាទ (ក្នុងពេលគ្មានការអនុវត្តន៏ច្បាប់ដែលមាន ប្រសិទ្ធិភាព) ការដកហូតសិទ្ធប្រើប្រាស់ពីសំណាក់ក្រុមនិងមន្ត្រីមូលដ្ឋានមានសមត្ថកិច្ច រាប់ទាំងប្រធានភូមិ និងប្រធានឃុំ មិនអនុញ្ញាតឱ្យសហគមន៏មានលទ្ធភាពចូលទៅនេសាទក្នុងតំបន់អនុញ្ញាតមួយចំនួនឡើយ តំបន់ដែលគេតែងនេសាទនៅក្នុងប្រព័ន្ធសម្បទានកាន់តែធ្វើឱ្យវិវាទមានលក្ខណៈស្រួចស្រាល់បន្ថែមទៀត [៤៦] ទន្ទឹមនឹងនេះផងដែរទំនាស់ផ្ទៃក្នុងវិស័យអំពីការប្រើប្រាស់ទឹកសំរាប់កសិកម្ម និងការប្រើប្រាស់សំរាប់សំរាប់ នាវាចរណ៏កើតមានជាទូទៅ ។

៧៥. ក្នុងឆ្នាំ ២000 ឡូត៏នេសាទធំៗត្រូវបានគេប៉ាន់ស្មានថាមានទំហំជិតស្មើនឹង ១0,000 គីឡូម៉ែត្រ ក្រឡាជាតំបន់នេសាទទឹកសាបដែលផ្តល់ផលិតភាពខ្ពស់បំផុតរាប់ទាំងតំបន់តាមដងទន្លេ និងតំបន់វាលរាប ធំល្វឹងល្វើយ ដែលមាននិវាសនដ្ឋានរបស់ប្រជាពលរដ្ឋរាប់សែននាក់ ដីកសិកម្មរាប់សែនហិកតា និងជំរក ព្រៃលិចទឹក ដែលមានសារៈសំខាន់ក្នុងការបន្តពូជ និងជាមូលដ្ឋានជំរកសំរាប់ត្រី និងមច្ឆជាតិជាច្រើន ។ ក្នុងខែមិថុនា ឆ្នាំ២00១ បន្ទាប់ពីមាន ទំនាស់ដោយអំពើហឹង្សាលើការប្រើប្រាស់ទឹក រវាងសម្បទានិក ឡូត៍នេសាទនិងកសិករមក ផ្ទៃទឹកដែលស្ថិតនៅក្នុងសម្បទាននេសាទត្រូវបានកាត់បន្ថយជាងពាក់កណ្តាល មកត្រឹម ៤១៧.000 ហិកតា ។ ការលុបសម្បទាននេះ ដែលកាត់បន្ថយដោយប្រសិទ្ធភាពនូវផ្ទៃដីកសិកម្ម ក៏ដូចជាកាត់បន្ថយចំនួនប្រជាពលរដ្ឋរស់នៅក្នុងតំបន់ សម្បទាន គួរណាស់តែកាត់បន្ថយទំនាស់ផ្ទៃក្នុងវិស័យ ក្នុងកំរិតណាមួយ ។ ទោះជាយ៉ាងនេះក្តី ការលុបចោលនេះប្រព្រឹត្តទៅដោយគ្មានការពិគ្រោះអំពីវិធីប្រើប្រាស់ ធនធានបន្ទាប់ពីការលុប ហើយក៏មិនបានរៀបចំផែនការពីដើមដំបូង សំរាប់គ្រប់គ្រងធនធានដែរ ធ្វើឱ្យតំបន់ មួយចំនួនកាន់តែមានសកម្មភាពអាជីវកម្មខ្លាំងឡើងលើធនធាន និងបង្កឱ្យមានទំនាស់កាន់តែច្រើនឡើង

---

[46] មានការវាយតំលៃមួយចំនួនបង្ហាញថាតំបន់ដែលគេអនុញ្ញាតគឺជាតំបន់ដែលមានត្រីតិចបំផុតហើយមិនងាយនឹងចូលទៅនេសាទ បានឡើយ ។

នៅផ្ទៃក្នុងវិស័យ ។ តំបន់ ដែលផ្តល់ឱ្យត្រូវគ្រប់គ្រងរួមគ្នាដោយប្រព័ន្ធគ្រប់គ្រងជលផលរបស់សហគមន៍ ។

៧៦. *សហគមន៍នេសាទត្រូវបានអនុវត្តសាកល្បងធ្វើជាប្រព័ន្ធគ្រប់គ្រងតាមជំរើសបែបផ្សេង ។* ដើម្បីដោះស្រាយវិវាទរវាងម្ចាស់ឡូតិ៍នេសាទ និងអ្នកនេសាទខ្នាតតូច និងដើម្បីដោះស្រាយបញ្ហាគ្រប់គ្រងជលផលទូទៅអំពីការធ្វើអជីវកម្មហួសហេតុ និងអំពីការប្រើបច្ចេកទេសនេសាទដែលមានចរិតបំផ្លិចបំផ្លាញ ដើម្បីសំរេចបាន នូវគោលដៅរួមនៃការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃការនេសាទ គេបានលើកអនុសាសន៍ស្តីពី ការរួមគ្នាគ្រប់គ្រងជលផល ដែលជាកិច្ចសហការដោយស្ម័គ្រចិត្តរវាងភាគីពាក់ព័ន្ធក្នុងការនេសាទ ។ DoF បានរៀបចំអនុក្រឹត្យមួយស្តីពីសហគមន៍នេសាទ ។ ក៏ប៉ុន្តែរហូតមកទល់ពេលនេះនៅកម្ពុជា ពុំមានបទពិសោធន៍គ្រប់គ្រាន់ ក្នុងការគ្រប់គ្រងរួមគ្នាឡើយ ។ CDRI (ឆ្នាំ២០០២) បានកំណត់ អតសញ្ញាណសហគមន៍នេសាទចំនួន ១៦២ ដែលបានបង្កើតឡើងចាប់តាំងពីចុងទសវត្សរ៍ ១៩៩០ដោយមាន ការឧបត្ថម្ភគាំទ្រពីអ្នកផ្តល់ជំនួយ និងពីអង្គការក្រៅរដ្ឋាភិបាល ពាក់ព័ន្ធជាមួយប្រជាពលរដ្ឋជាង ៣០០,០០០ នាក់ និងគ្របដណ្តប់លើផ្ទៃដី-ទឹកប្រមាណជា ២២៥,០០០ ហិកតា ។ មួយផ្នែកធំ ការងារទាំងនេះគឺជា កិច្ចប្រឹងប្រែងដែលមានចរិតបុគ្គល ដែលធ្វើឱ្យមានការសម្របសម្រួលមានប្រសិទ្ធភាពតិចតួចប៉ុណ្ណោះ ។ ការតាមដានសកម្មភាពអនុវត្តសាកល្បង និងដកពិសោធន៍មេរៀនសំរាប់អនុវត្តទូទៅ គឺជាការសំខាន់ណាស់ ។

៧៧. *ការគ្រប់គ្រងជលផលទឹកប្រៃក៏ជួបឧបសគ្គផងដែរដោយបញ្ហាអភិបាលកិច្ចធ្ងន់ធ្ងរ និងខ្វះធនធានសំរាប់អនុវត្តបទប្បញ្ញត្តិបច្ចុប្បន្ន ។* នេសាទទឹកប្រៃចែកចេញជាពីរផ្នែក (i) តាមឆ្នេរដែលមានជំរៅទឹកតិចជាង ២០ ម៉ែត្រ (ii) ការនេសាទនៅឯនាយសមុទ្រដែលមានជំរៅទឹកជ្រៅជាង ២០ ម៉ែត្រ ។ ដែនទឹកនេសាទ

ឯនាយសមុទ្រត្រូវបាននេសាទផ្តាច់មុខដោយកងនេសាទក្នុងទ្រង់ទ្រាយធំដែលរួមមាននាវាមានម៉ាស៊ីនមានកំលាំងធំជាង៥០សេះ។ ជាទូទៅ ទូកខ្នាតធំទាំងនេះមានម្ចាស់ជាជនជាតិថៃ ឬជនជាតិវៀតណាម ក្នុងនោះមាន ទូកមួយចំនួនតូចប៉ុណ្ណោះដែលមានអាជ្ញាប័ណ្ណអនុញ្ញាតឱ្យនេសាទនៅក្នុងដែនទឹកកម្ពុជា ។ ទូកដែលមានម្ចាស់ ជាពលរដ្ឋកម្ពុជានេសាទនៅក្នុងដែនទឹកតាមឆ្នេរសមុទ្រ ទាំងនេះរួមមាន

កងនេសាទដែលមានទូកខ្នាតតូចរួម មានទូកគ្មានម៉ាស៊ីន ឬមានម៉ាស៊ីនតូចដែលគេអនុញ្ញាតឱ្យនេសាទ ពុំចាំបាច់មានអាជ្ញាប័ណ្ណ និងកងនេសាទ ដែលមានខ្នាតមធ្យម រួមមាននាវាដែលមានម៉ាស៊ីនមានកំលាំងតិចជាង៥០សេះ ត្រូវមានអាជ្ញាប័ណ្ណ ។ នៅក្នុងដែនទឹកឯនាយសមុទ្រ មានទំនាស់ជាមួយជនជាតិថៃ និងជនជាតិវៀតណាម ជាទំនាស់កើតមាន ជាទូទៅ ហើយការអនុវត្តន៍ច្បាប់នេសាទស ្តីពីនាវាបរទេសដែលគ្មានអាជ្ញាប័ណ្ណ និងការនេសាទដោយខុស ច្បាប់ គឺជាបញ្ហាចំបងមួយក្នុងខណៈនាយកដ្ឋានជលផលមានធនធានតិចតួចស ្តួចសេ ្តីង ។ ផលនេសាទពី ដែនទឹកឯនាយសមុទ្រមិនត្រូវបានគេកត់ត្រាបានត្រឹមត្រូវឡើយ ព្រោះថាផលនេសាទមួយភាគធំត្រូវបានគេផ្ទេរដោយផ្ទាល់ទៅកាន់វៀតណាម និងថៃដែលធ្វើឱ្យការវាយ តំលៃស្ថានភាពធនធាន ជួបការលំបាក ។ ដោយមានគាំទ្រពី DANIDA កម្មវិធីគ្រប់គ្រងតំបន់ មាត់សមុទ្រកំពុងត្រូវបានអនុវត ្ត ដើម្បីដោះស្រាយបញ្ហាមួយចំនួននៃបញ្ហាទាំងអស់នេះ ។

៧៨. *ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សំរាប់វិស័យជលផលកំពុងត្រូវបានកែលំអ ប៉ុន្តែនៅមានការព្រួយបារម្ភមួយចំនួននៅឡើយ ។* សេចក្តីព្រាងច្បាប់នេសាទ សេចក្តីព្រាងអនុក្រឹត្យមួយចំនួន ក៏ដូចជាបានធ្វើសេចក្តីព្រាងផែនការមេសំរាប់កិច្ចអធិវឌ្ឍន៏ការនេសាទ ត្រូវបានរៀបចំ។ ច្បាប់ដែលបានកែសំរួលនិងរួមបញ្ចូលនូវការផ្តោតការយកចិត្តទុកដាក់ខ្លាំង អំពីការចូលរួមរបស់សហគមន៏ក្នុងគ្រប់គ្រងធនធានជលផល យ៉ាងហោចណាស់ក៏នៅក្នុងតំបន់ទឹកសាបដែរ។ មានការព្រួយបារម្ភមួយចំនួន :

- *ការវាយតំលៃកាន់តែប្រសើរអំពីធនធានជាការចាំបាច់ ដើម្បីជួយផ្តល់ដំណឹងចំពោះការសំរេចចិត្តលើគោលនយោបាយ ។*មានសញ្ញាណដែលបង្ហាញអំពីការនេសាទហួសហេតុ ដែលមានតំលៃនៃផលចាប់ និងផលចាប់ក្នុងមួយឯកតានៃកិច្ចប្រឹងប្រែងចុះថយ។ ទោះជាយ៉ាងនេះក្តី ស្ថិតិជលផលគឺជាតួលេខដែលមិនអាចជឿទុកចិត្តបានឡើយ ហើយគ្មានការវាយតំលៃអំពីបរិមាណស្តុកនៃប្រភេទត្រីផ្សេងៗ សំរាប់រៀបចំគោលនយោបាយ និងរៀបចំកិច្ចអភិវឌ្ឍន៏ដែលគ្រប់គ្រងដោយបទប្បញ្ញត្តិឡើយ ទោះជានៅទឹកសាប ឬទឹកប្រៃក្តី។
- *ការរៀបចំគ្រប់គ្រងដោយបទប្បញ្ញត្តិចាំបាច់ត្រូវជូនដំណឹង ដោយធ្វើការសិក្សាស្រាវជ្រាវនិងកិច្ចពិគ្រោះជាមួយនិងរបស់តួភាគីពាក់ព័ន្ធ ។* ការផ្តល់សម្បទាននៅឆ្នាំ ២០០០ នៅក្នុងក្របខ័ណ្ឌសាធារណៈ ពុំបានប្រព្រឹត្តទៅ ដោយការសិក្សាអំពីលទ្ធភាពអនុវត្តន៏បានគ្រប់គ្រាន់ និងពុំបានសិក្សាគ្រប់គ្រាន់អំពីផលប៉ះពាល់ឡើយ ហើយតំរូវឱ្យមានកិច្ចការបន្ថែមទៀតអំពីសក្តានុពលនៃ

ភាពក្រីក្រនិង ផលប៉ះពាល់មកលើសង្គមនៃកំណែទំរង់ មុនពេលបញ្ចប់បទប្បញ្ញត្តិសំខាន់ៗ។ ជាងនេះទៅទៀតនាយកដ្ឋានជលផលមានការរារែកក្នុងការ ពិគ្រោះយោបល់ នាយកដ្ឋានចាំបាច់ត្រូវមានលក្ខណៈសកម្មបន្ថែមទៀតក្នុងការចូលរួមពិភាក្សា ដែលសាធារណៈ ។ ដើម្បីដោះស្រាយកង្វល់ទាំងអស់នេះ ការវាយតំលៃអំពីផលប៉ះពាល់នៃកំណែទំរង់ថ្មីៗដែលបានទទួលហិរញ្ញប្បទានពី DFID កំពុងប្រព្រឹត្តទៅនិងត្រូវបានអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបំពេញបន្ថែមលើការពិគ្រោះយោបល់ ។ ទន្ទឹមជាមួយនេះ គេត្រូវការឱ្យមានការសិក្សាបន្ថែមទៀត ដើម្បីជូនដំណឹងអំពីកិច្ចអភិវឌ្ឍន៍ ការគ្រប់គ្រងលើមូលដ្ឋានដែលអាចស្ថិតស្ថេរ (ឬការគ្រប់គ្រងរួមគ្នា) និងដើម្បីស្វែងរកបែបផែននៃការគ្រប់គ្រងដទៃទៀតដែលសមស្របជាមួយស្ថានភាពនៅមូលដ្ឋាន និងស្របតាមសមត្ថភាពរបស់នាយកដ្ឋានជលផល ។ គេគប្បីធ្វើការសិក្សាមួយ ដើម្បីប្រៀបធៀបប្រព័ន្ធ "គ្រប់គ្រងរួមគ្នា " ជាមួយនឹងប្រព័ន្ធគ្រប់គ្រងឡូត៍នេសាទ ដោយពិចារណាអំពីរយៈពេលគ្រប់គ្រងខ្លីចំនួន២ឆ្នាំ។

- *នៅក្នុងការប្រែប្រួលបរិស្ថានកម្ពុជាយ៉ាងឆាប់រហ័ស ភាពគ្រប់គ្រាន់នៃប្បញ្ញាតិរបស់ច្បាប់ថ្មី និងបទប្បញ្ញត្តិជាបន្តបន្ទាប់ នាយកដ្ឋានរុក្ខាប្រមាញ់* ត្រូវតាមដានអោយមានជិតស្និទ្ធ ហើយត្រូវប្រកាន់យកវិធីសាស្រ្តសកម្ម ក្នុងការធ្វើវិសោធនកម្មបញ្ញត្តិច្បាប់ និង បទប្បញ្ញត្តិ ប្រសិនបើរកឃើញថាមានឥទ្ធិពលអវិជ្ជមាន ។
- *សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗនៅជាឧបសគ្គនៅឡើយ ។* ការបង្កើតច្បាប់ថ្មី និងការបង្កើតអនុក្រឹត្យជាបន្តបន្ទាប់នឹងមានផលប៉ះពាល់តិចតួច នៅពេលដែលគេមិនអាចអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិនានាបានសមស្រប ។ បញ្ហានេះមិនអាចដោះស្រាយបានដោយ នាយកដ្ឋានជលផល តែមួយបានទេ ហើយតំរូវឱ្យមានសហប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធសំខាន់ៗ ( អាជ្ញាធរមូលដ្ឋាន កងទ័ព ។ល។ )[47] ។

៧៩. *អត្ថប្រយោជន៍បន្ថែមទៀតអាចទទួលបានតាមរយៈកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម និងការកែលំអខ្សែសង្វាក់តំលៃនៃជលផល ។* មានសក្តានុពលជាច្រើនសំរាប់ធ្វើវារីវប្បកម្ម រាប់ទាំងអតិផលក៏វិតទាបដូចជាការធ្វើការចិញ្ចឹមត្រីនៅក្នុងវាលស្រែក្នុងធ្វើស្រែ។ ក្រៅពីនេះ ការបង្កើតបណ្តាញទីផ្សារតាមរយៈការវិនិយោគឯកជននៅលើប្រព័ន្ធទ្រទ្រង់ ដូចជាការផលិតទឹកកក និងមធ្យោបាយកែច្នៃដែលឆ្លើយតប និងស្តង់ដារ

[47] នេះគឺជាបញ្ហា ប្រឈមសំខាន់មួយ ទាក់ទងនិងបញ្ហានេះមានរបាយការស្តីពីការវាយប្រហាររបស់កងទ័ពនិងមន្ត្រី DoF ដែលព្យាយាមអនុវត្តន៍បទបញ្ញត្តិ ដែលធ្វើអោយប៉ះពាល់ដល់បញ្ហាកងទ័ព ។

អន្តរជាតិ អាចផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់កិច្ចអភិវឌ្ឍន៍សិប្បកម្ម នឹងពាណិជ្ជកម្មជលផលទូទៅ ។ បញ្ហាទាំងអស់នេះមានបញ្ជាក់ក្នុងផ្នែកខាងក្រោមនៅក្នុងផ្នែកនិយាយអំពី " ការលើកកំពស់ប្រាក់ចំណូលកសិកម្ម " ។

## អនុសាសន៍ស្តីពីសកម្មភាពជាអាទិភាពសំរាប់កំណែទំរង់ការគ្រប់គ្រងជលផល

### អាទិភាពទី ១ ពង្រឹងក្របខ័ណ្ឌស្ថាប័នសំរាប់គ្រប់គ្រងធនធានជលផល

- *កំណែទំរង់និងការពង្រឹងស្ថាប័ន* ៖ពិនិត្យមើលឡើងវិញនូវប្រព័ន្ធបច្ចុប្បន្ន រាប់ទាំងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ ។ បង្កើតគណៈកម្មាធិការអន្តរក្រសួងដើម្បីសម្របសម្រួលនិងប្រើប្រាស់ធនធានវារីជាតិ ។ ពង្រឹងការសម្របសម្រួលរបស់អ្នកផ្តល់ជំនួយនៅក្នុងវិស័យជលផល លើគោលការណ៍យុទ្ធសាស្រ្តទូទៅ (ឆ្ពោះទៅរកកម្មវិធីទូទៅនៅក្នុងវិស័យ) ។
- *តាមដានការអនុវត្តន៍ និង ផលប៉ះពាល់នៃក្របខ័ណ្ឌច្បាប់ និង បទប្បញ្ញត្តិថ្មី ដើម្បីកំណត់តំរូវការដែលអាចមានចំពោះការកែតំរូវបន្ថែម ។*
- *ដោះស្រាយភាពខុសគ្នារវាងការរៀបចំក្របខ័ណ្ឌគោលនយោបាយ / ក្របខ័ណ្ឌគ្រប់គ្រងដោយបទប្បញ្ញត្តិជាមួយនឹងការអនុវត្តន៍ ។* ពង្រឹងការធ្វើវិសហមជ្ឈការការិយាល័យជលផល នឹងវិសហមជ្ឈការសមត្ថភាពសំរាប់អនុវត្តច្បាប់និងបទប្បញ្ញត្តិបច្ចុប្បន្ននៅថ្នាក់មូលដ្ឋាន ។ ពង្រឹងភាពជាដៃគូនិងកិច្ចសហការជាមួយ នឹងអាជ្ញាធរមូលដ្ឋាន ជាមួយសហគមន៍ និងជាមួយអង្គការក្រៅរដ្ឋាភិបាល ។
- *បង្កើនសមត្ថភាពវាយតំលៃបរិមាណស្តុករបស់ត្រីជាបណ្តើៗចំពោះនេសាទទឹកសាប និងនេសាទទឹកប្រៃ ។* ការវាយតំលៃនេះនឹងត្រូវប្រើប្រាស់សំរាប់ជួយក្នុងការរៀបចំគោលនយោបាយ បទប្បញ្ញត្តិ និងយន្តការអនុវត្តន៍ ដើម្បីគ្រប់គ្រងបរិមាណស្តុករបស់ត្រីឱ្យមានប្រសិទ្ធភាព ធានាឱ្យបាននូវផលនេសាទដែលមាននិរន្តរភាព នឹងកាត់បន្ថយការនេសាទហួសហេតុ នឹងកាត់បន្ថយការរិចរិល នូវតំលៃស្តុកនៃធនធាន ។ ការងារទាំងអស់នេះនឹងរួមមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ហើយគប្បីពិចារណាអំពីហានិភ័យនៃផលប៉ះពាល់ដល់វិស័យនានាមកលើការនេសាទ ពីវិស័យកិច្ចអភិវឌ្ឍន៍កសិកម្ម អភិវឌ្ឍន៍ព្រៃឈើ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ សំរាប់រយៈពេលវែង ការវាយតំលៃ ឱ្យកាន់តែប្រសើរនូវបរិមាណស្តុកនៃជីវៈចំរុះ សមាសភាពជលផល និងរបាយធនធានជលផលនិមួយៗ នឹងអនុញ្ញាតឱ្យកំណត់នូវទិន្នផលមាននិរន្តរភាពផ្នែកសេដ្ឋកិច្ចដែលនៅក្នុងទិដ្ឋភាពផ្សេងៗ ។

## អាទិភាពទី ២ ពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងធនធានជលផល

- *ធ្វើសនិទានកម្មប្រព័ន្ធសម្បទាន* ។ ពិនិត្យមើលសារឡើងវិញនូវប្រសិទ្ធភាពនៃប្រព័ន្ធសម្បទានបច្ចុប្បន្ន ក្នុងការឆ្លើយតបនឹងគោលដៅរួមរបស់រដ្ឋាភិបាលអំពីការគ្រប់គ្រងធនធានជលផលដែលមាននិរន្តភាព និងមានប្រសិទ្ធភាព ។
- *ពិនិត្យមើលឡើងវិញនូវមេរៀនពីបទពិសោធន៍នានាជាមួយសហគមន៍នេសាទ ។* ពិនិត្យមើលឡើងវិញនូវផលិតផលការអនុវត្តន៍សាកល្បង និងរៀបចំប្រព័ន្ធគ្រប់គ្រងនៅតាមសហគមន៍ដែលអាចស្ថិតស្ថេររាប់ទាំងការបង្កើតនិតិវិធីសំរាប់ដាក់បញ្ចូល និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ។ ជំនួយបច្ចេក-ទេស / ការសិក្សា ក៏គប្បីស្វែងរកនៅជំរើសនៃការគ្រប់គ្រងដទៃទៀតសំរាប់ DoF ផងដែរ ។
- *ដាក់ឱ្យមានកំណែទំរង់លើគ្រប់គ្រងជលផលដែលដោះស្រាយសមស្របនូវនិរន្តរភាព លទ្ធភាពនេសាទ នឹងបញ្ហាសិទ្ធិរបស់អ្នកនេសាទខ្នាតតូច ។* ផ្អែកលើការពិនិត្យមើលសារឡើងវិញខាងលើនេះ នឹងផ្អែកលើបទពិសោធន៍អន្តរជាតិ ស្វែងរកជំរើសគ្រប់គ្រងដទៃទៀត ។

### កំណែទំរង់លើការគ្រប់គ្រងទឹក និងលើការគ្រប់គ្រងទឹកជំនន់

៨០. *ការគ្រប់គ្រងធនធានទឹក ការគ្រប់គ្រងធារាសាស្ត្រនិងទឹកជំនន់ នឹងការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ និងមានមុខងារសំខាន់នៅក្នុងរបៀបវារៈអភិវឌ្ឍន៍ជនបទ* ។ ទឹកគឺជាធនធានធម្មជាតិដែលមានសារៈសំខាន់ ហើយការប្រើប្រាស់និងការគ្រប់គ្រងបានត្រឹមត្រូវគឺជាគន្លឹះសំរាប់អភិវឌ្ឍន៍ជនបទ និងសំរាប់កាត់បន្ថយភាពក្រីក្រ តាមវិធីចំនួន ៥ យ៉ាងៈ (i) ជាកត្តាផលិតកម្មសំខាន់ៗសំរាប់ផលិតកម្មកសិកម្ម-ដើម្បីលើកកំពស់ជីវភាពឱ្យមានសន្តិសុខស្បៀងនិងអាហាររូបត្ថម្ភនៅជនបទ (ii) គឺជាប្រភពសំខាន់បំផុតតែមួយគត់នៃគ្រោះថ្នាក់ហានិភ័យនៅពេលមានភាពរាំងស្ងួតនិងនៅពេលមានទឹកជំនន់ (iii) គឺជាប្រភពនៃទឹកស្អាតសំរាប់បរិភោគ សំរាប់ងូត អនាម័យ និងសំរាប់ការប្រើប្រាស់ដទៃទៀតដើម្បីកាត់បន្ថយជំងឺដែលឆ្លងដោយសារទឹក និងកាត់បន្ថយការចំណាយពាក់ព័ន្ធនៃការថែទាំសុខភាព និងការប៉ះពាល់ដល់ការធ្វើការ និងការអប់រំ (iv) ជាមូលដ្ឋាននៃប្រព័ន្ធអេកូឡូស៊ីវារីជាតិ-ដើម្បីធ្វើឱ្យមាននិរន្តរភាពចំពោះការនេសាទទឹកសាប និង (v) ជាមធ្យោបាយសំខាន់មួយសំរាប់ដឹកជញ្ជូនមនុស្សនិងទំនិញ ជាពិសេសសំរាប់តំបន់ឆ្ងាយដាច់ស្រយាលនៅក្នុងរដូវវស្សា ។

៨១. ប្រទេសកម្ពុជាសំបូរណ៍ធនធានទឹក កម្ពុជាទទួលទឹកក្នុងមួយឆ្នាំប្រហែល ៤៧៥ BCM[48] ពីប្រព័ន្ធទន្លេមេគង្គដែលស្រោចស្រប់លើផ្ទៃប្រទេសប្រហែល៨៥% ។ ប៉ុន្តែភ្លៀងធ្លាក់មានរយៈពេល ៦ខែ នៅរដូវវស្សាហើយមានចំណុះអាងតិចតួចសំរាប់រក្សាទឹក និងសំរាប់សំរួលលំហូរទឹកនៅរដូវវស្សា ។ នៅក្នុង រយៈពេល ៦ខែនារដូវប្រាំង ការហួតហែងមានកំរិតលើសពីភ្លៀងធ្លាក់ ហើយកំពស់ទឹកនៅ តាមដងទន្លេធ្លាក់ចុះយ៉ាងខ្លាំង ធ្វើឱ្យប្រភពធនធានទឹកស្រទាប់លើដី ដែលស្ថិតនៅក្រៅចរន្តទន្លេមេគង្គនិង ទន្លេសាប មានតិចតួចនៅរដូវប្រាំង ។ ទឹកជំនន់កើតឡើងប្រចាំឆ្នាំហើយសឹងតែមិនអាចគ្រប់គ្រងបាន លើកលែងតែទំនប់ទឹកខ្សែក្រវាត់ក្រុងភ្នំពេញតែប៉ុណ្ណោះ ។ ក្នុងខណៈដែនទឹកជំនន់ប្រចាំឆ្នាំនាំមកនូវ អត្ថប្រយោជន៍វិជ្ជមានចំពោះវាលទំនាប ដោយបានបំពេញជីវជាតិនិងដីល្បប់ព្រមទាំងផ្តល់កន្លែងសំរាប់ឱ្យត្រីពង ទឹកជំនន់ក៏បង្កឱ្យមានការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធផលដំណាំ និងទ្រព្យសម្បត្តិបុគ្គលផងដែរ ព្រមទាំងធ្វើឱ្យអាក់ខានដល់ស្ថានភាពសេដ្ឋកិច្ចនិងសកម្មភាពដទៃទៀតជាច្រើន ។ ធនធានទឹកក្រោមដី ត្រូវបានប៉ាន់ស្មានថាមានប្រហែល 20 BCM ប៉ុន្តែសក្តានុពលសំរាប់ប្រើប្រាស់ទឹកក្រោមដី មានលក្ខណៈ ខុសៗគ្នាតាមភូមិសាស្ត្រ ហើយគ្មានការតាមដាន និងពុំបានយកមកប្រើប្រាស់ ។ នៅក្នុងតំបន់ជាច្រើន ជលសិលាមានស្រទាប់ស្មុគស្មាញ និងមានជាតិពុលខ្ពស់គឺជាបញ្ហាធ្ងន់ធ្ងរមួយនៅក្នុងតំបន់មួយចំនួននៅក្បែរ ផ្លូវទឹកទន្លេមេគង្គ។

៨២. *ចាំបាច់ត្រូវពង្រឹងក្របខ័ណ្ឌស្ថាប័នគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងទឹក* ។ ក្រសួង ធនធានទឹកនិងឧតុនិយម (MOWRAM) ដែលត្រូវបានបង្កើតនៅឆ្នាំ ១៩៩៩ ទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានទឹក រាប់ទាំងការគ្រប់គ្រងទឹកជំនន់ការស្រោចស្រព និងការបង្ហូរទឹកខ្នាតធំ ។ អង្គភាពរបស់ រដ្ឋាភិបាលដទៃទៀតដែលទទួលខុសត្រូវទាក់ទងនឹងបញ្ហាទឹករួមមានៈ (ក) ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (ផ្គត់ផ្គងទឹកស្អាតនិងអនាម័យនៅតំបន់ទីប្រជុំជននិងក្បែរទីប្រជុំជន) ក្រសួងអភិវឌ្ឍន៍ជនបទ (ផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យព្រមទាំងប្រព័ន្ធស្រោចស្រពខ្នាតតូច ) ក្រសួងសាធារណៈការនិងដឹកជញ្ជូន (បង្ហូរទឹក គ្រប់គ្រងទឹកជំនន់ និងនាវាចរណ៍) ក្រសួងបរិស្ថាន (គុណភាពទឹក) ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (ការគ្រប់គ្រងដីសើមនិងគ្រប់គ្រងការនេសាទ) នឹងក្រសួងសុខាភិបាល (ធនធានទឹកដែល ប៉ះពាល់ដល់សុខភាព) (ខ) អាជ្ញាធរខេត្តក្រុង (គ) ក្រុមប្រឹក្សាឃុំនិង (ឃ) គណៈកម្មាការអភិវឌ្ឍន៍ភូមិ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ មានការប្រឹងប្រែងយ៉ាងច្រើនក្នុងការអភិវឌ្ឍន៍គោលនយោបាយធនធាន ទឹក និងក្របខ័ណ្ឌច្បាប់ ។ ប្រការដែលគួរឱ្យកត់សំគាល់រួមមានមាន (i) គោលនយោបាយជាតិស្តីពី ធនធានទឹក រង់ចាំការអនុម័តពីក្រុមប្រឹក្សារដ្ឋមន្ត្រី (ii) សេចក្តីព្រាងច្បាប់

[48]ពាន់លានម៉ែត្រគូប

ថ្មីស្តីពីទឹក រង់ចាំការឯកភាពពី សភា (iii) យុទ្ធសាស្ត្រធនធានទឹក (iv) ក្របខ័ណ្ឌយុទ្ធសាស្ត្រទឹក (v) ផែនការយុទ្ធសាស្ត្រស្តីពីទឹក (vi) សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានទឹក ។ គោលនយោបាយ / យុទ្ធសាស្ត្រ / ច្បាប់ទាំងនេះបានទទួលការគាំទ្រ ពីអ្នកផ្តល់ជំនួយផ្សេងៗហើយរៀបចំបានល្អ ។ ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវ :

- ធ្វើសនិទានកម្ម ពង្រឹង និងអនុម័ត គោលនយោបាយ / យុទ្ធសាស្ត្រ /ច្បាប់ដែលមានក្នុងពេលបច្ចុប្បន្ន
- រៀបចំនិងអនុម័តអនុក្រឹត្យនិងបទប្បញ្ញត្តិផ្សេងៗ សំរាប់អនុវត្តន៍បញ្ញត្តិនានានៃច្បាប់ស្តីពីទឹក បោះផ្សាយអនុក្រឹត្យនិងបញ្ញត្តិទាំងនោះព្រមទាំងកសាងសមត្ថភាពរបស់ទីភ្នាក់ងារពាក់ព័ន្ធក្នុងការអនុវត្តន៍
- លើកកំពស់ភាពជាកម្មសិទ្ធរបស់រដ្ឋាភិបាលនិងបន្តលើកកំពស់ការសម្របសម្រួលរបស់អ្នកផ្តល់ជំនួយទាក់ទងនឹងរបៀបវារៈស្តីពីធនធានទឹកនៅកម្ពុជា
- លើកកំពស់ការងារសម្របសម្រួលរវាងស្ថាប័នរដ្ឋាភិបាលផ្សេងៗ លើការទទួលខុសត្រូវអំពីទឹកនៅគ្រប់ថ្នាក់
- បង្កើតផែនការសកម្មភាពជាយុទ្ធសាស្ត្រ ដោយផ្តោតការយកចិត្តទុកដាក់ ចំពោះអង្គភាពនានារបស់រដ្ឋាភិបាល ក្នុងការដឹកនាំកម្មវិធីពាក់ព័ន្ធនឹងទឹក ក្នុងបរិបទស្តីពីគោលនយោបាយ/យុទ្ធសាស្ត្រ/ច្បាប់ និងពិចារណាអំពីគោលដៅអភិឌ្ឍន៍តាមវិស័យដទៃទៀត (កសិកម្ម នេសាទ បរិស្ថាន ។ល។)

៨៣. *ការកសាងផែនការនិងការគ្រប់គ្រងធនធានទឹកនៅក្នុងក៏រិតនៃអាងទន្លេមេគង្គមានសារៈសំខាន់ក្នុងការ លៃយ៉ាងណាឱ្យការប្រើប្រាស់សិទ្ធិនិងធនធានដីធ្លីមាននិរន្តរភាពសំរាប់ជាអត្ថប្រយោជន៍នៃប្រជាពលរដ្ឋជនបទក្នុងពេលបច្ចុប្បន្ននឹងពេលអនាគត ។* គោលការណ៍អន្តរជាតិស្តីពីការគ្រប់គ្រងធនធានទឹកបង្ហាញថាការគ្រប់គ្រងធនធានទឹកគប្បីអនុវត្តន៍នៅក្នុងបរិបទអាងទន្លេមេគង្គ និងគប្បីឱ្យមានការចូលរួមពីក្រសួងមន្ទីរនៅថ្នាក់កណ្តាល អាជ្ញាធរមូលដ្ឋាន អ្នកប្រើប្រាស់ទឹក និងភាគីពាក់ព័ន្ធដទៃទៀត។ ដោយហេតុថាធនធានទឹករបស់កម្ពុជាមានប្រភពជាចំបងមកពីអាងទន្លេមេគង្គ ការកសាងផែនការអាងទន្លេ មេគង្គនៅក្នុងអនុអាងទន្លេមេគង្គនៅកម្ពុជាចាំបាច់ត្រូវអនុវត្តន៍ នៅក្នុងបរិបទនៃការកសាងផែនការអាងទន្លេមេគង្គដែលសម្របសម្រួលដោយគណៈកម្មការទន្លេមេគង្គ (MRC ) ។ កាលពីពេលថ្មីៗនេះ ក្រសួង MOWRAM បានជំនួសក្រសួងសាធារណៈការនិងដឹកជញ្ជូនក្នុងឋានៈជាស្ថាប័នរដ្ឋាភិបាលទទួលបន្ទុក និងទទួលខុសត្រូវក្នុងការសម្របសម្រួល ការចូលរួមរបស់កម្ពុជានៅក្នុង MRC និងសមត្ថភាពរបស់ MOWRAM ក្នុងការអនុវត្តន៍ការងារនេះ ចាំបាច់ត្រូវពង្រឹង។

៨៤. *កិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពចាំបាច់ត្រូវអនុវត្តន៍ នៅក្នុងបរិបទទូលាយពីការធ្វើពិពិធកម្មកសិកម្ម នៅក្នុងបរិបទគោលដៅរួមនៃការបង្កើនប្រាក់ចំណូលនៅជនបទ* ។ កសិកម្មរបស់ប្រទេសកម្ពុជាមួយចំណែកធំ ពឹងផ្អែកលើដំណាំស្រូវហើយមានដីស្រែប្រហែលតែ ២០% ឬ ៤៧៣.០០០ ហិកតាប៉ុណ្ណោះ ដែលមានកម្មវិធីស្រោចស្រព ។ ទោះជាយ៉ាងនេះក្តីទំហំនៃការរេសាចស្រពដែលមានប្រសិទ្ធិភាព មានកំរិតតិចជាងនេះឆ្ងាយណាស់ ។ នៅក្នុងចំណោមកម្មវិធីស្រោចស្រពបច្ចុប្បន្នចំនួន ៩៨៦ ដែលគ្របដណ្តប់លើផ្ទៃដី ៤៧០.០០០ ហិកតា និងមានផ្ទៃដីតែ ២៥០.០០០ ហិកតាប៉ុណ្ណោះ ដែលបានទទួលទឹកគ្រប់គ្រាន់ ដោយសារស្ថានភាពទ្រុឌទ្រោមទូទៅនិងដោយសារការរៀបចំ និងគ្រប់គ្រងកម្មវិធីពីដំបូងមិនបានល្អ។ ភាគច្រើនគេដាំស្រូវដោយគ្មានការស្រោចស្រព គឺដាំក្នុងរដូវវស្សា ឬដាំនៅចុងរដូវវស្សា និងដាំនៅក្នុងដើមរដូវប្រាំងលើតំបន់ធំល្វឹងល្វើយ ដែលទឹកស្រកបន្សល់ទុកដីល្បប់មានសំណើមយ៉ាងច្រើន-ហើយផលិតកម្មពីមួយឆ្នាំទៅមួយឆ្នាំមានការប្រែប្រួលយ៉ាងខ្លាំង ព្រោះថាផលិតកម្មស្រូវពឹងផ្អែកយ៉ាងខ្លាំងលើអាកាសធាតុ ជាពិសេសគឺពេលវេលាភ្លៀងធ្លាក់ និងកំរិតនៃទឹកភ្លៀង ។ បច្ចុប្បន្ននេះប្រទេសកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសផលិតដំណាំស្រូវ "ផ្គត់ផ្គង់ខ្លួនឯងបានគ្រប់គ្រាន់" គឺកម្ពុជាឆ្លើយតបនឹងតំរូវការទីផ្សារក្នុងស្រុក ហើយនាំចេញអង្ករមួយចំនួនតូចទៅក្រៅប្រទេស ។ ទោះជាយ៉ាងណាក៏ដោយ ផលិតកម្មស្រូវជាច្រើននៅប្រទេសកម្ពុជាត្រូវបានគេបរិភោគនៅតាមស្រែចំការហើយបញ្ហា អសន្តិសុខស្បៀងនៅជាបញ្ហាចំបងសំរាប់គ្រួសារក្រីក្រ ។ អាស្រ័យហេតុនេះវិធានការផ្សេងៗដូចជាការលើក កំពស់បច្ចេកវិទ្យាកសិកម្មនៅក្នុងតំបន់ស្រែវស្សា និងស្រែប្រដេញទឹក និងការធ្វើនិតិសម្បទាប្រព័ន្ធស្រោចស្រពខ្នាតតូចដែលមិនចំណាយខ្ពស់ ដើម្បីបង្កើនផលិតកម្មស្រូវប្រដេញទឹកសំរាប់កសិករធ្វើស្រែជីវព្រឹត្ត ក្នុងការបង្កើនផលិតកម្ម អាចជួយតំបន់មួយចំនួនឱ្យឆ្លើយតបនឹងកង្វះស្បៀងអាហារ ហើយអាចបង្កើនប្រាក់ចំណូលរបស់កសិករទាំងនេះ និងអាចដោះស្រាយដោយផ្ទាល់នូវភាពក្រីក្រ ។

៨៥. *ការពង្រីកឬការកែលំអប្រព័ន្ធស្រោចស្រពខ្នាតធំសំរាប់ផលិកម្មស្រូវ ភាគច្រើនគ្មានប្រសិទ្ធិភាពក្នុងការចំណាយឡើយ អាស្រ័យហេតុនេះកិច្ចអភិវឌ្ឍន៍ ប្រព័ន្ធស្រោចស្រព គប្បីផ្តោតលើដំណាំចំរុះដែលមានតំលៃខ្ពស់ជាងស្រូវ* ។ បញ្ហាដែលថាតើប្រទេសកម្ពុជាអាចនឹងមានលទ្ធភាពក្នុងការបង្កើន (តាមន័យសេដ្ឋកិច្ច) ការនាំចេញស្រូវច្រើនឬយ៉ាងណានោះ មួយផ្នែកធំអាស្រ័យលើការវិវឌ្ឍន៍នៃកត្តាផ្ទៃក្រៅ ដូចជាសមត្ថភាពផលិតកម្មលើសពីការប្រើប្រាស់នៅប្រទេសជិតខាង ។ ជាងនេះទៅទៀតផលិតកម្មស្រូវអាចកើនឡើងយ៉ាងច្រើនដោយមិនចាំបាច់ មានការវិនិយោគជាដុំកំភួនលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពថ្មីខ្នាតធំឡើយ ។ ចំណាយនិងចំណេញបន្ថែមនៃការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពថ្មីខ្នាតធំ ចាំបាច់ត្រូវប្រៀបធៀប

ជាមួយចំណាយនិងកំណើនផលចំណេញនៃការបង្កើនផលិតកម្មស្រូវវស្សា និងនិតិសម្បទានៃប្រព័ន្ធស្រោចស្រពបច្ចុប្បន្នដែលចំណាយតិច។ ភាពស្ថិតស្ថេរផ្នែកសេដ្ឋកិច្ចនៃវិនិយោគបែបនេះ ចាំបាច់ត្រូវមានការវាយតំលៃឱ្យបានប្រសើរតាមករណីជាក់ស្តែងនីមួយៗ ។ ក្នុងពេលបច្ចុប្បន្ននេះប្រទេសកម្ពុជានាំចូលផលិតផលមួយចំនួនដូចផ្លែឈើ និងបន្លែផ្សេងៗដែលគេអាចផលិតដោយចំណាយទាប សំរាប់បំរើសេចក្តីត្រូវការទីផ្សារក្នុងស្រុក ប្រសិនបើមានការត្រួតពិនិត្យគុណភាពដឹកជញ្ជូននិងយន្តការនិងរកទីផ្សារមានលក្ខណៈគ្រប់គ្រាន់ ។ ចាំបាច់ត្រូវយកចិត្តទុកដាក់លើប្រព័ន្ធស្រោចស្រពដោយផ្សារភ្ជាប់ជាមួយការដាំដំណាំចំរុះដែលផ្តល់តំលៃខ្ពស់ដោយពិចារណាអំពីភាពស្មុគស្មាញទាំងអស់ ពីការងារបែបនេះ ពោលគឺឧបសគ្គផ្នែកវប្បធម៌ ក្នុងការប្រែក្លាយកសិករដាំស្រូវឱ្យដាំដំណាំដទៃ កាតព្វកិច្ចពិនិត្យគុណភាពផ្លែឈើ និងបន្លែផ្សេងៗ ការរកទីផ្សារ ការកែច្នៃ បញ្ហាដឹកជញ្ជូននិងរក្សាទុក និងលទ្ធភាពបានទទួលឥទាណកសិកម្មបានទាន់ពេលវេលា។

## ប្រអប់ទី៤ : បញ្ហាប្រឈមនៃការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតធំនៅកម្ពុជា

គំរោងដែលបានទទួលហិរញ្ញប្បទានពីម្ចាស់ជំនួយភាគច្រើនប្រមូលផ្តុំលើកម្មវិធីស្រោចស្រពខ្នាតតូច និងខ្នាតមធ្យម លើមូលដ្ឋានដែលគិតថាភាពស្មុគស្មាញបន្ថែម នៃកម្មវិធីខ្នាតធំមានការលំបាកក្នុងការគ្រប់គ្រង នៅក្នុងបរិបទស្ថាប័ននិងសង្គមបច្ចុប្បន្ន :

- មាន FWUCs ជាច្រើននៅក្នុងកម្មវិធីមួយ នៅពេលដែល FWUCs នៅថ្មីនៅឡើយ ក្របខ័ណ្ឌច្បាប់មិនពេញលេញហើយចាំបាច់ត្រូវពង្រឹងសមត្ថភាពរបស់ MOWRAM
- ភាពខុសគ្នានៃសមត្ថភាពគ្រប់គ្រងរបស់ FWUC ដែលអាចធ្វើឱ្យមានទំនាស់
- ការលំបាកក្នុងការសំរេចបាននូវការរៀបចំកម្មវិធីស្រោចស្រពដែលមានការសម្របសម្រួលជាមួយមន្ទីរ MOWRAM（DOWRAMs）នៅថ្នាក់ខេត្ត ពុំមានជំនាញគ្រប់គ្រាន់ក្នុងការផ្តល់សេវា ដែលមានប្រសិទ្ធិភាព
- គ្មាននិតិវិធី O&M សំរាប់ផ្តល់មូនិធិចំពោះយថាប្រភេទហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដែល MOWRAM រក្សាទុក
- ការលំបាកមួយចំនួនក្នុងការធ្វើយ៉ាងណាឱ្យ FWUCs នៅក្នុងកម្មវិធីធំ ធ្វើសហប្រតិបត្តិការផ្ទុយទៅវិញ
- នៅក្នុងបណ្តាប្រទេសដែលវិស័យឯកជនទទួលអត្ថប្រយោជន៍អំពីបរិយាកាសអាជីវកម្មដែលមានលក្ខណៈអំណោយផល ការចូលរួមរបស់វិស័យឯកជននៅក្នុងកម្មវិធីធំៗមានលក្ខណៈងាយស្រួលជាង

- មានសេដ្ឋកិច្ចមាត្រដ្ឋាន សំរាប់ដំណាំថ្មីៗ ឧទាហរណ៍ កប្បាស សាកវប្បកម្ម ការចិញ្ចឹមត្រី ។ល។
-ការធ្វើកសិកម្ម ខ្នាតធំតាមបែបសហករណ៍ និងការរៀបចំចាត់ចែងផ្នែករកទីផ្សារ មានលទ្ធភាពច្រើន ក្នុងការចូលទៅកាន់ទីផ្សារនឹងមានភាពប្រកួតប្រជែងអំពីថ្លៃ
-គេកាន់តែមានឱកាសបន្ថែមទៀតនៅក្នុងការទទួលយកបច្ចេកវិទ្យា និងលើកកំពស់ប្រសិទ្ធិភាពនៃប្រព័ន្ធ ស្រោចស្រព ។

ទោះជាយ៉ាងនេះក៏ដោយកម្ពុជាត្រូវបង្កើតបរិស្ថានអំណោយផលបែបនេះ។

៨៦. *ការផ្តល់អាទិភាពនៃវិនិយោគក្នុងការគ្រប់គ្រងធនធានទឹក ចាំបាច់ត្រូវធ្វើសនិទានកម្មដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងផ្អែកលើគោលការណ៍ដែលបានរៀបរាប់ខាងលើ។* ឯកសារកសាងផែនការ សំរាប់ការវិនិយោគលើការងារគ្រប់គ្រងទឹក(ដូចឯកសារដែលបានរៀបចំ SEDP II ឬ NPRS) តាមធម្មតា មានបញ្ជីស្តីពីសំណើកម្មវិធីសំរាប់ធ្វើនិតិសម្បទាដែលរដ្ឋាភិបាលស្វែងរកធនធានបន្ថែម ។ របៀបដែល សំណើវិនិយោគទាក់ទងជាមួយគោលដៅរួមនិងគោលដៅជាក់លាក់របស់វិស័យនៃកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋាន តាមធម្មតាមានលក្ខណៈមិនច្បាស់លាស់ទេ ដូចគ្នាដែរចំពោះអាទិភាព លើការងារវិនិយោគ។

៨៧. *ការគ្រប់គ្រងទឹកជំនន់គប្បីគួសបញ្ជាក់អំពីការរស់នៅជាមួយទឹកជំនន់ ប្រសិនបើអាចធ្វើបានដាក់បញ្ចូល នូវការថែរក្សានិងការលើកកំពស់អត្ថប្រយោជន៍និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។* ទឹកជំនន់ប្រចាំឆ្នាំ ធ្វើឱ្យមានផលប៉ះពាល់ចំរុះបែប (ផ្នែកសង្គម-ផ្ទះសំបែងស្ថិតនៅឯកោ គេមិនអាចធ្វើដំណើរក្រៅពីទូក កាណូតបានទេ ប្រភពនៃទឹកស្អាតត្រូវបាត់បង់នៅពេលទឹកហូរចូលអណ្តូង ការរីករាលដាលនៃជំងឺពោះវៀន និងជំងឺដទៃទៀត និងផ្នែកសេដ្ឋកិច្ច- ខូចខាតផលដំណាំជាច្រើន ខូចខាតផ្លូវថ្នល់) ។ ការខាតបង់បែបនេះ នឹងកើនឡើងបន្ថែមទៀតនៅពេលដែលសេដ្ឋកិច្ចរបស់កម្ពុជារីកចំរើន ។ គោលនយោបាយរបស់រដ្ឋាភិបាល ដែលពឹងផ្អែកទៅលើទីភ្នាក់ងារអន្តរជាតិ ឱ្យរ៉ាប់រងចំពោះការខាតបង់ទាំងស្រុង ក្នុងការបញ្ចៀសគ្រោះ មហន្តរាយមិនអាចស្ថិតស្ថេរបានឡើយ ហើយរដ្ឋាភិបាល ត្រូវតៀមលក្ខណៈរែកពុនលើការខូចខាតទាំងនេះ មួយភាគធំ[49] ។ ដើម្បីធ្វើឱ្យកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រមាននិរន្តរភាព ចាំបាច់ត្រូវគ្រប់គ្រង

[49] នៅក្នុងពេលដែលមានទឹកជំនន់នៅឆ្នាំ២០០០/២០០១ជំនួយឧបត្ថម្ភគាំទ្រពីសហគមន៍អន្តរជាតិមានចំនួន ជិតស្មើនិងការខាតបង់ដោយផ្ទាល់ទាំងស្រុងបណ្តាលមកពីទឹកជំនន់ដែលមានបរិមាណទឹកប្រាក់ប្រហែល១៦០លានដុល្លា ( ស្មើនឹងពាក់កណ្តាលនៃចរន្តរបស់រដ្ឋាភិបាលសំរាប់ឆ្នាំ២០០០) ការខ្ចីប្រាក់ពីធនាគារADB និងពីធនាគារពិភពលោកមានបរិមាណស្មើនឹង៥០%នៃការខូចខាត

ហានិភ័យនៃគ្រោះមហន្តរាយតាមបែបមួយដែលមានលក្ខណៈសកម្មដោយប្រើប្រាស់វិធានការបង្ការ និង វិធានការបញ្ចៀស ប្រើប្រាស់ធាតុរចនាសម្ព័ន្ធ (ដូចជាហេដ្ឋារចនាសម្ព័ន្ធបង្ហូរទឹក ទំនប់ទឹកជាដើម) និងធាតុមិនមែនជារចនាសម្ព័ន្ធ ។

៨៨. *ទោះបីជាមានការប្រឹងប្រែងជាច្រើនក្នុងការកសាងសមត្ថភាពរបស់ខ្លួនក្ដី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៅតែខ្សោយ និងគ្មានលទ្ធភាពអនុវត្តន៍មុខងារសម្របសម្រួលរបស់ខ្លួនឡើយ ។* NCDM ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលកិច្ចប្រឹងប្រែងគ្រប់គ្រងមហន្តរាយនៅក្នុងប្រទេស ហើយគណៈកម្មាធិការ នេះមានសមាជិកភាពមកពីក្រសួងពាក់ព័ន្ធជាមួយទាក់ទង និងការគ្រប់គ្រងនឹងបញ្ចៀសគ្រោះមហន្តរាយធម្មជាតិ ។ ប៉ុន្តែសេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយដែលគេបានសសេរនៅឆ្នាំ ១៩៩៧ រដ្ឋាភិបាលនៅមិនទាន់អនុវត្តន៍នៅឡើយ ហើយថ្វីត្បិតតែគណៈកម្មាធិការនេះរាយការណ៍ដោយផ្ទាល់ទៅនាយករដ្ឋមន្ត្រីក្ដី គណៈកម្មាធិការនេះសឹងតែគ្មានអំណាច សូម្បីតែការសម្របសម្រួលសកម្មភាព ដូចជាការវាយតំលៃការខូចខាត និងការបញ្ជូនពត៌មានទៅកាន់សហគមន៍ងាយរងគ្រោះមុនពេលគ្រោះមហន្តរាយកើតឡើងក្ដី ។ ផ្អែកលើលទ្ធភាពនៃហេតុការណ៍គ្រោះមហន្តរាយនៅអនាគតចាំបាច់ត្រូវមានការជួយជ្រោមជ្រែងដល់ NCDM ឱ្យលើកកំពស់ប្រព័ន្ធ និងនិតិវិធីរបស់ខ្លួនសំរាប់វាយតំលៃការខូចខាត វាយតំលៃសេចក្ដីត្រូវការ និងរាយការណ៍អំពីគ្រោះមហន្តរាយ ក៏ដូចជាសមត្ថភាពសម្របសម្រួលរបស់ខ្លួនផងដែរ ។

៨៩. *ចាំបាច់ត្រូវមានវិធីសាស្ត្រដែលកាន់តែមានលក្ខណៈសកម្ម ចំពោះការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ ដោយផ្ដោតលើវិធានការបង្ការនិងបញ្ចៀស ។* បន្ថែមលើបទប្បញ្ញត្តិស្ដីពីការកសាងសមត្ថភាពលើកិច្ចប្រឹងប្រែងក្នុងពេលអនាគតក្នុងផ្នែកគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា ចាំបាច់ត្រូវមានការគាំទ្រពីយុទ្ធសាស្ត្រជាតិស្ដីពីការគ្រប់គ្រងនិងបញ្ចៀសគ្រោះមហន្តរាយដែលមានលក្ខណៈសកម្ម និងសំរបតាមលទ្ធភាពរបស់រដ្ឋាភិបាលជាពិសេសគឺលទ្ធភាពផ្នែកសារពើពន្ធនិងសមត្ថភាពផ្នែកបច្ចេកទេស ។ យុទ្ធសាស្ត្រនេះគប្បីផ្ដល់គ្រប់ខ័ណ្ឌគ្រប់គ្រងហានិភ័យពេញលេញមួយ ដែលកំណត់អត្តសញ្ញាណ ( យល់ដឹងអំពី ទំហំហានិភ័យបច្ចុប្បន្ន និងវាយតំលៃភាពងាយរងគ្រោះចំពោះសក្ដានុពលនៃផលប៉ះពាល់នៃគ្រោះមហន្តរាយនៃគ្រោះថ្នាក់ទាំងនោះ) ការកាត់បន្ថយហានិភ័យ ( ប្រកាន់យកវិធានការដើម្បីជៀសវាងគ្រោះមហន្តរាយនិងទប់ទល់ជាមួយផលប៉ះពាល់នៃគ្រោះមហន្តរាយ) និងការចែករំលែក /ផ្ទេរហានិភ័យ (អនុវត្តយុទ្ធសាស្ត្រ

---

ដោយផ្ទាល់ ។ គិតទៅក្នុងទូទាំងពិភពលោកជាទូទៅជំនួយឧបត្ថម្ភពីខាងក្រៅទូទាត់តិចជាង១០% នៃការខូតខាតបណ្ដាមកពីភាពអន្តរាយធម្មជាតិ ។

នានាសំរាប់កាត់បន្ថយផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ នៃគ្រោះមហន្តរាយមកលើពលរដ្ឋក្រីក្រ និងមកលើសេដ្ឋកិច្ច) ។ ក្របខ័ណ្ឌនេះចាំបាច់ត្រូវមានការទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសេចក្តីសំរេចចិត្តផ្នែកគោល-នយោបាយ ដើម្បីធ្វើយ៉ាងណាឱ្យសមាជិកនានារបស់ NCDM និងសហគមន៍ NGO ជាដៃគូមាន ប្រសិទ្ធិភាព ។ ការយកចិត្តទុកដាក់ក្នុងពេលបច្ចុប្បន្នលើសកម្មភាពក្រោយពេលមានគ្រោះមហន្តរាយ ចាំបាច់ត្រូវមានតុល្យភាពជាមួយនិងវិធានការបង្ការនិងបញ្ចៀស ។ ការធ្វើសុក្រិតកម្មនៃយុទ្ធសាស្ត្រនេះ ចាំបាច់ត្រូវមានការចូលរួម និងគប្បីប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធនានាទាក់ទងនឹងការផ្តល់មូលនិធិ លើការគ្រប់គ្រងគ្រោះមហន្តរាយ ។ជាពិសេសក្របខ័ណ្ឌនេះគប្បីដាក់បញ្ចូលមេរៀន ដែលត្រូវរៀនសូត្រពី កិច្ចប្រតិបត្តិល្អៗនៅអន្តរជាតិ និងនៅក្នុងស្រុក និងប្រើប្រាស់ បច្ចេកវិទ្យាបច្ចុប្បន្នសំរាប់គ្រប់គ្រងគ្រោះ មហន្តរាយ ក្នុងបរិបទនៃការកើតឡើងនូវគ្រោះមហន្តរាយទឹកដែលកាន់តែមានលក្ខណៈធ្ងន់ធ្ងរនៅកម្ពុជា ។

៩០. *ទាក់ទងនិងការកាត់បន្ថយភាពងាយរងគ្រោះនៅមូលដ្ឋាន ចាំបាច់ត្រូវមានការសិក្សាបន្ត នៅក្នុងផ្នែកសំខាន់ចំនួន ៣:* (i) ការគ្រប់គ្រងគ្រោះមហន្តរាយផ្អែកលើសហគមន៍ ។ គ្រោះមហន្តរាយធម្មជាតិមានផលប៉ះពាល់យ៉ាងខ្លាំងមកលើគ្រួសារក្រីក្រ និងធ្វើឱ្យរាំងស្ទះដល់ការផ្តល់សេវាសង្គមជាមូលដ្ឋាន ដូចជាទឹកស្អាត សុខាភិបាល និងការអប់រំ ។ វិធីល្អប្រសើបំផុតក្នុងការដោះស្រាយបញ្ហានេះគឺការបង្កលក្ខណៈឱ្យមានការចូលរួមពីសហគមន៍ មូលដ្ឋានក្នុងការបង្កើតវិធានការបញ្ចៀសនិងវិធានការសំរបខ្លួនតាមសភាពការណ៍ ។ អង្គការNGOs មួយចំនួនបាននិងកំពុងស្វែងរកវិធីទ្រទ្រង់សហគមន៍មូលដ្ឋានលើបញ្ហានេះ ដែលមានលទ្ធផលគួរឱ្យទុកចិត្ត ប៉ុន្តែតំរូវឱ្យមានការសិក្សាបន្ថែមទៀត (ii) ការគ្រប់គ្រងគ្រោះមហន្តរាយផ្អែកលើសហគមន៍ ចាំបាច់ត្រូវពង្រឹងបន្ថែមនូវកម្មវិធិយល់ដឹងបន្ថែមពីសាធារណៈជននិង (iii) ការកសាងបណ្តាញសុវត្ថិភាពសង្គមចំពោះសហគមន៍នានា ដើម្បីជយពួកគេក្នុងការសំរបខ្លួនក្រោយពេលមានគ្រោះមហន្តរាយ ។ បណ្តាញសុវត្ថិភាពទាំងនេះចាំបាច់ត្រូវលើកទឹកចិត្តឱ្យមានជំនឿជាក់លើខ្លួនឯង និងជៀសវាងការធ្វើឱ្យសហគមន៍ពឹងផ្អែកលើជំនួយជាដរាប តាមយៈការបង្កើតប្រភពចំណូលមិនមែនកសិកម្ម ការបង្កើតគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដែលផ្តល់សេវាសព្ជ័យ និងផ្តល់ឥណទាន ព្រមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ។ ត្រូវកំណត់គោលដៅបានសមស្របចំពោះសហគមន៍ដែលមានសេចក្តីខ្វះខាត ចាំបាច់ត្រូវយល់ដឹងអំពីយន្តការសម្របសម្រួលបច្ចុប្បន្ន និងយល់ដឹងថាតើត្រូវពង្រឹងយន្តការទាំងនោះដោយរបៀបណា ។

៩១. *ចាំបាច់ត្រូវដាក់បញ្ចូលវិធានការបញ្ចៀសទឹកជំនន់ទៅក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ* ។ ការរៀបចំប្លង់បច្ចេកទេស ជាពិសេសសំរាប់ប្លង់បច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ចាំបាច់ត្រូវមានគោលបំណងចំរុះបែប ។

ឧទាហរណ៏គេអាចកសាងផ្លូវដើម្បីទប់ទល់នឹងគ្រោះមហន្តរាយ និងធ្វើជាទីទួលខ្ពស់សំរាប់មនុស្សនិងសត្វ ដែលស្ថិតនៅក្នុងទីតាំងមិនអំណោយផល ។ គំរូប្លង់ដែលមានគោលដៅចំរុះទាំងនេះក៏អាចជាមធ្យោបាយ ផ្តល់ប្រសិទ្ធិភាពផងដែរអំពីការដាក់បញ្ចូលលក្ខណៈពិសេសស្តីពីការបញ្ចៀសទឹកជំនន់ទៅក្នុងគំរូប្លង់បច្ចេកទេស ហើយទិដ្ឋភាពទាំងនេះចាំបាច់ត្រូវពិនិត្យមើលឱ្យបានម៉ត់ចត់ ។ការសិក្សាបញ្ហានេះ ក៏ចាំបាច់ត្រូវសំដៅយល់ដឹង អំពីការបង្កើតនិងអនុវត្តន៏ក្រមកសាងនិងក្រមអធិការកិច្ច[៥០] ក៏ដូចជាការអនុវត្តន៏បទដ្ឋាននានា និងការទទួល ខុសត្រូវ ។ សកម្មភាពចុងក្រោយទាំងនេះចាំបាច់ត្រូវទទួល ការគាំទ្រពីក្របខ័ណ្ឌច្បាប់និងពីគោលនយោបាយ សមស្រប ។

៩២. *ផ្ទៃផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ នៅកម្ពុជាមានកំរិតទាប ទោះបីប្រៀបធៀបនិងស្តង់ដារ ណាក្តី ។* មានគ្រួសារនៅជនបទប្រហែល២៥%បានទទួលទឹកស្អាត ដែលមានសុវត្ថិភាពហើយគ្រួសារនៅ ជនបទ ប្រមាណជា១០%ប៉ុណ្ណោះដែលមានលទ្ធភាពប្រើប្រាស់ឧបករណ៏អនាម័យ នៅក្នុងខណៈដែលតំរូវការ ទឹកស្អាតកំពុងកើនឡើងនៅតំបន់ជនបទ នៅក្នុងតំបន់មួយចំនួន បរិមាណនិងគុណភាពទឹកនៅផ្ទៃខាងលើ និងប្រភព ទឹកក្រោមដីមានមិនគ្រប់គ្រាន់ឡើយ ។ នៅក្រៅទីក្រុងភ្នំពេញគ្មានប្រព័ន្ធបង្ហូរទឹកសំអុយឡើយ ។ បង្គន់អនាម័យត្រូវបានគេប្រើប្រាស់នៅតំបន់ជនបទ ប៉ុន្តែមានតិចតួចតែប៉ុណ្ណោះ ។ ប្រទេសកម្ពុជាគឺជា ប្រទេសមួយដែលមានជំងឺដែលបណ្តាលមកពីទឹកកខ្វក់ មានអាត្រាខ្ពស់បំផុតនៅក្នុងពិភពលោក ។ ការប្រើ-ប្រាស់ទឹកដែលគ្មានសុវត្ថិភាព និងឧបករណ៏អនាម័យមិនល្អគួបផ្សំនឹងអនាម័យមិនគ្រប់គ្រាន់ ត្រូវបានគេ កំណត់អត្តសញ្ញាណថាជាមូលហេតុចំបងបំផុតចំពោះអាត្រាមរណៈ/ឆ្លងជំងឺកុមារខ្ពស់បំផុត ។ នៅតំបន់មួយ ចំនួនមានកំរិតនៃជាតិពុលខ្ពស់ ។

៩៣. *ចាំបាច់ត្រូវធ្វើការងារបន្ថែមស ្តីពីយុទ្ធសាស្ត្រផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ ដើម្បីណែនាំ វិនិយោគនៅក្នុងវិស័យនេះ ។* MDGs សំរាប់ប្រទេសកម្ពុជាតំរូវឱ្យផ ្តល់ការផ្គត់ផ្គង់ទឹកស្អាតចំពោះ ប្រជា ពលរដ្ឋចំនួន ៤០ ភាគរយ នៅឆ្នាំ ២០០៥ និងផ ្តល់សេវាអនាម័យទៅឱ្យប្រជាពលរដ្ឋចំនួន ២០ ភាគរយនៅឆ្នាំ ២០០៥ ។ ថ្មីៗនេះក្រសួងអភិវឌ្ឍន៏ជនបទ (MRD) និងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល (MIME) បានបង្កើត និងអនុម័តស្របជាមួយគ្នានូវគោលនយោបាយផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅ ជនបទនិងនៅទីប្រជុំជន ។ គេពុំឃើញមានយុទ្ធសាស្រ ្តផ្គត់ផ្គង់ទឹក និងអនាម័យនៅតំបន់ជនបទ ដែល

---

[50] កំណត់សំគាល់របស់អ្នកបកប្រែ : ពាក្យដើមគឺ building codes and inspection codes ។ អ្នកបកប្រែមិនប្រាកដថាខ្លួនយល់ គំនិតរបស់អ្នកនិពន្ធឡើយ

ដាក់ចេញនូវសកម្មភាពនានា និងការវិនិយោគពាក់ព័ន្ធដែលត្រូវឆ្លើយតបនឹងគោលដៅរួមទាំងនោះឡើយ ។ ដោយសារសុខភាពរបស់ប្រជាពលរដ្ឋមានសារៈសំខាន់ចំពោះកំណើនសេដ្ឋកិច្ច និងចំពោះសុខុមាលភាព ទឹកស្អាតនិងអានាម័យនៅតំបន់ជនបទ គប្បីចាត់ទុកថាជាវិនិយោគសាធារណៈអាទិភាព ដោយពិចារណាដល់ឱកាសវិនិយោគឯកជនលើប្រព័ន្ធផ្គត់ផ្គង់ទឹកដោយបំពុងទុយោតូចៗ ។

៩៤. *គប្បីត្រូវពង្រឹងមុខងាររបស់ភាគីពាក់ព័ន្ធផ្សេងៗ* ។ MRD អនុវត្តគំរោងផ្គត់ផ្គង់ទឹកស្អាត និងអានាម័យនៅជនបទមួយចំនួន ដោយបានទទួលមូលនិធិពីអ្នកផ ្តល់ជំនួយ ហើយអង្គការក្រៅរដ្ឋាភិបាលក៏មាន លក្ខណៈសកម្មនៅក្នុងផ្នែកនេះផងដែរ ។ ជាងនេះទៅទៀតការផ្គត់ផ្គង់ទឹកស្អាត និងអានាម័យមានគំរោង ជាច្រើននៅថ្នាក់ឃុំ ដែលផ ្តល់ហិរញ្ញប្បទានដោយក្រុមប្រឹក្សាឃុំផ្អែកលើមូលនិធិឃុំ-សង្កាត់ (១៨០ គំរោង មានតំលៃ ៦២៧,៤៧៦ ដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ ២០០២) ។ នៅតំបន់ជនបទមួយចំនួននៅក្នុង ប្រទេសកម្ពុជា វិស័យឯកជនមានសកម្មភាពសកម្មជាបង្គួរ ក្នុងការផ្គត់ផ្គង់ទឹកនៅតំបន់ទ្រនាប់ទីប្រជុំជន និងមានឱកាសសំរាប់អនុវត្តន៍គំរោងបែបនេះ ។ ប៉ុន្តែ ្រត្រូវមានការតាមដានជាសាធារណៈ និងមានការគ្រប់គ្រងគុណភាពទឹកក៏ដូចជាគ្រប់គ្រងសក ្តានុពលផលប៉ះពាល់អវិជ្ជមានមកលើជលសិលាដែលជាស្រទាប់ ទឹកផងដែរ ។

**អនុសាសន៍ស្តីពីសកម្មភាពជាអាទិភាពសំរាប់កំណែទំរង់ការគ្រប់គ្រងទឹក និងទឹកជំនន់**

**អាទិភាពទី ១ ពង្រឹងក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយបច្ចុប្បន្ន**

- *រៀបចំ និងអនុម័តអនុក្រឹត្យ និងបទប្បញ្ញត្តិនានាដើម្បីអនុវត ្តបញ្ញត្តិ ្តច្បាប់ស ្តីពីទឹកស្អាត* ដោយផ្អែកលើ មេរៀនដែលបានទទួលពីគំរោងផ្សេងៗ និងប្រើប្រាស់ការពិគ្រោះគ្រប់ជ្រុងជ្រោយ ។ រៀបចំផែនការ សកម្មភាពជាយុទ្ធសាស្រ ្ត ដើម្បីណែនាំកម្មវិធីពាក់ព័ន្ធនឹងទឹករបស់ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋា- ភិបាល ។ កសាងសមត្ថភាពរបស់ស្ថាប័នទាំងនោះឱ្យអនុវត ្តបទប្បញ្ញត្តិ ្តនានាស្តីអំពីទឹក ។

- *បន ្តលើកកំពស់ការសម្របសម្រួលរបស់ម្ចាស់ជំនួយ[៥១] និងបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍រវាងក្រសួង ឬក្រុមការងារផ្សេងៗ* ដើម្បីដោះស្រាយបញ្ហាសម្របសម្រួលនៅក្នុងវិស័យទឹក និងតាមដានសហប្រតិបត ្តិការផ្ទៃក្នុងស្ថាប័ន ។
ពង្រឹងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីអនុវត ្តសកម្មភាពដែលបានឯកភាព ។
- *នៅក្នុងបរិបទវិសហមជ្ឈការ និងវិមជ្ឈការ ពិនិត្យរកមើលការគ្រប់គ្រងធនធានទឹក កិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ការគ្រប់គ្រងទឹកជំនន់ និងការផ្គត់ផ្គង់ទឹក ព្រមទាំងជំរើសអនាម័យនៅក៏រិតសហគមន៍ ។*
- *ចូលរួមនៅក្នុងកិច្ចផ ្តួចផ ្តើមរបស់គណៈកម្មការទន្លេមេគង្គនៅទូទាំងប្រទេស* រួមមានការបង្កើតយុទ្ធសាស្រ ្តធនធានទឹកដោយមានការចូលរួមពីភាគីពាក់ព័ន្ធមកពីអនុអាងទន្លេមេគង្គដែលមានអាទិភាព មួយចំនួន។ បង្កើនការចូលរួមនៅក្នុងគណៈកម្មការទន្លេមេគង្គរាប់ទាំងការលើកកំពស់ចំណងទាក់ទង និង ការសម្របសម្រួលយុទ្ធសាស្រ ្តនិងកម្មវិធីធនធានទឹករបស់កម្ពុជាជាមួយកម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៍ ធនធានទឹកទន្លេមេគង្គឆ្លងដែន ។

**អាទិភាពទី ២ កសាងផែនការនិងវិនិយោគឱ្យកាន់តែមានលក្ខណៈជាយុទ្ធសាស្ត្រ និងគាំទ្រគោលដៅរួមនៃកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចទៅ ។**

- *ធ្វើសនិទានកម្មចំពោះការផ្តល់អាទិភាពនៃគំរោងវិនិយោគ ទោះបីជាខ្នាតតូច ឬ ខ្នាតធំក្តី តាមរយៈការប្រើប្រាស់លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសច្បាស់លាស់ ។*
- *ចាប់ផ្តើមធ្វើការនៅក្នុងក៏រិតអាងទន្លេមេគង្គ និងធានាឱ្យមានភាពស៊ីសង្វាក់គ្នាជាមួយគោលដៅរួម រវាងការអភិវឌ្ឍន៍កសិកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចទូទៅដទៃទៀត។* រៀបចំអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងគ្រប់គ្រងទឹកជំនន់នៅក្នុងបរិបទនៃផែនការអាងទន្លេមេគង្គដែល (១) ផ្តោតការយកចិត្តទិកដាក់លើអត្ថប្រយោជន៍ចំពោះប្រជាពលរដ្ឋក្រីក្រ(១) មានលក្ខណៈចុះសម្រុងជាមួយនិងការបង្កើតអត្ថប្រយោជន៍នៃការនេសាទ (១) មានលក្ខណៈចុះសម្រុងជាមួយនិងរបបទឹកជំនន់ធម្មជាតិនិងរបបទឹកស្រក (៤) មានលក្ខណៈស្ថិតស្ថេរតាមន័យសេដ្ឋកិច្ចនិងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ

---

[51] នៅក្នុងដំណើរការបច្ចុប្បន្នក្នុងការបង្កើតក្រុមការងារបច្ចេកទេសរួមគ្នារវាងរដ្ឋាភិបាល និងអ្នកផ ្តល់ជំនួយ(TWG) គេបានបង្កើត ក្រុមមួយសំរាប់គ្រប់គ្រងកសិកម្ម និងទឹក ។ លើសពីនេះទៅទៀតកម្មវិធីមួយដែលផ ្តល់ហិរញ្ញប្បទានដោយប្រទេសបារាំងកំពុងគាំទ្រ ក្រុមការងារយុទ្ធសាស្រ ្តនៅក្រសួង MOWRAM ។

មួយភាគធំ (i) ត្រូវបានរៀបចំនិងអនុវត្តន៏ក្នុងទំនាក់ទំនងជាមួយ និងគណៈកម្មាធិការកសិករនៃអ្នកប្រើប្រាស់ទឹក ។

- *បង្កើតផែនការនិងនិតិវិធិសំរាប់គ្រប់គ្រងទឹកសំរាប់អនុអាងអាទិភាពនិងសហគមន៍* ដែលនឹង : (i) កំរិតការប្រើប្រាស់ទឹក និងកំរិតការបង្ហូរទឹកត្រលប់មកវិញធៀបនឹងបរិមាណនិងធៀបនឹងកំរិតគុណភាពទឹកដែលថែរក្សានិងដែលធ្វើឱ្យបរិស្ថានមាននិរន្តរភាព (ii) បែងចែកទូទៅចំពោះការប្រើប្រាស់ផ្សេងៗ ( បរិស្ថាន ស្រោចស្រពកសិកម្ម ទីក្រុង និងឧស្សាហកម្ម )និងល័ក្ខខ័ណ្ឌបង្ហូរចេញមកវិញ ដើម្បីឱ្យឆ្លើយតបនឹងគោលដៅដែលមាននិរន្តរភាព (iii) រៀបចំនិងអនុវត្តន៏ប្រព័ន្ធតាមដាន និងប្រព័ន្ធគ្រប់គ្រងសិទ្ធិ/ ការបង្ហូរ ដើម្បីគ្រប់គ្រងការប្រើប្រាស់ទឹក នៅក្នុងកំរិតឧបសគ្គទាំងនេះ ។

## អាទិភាពទី ៣ រៀបចំត្រៀមលក្ខណៈទប់ទល់និងបញ្ចៀសគ្រោះមហន្តរាយ

- *ពិនិត្យមើលសារជាថ្មីនិងឯកភាពចំពោះផែនការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។* ស្វែងរកជំនួយបច្ចេកទេសដែលគាំទ្រដោយអ្នកផ្តល់ជំនួយ ស្វែងរកការបណ្តុះបណ្តាលនិងវិនិយោគ ដើម្បីលើកកំពស់សមត្ថភាព លើកកំពស់ប្រព័ន្ធនិងនិតិវិធីរបស់ ណជឧំ ក្នុងការវាយតំលៃការខូចខាតនិងវាយតំលៃសេចក្តីត្រូវការ និងលើកកំពស់សមត្ថភាពក្នុងការរាយការណ៏ ។ រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ថ្លឹងថ្លែងវិធីសាស្ត្របច្ចុប្បន្នចំពោះការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិជាមួយនឹងវិធីសាស្ត្រមួយដែលមានលក្ខណៈសកម្ម និងសំរបតាមសមត្ថភាពរបស់រដ្ឋាភិបាលកម្ពុជា ជាពិសេសសំរបតាមសមត្ថភាពផ្នែកសារពើពន្ធនិងបច្ចេកទេស ។
- *ពិនិត្យសារឡើងវិញនូវមេរៀនដែលដកស្រង់ចេញពីបទពិសោធន៏ជាមួយនឹងវិធិសាស្ត្រនៃការគ្រប់គ្រងហានិភ័យផ្អែកលើសហគមន៍ ពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនិងម្ចាស់ជំនួយដទៃទៀត* ដោយយកចិត្តទុកដាក់ឆ្ពោះទៅរកការជូនដំណឹងអំពីការរៀបចំគាំទ្រក្នុងពេលអនាគត ពីអង្គការក្រៅរដ្ឋាភិបាល និងសហគមន៏អ្នកផ្តល់ជំនួយ ។
- *ធ្វើសមាហណកម្មការត្រៀមលក្ខណៈទប់ទល់ និងការបញ្ចៀសគ្រោះមហន្តរាយទៅក្នុងការកសាងផែនការប្រើប្រាស់ដីនឹងការរៀបចំ ហេដ្ឋារចនាសម្ព័ន្ធ ។*

**អាទិភាពទី ៤ កៀងគរធនធានសំរាប់ពង្រីកការផ្គត់ផ្គង់ទឹក និងអនាម័យនៅតំបន់ជនបទ**

- *បង្កលក្ខណៈឱ្យមានសមធម៌ចំពោះការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ* តាមរយៈការបង្កើនការវិនិយោគក្នុងការជីកអណ្តូងទឹក និងកសាងបង្គន់អនាម័យនៅតាមតំបន់ឆ្ងាយដាច់ស្រយាលក៏ដូចជាប្រព័ន្ធបង្ហូរទឹកសំអុយ នៅតាមទីកន្លែងសមស្រប ។
- *លើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន* ឃបង្កើតឱ្យមានការចូលរួមពីវិស័យឯកជនឱ្យបានកាន់តែច្រើនបន្ថែមទៀតនៅក្នុងការផ្គត់ផ្គង់ទឹកស្អាតនៅជនបទ និងកិច្ចអភិវឌ្ឍន៍ផ្នែកអនាម័យ គួរបានទទួលការលើកទឹកចិត្តដោយសារតែបញ្ហាកង្វះខាតមូលនិធិវិនិយោគវិស័យសាធារណៈ នឹងដោយសារប្រតិបត្តិការ និងការគ្រប់គ្រងមធ្យោបាយមួយចំនួន គួរទុកឱ្យវិស័យឯកជនជាអ្នករ៉ាប់រង ។ នៅប្រទេសដទៃទៀតវិស័យឯកជនកំពុងដើតួកាន់តែសំខាន់ឡើងៗ នៅក្នុងការផ្តល់ការផ្គត់ផ្គង់ទឹកស្អាត និងសេវាអនាម័យដែលមានលក្ខណៈជាសារវ័ន្ត ។

## ***ការបង្កើនប្រាក់ចំណូលកសិកម្ម***

៩៥. *ដើម្បីឱ្យមានវឌ្ឍនភាពលើការកាត់បន្ថយភាពក្រីក្រ នៅចំពោះមុខអាត្រាកំណើនប្រជាពលរដ្ឋខ្ពស់ វិស័យកសិកម្មនិងជនបទចាំបាច់ត្រូវរីកចំរើន យ៉ាងហោចណាស់មានកំណើនពិ ៥ ទៅ ៦% ក្នុងមួយឆ្នាំ (សូមអានផ្នែកទី ១)* ។ នេះគឺជាអាត្រាកំណើនខ្ពស់ធៀបនិងលទ្ធផលអនុវត្តន៍របស់វិស័យក្នុងពេលបច្ចុប្បន្ន ហើយការបង្កើនផលិតភាពដំណាំស្រូវ ក៏នឹងកើនឡើងឆ្ពោះទៅរកការឆ្លើយតបនឹងតំរូវការនេះ :

- សក្តានុពលក្នុងការរួមវិភាគទានចំពោះកំណើន GDP ពីការបង្កើនផលិតកម្មស្រូវ តាមរយៈការបង្កើនឬពង្រីកតំបន់ដាំដុះជួបនឹងការលំបាកដោយសារតែសមត្ថភាពស្រូបរបស់ទីផ្សារក្នុងស្រុកមានកំរិត មានគុណភាពមិនល្អសំរាប់ការនាំចេញ នៅមានសេសសល់សមត្ថភាពនៅក្នុងតំបន់ និងអាស្រ័យលើនិន្នាការរួមនៃថ្លៃធញ្ញជាតិនៅក្នុងតំបន់ និងនៅលើពិភពលោកដែលមានរយៈពេលវែង
- ប៉ុន្តែ សូម្បីតែនៅក្នុងកំហិតជាមួយនិងទីផ្សារក្តី ការបង្កើនឡើងនូវផលិតផលស្រូវ និងប្រសិទ្ធិភាពកិនស្រូវ អាចមានសក្តានុពលក្នុងការរួមវិភាគទានរហូតដល់ ៣% នៃកំណើនប្រចាំឆ្នាំ ( FAO ឆ្នាំ ២០០៣ )
- កំណើននៃផលិតកម្មព្រៃឈើនិងជលផលអាស្រ័យលើសមត្ថភាពរបស់ធនធានក្នុងការផ្តល់ផល និង តុល្យភាពរវាងការបង្កើនការប្រមូលផលក្នុងគោលដៅពាណិជ្ជកម្ម នឹងតំលៃធនធាននៅ

ក្នុងបរិបទអត្ថិភាពនៃផលិតផលមិនមែនឈើ នៅក្នុងបរិបទនៃបណ្តាញសុវត្ថិភាពជនបទ និងក្នុងបរិបទនៃការប្រើប្រាស់ដទៃទៀតក្រៅពីពាណិជ្ជកម្ម ។

៩៦. *ដើម្បីសំរេចបាននូវអត្រាកំណើនខ្ពស់ ចាំបាច់ត្រូវធ្វើពិពិធកម្មក្រៅពីការធ្វើដំណាំស្រូវ ដែលភាគច្រើនត្រូវផ្តោតលើទីផ្សារ និងផ្តោតលើការនាំចេញ ក្នុងវិសាលភាពមួយធំ :*

- វិភាគទានបន្ថែមចំពោះកំណើនដែលបានមកពីការធ្វើពិពិធកម្មក្រៅពីស្រូវ ផលិតផលព្រៃឈើ និងជលផលដែលមានលក្ខណៈជាប្រពៃណី ចាំបាច់ត្រូវមានការកំណត់ទិសដៅក្នុងការនាំចេញ ក្នុងស្ថានភាពដែលប្រាក់ក្នុងស្រុកមានកំរិតទាប មានការបណ្តុំនៃប្រាក់ចំណូលខ្ពស់ មានរបាយលំអៀង ដែលមានកំហិតលើកំណើននៃតំរូវការក្នុងស្រុក ។

- តំរូវការរបស់ជាតិអាចធ្វើឱ្យកំណើនវិស័យកសិកម្ម កើនជាមធ្យមប្រហែល ៤.៤% ក្នុងមួយឆ្នាំ ប្រសិនបើឧបសគ្គផ្នែកផលិតកម្មនិងឧបសគ្គផ្នែកទីផ្សារត្រូវបានដោះស្រាយ ។ តំរូវការស្បៀងអាហារក្នុងស្រុកកើនឡើងនាពេលអនាគត ដែលបណ្តាលមកពី (i) កំណើនប្រជាពលរដ្ឋ (ប្រហែល២.៥%ក្នុង១ឆ្នាំ) (ii) ការផ្លាស់ប្តូរសមាសភាពម្ហូបអាហារធៀបនឹងកំណើននៃប្រាក់ចំណូលដែលធ្វើឱ្យផ្លាស់ប្តូរពីការទទួលទានបាយ ទៅជាការទទួលសាច់ ត្រី បន្លែ និងស្បៀងអាហារកែច្នៃ[52] ។ ទោះបីជាមានសក្តានុពលជំនួសការនាំចូលអង្ករដែលមានគុណភាពខ្ពស់ (១០០.០០០តោន ត្រូវបានគេនាំចូលក្នុងពេលបច្ចុប្បន្ន ) និងជំនួសផលិតផនាំចូលដទៃទៀតដូចជា បន្លែបង្កា ផ្លែឈើ ស្ករ ប្រេងរុក្ខជាតិ បសុសត្វ ជ្រូក និងការអនុវត្តន៍នូវសក្តានុពលទាំងនេះអាចប្រព្រឹត្តទៅបាន នៅពេលណាដែលឧបសគ្គទីផ្សារ ឧបសគ្គស្ថាប័ន និងឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធត្រូវបានលុបបំបាត់ ។ ថ្មីៗនេះ ផលិតកម្ម ក្នុងស្រុកមិនអាចប្រកួតប្រជែងជាមួយទំនិញនាំចូលពីបរទេសឡើយ ជាពិសេសទំនិញនាំចូលពីប្រទេសវៀតណាមនិងប្រទេសថៃសំរាប់ផលិតផលមួយចំនួន ។

---

[52]ដោយពិចារណាអំពីការថយចុះនៅចំណែក ចំណាយសាធារណ:នៅពេលមានកំណើនប្រាក់ចំណូល អាត្រាកំណើនប្រាក់ចំណូលស្មើនិង ៣%នៅទូទាំងប្រទេស ដូចការប៉ាន់ស្មានជាគោល។ នឹងធ្វើអោយកំណើនកសិកម្ម មានកំរិតអតិបរមាស្មើនិង ៤.៤%ក្នុង១ឆ្នាំ( ការបូកផ្សំកំណើនប្រជាពលរដ្ឋ២.៥%និង១.៩%ទៀតបានមកពីនិន្នាការផាស់ប្តូរម្ហូបអាហារ ៣% @៦៣.៥% ដែល៦៣.៥% គឺជាចំណែកនៃកំណើនប្រាក់ចំណូលដែលបានចំណាយលើស្បៀងអាហារ) ។ភាពយឺតនៃប្រាល់ចំណុល(income elasticity) សំរាប់ស្បៀងអាហារខុសគ្នា។ត្រូវបានឡេប៉ាន់ស្មានថាស្មើ ០.៤៦ ០.៧៥ និង០.៩២ ចំពោះ អង្ករ ម្ហូបជាមូលដ្ឋានមិនមែនអង្ករនិងសាច់ / ត្រី ( FAO, Ernstberger និង Liu, 2003) ។

- ភាពប្រកួតប្រជែងរបស់កសិករនិងអាជីវកម្មកសិកម្ម និងការធ្វើសមាហរណកម្មជាមួយទីផ្សារពិភពលោកជួបឧបសគ្គ ដោយសារផលិតភាពទាប ហេដ្ឋារចនាសម្ព័ន្ធខ្សោយ និងកត្តាផ្នែកស្ថាប័នដទៃទៀត (ដូចជាអំពើពុករលួយ) ដែលទាំងអស់នេះធ្វើឱ្យចំណាយកើនឡើង នឹងទប់ស្កាត់ការបញ្ជូនសញ្ញានានាពីទីផ្សារប្រកបប្រសិទ្ធភាពទៅឱ្យកាន់ផលិតករ អ្នកដឹកជញ្ជូន និងអ្នកកែច្នៃនៅជនបទ និងសំរាប់ទីផ្សារហិរញ្ញវត្ថុជនបទរបស់កម្ពុជាដែលកំពុងចាប់កំណើត។

៩៧. *ចាំបាច់ត្រូវបង្កើតគោលនយោបាយគាំទ្រ និងបង្កើតកត្តាលើកទឹកចិត្តផ្សេងៗ ដើម្បីបង្កើនការឆ្លើយតប* ក្នុងការផ្គត់ផ្គង់ផលិតផលប្រពៃណី ដូចជាអង្ករ ជលផល និងបសុសត្វ ដើម្បីឱ្យមានពិពិធកម្មបន្ថែមលើផលិតកម្មនិងការកែច្នៃតំលៃបន្ថែម ក៏ដូចជាជួយសំរួលដល់ប្រជាពលរដ្ឋក្រីក្រ (ផលិតករនិងកសិករ) ដើម្បីឱ្យមានលទ្ធភាពរួមចំណែកមួយភាគកាន់តែធំលើតំលៃបន្ថែម ដែលបានមកពីផលិតកម្មនៅតំបន់ជនបទ។ ទោះបីជាមានការកាត់បន្ថយភាពខុសគ្នា អំពីតំរូវការនិងការឆ្លើយតបក្នុងការផ្គត់ផ្គង់ដែលមានប្រសិទ្ធិភាព និងដែលបានធ្វើពិពិធកម្មក្តី ការបង្កលក្ខណៈងាយស្រួលឱ្យកសិករខ្នាតតូច និងអ្នកលក់កំលាំងពលកម្មនៅតំបន់ជនបទ តំរូវឱ្យការលើកកំពស់ប្រសិទ្ធិភាព លើកកំពស់សមធម៌ អំពីលទ្ធភាពក្នុងការបានទទួលធនធាន ដែលមានផលិតភាព និងទីផ្សារកត្តាពលកម្ម រួមមានដី ទឹក ហិរញ្ញវត្ថុនិងបច្ចេកវិទ្យា ។មានជំរើស (និងឧទាហរណ៍មួយចំនួនកំពុងកើតមាននៅកម្ពុជា) សំរាប់អនុវត្តយុទ្ធសាស្ត្រកំណើននៅជនបទ ដែលផ្តោតលើប្រជាពលរដ្ឋក្រីក្រ តាមរយៈការធ្វើពិពិធកម្មដឹកនាំដោយទីផ្សារ រាប់ទាំងការធ្វើកសិកម្មយោងកិច្ចសន្យាសមាគមរកទីផ្សារ ។ល។ ប៉ុន្តែទាំងអស់នេះតំរូវឱ្យផ្លាស់ប្តូរជាច្រើននៅក្នុងបរិយាកាសវិនិយោគនៅជនបទ និងរចនាសម្ព័ន្ធស្ថាប័នដែលផ្សារភ្ជាប់ផលិតករនៅជនបទជាមួយអ្នកកែច្នៃ និងជាមួយទីផ្សារ ។

៩៨. *ប្រការនេះពាក់ព័ន្ធជាពិសេសនូវការប្រែក្លាយកសិកម្មជីវព្រឹត្ត ដែលសំគាល់ដោយការធ្វើដំណាំស្រូវតែមួយមុខ ប្រើប្រាស់កត្តាផលិតកម្មតិចតួច ហើយដីផ្តល់ផលតិចតួច ទៅកាន់កសិកម្មដែលតំរង់ឆ្ពោះទៅរកពាណិជ្ជកម្ម និងកសិកម្មចំរុះ។* អន្តរកាលនេះបានចាប់ផ្តើមរួចហើយ និងត្រូវសម្របសម្រួលដោយគោលនយោបាយ និងការវិនិយោគគាំទ្រ។ កំណែទំរង់ពាក់ព័ន្ធនឹងអន្តរាគមន៍ជាបន្តបន្ទាប់ តំរូវឱ្យកាត់បន្ថយហានិភ័យដែលគេដឹងជាមុន អំពីការប្តូរពីការធ្វើកសិកម្មជីវព្រឹត្តទៅជាការធ្វើកសិកម្ម ដែលមានលក្ខណៈពាណិជ្ជកម្ម ។ និន្នាការក្នុងពេលអនាគតអំពីការធ្វើកសិកម្ម មួយផ្នែកធំអាស្រ័យលើជំរើសគោលនយោបាយចំរុះរបស់រដ្ឋាភិបាលសំរាប់តំបន់ជនបទ ដែលទាក់ទងនឹង (i) ការកំណត់ទិសសារជាថ្មីនៃគោលនយោបាយកសិកម្ម ការបែងចែកធនធាន និងសេវាគាំទ្រដើម្បីឆ្លើយតបទៅនឹងតំរូវការនៃប្រព័ន្ធកសិកម្មចំរុះ និង

(ii) ដោះស្រាយការងារផលិតកម្ម ការរកទីផ្សារ និងបញ្ហាពាណិជ្ជកម្ម ដែលទំនិញសំខាន់ៗត្រូវប្រឈមមុខ (អង្ករ ត្រី បសុសត្វ កៅស៊ូ )ក៏ដូចជា (iii) អាទិភាពនៃការវិនិយោគលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងទឹក (iv) ការងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់និងផ្លូវភូមិ ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល និង (v) ការគ្រប់គ្រងដីធ្លី និងសុវត្ថិភាពផ្នែកកម្មសិទ្ធិ។ ផ្នែកនេះប្រមូលផ្តុំជាសំខាន់លើចំណុចទី (i) - (ii) - (iii) ដល់ទី (v) មានពិភាក្សានៅក្នុងផ្នែកផ្នែកទីពីរនៃរបាយការណ៍នេះ ។

៩៩. ការធ្វើពិពិធកម្មនៃស្ថានភាននៅមូលដ្ឋាន តំរូវឱ្យមានការយកចិត្តទុកដាក់លើវិធីសាស្ត្រវិមជ្ឈការ ដែល មានការចូលរួមច្រើនពីសហគមន៍។ ប៉ុន្តែឧបសគ្គមួយចំនួនមានលក្ខណៈជាប្រព័ន្ធ ដូចជាឧបសគ្គក្នុងការ រកទីផ្សារ និងបរិយាកាសគ្រប់គ្រងពាណិជ្ជកម្មដែលតំរូវឱ្យមានសកម្មភាពសម្របសម្រួល ពាក់ព័ន្ធនឹង ទីភ្នាក់ងារ នៅថ្នាក់កណ្តាល ។ការរួមផ្សំរវាង (i) សកម្មភាពនានា ដើម្បីពង្រឹងការគ្រប់គ្រងតាមវិស័យសំរាប់ អភិវឌ្ឍន៍ កសិកម្ម (ii) សេវាសំរាប់ទ្រទ្រង់ និងការផលិត ការរកទីផ្សារនិងពាណិជ្ជកម្មកសិផល (iii) កម្មវិធី ទំនិញជាក់លាក់ត្រូវបានលើកជាសំណើ ។

## ការពង្រឹង និងគ្រប់គ្រងតាមវិស័យ

១០០. *ការបង្កើតកម្មវិធីអភិវឌ្ឍន៍កសិកម្មច្បាស់លាស់គឺជាអាទិភាព។* ស្ថិតនៅក្នុងអាទិភាពទី១ យុទ្ធសាស្ត្រ របស់រដ្ឋាភិបាលសំរាប់អភិវឌ្ឍវិស័យកសិកម្ម ចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់ ហើយប្រែក្លាយនូវ អាទិភាព ទូទៅនានាឱ្យទៅជាកម្មវិធិជាក់លាក់ ដែលនឹងទទួលបាននូវការគាំទ្រពីរដ្ឋាភិបាលនិងពីម្ចាស់ជំនួយ កាន់តែ ច្រើន ។ឯកសារស្តីពី NPRS កំណត់អត្តសញ្ញាណអាទិភាពដូចតទៅ សំរាប់កិច្ចអភិវឌ្ឍន៍ផ្នែកកសិកម្ម : (i) ការបង្កើនល្បឿនកិច្ចអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដែលមាននិរន្តរភាព (ii) បង្កើនល្បឿនការផ្តល់ប័ណ្ណ កម្មសិទ្ធិដីធ្លី និងការបែងចែកដីទំនេរក្រោមការគ្រប់គ្រងរបស់ក្រសួង MAFF (iii) អភិវឌ្ឍន៍ការនាំចេញ ផលិតផលស្រូវ និងផលិតផលដទៃទៀត និងអភិវឌ្ឍន៍មធ្យោបាយកែច្នៃនិងត្រួតពិនិត្យគុណភាព (iv) ពង្រឹងសេវាសំខាន់ៗសំរាប់គាំទ្រវិស័យកសិកម្ម ក្នុងនោះរួមមាន ការផ្សព្វផ្សាយកសិកម្ម ការស្រាវជ្រាវ ការរកទីផ្សារ ឥណទាន និងការបែងចែកកត្តាផលិតកម្ម (v) ការពង្រីកផលិតកម្ម បសុសត្វ ដោយមាន ការយកចិត្តទុកដាក់ទៅលើសេវាសុខភាពសត្វ អាហារូបត្ថម្ភ ការគ្រប់គ្រងនិងការបង្កើត រោងចក្រកែច្នៃសាច់ (vi) ការដាក់ឱ្យមានបច្ចេកវិទ្យាសមស្របសំរាប់ការការចិញ្ចឹមត្រីក្នុងស្រែ និង វារីវប្បកម្ម (vii) ជំរុញការ គ្រប់គ្រងព្រៃឈើនិងជលផលដោយសហកមន៍ (viii) ពង្រឹងសមត្ថភាព នៅគ្រប់ថ្នាក់នៃស្ថាប័នតាមវិស័យ

នៅជនបទ ។ ប៉ុន្តែឯកសារ NPRS មិនបានកំណត់យុទ្ធសាស្ត្រច្បាស់លាស់ សំរាប់កសិកម្មឡើយ ហើយចាំបាច់ត្រូវប្រែក្លាយទិសដៅទូទៅរបស់ឯកសារនេះឱ្យទៅជាកម្មវិធីអាទិភាព ជាក់លាក់បន្ថែមទៀត ។

១០១. *គេឃើញមានយុទ្ធសាស្ត្រនិងគោលនយោបាយអនុវិស័យនៅតាមផ្នែកមួយចំនួន ប៉ុន្តែមានបញ្ហាអំពីភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្តន៍ជាក់ស្តែង ក៏ដូចជាមានបញ្ហាអំពីកម្មសិទ្ធិភាព និងមានបញ្ហាអំពីការគាំទ្រពីថ្នាក់នយោបាយ*[53] ។ការរួមផ្សំនៃកម្មវិធីស៊ីសង្វាក់គ្នាមានគោលដៅសំរាប់ធ្វើឱ្យអនុវិស័យសំខាន់ៗ បានរស់រានមានជីវិតសារជាថ្មី (ដោះស្រាយផលិតកម្ម ដែលបានកំណត់អត្តសញ្ញាណ និងដោះស្រាយឧបសគ្គនៃការរកទីផ្សារដែលធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងនៃអនុវិស័យជាក់លាក់ ឧទាហរណ៍ ស្រូវ កៅស៊ូ ត្រី បសុសត្វ ។ល) ។ ហើយកម្មវិធីនានាមានគោលដៅក្នុងការលើកកំពស់គុណភាពការផ្តល់សេវាចំពោះវិស័យកសិកម្ម (ឧទាហរណ៍ ប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ប្រព័ន្ធពតិមានទីផ្សារសេវាហិរញ្ញវត្ថុ សំរាប់អនុញ្ញាតឱ្យមានការធ្វើពិពិធកម្មបន្តទៀតនៃផលិតកម្មកសិកម្ម ក្នុងការឆ្លើយតបនិងតំរូវការរបស់ទីផ្សារ) និងផ្តល់ជាក្របខ័ណ្ឌមួយសំរាប់ធ្វើសនិទានកម្ម ហើយក្នុងពេលបច្ចុប្បន្ន ប្រមូលផ្តុំកិច្ចប្រឹងប្រែងដាច់ៗពីគ្នារបស់ភាគីពាក់ព័ន្ធនានានៅក្នុងវិស័យនេះ ។ យន្តសាស្ត្រកសិកម្មដែលអាចជឿទុកចិត្ត ក៏គាំទ្រផងដែរនូវកិច្ចប្រឹងប្រែងទ្រទ្រង់របស់ក្រសួង MAFF ដើម្បីឱ្យបង្កើនការបែងចែកថវិកាមកឱ្យវិស័យនេះ ។

១០២. *ធនធានចាំបាច់ត្រូវមានលក្ខណៈស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម* ។ ទាក់ទងនឹងការកែ លំអគោលនយោបាយការគ្រប់គ្រងចំណាយសាធារណៈ ការរៀបចំធនធានជាមួយនិងគោលដៅអភិវឌ្ឍន៍យុទ្ធសាស្ត្រ វិស័យកសិកម្មនិងការងារអភិវឌ្ឍន៍ជនបទ ដើរយឺតជាងវិស័យដទៃទៀត ។ ចំណងទាក់ទងរវាង ការកសាងផែនការថវិកានិងការកំណត់គោលដៅឆ្ពោះ ទៅរកប្រជាពលរដ្ឋក្រីក្រលើផ្នែកធនធាន បានលើកកំពស់វិស័យសុខាភិបាលនិងអប់រំ ប៉ុន្តែកសិកម្មនៅជនបទ ចាំបាច់ត្រូវធ្វើឱ្យមានការរីកចំរើនដូចគ្នានេះដែរ ។ ជាមួយនិងការព្យាករណ៍នៃឯកសារNPRSលើការប្រមូលចំណូលដែលមានកំរិតទាបជាងយ៉ាងច្រើនធៀបនឹង តំរូវការក្នុងការផ្តល់ហិរញ្ញប្បទាន ការធ្វើសនិទានកម្មគួរជាអាទិភាពមួយខ្ពស់ ។ ជាងនេះទៅទៀតកង្វះ គោលនយោបាយតាមវិស័យច្បាស់លាស់និងកង្វះ ពតិមានអំពីលទ្ធផល ធ្វើឱ្យការវាយតំលៃប្រសិទ្ធិភាពនៃ ចំណាយសាធារណៈក្នុងកិច្ចអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ជនបទជួបការលំបាក ។ ជាចុងក្រោយ ត្រូវលៃយ៉ាងណាឱ្យមានការរៀបចំកាន់តែល្អប្រសើរនូវអាទិភាពនានារបស់

---

[53]គួរកត់សំគាល់ថា : សេចក្តីព្រាងច្បាប់ គ្រាប់ពូជ និងយុទ្ធសាស្ត្រគ្រាប់ពូជ គោលនយោបាយបសុសត្វ យុទ្ធសាស្ត្រ អប់រំវិស័យកសិកម្មសេចក្តីណែនាំថ្នាក់ជាតិអំពីការផ្សព្វផ្សាយកសិកម្ម សេចក្តីព្រាងច្បាប់អំពីច្បាប់ជលផល (ជាមួយនិងក្រុមប្រឹក្សារដ្ឋមន្ត្រី) និងសេចក្តីព្រាងអនុក្រឹត្យ បទបញ្ញត្តិ នឹងស្តង់ដារកសិកម្មផ្សេងៗ ។

រាជរដ្ឋាភិបាលរបស់កម្ពុជា ក្នុងការលើក កំពស់ការគ្រប់គ្រងជំនួយបរទេស ព្រោះថាបរិមាណជំនួយបរទេស នៅក្នុងចំណាយសរុបរបស់រដ្ឋាភិបាល- មានចំនួនប្រហែល ៧៥% ឬ ខ្ពស់ជាងនេះសំរាប់កសិកម្មនិងកិច្ច អភិវឌ្ឍន៍ជនបទ ។

១០៣. *បញ្ហាធ្ងន់ធ្ងរនៃការគ្រប់គ្រងចំណាយសាធារណៈធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានចំពោះការបែងចែក ធនធានសេដ្ឋកិច្ចទៅតាមភូមិសាស្ត្រ និងប៉ះពាល់ដល់ប្រសិទ្ធភាពផ្នែកក្នុងវិស័យនៅតំបន់ជនបទ ហើយកញ្ចប់ ធនធាន តិតួច ជាទូទៅ ធ្វើឱ្យមានឥទ្ធិពលតិចតួច ។* ឯកសារពិនិត្យសារឡើងវិញអំពី ចំណាយសាធារណៈឆ្នាំ ២០០៣ (IFAPER) បានកំណត់បញ្ហាចំបងៗនៅក្នុងវិស័យនេះដោយ ផ្អែកលើការពិនិត្យឡើងវិញរបស់ ក្រសួង MAFF និងក្រសួង MOWRAM [54]:

## ប្រអប់ទី ៥ : បញ្ហាគន្លឹះនៃ PEM នៅក្នុងវិស័យកសិកម្ម

- *ធនធានរបស់រដ្ឋាភិបាលដែលបែងចែកឱ្យវិស័យ មានចំនួនតិច (តិចជាង១ដុល្លារសំរាប់ ប្រជាពលរដ្ឋម្នាក់)* ខណៈដែលប្រជាពលរដ្ឋភាគច្រើនរស់នៅពឹងផ្អែកលើវិស័យកសិកម្ម ។ ក៏ប៉ុន្តែ ចាំបាច់ត្រូវមានកម្មវិធីកំណើនផ្តោតទៅរកប្រជាពលរដ្ឋក្រីក្រច្បាស់លាស់ ដែលអាច ប្រែក្លាយទៅជា MTEF មុនពេលធ្វើវិចារណកម្មស្តីពីការបង្កើនថវិកា ។ កំណើនចំណាយ កាលពីពេលថ្មីៗនេះគឺជាចំណាយលើការបំពេញខាត(ពូជស្រូវ)ជាជាងការបង្កើនចំណាយ ទៅឱ្យវិស័យអាទិភាព ។
- *កិច្ចដំណើរការថវិការងផលប៉ះពាល់ជាខ្លាំងពីលំហូរថវិកាក្រៅប្រព័ន្ធ* ការប្រមូលចំណូល ក្រៅថវិកាដែលមានបរិមាណច្រើនគឺជាការព្រួយបារម្ភធ្ងន់ធ្ងរមួយ ជាពិសេសនៅក្នុង អនុវិស័យព្រៃឈើ និងជលផលដែលគ្មានការតាមដានការប្រមូលប្រាក់ចំណូលឱ្យមាន ប្រសិទ្ធភាព ។ ក្រុមហ៊ុនកៅស៊ូរកបានប្រាក់ចំណេញតិចតួចហួស ហើយគ្មានការតាមដាន ពីក្រសួង MAFF ចំពោះសហគ្រាសកសិកម្មរបស់រដ្ឋឡើយ ។ ការគ្រប់គ្រងជំនួយ

[54] របកគំហើញអនុវត្តចំពោះផ្នែកនានានៃវិស័យកសិកម្ម និងទឹកស្អាតនៃសេដ្ឋកិច្ចជនបទ IFAPER មិនបាននិយាយពីស្ថាប័នដែល ពាក់ព័ន្ធដោយផ្ទាល់ដែលនៅក្នុងសេដ្ឋកិច្ចជនបទឡើយ

របស់អ្នកផ្តល់ជំនួយក៏ជាបញ្ហាចំបងមួយផងដែរ ដោយគ្មានការកត់ត្រា និងគ្មានការតាមដានការបែងចែកធនធាន និងការចំណាយនៅក្នុងវិស័យនេះឱ្យបានពេញលេញឡើយ

- *ការបែងចែកធនធានសេដ្ឋកិច្ចមានអប្រសិទ្ធភាព* ។ ចំណែកនៃតួលេខប្រាក់ខែធៀបនឹងចំណាយចរន្តបានធ្លាក់ចុះពាក់កណ្តាលក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ។ លើទិដ្ឋភាព វិជ្ជមាន ចំណាយប្រតិបត្តិការនិងចំណាយថែទាំនៅថ្នាក់ខេត្តបានកើនឡើង ។ ការអនុវត្តន៍មិនបានល្អនៅដើមឆ្នាំនីមួយៗ ធ្វើឱ្យប៉ះពាល់ដល់ការគ្រប់គ្រងថវិកាដែលមានផលប៉ះពាល់អវិជ្ជមាន ជាពិសេសលើសកម្មភាពនានាដែលទាក់ទងនឹងប្រតិទិនកសិកម្មដែលមានចរិតរដូវកាល ។
- *ការបែងចែកធនធានទៅកាន់អនុវិស័យនិងបែងចែកតាមភូមិសាស្រ្តគ្មានប្រសិទ្ធភាព* ។ ការបែងចែករបស់ MAFF ចំពោះការផ្សព្វផ្សាយកសិកម្មមានចំនួនតិចជាងមួយភាគរយនៃថវិកា[៥៥] នៅពេលដែលការផ្សព្វផ្សាយកសិកម្មស្ថិតនៅក្នុងអាទិភាពខ្ពស់នៅក្នុងយុទ្ធសាស្រ្តរបស់រដ្ឋាភិបាលសំរាប់កាត់បន្ថយភាពក្រីក្រ( SEDP II, NPRS ) ធនធានមួយចំណែកធំត្រូវបានបែងចែកទៅឱ្យក្រសួងនៅថ្នាក់កណ្តាល (MAFF, MOWRAM ) ។ ចំណាយ PAP របស់ MAFF ជាងពាក់កណ្តាលត្រូវបានចំណាយលើការដាំព្រៃឈើសារឡើងវិញ ក្នុងនោះមួយចំណែកធំត្រូវបានចំណាយលើលាភការរបស់បុគ្គលិក ។ គេពុំឃើញមានយន្តការកំណត់គោលដៅ/ដើម្បីធានាឱ្យមានថវិកា និងចំណាយឆ្ពោះទៅរក ប្រជាពលរដ្ឋក្រីក្រឡើយ ។ គេពុំឃើញមានប្រព័ន្ធសំរាប់តាមដានថវិកា និងពតិមាន ហិរញ្ញវត្ថុរបស់នាយកដ្ឋាន និងផ្នែកពាក់ព័ន្ធដទៃទៀតរបស់ MAFF ឡើយ ។

១០៤. *ចាំបាច់ត្រូវធ្វើទំនើបភាវូបនីយកម្មស្ថាប័នវិស័យកសិកម្មដើម្បីឆ្លុះបញ្ចាំងការផ្ទេរទិសដៅផ្នែកសេដ្ឋកិច្ច ពីសេដ្ឋកិច្ចផែនការ និងសេដ្ឋកិច្ចផ្តោតលើការផលិត ទៅរកការធ្វើពាណិជ្ជកម្ម*

[55] នៅប្រទេសថៃស្មើរ ១៦%

*និងការផ្តោតទៅលើទីផ្សារ* ។ ការផ្លាស់ប្តូររបស់កម្ពុជាឆ្ពោះទៅរកកសិកម្មដែលផ្តោតទៅលើទីផ្សារត្រូវបានបង្ហាញតាមរយៈ ការដកចេញនូវការវិនិយោគ/ឯកជនភាវូបនីយកម្មដែលកំពុងដំណើរការនៅអតីតសហគ្រាសដែលគ្រប់គ្រងដោយរដ្ឋ (AIC, KAMFIMEX ចំការកៅស៊ូ កសិដ្ឋានបណ្តុះពូជ) និងការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្មកសិកម្មដែលអនុវត្តបន្តពីសេរីភាវូបនីយកម្មលើថ្លៃកសិកម្ម ។ ប៉ុន្តែការផ្លាស់ប្តូរទាំងនេះមានល្បឿនយឺត ហើយនៅបន្តប្រឈមមុខនឹងការប្រឈមជាច្រើនពីផលប្រយោជន៍ឯកជន ។ ស្របជាមួយគ្នានេះ ស្ថាប័ននៅតាមវិស័យចាំបាច់ត្រូវរៀបចំកែទំរង់ដើម្បីឆ្លុះបញ្ចាំងនូវទិសដៅសេដ្ឋកិច្ចថ្មី ។ ទិដ្ឋភាពបួនដែលតំរូវឱ្យមានការគាំទ្ររួមមាន (i) ការកំណត់ឡើងវិញនូវមុខងារនៃវិស័យសាធារណៈអំពីកសិកម្ម (ii) ពិនិត្យឡើងវិញនូវមុខងារនិងភារកិច្ចរបស់ស្ថាប័នសំខាន់ៗជាពិសេសនៅក្នុងបរិបទនៃវិមជ្ឈការ និងវិសហមជ្ឈការ (iii) អនុវត្តបញ្ចប់នូវការធ្វើឯកជនភាវូបនីយកម្មដែលកំពុងដំណើរការ និង(iv) ដោះស្រាយបញ្ហាកង្វះជំនាញ សំខាន់ៗ ។

១០៥. *ការកំណត់សារជាថ្មីនូវមុខងាររបស់វិស័យសាធារណៈអំពីកសិកម្ម* ។ មុខងារមួយចំនួននៃមុខងារបច្ចុប្បន្នដែលអនុវត្តដោយក្រសួង MAFF និងស្ថាប័នពាក់ព័ន្ធជាមុខងារចាស់ហួសសម័យ និងជាមុខងារដែលមិនសមស្របចំពោះស្ថាប័នសាធារណៈនៅក្នុងសេដ្ឋកិច្ចទីផ្សារ ។ ក្រសួង MAFF និងស្ថាប័នកសិកម្មសាធារណៈចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើការផ្តល់ទំនិញសាធារណៈ ដោយងាកចេញពីការចូលរួម ដោយផ្ទាល់នៅក្នុងការងារផលិតកម្ម ការបែងចែកកត្តាផលិតកម្ម និងការរកទីផ្សារ ដែលការងារនេះគួរតែ ទុកឱ្យវិស័យឯកជនជាអ្នកធ្វើ ។ ឧទាហរណ៍ ផលិតកម្មគ្រាប់ពូជនៅកសិដ្ឋានបណ្តុះគ្រាប់ពូជរបស់រដ្ឋសំរាប់ លក់និងឬចែកចាយទៅឱ្យកសិករ និងការចែកចាយជីគីមី[56] ។ ម្យ៉ាងវិញទៀតមុខងារសាធារណៈសំខាន់ៗ មួយចំនួននៅមានការអភិវឌ្ឍន៍តិចតួចនៅឡើយ ឧទាហរណ៍ការវិភាគសេដ្ឋកិច្ចចំពោះការអភិវឌ្ឍន៍ គោលនយោបាយ ការឃ្លាំមើលអេពីដេមីសាស្រ្ត ការជំរុញគ្រឹះស្ថានផលិតកម្មជនបទ ការអភិវឌ្ឍន៍

---

[56] កំណត់សំគាល់របស់អ្នកបកប្រែៈ អត្ថបទដើមមិនបានបញ្ជាក់ថាតើកសិដ្ឋានបណ្តុះគ្រាប់ពូជរបស់រដ្ឋនេះគប្បីធ្វើឯកជនភាវូបនីយកម្ម ឬយ៉ាងណានោះឡើយ ។

និងអនុវត្ត ន៍ស ង់ដារសុវត្ថិភាពស្បៀង ចាំបាច់ត្រូវពិនិត្យមើលសារឡើងវិញនូវមុខងាររបស់ក្រសួង MAFF នៅក្នុងក្របខ័ណ្ឌអនុវត្ត ឥណទានអភិវឌ្ឍន៏វិស័យកសិកម្មរបស់ ADB និងផ ល់ជាមូលដ្ឋានសំរាប់ផែនការ ធ្វើទំនើបភាវូបនីយកម្មស្ថាប័ននេះ រួមមានការកំណត់សារជាថ្មីនូវមុខងារសំខាន់ៗរបស់ក្រសួង និងសេចក ី ត្រូវការក្នុងការរៀបចំបុគ្គលិក និងជំនាញសមស្រប ។ ការបង្កើនផ្តល់ការគាំទ្រផ្នែកនយោបាយ និងបង្កើន ភាពជាអ្នកដឹកនាំ គឺជាការចាំបាច់ដើម្បីអនុវត្ត នូវការរៀបចំរចនាសម្ព័ន្ធសារជាថ្មី ។ វឌ្ឍនភាពលើកំណែ-ទំរង់មុខងារសាធារណៈក៏មានសារៈសំខាន់ផងដែរក្នុងការគាំទ្រការផ្លាស់ប រទាំងនេះ ។

១០៦. *ការពិនិត្យមើលសារជាថ្មីនូវមុខងារ និងភារកិច្ចរបស់ស្ថាប័នសាធារណៈសំខាន់ៗ និងបង្កើនកិច្ចប្រឹងប្រែងរួមគ្នាជាមួយដំណើរការកសាងផែនការនៅមូលដ្ឋាន ។* ការរៀបចំ និងអាណត ិរបស់ MAFF នៅថ្នាក់កណ ាល និងក៏រិតរដ្ឋបាលជាន់ទាប (ថ្នាក់ខេត និងថ្នាក់ស្រុក) នៅមិនទាន់បានវិវឌ្ឍដើម្បីឆ្លុះបញ្ចាំងនូវការផ្លាស់ប រថ្មីៗ នៅក្នុងទិសដៅសេដ្ឋកិច្ច និងរដ្ឋបាលរបស់កម្ពុជានៅឡើយទេៈ មុខងារថ្មីរបស់វិស័យសាធារណៈនៅក្នុងសេដ្ឋកិច្ចទីផ្សារ ហើយថ្មីៗនេះគឺមុខងារនៅក្នុងដំណើរការវិមជ្ឈការ និងសហ-វិមជ្ឈការ ។ ជាពិសេសមុខងាររបស់ PDAFF និង DAO[57]ដែលមានសារៈសំខាន់សំរាប់ឱ្យមានចំណងទាក់ទងមានប្រសិទ្ធវាងកសិករនិងក្រសួង មិនត្រូវបានគេកំណត់ច្បាស់លាស់ឡើយ ដែលធ្វើឱ្យកាត់បន្ថយប្រសិទ្ធភាពនៃការរៀបចំគោលនយោបាយ ការអនុវត្តន៏គោលនយោបាយ និងការផ ល់សេវាកសិកម្ម ។ មានតំរូវការបន្ទាន់ក្នុងការកំណត់សារជាថ្មីឡើងវិញ នូវអាណត ិការងាររបស់ការិយាល័យទាំងនោះដើម្បីបំរើ ឱ្យបានប្រសើរនូវមុខងារស្នូលនៃការកសាងផែនការ និងពុទ្ធិនៃសេដ្ឋកិច្ចនៅមូលដ្ឋានជំរុញផលិតភាពកសិកម្ម (គាំទ្រការអភិវឌ្ឍន៏ការរៀបចំរបស់កសិករ សេវាផ្សព្វផ្សាយកសិកម្មសេវាពត៌មានទីផ្សារ ការតាមដាន និងត្រួតពិនិត្យជំងឺសត្វ និងជំងឺរុក្ខជាតិ និងការគ្រប់គ្រងធនធានព្រៃឈើ និងជលផល ។ វត មានរបស់ មន្ទីរកសិកម្មនៅមូលដ្ឋាន/ថ្នាក់ស្រុកក្នុងការអនុវត្តន៏គោលនយោបាយជាតិ ផ ល់ដំណឹងដល់ក្រសួងអំពីកិច្ច អភិវឌ្ឍន៏កសិកម្មនៅមូលដ្ឋាន តាមដានការអនុវត្តន៏ច្បាប់ និងអនុវត្តន៏បទប្បញ្ញត្តិ ទាក់ទងនឹងផលិតកម្ម កសិកម្ម ។ល។ ក៏ចាំបាច់ត្រូវកំណត់សារឡើងវិញ ឱ្យស្របគ្នាជាមួយនឹងគោលនយោបាយវិមជ្ឈការរបស់ រដ្ឋាភិបាលផងដែរ ។ ដូចគ្នាដែរ

---

[57] មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យកសិកម្មស្រុក

មុខងារនិងវត ្តមានរបស់សេវាផ្សព្វផ្សាយកសិកម្មថ្នាក់ខេត ្ត និងថ្នាក់ស្រុក ក៏ចាំបាច់ត្រូវកំណត់សារជាថ្មី ជាផ្នែកមួយនៃការវិភាគទូទៅអំពីវត ្តមានរបស់ MAFF នៅថ្នាក់ខេត ្ត និងថ្នាក់មូលដ្ឋាន រួមមានកិរិតនៃការផ ្តល់មូលនិធិ និងការរៀបចំបុគ្គលិកសមស្របនៅកិរិតទាំងនោះ ។ មានការផ ្តួចផ្តើមការងារដែលបានទទួលការគាំទ្រពីគំរោង APIP និង ADESS អំពីសេចក ្តីត្រូវការ ធ្វើទំនើបភាវូបនីយកម្មនៃ PDAFFs និង DAOs ។

១០៧. *បញ្ចប់ការធ្វើឯកជនភាវូបនីយកម្មដែលកំពុងប្រព្រឹត ្តទៅនៅសហគ្រាសរបស់រដ្ឋ និងបង្កើតក្របខ័ណ្ឌ បង្កលក្ខណៈងាយស្រួលសំរាប់វិស័យឯកជន* ។ ឯកជនភាវូបនីយកម្មនៃសហគ្រាសរដ្ឋសំខាន់ៗនៅក្នុងវិស័យ កសិកម្មកំពុងប្រព្រឹត ្តទៅដោយមានការគាំទ្រពី ADB [៥៨] ។ គេរំពឹងថាដំណើរការនេះនឹងបញ្ចប់នៅឆ្នាំ ២០០៦ ដែលរួមផ្សំជាមួយនឹងការកែលំអបរិយាកាសអាជីវកម្ម និងបើកផ្លូវឱ្យមានការចូលរួមកាន់តែច្រើន ពីវិស័យឯកជនក្នុងការផ ្តល់សេវាលើកត ្តាផលិតកម្ម និងសេវាគាំទ្រក្នុងការរកទីផ្សារ ។

១០៨. *ដោះស្រាយលើកង្វះខាតជំនាញជាក់លាក់នៅក្នុងវិស័យ* ។ កង្វះការយល់ដឹងអំពីផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឬកង្វះខាតជំនាញ ឆ្លុះបញ្ចាំងតាមរយៈកង្វះសមត្ថភាព (នៅគ្រប់ថ្នាក់) ក្នុងការរៀបចំគោល-នយោបាយ ការវិភាគសេដ្ឋកិច្ចសង្គមកិច្ច/ការវិភាគអំពីការវិនិយោគ វិទ្យាសាស្រ ្តសេដ្ឋកិច្ចអំពីការ គ្រប់គ្រងទឹកនិងកសិដ្ឋាន ការរកទីផ្សារកសិកម្មនិងបញ្ញាពាណិជ្ជកម្ម និងជំនាញអាជីវកម្មទូទៅនៅជនបទ ។ គេត្រូវការជំនាញទាំងនេះជាបន្ទាន់ ប្រសិនបើស្ថាប័នពាក់ព័ន្ធរួមវិភាគទានប្រកបដោយប្រសិទ្ធភាព ចំពោះ ការកសាងផែនការគោលនយោបាយ ផ ្តល់អនុសាសន៍ល្អប្រសើរ ដើម្បីឱ្យមានការវិនិយោគពីកិរិតកសិករ ទៅកាន់កិរិតវិស័យ និងដើម្បីវាយតំលៃតថភាពពិតប្រាកដនៃជំរើសគោលនយោបាយ និងជំរើសវិនិយោគ ។ ការរៀបចំផែនការតាមវិស័យផ្អែកលើលទ្ធភាពផ្គត់ផ្គង់ និងផ្អែកលើលទ្ធផល ជាជាងការផ្ដោតលើប្រាក់ចំណូល ជនបទ/ការកាត់បន្ថយភាពក្រីក្រ ។ មានការយល់ដឹងតិចតួច ឬបទពិសោធន៍ស្ដួចស្ដើងអំពីវិធីសាស្រ ្តដែល មានការចូលរួម អំពីវិធីសាស្រ ្តស្ដីពីប្រព័ន្ធធ្វើកសិកម្ម និង/ឬសេដ្ឋកិច្ចកសិកម្មនៅក្នុងក្រសួងជំនាញ និងនៅក្នុងនាយកដ្ឋានរបស់ក្រសួងទាំងនោះ (ទាំងនៅថ្នាក់កណ ្តាល និងថ្នាក់ខេត្ត) ។ បបុគ្គលិករដ្ឋាភិបាល ទំនងជាប្រកាន់យកវិធីសាស្រ ្តពីលើ-

[58] ឥណទានវិស័យកសិកម្មលើកទីមួយ និងឥណទានអភិវឌ្ឍន៍វិស័យកសិកម្មនៅពេលខាងមុខ

ចុះក្រោមជាជាងការប្រកាន់យកវិធីសាស្រ្ត ក្នុងឋានៈជាអ្នកផ្តល់សេវា (ឧទាហរណ៍នៅក្នុងការផ្សព្វផ្សាយកសិកម្ម ការគ្រប់គ្រងទឹក) ។

## ការសំរួលសេវាគាំទ្របច្ចេកទេស និងសេវាគាំទ្រទីផ្សារ

១០៩. *ការផ្សព្វផ្សាយកសិកម្មអាចមានមុខងារសំខាន់ ក្នុងការតភ្ជាប់គំលាតផ្នែកបច្ចេកទេសបច្ចុប្បន្ន នៅក្នុងផលិតកម្មកសិកម្ម និងនៅក្នុងការចាត់ចែង និងកែច្នៃក្រោយពេលប្រមូលផល ។* អាណត្តិការងារសំរាប់សេវាផ្សព្វផ្សាយកសិកម្មត្រូវបានផ្តល់ទៅឱ្យនាយកដ្ឋានមួយដែលទើបបង្កើតឡើង (ឆ្នាំ ១៩៩៨) គឺនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៅភ្នំពេញ និងការិយាល័យផ្សព្វផ្សាយកសិកម្ម (ថ្នាក់ខេត្ត ថ្នាក់ស្រុក) ។ នៅឆ្នាំ ១៩៩៨ មានការបង្កើតឡើងនូវយុទ្ធសាស្រ្តស្តីពីការផ្សព្វផ្សាយកសិកម្មដែលមានការគាំទ្រពីអង្គការ AusAID និងមានការបណ្តុះបណ្តាលដល់បុគ្គលិកផ្សព្វផ្សាយកសិកម្ម (AEW) នៅថ្នាក់ខេត្ត និងនៅថ្នាក់ស្រុកនៅ ១៣ខេត្ត (CAAEP និង CAAEP II) ។ ស្របជាមួយគ្នានេះអង្គការក្រៅរដ្ឋាភិបាលមួយចំនួន និងកម្មវិធីដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយបានបង្កើតឡើងនូវគំរូខុសៗគ្នាសំរាប់ផ្តល់សេវាផ្សព្វផ្សាយកសិកម្ម[៥៩] រួមមានគំរូផ្ទេរបច្ចេកវិទ្យាពីកសិករទៅកសិករ និងការអនុវត្តន៍រួមផ្សំរវាងការផ្តល់កញ្ចប់ផតណទាន និងការផ្សព្វផ្សាយកសិកម្មដែលដៅចំពោះកសិករក្រីក្រ ។

១១០. *ប៉ុន្តែសេវាផ្សព្វផ្សាយនៅមានលក្ខណៈ ក្មេងខ្ចីនៅឡើយ ដែលកសិករចំនួនតែ 0.៧%ប៉ុណ្ណោះ ដែលមានលទ្ធភាពបានទទួលសេវាផ្សព្វផ្សាយក្នុងទំរង់ណាមួយ[60] ហើយបញ្ហាគុណភាពនិងប្រសិទ្ធិភាពនៅតែជាបញ្ហានៅឡើយ ។* ក្នុងចំណោមប្រជាកសិករ ស្ត្រីមានចំនួន ៥៤% ប៉ុន្តែមានកសិករស្ត្រីតែ ១០% ប៉ុណ្ណោះដែលបានទទួលសេវាផ្សព្វផ្សាយកសិកម្ម ។ជាទូទៅពតិមាននានាមានទំរង់ជាពតិមានដែលផ្តល់ពីលើចុះក្រោម ហើយឧបសគ្គលើជំនាញ culturaland[61] បានធ្វើឱ្យរាំងស្ទះដល់ការចូលរួមរបស់ AEW លើការផ្លាស់ប្តូរ

---

[59] ត្រូវបានពិនិត្យមើលសារឡើងវិញនៅក្នុងការពិនិត្យមើល"ការផ្សព្វផ្សាយកសិកម្ម" សេចក្តីព្រាងរបាយការណ៍ Castellanet ២០០៣ សំរាប់ធនាគារពិភពលោក

[60] Castellanet ឆ្នាំ 2003.

[61] បុគ្គលិកមន្ទីរកសិកម្ម ចំនួនតិចជាង២៥%មានវិញ្ញាបនប័ត្រ ឬ មានលក្ខណៈសម្បត្តិខ្ពស់ជាងនេះ អត្រាភាគរយ នេះអាចមានកំរិតទាបជាងនេះ នៅថ្នាក់ស្រុក ។ សេចក្តីណែនាំស្តីពីការកសិកម្មក្នុងពេលបច្ចុប្បន្ន ប៉ាន់ស្មានថា ការរៀបចំបុគ្គលិក ត្រូវការ

គំនិតទៅវិញទៅមកជាមួយកសិករ ។ គេឃើញមានសញ្ញាណនៃគំនិតឆ្នៃប្រឌិតផ្សេងៗដែលកសិករផ្តួចផ្តើម ប៉ុន្តែសញ្ញាណទាំងអស់នោះមិនទាន់បានរៀបចំចងក្រងជាឯកសារបានល្អនៅឡើយទេ ហើយមានកម្មវិធីតិចតួចប៉ុណ្ណោះដែលបង្កលក្ខណៈឱ្យមានការផ្លាស់ប្តូរមតិយោបល់របស់កសិករ ឬផ្លាស់ប្តូរយោបល់ជាមួយសមាគមកសិករ ។ ជោគជ័យក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មក្នុងផ្នែកឯកជនកើតមានដោយកម្រ ហើយទំនងជាមានទំនាក់ទំនងជាមួយសមត្ថភាពវិនិយោគខ្ពស់ អនុញ្ញាតឱ្យមានយុទ្ធសាស្ត្រផ្អែកលើអត្ថប្រយោជន៍ពេលវែងចំពោះការវិនិយោគ ។កសិករដែលចូលរួមនៅក្នុងកម្មវិធីបែបនេះទំនងជាកសិករដែលមានជីវភាពធូរធារបំផុត និងមានទ្រព្យសម្បត្តិច្រើន។ ប៉ុន្តែគេពុំឃើញមានការវាយតំលៃដែលមានលក្ខណៈជាប្រព័ន្ធអំពីប្រសិទ្ធភាពនៃកម្មវិធីផ្សេងគ្នាៗទាំងនោះឡើយ ។

១១១. *ការសិក្សាស្រាវជ្រាវកសិកម្មនៅទន់ខ្សោយ ភាគច្រើនជាការសិក្សាស្រាវជ្រាវដែលបានទទួលការគាំទ្រ តាមគំនិតផ្តួចផ្តើមរបស់អ្នកផ្តល់ជំនួយ ។* សមិទ្ធផលដែលគួរឱ្យកត់សំគាល់បំផុតគឺការបង្កើត CARDI[62] ដែលជាស្ថាប័នចំបងរបស់ជាតិ ធ្វើការស្រាវជ្រាវកសិកម្មដោយទទួលការឧបត្ថម្ភគាំទ្រពីអូស្ត្រាលី។ ស្ថាប័ន ស្រាវជ្រាវក្នុងស្រុកនៅមានភាពទន់ខ្សោយក្នុងការធ្វើសមាហរណកម្មជាមួយវិស័យឯកជន (កសិករ និង អាជីវកម្មកសិកម្ម) និងជាមួយស្ថាប័នដទៃទៀត ដូចជាស្ថាប័នផ្សព្វផ្សាយកសិកម្ម និងអប់រំកសិកម្ម ជាដើម។ នៅពេលខាងមុខឥណទានអភិវឌ្ឍន៍កសិកម្ម (ADB) នឹងមានការរៀបចំផែនការមេសំរាប់សិក្សាស្រាវជ្រាវ កសិកម្ម ដើម្បីដោះស្រាយបញ្ហាដែលវិស័យនេះប្រឈមមុខ ។ ដោយមានការគាំទ្រពីគំរោង APIP គេបានបង្កើតយុទ្ធសាស្ត្រសំរាប់អប់រំកសិកម្ម ប៉ុន្តែចាំបាច់ត្រូវអនុវត្តន៍យុទ្ធសាស្ត្រនេះ ។

១១២. *បញ្ហាចំបងសំរាប់អនាគតនៃប្រព័ន្ធជាតិផ្សព្វផ្សាយកសិកម្ម ដែលគាំទ្រដោយវិស័យសាធារណៈ គឺបញ្ហា ទាក់ទងនឹងការផ្តល់ហិរញ្ញប្បទាននិងនិរន្តរភាព។* ថវិការបស់ MAFF មានចំនួន ១,៤% នៃ ថវិការបស់ រដ្ឋាភិបាល ( IFAPER ឆ្នាំ 2003)ក្នុងនោះ មានចំនួនតែ ១% ប៉ុណ្ណោះ ដែលផ្តល់ទៅឱ្យនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ ប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅថ្នាក់កណ្តាលមានលក្ខណៈជាប្រព័ន្ធសាធារណៈទាំងស្រុង មានលទ្ធភាពចូលទៅដល់សហគមន៍និងភូមិទាំងអស់ គឺជាប្រព័ន្ធមួយដែលរដ្ឋាភិបាលត្រូវចំណាយខ្ពស់ ទោះបីជាក្នុងរយៈពេលមធ្យមក្តី។ បញ្ហាបៀវត្សរបស់បុគ្គលិកគឺជាការសំខាន់ សំរាប់ធានាឱ្យសេវាផ្សព្វផ្សាយកសិកម្មសាធារណៈមានប្រសិទ្ធភាពនិងតម្លាភាព។ កំរិតប្រាក់បៀវត្សបច្ចុប្បន្ននៅថ្នាក់ស្រុក មានកំរិតទាប

---

មន្ត្រីកសិកម្មដែលមានជំនាញចំនួន៥នាក់ ក្នុងស្រុកនីមួយៗ(សរុបចំនួន៩០០នាក់ សំរាប់ប្រទេសទាំងមូល)ក្នុងនោះ មានមន្ត្រីពី១៥០ទៅ២០០នាក់ដែលបានទទួលការបណ្តុះបណ្តាជំហ៊ានដំបូងរួចហើយ ។

[62] វិទ្យាស្ថានស្រាវជ្រាវកសិកម្មនិងអភិវឌ្ឍន៍កម្ពុជា

ឆ្ងាយណាស់ធៀបនឹងកំរិតប្រាក់បៀវត្ស ដែលគេផ្តល់ក្នុងគំរោងផ្តត់ផ្គង់ដោយម្ចាស់ជំនួយ ឬដោយអង្គការក្រៅរដ្ឋាភិបាល និងដោយវិស័យឯកជន ដែលធ្វើឱ្យជួបការលំបាកក្នុងការរក្សាមន្ត្រីរាជការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក។ នៅពេលដែលកំរិតប្រាក់ខែនិងថវិកាប្រតិបត្តិការមិនគ្រប់គ្រាន់ សេវាផ្សព្វផ្សាយកសិកម្មសាធារណៈនឹងនៅតែមានលក្ខណៈទន់ខ្សោយតទៅទៀត[63] ។ ជាងនេះទៅទៀតប្រព័ន្ធនេះ អាចជាប្រព័ន្ធពុំមែនមានលក្ខណៈប្រសើរបំផុត ក្នុងការផ្តល់អត្ថប្រយោជន៍លើគំនិតផ្តួចផ្តើមផ្ទាល់និងលើសមត្ថភាពនៃប្រឹក្សាឱតរបស់កសិករឡើយ រាប់ទាំងការផ្តល់ពតិមាន[64]ពីកសិករទៅកសិករផងដែរ។ ការផ្សព្វផ្សាយកសិកម្ម" បែបពាក់កណ្តាល "ដែលកំណត់គោលដៅដោយបានទទួលមូលនិធិពីផ្នែកសាធារណៈ អនុញ្ញាតឱ្យមានការគាំទ្រចំពោះការបង្កើតវិធីសាស្ត្រចំរុះ ដែលមានការប្រកួតប្រជែងខ្លះៗរវាងអ្នកផ្តល់សេវាផ្សេងៗគ្នា (ឯកជន អង្គការក្រៅរដ្ឋាភិបាល។ល) អាចដំណើរការបានក្នុងបរិបទបច្ចុប្បន្នកាន់តែប្រសើរ។ ទោះជាយ៉ាងនេះក្តីការបញ្ជាក់ច្បាស់លាស់អំពីចំណាប់អារម្មណ៍និងឆន្ទៈរបស់រដ្ឋាភិបាលក្នុងការធ្វើការងារតាមទិសដៅនេះគឺជាការចាំបាច់ ព្រោះថាកាលពីមុនមានការប្រឆាំងតបនឹងវិធីសាស្ត្របែបនេះនៅក្នុង MAFF[65] ។

## តារាងទី ៦ : លក្ខណៈស្តីពីបច្ចេកវិទ្យាកសិកម្ម និងកត្តាលើកទឹកចិត្តវិស័យឯកជនក្នុងការផ្តល់បច្ចេកវិទ្យាទាំងនោះ

[63] ក្នុងពេលបច្ចុប្បន្ននេះបុគ្គលិកផ្សព្វផ្សាយកសិកម្ម ត្រូវបន្តរកមើលប្រភពប្រាក់ចំណូលបន្ថែមជាប្រចាំ ស្វែងរក "អត្ថប្រយោជន៍ " ដែលធ្វើអោយប៉ះពាល់ដល់ការកសាងផែនការសកម្មភាពរបស់ពួកគេ ។

[64] ការបង្កើនប្រាក់ខែដើម្បីទ្រទ្រង់ប្រព័ន្ធផ្ស ព្វផ្សាយកសិកម្មសាធារណៈ ផ្អែកលើមូលដ្ឋាននៃសំណើមកផ្សព្វផ្សាយ កសិកម្មចំនួន៥នាក់ ក្នុងមួយស្រុក ដែលផ្តល់លាភការក្នុងកំរិតសមស្រប ដើម្បីរក្សាទុកនៅបុគ្គលិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (ប្រហែល ១៥០ដុលាក្នុង១ខែ លើមូលដ្ឋាននៃគំរោង/ជប្រាក់បៀវត្សវិស័យឯកជនសមរាប់អ្នកបច្ចេកទេស កសិកម្មដែលបានទទួលការ បណ្តុះបណ្តា) ត្រូវមានថវិការស្មើនិង១.៦២លានដុលាអាមេរិកក្នុង១ឆ្នាំ សំរាប់ចំណាយលើប្រាក់ខែ សុទ្ធដែលមាន ទំហំ៣ដងនៃ ថវិការ ចរន្តសរុប សំរាប់ផ្នែកផ្សព្វផ្សាយកសិកម្ម ឬ (៤២%នៃថវិការ PDAFFs សរុបបច្ចុប្បន្ន ) ។

[65]ក្នុងពេលកនងទៅគោលនយោបាយ របស់ MAFF’s ស្តីពីការផ្សព្វផ្សាយកសិកម្ម ពុំមានលក្ខណៈច្បាស់លាស់ នៅក្នុងការងនុវត្តន៏ជាក់ស្តែងឡើយ ដែលក្រសួងអនុញ្ញាត្តិអោយមានការបង្កើនប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ដោយឡែកនៅក្នុងនាយកដ្ឋានផ្សេងៗ( IPM នៅក្នុង DAHP ការផ្សព្វផ្សាយកសិកម្មបសុសត្វនៅក្នុង DAALI ការផ្សព្វផ្សាយដំណាំកៅស៊ូនៅក្នុង DGPH )ស្របជាមួយនិងសកម្មភាពរបស់ DAE ព្យាយាមនៅក្នុងការភ្ជាប់ជាមួយនិងអ្នកផ្តល់ សេវាឯកជនលើការងារផ្សព្វផ្សាយកសិកម្មជាមួយនិងកម្មវិធីអនុវត្តន៍ដោយក្រសួង MAFF ដោយធ្វើអោយមានការជំទាស់យ៉ាងខ្លាំងក្លាពីក្រសួង MAFF (ឧទាហរណ៏ APIP និងការបណ្តុះបណ្តាចំពោះ VAHWs ដោយ by NGOs ការផ្តល់អោយធ្វើកិច្ចសន្យាអំពីសេវាផ្សព្វផ្សាយកសិកម្ម ដល់ អង្គការក្រៅរដ្ឋាភិបាលរបស់ CAAEP’s ) ។

| ប្រភេទទំនិញ | ទំនិញសាធារណៈ | សម្បត្តិរួម | ពន្ធ | ឯកជន |
|---|---|---|---|---|
| លក្ខណៈ | មិនអាចផាត់ចេញ និងមិនប្រកួតប្រជែង | ដែលអាចប្រកួតប្រជែងប៉ុន្តែមិនអាចផាត់ចេញ | ដែលអាចផាត់ចេញ និងមិនប្រកួតប្រជែង | ដែលអាចផាត់ចេញ និងប្រកួតប្រជែង |
| ឧទាហរណ៍ | ការព្យាករណ៍អាកាសធាតុ ទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយអំពីផលិតកម្មនិងអំពីព័ត៌មានទីផ្សារ បច្ចេកទេសគ្រប់គ្រងដោយធម្មជាតិ ការគ្រប់គ្រងការឆ្លងជំងឺបសុសត្វ | គ្រាប់ពូជដែលកកើតដោយឯកឯង ការគ្រប់គ្រងវាលស្មៅរួម នេសាទរួម | ការវិភាគដី កម្មវិធីកុំព្យូទ័រគ្រប់គ្រងកសិដ្ឋាន ការពិគ្រោះផ្នែកឯកជនស្តីពីការដាំដុះនិងការរកទីផ្សារ ថ្នាំវ៉ាក់សាំងបង្ការមេរោគសំរាប់បសុសត្វ | គ្រាប់ពូជបង្កាត់ផលិតផលជីវៈបច្ចេកវិទ្យា គ្រឿងចក្រកសិកម្ម និងថ្នាំបសុសត្វ |
| លទ្ធភាពនៃការផ្តល់របស់ឯកជន | ទាបណាស់ | ទាប | ខ្ពស់ជាង | ខ្ពស់ |

*កំណត់សំគាល់:* មិនអាចផាត់ចេញ = អ្នកដែលមិនបង់ប្រាក់នៅតែអាចទទួលបាន។ មិនប្រកួតប្រជែង = ការប្រើរបស់បុគ្គលម្នាក់មិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកម្នាក់ទៀតក្នុងការប្រើប្រាស់

ប្រភព: Umali-Deininger 1997; World Bank 2002

១១៣. *អវត្តមាននៃទីផ្សារ និងអវត្តមាននៃសេវាពាណិជ្ជកម្ម ព្រមទាំងអប្រសិទ្ធភាពនៅក្នុងខ្សែសង្វាក់តំលៃ ធ្វើឱ្យប៉ះពាល់ភាពប្រកួតប្រជែងកសិកម្មរបស់កម្ពុជា។* ចាប់តាំងពីឆ្នាំ១៩៩៤មក នៅឆ្នាំ ២០០១ ការនាំចេញ កសិកម្ម(លើកលែងតែព្រៃឈើ) បានចុះថយដល់កំរិតទាបបំផុត ក្នុងកំរិតត្រឹម ៥៤ លាន ដុល្លារអាមេរិក (ក្នុងនោះ៩០%ជាកៅស៊ូ) ក្នុងខណៈដែលការនាំចូលផ្នែកកសិកម្មបានកើនឡើងដល់ ៣០១ លាន ដុល្លារ (FAOSTATS)។ ប្រសិទ្ធភាពផ្នែកផលិតកម្មមិនអាចប្រៀបធៀបបានច្បាស់លាស់ឡើយ។ គ្មានការ ស្រាវជ្រាវអំពីប្រព័ន្ធពត៌មានទីផ្សារផលិតផលដែលមានតំលៃខ្ពស់ ក្នុងខណៈដែលគ្មានការអនុវត្តន៍ឱ្យបានសមស្របនូវស្តង់ដារសុវត្ថិភាព ចត្តាឡីសក្ត ស្តង់ដារសុវត្ថិភាពស្បៀងអាហារ ស្តង់ដារសុវត្ថិភាពជីវៈ

ការអនុវត្តន៏ច្បាប់មិនបានល្អ ចំណាយដឹកជញ្ជូនខ្ពស់ ការយកប្រាក់ក្រៅផ្លូវការច្រើន ចំណាយនៃការធ្វើអាជីវកម្មកើនឡើង គឺជាឧបសគ្គចំបងចំពោះការវិនិយោគឯកជននៅក្នុងវិស័យកសិកម្ម និងអាជីវកម្មកសិកម្ម ។ ដំណើរការចូលទៅក្នុងប្រព័ន្ធ WTO បានលើកបញ្ហាទាំងនេះ ឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ ។

១១៤. *លើកលែងចំពោះសមាគមវិជ្ជាជីវៈនៃក្រុមធ្វើកសិកម្ម និងក្រុមធ្វើកសិអាជីវកម្ម ដែលមានចំនួនតិចតួច កម្ពុជាស្ទើរតែគ្មានស្ថាប័នរកទីផ្សារផ្លូវការ និងស្ថាប័នសំរួលពាណិជ្ជកម្មសោះឡើយ ។* មានឧបសគ្គចំបងមួយក្នុងការទទួលព័ត៌មានអំពីការធ្វើពិពិធកម្មនៃផលិតកម្ម ។ ជាងនេះទៅទៀត ការផ្តោតការយកចិត្តទុកដាក់លើលទ្ធផលនៅក្នុងគោលនយោបាយសាធារណៈក្នុងពេលកន្លងទៅ មិនបានយកចិត្តទុកដាក់អំពីតំរូវការរបស់ទីផ្សារលើគុណភាព និងស្តង់ដារនានាឡើយ ។ ខណៈដែលសមត្ថភាពរបស់ផលិតករខ្នាតតូចក្នុងការទាញយកឧត្តមភាពពេញលេញអំពីកាលានុវត្តភាពទីផ្សារដែលកំពុងកើតមាន ពឹងផ្អែកមួយផ្នែកធំលើសមត្ថភាពរបស់ពួកគេ ក្នុងការឆ្លើយតបនឹងតំរូវការរបស់ទីផ្សារអំពីគុណភាពនិងស្តង់ដារ ។ ស្តង់ដារទាំងអស់នេះគឺជាស្តង់ដារនិងជាប្រព័ន្ធដែលកាន់តែទទួលនូវការគ្រប់គ្រងច្រើនឡើងៗ ជាពិសេសសំរាប់ពាណិជ្ជកម្មអន្តរជាតិលើផ្នែកផលិតផល ស្តង់ដារ និងប្រព័ន្ធអន្តរជាតិ តាមរយៈកិច្ចព្រមព្រៀងអន្តរជាតិ និងកិច្ចព្រមព្រៀងទ្វេភាគី ។ វិស័យឯកជនដើរតួនាទីកាន់តែសំខាន់នៅក្នុងកិច្ចអភិវឌ្ឍន៍ស្តង់ដារគុណភាព ។ ផលិតភាពរបស់ផលិតករខ្នាតតូច ច្រើនតែពឹងផ្អែកលើគុណភាពនៃវត្ថុធាតុដើម ដែលជាញឹកញាប់អ្នកទិញជួបការលំបាកក្នុងការប៉ាន់ស្មានអំពីគុណភាព ហើយផលិតករខ្នាតតូចច្រើនតែរងគ្រោះពីផលិតផលក្លែងក្លាយ ។ ឧទាហរណ៍ដែលបញ្ជាក់ថាបញ្ហានេះមានសារៈសំខាន់គឺ គុណភាពគ្រាប់ពូជ ឱសថសំរាប់សត្វ សារធាតុផ្សំនៃជីរនិងថ្នាំសំលាប់សត្វល្អិត ដែលការបិតផ្លាកសញ្ញានិងការវេចខ្ចប់ចំពោះផលិតផលនីមួយៗចាំបាច់ត្រូវច្បាស់លាស់ និងផ្តល់ពត៌មានឱ្យអ្នកទិញបានដឹង ។ ដោយសារប្រទេសកម្ពុជាកំពុងបន្តអនុវត្តយុទ្ធសាស្ត្រនៃការធ្វើសមាហរណកម្មជាមួយទីផ្សារអន្តរជាតិ ហើយជាបន្តបន្ទាប់ៗ កម្ពុជាក្លាយជាសមាជិកមួយនៃសមាគមពាណិជ្ជកម្មអន្តរជាតិផ្សេងៗ ដែលមានភារកិច្ចក្នុងការរៀបចំពាណិជ្ជកម្ម ការព្រួយបារម្ភជាក់លាក់នៅក្នុងស្រុក (ឧទាហរណ៍ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត ) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិបច្ចុប្បន្នកំពុងជំរុញរបៀបវារៈ ក្នុងស្រុកដើម្បីឱ្យមានការកសាងសមត្ថភាព ។

១១៥. *ជាផ្នែកមួយនៃកំណែទំរង់ការភ្ជាប់ខ្លួនជាមួយនឹង ASEAN និង WTO ការអភិវឌ្ឍន៏បទប្បញ្ញត្តិស្តីគុណភាពនិងស្តង់ដារ បានបង្កើនល្បឿន ។* គំនិតផ្តួចផ្តើមគួរឱ្យកត់សំគាល់រួមមាន : (i) សេចក្តីព្រាងច្បាប់ស្តីពីបទប្បញ្ញត្តិបច្ចេកទេស និងស្តង់ដារផ្សេងៗកំពុងត្រូវបានរៀបចំ សំរាប់វិទ្យាស្ថានស្តង់ដារជាតិ របស់កម្ពុជា (ដែលដើរតួជាចំណុចទំនាក់ទំនង យោងតាមកិច្ចព្រមព្រៀងរបស់ WTO ស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម )

និងស្តីពីគុណភាពនិងសុវត្ថិភាពនៃផលិតផលនិងសេវា (ii) ក្រោមសំពាធឱ្យដោះស្រាយការប្រឈមមុខនឹងគ្រោះថ្នាក់របស់ប្រជាពលរដ្ឋជនបទចំពោះថ្នាំសំលាប់សត្វល្អិតដែលងាយបង្កគ្រោះថ្នាក់ រដ្ឋាភិបាលបានចេញអនុក្រឹត្យមួយស្តីពីស្តង់ដារនិងការគ្រប់គ្រងសំភារៈកសិកម្មនិងបានបង្កើតការិយាល័យ (BAMS) នៅក្នុងក្រសួង MAFF និងដើម្បីអនុវត្តន៍និងតាមដានការអនុវត្តន៍អនុក្រឹត្យនេះ និង (iii) បង្កើតគណៈកម្មាធិការជាតិស្តីពីស្បៀងអាហារ ។ ប៉ុន្តែការអនុវត្តន៍បទប្បញ្ញត្តិនៅតែជាបញ្ហាសំខាន់ ។

១១៦. *លៃយ៉ាងណាឱ្យផលិតករតូចតាចមានមធ្យោបាយក្នុងការឆ្លើយតប និងតំរូវការទីផ្សារ តំរូវឱ្យមានការបង្កើនការគាំទ្រ ។ ប្រទេសកម្ពុ*ជាបានចាប់ផ្តើមរៀបចំប្រភពផ្សេងៗនៃជំនួយអន្តរជាតិ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងផលិតផលកសិកម្ម និងគ្រប់គ្រងសុវត្ថិភាពស្បៀង[66] ។ ទោះបីជាមានកិច្ចប្រឹងប្រែងទាំងនេះក្តី កង្វះសមត្ថភាពលើការគ្រប់គ្រងទីផ្សារក្នុងស្រុក និងការគ្រប់គ្រងផ្នែកអនាម័យនិងភូតគាមអនាម័យ (SPS) សំរាប់ការនាំចេញ នៅជាឧបសគ្គផ្ទាល់ចំពោះផលិតភាពរបស់ផលិតករនិងមានឧបសគ្គក្នុងការចូលទៅកាន់ទីផ្សារនានា ។ កង្វះសមត្ថភាពនៃប្រព័ន្ធត្រួតពិនិត្យបសុសត្វរបស់កម្ពុជាមានន័យថា ទោះបីជាកម្ពុជាមានលទ្ធភាពនាំចូលទីផ្សារ EU ដោយគ្មានការដាក់កំហិតលើកូតាក្តី ប៉ុន្តែនៅក្នុងកម្មវិធីEBA ផលិតផលសាច់សត្វ ផលិផលបសុបក្សី និងផលិតផលនេសាទក្នុងស្រុកមិនបំពេញតាមល័ក្ខខ័ណ្ឌអនាម័យនិងភូតគាមអនាម័យរបស់ EC ឡើយ ហេតុដូចច្នេះកម្ពុជាមិនអាចនាំចូលផលិតផលទាំងនោះទៅកាន់សហគមន៍អឺរ៉ុបបានទេ ។ ជាងនេះទៅទៀត ទីផ្សារនាំចេញច្រើនតែមានស្តង់ដារផ្ទាល់របស់ខ្លួន ដែលធ្វើឱ្យកាន់តែមានភាពស្មុគស្មាញ និងពិបាកជ្រៀតចូលទៅកាន់ទីផ្សារទាំងនេះ ។ ប្រទេសកម្ពុជាមានផែនការនាំចេញគ្រឿងសមុទ្រទៅកាន់ប្រទេសជប៉ុន ហើយគ្រោងនាំចេញត្រីទឹកសាបទៅ

---

[66] ក្រោមកម្មវិធី APIP មជ្ឈមណ្ឌលជាតិតាមដានសុខភាពនិផលិតកម្មសត្វ (NAHPIC) ត្រូវបានរៀបចំសាជាថ្មី នឹងពង្រឹង ធ្វើជាមណ្ឌលនៃបណ្តាញមន្ទីរពិសោធជាតិ ដែលមានសារៈសំខាន់ជាងផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងចំពោះសុវត្ថិភាព ស្បៀងអាហារក្នុងស្រុកនិងពាណិជ្ជកម្មអន្តរជាតិអំពីបសុសត្វ និងសាច់សត្វ ប្រទេស នូវែលហ្សេឡង់ តាមរយៈគំរោងគាំទ្រ របស់ ASEAN ដាក់បញ្ចូលប្រទេសកម្ពុជាទៅក្នុងសកម្មភាព សំរាប់ធ្វើកិច្ចអភិវឌ្ឍន៍សមាសភាពផ្នែកភូតគ្គកាមអនាម័យ រួមមានទិន្នន័យ មូលដ្ឋានជាតិនិងស្តីពីភូតគ្គគាមអនាម័យ ដែលជួយក្នុងការចេញ លិខិតអនុញ្ញាតិសំរាប់នាំចូលនៅវិញ្ញាបនប័ត្រ នាំចេញក្នុងចំណោមសមត្ថភាពដទៃទៀត ។មានដំណាក់កាលពីបន្ថែមទៀតផ្តល់ការបណ្តុះបណ្តាដល់មន្ត្រីជាន់ខ្ពស់រៀបចំផែនការយុទ្ធសាស្ត្រ សំរាប់ប្រទេសទីមួយៗ UNESCAP (បាងកក) តាមរយៈការឧបត្ថម្ភគាំទ្រផ្នែក បច្ចេកទេសចំពោះឧស្សាហកម្ម សំរាប់ការនាំចេញ (AAIEP) បានផ្តល់ការគាំទ្រ ចំពោះកម្ពុជា លើវិស័យជលផល ក្នុងការកំណត់អត្តសញ្ញាណតាមរយៈការសិក្សាទីផ្សារស្តីអំពីសក្តានុពលនាំចេញថ្មីរួមជាមួយទីប្រឹក្សាមកពីប្រទេស Infofish សិក្ខសាលាស្តីពី សុវត្ថិភាពស្បៀងនិង HACCP; ប្រទេស UNIDO បានផ្តល់ការគាំទ្រផងដែរចំពោះប្រព័ន្ធសុវត្ថិភាពស្បៀងអាហារអង្គការ AusAid ក៏កំពុងផ្តល់ជំនួយផងដែរតាមរយៈ គំរោងមួយរបស់ ASEAN ។

ប្រទេសអង់គ្លេស ប៉ុន្តែប្រទេសកម្ពុជាចាំបាច់ត្រូវលើកកំពស់អធិការកិច្ច លើកកំពស់ការវេចខ្ចប់ ការគ្រប់គ្រង ដើម្បីឱ្យកិច្ចការទាំងអស់នេះអនុវត្តន៏ឱ្យបានចប់សព្វគ្រប់ ។ មុននេះមានការប្រឹងប្រែងនាំចេញត្រីទៅកាន់អឺរ៉ុប ប៉ុន្តែមិនអាចអនុវត្តបានដោយសារគ្មានការពិនិត្យគុណភាព ។ ជាងនេះទៅទៀត ប្រសិនបើការជំរុញការវិនិយោគកសិឧស្សាហកម្មបច្ចុប្បន្ននៅកម្ពុជាមានអំណោយផលចំពោះផលិតកម្មខ្នាតធំ ហានិភ័យកើតឡើងចំពោះផលិតករតូចតាច ក្នុងការរៀបចំខ្លួនឱ្យមានជំនាញ និងមានមធ្យោបាយឆ្លើយតបនឹងល័ក្ខខ័ណ្ឌនៃទីផ្សារនាំចូលទាំងនោះ ។

១១៧. *បញ្ហាមួយដែលពិបាក ប៉ុន្តែមានសារៈសំខាន់សំរាប់រដ្ឋាភិបាលគឺ តើត្រូវកសាងសមត្ថភាពក្នុងស្រុកយ៉ាងដូចម្តេចដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពស្បៀង និងដើមម្បីឆ្លើយតបតាមល័ក្ខខ័ណ្ឌទីផ្សារនាំចេញដើម្បីឱ្យមានគុណភាពនិងមានស្តង់ដារ ហើយជំរុញឱ្យផលិតករខ្នាតតូចមានលទ្ធភាពទទួលបានប្រព័ន្ធនិងសុវត្ថិភាពទាំងនេះសំរាប់ឆ្លើយតបនឹងល័ក្ខខ័ណ្ឌផ្សេងៗ* ។ ប្រការនេះតំរូវឱ្យមានវិធានការរួមគ្នា គេអាចធ្វើតាមរយៈក្រុមផលិតករក្នុងការកាត់បន្ថយចំណាយប្រតិបត្តិការ ដោយមានការផ្សព្វផ្សាយ និងមានលទ្ធភាពទទួលពតិមានសំខាន់ៗ ដើម្បីជួយសំរួលសមត្ថភាពរបស់ផលិតករ តូចតាចឱ្យចូលរួមនៅក្នុងទីផ្សារបច្ចុប្បន្ន។ មានការងារត្រូវធ្វើបន្ថែមទៀត ក្នុងការកំណត់រកជំរើសនានា ដើម្បីដោះស្រាយបញ្ហាទាំងនេះក្នុងក្របខ័ណ្ឌនៃសមត្ថភាព និងធនធានសមត្ថភាពជាក់លាក់ និងក្នុងក៏រិតនៃធនធានរបស់កម្ពុជា ។

១១៨. ទោះជាយ៉ាងនេះក្តី ការដោះស្រាយបញ្ហាពាក់ព័ន្ធ ដែលប៉ះពាល់ដល់ការរកទីផ្សារនិងបណ្តាញពាណិជ្ជកម្ម ចំពោះទំនិញកម្ពុជាលើផលិតកម្មកសិកម្ម គឺហួសពីការទទួលខុសត្រូវតែឯងនៃស្ថាប័នវិស័យជនបទ ហើយ តំរូវឱ្យមានសកម្មភាពរួមគ្នាជាមួយស្ថាប័នដទៃទៀតដូចជា ក្រសួងពាណិជ្ជកម្ម គយ នគរបាល និងយោធា (សូមអានប្រអប់ទី៥)។ នៅក្នុងខណៈដែលស្ថាប័នកសិកម្មមានមុខងារជំរុញឱ្យមានការបង្កើនល្បឿនក្នុងការផ្លាស់ប្តូរ រដ្ឋាភិបាលចាំបាច់ត្រូវផ្តល់គាំទ្រផ្នែកនយោបាយ ក្នុងឋានៈជាអ្នកដឹកនាំ ក្នុងការឆ្លើយតប ចំពោះកង្វះខាត ដើម្បីបង្កលក្ខណៈសំរួលការធ្វើពាណិជ្ជកម្ម ។ ការផ្តោតការយកចិត្តទុកដាក់ក្នុងវិស័យសាធារណៈ គប្បីសង្កត់ធ្ងន់លើការជំរុញសុវត្ថិភាពនិងស្តង់ដារម្ហូបអាហារ ដែលយកល្អ ការជំរុញគុណភាព គឺធ្វើតាមរយៈវិស័យឯកជន ។ ចាំបាច់ត្រូវមានការកែលំអលទ្ធភាពឱ្យទទួលបាននូវសេវាហិរញ្ញវត្ថុ និងសេវា អាជីវកម្ម ដើម្បីអនុញ្ញាតឱ្យមានការវិនិយោគលើបច្ចេកវិទ្យាកែច្នៃ ក្នុងការបង្កើនតំលៃរបស់ផលិតផល ។

**ប្រអប់ទី៦ : ឧបសគ្គសំខាន់ៗចំពោះកិច្ចអភិវឌ្ឍន៍ពាណិជ្ជកម្ម**

- មានឧបសគ្គជាច្រើនទាក់ទងនឹងការ*សម្របសម្រួលពាណិជ្ជកម្ម* ដោយសារមានភាពទន់ខ្សោយនៅក្នុងនាយកដ្ឋានគយ និងរដ្ឋាករ
- *មានស្ថាប័នរបស់រដ្ឋាភិបាលមួយចំនួនធំចូលរួមពាក់ព័ន្ធ*ក្នុងការរៀបចំ និងធ្វើអធិការកិច្ចលើការនាំចូល និងការនាំចេញធ្វើឱ្យបង្កើនចំណាយ និងបង្កើនការអូសបន្លាយប្រតិបត្តិការក្នុងការទិញលក់ ។ ក្នុងពេលបច្ចុប្បន្នច្បាប់អនុញ្ញាតឱ្យស្ថាប័នមួយក្នុងចំណោមស្ថាប័ន ១០ មានវត្តមាននៅច្រកត្រួតពិនិត្យអន្តរជាតិ ដែលយ៉ាងហោចណាស់ត្រូវមានតំណាងសមត្ថកិច្ចប្រចាំការចំនួនប្រាំ
- *ការបង់ប្រាក់ក្រៅប្រព័ន្ធ,ក្រៅផ្លូវការ*ជាលក្ខណៈសំគាល់នៃប្រព័ន្ធរកទីផ្សារនៅកម្ពុជា រាប់ទាំងការប្រមូលពន្ធផ្លូវច្ពល់ផ្លូវការ "ប្រាក់បន្ទុក"យកពីអាជ្ញាប័ណ្ណនាំចេញ និងប្រាក់បន្ទុកនៅតាមព្រំដែន និងនៅទីផ្សារ ។ ការបង់ប្រាក់ទាំងនេះបានបង្កើននូវចំណាយពាណិជ្ជកម្មយ៉ាងច្រើន ហើយជំរុញឱ្យមានការរត់ពន្ធ ។ ប្រការនេះកាន់តែមានលក្ខណៈធ្ងន់ធ្ងរបន្ថែមទៀត ដោយសារមានព្រំដែនវែងជាមួយប្រទេសជិតខាង និងដាច់ស្រយាល ពន្ធនាំចូលមានអត្រាខ្ពស់លើទំនិញមួយចំនួន ដូចជាទំនិញប្រើប្រាស់ និងប្រេងឥន្ធនៈជាដើម ។
- *ហេដ្ឋារចនាសម្ព័ន្ធជនបទមិនល្អ*ដែលធ្វើឱ្យចរាចរផលិតផលជួបការលំបាកនៅក្នុងប្រទេស ហើយធ្វើឱ្យសហគមន៍កសិកម្មជាច្រើនស្ថិតនៅឯកោ ពិសេសនៅរដូវវស្សា
- *ផលិតផលកសិកម្មមានគុណភាពមិនល្អ*ដោយសារកសិករខ្វះការយល់ដឹងអំពីបញ្ហាគុណភាព ខ្វះការយល់ដឹងលើបច្ចេកវិទ្យាកែច្នៃ បរិក្ខារនិងសម្ភារៈដំដាំកែច្នៃជាបរិក្ខារចាស់ៗ និងការខូចខាតបណ្តាលមកពី ការចាត់ចែងមិនបានល្អក្នុងការទុកដាក់និងដឹកជញ្ជូន
- វិស័យសហគ្រាសកសិកម្មមានទំហំតូច អភិវឌ្ឍមិនបានល្អ *បង្កើនតំលៃបន្ថែមបានតិចតួចក្នុងការកែច្នៃផលិតផល* ។ ប្រការនេះពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធមិនល្អ និងពាក់ព័ន្ធជាមួយឧបសគ្គចំពោះការអភិវឌ្ឍន៍អាជីវកម្ម រួមជាមួយវត្តមាននៃវិស័យហិរញ្ញវត្ថុទន់ខ្សោយ អំពើពុករលួយខ្លាំងក្លា និងមានជំនាញអាជីវកម្មតិចតួច។

(*ប្រភព*: *Integrated Framework, 2001*)

**កំណត់កម្មវិធីសំរាប់លើកកំពស់លទ្ធផលអនុវត្តន៍នៃអនុវិស័យសំខាន់ផ្នែកកសិកម្ម**

១១៩. ក្នុងខណៈដែលការឆ្លើយតបចំពោះកិច្ចអភិវឌ្ឍន៍នៅទូទាំងប្រទេស តាមវិស័យនានា ប្រឈមមុខនឹងបញ្ហាជាច្រើននៅកំរិតខុសៗគ្នានៃខ្សែសង្វាក់ទំនិញត្រូវការពេលវេលាច្រើន ដំណោះស្រាយបញ្ហាចំពោះទំនិញជាក់លាក់សំខាន់ៗអាចនឹងទទួលការគាំទ្របានឆាប់រហ័សនិងងាយស្រួលពីកម្មវិធីទ្រទ្រង់ជាក់លាក់ ។ វិធីសាស្រ្តនេះនឹងអនុញ្ញាតឱ្យពង្រឹងការរៀបចំផលិតករ និង ផ្អែកលើភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដើម្បីដោះស្រាយឧបសគ្គនានា ។

## *អង្ករ*

១២០. *ការរួមវិភាគទាននៃអង្ករចំពោះកំណើនកសិកម្មមានកំរិតតិចតួច ប៉ុន្តែការលើកកំពស់ប្រព័ន្ធបច្ចុប្បន្ន មានលក្ខណៈសំខាន់សំរាប់សន្តិសុខស្បៀង និងជាមូលដ្ឋានមួយសំរាប់ការធ្វើពិពិធកម្មផលិតកម្ម ។* កម្មវិធីសកម្មភាពបច្ចុប្បន្នរបស់ MAFF [67] ផ្តល់ការយកចិត្តទុកដាក់លើការបង្កើនផលិតកម្មស្រូវ និងការនាំចេញអង្ករ (ផែនការផលិតផលសំរាប់ឆ្នាំ ២០០៣-២០០៤ គឺ ៤,៥លានតោន ពីកំរិត ៤លានតោន នៅឆ្នាំ ២០០២) ។ ប៉ុន្តែសមត្ថភាពស្រូបរបស់ទីផ្សារក្នុងស្រុក បរិមាណលើសនៃស្រូវអង្ករនៅលើទីផ្សារអន្តរជាតិ និងសមត្ថភាពផលិតកម្មយ៉ាងច្រើននៅប្រទេសជិតខាងក្នុងពេលបច្ចុប្បន្ន ធ្វើឱ្យកម្ពុជាជួបកំហិតលើសក្តា-នុពលនៃការរួមចំណែករបស់វិស័យផលិតកម្មស្រូវអង្ករចំពោះកំណើនកសិកម្មនៅកម្ពុជា ។ ជាងនេះទៅទៀត ប្រមាណជា ១០% នៃស្រូវអង្ករដែលលក់នៅក្នុងស្រុក ត្រូវបានគេនាំចេញជាផ្លូវការ (ប្រមាណ ៦០,០០០តោន) និងស្រូវ ៣៣% ត្រូវបានប្រជាពលរដ្ឋកសិករ លក់ហើយនាំចេញក្រៅផ្លូវការ (ជាង ៤៥,០០០តោន) នៅឆ្នាំ ២០០១ បង្ហាញនូវខ្សែសង្វាក់រកទីផ្សារថាគ្មានលក្ខណៈជាប្រព័ន្ធ ។

១២១. *នៅកំរិតកសិដ្ឋានការបង្កើនទិន្នផលស្រូវតែមួយមុខគត់គ្រាន់តែអាចរួមវិភាគទានបានតិចតួចប៉ុណ្ណោះក្នុងការបង្កើនប្រាក់ចំណូលរបស់កសិករ ដែលប្រាក់ចំណូលពីការផលិតស្រូវត្រូវបានប៉ាន់ស្មានថាមានចំនួន ១០០-១៥០ ដុល្លារក្នុងមួយហិកតាគិតតាមថ្លៃបច្ចុប្បន្ន ហើយទំហំស្រែជាមធ្យមគឺ ១,៥ហិកតា ប៉ុន្តែមានលទ្ធភាពនៅក្នុងការធានាឱ្យមានសន្តិសុខស្បៀងក្នុងរយៈពេលខ្លីចំពោះផលិតករជីវព្រឹត្តនៅក្នុងតំបន់នានា ដែលគ្មានជំរើសសេដ្ឋកិច្ចដទៃផ្សេងទៀតក្នុងពេលបច្ចុប្បន្នក្នុង ។* សក្តានុពលនៃការបង្កើនកំរិតទិន្នផលស្រូវ ប្រពលភាពនៃផលិតផលកសិកម្ម

[67] សន្និសិទ្ធប្រចាំឆ្នាំស្តីពីកសិកម្មនេសាទ និងព្រៃឈើឆ្នាំ ២០០៣-២០០៤ MAFF

និងផលិតភាពក្នុងមួយឯកតាផ្ទៃដីនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃដំណាំស្រូវ ខុសៗគ្នាមានលក្ខណៈល្អប្រសើរ ។ ការបង្កើនផលិតភាពតំរូវឱ្យមានការបង្កើនទិន្នផលតាមរយៈការប្រើប្រាស់
នូវប្រភេទពូជផ្សេងៗដែលត្រូវបានកែលំអ ការប្រើប្រាស់ជី និងការស្រោចស្រព ។ ការផ្សព្វផ្សាយកសិកម្ម គឺជាបញ្ហាសំខាន់ក្នុងការជំរុញលើការធ្វើអតិផលភាវូបនីយកម្មនៃប្រព័ន្ធកសិកម្មក៏ដូចជាកិច្ចអភិវឌ្ឍន៍ប្រព័ន្ធ គ្រាប់ពូជដែលបង្កើនលទ្ធភាពឱ្យកសិករតូចតាចបានទទួលពូជល្អៗ ។ ទាក់ទងនឹងគ្រាប់ពូជ មានវឌ្ឍនភាព ជាច្រើនដែលគេសំរេចបានក្នុងកិច្ចអភិវឌ្ឍន៍ និងក្នុងការផ្សព្វផ្សាយនូវប្រភេទពូជថ្មីៗជាពិសេសដែលមានការ គាំទ្រពីគំរោង CIAP និង AQIP (AusAID) និងគំរោង APIP (ធនាគារពិភពលោក) ។ គេចាំបាច់ ត្រូវធ្វើការជាច្រើនបន្ថែមទៀតដើម្បីអភិវឌ្ឍនូវក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ និងស្ថាប័នចាំបាច់ដើម្បី អនុញ្ញាតឱ្យមានកិច្ចអភិវឌ្ឍន៍វិស័យគ្រាប់ពូជឯកជនដែលមានលក្ខណៈប្រកួតប្រជែង និងមានប្រសិទ្ធភាព ។ រួមជាមួយនឹងការប្រើប្រាស់ជីរច្រើនជាងមុន ប្រើប្រាស់ក្នុងកំរិតមានតុល្យភាព ការកែលំអពូជ និងការ គ្រប់គ្រងការដ្ឋានការស្រោចស្រពបានល្អអាចបង្កើនទិន្នផល និងបង្កើនការដាំដុះ ជាពិសេសនៅតំបន់ដែលដី មានជីជាតិមធ្យម និងដីមានជីជាតិច្រើនដែលអាចផ្តល់ផលស្រូវចំនួន ៥តោន ក្នុងមួយហិកតាក្នុងមួយឆ្នាំ ស្មើនឹងពីរដងនៃកំរិតផលិតភាពបច្ចុប្បន្ន (FAO ២០០) ។ ប៉ុន្តែ គិតតាមថ្លៃបច្ចុប្បន្ន ការវិនិយោគលើប្រព័ន្ធ
ស្រោចស្រពយ៉ាងច្រើនចំពោះការធ្វើដំណាំស្រូវតែមួយមុខពុំមានលទ្ធភាពផ្តល់ផលចំណេញឡើយ ហើយ ការវិនិយោគលើប្រព័ន្ធស្រោចស្រព គប្បីដាក់បញ្ចូលនូវវិធានការបំពេញបន្ថែម ដើម្បីធានាឱ្យមានពិពិធកម្ម នៃប្រព័ន្ធកសិកម្មដំណាំស្រូវ ឧទាហរណ៍ការចិញ្ចឹមត្រីនៅក្នុងស្រែ ឬប្រព័ន្ធនៃការធ្វើដំណាំស្រូវ និងការ ចញ្ចឹមសត្វ ឬការអភិវឌ្ឍន៍ផលិតផលកសិកម្មដែលមានតំលៃខ្ពស់ ។

១២២. *ការចំណាយលើស្រូវអង្ករក៏ជាចំណែកមួយត្រូវចំណាយខ្ពស់ផងដែរនៅក្នុងមុខចំណាយរបស់គ្រួសារ ដែលក្រីក្របំផុត*

ហើយគប្បីគិតអំពីសក្តានុពលផលប៉ះពាល់អវិជ្ជមាននៃគោលនយោបាយនៃវិស័យស្រូវអង្ករ ដែលបង្កើនថ្លៃអង្ករមកលើប្រជាពលរដ្ឋក្រីក្រ ។

១២៣. *ការអភិវឌ្ឍន៍ផលិតកម្មដំណាំស្រូវដែលគុណភាពខ្ពស់សំរាប់នាំចេញអាស្រ័យលើបរិយាកាសវិនិយោគ ជារួម ។* គេរំពឹងថាផលិតកម្មដំណាំស្រូវដែលមានគុណភាពខ្ពស់ ("វិធីសាស្រ្តរបស់ថៃ") ផ្តល់ផលខ្ពស់ជាង ការផលិតស្រូវដែលមានគុណភាពមិនសូវល្អ ប៉ុន្តែផ្តល់ទិន្នផលខ្ពស់

(”វិធីសាស្រ្តរបស់វៀតណាម”) ។ ប៉ុន្តែ ផលិតកម្មដំណាំស្រូវដែលមានគុណភាពខ្ពស់គេអាចផលិតបានតែមួយផ្នែកនៅលើផ្ទៃដីដែលមានគុណភាពល្អ និងមានលក្ខណ្ឌអំណោយផលផ្នែកកសិកម្ម ដូច្នេះមានតែកសិករមួយចំនួនតូចប៉ុណ្ណោះដែលអាចចូលរួមក្នុងការធ្វើដំណាំស្រូវប្រភេទនេះ ។ ជាងនេះទៅទៀតផលិតកម្ម និងការរកទីផ្សារនៃអង្ករដែលមានគុណភាពខ្ពស់ ចំណុះយ៉ាងខ្លាំងលើការវិនិយោគរបស់ឯកជន និងបរិយាកាសបង្កលក្ខណៈឱ្យមានអាជីវកម្ម[៦៨] ។ ការសិក្សាអំពីខ្សែសង្វាក់តំលៃនៃស្រូវអង្ករ (ធនាគារពិភពលោកឆ្នាំ ២០០២) បានប៉ាន់ស្មានថាសក្តានុពលសំរាប់ការនាំចេញអង្ករដែលមានគុណភាពខ្ពស់មានកំរិត ២00,000-៣00,000តោន ( ADB ឆ្នាំ ២០០២) ហើយមានបរិមាណ ១00,000 បន្ថែមទៀតដែលគេអាចផលិត ដើម្បីជំនួសអង្ករនាំចូលក្នុងពេលបច្ចុប្បន្ន[៦៩] ។

១២៤. *ការបង្កើនលក្ខណៈប្រកួតប្រជែងនៃអង្ករកម្ពុជាសំរាប់នាំចេញ ។* ការនាំចេញអង្ករទៅកាន់ទីផ្សារពិភពលោកក៏តំរូវឱ្យមានការកែលំអក្រោយពេលប្រមូលផលផងដែរ និងដោះស្រាយឧបសគ្គនានាចំពោះការរកទីផ្សារ និងពាណិជ្ជកម្មអង្ករ ។ ថ្លៃអង្ករនៅកសិដ្ឋានក្នុងពេលបច្ចុប្បន្នពុំបានលើកទឹកចិត្តការវិនិយោគ លើកត្តាផលិតកម្ម និងការលើកកំពស់បច្ចេកវិទ្យាផលិតកម្មឡើយ (ADB ឆ្នាំ ២០០២) ។ ឧបសគ្គចំពោះ ការរកទីផ្សារ និងការធ្វើពាណិជ្ជកម្មអង្ករចាំបាច់ត្រូវដោះស្រាយ គឺត្រូវដោះស្រាយអំពីបញ្ហាគុណភាព ការបាត់បង់ក្រោយពេលប្រមូលផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាទ្រទ្រង់មិនល្អ ភាពស៊ីសង្វាក់គ្នាអំពីការផ្គត់ផ្គង់ និងតម្លាភាពនៃប្រតិបត្តិការ ។ សមាគមអ្នកកិនស្រូវកម្ពុជាបានបញ្ជាក់ថាមាន ”ភាពមិនធម្មតា” ជាឧបសគ្គចំបងចំពោះការនាំចេញអង្ករជាផ្លូវការពីប្រទេសកម្ពុជា ។ ពិធីសារនាំចេញ របបអធិការកិច្ចត្រូវចំណាយពេលវេលាយូរ ហើយនីហារិនត្រូវចំណាយខ្ពស់ ដែលធ្វើឱ្យការនាំចេញអង្ករប្រព្រឹត្តទៅតាមបណ្តាញក្រៅប្រព័ន្ធ[៧០] ។ ទន្ទឹមនឹងនេះគេក៏បានធ្វើការប៉ាន់ស្មានផងដែរសកម្មភាពស្វែងរកអត្ថប្រយោជន៏

---

68 មានការវិនិយោគឯកជនមួយចំនួនលើរោងចក្រកិនស្រូវដែលមានគុណភាពខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ហើយបានទទួលជោគជ័យមួយចំនួនសំរាប់កសិករ និងសំរាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ (ការសិក្សាប្រភពនៃកំណើន FAO ២០០៣)

69 តួលេខនេះប្រៀបធៀបជាមួយផលិតកម្មស្រូវសរុបប្រមាណជាបួនលានតោននៅឆ្នាំ ២០០១ ( FAOSTATS )

70 ចំណាយសរុបនៃនិតិវិធីនាំចេញបានបន្ថែមចំណាយចំនួន ១៤ដុល្លាក្នុងមួយតោននូវចំណាយសំរាប់នាំអង្ករចេញ ហើយចំណាយចំពោះបទប្បញ្ញត្តិដែលអប្រសិទ្ធភាពមានចំនួនប្រហែល ៨៥-១២៦% នៃចំណាយសរុបរបស់រដ្ឋាភិបាលនៅក្នុងវិស័យកសិកម្មនៅឆ្នាំ ១៩៩៩ ( CIE និង MOC ឆ្នាំ២០០២) ។

បុគ្គលមានចំណែកស្មើនឹង ២០-៣០% នៃថ្លៃដែលកសិករទទួល ។ ការកាត់បន្ថយចំណាយប្រតិបត ្តិការ អាចលើកកំពស់ភាពប្រកួតប្រជែងនៃអង្ករកម្ពុជានៅលើទីផ្សារអន ្តរជាតិ ហើយធ្វើឱ្យថ្លៃអង្ករនៅកសិដ្ឋានមានតំលៃខ្ពស់ ដែលមានលទ្ធភាពធ្វើឱ្យមានការវិនិយោគបន្ថែមក្នុងការកែលំអបច្ចេកវិទ្យារោងចក្រកិនស្រូវ និងការអនុវត្តន៍ ក្រោយពេលប្រមូលផល ។

១២៥. *ការដោះស្រាយឧបសគ្គ និង អប្រសិទ្ធិភាពដែលបានរកឃើញនៅតាមខ្សែសង្វាក់ទីផ្សារ ក្នុងសភាពជាជាមួយសហគ្រិនឯកជន* ប្រសិនបើប្រៀបធៀបជាមួយវិស័យដទៃទៀត វិស័យដំណាំស្រូវទទួលអត្ថ - ប្រយោជន៍ពីអង្គការដែល មានវិជ្ជាជីវៈខ្ពស់ (ដូចជាសមាគមអ្នកកិនស្រូវ សមាគមផលិតគ្រាប់ពូជ) ទោះបីជានៅមានលក្ខណៈ ទន់ខ្សោយនៅឡើយក ្តី ។ កិច្ចការនេះក៏ផ ្តល់អត្ថប្រយោជន៍ពីការយកចិត ្តទុកដាក់ របស់រដ្ឋាភិបាលបន្ថែមទៀត អំពីការគាំទ្រលើការស្រាវជ្រាវ និងការផ្សព្វផ្សាយផងដែរ ។ ឧបសគ្គចំពោះ ផលិតកម្ម និងការរកទីផ្សារមានឯកសាររៀបចំទុកដាក់បានល្អ ហើយអាទិភាពគឺត្រូវប្រែក្លាយអនុសាសន៍ឱ្យ ទៅជាសកម្មភាពអនុវត ្តជាក់សែ ្តង ។

## *បសុសត្វ*

១២៦. *មានសក ្តានុពលនៅក្នុងការទទួលបាននូវផលិតភាពទូទៅ និងកំណើនប្រាក់ចំណូលនៅក្នុងវិស័យបសុសត្វ* ។ តំរូវការចំពោះសាច់សត្វនៅប្រទេសជិតខាងត្រូវបានគេគ្រោងថានឹងកើនឡើង ។ ប្រទេសថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី បាននាំចូលសត្វរស់យ៉ាងច្រើន ។ នៅក្នុងពេលអនាគតដ៏ខ្លីនៅពេលណាជីវភាពរស់នៅ និងកំលាំងទិញនៅប្រទេសវៀតណាមកើនឡើង គេរំពឹងថាការផ្គត់ផ្គង់សាច់នឹងមានកង្វះខាត ។ មានអំពើរត់ពន្ធគោ-ក្របីរស់ឆ្លងដែនពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម ហើយក៏មានការនាំចេញគោ-ក្របីរស់ទៅកាន់ប្រទេសថៃបានប្រព្រឹត ្តទៅអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដោយមិនបានប្រកាសពតិមាន (ADB ឆ្នាំ២០០២) ។

១២៧. *ការលើកកំពស់ផលិតកម្មបសុសត្វ និងប្រព័ន្ធរកទីផ្សារអាចនាំមកនូវប្រាក់ចំណេញរហ័សសំរាប់ប្រជាពលរដ្ឋមួយផ្នែកធំនៅតំបន់ជនបទ* ។ ការចិញ្ចឹមបសុសត្វគឺជាផ្នែកមួយនៃប្រព័ន្ធកសិកម្មកម្ពុជា ហើយ

ផ ្តល់នូវការរួមវិភាគទានសំខាន់ចំពោះប្រាក់ចំណូលសំរាប់គ្រួសារភាគច្រើន [៧១] ។ ការចិញ្ចឹមជ្រូក និងបសុបក្សី គឺជាប្រភពចំបងនៃប្រាក់ចំណូលសំរាប់គ្រួសារនៅជនបទភាគច្រើន ទោះបីជាផលិតកម្មនេះមាន ចំនួនតិចតួច ហើយអត្រាស្លាប់មានកំរិតខ្ពស់ក ្តី ។ លើកលែងតែបសុបក្សីចេញ អត្រាកំណើននៃបរិមាណសត្វ ពុំមាន កំរិតខ្ពស់ឡើយ ។ សត្វធំៗ (ក្របី គោ) នៅកំពុងត្រូវបានប្រើប្រាស់ជាកំលាំងអូសទាញហើយកំណើន នៃ ចំនួនសត្វទាំងនោះបានចុះថយក្នុងទសវត្សចុងក្រោយនេះ សំខាន់បំផុតគឺដោយសារតែការកើនឡើងនូវ យន ្តបភាវូបនីយកម្ម ។ ការចិញ្ចឹមជ្រូកនៅចាប់ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២000 បានរងគ្រោះដោយទឹកជំនន់ និងដោយសារបញ្ហាជំងឺសត្វ ។ បសុបក្សីជាមធ្យមកើនឡើង ៨,៨ភាគរយក្នុងមួយឆ្នាំចាប់ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២000 ( ADB ឆ្នាំ ២00២) ប៉ុន្តែ ្តកំណើននេះកើនឡើងដោយសារការកសាងនូវអង្គភាពផលិតកម្ម ឧស្សាហកម្មខ្នាតធំនៅក្បែរតំបន់ទីប្រជុំជនដែលក្រួតប្រជែងដោយផ ្ទាល់ជាមួយនឹងផលិតករតូចៗ ។

១២៨. *ក្នុងរយៈពេលខ្លីទៅរយៈពេលមធ្យមគេសង្កេតឃើញមានឱកាសសំរាប់បង្កើនប្រសិទ្ធភាពយ៉ាងច្រើន ក្នុងការចិញ្ចឹមបសុសត្វនៅតាមផ្ទះ ដោយសង្កត់ធ្ងន់ទៅលើការផ ្តល់សេវាសុខភាពសត្វ និងអាហារូបត្ថម្ភ ។* ទោះបីជាចាំបាច់ មានការងារជាច្រើនទៀតដែលត្រូវធ្វើអំពីប្រព័ន្ធសុខភាពសត្វនៅថ្នាក់ជាតិក ្តី រួមមាន ការឃ្លាំមើលដែលមានប្រសិទ្ធភាពអំពីផ្នែកអេពីដេមីសាស្រ ្ត និងការត្រួតពិនិត្យតាមព្រំដែន ការវិនិយោគ ក្នុងកិច្ចអភិវឌ្ឍន៍សេវាបសុសត្វឯកជននៅតាមភូមិនៅក្នុងបណ ្តាខេត្តមួយចំនួនបានកាត់បន្ថយនូវអត្រាស្លាប់នៃ សត្វនៅតាមកសិដ្ឋានដែលតំរូវឱ្យមានការពង្រីកនៅក្នុងក្របខ័ណ្ឌជាតិនូវសេវាបែបនោះ ។ ទោះបីជាចំណូល ពីការលក់បសុសត្វមានសារៈសំខាន់សំរាប់សេដ្ឋកិច្ចគ្រួសារក ្តី គេពុំឃើញមានឯកសារនិយាយអំពីខ្សែសង្វាក់ នៃទីផ្សារបសុសត្វឡើយហើយក៏ពុំឃើញមានឯកសារដែលនិយាយអំពីឱកាសសំរាប់បង្កើនប្រសិទ្ធភាពរបស់ ផ្នែកនេះដែរ ។ ទោះបីជាមានសារៈសំខាន់ ស្តីពីការលក់បសុសត្វចំពោះសេដ្ឋកិច្ចគ្រួសារក្តី កន្លងមកឱកាស សំរាប់បង្កើនប្រសិទ្ធិភាព នៃខ្សែសង្វាក់ទីផ្សារបសុសត្វ និង តំលៃបន្ថែមដែលបានទទួលដោយផលិតករតូច តាច មិនសូវបានគេទទួលយកចិត្តទុកដាក់ឡើយ ។ នៅក្នុងរយៈពេលវែង ការប្រមើលមើលចំពោះការ ចញ្ចឹមជ្រូក និងបសុបក្សីតាមរយៈ ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនផលិតអាហារ និងអាជីវកម្មកសិកម្មក្នុង

---

[71] ជាមធ្យមបសុសត្វផ ្តល់ ១៧% នៃចំណូលគ្រួសារនៅថ្នាក់ជាតិ ( Helmers et al នៅឆ្នាំ ២00៣) ។

ឋានៈជាវិនិយោគិន អាចជាទំរង់វិនិយោគដែលមានសារៈសំខាន់ ។ ជាមួយនឹងការកើនឡើងនូវផលិតផលកសិកម្មមានសក ្តានុពលសំរាប់ អភិវឌ្ឍប្រព័ន្ធអាជីវកម្មកសិកម្មដែលបានធ្វើសមាហរណកម្មតាមខ្សែបណ្តោយ លើកសិផលបសុសត្វ និងផលិតផលនេសាទក្នុងស្រុក រួមមានផលិតកម្មចំណីអាហារខ្នាតតូចនិងខ្នាតមធ្យម រោងចក្រកែច្នៃអាហារ សត្វនិងអាហារត្រី ការចិញ្ចឹមជ្រូក បសុបក្សី និងចញ្ចឹមត្រីដោយប្រើប្រាស់អាហារផលិតនៅក្នុងស្រុក ការកែច្នៃត្រី និងកែច្នៃសាច់ ។ ប្រទេសកម្ពុជា អាចមានលក្ខណៈឈានមុខ ធៀបនឹងបណ ្តាប្រទេសអាស៊ាន នៅក្នុងការរកស៊ីបែបនេះព្រោះកម្ពុជា គឺជាប្រទេសដែលការផលិតវត្ថុធាតុដើមមានតំលៃថោក សំរាប់ការកែច្នៃអាហារត្រី និងអាហារសត្វ (FAO ឆ្នាំ ២000) ។ ក៏ប៉ុន្តែ ្តបទពិសោធន៍ថ្មីៗនេះ (យោងករណី រោងចក្រចំណីសត្វ CP របស់ថៃបង្ហាញថាបរិយាកាសវិនិយោគ និងបញ្ហាសម្រួលលើការនាំចេញ ចាំបាច់ត្រូវ ដោះស្រាយជាមុន ។

## ***នេសាទ***

១២៩. បញ្ហាសំខាន់នៅក្នុងផ្នែកនេះគឺការចិញ្ចឹមត្រី និងការរកទីផ្សារនៃផលិតផលជលផលពីការនេសាទ និងពីការចិញ្ចឹម ។ ទិដ្ឋភាពនៃការគ្រប់គ្រងការនេសាទត្រូវបានពិនិត្យមើលពីខាងដើមនៅត្រង់ចំណុចនិយាយអំពីការគ្រប់គ្រងធនធានធម្មជាតិ ។ បន្ថែមលើមុខងារនៃការគ្រប់គ្រងការនេសាទ DoF ក៏ទទួលខុសត្រូវផងដែរក្នុងការជំរុញវារីវប្បកម្ម ឬការចិញ្ចឹមត្រីក៏ដូចជាការត្រួតពិនិត្យលើការកែច្នៃ ពាណិជ្ជកម្ម និងសកម្មភាពនាំចេញផលិតផលត្រីផងដែរ ។

១៣០. *វារីវប្បកម្ម ជាពិសេសប្រព័ន្ធនៃការចិញ្ចឹមត្រីនៅក្នុងស្រែ ផ ្តល់ឱកាសសំរាប់បង្កើនការចិញ្ចឹមត្រីដែលមានលក្ខណៈជាគ្រួសារ* ។ ថ្មីៗនេះវារីវប្បកម្មមានកំហិតលើសកម្មភាពជាក់លាក់ ដូចជាការរក្សាទុកបំប៉នត្រីឱ្យបានធាត់ធំដើម្បីលក់ឱ្យបានថ្លៃ ស្រះតូចៗសំរាប់ចិញ្ចឹមត្រីទុកបរិភោគតាមគ្រួសារ និងការចិញ្ចឹមផលិតផលជលផលដូចជា ក្រពើ អន្ទង់ កង្កែប ជាដើម[៧២] ។ ជារឿយៗវារីវប្បកម្មតំរូវឱ្យមានការវិនិយោគច្រើនលើហេដ្ឋារចនាសម្ព័ន្ធ និងត្រូវការទុនបង្វិលច្រើន និងត្រូវប្រឈមមុខនឹងហានិភ័យខ្ពស់ ទាមទារឱ្យមានជំនាញក្នុងការគ្រប់គ្រងល្អប្រសើរ ដើម្បីគ្រប់គ្រងឱ្យបាននូវការខាតបង់ពីជំងឺ ឬពីគ្រោះធម្មជាតិផ្សេងៗ ។ ទាក់ទងទៅនឹងកំណើនក្នុងពេលអនាគតសំរាប់រយៈពេលខ្លី វារីវប្បកម្មសមុទ្រមិនត្រូវបានគេរំពឹងថានឹងរួមវិភាគទានច្រើនឡើយ ។ ការចិញ្ចឹមបង្គាត្រូវបានអាជីវករថៃបង្កើតនៅតាមឆ្នេរសមុទ្រកម្ពុជា ទោះបីជាកសិដ្ឋានភាគច្រើនត្រូវបានគេបោះបង់ចោលក៏ដោយ ដោយសារបានផលចំណេញតិចតួច

[72] គេកត់ត្រាថាផលិតកម្មត្រីមានចំនួន ១៥,000តោន និងក្រពើចំនួន ២៥,000ក្បាល ( NIS ឆ្នាំ ២00១) ។

បណ ្តាលមកពីកត្តា ផ្សេងៗរួមមានការគ្រប់គ្រងមិនបានល្អដោយមានជំងឺបង្គាឆ្លងនៅក្នុងតំបន់ ។ ក៏ប៉ុន្តែ ្តទំរង់នៃវារីវប្បកម្មដែល គេអនុវត ្តជាទូទៅអំពីការចិញ្ចឹមត្រីនៅក្នុងស្រែដោយជីកអន្លង់ គេត្រូវចំណាយប្រាក់វិនិយោគតិចតួច និង អាចរកប្រាក់ចំណូល ដែលប្រាក់ចំណូលនោះអាចមានចំនួនខ្ពស់ជាងការធ្វើដំណាំស្រូវតែមួយមុខ[៧៣] ។ ផលិតផលមានបរិមាណខ្ពស់ជាងនៅក្នុងតំបន់លិចទឹក នៅពេលដែលកសិករម្ចាស់ការបានល្អលើការគ្រប់គ្រងទឹកជាពិសេសនៅក្នុងរដូវប្រាំង ។ ប្រការនេះបង្ហាញថាកិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតតូចពុំមែនគ្រាន់តែអាចលើកកំពស់លទ្ធផលកសិកម្មប៉ុណ្ណោះទេ

ក៏ប៉ុន្តែ ្តក៏ផ ្តល់ទិន្នផលត្រីខ្ពស់ផងដែរនៅក្នុងផ្ទៃដីដដែល ដែលគេធ្វើដំណាំស្រូវ ។ ជាងនេះទៅទៀត ការចិញ្ចឹមត្រីក្នុងស្រែតំរូវឱ្យមានការប្រើប្រាស់ជីរតិចតួច និង តំរូវឱ្យប្រើប្រាស់ជីគីមីតិចក្នុងការទទួលទិន្នផលដូចគ្នា ។ ក៏ប៉ុន្តែ ្តការចិញ្ចឹមត្រីក្នុងស្រែចាំបាច់រៀបចំ និង គ្រប់គ្រងដោយយកចិត ្តទុកដាក់ក្នុងការកាត់បន្ថយហានិភ័យចំពោះត្រី បណ ្តាលមកពីការប្រើប្រាស់សារធាតុ គីមីកសិកម្មនៅក្នុងដំណាំស្រូវ ។

១៣១. *ដោះស្រាយអប្រសិទ្ធភាព នៃការរកទីផ្សារ និងបណ្តាញពាណិជ្ជកម្ម ដើម្បីបង្កើន តំលៃបន្ថែម និង បង្កើនលទ្ធផលទូទៅរបស់វិស័យនេះ។* កាលពីប៉ុន្មានឆ្នាំកន្លងទៅការនាំចេញត្រីជាផ្លូវការនៅប្រទេសកម្ពុជា មានចំនួនពី ៣០,០០០ ទៅ ១០០,០០០ តោន (ប្រហែល១០ - ២៥%នៃបរិមាណផលនេសាទសរុប) ភាគច្រើនគឺការនាំចេញត្រីទឹកសាបពុំទាន់កែច្នៃទៅវៀតណាម ក្នុងខណៈដែលការនាំចេញក្រៅផ្លូវការបាននិងកំពុងកើនឡើង ។ ទន្ទឹមជាមួយគ្នានេះ មានការខាតបង់ត្រីយ៉ាងច្រើនដោយសារត្រីស្អុយ បណ្តាលមកពីកង្វះបណ្តាញទីផ្សារដែលមានប្រសិទ្ធិភាពដោយ រួមទាំងកង្វះមធ្យោបាយរក្សាទុកផងដែរ ។ មូលហេតុដែលបណ្តាលឱ្យមានបញ្ហានេះគឺដោយសារក្របខ័ណ្ឌស្ថាប័នមិនដំណើរការក្នុងការរកទីផ្សារត្រី ដែលធ្វើឱ្យបាត់បង់ឱកាសសំរាប់បង្កើនតំលៃបន្ថែមនៅក្នុងស្រុក ហើយបរិមាណមួយផ្នែកធំនៃតំលៃនាំចេញត្រីស្រស់ត្រូវខាតបង់ដោយសារតែត្រីខូចគុណភាពបណ្តាលមកពីការអូសបន្លាយពេលវេលាក្នុងការរកទីផ្សារ និងការរក្សាទុកមិនបានត្រឹមត្រូវ ។ ប្រព័ន្ធរកទីផ្សារចាំបាច់ ត្រូវដឹកជញ្ជូនផលិតផលងាយខូចគុណភាពទៅដល់ទីផ្សារលក់ឱ្យបានឆាប់រហ័ស ឬ ត្រូវមានបរិក្ខារបញ្ចុះសីតុណ្ហភាព និងបរិក្ខាកែច្នៃ រក្សាទុកនៅក្នុងសីតុណ្ហភាពត្រជាក់ ឬ

---

[73] ផលិតកម្មស្រូវប្រចាំឆ្នាំតាមធម្មតាមានចំនួន ២០០ ទៅ ៤០០ គីឡូក្រាមក្នុងមួយហិកតា ឬមានបរិមាណ បួនដងទៅប្រាំបីដងច្រើនជាងពីការនេសាទត្រី

មធ្យោបាយផលិតទឹកកក ដើម្បីរក្សាភាពស្រស់របស់ត្រី ។ ទន្ទឹមជាមួយគ្នានេះ ដោយសារអ្នកនេសាទជាអ្នកនេសាទខ្នាតតូច នេសាទត្រីបានតិចតួច គ្មានលទ្ធភាពឈានទៅដល់ការនេសាទបានបរិមាណត្រីគ្រប់គ្រាន់ឱ្យប្រព័ន្ធប្រមូលទិញដែលមានលក្ខណៈស្មុគស្មាញ ដែលគ្រប់គ្រងដោយអ្នកចែកចាយនិងឈ្មួញកណ្តាល។ ជាមួយនិងការកែលំអបណ្តាញទីផ្សារ រួមមានការដឹកជញ្ជូន ការដាក់ទឹកកក ការបង្កក និងការកែច្នៃដទៃទៀតសំរាប់ការប្រើប្រាស់ក្នុងស្រុកនិងសំរាប់នាំចេញ តំលៃនៃការប្រមូលផលនិងលទ្ធផលផ្នែកសេដ្ឋកិច្ចនៃវិស័យនេះនឹងកើនឡើង។ ដើម្បីដោះស្រាយឱ្យមានប្រសិទ្ធភាពក្នុងការរកទីផ្សារពាណិជ្ជកម្មផលិតផលត្រី គេក៏ចាំបាច់ត្រូវមានផង ដែរនូវការសម្របសម្រួលពីស្ថាប័នជាច្រើន( គយ ជលផល ពាណិជ្ជកម្ម ) ។

១៣២. *នៅលើផ្នែកគោលនយោបាយ គេសង្កេតឃើញមានវឌ្ឍនភាពមួយចំនួនក្នុងការធ្វើសេរីភាវូបនីយកម្មនៃវិស័យនេះ ប៉ុន្តែចំណាយប្រតិបត្តិការ មានកំរិតខ្ពស់ហើយការសម្របសម្រួលផ្នែកពាណិជ្ជកម្មគ្មានប្រសិទ្ធភាព ។* KAMFIMEX ជាក្រុមហ៊ុនរបស់រដ្ឋ ដែលដំណើរការក្រោមកាគ្រប់គ្រងរបស់ MAFF មានភាពផ្តាច់មុខក្នុងការនាំចេញត្រីរហូតដល់ចុងឆ្នាំ២០០១ ។ ចាប់តាំងពីពេលនោះមក ជាង ២០ ក្រុមហ៊ុនដទៃទៀតបានទទួលអាជ្ញាប័ណ្ណក្នុងការនាំចេញ ហើយមុខងាររបស់ KAMFIMEX ក៏បានធ្លាក់ចុះជាខ្លាំង ។ ទោះជាយ៉ាងនេះក្តី ទីផ្សារត្រូវបានរំខានដោយការបង់ប្រាក់ក្រៅផ្លូវការ និងដោយសារការតំរូវឱ្យបង់ប្រាក់បន្ទុកមួយចំនួនដែលទំនងជាបំរើគោលដៅតិចតួច។ ប្រាក់បន្ទុកផ្លូវការនិងក្រៅផ្លូវការ ធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណេញលើពាណិជ្ជកម្មត្រី និងធ្វើឱ្យគេបន្ថោកថ្លៃទិញពីអ្នកនេសាទ [74] ។

១៣៣. *វិស័យរកទីផ្សារត្រីក៏រងគ្រោះយ៉ាងខ្លាំងពីកង្វះវិនិយោគ ពីវិស័យឯកជនក្នុងការរៀបចំកន្លែងស្តុកទុក កែច្នៃនិងដឹកជញ្ជូន ។*ប្រព័ន្ធឥណទានជលផលក្តោបក្តាប់ភាគច្រើនដោយអ្នករកស៊ីចងការឯកជន ដែលប្រព្រឹត្តទៅនៅក្រៅប្រព័ន្ធហិរញ្ញវត្ថុផ្លូវការ ហើយគេយកអត្រាការប្រាក់យ៉ាងខ្ពស់។ គេពុំមានពតិមានច្បាស់លាស់ទេថា ហេតុអ្វីបានជាក្រុមហ៊ុនធំៗ ដែលមានលទ្ធភាពក្នុងការរកប្រភពឥណទាន មិនបានធ្វើការ

---

[74] ការសិក្សាថ្មីមួយស្តីអំពីការបង់ប្រាក់ ( CDRI ឆ្នាំ 2003) បានបញ្ជាក់ថាមានការបង់ប្រាក់២៧លើក ផ្សេងៗគ្នា ទៅអោយ ស្ថាប័នចំនួន១៥ នៅទីកន្លែង១៦ នៅតាមខ្សែសង្វាក់ទីផ្សារ សំរាប់នាំចេញត្រីស្រស់ ទៅប្រទេសថៃ ។ ប្រាក់បន្ទុកផូវការជាច្រើន មិនត្រូវបាន គេបង់គ្រប់គ្រាន់ឡើយ ពាណិជ្ជកររចចាបង់ប្រាក់លើបរិមាណត្រី ដែលគេរាយការណ៍មិនគ្រប់ចំនួន ហើយបង់ប្រាក់ក្រៅផូវការណ៍បន្ថែម ។ការរាយការណ៍មិនគ្រប់គ្រាន់អាចមានទំហំរហូតដល់ ៩0% ធ្វើបែបនេះចង់អោយពាណិជ្ជករ ជៀសវាង នៅការ បង់ពន្ធនាំចេញ ១0% ដែលគេយកលើ ត្រីនាំចេញទាំងអស់ ។ពន្ធផូវការណ៍ដទៃទៀត រួមមានប្រាក់បន្ទុក " របស់អ្នកចែកចាយ "ស្មើនិង៤% នៃត្រីសរុបដែលបានដឹកជញ្ជូន តាមខេត្តឆ្ពោះទៅរកការនាំចេញ ។អាជ្ញាប័ណ្ណសំរាប់ការនាំចេញ " ចែកចាយ" ដែលប្រមូលប្រាក់បន្ទុកទាំងនេះ ត្រូវបានផ្តល់តាមរយៈដំណើរការដេញថ្លៃដែលមាន លក្ខណៈប្រកួតប្រជែងប៉ុន្តែ "ចែកចាយ" មិនផ្តល់សេវាណាមួយទៅអោយវិស័យត្រីឡើយ ។

វិនិយោគទៅលើមធ្យោបាយកែច្នៃ និងរក្សាទុកជលផល។ មានការផលិតផ្អក ប្រហុក និងទឹកត្រីមួយចំនួន ទោះបីជាក្នុងទ្រង់ទ្រាយតូចក្តី ហើយភាគច្រើនគេធ្វើជាលក្ខណៈគ្រួសារ ជាជាងធ្វើសំរាប់លក់ដូរ ។ ម្យ៉ាងវិញទៀត គេត្រូវការឱ្យមានវិនិយោគជាច្រើន ក្នុងការលើកកំពស់គុណភាព ស្តង់ដារ សុវត្ថិភាពស្បៀងអាហារ តាមរយៈការផ្តល់វិញ្ញាបនប័ត្រ HACCP និងស្តង់ដារអនាម័យស្បៀងអាហារដទៃទៀត ដើម្បីបើកផ្លូវទៅកាន់ទីផ្សារបរទេសដែលមានតំលៃខ្ពស់ (សហរដ្ឋអាមេរិក ឬ សហភាពអឺរ៉ុប ) ។

## *កៅស៊ូ*

១៣៤. *ការរៀបចំរចនាសម្ព័ន្ធឡើងវិញចំពោះវិស័យ កៅស៊ូមានសារៈសំខាន់ណាស់ ក្នុងការរក្សាការប្រកួតប្រជែងរបស់វិស័យនេះនៅលើទីផ្សារពិភពលោក ខណៈដែលកិច្ចអភិវឌ្ឍន៍ផលិតកម្មកៅស៊ូខ្នាតតូច មានលក្ខណៈរស់រវើក អាចផ្តល់ឱកាស និងផ្តល់ប្រាក់ចំណូលផ្សេងទៀតចំពោះផលិតករ ។* ការព្យាករណ៍សំរាប់រយៈពេលវែង អំពីថ្លៃកៅស៊ូធម្មជាតិ(NR) បង្ហាញឱ្យឃើញលក្ខណៈអំណោយផល[75] ។ សំរាប់ល័ក្ខខ័ណ្ឌអេកូឡូស៊ីកសិកម្មដែលមានអំណោយផលចំពោះដាំណាំកៅស៊ូ កម្ពុជាមានដីជាច្រើន និងមានចំណាយពលកម្មថោក កម្ពុជារួមជាមួយនិងប្រទេសផលិតកៅស៊ូដទៃទៀតក្នុងតំបន់ ដូចជា វៀតណាម ឥណ្ឌូនេស៊ី ចែករំលែកនូវការកើនឡើងនៃឧត្តមភាពប្រៀបធៀប អំពីផលិតកម្មកៅស៊ូ ធៀបនឹងការផលិតកៅស៊ូខ្នាតធំដូចជាប្រទេសម៉ាឡេស៊ី ដែលកំពុងកាត់បន្ថយការដាំដំណាំកៅស៊ូ ដោយសារថ្លៃពលកម្ម និងថ្លៃដីកើនឡើងយ៉ាងខ្ពស់ ។ ទោះជាយ៉ាងណាក៏ដោយ កៅស៊ូរបស់កម្ពុជា ថ្មីៗនេះរងគ្រោះដោយការផ្តល់ទិន្នផលទាប កង្វះការទទួលស្គាល់ពីអន្តរជាតិ អំពីការបញ្ជាក់គុណភាព និងកង្វះតម្លាភាព និងកង្វះការប្រកួតប្រជែងនៅក្នុងដំណើរការរកទីផ្សារ ។ អប្រសិទ្ធភាពទាំងអស់នេះ នៅក្នុងការផលិតនិងនៅក្នុងការរកទីផ្សារ ធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូលនៃចំការកៅស៊ូ[76] ។ ស្ថានភាពនេះត្រូវបានកែលំអខ្លះៗ ដោយសារ

---

[75] ការវិភាគអំពីនិន្នាការណ៍ រយៈពេលវែងចំពោះ តំរូវការផលិតកម្ម កៅស៊ូធម្មជាតិ បងាញថាអាចមាន កង្វះកៅស៊ូធម្មជាតិ ។ កៅស៊ូធម្មជាតិមានចំណែក ៣៥ទៅ ៤០% នៃទីផ្សារកៅស៊ូសរុប ថៃកៅស៊ូអន្តរជាតិធម្មជាតិ ដែលបាន ចាប់ផ្តើម ងើបឡើង មកវិញនៅឆ្នាំ២០០២ ហើយបានឈានទៅដល់ថៃ ១,២ដុលាក្នុងមួយគីឡូក្រាម នៅចុងឆ្នាំ២០០៣ ត្រូវបានគេរំពឹងថានិង បន្តកើនឡើង និងមាន ស្ថេរភាពក្នុងតំលៃ ប្រហែល២ដុលាសហរដ្ឋអាមេរិកក្នុងមួយគីឡូក្រាម នៅក្រោយឆ្នាំ២០១០( " កំណើតសេដ្ឋកិច្ចនិងអនាគតកៅស៊ូធម្មជាតិ " និពន្ធដោយ Burger និង Smit Yamoussoukro ខែវិច្ឆិការឆ្នាំ ២០០១)

[76] វិស័យដំណាំកៅស៊ូ គ្រប់ដណ្តប់ភាគច្រើន ដោយក្រុមហ៊ុនរដ្ឋចំនួន ៧ (ជប់ ក្រែក ម៉េម៉ត់ ស្នួល ចំការអណ្តូង បឹងកេត និងពាមជាំង) នៅឆ្នាំ២០០១ ក្នុងផ្ទៃដីសម្បទានសរុបចំនួន ៦៨,៧០៩ហិកតា មានផ្ទៃដីប្រមាណ ៩០% ស្ថិតនៅ ក្រោមការ គ្រប់គ្រងរបស់រដ្ឋចំនួន៧ ផ្ទៃដីប្រមាណជា ១,៥% ( ១០៣៣ហិកតា ) ជារបស់វិទ្យាស្ថានស្រាវជ្រាវ ដំណាំកៅស៊ូ ( IRCC) និងផ្ទៃដី ៨,៥% ជារបស់វិស័យឯកជន នៅខេត្តតាកែវ និងរតនៈគីរី។ ទាក់ទងទៅនិងតំបន់ធ្វើអាជីវកម្ម ក្រុមហ៊ុនរដ្ឋទាំង៧ គ្រប់ដណ្តប់ ប្រមាណ

ការរៀបចំរចនាសម្ព័ន្ធ សារឡើងវិញដែលបានផ្ដួចផ្ដើមនៅក្នុងឥណទានកសិកម្មនៅលើកដំបូង(ADB) ដែលមានការដកចេញនូវការវិនិយោគពីចំការកៅស៊ូធំៗទាំង ៧ ក្រោមការត្រួតពិនិត្យរបស់ MAFF និងការប្រែក្លាយក្រុមហ៊ុនទាំងនោះទៅជាសហគ្រាសសាធារណៈឯករាជ្យ ។ ទោះជាយ៉ាងនេះក្ដី ដំណើរការនេះចាំបាច់ត្រូវតែស៊ីជំរៅបន្ថែមទៀត ដើម្បីធ្វើឱ្យវិស័យនេះមានលក្ខណៈកាន់តែប្រកួតប្រជែង និងកាន់តែមានលទ្ធភាពក្នុងការស្រូបយកការងារ ដែលរួមវិភាគទានចំពោះកំណើនបន្ថែមនៃវិស័យកសិកម្ម (ADB, 2002) ។

១៣៥. ផ្អែកលើថ្លៃបច្ចុប្បន្ន( ថ្លៃកៅស៊ូកម្ពុជាត្រូវបានគេបញ្ចុះពី ២០%ទៅ៣០% ដោយសារគ្មានការបញ្ជាក់ទទួលស្គាល់ពីអន្តរជាតិ )និងផ្អែកចំណាយផលិតកម្មប្រហែល០.៥ដុល្លារក្នុងមួយតោន សក្ដានុពលប្រាក់ចំណូលសរុបរបស់ប្រទេសពីដំណាំកៅស៊ូត្រូវបានគេប៉ានស្មានថាមានចំនួនប្រហែល ១៨០ លានដុល្លារ ក្នុងមួយឆ្នាំ ដែលមានចំណូលសុទ្ធស្មើនិង ៩០ លានដុល្លារក្នុងមួយឆ្នាំ ។ ចំពោះម្ចាស់ចំការកៅស៊ូតូចៗប្រាក់ចំនូលពីពលកម្មត្រូវបានគេប៉ាន់ស្មានថាមានកំរិតពី៤ទៅ៥ដុល្លារអាមេរិកក្នុងមួយថ្ងៃ មានន័យថា មានកំរិតស្មើ ៤ ឬ ៥ដងនៃប្រាក់ឈ្នួលប្រចាំថ្ងៃក្នុងពេលបច្ចុប្បន្ន ចំពោះវិស័យកសិកម្ម អាស្រ័យហេតុនេះទាក់ទាញ ឱ្យកសិករមានចំណាប់អារម្មណ៍នៅក្នុង វិស័យដំណាំកៅស៊ូ ។

១៣៦. រដ្ឋាភិបាលបានដាក់ចេញនូវគោលដៅដែលមានមហិច្ឆតាខ្ពស់ ក្នុងការពង្រីកផ្ទៃដីដាំដុះឱ្យបានដល់ ៣០០,០០០ ហិកតា ។ ការពង្រីកឧស្សាហកម្មឯកជនត្រូវបានលើកទឹកចិត្តពីសំណាក់រដ្ឋាភិបាលក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ចំការកៅស៊ូខ្នាតតូច ។ ប្រសិទ្ធភាពនិងភាពប្រកួតប្រជែងនៃប្រព័ន្ធផលិតកម្មខ្នាតតូចបានបង្ហាញឱ្យឃើញនៅក្នុងបណ្ដាប្រទេសដទៃទៀតក្នុងតំបន់ ។ ចាប់តាំងពីឆ្នាំ ១៩៩៩មក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD) បាននិងកំពុងផ្ដល់ហិរញ្ញប្បទានចំពោះគំរោងអភិវឌ្ឍន៍ចំការកៅស៊ូគ្រួសារ រីឯធនាគារពិភពលោកវិញ បាននិងកំពុងគាំទ្រការសិក្សាស្រាវជ្រាវកៅស៊ូខ្នាតតូច ។ អន្តរាគមន៍ទាំងពីរនេះត្រូវបានរៀបចំ ដើម្បីបញ្ជាក់នូវសក្ដានុពលចំពោះលទ្ធភាពអភិវឌ្ឍន៍កៅស៊ូលក្ខណៈគ្រួសារដែលមានខ្នាតធំនាពេលអនាគត ។ រហូតមកដល់ពេលនេះ លទ្ធផលជំហ៊ានដំបូងបានបង្ហាញអំពីចំណាប់អារម្មណ៍របស់កសិករនៅក្នុងដំណាំកៅស៊ូ និងភាពសមស្របនៃកិច្ចអភិវឌ្ឍន៍ដំណាំកៅស៊ូរបស់កម្ពុជា ។ ផ្ទៃដីរបស់កម្ពុជាសំរាប់កិច្ចអភិវឌ្ឍន៍ដំណាំកៅស៊ូ (ចំការកៅស៊ូធំៗ និងចំការកៅស៊ូគ្រួសារ ) ត្រូវបានគេប៉ាន់ស្មានថាមានផ្ទៃដី

---

ជា៨៤% នៃផ្ទៃដីសរុប ចំនួន ៣៦,៤០២ហិកតា នៅឆ្នាំ២០០១ ប្រាក់ចំណេញនិងប្រាក់ចំណូល បានមកពីទ្រព្យសម្បត្តិ ក្នុងពេលបច្ចុប្បន្ន មានកំរិតទាប ហើយពុំមានភាពគ្រប់គ្រាន់ ក្នុងការទាក់ទាញ ចំណាប់អារម្មណ៍ពីវិនិយោគគិនដែលមានបំណងវិនិយោគឡើយ ។

ប្រហែល ១៥០,០០០ ហិកតា ដែលមានសក្តានុពលផលិតកម្មសរុបចំនួន ១៨០,០០០តោន[77] ។ ប៉ុន្តែជោគជ័យនៃកម្មវិធីអភិវឌ្ឍន៍កៅស៊ូលក្ខណៈគ្រួសារត្រូវបានគេរំពឹងថា អាស្រ័យលើការលើកកំពស់តម្លាភាព ភាពប្រកួតប្រជែងនៅក្នុងវិស័យនេះទាំងមូល។ ទាល់តែគ្រួសារនានាមានអារម្មណ៍ថាពួកគេមានសុវត្ថិភាពអំពីកម្មសិទ្ធិលើដីធ្លីរបស់ខ្លួនប៉ុណ្ណោះ គេមានជំនឿទុកចិត្តថាផលិតផលរបស់ពួកគេអាចលក់ក្នុងលក្ខណៈប្រកួតប្រជែង ពុំនោះសោតវិនិយោគនិងមានដំណើរការយឺត។ ការរៀបចំរចនាសម្ព័ន្ធសារជាថ្មី និងការធ្វើឯកជនភាវូនីយកម្មនៅពេលណាមួយនៃសហគ្រាសកៅស៊ូ និងផ្តល់ជាផ្លូវត្រួសត្រាយ ដើម្បីឱ្យវិស័យកៅស៊ូមានប្រសិទ្ធភាព និងផ្តល់បរិយាកាសលើកកំពស់សំរាប់កៅស៊ូគ្រួសារ ( ADB, 2002 ) ទន្ទឹមជាមួយគ្នានេះការបង្កើតមធ្យោបាយកែទម្រង់របស់វិស័យឯកជនដែលមានលក្ខណៈឯករាជ្យពីចំការកៅស៊ូធំៗ គួបផ្សំជាមួយនឹងការធ្វើសេរីភាវូបនីយកម្មនៃទីផ្សារកៅស៊ូ នឹងបង្កើតបានជាល័ក្ខខ័ណ្ឌអំណោយផល សំរាប់ជំរុញកិច្ចអភិវឌ្ឍន៍កៅស៊ូដែលមានលក្ខណៈគ្រួសារ ។

## *ដំណាំផ្តល់ប្រាក់ដទៃទៀត និងផលិតផលជាមូលដ្ឋាន*

១៣៧. *ឧបសគ្គចំពោះការផលិតនិងការរកទីផ្សារនៃផលិតផលកសិកម្មដទៃទៀត តំរូវឱ្យមានការវិភាគកាន់តែប្រសើរបន្ថែមទៀត ។* ថ្មីៗនេះមានការសិក្សាមួយចំនួនវាយតំលៃអំពីឧត្តមភាពប្រៀបធៀបរបស់ប្រទេសកម្ពុជានៅក្នុងផលិកម្មកសិផលមិនមែនស្រូវ(ដូចជាអាហាស្បៀង)និងផលិតផលជាមូលដ្ឋាន (គ្រឿងទេស ប្រេងសំខាន់ៗ ។ល) តំរូវការបច្ចុប្បន្ននិងតំរូវការអនាគតលើទីផ្សារអន្តរជាតិ។ ទោះជាយ៉ាងនេះក្តីដូចដែលបានពិភាក្សាពីខាងដើម ការធ្វើពិពិធកម្មដែលកសិករកម្ពុជាកំពុងអនុវត្តក្នុងបរិយាកាសបច្ចុប្បន្ន គឺជាការប្រថុយប្រថាន។ សមត្ថភាពរបស់កសិករកម្ពុជា ក្នុងការច្បាមយកកាលានុវត្តភាពទាំងនោះ អាស្រ័យលើវឌ្ឍនភាពក្នុងការធានាបរិយាកាសសេដ្ឋកិច្ចរបស់ពួកគេ (ការលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធ លទ្ធភាពបានទទួលហិរញ្ញប្បទាន លទ្ធភាពបានទទួលពតិមានទីផ្សារ សុវត្ថិភាពក្នុងការបានទទួលកម្មសិទ្ធិដីធ្លី ។ល។) និងការធ្វេ សមាហរណកម្មបន្ថែមទៀតនៃផលិករនៅតំបន់ជនបទជាមួយទីផ្សារជាតិ និងទីផ្សារអន្តរជាតិ ។ កសិករចាំបាច់ត្រូវយល់ដឹងកាន់តែប្រសើរអំពីឧបសគ្គផលិតកម្ម និងឧបសគ្គទីផ្សារ ។

**អនុសាសន៍ស្តីពីសកម្មភាពអាទិភាពសំរាប់វិស័យកសិកម្ម**

[77] ផ្អែកលើទិន្នផល មធ្យមក៏រ៉ិតទាប ស្មើនិង ១,២តោន ក្នុងមួយហិកតា

## អាទិភាពទី ១ ពង្រឹងការគ្រប់គ្រងវិស័យកសិកម្មដើម្បីបង្កើនប្រសិទ្ធភាព និងឥទ្ធិពលនៃការប្រើប្រាស់ធនធាន

*ពង្រឹងការគ្រប់គ្រងវិស័យ*ដើម្បីបង្កើនប្រសិទ្ធភាពនិងឥទ្ធិពលលើកម្មវិធីគាំទ្រដែលសម្របសម្រួលមិនបានល្អក្នុងពេលបច្ចុប្បន្នក្នុងផ្នែកកសិកម្ម ហើយណែនាំកិច្ចអភិវឌ្ឍន៍នៃកម្មវិធីអនាគត

- *បង្កើតកម្មវិធីអភិវឌ្ឍន៍កសិកម្ម* ដោយផ្តោតលើប្រាក់ចំណូលគ្រួសារនៅជនបទ និងទទួលស្គាល់ស្ថានភាព នានានៅមូលដ្ឋាន និងទទួលស្គាល់តំរូវការរបស់ក្រុមកសិករផ្សេងៗគ្នា ដោយពិគ្រោះជាមួយដៃគូ និងភាគីពាក់ព័ន្ធសំខាន់ៗ ។ អាទិភាពទី១ គឺយុទ្ធសាស្រ្តរបស់រដ្ឋាភិបាលចំពោះកិច្ចអភិវឌ្ឍន៍កសិកម្ម ចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់ ហើយប្រែក្លាយអាទិភាពទូទៅទៅជាផែនការជាក់លាក់ ដែលមាន អាទិភាពសំរាប់បែងចែកធនធាន ។ ដើម្បីធ្វើកិច្ចការនេះ ចូរប្រើការសម្របសម្រួលរបស់ម្ចាស់ជំនួយ[៧៨] និងវេទិកាពិគ្រោះជាមួយវិស័យឯកជន និងភាគីពាក់ព័ន្ធដទៃទៀត ។
- កិច្ចប្រឹងប្រែងបន្ទាន់និងពិសេស គប្បីមានទិសដៅឆ្ពោះទៅកាន់ (i) *ការកំណត់ជាថ្មីរបស់វិស័យសាធារណៈ*ក្នុងផ្នែកកសិកម្ម *និង ជំរុញកិច្ចអភិវឌ្ឍន៍វិស័យឯកជន និង ការចូលរួមរបស់វិស័យនេះក្នុងការផ្តល់សេវាទ្រទ្រង់កសិកម្ម* (ii) *ពិនិត្យសារឡើងវិញនូវមុខងារ និងភារកិច្ចរបស់ស្ថាប័នសាធារណៈសំខាន់ៗនៅថ្នាក់កណ្តាលនិងនៅមូលដ្ឋាន*ដោយចាប់ផ្តើមពី MAFF និងមន្ទីរកសិកម្ម និងការិយាល័យ ថ្នាក់ស្រុក (ការពិនិត្យសារឡើងវិញនូវមុខងារ) និង (iii) *បញ្ចប់នូវដំណើរការឯកជនភាវូបនីយកម្ម* ។
- *រៀបចំធនធាន*ជាជំហានៗស្របជាមួយអាទិភាពកម្មវិធីដែលបានឯកភាព និងលើកកំពស់ការគ្រប់គ្រងសាធារណៈនៅក្នុងវិស័យកសិកម្ម

## អាទីភាពទី ២ សម្របសម្រួលសេវាគាំទ្របច្ចេកទេស និងគាំទ្រទីផ្សារ ដើម្បីអនុញ្ញាតឱ្យមានការធ្វើពិពិធកម្មនៃកសិកម្មដែលផ្តោតទៅរកទីផ្សារ

*ពង្រឹងសេវាគាំទ្រសំខាន់ៗចំពោះវិស័យនេះ*ដោយប្រមូលផ្តុំធនធានសាធារណៈលើទំនិញសាធារណៈ:

[78] ជាជំហ៊ានដំបូង ការបង្កើតជាផ្លូវការនូវក្រុមការងារកសិកម្មរួមគ្នារវាងរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយកំពុងត្រូវបានពិភាក្សា

- អភិវឌ្ឍជាបន្ត នូវ *ការសិក្សាកសិកម្មជាតិ និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មទៅក្នុងប្រព័ន្ធចំរុះមានប្រសិទ្ធភាព ស្របនឹងចំណាយ និងប្រែប្រួលទៅតាមតំរូវការ* ផ្អែកលើមូលដ្ឋានពិនិត្យមើលសារឡើងវិញនូវតំរូវការរបស់ក្រុមកសិករផ្សេងៗគ្នា និងផ្អែកលើតំរូវការនិងការឆ្លើយតប អាចមានអ្នកផ្តល់សេវាសាធារណៈ អ្នកផ្តល់សេវាមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាឯកជន ។ ងាកចេញពីការផ្តល់ការប្រឹក្សាសុទ្ធសាធ លើផ្នែកបច្ចេកទេស ។
- ពង្រឹងសមត្ថភាពរបស់ MAFF ដើម្បីអភិវឌ្ឍ និងអនុវត្ត អំពី*សន្តិសុវត្ថិភាព និងគុណភាពស្បៀងអាហារ*ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងភាគីពាក់ព័ន្ធទៅតាមធនធាន និងសមត្ថភាពរបស់ប្រទេស និងស្របតាមសមត្ថភាពរបស់ផលិតករលក្ខណៈគ្រួសារ និងនៅតាមជនបទ ។
- សិក្សាអំពីឧបសគ្គចំពោះ*កិច្ចអភិវឌ្ឍន៍ស្ថាប័នផលិតករជនបទបច្ចុប្បន្ន* ដើម្បីផ្តល់ដំណឹងអំពីកិច្ចអភិវឌ្ឍន៍ យុទ្ធសាស្រ្តកសិកម្ម និងដើម្បីរួមវិភាគទានក្នុងការកំណត់ និងការអនុវត្តន៍គោលនយោបាយអំពី របៀបវារៈតាមវិស័យពាក់ព័ន្ធ ដែលប៉ះពាល់ដល់សមត្ថភាពរបស់ផលិតករនៅជនបទ ក្នុងការឆ្លើយតប នឹងព័ត៌មានទីផ្សារ (បរិយាកាសវិនិយោគ កិច្ចអភិវឌ្ឍន៍សេវាហេដ្ឋារចនាសម្ព័ន្ធ កិច្ចអភិវឌ្ឍន៍សេវា ហិរញ្ញវត្ថុ ។ល។) ។
- ពង្រឹង*ប្រព័ន្ធឃ្លាំមើលអេពីដេមីសាស្រ្ត* (សំរាប់រុក្ខជាតិ និងសត្វ) *និងប្រព័ន្ធផ្តល់ពត៌មានជាមុន* ដើម្បី តាមដានការប្រែប្រួលបរិយាកាស (ទឹកជំនន់ ការរាំងស្ងួត) ដើម្បីអនុញ្ញាតឱ្យមានការបង្កើននូវការ ត្រៀមលក្ខណៈ និងការបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ។

## អាទិភាពទី ៣ បង្កើតកម្មវិធីសមាហរណកម្មដើម្បីលើកកំពស់លទ្ធផលអនុវត្តនៃអនុវិស័យសំខាន់ៗអំពីសារៈនៃប្រាក់ចំណូលនៅជនបទ

*ដោះស្រាយឧបសគ្គជាក់លាក់ដែលអនុវិស័យកសិកម្មប្រឈមមុខ* និងជំរុញយ៉ាងសកម្មនូវការឆ្លើយតបដែលមានការសម្របសម្រួលដើម្បីកំណត់រកឧបសគ្គរបស់អនុវិស័យ:

- **ដំណាំស្រូវ:**

- o បង្កើតយុទ្ធសាស្រ្ត ច្បាស់លាស់សំរាប់វិស័យដំណាំស្រូវជុំវិញគោលដៅពីរនៃសន្តិសុខស្បៀង ជាពិសេសចំពោះផលិតករជីវព្រឹត្ត និងបង្កើនភាពប្រកួតប្រជែងលើការនាំចេញ ។
- o សហការជាមួយវិស័យឯកជន កសិករ និងស្ថាប័នពាក់ព័ន្ធដទៃទៀតដើម្បីដោះស្រាយឧបសគ្គចំពោះភាពប្រកួតប្រជែងនៃអង្ករកម្ពុជា ។

• **បសុសត្វ:** ផ្តោតលើការបង្កើនប្រាក់ចំណូល និងតំលៃបន្ថែមចំពោះវិស័យបសុសត្វដែលមានលក្ខណៈជាគ្រួសារតាមរយៈ

- o លើកទឹកចិត្តការពង្រីកសេវាពេទ្យសត្វឯកជននៅតាមភូមិឱ្យបានរហ័ស
- o ពង្រឹងប្រព័ន្ធតាមដាន (សូមអានផ្នែកខាងដើម) ។
- o ធ្វើការវិភាគខ្សែសង្វាក់តំលៃ និងសិក្សាអំពីប្រតិបត្តិការផ្តល់ហិរញ្ញប្បទាននៅក្នុងទីផ្សារ ចំពោះផលិតផលសត្វ ដើម្បីកំណត់ជាបន្ទាន់នូវសកម្មភាពគាំទ្រ (គោលនយោបាយ និង វិនិយោគ) ។

• **បង្កើនតំលៃបន្ថែមឱ្យបានជាអតិបរិមាពីការកែច្នៃ និងលក់ត្រី និងវារីវប្បកម្ម**

- o ដាក់បញ្ចូលប្រព័ន្ធចិញ្ចឹមត្រីនៅក្នុងស្រែនៅក្នុងកម្មវិធីគាំទ្រការធ្វើពិពិធកម្មនៃកសិកម្ម
- o សិក្សាជំរើសនានាដើម្បីសម្រួលវិស័យឯកជនក្នុងការទុកដាក់ និងកែច្នៃផលិតផលត្រី
- o ដោះស្រាយឧបសគ្គនានាចំពោះការនាំចេញត្រីទៅកាន់ទីផ្សារដែលមានតំលៃខ្ពស់ និងដោះ-ស្រាយអប្រសិទ្ធភាពក្នុងការសម្របសម្រួលពាណិជ្ជកម្ម ។

• **រៀបចំរចនាសម្ព័ន្ធវិស័យដំណាំកៅស៊ូសារឡើងវិញ**

- o បង្កើនល្បឿន និងបញ្ចប់នូវការរៀបចំរចនាសម្ព័ន្ធ និងឯកជនភាវូបនីយកម្មនៃក្រុមហ៊ុនចំការកៅស៊ូរបស់រដ្ឋ ។
- o បង្កើតកម្មវិធីទទួលស្គាល់គុណភាពកៅស៊ូដែលទទួលស្គាល់ដោយអន្តរជាតិ ។
- o ធ្វើសេរីភាវូបនីយកម្មទីផ្សារកៅស៊ូ
- o អនុញ្ញាតឱ្យមានការបង្កើតនូវមធ្យោបាយកែច្នៃរបស់វិស័យឯកជនដែលមានលក្ខណៈឯករាជ្យពីចំការកៅស៊ូធំៗ ។
- o អនុវត្តកម្មវិធីសំរាប់អភិវឌ្ឍចំការកៅស៊ូលក្ខណៈគ្រួសារ ។

• **បង្កើនការយកចិត្តទុកដាក់លើដំណាំផ្តល់ប្រាក់និងបង្កើនផលិតផលជាមូលដ្ឋាន**

o វិភាគបន្ថែមទៀតអំពីឧបសគ្គចំពោះកសិករ ដើម្បីធ្វើពិពិធកម្មបន្ថែមទៀតទៅកាន់ផលិតផលដែលតំលៃខ្ពស់នៅតំបន់ខុសៗគ្នា (ឧទាហរណ៍ផលិតករដំណាំផ្តល់អាហារនៅតំបន់វាលរាប ផលិតករឈើស៊ីផ្លែក្នុងតំបន់ពាយ័ព្យ ផលិតករដាំបន្លែនៅតំបន់ទ្រនាប់ក្បែរទីក្រុង) ។

## *ផ្សារភ្ជាប់តំលាតលើលទ្ធភាពទទួលបានសេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធ*

### អភិវឌ្ឍន៍សេវាហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទ

១៣៨. *ហេដ្ឋារចនាសម្ព័ន្ធមិនផ្តល់សេវាគ្រប់គ្រាន់នៅតំបន់ជនបទឡើយ* ។ ហេដ្ឋារចនាសម្ព័ន្ធជនបទរងការខូចខាតយ៉ាងធ្ងន់ធ្ងរ/មិនទទួលបាននូវការយកចិត្តទុកដាក់នៅក្នុងអំឡុងពេលមានសង្គ្រាម ហើយទោះបីជាមានការកែលំអកាលពីប៉ុន្មានឆ្នាំកន្លងទៅនេះក្តី នៅមានផ្លូវដ៏វែងឆ្ងាយបន្តទៅទៀតដែលត្រូវលើកកំពស់សេវាហេដ្ឋារចនាសម្ព័ន្ធឱ្យដល់កំរិតដែលអាចធៀបជាមួយប្រទេសជិតខាង និងជួយលើកកំពស់ឱ្យពលរដ្ឋនៅជនបទមានលទ្ធភាពបានទទួលសេវាសំខាន់ៗ (សូមអានផ្នែកទី១) ។ អង្កេតនានាអំពីគ្រួសារនៅជនបទបង្ហាញថាការលើកកំពស់លទ្ធភាពបានទទួលហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវថ្នល់ និងការផ្គត់ផ្គង់ទឹក[79] ជាអាទិភាពខ្ពស់ក្នុងការចំណោមអាទិភាពនានា ។ ក្នុងចំណោមសេវាហេដ្ឋារចនាសម្ព័ន្ធប្រតិបត្តិការនៃសហគ្រាសតូចៗនៅតំបន់ជនបទបង្ហាញឱ្យឃើញការលើកកំពស់លទ្ធភាពក្នុងការដឹកជញ្ជូន ទំនាក់ទំនង និងសេវាថាមពលគឺជាអាទិភាព ។ ការងារជាច្រើនក្នុងការដោះស្រាយឧបសគ្គជាក់លាក់នៅក្នុងអនុវិស័យនីមួយៗទាំងនេះកំពុងដំណើរការ ជាពិសេសជាផ្នែកនៃការរៀបចំ ឬការអនុវត្តន៍នៃគំរោងដែលផ្តល់ហិរញ្ញ-ប្បទានពីអ្នកផ្តល់ជំនួយ ។

១៣៩. *គេកំពុងរៀបចំឱ្យមានវឌ្ឍនភាពលើក្របខ័ណ្ឌគោលនយោបាយផ្លូវថ្នល់ជនបទ និងការទទួលខុសត្រូវរបស់ស្ថាប័ន* ។ NPRS កំណត់អត្តសញ្ញាណថាប្រព័ន្ធផ្លូវថ្នល់មិនគ្រប់គ្រាន់ជាឧបសគ្គចំបងចំពោះការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ។ ជាពិសេសកង្វះលទ្ធភាពក្នុងការប្រើប្រាស់ផ្លូវថ្នល់នៅគ្រប់រដូវ និងកង្វះហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងកង្វះសេវាដទៃទៀតនៅតំបន់ជនបទត្រូវបានចាត់ទុកថាជាឧបសគ្គក្នុងការលើកកំពស់គុណភាពជីវិតរស់នៅ និងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ។ SEDP II បញ្ជាក់បន្ថែមអំពី

---

[79] ការផ្តល់សេវាផ្គត់ផ្គង់ទឹក និងអនាម័យមានពិភាក្សានៅក្នុងផ្នែកនិយាយអំពីការគ្រប់គ្រងទឹក ។

ភស ុតាងនៃកង្វះការរៀបចំជាយុទ្ធសាស្រ ្តនៃវិស័យនេះ ក្នុងការរួមវិភាគទានឱ្យមានប្រសិទ្ធភាពចំពោះយុទ្ធសាស្រ ្តកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ។ ការយកចិត ្តទុកដាក់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនៃការកសាងសារឡើងវិញផ ្តោតជាសំខាន់លើបណ ្តាញ និងផ្លូវថ្នល់សំខាន់ៗមួយចំនួននៅតាមទីក្រុង ។ ទន្ទឹមនឹងនេះក៏មានការយកចិត ្តទុកដាក់ផងដែរចំពោះហេដ្ឋារចនាសម្ព័ន្ធនៅសហគមន៍តាមរយៈកម្មវិធីសិលា និងកម្ម វិធីដទៃទៀត ។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅគេមិនសូវបានយកចិត ្តទុកដាក់ចំពោះបណ ្តាញផ្លូវលំ និងផ្លូវភូមិដែលសារៈសំខាន់ក្នុងការបំពេញនូវកង្វះខាតនានានៅក្នុងបណ ្តាញនេះ ។

១៤០. *ការទទួលខុសត្រូវផ្នែកស្ថាប័នចំពោះបណ ្តាញដឹកជញ្ជូនជនបទត្រូវបានទទួលខុសត្រូវដោយក្រសួង* សាធារណៈការ និងដឹកជញ្ជូនដែលទទួលខុសត្រូវចំពោះការគ្រប់គ្រង និងការអភិវឌ្ឍន៍ទូទៅនៃវិស័យផ្លូវថ្នល់ និងដឹកជញ្ជូន រាប់ទាំងផ្លូវថ្នល់សំខាន់ៗ និងផ្លូវថ្នល់បន្ទាប់បន្សំ ហើយក្រសួងអភិវឌ្ឍន៍ជនបទទទួលខុសត្រូវ ចំពោះផ្លូវលំ និងផ្លូវដទៃទៀត ។ គេកំពុងរៀបចំសេចក ្តីព្រាងច្បាប់ស ្តីអំពីផ្លូវថ្នល់ដែលបញ្ជាក់អំពីភារកិច្ច របស់ MPWT និង MRD ។ បច្ចុប្បន្ននេះ MRD ទទួលខុសត្រូវចំពោះផ្លូវថ្នល់ដែលមានយានយន ្តធ្វើដំណើរតិចជាង ៥០ ក្នុងមួយថ្ងៃ (និយមន័យនេះមានលក្ខណៈមិនច្បាស់លាស់ទេពីព្រោះថាគ្មានមធ្យោបាយដែលមានលក្ខណៈជាប្រព័ន្ធនៅក្នុងការចាត់ចែងផ្លូវថ្នល់នៅពេលដែលមានយានយន ្តឆ្លងកាត់ចំនួន ៥១ ក្នុងមួយថ្ងៃ) ។ ច្បាប់ស ្តីពីផ្លូវថ្នល់នឹងជួយកំណត់ថាតើផ្លូវណាស្ថិតនៅក្រោមសមត្ថកិច្ចរបស់ស្ថាប័នដែលមានមូលដ្ឋានផ្អែកលើមុខងារជាជាងផ្អែកលើចំនួនយានយន ្តធ្វើដំណើរឆ្លងកាត់ ។

១៤១. *វិស័យដឹកជញ្ជូនខ្វះគោលនយោបាយផ្លូវថ្នល់និងគោលនយោបាយវិស័យដឹកជញ្ជូនដែលមានលក្ខណៈស្ថិតរមួតក្នុងការជំរុញអនុវត ្តគោលដៅរបស់វិស័យ និងក្នុងទំរង់សំរេចបាននូវគោលដៅទាំងនេះ ។ប៉ុន្តែ ្ត* MRD បានអនុម័តគោលនយោបាយមួយចំពោះផ្លូវជនបទនៅឆ្នាំ ២០០២ ដែលមានគោលដៅបង្កើនលទ្ធភាពទៅកាន់ជនបទតាមរយៈការផ ្តល់អាទិភាពក្នុងការថែទាំដោយមានប្រសិទ្ធភាព

និងការធ្វើនីតិសម្បទាចំពោះ ផ្លូវថ្នល់ជនបទ និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាសមស្របផ្អែកលើពលកម្ម (LBAT) ដោយមានការ ចូលរួមពីវិស័យឯកជននៅមូលដ្ឋាន (អ្នកម៉ៅការខ្នាតតូច និងខ្នាតមធ្យម) ក្នុងការអនុវត្តន៍ការងារនេះ ។ គោលនយោបាយនេះក៏ផ ្តល់សេចក្តីណែនាំផងដែរចំពោះការបែងចែកភារៈកិច្ចចំពោះផ្លូវជនបទ ពីក្រសួងនៅ ថ្នាក់កណ ្តាល (MRD) និងមន្ទីរខេត ្តរហូតដល់មន្ទីរឃុំ ។ ទោះបីជាគេអាចលើកកំពស់បានក ្តី នៅក្នុង ទិដ្ឋភាពជាច្រើន នេះជាគោលនយោបាយសមស្រប ហើយផ ្តល់នូវក្របខ័ណ្ឌមួយសំរាប់គ្រប់គ្រងផ្លូវជនបទ ។ អាស្រ័យហេតុនេះការយកចិត ្តទុកដាក់លើកិច្ចការបន្ថែមទៀតគប្បីពិចារណារកវិធីអនុវត ្តឱ្យបានប្រសើរ ចំពោះគោលនយោបាយនេះ (ដើម្បីជំនះវឌុបសគ្គផ្អែកការយល់ដឹង បច្ចេកទេស និងហិរញ្ញវត្ថុ) ។

១៤២. *កិច្ចអភិវឌ្ឍន៍ផ្លូវថ្នល់និងសេវាដឹកជញ្ជូនជួបឧបសគ្គដោយខ្វះការកសាងផែនការ និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ព្រមទាំងខ្វះដំណើរការរៀបចំថវិកា ដើម្បីធានាឱ្យមានមូលនិធិគ្រប់គ្រាន់សំរាប់កសាងនិងសំរាប់ថែទាំ។* មូលនិធិសំរាប់ជួសជុលនិងថែទាំផ្លូវថ្នល់ (FRMR) *ផ្តល់មូលនិធិតាមបែបមួយមិនទៀងទាត់* ជាពិសេសសំរាប់ការធ្វើនិតិសម្បទាផ្លូវថ្នល់ គ្មានលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគំរូ ឬក្នុងការជ្រើសរើសយុទ្ធសាស្ត្រសមស្របសំរាប់បែងចែកធនធាន ។ ទោះបីជាមានភាពច្បាស់លាស់ក្តី ឧបសគ្គផ្ទាល់ក្នុងការផ្តល់មូលនិធិរបស់ FRMR ពិបាកផ្តល់មូលនិធិគ្រប់គ្រាន់សំរាប់ការជួសជុល ជាពិសេសគឺនៅបណ្តាញថ្នាក់ក្រោម។ ចាប់តាំងពីឆ្នាំ ២០០២ មក ការទទួលខុសត្រូវលើហេដ្ឋារចនាសម្ព័ន្ធរបស់ថ្នាក់ឃុំត្រូវបានធ្វើវិមជ្ឈការឱ្យក្រុមប្រឹក្សាឃុំសង្កាត់ដែលជាប់ឆ្នោតថ្មី ដោយផ្តល់ហិរញ្ញប្បទានចំពោះការកសាង និងនិតិសម្បទាផ្លូវថ្នល់នៅតាមឃុំសង្កាត់ ដែលមានជំនួយបច្ចេកទេសមកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។ យន្តការផ្ទេរសារពើពន្ធរវាងអាជ្ញាធរអន្តរដ្ឋាភិបាលនិងមូលនិធិឃុំសង្កាត់ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ហិរញ្ញប្បទានសំខាន់ចំពោះកិច្ចការនេះ និងចំពោះភារកិច្ចដទៃទៀតរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ប៉ុន្តែមូលនិធិមានចំនួនបន្តិចបន្តួច។ តាមរយៈសិក្ខាសាលាស្តីពីសមាហរណកម្មស្រុកបានឱ្យដឹងថា ការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ និងNGOដទៃទៀត ផ្តល់ទៅកាន់គំរោងនិងកម្មវិធីផ្សេងគ្នាជាច្រើន ផ្តោតលើថ្នាក់ភូមិ ឬថ្នាក់ឃុំ ហើយមូលនិធិនេះមិនត្រូវបានគេសម្របសម្រួលបានល្អជាមួយនឹងកិច្ចប្រឹងប្រែងនៅថ្នាក់ឃុំ និងសង្កាត់ឡើយ។ ការផ្តល់ហិរញ្ញប្បទានចំពោះបណ្តាញនៅមូលដ្ឋាន នៅតែជាបញ្ហានៅឡើយ ព្រោះគេមានមន្ទិលថា កិច្ចប្រឹងប្រែងទាំងនេះ មិនអាចបង្កើតបានជាមូលដ្ឋានសំរាប់ ពង្រីកដល់ថ្នាក់ជាតិឡើយ។

១៤៣. *សេវាថាមពល និងទូរគមនាគមន៍ មានជាមូលដ្ឋាននៅតំបន់ទីក្រុង និងតំបន់ទីក្រុងធំៗតែប៉ុណ្ណោះ។* ប្រទេសកម្ពុជាមានអនុបាតអគ្គិសនីភាវូបនីយកម្មទាបជាងគេបំផុត ក្នុងចំណោមបណ្តាប្រទេសនៅអាស៊ីខាងកើត គឺមានកំរិតត្រឹមតែ ៥%ប៉ុណ្ណោះនៅតំបន់ជនបទ ។ រីឯទូរគមនាគមន៍វិញ បណ្តាញទូរស័ព្ទអចល័តសំរាប់ប្រទេសកម្ពុជាទាំងមូលមានកំរិតតែ ០,២៧ ប៉ុណ្ណោះក្នុងចំណោម ១០០គ្រួសារ។ រីឯទូរស័ព្ទវិញ នៅឆ្នាំ ២០០០ មានកំរិត ១,២៧ ក្នុងចំណោម ១០០ គ្រួសារ។ ទូរស័ព្ទអចល័តលើតុ កាន់តែមានចំនួនតិច នៅតំបន់ជនបទ ដែលការពង្រីកបណ្តាញនេះទាមទារឱ្យមានការវិនិយោគជាច្រើន ក្នុងខណៈដែលសេវាទូរស័ព្ទចល័តបានពង្រីកជាច្រើន ដោយអាត្រាខ្ពស់ទៅកាន់តំបន់មួយចំនួន។ នៅក្នុងវិស័យអគ្គិសនី ក្របខ័ណ្ឌស្ថាប័នមានលក្ខណៈខ្សោយ ហើយការផ្គត់ផ្គង់ថាមពលមិនអាចជឿទុកចិត្តបាន មានតំលៃខ្ពស់ ហើយភាគច្រើនសំរាប់ផ្គត់ផ្គង់នៅតំបន់ទីក្រុងតែប៉ុណ្ណោះ ។ អ្នកភូមិបំពេញតំរូវការផ្នែកថាមពលរបស់ខ្លួនដោយលក្ខណៈសាមញ្ញ ប៉ុន្តែត្រូវចំណាយខ្ពស់ ដូចជាការប្រើប្រាស់អាគុយជាដើម ។ ការពង្រឹងស្ថាប័នជួបឧបសគ្គដោយ : (ក) កង្វះបុគ្គលិកជំនាញធ្ងន់ធ្ងរ (ខ) វិធីសាស្ត្រចាក់ឬសផ្តោតលើវិស័យសាធារណៈក្នុងការគ្រប់គ្រងប្រព័ន្ធថាមពលសាធារណៈ (គ) អន្តរាគមន៍ផ្នែកនយោបាយ (ឃ) កង្វះតម្លាភាពក្នុងការផ្តល់ហិរញ្ញប្បទានមានរចនាសម្ព័ន្ធពន្ធគយអប្រសិទ្ធភាព ថ្លៃមានកំរិតខ្ពស់បំផុតនៅក្នុងពិភពលោក ។ ការពង្រីកនៅបណ្តាញទូរគមនាគមន៍អចល័តទៅកាន់តំបន់ជនបទ តំរូវឱ្យមានការវិនិយោគច្រើន។ ចំពោះសេវាទូរស័ព្ទចល័តឯកជនមានកត្តាលើកទឹកចិត្តមានតិចតួចសំរាប់ធ្វើឱ្យមានវិនិយោគពង្រីកផ្ទៃសេវាទូរស័ព្ទ ដែលមានគុណភាព ។

១៤៤. *ត្រូវមានវិធីសាស្ត្រដែលមានលក្ខណៈយុទ្ធសាស្ត្របន្ថែមទៀត ចំពោះកិច្ចអភិវឌ្ឍន៍សេវា ហេដ្ឋារចនា-សម្ព័ន្ធជនបទ។* ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះមានកិច្ចប្រឹងប្រែងជាច្រើន នៅក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធជនបទ រួមមានគំរោងជាច្រើនដែលបានផ្តល់មូលនិធិពីម្ចាស់ជំនួយ ដើម្បីកែលំអរចនាសម្ព័ន្ធនៅជនបទ និងភាពជិតស្និទ្ធរវាងការកសាងផែនការនិងការគ្រប់គ្រង។ ទន្ទឹមជាមួយគ្នានេះ គោលនយោបាយនិងយុទ្ធសាស្ត្រនានាត្រូវបានបង្កើតឡើងដោយស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធមួយចំនួន។ ចាំបាច់ត្រូវមានការតាមដានបន្ថែមទៀត ដើម្បីផ្តល់ដំណឹងអំពីសក្តានុពលនៃការកែប្រែគោលនយោបាយ យុទ្ធសាស្ត្រកម្មវិធីគំរោង ជាពិសេសធ្វើគំរោងទាក់ទងនឹងការធ្វើវិមជ្ឈការទៅកាន់ក្រុមប្រឹក្សាឃុំសង្កាត់ និងវិសហ-មជ្ឈការនៃភារៈកិច្ចពីក្រសួងស្ថាប័នថ្នាក់កណ្តាល ទៅមន្ទីរនិងការិយាល័យស្រុក។ មានសារៈសំខាន់ដូចគ្នាដែរ គឺលំហូរនៃមូលនិធិ ដែលមានស៊ីគ្នាដែរជាមួយនិងភារកិច្ចទាំងអស់នេះ។

## អនុសាសន៍ស្តីពីសកម្មភាពជាអាទិភាពសំរាប់កែលំអសេវាហេដ្ឋារចនាសម្ព័ន្ធជនបទ

### អាទិភាពទី ១ ពង្រឹងការកំណត់ទិសដៅ យុទ្ធសាស្ត្រវិនិយោគហេដ្ឋារចនាសម្ព័ន្ធ

*បង្កើតយុទ្ធសាស្ត្រសំរាប់កិច្ចអភិវឌ្ឍន៍សេវាហេដ្ឋារចនាសម្ព័ន្ធជនបទជាមួយការគាំទ្រពីដៃគូដទៃទៀត* ។ ប្រការនេះតំរូវឱ្យមានការពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រនិងគោលនយោបាយក្នុងពេលបច្ចុប្បន្ន និងការរៀបចំផ្នែកស្ថាប័នសំរាប់គ្រប់គ្រងនិងផ្តល់ហិរញ្ញប្បទានចំពោះហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសស្វែងរកចំណងទាក់ទងរវាងហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចអភិវឌ្ឍន៍ជនបទទូទៅ ។ ផ្អែកលើពតិមាននេះ ការវាយតំលៃអំពីភាពគ្រប់គ្រាន់នៃក្របខ័ណ្ឌការងារបច្ចុប្បន្នចំពោះកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន ចាំបាច់ត្រូវមានការកំណត់អត្តសញ្ញាណអំពីកង្វះខាតនិងផលប៉ះពាល់ផ្សេងៗចំពោះការបែងចែកធនធាន និងការគ្រប់គ្រង។ ការវាយតំលៃបែបនេះនឹងពិចារណាអំពីលក្ខណៈនៃប្រភេទខុសគ្នាៗ នៃហេដ្ឋារចនាសម្ព័ន្ធ និងមុខងាររបស់វិស័យសាធារណៈនិងឯកជន នៅក្នុងអនុវិស័យផ្សេងៗ ។ ជាពិសេសយុទ្ធសាស្ត្ររួមមាន :

- *ពង្រឹងភាពស៊ីសង្វាក់គ្នានៃការកសាងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាមួយនឹងការកសាងផែនការអភិវឌ្ឍន៍ក្នុងតំបន់*
- *ពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន ក្នុងការកំណត់អាទិភាពលើផែនការនិងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងផ្តល់សេវា*
- *បង្កើតការរួមវិភាគទានរបស់ វិស័យឯកជនក្នុងការផ្តល់សេវា* (តាមរយៈលទ្ធភាពបានទទួលឥណទាន ការធានារ៉ាប់រង ភាពងាយស្រួលក្នុងការទទួលលិខិតអនុញ្ញាត)
- *លើកកំពស់ការស្តារចំណាយនៅក្នុងហេដ្ឋារចនាសម្ព័ន្ធជនបទនិងនៅក្នុងសេវានានា ដើម្បីឱ្យមាននិរន្តរភាព ។*

### អាទិភាពទី ២ កិច្ចអភិវឌ្ឍន៍ឱ្យមាននិរន្តរភាព និងមានលក្ខណៈជាយុទ្ធសាស្ត្រនៃបណ្តាញផ្លូវថ្នល់ ដើម្បីសំរួលការធ្វើសមាហរណកម្មតំបន់ជនបទជាមួយនឹងសេដ្ឋកិច្ចក្នុងតំបន់

- *លៃយ៉ាងណាឱ្យគោលនយោបាយដឹកជញ្ជូនគាំទ្រ គោលនយោបាយកាត់បន្ថយ ភាពក្រីក្រ តាមរយៈ*
    - o ការបង្កើត ការអនុម័ត និងការអនុវត្តន៍គោលនយោបាយភាពនៃការដឹកជញ្ជូនដែលដោះស្រាយតំរូវការធ្វើដំណើរនៅជនបទ

- o រៀបចំគោលនយោបាយជាតិ និងយុទ្ធសាស្ត្រ ផ្លូវថ្នល់នៅជនបទ ។

- *លើកកំពស់លទ្ធភាពនៅជនបទ តាមរយៈការថែទាំ សម្បត្តិផ្លូវថ្នល់បច្ចុប្បន្ន និងបង្កើនចរាចរណ៍នៅជនបទ :*
  - o រៀបចំសារពើពន្ធ នៅជនបទ និងកសាងផែនទី
  - o លៃយ៉ាងណាឱ្យមានទំនាក់ទំនងគ្រប់គ្រាន់ (ផ្លូវបន្ទាប់បន្សំនិងផ្លូវភូមិ) រវាងបណ្តាញផ្លូវថ្នល់ សំខាន់ៗ និងផ្លូវថ្នល់នៅមូលដ្ឋាន
  - o ធ្វើឱ្យមាននិរន្តរភាពនិងលើកកំពស់ប្រាក់ចំណូលជនបទ តាមរយៈការថែទាំផ្លូវជនបទដោយប្រើប្រាស់បច្ចេកវិទ្យាសមស្របផ្អែកលើពលកម្ម (LBAT)
  - o ពិនិត្យមើលសារឡើងវិញ នៅវត្តមានលទ្ធភាពរាប់រង និងសុវត្ថិភាព នៃសេវាដឹកជញ្ជូនជនបទ កំណត់រកកង្វះខាត និងអនុវត្តអនុសាសន៍នានាដើម្បីលុបបំបាត់កង្វះខាតទាំងនោះ
  - o ដាក់បញ្ចូលវិស័យឯកជន ក្នុងការផ្តល់សេវាផ្លូវថ្នល់និង សេវាដឹកជញ្ជូន ។

- *ផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សំរាប់ការថែទាំផ្លូវថ្នល់ និងការកែលំអផ្លូវនៅមូលដ្ឋាន :*
  - o មូលនិធិកំណែទំរង់ សំរាប់ជួសជុលនិងថែទាំ ផ្លូវថ្នល់ លៃយ៉ាងណាឱ្យមានការផ្តល់មូលនិធិបានគ្រប់គ្រាន់ អាចប៉ាន់ប្រមាណជាមុនបានសំរាប់ថែទាំផ្លូវថ្នល់ជនបទ
  - o បង្កើតមូលដ្ឋានធនធាន អាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្ទេរសារពើពន្ធ ។

**អាទិភាពទី ៣ ការផ្គត់ផ្គង់ថាមពលអគ្គីសនី នៅជនបទនិង ការបង្កើនវិសាលភាពផ្គត់ផ្គង់អគ្គិសនី**

បង្កើនការផ្គត់ផ្គង់ថាមពលអគ្គីសនី និងវិសាលភាពផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ :

- *កសាងផែនការមេក្នុងការធ្វើអគ្គីសនីភាវូបនីយកម្មនៅតំបន់ជនបទ* ដើម្បីណែនាំវិនិយោគវិមជ្ឈការអំពីការធ្វើអគ្គីសនីភាវូបនីយកម្មនៅជនបទ កំណត់តំបន់ដែលត្រូវផ្តល់បណ្តាញអគ្គីសនី និងតំបន់ស្ថិតនៅក្រៅពីកន្លែងផ្តល់សេវាអគ្គីសនី
- លើកកំពស់លទ្ធភាពក្នុងការបានទទួលហិរញ្ញប្បទាន ជាពិសេសសំរាប់អ្នកផ្គត់ផ្គង់នៅជនបទ
- បង្កើតទស្សនាទានស្តីពី តម្លាភាពនិងការបំពេញខាតផ្អែកលើលទ្ធផលអនុវត្តន៍ ។

## ការពង្រីកសេវាហិរញ្ញវត្ថុនៅតំបន់ជនបទ [80]

១៤៥. *លើកលែងតែ ACLEDA ដែលមានអតីតភាពជា MFI*[81] *ថ្មីៗនេះបាន ក្លាយទៅជាធនាគារមួយ ហើយវិស័យធនាគារផ្លូវការមិនបំរើប្រជាពលរដ្ឋនៅជនបទឡើយ ។* ក្នុងចំណោមខេត្តទាំង២៤ មាន១៦ខេត្ត គ្មានធនាគារពាណិជ្ជកម្ម លើកលែងតែសាខា របស់ ACLEDA ហើយ៩ខេត្ត គ្មានសេវាធនាគារផ្លូវការ ណាមួយឡើយ។ នៅខណៈដែលមានសេវានៅបណ្ដាខេត្តជុំវិញទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងជុំវិញ តំបន់ទន្លេសាប ខេត្តដទៃទៀតនៅភាគខាងជើង និងភាគឦសាននៃប្រទេសកម្ពុជា និងនៅកោះកុងមិនទាន់ មានការផ្ដល់សេវានៅឡើយ ។ នៅពេលមានសាខានានា សាខាទាំងនោះជាទូទៅ ស្ថិតនៅទីរួមខេត្ត ហើយសឹងតែគ្មានសាខានៅមូលដ្ឋានទាល់តែសោះ ។ លទ្ធភាពរបស់គ្រួសារនៅជនបទក្នុងការទទួលសេវា ហិរញ្ញវត្ថុផ្លូវការនៅមានបរិមាណតិចតួចបំផុត (សូមអានភាគទី ១) ។

១៤៦. ធនាគារអភិវឌ្ឍន៍ជនបទ (RDB) ត្រូវបានបង្កើតឡើងដោយ រដ្ឋាភិបាល (ដោយមានជំនួយ បរទេស) នៅឆ្នាំ ១៩៩៨ និងបានក្លាយទៅជាធនាគារបោះដុំក្នុងការបញ្ជូនមូលនិធិ ពីសហគមន៍អន្តរជាតិ ទៅ កាន់មីក្រូហិរញ្ញវត្ថុកម្ពុជា (MFIs) នៅឆ្នាំ២០០០ ។ នៅឆ្នាំ២០០២ RDB បានផ្ដល់ឥណទានចំនួនត្រឹមតែ ២,៥លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងចំណោមមូលនិធិរបស់ខ្លួនចំនួនជាង ២០ លានដុល្លារ ដែលបង្ហាញ ឱ្យឃើញសមត្ថភាពទន់ខ្សោយរបស់ RDB និង MFI។ យោងតាមរបាយការណ៍សវនកម្ម លើលទ្ធផល អនុវត្តន៍របស់ ADB ស្ដីពីកម្មវិធីវិស័យកសិកម្ម បញ្ជាក់ថាការផ្ដល់ឥណទានយឺតយ៉ាវនេះ ធ្វើឱ្យ ADB លុបចោលទឹកប្រាក់ចំនួន ១៤,៨លានដុល្លារ នៃចំណូលប្រាក់កម្ចីចំនួន ២០,៧ លានដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ២០០២។ មុខងាររបស់ RDB នៅក្នុងយុទ្ធសាស្ត្រមួយសំរាប់លើកទឹកចិត្តកិច្ចអភិវឌ្ឍន៍សេវាហិរញ្ញវត្ថុ ជនបទ ដែលត្រូវធ្វើការពិចារណាសារជាថ្មីឡើងវិញអំពីបទពិសោធន៍របស់ម្ចាស់ជំនួយនិង MFI ជាមួយ RDB កាលពីពេលថ្មីៗ។

១៤៧. *វិស័យហិរញ្ញវត្ថុក្រៅផ្លូវការ និងពាក់កណ្ដាលក្រៅផ្លូវការបំពេញមុខងារយ៉ាងសំខាន់ក្នុងឋានៈជា អ្នកផ្ដល់សេវាឥណទាននៅតំបន់ជនបទ ។* អ្នកផ្ដល់សេវានេះឈានមុខនៅក្នុងទីផ្សារគឺ ACLEDA

---

[80] ផ្នែកនេះដកស្រង់ចេញពីការងារ ដែលដឹកនាំដោយ Olga Torres *វិស័យមេក្រូហិរញ្ញវត្ថុ និងហិរញ្ញវត្ថុជនបទនៅកម្ពុជា ខែមករាឆ្នាំ ២០០៤ ។*

[81] គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) គឺជាគ្រឹះស្ថានដែលផ្ដោតទៅលើសេវាហិរញ្ញវត្ថុ អង្គការមីក្រូហិរញ្ញវត្ថុ (MFO) ផ្ដល់នូវ សេវាទូទៅ ។

ដែល គ្របដណ្តប់លើទីផ្សារចំនួន ៥៨% គិតលើឥណទានដែលបានផ្តល់ ។ ACLEDA បានចាប់ដំណើរការប្រតិបត្តិការរបស់ខ្លួនក្នុងឋានៈជាអង្គការក្រៅរដ្ឋាភិបាល បានក្លាយជាធនាគារឯកទេស ហើយថ្មីៗនេះជា ធនាគារពាណិជ្ជដែលផ្តល់សេវាហិរញ្ញវត្ថុនៅតំបន់ជនបទ ជាទូទៅគឺបំរើសហគ្រិន ។ MFO ធំៗចំនួន ១០[82] ដែលផ្តល់ឥណទានសរុបចំនួន ៩០% និងផ្តល់សេវាបំរើដល់អ្នកខ្ចីប្រាក់ ៩៤% បានជ្រើសរើស ឱ្យមាន ការផ្តល់អាជ្ញាប័ណ្ណ និងកំពុងប្រតិបត្តិការដើម្បីឱ្យមាននិរន្តរភាព ។ ប្រការនេះក៏មានន័យផងដែរថា ជាទូទៅគេអាចសង្កេតឃើញមានការងាកទៅរកការផ្តល់ឥណទានធំៗនៅពេលដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានឈានទៅដល់ការបំពេញតំរូវការរបស់ទីផ្សារថ្នាក់លើ ដោយផ្តោតលើការផ្តល់ឥណទានបុគ្គល (ជាជាង ផ្តល់ឥណទានក្នុងលក្ខណៈជាក្រុម) ហើយបង្កើននូវប្រតិបត្តិការនៅក្នុងគ្រឹះស្ថានរបស់ខ្លួន (ជាជាងនៅតាមភូមិ) ដើម្បីកាត់បន្ថយចំណាយ ។ អាស្រ័យហេតុនេះមានលទ្ធភាពដែលថាកិច្ចអភិវឌ្ឍន៍ក្នុងពេលថ្មីៗ លើការផ្តល់សេវាមីក្រូហិរញ្ញវត្ថុពុំបានផ្តល់អត្ថប្រយោជន៍ចំបងដល់គ្រួសារនៅជនបទឡើយ ហើយជាពិសេស គឺគ្រួសារក្រីក្រ ។

១៤៨. *វិស័យមីក្រូហិរញ្ញវត្ថុទទួលអត្ថប្រយោជន៍ពីក្របខ័ណ្ឌគ្រប់គ្រងដែលមានលក្ខណៈអំណោយផល ប៉ុន្តែការពិនិត្យមើលឡើងវិញកាលពីពេលថ្មីៗនេះ បានរកឃើញសកម្មភាពបីផ្នែកក្នុងការគាំទ្រកិច្ចអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុនៅជនបទ ។* បទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាប័ណ្ណដែលគ្រប់គ្រងដោយច្បាប់ស្តីពីគ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុត្រូវបានអ្នកផ្តល់មីក្រូហិរញ្ញវត្ថុចំបងៗចាត់ទុកថា ជាជំហានវិជ្ជមានក្នុងការធានា នូវការការពារប្រាក់បញ្ញើ និងបង្កលក្ខណៈឱ្យមានការរីកចំរើន ។ ធនាគារជាតិនៃកម្ពុជាជាតិនៃកម្ពុជា (NBC) ធ្វើការត្រួតពិនិត្យ ហើយសមត្ថភាពរបស់ធនាគារនេះកំពុងត្រូវបានពង្រឹង ។ ការពង្រីក ការផ្តល់សេវាហិរញ្ញវត្ថុនៅតំបន់ជនបទ ចាំបាច់ត្រូវដោះស្រាយនូវបញ្ហាកង្វល់ចំបងពីរៈ (i) ការបង្កើន ជំនឿទុកចិត្តនៃគ្រួសារនានាចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ និង (ii) ការកាត់បន្ថយចំណាយនៃការបំរើ ប្រជាពលរដ្ឋ ។ សកម្មភាពសំរាប់ដោះស្រាយការព្រួយបារម្ភទាំងនេះរួមមានៈ

---

[82] ធនាគារ ACLEDA EMT PCA TPC CEB សិលាមិថិ ហត្ថាកសិករ AMK ឥណទាន VisionFund Cambodia

(i) ការផ្លាស់ប ្តូរគំរូរពីវិស័យដឹកនាំដោយឥណទានទៅកាន់ការផ ្តល់សេវាមីក្រូហិរញ្ញវត្ថុពេញលេញ ។ MFI/MFO ភាគច្រើននៅកម្ពុជាផ ្តោតការយកចិត្តទុកដាក់លើការផ្តល់ឥណទាននៅឡើយ ។ សេវាហិរញ្ញវត្ថុដទៃទៀតជាពិសេសសញ្ជ័យ មានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រជាពលរដ្ឋក្រីក្រនៅជនបទ ក្នុងការជួយពួកគេដោះស្រាយជាមួយភាពងាយរងគ្រោះ ។ កង្វះសេវាសញ្ជ័យឆ្លុះបញ្ចាំងឱ្យឃើញភាពអល់ឯកជាទូទៅ ក្នុងការដាក់ប្រាក់បញ្ញើនៅក្នុងវិស័យហិរញ្ញវត្ថុផ្លូវការ/ពាក់កណ ្តាលផ្លូវការ និងត្រូវចំណាយខ្ពស់ក្នុងការកៀងគរប្រាក់បញ្ញើនៅតំបន់ជនបទ ។ ឥណទានរយៈពេលវែងក៏សឹងតែគ្មានសេវាបែបនេះដែរ ។ កម្មវិធីសាកល្បងស ្តីពីការធានារ៉ាប់រងសុខភាពនៅជនបទត្រូវបាន ដាក់ឱ្យប្រើប្រាស់ដោយអង្គការក្រៅរដ្ឋាភិបាលមួយ (GRET) នៅបណ ្តាខេត្តជុំវិញ ទីក្រុងភ្នំពេញ។

(ii) រក្សាបរិយាកាសអំណោយផលចំពោះប្រតិបត ្តិករមីក្រូហិរញ្ញវត្ថុ សហគ្រិនមីក្រូ និងវិស័យឯកជនតាមរយៈការកាត់បន្ថយចំណាយមិនសមស្របនៃប្រតិបត ្តិការ (ជាពិសេសអំពើពុករលួយ ភាពទន់-ខ្សោយនៃតុលាការ និងកង្វះហេដ្ឋារចនាសម្ព័ន្ធ)

(iii) លើកកំពស់ការយល់ដឹងរួមអំពីវិធីដែលគ្រួសារនៅជនបទធ្វើសេចក ្តីសំរេចចិត ្តអំពីប្រភព និងការប្រើ ប្រាស់ប្រាក់ចំណូល ។ MFI ប្រឈមមុខនឹងឧបសគ្គរចនាសម្ព័ន្ធដូចសហគ្រិនមីក្រូនិងអាជីវកម្ម ខ្នាតតូចនៅតំបន់ជនបទផងដែរគឺ ចំណាយខ្ពស់លើការដឹកជញ្ជូនចំណាយទំនាក់ទំនងខ្ពស់ ហើយជាទូទៅ បរិយាកាសអាជីវកម្មមិនល្អ ។ ជានេះទៅទៀតឧបសគ្គមួយចំនួនដែលមាន ចំពោះវិស័យនេះ បង្កើន ចំណាយប្រតិបត ្តិការដូចជាកង្វះការផ្លាស់ប ្តូរពតិមានស ្តីពីអតិថិជន បន្ទុកផ្នែកពន្ធដារ និងហានិភ័យ រូបិយវត្ថុ និង

(iv) ការបង្កើនតម្លាភាព និងបង្កើនវិជ្ជាជីវៈនៅក្នុងប្រតិបត ្តិការមីក្រូហិរញ្ញវត្ថុជាពិសេសអ្នកផ ្តល់ឥណទាន ខ្នាតតូចដែលគ្មានអាជ្ញាប័ណ្ណ គ្មានការត្រួតពិនិត្យពី NBC ឬគ្មានការតាមដានពីអ្នកផ ្តល់ជំនួយ (ឬពី ស្ថាប័នរដ្ឋាភិបាលកម្ពុជា) ។

**អនុសាសន៍ចំពោះសកម្មភាពជាអាទិភាពក្នុងការគាំទ្រកិច្ចអភិវឌ្ឍន៍ហិរញ្ញវត្ថុជនបទ**

**អាទិភាពទី១ កាត់បន្ថយចំណាយប្រតិបត ្តិការមីក្រូហិរញ្ញវត្ថុដែលធ្វើឱ្យកាត់បន្ថយចំណាយឥណទានចំពោះអ្នកខ្ចី**

- *កាត់បន្ថយចំណាយប្រតិបត ្តិការមីក្រូហិរញ្ញវត្ថុ* តាមរយៈជំរើសដូចខាងក្រោមៈ
    - o បង្កើតការិយាល័យឥណទានសំរាប់ផ្លាស់ប ្តូរពត៌មាន និងតាមដានអតិថិជនអំពីភាពជំពាក់ បំណុល
    - o កាត់បន្ថយហានិភ័យប ្តូរប្រាក់ចំពោះ MFO ព្រោះថាការផ ្តល់មូលនិធិភាគច្រើនចំពោះ MFI ធ្វើជាដុល្លារសហរដ្ឋអាមេរិកដែលបង្កើនហានិភ័យក្នុងការបំរើប្រជាពលរដ្ឋជនបទ ជាមួយនឹងផលិតផលជាប្រាក់រៀល
    - o ជំរុញផែនការរបស់NBC ក្នុងការផ្ទេរប្រាក់រវាងបណ ្តាខេត្តផ្សេង១ជាប្រាក់រៀល និងពង្រីក សេវាផាត់ទាត់មូលប្បទានប័ត្រនៅតាមបណ ្តាខេត្ត
    - o ជំរុញឱ្យមានការបង្កើតសមាគម MFI
    - o កែតំរូវកាតព្វកិច្ចទទួលខុសត្រូវរបស់ភាគទុនិកដែលមានឥទ្ធិពល [៨៣]
    - o បន ្តកិច្ចប្រឹងប្រែងកសាងសមត្ថភាពនៅក្នុងវិស័យនេះរាប់ទាំងការកសាងសមត្ថភាពរបស់ NBC និង MFI /MFO ផងដែរ ។
- *បង្កើនតម្លាភាព និងវិជ្ជាជីវៈនៃអ្នកផ ្តល់ឥណទានខ្នាតតូច* តាមរយៈការបន ្តបង្កើនឱ្យនាយកដ្ឋាន ត្រួតពិនិត្យរបស់ NBC - លើកកំពស់ការយល់ដឹងរបស់ម្ចាស់ជំនួយ និងស្ថាប័នរដ្ឋាភិបាលស ្តីពីបញ្ហា មីក្រូហិរញ្ញវត្ថុ និងបង្កើតយុទ្ធនាការពត៌មានស ្តីពីប្រតិបត ្តិការល្អនៅក្នុងសេវាមីក្រូហិរញ្ញវត្ថុ ។

**អាទិភាពទី២ សម្រួលកិច្ចអភិវឌ្ឍន៍សេវាហិរញ្ញវត្ថុថ្មី១**

---

[83] នៅក្នុងច្បាប់ NBC អាចតំរូវ "ភាគទុនិកដែលមានឥទ្ធពល"-ពោលគឺមានចំណែកទុនច្រើនជាង ២០% នៅក្នុង MFI អោយបង្កើនការរួមវិភាគទានទុនរបស់ខ្លួនដែលធ្វើអោយប៉ះពាល់ដល់វិនិយោគិនសក ្តានុពលពីការសំរេចចិត ្តជាផ្លូវការរបស់ពួកគេ

- *គាំទ្រកិច្ចអភិវឌ្ឍន៍សេវាហិរញ្ញវត្ថុក្នុងទ្រង់ទ្រាយធំ* ។ ដើម្បីជំរុញជំនឿទុកចិត្តរបស់អតិថិជននៅក្នុងវិស័យហិរញ្ញវត្ថុ ពង្រឹងការកៀងគរប្រាក់បញ្ញើ និងលើកទឹកចិត្តសញ្ជ័យក្នុងស្រុក តាមរយៈ ការស្វែងយល់បន្ថែមទៀតអំពីលទ្ធភាពក្នុងការ:
  - o បង្កើតមូលនិធិធានាប្រាក់បញ្ញើ ឬបង្កើតស្ថាប័នធានាការសងប្រាក់បញ្ញើ និងការពារផលប្រយោជន៍របស់អ្នកផ្ញើប្រាក់
  - o ធ្វើឱ្យបន្ទុកពន្ធរបស់ MFI មានលក្ខណៈសាមញ្ញដើម្បីជំរុញការផ្តល់ឥណទានទៅឱ្យ SME និងកិច្ចអភិវឌ្ឍន៍សេវាសញ្ជ័យសំរាប់អ្នកផ្ញើប្រាក់តូចៗ ។

- *លើកកំពស់ការយល់ដឹងទូទៅនៃប្រភពប្រាក់ចំណូលរបស់គ្រួសារជនបទ និងយុទ្ធសាស្រ្តសម្របខ្លួន* ជាពិសេសដើម្បីសម្រួលនូវការពង្រីកសេវាហិរញ្ញវត្ថុនៅជនបទ:
  - o តំរូវការសេវាហិរញ្ញវត្ថុពីសំណាក់ SME សហគ្រាសមីក្រូ កសិដ្ឋាន និងគ្រួសារនៅជនបទ និងការផ្គត់ផ្គង់បច្ចុប្បន្ន ដើម្បីប្រើងប្រែងជំរុញប្រតិបត្តិការធនាគារ និងបង្កើនការស៊ីជំរៅនៃទីផ្សារហិរញ្ញវត្ថុជនបទ
  - o យន្តការសម្របខ្លួន និងលំហូរសាច់ប្រាក់នៃគ្រួសារជនបទក្នុងការរៀបចំសេវាមីក្រូហិរញ្ញវត្ថុសំរាប់ប្រជាពលរដ្ឋនៅជនបទ[៨៤] ។

## ការធានាលទ្ធភាពឱ្យបានទទួលសេវាសង្គមនៅជនបទដែលមានគុណភាព

### *ការអប់រំនៅជនបទ*

១៤៩. *ការអប់រំគឺជាផ្នែកសំខាន់មួយនៃកិច្ចអភិវឌ្ឍន៍ជនបទ* ។ ការធានាឱ្យមានលទ្ធភាពទូទៅចំពោះការអប់រំនៅជនបទប្រកបដោយគុណភាព គប្បីជាផ្នែកមួយនៃយុទ្ធសាស្រ្តរួម សំរាប់កិច្ចអភិវឌ្ឍន៍ជនបទ ។ ការអប់រំមានចំណងទាក់ទងជាមួយកិច្ចអភិវឌ្ឍន៍ជនបទតាមមធ្យោបាយសំខាន់ៗពីរ ។ ទីមួយមានចំណងទាក់ទងដោយផ្ទាល់រវាងកំរិតនៃការអប់រំ និងការអភិវឌ្ឍន៍ជំនាញព្រមទាំងសមត្ថភាពរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទក្នុងការបង្កើនផលិតភាពកសិកម្ម និងការចូលរួមនៅក្នុងឱកាសការងារ ស្រែចំការនៅពេលដែលមានឱកាសទាំងនោះ ។ ការសិក្សានៅទូទាំងពិភពលោកបង្ហាញថាប្រសិន បើគេចាត់ទុកថាកត្តាដទៃ

---

[84] យោងតាមប្រភពខុសៗគ្នា ជាង ៧៥% នៃអតិថិជនមីក្រូឥណទានជាស្រ្តី ។

ទៀតឥតប្រែប្រួល កសិករដែលមានការអប់រំច្រើនមានលទ្ធភាពផលិតទិន្នផលកសិកម្មកាន់តែខ្ពស់ ។ ជាមួយគ្នានេះផងដែរការអប់រំបន្ថែមបង្កើនឡើងយ៉ាងច្រើននូវលទ្ធភាពរបស់បុគ្គលក្នុងការស្វែងរកការងារក្រៅពីស្រែចំការ ។ ទីពីរមានទំនាក់ទំនងទូទៅតាមរយៈកម្មវិធីអក្ខរកម្ម ជាពិសេសកម្មវិធីអក្ខរកម្មដែលផ្តោតទៅរកសហគមន៍ជនបទ ។ ការអប់រំជួយលើកំពស់សុខភាព និងអាហារូបត្ថម្ភនៅសហគមន៍ជនបទ និងដើម្បីធ្វើសមាហរណកម្មតំបន់ជនបទដាច់ស្រយាល និងដែលគ្មានលក្ខណៈអំណោយផលបញ្ចូលមកក្នុងសង្គមជាតិទាំងមូល ។

១៥០. *បញ្ហាជាក់លាក់សព្វីពីលទ្ធភាពបាលទទួលការអប់រំជាមូលដ្ឋានប្រកបដោយគុណភាពនៅតំបន់ជនបទ ត្រូវបានគេទទួលស្គាល់នៅក្នុងយុទ្ធសាស្រ្តវិស័យអប់រំពេញលេញ ។* ចក្ខុវិស័យសំរាប់កិច្ចអភិវឌ្ឍន៏ការអប់រំជាតិត្រូវបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្រ្តនៃវិស័យអប់រំរបស់រដ្ឋាភិបាល ដែលថ្មីៗនេះកំពុងស្ថិតនៅ ក្នុងការកែសម្រួល ។ ដើម្បីគាំទ្រការអនុវត្តន៏យុទ្ធសាស្រ្តនេះ ក្រសួងអប់រំយុវជន និងកីឡា ( MOEYS) បានអនុម័តនូវកម្មវិធីគាំទ្រវិស័យអប់រំរំកិល (ESSP) ដែលផ្តល់ហិរញ្ញប្បទានក្នុងកិច្ចសហការជាមួយម្ចាស់ ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ។ ESSP បានអនុម័តនូវរបៀបវារៈដែលមានមហិច្ឆិតាខ្ពស់ ផ្តោះទៅរកប្រជាពលរដ្ឋក្រីក្រសំដៅ (i) បង្កើនលទ្ធភាពក្នុងការទទួលបានការអប់រំជាមូលដ្ឋាន (ថ្នាក់ទី១ ដល់ថ្នាក់ទី៩) ចំពោះកុមារក្នុងវ័យសិក្សាទាំងអស់នៅឆ្នាំ ២០១០ (ii) លើកកំពស់គុណភាព និងភាពទាក់ទងនៃការចូលរៀន និង (iii) បង្កើនការគ្រប់គ្រង និងបង្កើនប្រសិទ្ធភាពនៃសេវាអប់រំ ។ ESSP ក៏បេព្ជា យ៉ាងម៉ឺងម៉ាត់ផងដែរចំដពោះការធ្វើវិមជ្ឈការក្នុងការផ្តល់វិមជ្ឈការលើការងារអប់រំ និងរួមមានផងដែរនូវ ការធ្វើប្រតិភូកម្មនៃភារៈកិច្ចទៅកាន់ស្រុក កំរងសាលារៀន និងឃុំ ។

១៥១. *ទោះជាយ៉ាងណាក៏ដោយលទ្ធភាពទៅកាន់កំរិតខុសៗគ្នានៃការចូលរៀន និងគុណភាពនៃសាលារៀនមានលក្ខណៈមិនដូចគ្នាទេនៅក្នុងតំបន់ផ្សេងៗ ។* ការចុះឈ្មោះចូលរៀននៅសាលាកំរិតបឋមសិក្សា និងជាពិសេសមធ្យមសិក្សាមានកំរិតទាបជាងនៅបណ្តាប្រទេសដទៃទៀតនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច ។ ស្ថានភាពនេះកាន់តែមានលក្ខណៈធ្ងន់ធ្ងរបន្ថែមទៀតនៅតំបន់ជនបទ ហើយជាពិសេសគឺចំពោះក្មេងស្រី និងកុមារមកពីក្រុមដែលគ្មានលក្ខណៈអំណោយផល ។ នៅក្នុងតំបន់ជនបទប្រជាពលរដ្ឋ ២០% ក្នុងស្រទាប់ក្រីក្របំផុតមានអត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកំរិតបឋមស្មើនឹង ៥០% និងតិចជាង ៥% ចំពោះកុមារ

ដែលមានអាយុចាប់ពី ១២-១៤ឆ្នាំ ដែលបានចុះឈ្មោះចូលរៀននៅកំរិតមធ្យមសិក្សាបឋមភូមិ ។ ចំនួនឆ្នាំជាមធ្យមនៃការសិក្សាចំពោះមនុស្សពេញវ័យនៅជនបទគឺ ៤,៤ឆ្នាំ សំរាប់បុរស និង ២,២ឆ្នាំ សំរាប់ស្រ្តី ដែលកំរិតមានកំរិតទាបជាងកំរិតមធ្យមភាគនៅថ្នាក់ជាតិ ។ យោងតាមការសិក្សារបស់ CDRI អត្រាកម្មករដែលមិនធ្លាប់ទៅសាលារៀនមានចំនួនច្រើននៅក្នុងចំណោមកសិករធ្វើស្រូវដែលមានចំនួនប្រហែល ៥១% ។ មានចំនួនតែ ៤៦%ប៉ុណ្ណោះនៃភូមិនៅជនបទដែលមានសាលាបឋមសិក្សា ។

១៥២. *សាលារៀននៅតំបន់ជនបទ កម្រស្ថិតនៅក្បែរកន្លែងដែលកុមាររស់នៅ* ។អាស្រ័យហេតុនេះ កុមារត្រូវដើរលើចំងាយផ្លូវឆ្ងាយទៅកាន់សាលារៀនដែលគ្មានថ្នាក់រៀនគ្រប់គ្រាន់ក្នុងកំរិតបឋមសិក្សា ។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលឡើយ ប្រការនេះធ្វើឱ្យមានអត្រារៀនត្រួតថ្នាក់ខ្ពស់ និងធ្វើផមានអត្រាបោះបង់សាលារៀនច្រើននៅតាមតំបន់ជនបទ ។

១៥៣. *គុណភាពនៃការអប់រំ គឺជាបញ្ហាមួយ ។* ជាមួយគ្នានេះផងដែរសាលារៀន នៅជនបទកម្រ ផ្តល់ការសិក្សាពេញពេល ហើយមានការបារម្ភជាទូទៅអំពីគុណភាពនៃការអប់រំនៅក្នុងសាលារៀនទាំងនោះ ។ បញ្ហាមួយផ្នែកគឺទាក់ទងនឹងកង្វះគ្រូបណ្តុះបណ្តាល ដោយសារគ្រូបង្រៀនភាគច្រើន នៅបឋមសិក្សានិងមធ្យមសិក្សាពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់បង្រៀន ។ ប្រការនេះរួមផ្សំ ជាមួយនឹងប្រាក់បៀវត្សទាបរបស់គ្រូបង្រៀន ដែលធ្វើឱ្យគ្រូបង្រៀនកាត់បន្ថយម៉ោងសិក្សាប្រចាំថ្ងៃ ដើម្បីធ្វើការងារផ្សេង ។ កង្វះខាតសាលារៀនក៏ជំរុញឱ្យមានការកាត់បន្ថយម៉ោងរៀន ផងដែរ ដើម្បីបង្កើនវេនរៀន ២ ឬ ៣ វេន ។

១៥៤. *ការយកប្រាក់ក្រៅផ្លូវការចំពោះការចូលសាលារៀនក៏ធ្វើឱ្យប៉ះពាល់ដល់ការចូលរៀនជាខ្លាំងផងដែរ ។* ក្រៅពីការចំណាយដោយផ្ទាល់ពីការរៀនសូត្រនៅជនបទ តំលៃឱកាសក៏មានកំរិតខ្ពស់ផងដែរ ។ មានគ្រួសារ ជាច្រើនដកកូនរបស់ខ្លួនពីសាលារៀនឱ្យមកជួយធ្វើការ ឬជួយមើលប្អូនរបស់ខ្លួន ។

១៥៥. *ចំណងទាក់ទងទីពីរ - គឺចំណងទាក់ទងកម្មវិធីអក្ខរភាព និងកិច្ចអភិវឌ្ឍន៍ជនបទ ក៏មាន សារៈសំខាន់ផងដែរនៅក្នុងដំណាក់កាលនេះនៃកិច្ចអភិវឌ្ឍន៍កម្ពុជា ។* ជារួម អត្រាអក្ខរភាព និងមានកំរិតទាបណាស់ មនុស្សធំមានចំនួនតែ ៦៧% ប៉ុណ្ណោះ ដែលអាចអានបាន ហើយក្នុងចំណោមនោះមានមនុស្សធំ ៣៥%នៅតំបន់ជនបទ និងស្ត្រីពេញវ័យតែ ៤៦% ប៉ុណ្ណោះនៅតំបន់ជនបទដែលអាចអានបាន។ កំរិតនៃអនក្ខរភាពកើនឡើងនៅតំបន់ខ្ពង់រាប។ កម្មវិធីអក្ខរភាពច្រើនតែខ្វះការលើកឡើងអំពីការអនុវត្តន៍ជាក់ស្តែង និងខ្វះទំនាក់ទំនងជាមួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាច្រើននៅតំបន់ជនបទ ។

## អនុសាសន៍ជាអាទិភាពចំពោះការអប់រំនៅជនបទ

១៥៦. សកម្មភាពខាងក្រោមនេះ ជាអនុសាសន៍ជាអាទិភាពក្នុង ការគាំទ្រកិច្ចអភិវឌ្ឍន៍នៅជនបទ :

- *បង្កលក្ខណៈប្រកបដោយសមធម៌ ក្នុងការបានទទួលការអប់រំនៅជនបទ* - តាមរយៈការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ សាលារៀន បរិក្ខារ សៀវភៅ និងសំភារៈផ្សេងៗ នៅក្នុងតំបន់ក្រីក្រ និងតំបន់ដែលបានទទួលសេវាមិនគ្រប់គ្រាន់ គាំទ្រអន្តរាគមន៍លើតំរូវការនិងលើគោលនយោបាយ ដើម្បីបង្កើនការចូលរួមនៅក្នុងការចូលរៀន កាត់បន្ថយចំណោយនៃការចូលរៀន តាមរយៈការលុបបំបាត់កាតព្វកិច្ចបង់ប្រាក់ផ្លូវការ ។

- *លើកកំពស់ គុណភាពនៃការអប់រំនៅជនបទ* -តាមរយៈការពង្រឹងការកសាងផែនការអប់រំ និងគ្រប់គ្រងតាមបែបវិមជ្ឈការ និងការកសាងផែនការកែលំអគុណភាពសាលារៀនតាមបែបវិមជ្ឈការ ការបង្កើនកិច្ចអភិវឌ្ឍន៍គ្រូវិជ្ជាជីវៈ( ប្រាក់បៀវត្ស ផ្ទះសំបែងនិងវិជ្ជាជីវៈ )និងលើកកំពស់គុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន (ជាពិសេសការបណ្តុះបណ្តាលគ្រូបង្រៀន ឱ្យនិយាយភាសានៅមូលដ្ឋាន ) បង្កើតការធានាឱ្យមានគុណភាពនិងប្រព័ន្ធតាមដាន ។ គប្បីកែលំអកម្មវិធីសិក្សា និងគួរដាក់បញ្ចូលនៅប្រធានបទដែលមានទំនាក់ទំនងនឹងសហគមន៍នៅជនបទ ដូចជាកសិកម្ម ព្រៃឈើ សុខភាពនិងអាហារូបត្ថម្ភ ព្រមទាំងការសិក្សាខាងផ្នែកបរិស្ថាន ។

- *ការកែសំរួលកម្មវិធីអក្ខរកម្ម ។* ចាំបាច់ត្រូវរៀបចំសារឡើងវិញនូវកម្មវិធីអក្ខរកម្ម និងធ្វើយ៉ាងណាឱ្យមានទំនាក់ទំនងជាមួយសហគមន៍ជនបទ ។ ប្រការនេះអាចកើតមាន តាមរយៈការងាកចេញពីវគ្គសិក្សាអក្ខរភាពសាមញ្ញ ទៅកាន់កម្មវិធីដែលមានខ្លឹមសារប្រតិបត្តិច្រើនជាងមុន ដោយផ្តោតទៅរកសហគមន៍ជនបទ និងសហគមន៍កសិកម្ម ដែលមានអក្ខរភាពទាប។

- *ការកំណត់គោលដៅកាន់តែប្រសើរទៅរកក្រុមពលរដ្ឋងាយរងគ្រោះ ។* កុមារនៅជនបទដែលមិនចុះឈ្មោះចូលរៀន ឬ ដែលធ្លាប់បោះបង់សាលា ច្រើនបណ្តាលមកពីសង្គមពុំមានលក្ខណៈអំណោយផលពោលគឺប្រជាពលរដ្ឋក្រីក្រ ជនជាតិភាគតិច និងក្មេងស្រី ។ ភាពលំអៀងយ៉ាងច្បាស់លាស់នេះអាកែតំរូវតាមរយៈការលើកកំពស់លទ្ធភាពចូលរៀននៅសាលាជនបទ -តាមរយៈការបង្កើត សាលារៀនបន្ថែម និងបំពាក់បរិក្ខារបន្ថែមដោយដាក់ទីតាំងសាលារៀនស្ថិតនៅជិតទីកន្លែងដែលកុមាររស់នៅ -ហើយបណ្តុះបណ្តាគ្រូបង្រៀន ឱ្យនិយាយភាសាមូលដ្ឋាន ។

***ការថែទាំសុខភាពនៅជនបទ***

១៥៧. *ផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលទទួលស្គាល់បញ្ហាប្រឈមជាក់លាក់អំពីលទ្ធភាពបានទទួលសេវាសុខភាពនៅតំបន់ជនបទ* ។ ចាប់តាំងពីឆ្នាំ១៩៩៦មក ក្រសួងសុខាភិបាលបានបន្តការធ្វើកំណែទំរង់គ្រប់ជ្រុងជ្រោយលើផ្នែកសុខាភិបាល ដោយផ្តែកលើគោលការណ៍គ្រឹះស្តីពី សមធម៌ ការទទួលបាននូវសេវាសុខាភិបាលជាមូលដ្ឋានក្របដោយគុណភាព និងផ្តល់ការការពារចំពោះប្រជាពលរដ្ឋក្រីក្រ ។ ដើម្បីគាំទ្រដល់ការអនុវត្តន៍តាមគោលដៅនេះ ក្រសួងបានប្រកាសគំនិតផ្តួចផ្តើម និងធ្វើកំណែទំរង់ការងារគ្រប់គ្រងនៅទូទាំងវិស័យ ដើម្បីលើកកំពស់លទ្ធផលអនុវត្តន៍ តាមរយៈការបង្កើតផែនការយុទ្ធសាស្ត្ររបស់វិស័យ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ព្រមទាំងលើកកំពស់សមត្ថភាពគប់គ្រងរបស់វិស័យសុខាភិបាល។ ផែនការយុទ្ធសាស្ត្រអំពីសុខាភិបាលឆ្នាំ២០០៣-២០០៧ ឥឡូវនេះបានទទួលការអនុម័តហើយ។ ប្រការនេះគាំទ្រការធ្វើវិមជ្ឈការនៃសេវាសុខាភិបាល ការពង្រឹងរដ្ឋបាលសុខាភិបាលថ្នាក់ខេត្ត និងថ្នាក់ស្រុក ដោយគូសបញ្ជាក់អំពីសេចក្តីត្រូវការក្នុងការបញ្ជាក់អំពីវិសាលភាព និងលទ្ធភាពទទួលសេវា (រាប់ទាំងលទ្ធភាពបង់ប្រាក់ផងដែរ )ការយកចិត្តទុកដាក់ចំពោះគុណភាព សារៈសំខាននៃការថែទាំសុខភាពបឋម និងតំរូវការក្នុងការអភិវឌ្ឍន៍ធនធានហិរញ្ញប្បទានដែលមាននិរន្តរភាព ។

១៥៨. *ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋនៅជនបទភាគច្រើនរស់នៅឆ្ងាយពីមណ្ឌលសុខភាព*–មណ្ឌលសុខភាព ត្រូវបានគេបង្កើតនៅតំបន់ទីប្រជុំជនធំៗ ដោយទុកឱ្យតំបន់ជនបទសឹងតែមិនបានទទួលសេវាសុខាភិបាលសោះឡើយ។ ជាមួយគ្នានេះ ស្ថានភាពនៅតំបន់ជនបទជាទូទៅមានលក្ខណៈទន់ខ្សោយ ដោយមានការកើតឡើងយ៉ាងខ្ពស់នូវជំងឺដែលមានប្រភពមកពីទឹកនិងសត្វល្អិត។ អត្រាមរណៈកុមារនិងអត្រាស្លាប់ដោយឆ្លងទន្លេក៏មានកំរិតខ្ពស់ផងដែរ ។វិបត្តិផ្នែកសុខភាព គឺជាប្រភពទី១នៃការបាត់បង់ចំណូល ( Helmers. et al., ឆ្នាំ2003)ហើយ គឺជាមូលហេតុចំបងមួយនៃការបង្ខំលក់ដីធ្លី ដែលធ្វើឱ្យកើនឡើងនូវ ភាពគ្មានដីធ្លី។ ការលើកកំពស់លទ្ធភាពឱ្យបានទទួលសេវាសុខភាព ដែលអាចពលរដ្ឋនៅជនបទអាច រ៉ាប់រងចំណាយបានគឺជាផ្នែកមួយសំខាន់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរស់នៅជនបទ។

១៥៩. *គុណភាពនៃសេវាសុខភាពនៅតំបន់ជនបទ គឺជាបញ្ហាមួយទៀត* ។ ជាជាងធ្វើដំណើរទៅកាន់មណ្ឌលសុខភាពសាធារណៈ គ្រួសារនៅជនបទច្រើនតែទៅពិគ្រោះជាមួយអ្នកលក់ថ្នាំនៅមូលដ្ឋាន ដែលអ្នកទាំងនោះពុំមែនជាអ្នកមានលក្ខណៈសម្បត្តិខាងផ្នែកវេជ្ជសាស្ត្រឡើយ ប៉ុន្តែពួកគេមិនចំណាយប្រាក់កាសច្រើនហើយអាចទាក់ទងបាន ប៉ុន្តែគុណភាពនៃសេវានេះបង្កជាចំណោទ។ ការបញ្ជាក់អំពីការប្រើប្រាស់ថ្នាំ

ដែលគ្មានការពិនិត្យជាក់ស្តែង ឬគ្មានការធ្វើតេស្ត ឬខ្វះការពិចារណាអំពីបច្ច័យអាក្រក់ ដែលអាចកើតមានចំពោះឱសថ ត្រូវបានគេលក់ទៅតាមកំរិតដូសតិចៗមិនសមស្រប គ្មានការណែនាំវេជ្ជសាស្ត្រច្បាស់លាស់ ។

១៦០. *ជាងនេះទៅទៀត វត្តមាននៃការយកប្រាក់ក្រៅផ្លូវការចំពោះការថែទាំសុខភាពសាធារណៈ និង/ឬ ថ្លៃរបស់អ្នកលក់ថ្នាំពេទ្យឯកជន ធ្វើឱ្យមានបន្ទុកធ្ងន់ធ្ងរមកលើគ្រួសារក្រីក្រនៅជនបទ ។* អង្កេតគ្រួសារជាច្រើនបានបង្ហាញថាចំណាយលើការថែទាំសុខភាព គឺជាទិដ្ឋភាពសំខាន់មួយនៃភាពងាយរងគ្រោះនៃគ្រួសារនៅជនបទ និងជាមូលហេតុសំខាន់មួយនៃភាពជំពាក់បំណុល ។

១៦១. *បញ្ហាប្រឈមចំបងចំពោះវិស័យសុខាភិបាលនៅកម្ពុជា ដូចនៅប្រទេសជាច្រើនដទៃទៀតដែរ គឺត្រូវស្វែងរកនូវការរួមផ្សំបសើរបំផុតនៃការផ្តល់សេវារវាងសុខាភិបាលឯកជននិងសាធារណៈ ។* អ្វីដែលគេត្រូវការ គឺជាការរួមផ្សំ ដែលជំរុញទៅរកការបែងចែកធនធានដែលមានប្រសិទ្ធិភាព ទន្ទឹមជាមួយគ្នានោះអនុញ្ញាតឱ្យមានការផ្តល់សេវាសុខភាពគ្រប់គ្រាន់ចំពោះប្រជាពលរដ្ឋក្រីក្រ និងផ្តល់សេវាថែទាំសុខភាព ដល់អ្នកដែលស្ថិតនៅក្នុងតំបន់ដែលពិបាកទៅដល់ ។ ចំណាយចាំបាច់ត្រូវប្រមូលផ្តុំទៅលើប្រសិទ្ធិភាពនៃការប្រើប្រាស់មណ្ឌលសុខភាពផ្សេងៗ ការរៀបចំចាត់តាំងឡើងវិញនូវប្រព័ន្ធសុខាភិបាលសាធារណៈ នៅទូទាំងប្រទេសគឺជាការចាំបាច់ និងកម្មវិធីបង្កាសុខភាព ចាំបាច់ត្រូវពង្រឹង ។ សំខាន់បំផុត គោលនយោបាយ និងកម្មវិធីចំណាយចាំបាច់ត្រូវលើកកំពស់លទ្ធភាពក្នុងការបានទទួលសេវាសុខាភិបាលជាមូលដ្ឋាន ចំពោះប្រជា-ពលរដ្ឋក្រីក្រនៅជនបទ ។ ការយកចិត្តទុកដាក់ជាអាទិភាព ក៏មានលក្ខណៈចាំបាច់ផងដែរ ក្នុងការដោះស្រាយបញ្ហាប្រឈមស្តីពីកង្វះអាហាររូបត្ថម្ភ ជាពិសេសកង្វះអាហារូបត្ថម្ភក្នុងចំណោមជនជាតិភាគតិចនៅតំបន់ខ្ពង់រាប ។

**អនុសាសន៍នៃសកម្មភាពគឺជាអាទិភាពសំរាប់ ការថែទាំសុខភាពនៅជនបទ**

១៦២. សកម្មភាពខាងក្រោមនេះគឺជាអនុសាសន៍សំរាប់ការថែទាំសុខភាពនៅជនបទ ក្នុងការគាំទ្រកិច្ចអភិវឌ្ឍន៍ នៅជនបទ :

- *បង្កើនលទ្ធភាពទទួលសេវាសុខាភិបាលដែលមានគុណភាព-* តាមរយៈកិច្ចអភិវឌ្ឍន៍ជាប្រចាំ នូវមធ្យោបាយថែទាំសុខភាពបឋម និងមន្ទីរពេទ្យបង្អែកទី១ (សរុប)និងទី២ (ខេត្ត) តាមរយៈការផ្តល់ហិរញ្ញប្បទាន និតិសម្បទានិងការកសាងថ្មី បរិក្ខារនិងការថែទាំ ។ប្រការនេះតំរូវឱ្យមានទិន្នន័យ

ឱ្យកាន់តែប្រសើរស្តីពីតំរូវការថែទាំសុខភាពតាមតំបន់ មានការកសាងផែនការដែលកាន់តែមានប្រសិទ្ធិភាព និងចំណាយសាធារណៈ លើមណ្ឌលសុខភាព ។

- *លើកកំពស់លទ្ធភាពបង់ប្រាក់នៅសេវាសុខភាពសំរាប់ប្រជាពលរដ្ឋក្រីក្រនិងប្រជាពលរដ្ឋដែលបានទទួលសេវាមិនគ្រប់គ្រាន់* -តាមរយៈការពង្រឹងសមត្ថភាពគ្រប់គ្រងនៅមូលដ្ឋាន និងបង្កើនការផ្តល់មូលនិធិនិងមូលដ្ឋានដែលមាននិរន្តរភាព ។ការកំណត់ថ្លៃសេវាថែទាំសុខភាព គប្បីពិនិត្យនិងថ្លឹងថ្លែងឆ្ពោះទៅរកការកាត់បន្ថយថ្លៃសេវាសំរាប់ការថែទាំសុខភាពសាធារណៈនិងបង្ការសុខភាពហើយបង្កើតយន្តការកំណត់គោលដៅកាន់តែមានប្រសិទ្ធិភាពចំពោះគ្រួសារក្រីក្រ ។ ផ្តោតការយកចិត្តទុកដាក់ជាបន្តលើការថែទាំសុខភាព និងការបង្ការសុខភាពដែលមានប្រសិទ្ធិភាពក្នុងការចំណាយជាជាងការព្យាបាលជំងឺ ។

- *ជំរុញការចូលរួមរបស់វិស័យឯកជន* ៖ការផ្តល់ការថែទាំសុខភាព របស់វិស័យឯកជន គប្បីត្រូវបានលើកកំពស់ឱ្យអភិវឌ្ឍន៏តាមការចាំបាច់ ។ ទំនងជាមានវិសាលភាពតិចតួចចំពោះកិច្ចការនេះ នៅតំបន់ជនបទដាច់ស្រយាលហើយរដ្ឋាភិបាលគប្បីដើរតួសកម្មនៅទីនោះ ។

# ផ្នែកទី III : ការផ្តល់លទ្ធផល និងជំហានបន្ទាប់

១៦៣. *ផ្នែកទី II នៃឯកសារនេះ ស្វែងរកគោលដៅ និងគោលនយោបាយ ៣ ដែលអាចជាស្នូលនៃយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជនបទ ឆ្ពោះទៅរកប្រជាពលរដ្ឋក្រីក្រ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ* ។ទាំងអស់នេះរួមមានគោលនយោបាយ កំណែទំរង់កម្មវិធី និងកំណែទំរង់ស្ថាប័ន ដើម្បី : (i) លើកកំពស់លទ្ធភាពបានទទួលមូលដ្ឋានធនធានធម្មជាតិរបស់កម្ពុជា និងការគ្រប់គ្រងមូលដ្ឋានធនធានធម្មជាតិកម្ពុជា (ii) បង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូលកសិកដ្ឋាន (iii) ផ្តល់គុណភាពហេដ្ឋារចនាសម្ព័ន្ធនៅជនបទនិងលើកកំពស់លទ្ធភាពរបស់ជនបទ ក្នុងការទទួលសេវាសេដ្ឋកិច្ចនិងសេវាសង្គម (រួមមានសេវាហិរញ្ញវត្ថុផងដែរ) ។ ក្នុងការគាំទ្រគោលដៅទាំង ៣នេះ អនុសាសន៍មួយចំនួនត្រូវបានស្នើឡើង រួមមាន បញ្ជីនៃអន្តរាគមន៍ជាអាទិភាព និងទំរង់ដទៃទៀតនៃការគាំទ្រប្រតិបត្តិការដែលត្រូវអនុវត្តតាមរយៈធនធានផ្ទាល់របស់រដ្ឋាភិបាលកម្ពុជា បំពេញបន្ថែមដោយឥណទានពីធនាគារពិភពលោក អន្តរាគមន៍ពីពហុភាគីនិង ទ្វេភាគី ព្រមទាំងសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលនិងវិស័យឯកជន។ ដោយចាប់ផ្តើមចេញពីបញ្ជីសំណើសកម្មភាពដែលបានរៀបចំជុំវិញគោលដៅ និងគោលនយោបាយទាំង ៣ មកកាន់ការកំណត់ទិសដៅជាក់ស្តែង នៃសកម្មភាពនិងគោលដៅ ចាំបាច់ត្រូវពាក់ព័ន្ធជាមួយដៃគូដទៃទៀត និងចាំបាច់ត្រូវសម្របសម្រួល និងសរុបបញ្ចូលគ្នាតាមរយៈកិច្ចពិគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធទាំងអស់ ។

១៦៤. *ដើម្បីផ្តល់លទ្ធផល ចាំបាច់ត្រូវពិចារណាអំពីកត្តាសំខាន់ៗមួយចំនួន នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទដែលបានទទួលការកែលំអ ដែលមានទំនាក់ទំនងជាមួយតំបន់ជនបទ និងផ្សារភ្ជាប់ទៅកាន់ផ្នែកផ្សេងៗទៀតនៃសេដ្ឋកិច្ច ។* ទិដ្ឋភាពទាំងនេះត្រូវបានលើកឡើងក្នុងពេលបន្ទាប់នោះគឺៈ ទំនាក់ទំនងតាមខ្សែទទឹង ទៅកាន់របៀបវារៈដទៃទៀត ឧបសគ្គសុខភាពផ្នែកស្ថាប័ន ដែលស្នើរឱ្យមានការយកចិត្តទុកដាក់ចំពោះវិស័យសាធារណៈ លើមុខងារសំខាន់ៗ និងបន្តអនុវត្តន៍នៅ សេចក្តីត្រូវការសម្របសម្រួលមួយចំនួនរួមមានការគាំទ្ររបស់ម្ចាស់ជំនួយ ។ ចុងក្រោយសំណើរសំរាប់ជំហានបន្ទាប់ សំរាប់ឯកសារនេះ និងក្រៅពីឯកសារនេះ ។

## *ពង្រឹងចំណងទាក់ទងចំពោះរបៀបវារៈ គាំទ្រតាមវិស័យ*

១៦៥. *វឌ្ឍនភាពលើកិច្ចអភិវឌ្ឍន៍តំបន់កសិកម្មនិងតំបន់អភិវឌ្ឍន៍ជនបទ ពុំមែនអាស្រ័យលើការដោះស្រាយបញ្ហាជាក់លាក់នៅក្នុងក្របខ័ណ្ឌទាំងនេះឡើយ ក៏ប៉ុន្តែក៏ទាក់ទងជាមួយវឌ្ឍនភាពនឹងរបៀបវារៈដែលមានសារៈសំខាន់ ដែលមានទំនាក់ទំនងតាមខ្សែទទឹងចំពោះវិស័យផ្សេងៗផងដែរ* ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ(NPRS, 2003-2005)និងផែនការសេដ្ឋកិច្ចអភិវឌ្ឍន៍សង្គមកិច្ច៥ឆ្នាំលើកទីពីរ (SEDPII, 2001-2005)កំណត់បញ្ហាទាំងនេះតាមការមានសារៈសំខាន់បំផុត ។ គោលដៅនៃកិច្ចអភិវឌ្ឍន៍ជាតិដែលបញ្ជាក់នៅក្នុងឯកសារទាំងនេះផ្តោតលើកំណើនសេដ្ឋកិច្ច ដែលមានលក្ខណៈទូទៅគ្រប់គ្រាន់ក្នុងការដាក់បញ្ចូលវិស័យនានាដែលប្រជាពលរដ្ឋក្រីក្រពឹងអាស្រ័យ កិច្ចអភិវឌ្ឍន៍សង្គមនិង វប្បធម៌ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានធម្មជាតិព្រមទាំងការគ្រប់គ្រងបរិស្ថានសមស្រប ។ ក្នុងខណៈដែលកិច្ចអភិវឌ្ឍន៍កសិកម្មនិងជនបទ គឺជាអាទិភាពពីរក្នុងចំណោមវិស័យអាទិភាព ៤ ដែលត្រូវបានកំណត់ វឌ្ឍនភាពតាមវិស័យ ត្រូវបានទទួលស្គាល់ថាពឹងផ្អែកទៅលើភាពស្របគ្នា នៃវឌ្ឍនភាពស្តីពីទិដ្ឋភាព៣នៃការលើកកំពស់អភិបាលកិច្ច :ការគ្រប់គ្រងធនធានសាធារណៈ វិមជ្ឈការនិងអភិបាលកិច្ចមូលដ្ឋាន និងការប្រឆាំងអំពើពុករលួយ ។ក្រៅពីនេះ មានរបៀបវារៈតាមខ្សែទទឹងស្តីពីកិច្ចអភិវឌ្ឍន៍តាមវិស័យឯកជនដែលផ្តោតលើខ្សែសង្វាក់តំលៃកែច្នៃកសិកម្ម និងសេដ្ឋកិច្ចជនបទ ក្រៅពីកសិកម្មទូទៅ ។

១៦៦. *បញ្ហាទាំងនេះកំណត់បរិយាកាសបង្កលក្ខណៈចំពោះកិច្ចអភិវឌ្ឍន៍ជនបទ* ហើយគឺជាភាពដែលសំខាន់ៗ ដើម្បីអនុវត្តន៍ឱ្យបានត្រឹមត្រូវ សំដៅឱ្យមានកិច្ចអភិវឌ្ឍន៍ជនបទប្រព្រឹត្តទៅតាមល្បឿន ដែលត្រូវការ ដើម្បីនាំមកនូវការលើកកំពស់សុខមាលភាពចំពោះប្រជាជននៅជនបទ ។ ការត្រួតពិនិត្យលើការទទួលខុសត្រូវសំខាន់ៗ ក្នុងការកំណត់និងដឹកនាំទិសដៅកំណែទំរង់ស្នូលចំពោះបញ្ហាទាំងនេះគឺជាវិធានការដែលស្ថិតនៅក្រៅស្ថាប័នទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍន៍កសិកម្មនិងអភិវឌ្ឍន៍ជនបទ ប៉ុន្តែការចូលរួមដែលមានលក្ខណៈអកម្ម ចំពោះពួកគេគឺជាកំហុសមួយ ។ (ទី១ទិសដៅនៃកំណែទំរង់ចាំបាច់ត្រូវមានប្រភពពីរបៀបវារៈតាមវិស័យដែលត្រូវមានប្រសិទ្ធិភាព និងការរៀបចំរបៀបវារៈតាមវិស័យ និងដាក់ឱ្យស្ថាប័នដែលផ្តោតលើផ្នែកជនបទទាំងនេះ នៅក្នុងរណសិរ្សជួរមុខ នៃការទទួលអត្ថប្រយោជន៍ពីការផ្លាស់ប្តូរ។ ស្ថាប័ន តាមវិស័យអាចទទួលអត្ថប្រយោជន៍ តាមរយៈការចូលរួមដែលមានលក្ខណៈកសាង ប៉ុន្តែចាំបាច់ត្រូវលើកកំពស់នៅសមត្ថភាពស្ថាប័នរបស់ខ្លួនក្នុងការធ្វើកិច្ចការនេះ ។ ទី២ នៅក្នុងតំបន់មួយចំនួន ទីភ្នាក់ងារការអភិវឌ្ឍន៍ជនបទកំពុងស្វែងរកដំណោះស្រាយ ដែលមានលទ្ធភាពក្នុងការរួមវិភាគទាន នៅក្នុងរបៀបវារៈទូទៅ(ដូចជាការលើកកំពស់ការផ្ទេរហិរញ្ញវត្ថុអន្តររដ្ឋាភិបាល ក៏ដូចជាការកសាងផែនការនិងការអភិវឌ្ឍន៍

នៅមូលដ្ឋានក្នុងបរិបទនៃកំណែទំរង់វិមជ្ឈការថ្មីៗ ដែលកាន់តែមានតម្លាភាព និងកាន់តែមានភាពទទួលខុសត្រូវ )។

## ការគ្រប់គ្រងធនធានសាធារណៈ

១៦៧. *ការគ្រប់គ្រងចំណាយសាធារណៈ បានកើនឡើងចាប់តាំងពីឆ្នាំ ១៩៩៩ ប៉ុន្តែ នៅមានបញ្ហា នៅក្នុងផ្នែកមួយចំនួននៅឡើយ* ។ គេត្រូវការឱ្យមានវឌ្ឍនភាពជាច្រើនបន្ថែមទៀត ហើយបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តន៍គោលដៅអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ជាពិសេសគឺការកែលំអការគ្រៀងគរធនធានដើម្បីធានាឱ្យមាននិរន្តរភាពផ្នែកសាពើពន្ធ កាត់បន្ថយហានិភ័យចំពោះមូលនិធិសាធារណៈ តាមរយៈការធ្វើកំណែទំរង់លើការអនុវត្តន៍ថវិកា ការគ្រប់គ្រងសាច់ប្រាក់ និងប្រព័ន្ធត្រួតពិនិត្យសាធារណៈ ការធ្វើសនិទានកម្មគោលនយោបាយសាធារណៈ និងការគ្រប់គ្រងដើម្បីអភិវឌ្ឍន៍ SEDP II និង NPRS និងការប្រកាន់យកការធ្វើកំណែទំរង់សាធារណៈដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីផ្តល់នូវ សេវាកាត់បន្ថយភាពក្រីក្រ ( IFAPER, 2003) ។

១៦៨. *គេត្រូវការឱ្យមានការកំណែមុខងារសាធារណៈ បន្ទាន់ដើម្បី លើកកំពស់ការផ្តល់សេវាសាធារណៈ* ។ បទពិសោធន៍ក្នុងពេលកន្លងទៅនៅក្នុងវិស័យនេះបានបង្ហាញថាកំរិតប្រាក់ខែទាបរបស់មន្ត្រីរាជការ គឺជាបញ្ហាចំបងដែលធ្វើឱ្យមានឧបសគ្គចំពោះវឌ្ឍនភាពនៃកំណែទំរង់ និងចំពោះប្រសិទ្ធិភាពនៃការផ្តល់សេវា។ ដំណោះស្រាយបណ្តោះអាសន្ន គឺការអនុញ្ញាតិឱ្យមានការអនុវត្តន៍គំរោងផ្តល់សេវាមានប្រសិទ្ធិភាព។ ដំណោះស្រាយបណ្តោះអាសន្នគឺការអនុញ្ញាតិ ឱ្យមានការអនុវត្តន៍គំរោងដែលមានប្រសិទ្ធិភាព ដែលអ្នកផ្តល់ជំនួយភាគច្រើន/គំរោងផ្សេងៗផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ។ ខណៈដែលប្រការនេះបានផ្តល់កត្តាលើកទឹកចិត្តចំពោះបុគ្គលិកដែលបានទទួលលាភការក្នុងការប្រឹងប្រែងធ្វើការងារ ទន្ទឹមជាមួយគ្នាផងដែរ ក៏បង្កើតឱ្យមានផលប៉ះពាល់ក្នុងការអនុវត្តន៍ នៅកម្មវិធីរបស់រដ្ឋាភិបាលទូទៅតាមរយៈការជំរុញឱ្យមានឥរិយាបថស្វែងរកអត្ថប្រយោជន៍បុគ្គលរួម ការជ្រើសរើសបុគ្គលិក និងការតម្លើងឋានៈដោយគ្មានតម្លាភាព ដែលមិនអាចបង្កាការរក្សាទុកនូវបុគ្គលិកដែលមានលក្ខណៈសម្បត្តិនិងទទួលការលើកទឹកចិត្តបំផុត នៅក្នុងឋានៈសំខាន់ៗ ដែលមិនផ្តល់ហិរញ្ញប្បទានតាមរយៈជំនួយបរទេស ។ បញ្ហាដែលរក្សាទុកបុគ្គលិកក៏បានធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃកម្មវិធីកសាងសមត្ថភាពនៅក្នុងស្ថាប័នជាច្រើន ដែលបុគ្គលិកបានទទួលការបណ្តុះបណ្តាល បានចាកចេញពីវិស័យសាធារណៈនៅពេលដែលគំរោងចប់ ។ ជាងនេះទៅទៀត បុគ្គលិកមានជំនាញ ប្រមូលផ្តុំនៅតាមស្ថាប័ននៅទីក្រុងភ្នំពេញ និងដោយសារកំរិតប្រាក់ខែទាបនិងអវត្តមាននៃ

ឱកាសសេដ្ឋកិច្ចដទៃទៀតនៅតាមខេត្តនិងតាមស្រុក គេពុំឃើញមានកត្តាលើកទឹកចិត្តសោះសំរាប់ឱ្យសិស្ស ថ្មីៗ ដែលបញ្ចប់ការសិក្សា / ឬបុគ្គលិកដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការស្វែងរកមុខតំណែង នៅតាម ការិយាល័យមន្ទីរនៅខេត្ត ឬតាមស្រុកឡើយ[85] ។ អាស្រ័យហេតុនេះ ការអនុវត្តន៍អំពីគោលនយោបាយ ផ្តល់លាភការគ្រប់គ្រាន់ និងផ្តល់ការងារគ្រប់គ្រាន់ចំពោះមន្ត្រីរាជការ មានសារៈសំខាន់នៅក្នុងការផ្តល់នូវ ទំនិញនិងផ្តល់សេវាសាធារណៈ ចំពោះប្រជាពលរដ្ឋនិងផលិតករនៅជនបទ ជាមួយនេះត្រូវកំណត់និងដឹកនាំ ឱ្យបានកាន់តែគ្រប់ជ្រុងជ្រោយ មិនត្រឹមតែគិតលើការ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទប៉ុណ្ណោះទេ ។

១៦៩. *ការរៀបចំធនធានជាមួយគោលនយោបាយវិស័យនិង អាទិភាពនៃការវិនិយោគ* ៗតារាងម៉ាទ្រីស ភ្ជាប់ជាមួយ និងខ្លឹមសារសង្ខេបនៃឯកសារនេះ សង្ខេបសកម្មភាពអាទិភាពសំខាន់ៗនៃរបៀបវារៈជនបទ សំរាប់រយៈពេលខ្លី សំរាប់រយៈពេលមធ្យមនិង សំរាប់រយៈពេលវែង ដែលមានពតិនានានៅក្នុងផ្នែក ទី II ។ ខ្លឹមសារសង្ខេបនេះក៏បញ្ជាក់ផងដែរ អំពីទីកន្លែងដែលធនធាន ត្រូវបានកំណត់អត្តសញ្ញាណ និងបង្ហាញ អំពីអវត្តមាន និងកន្លែងអាទិភាពដែលត្រូវកំណត់ធនធានបន្ថែមចាំបាច់ ហើយតំរូវឱ្យមានការយកចិត្ត ទុកដាក់បន្ថែមទៀត —ជាពិសេសនៅក្នុងរយៈពេលខ្លី ។ទោះជាយ៉ាងណាក៏ដោយ នៅក្នុងជំហានទី១ ចាំបាច់ត្រូវមានលក្ខណៈច្បាស់លាស់ និងមានកិច្ចព្រមព្រៀងទូទៅរវាងរដ្ឋាភិបាលនិងដៃគូរបស់រដ្ឋាភិបាល លើសំណើក្របខ័ណ្ឌអាទិភាព ។ ការលំបាកមួយក្នុងការផ្តល់អាទិភាពបន្ថែមទៀតចំពោះវិនិយោគសាធារណៈ នៅកម្ពុជា ក្រៅពីការរៀបរាប់ អំពីផលប្រយោជន៍នៃ ការវិនិយោគសាធារណៈ គឺកង្វះទិន្នន័យដែលអាចជឿ ទុកចិត្តបាន ។ មានឧទាហរណ៍នានាមកពីបណ្តាប្រទេសនៅអាស៊ី (សូមអានតារាង៧នៅខាងក្រោម) ប៉ុន្តែការសិក្សានៅតែតំរូវឱ្យមានការស្រាវជ្រាវដូចគ្នានៅកម្ពុជា ។ ទន្ទឹមជាមួយការពង្រឹងដំណើរការកសាង ផែនការនៅមូលដ្ឋាន ត្រូវមានការពិគ្រោះការពិភាក្សាជាមួយភាគីពាក់ព័ន្ធផ្សេងៗគ្នា ដើម្បីបង្កើន ភាពឆ្លើយតបនៃស្ថាប័ននៅវិស័យជនបទនឹងតំរូវការមូលដ្ឋាន ជាមួយនិងការពិនិត្យឡើងវិញនូវមូលដ្ឋាន ទិន្នន័យបច្ចុប្បន្នស្តីពីផលប៉ះពាល់នៃការវិនិយោគពីអតីតកាល នៅក្នុងតំបន់ផ្សេងៗគ្នា គេអាចផ្តល់អាទិភាព ជាសាធារណៈនៅថ្នាក់ខេត្តនិងថ្នាក់មូលដ្ឋាន។

[85] បុគ្គលិកជាង៥០% នៃ MAFF នៅក្នុងក៏រិតនេះ គ្មានលក្ខណៈសម្បត្តិឡើយ ( IFAPER, 2003) ។

*តារាងទី ៧ :ផលចំណូលនៃការធ្វើវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម និងផលប៉ះពាល់ទៅលើការកាត់បន្ថយភាពក្រីក្រនៅប្រទេសចិន និងឥណ្ឌា*

| | **ផលចំណូលសេដ្ឋកិច្ច*** | | **កាត់បន្ថយភាពក្រីក្រ**** | |
|---|---|---|---|---|
| **ផ្នែក** | **ចិន** | **ឥណ្ឌា** | **ចិន** | **ឥណ្ឌា** |
| ស្រាវជ្រាវ និង ផ្សព្វផ្សាយ | 9.59 | 13.45 | 6.79 | 84.5 |
| ធារាសាស្ត្រ | 1.88 | 1.36 | 1.33 | 9.7 |
| ផ្លូវ | 8.83 | 5.31 | 3.22 | 123.8 |
| អប់រំ | 8.68 | 1.39 | 8.80 | 41.0 |
| អគ្គីសនី | 1.26 | 0.26 | 2.27 | 3.8 |
| កម្ចីដើម្បីកាត់បន្ថយភាពក្រីក្រ | n.a. | 1.09 | 1.13 | 17.8 |

*សំរាប់ប្រទេសចិន ផលិតផលក្នុងសរុបគិតជា *yuan* សរុប/ចំណាយគិតជា *yuan* ហើយសំរាប់ឥណ្ឌា ផលិតផលក្នុងសរុបគិតជា *Rupee* សរុប/ចំណាយគិតជា *Rupee*

** សំរាប់ប្រទេសចិន ចំនួនអ្នកក្រីក្រដែលត្រូវបានកាត់បន្ថយ/តំលៃចំណាយ ១០ ០០០ *yuan* សំរាប់ប្រទេសឥណ្ឌា ចំនួនអ្នកក្រីក្រដែលត្រូវបានកាត់បន្ថយ/តំលៃចំណាយ ១០០០ ០០០ *Rupee*

*ប្រភព: ឯកសារពិគ្រោះអំពី ការវិនិយោគវិស័យកសិកម្ម, ធនាគាពិភពលោក*

## វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន

១៧០. *កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាចំណុចស្នូលនៃការធ្វើកំណែទំរង់ការគ្រប់គ្រងនៅក្នុងតំបន់ជនបទ*។ បន្ទាប់ពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅខែ កុម្ភៈឆ្នាំ ២០០២ រដ្ឋាភិបាលបានចូលរួម នៅក្នុងកម្មវិធីវិមជ្ឈការដ៏ទូលំទូលាយមួយ។ គណកម្មាធិការជាតិគាំទ្រឃុំសង្កាត់ គឺជាអ្នកទទួលបន្ទុកក្នុងការធ្វើកំណែទំរង់វិមជ្ឈការ។ កម្មវិធីសិលាបានផ្តល់នូវមេរៀនបទពិសោធន៍យ៉ាងច្រើន សំរាប់ការរៀបចំ ធ្វើកំណែទំរង់វិមជ្ឈការ ពីការរៀបចំផែនការអភិវឌ្ឍនៅមូលដ្ឋាន ការរៀបចំថវិកា និងការអនុវត្តន៍នៅក្នុងដំណាក់កាលសាកល្បងលើកដំបូងរបស់ខ្លួន ហើយលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃ កម្មវិធីសិលា (សេនាធិការប្រតិបត្តិរបស់ គណៈកម្មាធិការដឹកនាំការងារនៃ

កម្មវិធីសិលា) សំរបសំរួលការ ផ្តល់ហិរញ្ញប្បទានរបស់អ្នកផ្តល់ជំនួយទៅនឹងការអនុវត្តនីការធ្វើកំណែទំរង់វិមជ្ឈការ[៨៦] ហើយដូច្នេះតំណាង ឱ្យ ទស្សនៈមួយដ៏សំខាន់នៃការធ្វើកំណែទំរង់វិមជ្ឈការ ។

១៧១. *វិធីសាស្ត្រពីរយ៉ាងបំពេញឱ្យគ្នាទៅវិញទៅមកកំពុងត្រូវបានប្រើប្រាស់នៅកម្ពុជាដើម្បីធ្វើឱ្យរបៀបវារៈវិមជ្ឈការឈានឆ្ពោះទៅមុខ ។* វិធីសាស្ត្របទដ្ឋានមួយ ដោយចាប់ផ្តើមពីក្របខ័ណ្ឌទស្សនាទានអំពីចរិកលក្ខណៈ នៃរដ្ឋដែលជាមូលដ្ឋានសំរាប ច្បាប់អង្គការ និងវិធីសាស្ត្រដែលមានលក្ខណៈអនុវត្តជាក់ស្តែងដោយផ្អែកលើការធ្វើពិសោធន៍តាមរយៈការសាកល្បងដោយផ្តោតទៅលើការផ្លាស់ប្តូរជាបណ្តើរៗ ដែលកសាងបន្ថែមទៅលើជំរើស ឬម៉ូដែលមួយចំនួនដែលអាចប្រើប្រាស់ជាមូលដ្ឋានសំរាប់ការរៀបចំច្បាប់ទៅអនាគត ។ វិធីសាស្ត្រនិមួយៗមានភាពខ្លាំង និងខ្សោយរៀងៗខ្លួន ហើយមានឥទ្ធិពលខ្លាំងណាស់នៅពេលប្រើរួមគ្នា ។ វិធីសាស្ត្របទដ្ឋាន អនុវត្តទៅមានហានិភ័យដែល ម៉ូដែលតែមួយប្រើសំរាប់គ្រប់ករណី មិនអាចអនុវត្តបានទេ ហើយប្រាក់ឧបត្ថម្ភត្រូវតែរៀបចំសំរាប់ករណីពិសេសជាក់ស្តែងនៃមុខងារសាធារណៈ ខុសៗគ្នាគឺថា អ្វីដែលអាចដំណើរការបានល្អសំរាប់ការចែកចាយសេវាអប់រំ ឬសុខភាពមិនអាចសមស្រប ឬមានប្រសិទ្ធិភាពសំរាប់សេវាផ្តល់យោបល់កសិកម្មឬអាជីវកម្ម ។ ដូចគ្នានេះដែរ វិធីសាស្ត្រផ្លាស់ប្តូជាបណ្តើរៗរាំងស្ទះមិនអាចទៅមុខបានដោយការខ្វះខាតនូវនីតិបញ្ញត្តិ ដែលមានចែងអំពីគោលការណ៍សំខាន់ៗមួយចំនួនចាំបាច់ដើម្បីពន្លឿនកំណែទំរង់ទូលំទូលាយនៅមូលដ្ឋាន ដែលវិសាលភាពសំរាប់ការកែលំអនិងកំណែទំរង់អាចមានកំរិត រហូតដល់នីតិបញ្ញត្តិថ្មីដោះស្រាយនូវបញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងកាតព្វកិច្ចអាជ្ញាធរ និងការទទួលខុសត្រូវរវាងថ្នាក់កណ្តាលនិងខេត្តក្រុង ។

១៧២. *ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល*[87] *ទទួលខុសត្រូវក្នុងការនាំមុខនៃការធ្វើកំណែទំរង់វិសហមជ្ឈការដែល ផ្តោតទៅលើការផ្ទេរអំណាចរដ្ឋបាលនិងមុខងារទៅអភិបាលខេត្ត រដ្ឋបាលថ្នាក់ខេត្ត និងស្រុក ។* ទោះបីជាមាន ការចាប់អារម្មណ៍ពីអ្នកផ្តល់ជំនួយ និងឆន្ទៈនយោបាយ ក៏នៅមានការខ្វះខាតនូវវឌ្ឍនភាពក្នុងការបង្កើតឡើង នូវគោលនយោបាយ និងយុទ្ធសាស្ត្រវិសហមជ្ឈការ ។

---

[86] អ្នកផ្តល់ជំនួយដែលជួយកម្មវិធីសិលាមាន: DFID, SIDA, UNDP, IFAD, DANIDA, UNICEF, ធនាគារពិភពលោក, WHO, និង AusAID ។

[87] ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងអគ្គលេខាធិការរបស់ខ្លួន មានក្រុមការងារអន្តរក្រសួងមួយសហការជាមួយក្រុមការងារ របស់ក្រសួងចំនួន ១១ថែមទៀតដែលធ្វើការងារពាក់ព័ន្ធនឹងបញ្ហាវិមជ្ឈការនិងវិសហមជ្ឈការ ។ ក្រសួងទាំង ១១នោះរួមមាន សុខាភិបាល អប់រំ សាធារណៈការ ការងារសង្គមកិច្ច អភិវឌ្ឍន៍ជនបទ ផែនការ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់គ្រងដែនដី ឧស្សាហកម្ម មហាផ្ទៃ និង កសិកម្ម ។ គេសង្ឃឹមថានឹងមានក្រសួងផ្សេងៗទៀតនឹងចូលរួមនៅក្នុងក្រុមការងារនេះនៅពេលដែលកាតព្វកិច្ចការងារ វិមជ្ឈការ និងវិសហមជ្ឈការដំណើរការទៅមុខ ។

មានទស្សនៈពីរដាច់ពីគ្នាប៉ុន្តែមានទំនាក់ទំនងនឹងគ្នា ចំពោះវិសហមជ្ឈការនៃអំណាចរដ្ឋបាល និងមុខងារ។ ទស្សនៈទីមួយពាក់ព័ន្ធនឹងភាពបំពេញឱ្យគ្នាទៅវិញទៅ មករវាងវិមជ្ឈការនិងវិសហមជ្ឈការ និងតួនាទីពាក់ព័ន្ធគ្នារបស់អភិបាលខេត្តនិងរដ្ឋបាលថ្នាក់ខេត្តនិងស្រុក ក្នុងការផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំសង្កាត់។ ក្នុងទិដ្ឋភាពនេះ មានភាពជឿនលឿនល្អចំពោះបញ្ហានេះ ព្រោះថាតួនាទីរបស់អភិបាលខេត្តត្រូវបានកំណត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់ នៅក្នុងក្របខ័ណ្ឌបញ្ញត្តិវិមជ្ឈការតាមរយៈប្រកាស[៨៨] ហើយគោលការណ៍ណែនាំ[៨៩]ថ្មីៗមួយ ដោយគណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលា ផ្តល់នីតិវិធីអន្តរកាលសំរាប់រចនាសម្ព័ន្ធទ្រទ្រង់ថ្នាក់ខេត្ត តាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ ជនបទខេត្ត រហូតដល់ក្រុមប្រឹក្សាឃុំសង្កាត់។ ប៉ុន្តែនៅមិនទាន់មានវឌ្ឍនភាពល្អចំពោះទិដ្ឋភាពទីពីរទេ ដែលទិដ្ឋភាពនោះពាក់ព័ន្ធនឹងតួនាទីរបស់អភិបាលខេត្ត និងរដ្ឋបាលខេត្ត និងស្រុក ក្នុងការផ្តល់នូវសេវាតាម ផ្នែកនានានៅកំរិតថ្នាក់ខេត្ត តាមរយៈមន្ទីរតាមខេត្តរបស់ក្រសួងនានា។ ច្បាប់អង្គការស្តីពីវិសហមជ្ឈការ មានគោលបំណងផ្តល់នូវមូលដ្ឋានគតិយុត្តិសំរាប់ទិដ្ឋភាពទីពីរនៃកំណែទំរង់វិសហមជ្ឈការ ប៉ុន្តែច្បាប់នេះ កំពុងនៅក្នុងដំណាក់កាលដំបូងនៃការពិភាក្សា ហើយនៅមិនទាន់មានការឯកភាពគ្នាអំពីគោលការណ៍សំខាន់ៗនៅឡើយទេ។ បញ្ញត្តិវិសហមជ្ឈការនឹងជំនួសផងដែរនូវអនុក្រិត្យ និងប្រកាសដែលបានអនុញ្ញាតិ ឱ្យស្ថាប័ន ថ្នាក់ខេត្តដូចជា គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួន ដែលស្ថិតនៅ ក្រោមកម្មវិធីសិលាដំណើរការបាន។

១៧៣. *បច្ចុប្បន្ននេះមន្ទីរតាមខេត្តរបស់ក្រសួងនានា ពុំទាន់មានសិទ្ធិអំណាចក្នុងការរៀបចំនិងអនុវត្តគំរោងអភិវឌ្ឍន៍នានានៅក្នុងខេត្តរបស់ខ្លួនទេ លើកលែងតែក្នុងករណីពិសេសខ្លះនៃសកម្មភាពសាកល្បងនានា* ដូចជា មូលនិធិវិនិយោគខេត្ត និងការសាកល្បងនូវកម្មវិធីវិសហមជ្ឈការតាមផ្នែកថ្នាក់ជាតិដែលនៅក្រោមកម្មវិធីសិលា។ ឧទាហរណ៍ នៅក្នុងផ្នែកកសិកម្ម ការធ្វើវិសហមជ្ឈការត្រូវបានធ្វើការសាកល្បងដោយគំរោងគាំទ្រកិច្ចអភិវឌ្ឍន៍កសិកម្មនៅក្នុងកម្មវិធីសិលា (ADESS) ដែលផ្តល់ហិរញ្ញប្បទានដោយអង្គការ IFAD ដែលដំណើរការនៅតំបន់ភាគពាយ័ព្យ ដោយមានការចូលរួមពីក្រសួងកសិកម្ម និងមន្ទីរកសិកម្មខេត្តក្នុងការជួយទ្រទ្រង់នូវការអភិវឌ្ឍន៍កសិកម្មដោយមានការចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ[៩០]។ សកម្មភាព ទាំងនេះផ្តល់ដល់ក្រសួងកសិកម្មនូវបទពិសោធន៍និងជំនាញដើម្បីចូលរួមជាមួយគណៈកម្មាធិការ

---

[88] ប្រកាសស្តីពីប្រតិភូកម្មអំណោចដល់អភិបាលខេត្តក្រុងក្នុងការគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់។

[89] ប្រកាសស្តីពីការបង្កើតរចនាសម្ព័ន្ធតួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តក្រុងនៃកម្មវិធីសិលា។

[90] បន្ទាយមានជ័យ បាត់ដំបង សៀមរាប និងពោធិសាត់។ ខេត្តពីរបន្ថែមទៀតត្រូវបានបញ្ចូលជាបន្តបន្ទាប់គឺឧត្តរមានជ័យនិងប៉ៃលិន។

ដឹកនាំការងារ នៃកម្មវិធីសិលា និងលេខាធិការដ្ឋានរបស់ខ្លួន ក្នុងការពិភាក្សាអំពីគោលនយោបាយដើម្បីរៀបចំគោលនយោបាយវិសហមជ្ឈការនៅក្នុងវិស័យកសិកម្ម ។ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទបានផ្តល់ការទទួលខុសត្រូវទៅដល់អង្គភាពគាំទ្រកម្មវិធី ADESS និងក្រុមការងារសិលាក្រសួងកិសកម្ម ។ ប៉ុន្តែក្រុមការងារ នៅក្រសួងកសិកម្មនេះមានសិទ្ធិអំណាចតិចតួច (គឺថា តួនាទីនិងការងាររបស់ខ្លួននៅមិនទាន់បានបង្កើតឡើង ជាផ្លូវការឬត្រូវបានទទួលស្គាល់នៅឡើយទេ គឺគ្រាន់តែជាផ្នែកនៃគំរោងមួយតែប៉ុណ្ណោះ) ហើយដូចនេះ ក្រសួងកសិកម្មនៅមិនទាន់មានភាពជាម្ចាស់/ទទួលខុសត្រូវ ចំពោះអង្គភាពនេះនៅឡើយ ។ នៅក្នុងក្រសួង រៀបចំដែនដី ការផ្តល់កម្មសិទ្ធិដីធ្លីត្រូវបានធ្វើវិសហមជ្ឈការទៅដល់កំរិតថ្នាក់ខេត្ត និងស្រុក និងការិយាល័យ ហើយគណៈកម្មការសូរិយោដីដែលទទួលខុសត្រូវក្នុងការដោះ ស្រាយជំលោះគឺស្ថិតនៅក្រោមកាតព្វកិច្ចរបស់ រដ្ឋាភិបាលមូលដ្ឋាន ។ ជាចុងក្រោយ នៅក្រសួងធនធានទឹក នៅក្នុងគំរោង APIP ការធ្វើឱ្យដំណើរការរៀបចំ ផែនការក្នុងការស្តារឡើងវិញនូវគំរោង ធារាសាស្ត្រខ្នាតតូចស្របគ្នាជាមួយនឹងដំណើរការរៀបចំផែនការ ថ្នាក់មូលដ្ឋានត្រូវបានលើកទឹកចិត្ត ។[៩១]

១៧៤. *ដូចនេះ គឺជាការសំខាន់ណាស់ថា វិធីសាស្ត្រសាកល្បងជាក់ស្តែងចំពោះវិសហមជ្ឈការបន្តដំណើរការទៅមុខ* ដើម្បីជំរាប់ប្រាប់អំពីការងាររៀបចំច្បាប់អង្គការ ។ ភ្នាក់ងាររដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយគួរបន្តសាកល្បង នូវវិធីសាស្ត្រដែលបានរៀបចំរួចហើយចំពោះវិស័យផ្សេងៗក្នុងការធ្វើវិសហមជ្ឈការ និងរៀបចំឯកសារអំពីមេរៀនបទពិសោធន៍កន្លងមកចំពោះទិដ្ឋភាពសំខាន់ៗនៃការគ្រប់គ្រងនិងរដ្ឋបាលតាមខេត្ត ដូចជាតួនាទីរបស់ អភិបាលខេត្ត ទំនាក់ទំនងរវាងអភិបាលខេត្ត មន្ទីរខេត្តក្រុង និងក្រសួងនានា ការបែងចែកមូលនិធិរវាងថ្នាក់ មជ្ឈឹមនិងខេត្ត ការទទួលខុសត្រូវចំពោះការរៀបចំបុគ្គលិក គណនេយ្យភាពចំពោះសមាជិកធម្មនុញ្ញថ្នាក់មូលដ្ឋាននិងតួនាទីរបស់ស្រុកនិឃុំ ។

១៧៥. មានអង្គភាពអន្តរក្រសួងចំនួនបីដោយមានការផ្តល់នូវការទទួលខុសត្រូវចំពោះ វិមជ្ឈការនិងវិសហមជ្ឈការ - គណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា - និងក្រសួងសំខាន់ពីរទៀតគឺ មហាផ្ទៃ និងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការសំរបសំរួលបានល្អរវាងអង្គភាពនិងភ្នាក់ងារទាំងនេះគឺជាការសំខាន់ណាស់ ។ ជាជំហានវិជ្ជមានមួយក្នុងទិសដៅនេះ ក្រុមដឹកនាំការងារផ្ទៃក្នុង នៅក្នុងក្រសួងមហាផ្ទៃបានបញ្ចប់នាពេល ថ្មីៗនេះនូវរបាយការណ៍មួយដែលមាន

[91] ក្រសួងអភិវឌ្ឍន៍ជនបទគឺជាករណីមួយខុសគ្នាបន្តិចទៅនឹងអណត្តិជាក់លាក់មួយសំរាប់ការអភិវឌ្ឍន៍ជនបទថ្នាក់មូលដ្ឋាន ។

បីភាគស្តីអំពីវិមជ្ឈការនិងវិសហមជ្ឈការ ហើយរំពឹងថានឹងរៀបចំនូវ ការពិភាក្សាមួយចំនួនអំពីបញ្ហាជាក់លាក់ខ្លះដែលជាជំហានដំបូងឆ្ពោះទៅការរៀបចំសេចក្តីព្រាងច្បាប់អង្គការ ស្តីពីរដ្ឋបាលនិងការគ្រប់គ្រងថ្នាក់ខេត្ត ដែលនឹងអាចដកស្រង់នូវមេរៀនបទពិសោធន៍ថ្មីៗ។ ក្រុមការងាររដ្ឋាភិបាល-អ្នកផ្តល់ជំនួយគួរតែចូលរួមយ៉ាងសកម្មក្នុងការធានាឱ្យបានគ្រប់គ្រាន់នូវការសំរបសំរួល។ ការបន្តនូវការចូលរួម និងការគាំទ្រដល់ដំណើរការវិមជ្ឈការនិងវិសហមជ្ឈការដោយភ្នាក់ងារសំខាន់ៗនៅជនបទ ដូចជាក្រសួងកសិកម្ម និងក្រសួងធនធានទឹក គឺក៏ជាការមួយដ៏សំខាន់ដើម្បីធានានូវភាព ជោគជ័យនៃការធ្វើកំណែទំរង់ដែលកំពុងដំណើរការ។

## ការប្រឆាំងអំពើពុករលួយ និងកំណែទំរង់ប្រព័ន្ធច្បាប់និងតុលាការ

១៧៦. *អំពើពុករលួយបន្ថែមទៅលើថ្លៃដើមចំណាយរបស់កសិករ និងគំរាមដល់ភាពប្រកួតប្រជែងនៃផលិតករជនបទនៅកម្ពុជា។* ប្រទេសកម្ពុជាប្រហែលមិនមែនជាករណីវិមិនធម្មតាដែលផលិតករជនបទរបស់ខ្លួនជួប ប្រទះនូវការបង់ថ្លៃឆ្លងកាត់មិនផ្លូវការក្នុងការដឹកជញ្ជូនកសិផលរបស់ខ្លួន ជួបប្រទះនូវការបង់ថ្លៃមិនផ្លូវការ ដើម្បីអាចចូលដល់ទីផ្សារសាធារណៈ និងចំណាយរដ្ឋបាលដែលមិនត្រូវបានអនុញ្ញាតិឱ្យមានក្នុងការទទួលបាន នូវសេវាសាធារណៈ ប៉ុន្តែទាំងនេះគឺជាការគួរឱ្យកត់សំគាល់ចំពោះបន្ទុកដ៏ធ្ងន់ធ្ងរដែលលេចឡើងនូវការចំណាយទាំងនេះ។ ការវិភាគខ្សែចង្វាក់តំលៃនៃការធ្វើម៉ាឃេតធីងនូវផលិតផលស្រូវបង្ហាញថា ការបង់ថ្លៃ មិនផ្លូវការបានបន្ថែមនូវតំលៃប្រហែល ១៤ដុល្លា (ពី១០% ទៅ ១៥%) ទៅលើថ្លៃអង្ករដែលដឹកដល់ទីផ្សារ។ ការសិក្សាស្រាវជ្រាវថ្មីៗដែលបានធ្វើឡើងដោយ CDRI ក៏បានគណនានូវថ្លៃមិនផ្លូវការដែលចំណាយដោយ អ្នកនាំត្រីចេញទៅលក់ក្រៅប្រទេស ក៏ដូចជាចំណាយផ្សេងៗមួយចំនួនទៀតនិងស្ថាប័នដែលពាក់ព័ន្ធក្នុងបញ្ហា នោះផងដែរ ( CDRI, 2003)។ សំរាប់កសិករការចំណាយមិនផ្លូវការទាំងនេះបន្ថយដោយផ្ទាល់នូវចំណូលពីការលក់ ហើយបណ្តាលឱ្យជ្រើសរើសជីវភាពរស់នៅពាក់កណ្តាលជីវព្រឹត្តិ។ ភាគច្រើននៃការអនុវត្តន៍ទាំង នេះបន្តកើតមានតាមរយៈភាពអត់ឱននិងវប្បធម៌មិនយោបាយក្នុងស្រុក។ ការអភិវឌ្ឍន៍សមាគមអ្នកផលិត នៅជនបទដ៏សកម្ម អាចបង្កើតឡើងនូវតុល្យភាពមួយដ៏សំខាន់ ដោយធ្វើការជាមួយរដ្ឋាភិបាលមូលដ្ឋានដើម្បី កំណត់និងដោះស្រាយនូវការលំបាកនៃការប្រព្រឹត្តទាំងនេះ។

១៧៧. *ក្រុមហ៊ុនជនបទមិនរៀបរយដែលមិនរកស៊ីធ្វើស្រែចំការកំណត់នូវការអនុវត្តន៍ដូចគ្នានេះដែរថាជាឧបសគ្គដ៏ចំបង* ប៉ុន្តែថានេះគឺជាឧបសគ្គដែលមិនសូវធ្ងន់ធ្ងរដូចអ្វីដែលគេរាយការណ៍ថាកើតមានចំពោះក្រុមហ៊ុនក្នុង វិស័យរៀបរយឡើយ។ មីក្រូសហគ្រាស និងសហគ្រាសធុនតូចទាំងនេះហាក់ដូចជាជៀស

ផុតនូវបញ្ហា និង ការចំណាយជាច្រើន ដែលត្រូវបានប្រឈមមុខដោយប្រតិបត្តិការដែលមានលក្ខណៈវៀបរយ ជាងដែលមាន អន្តរសកម្មភាពជាទៀតទាត់ជាមួយរដ្ឋាភិបាល។ ទិន្នន័យនៃការវាយតំលៃបរិយាកាសវិនិយោគបង្ហាញថា ក្រុមហ៊ុននៅជនបទ (ឧទាហរណ៍ អ្នកផ្គត់ផ្គង់ទឹកជនបទ អ្នកផ្គត់ផ្គង់អគ្គិសនីជនបទ) មានជួបឧបសគ្គ ដោយ ការសូកប៉ាន់តិចជាងក្រុមហ៊ុននៅតំបន់ទីប្រជុំជនដូចជា ក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ឬទេសចរណ៍។ ប្រសិនបើអំពើពុករលួយនៅក្នុងកំរិតដែលកំពុងកើតមាននៅតំបន់ទីប្រជុំជន ត្រូវបានដាក់បន្ទុកទៅលើកសិករ នោះកសិករពុំអាចដំណើរការរកស៊ីបានឡើយ។ ប្រភេទសំណូកដែលត្រូវបានចំណាយដោយវិស័យកាត់ដេរ (ជាង ១.០០០ ដុល្លារអាមេរិកក្នុងមួយកុងតែន័រ) អាចលើសពីកំរិតចំណេញនៃទំនិញកសិផលជាច្រើន។ ទាំងសំណូកនិងវិធានការណ៍រដ្ឋបាលនានាដែលធ្វើឱ្យអំពើពុករលួយកើតឡើង រួមគ្នាធ្វើឱ្យវិស័យនៅជនបទមានភាព មិនរៀបរយ។ ដូច្នេះ ស្ថានភាពនេះសមនឹងទទួលនូវការយកចិត្តទុកដាក់ ដើម្បីឱ្យសកម្មភាពមិនផ្លូវការដែល មានទំហំតូចមិនបោះបង់ចោលនូវកាលានុវត្តភាពសំរាប់ការពង្រីកនូវសកម្មភាព ដោយហេតុផលនៃចំណាយ ដែលគេអាចដឹងបានកាន់តែឃើញច្បាស់។

១៧៨. *ការកែលំអនូវការពង្រឹងការអនុវត្តច្បាប់តុលាការនិងវិធានច្បាប់ដែលគ្មានប្រសិទ្ធិភាពអាចជួយផ្តល់ផលប្រយោជន៍ដល់វិស័យសំខាន់ៗនានាសំរាប់សេដ្ឋកិច្ចជនបទ*។ ដូចដែលបានពិភាក្សាខាងលើ ភាពទន់ខ្សោយនៃ ប្រព័ន្ធច្បាប់និងតុលាការត្រូវបានយល់ដឹងដោយធនាគារថាជាឧបសគ្គដ៏ធំបងក្នុងការពង្រីកភាពគ្រប់ដណ្តប់នៃ សេវាកម្មទាំងភូមិសាស្ត្រ-នៅតំបន់ជនបទ និងទាំងចរិតលក្ខណៈនៃអតិថិជន (សហគ្រាសធុនតូចនិងមធ្យម និងមីក្រូសហគ្រាស)។ ការខ្វះខាតនូវវិធានច្បាប់ និងការពង្រឹងការអនុវត្តច្បាប់តុលាការ រួមចំណែកដល់ការ យល់ឃើញរបស់អ្នកវិនិយោគិននូវបរិយាកាសនៃការធ្វើអាជីវកម្មដែលមានលក្ខណៈមិនអំណោយផល។ ការវាយតំលៃបរិយាកាសវិនិយោគ (ជាសេចក្តីព្រាង) បង្ហាញថាស្ថាប័ននិងភ្នាក់ងារសាធារណៈមួយចំនួនដែល ត្រូវបានវាយតំលៃអំពីសុចរិតភាពរបស់ខ្លួននោះ ប្រព័ន្ធតុលាការត្រូវបានវាយតំលៃទាបជាងគេបំផុត។ នៅពេលដែលសេដ្ឋកិច្ចរីកចំរើននិងមានលក្ខណៈរៀបរយ ប្រព័ន្ធតុលាការនឹងកាន់តែមានសារៈសំខាន់ឡើងៗ ដែលជាមធ្យោបាយមួយដើម្បីបង្ការនូវសិទ្ធិសេដ្ឋកិច្ចនៃការធ្វើអាជីវកម្ម និងលើកដំកើងនូវកិច្ចសន្យា។

១៧៩. ជាងនេះទៅទៀត ដោយមានប្រជាជនបីភាគបួនដែលពឹងផ្អែកទៅលើធនធានធម្មជាតិសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ជំលោះតែងតែកើតមានឡើងនៅជុំវិញការប្រើប្រាស់នូវធនធានធម្មជាតិ ប៉ុន្តែបញ្ហានេះ មិនអាចដោះស្រាយបានដោយសារការខ្វះនូវច្បាប់ដែលមានលក្ខណៈច្បាស់លាស់ និងអាចបង្ខំអនុវត្តបាន

ហើយពីព្រោះតែផលចំណេញ ដែលបានមកពីភាពបត់បែននៃការអនុវត្តន៍ច្បាប់អាចមានទំហំធំធេងចំពោះក្រុមមនុស្សដែលស្ថិតនៅក្នុងតួនាទីមានអំណាច។ ការប្រែប្រួលនៃគោលនយោបាយរបស់រដ្ឋាភិបាលអំពីការផ្តល់នូវសមប្បទានជលផលនិងព្រៃឈើ គឺជាភស្តុតាងនៃអំណាចសេដ្ឋកិច្ចនិងនយោបាយដែលជាអ្នកដើរតួកន្លងមកដែលធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលំទូលាយ និងសមធម៌។ ដោយធ្វើដំណើរទៅមុខទៀត តម្លាភាពក្នុងការរៀបចំគោលនយោបាយ និងការរៀបចំនិងការប្រើប្រាស់នូវយន្តការអនុវត្តន៍នានាគឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធានានូវកម្មសិទ្ធិទ្រព្យសម្បត្តិ ដែលនឹងមានវឌ្ឍនៈភាពជាមួយនឹងការអនុវត្តន៍ច្បាប់តុលាការដើម្បីបង្ការនូវសិទ្ធិទាំងនោះ។

១៨០. *ភាពជឿនលឿនត្រូវបានធ្វើឡើងក្នុងការធ្វើកំណែទំរង់ប្រព័ន្ធច្បាប់និងតុលាការ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្សេងៗនៃវិស័យនានានៅជនបទ។* យុទ្ធសាស្រ្តកំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការរបស់រដ្ឋាភិបាលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅក្នុងខែមិថុនាឆ្នាំ២០០៣ ហើយការងារកំពុងតែដំណើរការទៅមុខដើម្បីធ្វើអាទិភាពកម្មការធ្វើអន្តរាគមន៍លើផែនការសកម្មភាព កំណែទំរង់ប្រព័ន្ធច្បាប់និងតុលាកាដើម្បីអនុវត្តយុទ្ធសាស្រ្តនេះ។ ការខិតខំប្រឹងប្រែងជាច្រើនគឺត្រូវការជាចាំបាច់ដើម្បីបំពេញឱ្យកិច្ចអភិវឌ្ឍន៍ទាំងនេះ។ ជាឧទាហរណ៍ កិច្ចសន្យាធ្វើស្រែចំការលើកឡើងមិនជៀសបាននូវបញ្ហាធំៗនៅកម្ពុជាអំពីការខ្វះខាតនូវភាពដែលអាចព្យាករណ៍បាននៃកិច្ចសន្យា ដែលជាលក្ខខណ្ឌលើកកំពស់បរិយាកាសវិនិយោគជនបទ និងការផ្តល់អំណាចដល់អ្នកក្រីក្រជនបទនៅកម្ពុជា។ ភាពចាំបាច់សំរាប់ធ្វើឱ្យប្រសើរឡើងនូវភាពដែលអាចព្យាករណ៍បាននៃកិច្ចសន្យានឹងជាប់ពាក់ព័ន្ធ នឹងភាពស្មុគ្រស្មាញនៃសំណុំសកម្មភាពនានា ដែលបានរៀបរាប់នៅក្នុង ប្រអប់លេខ ៦ ខាងក្រោម។

១៨១. ការស្រាវជ្រាវនិងការវិភាគជាច្រើនគឺត្រូវការជាចាំបាច់ដើម្បីកំណត់នូវកម្មវិធីកំណែទំរង់ដែលអាចផ្តល់នូវទំងន់សមស្របមិនត្រឹមតែដល់ផ្នែកផ្គត់ផ្គង់នៃសេវានានាតែប៉ុណ្ណោះទេ (រួមមាន ដំណើរការនៃការរៀបចំ ច្បាប់ សេវាដោះស្រាយវិវាទនិងសេវាចុះបញ្ជីការិយាល័យ) ប៉ុន្តែថែមទាំងដល់ផ្នែកតំរូវការសេវានានាផងដែរ រួមមាន ការពិគ្រោះយោបល់សង្គមស៊ីវិល ការគាំទ្រដល់ជំនួយផ្នែកច្បាប់ និងក្រុមសិទ្ធិស៊ីវិលនិងលទ្ធភាព ទទួលបាននូវយុត្តិធម៌។ ឧទាហរណ៍ ជាពិសេសដោយពាក់ព័ន្ធនឹងការគោរពនូវគំនិតផ្តួចផ្តើមខាងផ្នែកតំរូវការ គឺជាការសំខាន់ណាស់ដែលត្រូវដឹងថា ទំរង់ជាលក្ខណៈប្រពៃណីជាច្រើនរបស់កម្ពុជាក្នុងការដោះស្រាយវិវាទនៅជនបទ ក៏ដូចជាកិរិតដែលសហគមន៍ជនបទត្រូវឬអាចត្រូវបានរៀបចំដើម្បីផ្តល់ (និងត្រូវបានមើលឃើញថាមានសមត្ថភាព/ចាប់អារម្មណ៍ក្នុងការផ្តល់) ធាតុចូលអំពីគំនិតផ្តួចផ្តើមនានា។ ច្បាស់

ណាស់ ច្បាប់និងសិទ្ធិ នៅកម្ពុជានឹងនៅតែពុំមានន័យទាល់តែសោះប្រសិនបើប្រជាជនកម្ពុជាមិនអាចយល់ដឹង បង្ខំឱ្យអនុវត្ត និងទទួលអត្ថប្រយោជន៍ពីច្បាប់និងសិទ្ធិទាំងនោះតាមរយៈការទទួលបាននូវភាពយុត្តិធម៌។ លើសពីនេះទៀត ទំងន់ដីសមស្របក៏ត្រូវតែផ្តល់ជូនផងដែរដល់គំនិតផ្តួចផ្តើមនានា ដែលក្នុងករណីណាមួយនោះផ្តល់ដល់ទាំង ទិដ្ឋភាពផ្គត់ផ្គង់និងតំរូវការ ហើយហៅបញ្ហានេះថា "បរិស្ថានអំណោយផល "រួមមានការអប់រំជនបទ/សា-ធារណៈអំពីបញ្ហានានាទាក់ទងនឹងសិទ្ធិស៊ីវិលនិងទ្រព្យសម្បត្តិ និងការផ្តល់នូវសេវាជំនួយផ្នែកច្បាប់ក្នុងបញ្ហា ដីធ្លី និងមិនមែនព្រហ្មទណ្ឌ។

*ប្រអប់ទី ៧: កែលំអភាពដែលអាចព្យាករណ៍បាននៃកិច្ចសន្យា*

- ទីមួយ. ច្បាប់កិច្ចសន្យាត្រូវការជាចាំបាច់ (គឺថា វិធាននានាដែលសង្គមកម្ពុជាទទួលយក ដែលជាលទ្ធផលនៃការមានកាលានុវត្តភាពក្នុងការកែប្រែ ដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចជា តើអ្វីដែលត្រូវមាននៅក្នុងកិច្ចសន្យាដើម្បីឱ្យមានសុពលភាព តើបញ្ហាអ្វីដែលមិនមែនជាប្រធានបទនៃកិច្ចសន្យា។ល។)។ ទន្ទឹមនឹងច្បាប់កិច្ចសន្យាលេខ ៣៦ នៃឆ្នាំ ១៩៨៨ ដែលកំណត់នូវក្របខ័ណ្ឌដ៏ទូលំទូលាយសមស្របមួយ គ្មានមាត្រាណាមួយនៃច្បាប់ត្រូវបានបកស្រាយដោយតុលាការកម្ពុជាឡើយ ហើយច្បាប់នេះគឺនឹងត្រូវបានជំនួសដោយការអនុម័តក្រមស៊ីវិលដែលសេចក្តីព្រាងក្រមនេះចាំបាច់ត្រូវចែកចាយយ៉ាងទូលំទូលាយជាមួយនឹងសង្គមស៊ីវិលនិងផ្នែកឯកជនដើម្បីពិនិត្យឡើងវិញនិងផ្តល់យោបល់។
- ទីពីរ ច្បាប់កិច្ចសន្យាត្រូវតែត្រូវបានបោះពុម្ភ និងផ្សព្វផ្សាយឱ្យបានសមស្រប និងទូលំទូលាយ។ ប៉ុន្តែការបោះពុម្ភផ្សាយនូវច្បាប់ណាមួយនៅប្រទេសកម្ពុជានៅតែជាបញ្ហានៅឡើយ ក៏ដូចជាការផ្សព្វផ្សាយទូលំទូលាយដែរ។
- ទីបី ច្បាប់នេះត្រូវតែត្រូវបានយល់ដឹង និងអនុវត្តជាទូទៅ ទីមួយដោយចៅក្រមនិងអ្នកផ្តល់យោបល់ផ្នែកច្បាប់ ទីពីដោយអ្នកដែលចាប់អារម្មណ៍ក្នុងកិច្ចសន្យា។ ប៉ុន្តែ ការបង្ហាត់បង្រៀនអំពីច្បាប់កម្ពុជានៅតែជាលក្ខណៈមូលដ្ឋាននៅឡើយចំពោះការអនុវត្តន៏របស់ចៅក្រមនិងអ្នកញផ្តល់យោបល់ផ្នែកច្បាប់ មិនទាន់រាប់ទាំងអ្នកដែលចាប់អារម្មណ៏ក្នុងកិច្ចសន្យាផង រួមមានអ្នករកទទួលទានផ្នែកកសិកម្ម។
- ទីបួន នៅពេលមានបទល្មើសកិច្ចសន្យានិងច្បាប់កិច្ចសន្យាកើតឡើង កិច្ចសន្យានិងច្បាប់ត្រូវតែត្រូវបានយកមកអនុវត្តនៅក្នុងលក្ខណៈស៊ីសង្វាក់និងមិនលំអៀង ដោយតុលាការដែលមានសមត្ថភាព ឬយន្តការដោះស្រាយវិវាទផ្សេងៗ។ និង

- ទីប្រាំ ការវិនិច្ឆ័យរបស់តុលាការនៅក្នុងបញ្ហាទាំងអស់នោះត្រូវតែសរសេរចងក្រងឡើង ដោយផ្អែកទៅលើច្បាប់ សំរាប់បោះពុម្ភផ្សាយទូលំទូលាយ និងត្រូវមានការប្តឹងឧទ្ធរណ៍ចំពោះសំណើនានានៃការអនុវត្តន៍ច្បាប់របស់តុលាការជាន់ទាប ត្រូវតែបង្ខំឱ្យអនុវត្តប្រកបដោយមធ្យ័តនិងប្រសិទ្ធិភាព។ ការវិនិច្ឆ័យនៅក្នុងរឿងក្តីស៊ីវិលនានា មិនមានលក្ខណៈស្តង់ដារ៍ មិនតាមការវិនិច្ឆ័យមុនៗ ជាទូទៅមិនមានការពិចារណាហេតុផលត្រឹមត្រូវ (គឺបានន័យថា សឹងតែមិនយោងទៅនឹងថាតើច្បាប់អនុវត្តទៅនឹងអ្វីដែលកើតមានឡើងជាក់ស្តែងយ៉ាងដូចម្តេច) និងមិនត្រូវបានបោះផ្សាយ ហើយជាញឹកញាប់មិនត្រូវបានបង្ខំឱ្យអនុវត្ត។ ដូច្នេះក្នុងការអនុវត្តន៍ជាក់ស្តែង ការបង្ខំអនុវត្តកិច្ចសន្យាផ្អែកយ៉ាងធំទៅលើការធានាឱ្យគ្រប់ភាគីទាំងអស់ទទួលបានអត្ថប្រយោជន៍គ្រប់គ្រាន់ ដើម្បីឱ្យមានប្រយោជន៍ទៅវិញទៅមកដើម្បីលើកកំពស់លក្ខខណ្ឌកិច្ចសន្យាទាំងអស់។

## ការអភិវឌ្ឍន៍ផ្នែកឯកជន និងសេដ្ឋកិច្ចជនបទមិនមែនកសិកម្ម

១៨២. *មានការទទួលស្គាល់កាន់តែខ្លាំងឡើងនូវតួនាទីសេដ្ឋកិច្ចមិនមែនកសិកម្មក្នុងការអភិវឌ្ឍន៍ជនបទនៅកម្ពុជា។* ការកើនឡើងយ៉ាងលឿនក្នុងផ្នែកកម្មន្តសាលមិនបានទទួលជោគជ័យក្នុងការបង្កើតការងារថ្មីៗឡើយ។ ភាគច្រើននៃប្រជាជន ០,២៥លាននាក់ដែលកំពុងបន្ថែមចូលក្នុងកំលាំងពលកម្មជារៀងរាល់ឆ្នាំ ត្រូវបានស្រូបបញ្ចូលទៅក្នុងវិស័យកសិកម្ម និងផ្នែកមិនរៀបរយដែលផលិតភាពពលកម្មនិងក៏រិតចំណូលមានទាបជាងនៅក្នុងផ្នែកកម្មន្តសាលនិងសេវាកម្ម។ ទោះបីជាមានសារៈសំខាន់ក្នុងការទាញយកអត្ថប្រយោជន៍អំពីសក្តានុពលកំណើនផលិតភាព និងពិពិធកម្មកសិកម្មក៏ដោយ ក៏នៅក្នុងរយៈពេលវែង ផ្នែកកសិកម្មនឹងជួបប្រទះកាន់តែខ្លាំងឡើងនូវគុណវិបត្តិនៃសមត្ថភាពរបស់ខ្លួនក្នុងការបង្កើតការងារ។ ដូច្នេះ ការបង្កើតកាលានុវត្តភាពការងារក្រៅពីស្រែចំការ គឺជាលទ្ធភាពមួយដ៏សំខាន់ក្នុងកាត់បន្ថយភាពក្រីក្រនិងកាត់បន្ថយកំណើនគំលាតចំណូលជនបទ-ទីប្រជុំជននៅកម្ពុជា។ កាលានុវត្តភាពការងារក្រៅពីធ្វើស្រែចំការនៅជនបទអាចបានមកពីៈ

- ការធ្វើពាណិជ្ជកម្មភាវូបណីយកម្មនៃវត្ថុធាតុចូល ចូលក្នុងផ្នែកកសិកម្ម ព្រៃឈើ និងជលផល។
- អភិវឌ្ឍន៍ ការកែច្នៃ ការរក្សាទុក ការដឹកជញ្ជូន ខ្សែចង្វាក់ទិញលក់ពីរបងវាលស្រែរហូតដល់ចំណុចលក់ចេញក្នុងស្រុក ឬនាំចេញ។ និង
- អភិវឌ្ឍន៍ឧស្សាហកម្មកម្មន្តសាលនិងសេវាកម្មអតិពលកម្ម។

១៨៣. ការធ្វើពិពិធកម្មនៃប្រភពចំណូលជនបទក្រៅពីស្រែចំការនៃផ្នែកផ្សេងៗ ទំហំនៃរបៀបវារៈដែលនឹងដោះស្រាយដោយជោគជ័យនូវឧបសគ្គនានាដែលប្រឈមមុខនឹងការអភិវឌ្ឍន៍ដ៏លឿននៃ NFRE និងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗដែលមានអណត្តិដែលពឹងផ្អែកទៅលើផ្នែកខ្លះនៃរបៀបវារៈនេះបង្ហាញចរិតរួមនៃបញ្ហាប្រឈមនៃការអភិវឌ្ឍន៍។

១៨៤. ការសិក្សាស្រាវជ្រាវថ្មីៗបង្ហាញថាអន្តរកាលឆ្ពោះទៅជីវភាពរស់នៅដែលផ្អែកលើសកម្មភាពមិនមែនធ្វើស្រែចំការនេះគឺកំពុងប្រព្រឹត្តទៅបានល្អ ដែលទោះបីជាមានកាលានុវត្តភាពតិចតួចក៏ដោយនាពេលបច្ចុប្បន្ននេះ ប្រឈមមុខនឹងទស្សនៈជាប្រពៃណីដែលយល់ថាចំណូលជនបទភាគច្រើនលើសលុបបានមកពីការធ្វើស្រែ។ លើសពីនេះទៅទៀត នឹងមានសំពាធទៅលើសេដ្ឋកិច្ចដែលមិនផ្អែកលើការធ្វើស្រែចំការក្នុងការដើរតួ នាទីកាន់តែធំជាងមុនដើម្បីបង្កើនកំរិតគ្រួសារជនបទដែលគ្មានដីធ្លី និងដីពុំមានជីជាតិ។

១៨៥. *ទោះបីជាមានសារៈសំខាន់អំពីចំណូលមិនមែនស្រែចំការក៏ដោយ គេមានការដឹងឮតិចតួចណាស់អំពីលក្ខណៈពិតប្រាកដនៃសកម្មភាពទាំងនេះ*។ បច្ចុប្បន្ននេះ កាលានុវត្តភាពពលកម្មដែលទទួលប្រៀវត្សរ៍ភាគច្រើនគឺមាននៅក្នុងផ្នែកមិនរៀបរយ ហើយដូច្នេះមានការលំបាកក្នុងការវាស់វែងនិងចាត់ជាផ្នែកជាក្រុម។ ប៉ុន្តែអ្វីដែលច្បាស់នោះ គឺពិពិធកម្មនៃប្រភពការងារ និងប្រភេទនៃមីក្រូសហគ្រាស។ ប្រហែលមួយភាគបីនៃចំណូលដែលជាប្រៀវត្សរ៍ដែលផ្អែកលើកសិកម្ម ក៏គឺមានលក្ខណៈផ្អែកតាមរដូវខ្លាំងផងដែរ (Helmers et al, 2003)។ សំណង់គឺជាប្រភពធំទីពីរ (ប្រហែល ២០%) ដោយមានផ្នែកដែលនៅសល់មាន ការដឹកជញ្ជូន ការងាររោងចក្រ សេវាកម្ម (មិនបញ្ជាក់) និងការងាររដ្ឋាភិបាល។ សំរាប់មីក្រូអាជីវកម្ម រូបភាពមានលក្ខណៈផ្សេងៗគ្នា: ការកែឆ្នៃចំណីអាហារសំរាប់លក់ និងការផ្គត់ផ្គង់សេវាកម្ម (មិនបញ្ជាក់)ទាំងពីរមានចំណែកប្រហែលពាក់កណ្តាលអាជីវកម្មនេះ ហើយផ្នែកនៅសល់រួមមាន ការលក់ដូរតូចតាចនៃកសិផលត្រីនិងបសុសត្វ និងការផលិតនិងលក់ទំនិញសិប្បកម្ម។

១៨៦. *ឧបសគ្គចំបងចំពោះការអភិវឌ្ឍន៍ការធ្វើអាជីវកម្មក្រៅពីធ្វើស្រែចំការជនបទ ពឹងផ្អែកលើទំហំ និងទីតាំង និងភាពចាំបាច់ដើម្បីធ្វើការវិភាគបានល្អ*។ ប្រទេសកម្ពុជាគួរតែស្ថិតក្នុងជំហរមួយល្អដើម្បីអភិវឌ្ឍសកម្មភាពអតិពលកម្ម ប៉ុន្តែទំរង់ខ្លះៗទៀតនៃភាពលំអៀងក្នុងការរៀបចំគោលនយោបាយសាធារណៈកំពុងប្រព្រឹត្តទៅដោយប្រឆាំងទៅនឹងការអភិវឌ្ឍន៍នៃសកម្មភាពទាំងនេះ។ ការបែងចែកកើតមានរវាងសហគ្រាសធុនតូចនិងមធ្យម ដោយមាននិយោជិកទទួលប្រៀវត្សរ៍ដែលដំណើរការភាគច្រើននៅទីប្រជុំជន ជនបទ

តូច១[92] និងមីក្រូសហគ្រាសក៏រិតភូមិដែលមានលក្ខណៈទៅតាមរដូវនិងមិនរៀបរយ។ ការបែងចែកនេះមានសារៈ សំខាន់ណាស់នៅពេលគិតពិចារណាពីការអភិវឌ្ឍន៍ផ្នែកនេះ ដូចដែលការសិក្សាស្រាវជ្រាវបានបង្ហាញថា សហគ្រាសទាំងពីរប្រទេសនេះមានឧបសគ្គខុស១គ្នា។ ការសិក្សាស្រាវជ្រាវដែលកំពុងដំណើរការអំពីបរិយាកាសវិនិយោគនៅកម្ពុជា បំភ្លឺច្បាស់អំពីឧបសគ្គនានាចំពោះការធ្វើអាជីវកម្មសហគ្រាសធុនតូចនិងមធ្យមរៀបរយ នៅតំបន់ជនបទនៃប្រទេស។

១៨៧. ក្រៅពីឧបសគ្គដែលពាក់ព័ន្ធនឹងអភិបាលកិច្ចដែលបានពិភាក្សាលើកមុន ឧបសគ្គសំខាន់១ដទៃទៀតមាន ចោរកម្មនិងភាពច្របូកច្របល់ ភាពមិនច្បាស់លាស់នៃគោលនយោបាយសេដ្ឋកិច្ច អស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការប្រព្រឹត្តិប្រឆាំងនឹងភាពប្រកួតប្រជែងនិងមិនយុត្តិធម៌។ គួរឱ្យភ្ញាក់ផ្អើលដែរ លទ្ធភាពទទួលបាននូវអគ្គិសនី ការដឹកជញ្ជូន និងសេវាហិរញ្ញវត្ថុមិនត្រូវបានលើកឡើងដោយអ្នកចូលរួមឆ្លើយនឹងអង្កេតថាជា ឧបសគ្គធ្ងន់ធ្ងរនោះទេ[93] ទោះបីជាប្រព័ន្ធទីផ្សារដែលមានភាពខ្សោយក៏ដោយ រួមមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងសេវាកម្មដឹកជញ្ជូនត្រូវបានរកឃើញជាញឹកញាប់ថាសំខាន់ និងមិនបំពេញបានតំរូវការភាគច្រើន ចំពោះឥណទានសំរាប់គោលដៅផលិតភាពនៅតំបន់ជនបទនិងជាពិសេសនៅភូមិនានា។ ជាទូទៅ ប្រព័ន្ធទីផ្សារនៅតំបន់ជនបទត្រូវបានបង្ហាញដោយសមាហរណកម្មទីផ្សារក៏រិតទាប ការប្រកួតប្រជែងក្នុងផ្នែកជាក់ លាក់ណាមួយមានភាពផុយស្រួយ ជាញឹកញាប់ជាមួយនឹងហានិភ័យនៃក្រុមហ៊ុនរកស៊ីផ្តាច់មុខនៅមូលដ្ឋាន ហើយចំណាយម៉ាឃេតធីងនិងប្រតិបត្តិការខ្ពស់។ ការសិក្សាស្រាវជ្រាវក៏បានបំភ្លឺផងដែរពីសារៈសំខាន់នៃភាព នៅជិតផ្លូវដឹកជញ្ជូន ដែលជាកត្តាកំណត់មួយនៃទំហំនិងភាពខ្លាំងនៃសកម្មភាពមិនមែនស្រែចំការនៅក្នុងការ រកចំណូលគ្រួសារជនបទ ដោយបង្ហាញប្រាប់ថា នៅពេលដែលឧបសគ្គការដឹកជញ្ជូនមិនត្រូវបានគេយល់ថាជា ឧបសគ្គជាអាទិភាពបន្ទាន់មួយចំពោះសកម្មភាពទាំងនោះ ប៉ុន្តែគឺកាលានុវត្តភាពពលកម្មផ្អែកលើបៀវត្សរ៍ និង/ឬ កាលានុវត្តភាពអាជីវកម្មមានទំនាក់ទំនងទៅនឹងការចូលដល់ទីផ្សារឬសហគ្រាសដែលហួសពីតំបន់ ជុំវិញភូមិ។ ភាគច្រើន (៨១%) នៃសកម្មភាពអាជីវកម្មដោយគ្រួសារនៅក្នុងភូមិគឺស្ថិតនៅក្នុងភូមិ ឬឃុំ ហើយពាក់កណ្តាលនៃពលកម្មផ្អែកលើបៀវត្សរ៍គឺស្ថិតនៅក្នុងភូមិឬឃុំតែមួយ បានន័យថា ៥០%ទៀតទាម ទារការធ្វើដំណើរ/ចាកស្រុកទៅកន្លែងផ្សេងទៀតនៅក្នុងស្រុក ខេត្ត ឬប្រទេស (និងម្តងម្កាលទៅប្រទេស ជិតខាង)។

---

[92] ប៉ុន្តែ ទាំងនេះមានទំហំតូចណាស់ដោយមានជាង ៨០% ជួលនិយោជិកតិចជាង១០នាក់ ហើយសហគ្រាសទាំងអស់នោះផ្តល់ទំនិញ និងសេវាកម្មសំរាប់ទីផ្សារក្នុងស្រុកតែប៉ុណ្ណោះ។

[93] មានការពន្យល់មួយថា អាជីវកម្មដែលមានសព្វថ្ងៃនេះគឺជាក់ស្តែងជាប់ពាក់ព័ន្ធនឹងសកម្មភាពមិនសូវចំណុះនឹងកត្តាទាំងនោះ។

១៨៨. *រដ្ឋាភិបាលពុំមានគោលនយោបាយច្បាស់លាស់សំរាប់ជំរុញសហគ្រាសនិងឧស្សាហកម្មជនបទមិន-មែនស្រែចំការ*។ សហគ្រាសជនបទមិនមែនស្រែចំការមិនត្រូវបានលើកឡើងនៅក្នុងផែនការសេដ្ឋកិច្ចសង្គម-កិច្ច ៥ឆ្នាំលើកទីពីរទេ ហើយគ្រាន់តែលើកឡើងបន្តិចបន្តួចនៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ អ្នក រៀបចំគោលនយោបាយបានផ្តល់ការយកចិត្តទុកដាក់បន្តិចបន្តួចដល់ផ្នែកក្រៅពីស្រែចំការ ដែលបង្ការដល់ការឆ្លើយតបជាទូទៅចំពោះបញ្ហាប្រឈមនៃផ្នែកនេះ។ ជាជំនួសវិញ គំនិតផ្តួចផ្តើមនានាខិតខំដោះស្រាយនូវសមាសធាតុផ្សេងៗគ្នានៃបញ្ហា ប៉ុន្តែសមាសធាតុនិមួយៗទំនងជាមិនរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សកម្មភាពក្រៅពីស្រែចំការនៅជនបទឡើយ។

១៨៩. *ករណីជាក់លាក់នៃកសិ-អាជីវកម្មចាំបាច់ធ្វើការវិភាគថែមទៀត*។ ទន្ទឹមនឹងកសិ-អាជីវកម្មគួរតែបានផលចំណេញពីអត្ថប្រយោជន៍ធៀបនៅកម្ពុជា ដែលផ្អែកលើការចំណាយពលកម្មទាប និងលទ្ធភាពទទួលបាននូវធនធានធម្មជាតិ និងដីផលិតកម្ម ចរិតលក្ខណៈជីវព្រឹត្តិនៃកសិកម្មដែលបង្ហាញដោយផលិតភាពទាបនិងអតិរេកទីផ្សារទាប រារាំងដល់សក្តានុពលសំរាប់ការកែឆ្នៃដែលផ្តល់តំលៃបន្ថែមនៅក្នុងផ្នែកនេះ។ ឧបសគ្គចំពោះការអភិវឌ្ឍន៍កសិ-អាជីវកម្ម កំពុងតែផ្តោតការយកចិត្តទុកដាក់ទាំងក្នុងរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយដោយគិតគូរអំពីគុណវិបត្តិជាសក្តានុពលដែលមានន័យចំពោះសេដ្ឋកិច្ចជនបទ។ បន្ថែមទៅលើឧបសគ្គបរិយា-កាសអាជីវកម្មទូទៅ ការសិក្សាដំបូងនានាចង្អុលបង្ហាញ ភាពខ្វះខាតនូវលទ្ធភាពទទួលបានហិរញ្ញវត្ថុ (ឧទាហរណ៍ សំរាប់ការលើកកំពស់បច្ចេកវិជ្ជា) ភាពខ្វះខាតពត៌មានអំពីតំរូវការទីផ្សារ និងភាពខ្វះខាតនូវជំនាញអាជីវកម្មមូលដ្ឋាន។ ដោយសារមានផលប៉ះពាល់ជាសក្តានុពលទៅលើចំណូលគ្រួសារជនបទ ការសិក្សាស្រាវជ្រាវបន្ថែមទៀតគឺត្រូវការជាចាំបាច់ដើម្បីវិភាគនូវតំរូវការជាក់លាក់នៃផ្នែកនេះកាន់តែល្អថែមទៀត។

១៩០. *ផ្នែកមួយទៀតដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពីអ្នករៀបចំគោលនយោបាយគឺការចូលរួមរបស់វិស័យឯកជននៅក្នុងហេដ្ឋារចនាសម្ព័ន្ធ*

១៩១. យុទ្ធសាស្ត្រវិស័យឯកជនរបស់កម្ពុជាមួយកំពុងរៀបចំឡើងដើម្បីដោះស្រាយនូវសកម្មភាពទូទៅចាំបាច់ ដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍វិស័យឯកជន។ ការបញ្ចប់ការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្រនេះនឹងមានសារៈសំខាន់យ៉ាងខ្លាំង ដោយមានការបញ្ចូលគ្រប់គ្រាន់នូវសេចក្តីត្រូវការសហគ្រាសជនបទ (ឧទាហរណ៍ ហិរញ្ញវត្ថុ ហេដ្ឋរចនាសម្ព័ន្ធ ជំនាញ) ដើម្បីចាប់ផ្តើមបំភ្លឺឱ្យបានច្បាស់អំពីមូលដ្ឋានវិនិច្ឆ័យចំពោះសកម្មភាពជា អាទិភាពដែលចាំបាច់ត្រូវចាប់ផ្តើមកើតឡើងស្របគ្នា។ ជំហានបន្ទាប់ដែលមានប្រយោជន៍

អាចចាប់ផ្តើម អនុវត្តជំនួយបច្ចេកទេសដោយមានការសិក្សាស្រាវជ្រាវជាជំនួយ អាចរៀបចំផែនការ សកម្មភាពនានាដែល អាចជំរុញឱ្យមានបរិស្ថានទ្រទ្រង់អាជីវកម្មជនបទ និងជួយបង្កើនបច្ចេកវិជ្ជា ជំនាញ អាជីវកម្មនិងបច្ចេកទេស និងម៉ាឃេតធីង ការជាវផលិតផល និងការលំបាកហិរញ្ញប្បទាន ក៏ដូចជាបញ្ហាទីតាំង ។

***តារាងទី ៨: វិស័យដែលកំណែទំរង់អន្តរវិផ្នែកមានឥទ្ធិពលទៅលើសេដ្ឋកិច្ចជនបទ-ឧទាហរណ៍ជ្រើសរើស***

| កំណែទំរង់ សេវាស៊ីវិល | វិមជ្ឈការ & វិសហមជ្ឈការ | កំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ | ប្រយុទ្ធអំពើពុករលួយ | ការកែលំអ បរិយាកាស វិនិយោគ |
|---|---|---|---|---|
| *ដីធ្លី* | | | | |
| កែលំអសេវាចុះបញ្ជីដីធ្លី<br><br>ចិរភាពរដ្ឋបាល ដីធ្លី | កែលំអសេវាចុះ បញ្ជីដីធ្លី<br><br>កែលំអផែនការប្រើប្រាស់ដីធ្លី | កែលំអ និងការបង្ខំអនុវត្តកិច្ចសន្យា ដោះស្រាយវិវាទ | កែលំអដំណោះស្រាយជំលោះដីធ្លី<br><br>តម្លាភាពនិងគណនេយ្យភាពនៃភ្នាក់ងារដីធ្លី | លទ្ធភាពទទួលបានឥណទាន<br><br>ការវិនិយោគក្នុងដីធ្លីកែលំអ |
| *ជលផល* | | | | |
| បណ្តុះបណ្តាលផ្តល់បៀវត្សរ៍មន្ត្រីជលផល<br><br>កែលំអរដ្ឋបាលជលផល | កែលំអការគ្រប់គ្រងមូលដ្ឋាន និងសហគមន៍នៃធនធាន ជលផល | ពង្រឹងការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិជលផល<br><br>លទ្ធភាពទទួលបានធនធានសំរាប់សហគមន៍ | កាត់បន្ថយវិវាទជលផល<br><br>ពង្រីកការអនុវត្តន៍ច្បាប់និងបទបញ្ញត្តិ<br><br>លទ្ធភាពទទួលបានធនធានសំរាប់សហគមន៍ | វិនិយោគឯកជនក្នុងមូលដ្ឋានសំភារៈ រក្សាទុកក្លាសេ និងកែឆ្នៃ<br><br>ភាពប្រកួតប្រជែងនៃការនាំត្រីចេញ |

| | | | | |
|---|---|---|---|---|
| *ការគ្រប់គ្រងផ្នែកកសិកម្ម* | | | | |
| កែលំអការបែងចែកធនធាន<br><br>កែលំអសេវាសាធារណៈ | កែលំអផែនការអភិវឌ្ឍន៏កសិកម្មតំបន់និងមូលដ្ឋាន | អភិវឌ្ឍន៏ការធ្វើកសិកម្មដែលមានកិច្ចសន្យា<br><br>លទ្ធភាពទទួលបានឥណទានជនបទ | កែលំអការប្រមូលប្រាក់ឈ្នួលធ្វើអាជីវកម្ម | កាអភិវឌ្ឍន៏កសិអាជីវកម្ម |
| *សេវាកសិកម្ម* | | | | |
| | សេវាអូសទាញដោយតំរូវការ | កាលានុវត្តភាពសំរាប់ធ្វើកិច្ចសន្យាសេវាកម្ម | កែលំអការចែកចាយសេវាកម្ម | ការផ្តល់សេវាកសិកម្មដោយផ្នែកឯកជន |
| *ការធ្វើពាណិជ្ជកម្មកសិកម្ម* | | | | |
| ភ្នាក់ងារសំរបសំរួលពាណិជ្ជកម្មប្រកបដោយប្រសិទ្ធិភាព | | ការពង្រឹងការអនុវត្តន៏កិច្ចសន្យា<br><br>លទ្ធភាពទទួលបានឥណទាន | កែលំអភាពប្រកួតប្រជែងនៃផលិតផលកម្ពុជា | វិនិយោគឯកជនក្នុងបណ្តាញម៉ាឃេតធីង |
| *សេវាបរិញ្ញវត្ថុជនបទ* | | | | |
| | កែលំអលទ្ធភាពទទួលបានផលិតផលកែឆ្នៃបានល្អ | ការពង្រឹងការអនុវត្តន៏កិច្ចសន្យា | កាត់បន្ថយចំណាយធ្វើអាជីវកម្ម | កាលានុវត្តភាពសេដ្ឋកិច្ច |
| សេវាហេដ្ឋារចនាសម្ព័ន្ធ | | | | |
| បង្កើប្រសិទ្ធិភាពនិងគណនេយ្យភាព | កែលំអការថែទាំនិងការរៀបចំផែនការមូលដ្ឋាន | ការពង្រឹងការអនុវត្តន៏កិច្ចសន្យា | កាត់បន្ថយចំណាយធ្វើអាជីវកម្ម | ការវិនិយោគឯកជន |

## ***ការប្រមូលផ្តុំទៅលើតួនាទីផ្នែកសាធារណៈសំខាន់ៗ***

១៩២. *បញ្ហាប្រឈមមួយសំរាប់រដ្ឋាភិបាល គឺការជ្រើសរើសក្នុងការផ្តោតរបស់ខ្លួននៃការកសាងសមត្ថភាព សំរាប់បំពេញនូវតួនាទីក្នុងការណែនាំការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីឱ្យមានកំណើនប្រកបដោយប្រសិទ្ធិភាពនិង*

*សមធម៌។* នៅក្នុងករិតណាមួយនោះ រដ្ឋាភិបាលបានលុបចោលនូវសកម្មភាពនានាដែលនៅតែមានបន្ទុកទៅលើផ្នែកសាធារណៈនៅក្នុងប្រទេសជិតខាង ដូចជាការជាប់ពាក់ព័ន្ធផ្ទាល់ក្នុងផលិតកម្ម និងឥទ្ធិពលរបស់រដ្ឋទៅលើស្ថាប័នទីផ្សារ។ រដ្ឋាភិបាលនៅតែជួបប្រទះនូវកាតព្វកិច្ចដ៏ធំក្នុងការផ្តល់នូវទំនិញសាធារណៈ ដោះស្រាយនូវភាពបរាជ័យនៃទីផ្សារ និងផ្តល់សេវាដ៏មានប្រយោជន៍ដែលផ្នែកឯកជនយល់ឃើញថារកស៊ីមិនចំណេញ។ តួនាទីបន្ថែមទៀតរួមមាន ការបង្កើតការឯកភាព ការអនុវត្តន៍និងការសំរបសំរួលគោលនយោបាយតាមផ្នែកដែលពាក់ព័ន្ធនឹងភាពចំរូងចំរាស់នៃគោលដៅ។ លើសពីនេះទៅទៀត ដោយមានភាពដ៏សំខាន់នៃអ្នកផ្តល់ជំនួយក្នុងការផ្តល់មូលនិធិសំរាប់ការវិនិយោគសាធារណៈ គឺមានការប្រឈមមុខបន្ថែមទៀតនៃការសំរបសំរួលសកម្មភាពរបស់អ្នកផ្តល់ជំនួយទាំងនោះ ដើម្បីឱ្យស៊ីសង្វាក់គ្នាជាមួយអាទិភាពជាតិ។

១៩៣. សមត្ថភាពមានកំរិតនៃភ្នាក់ងាររដ្ឋាភិបាលបានចាត់ទុកការជ្រើសរើសមានសារៈសំខាន់សូម្បីតែក្នុងការ ផ្តល់នូវសេវាផ្សេងៗដែលនឹងមានសារៈសំខាន់ចំពោះផលិតករជនបទ ដែលពួកគេស្វែងរកការធ្វើពិពិធកម្ម សកម្មភាព និងតំរង់ទិសទៅរកកាលានុវត្តភាពទីផ្សារ។ ឧទាហរណ៍ ចំពោះការផ្សព្វផ្សាយកសិកម្ម គឺអាចមាន ផលប៉ះពាល់លឿនជាងដល់រដ្ឋាភិបាលដែលស្វែងរកដៃគូរ ក្នុងវិធីសាស្ត្រមួយដែលមានការសំរបសំរួលនិងមាន អ្នកផ្តល់ច្រើនចំពោះអ្នកបែងចែកសេវា ជាងមានគោលបំណងដើម្បីកសាងសមត្ថភាពដ៏ទូលំទូលាយនៅក្នុង ផ្នែកសាធារណៈ។ អង្គការក្រៅរដ្ឋាភិបាល សាលាបច្ចេកទេសកសិកម្ម និងអ្នកផ្គត់ផ្គង់ឯកជនអាចបន្ថែម សមត្ថភាពក្នុងការផ្តល់នូវសេវាផ្សព្វផ្សាយ ធ្វើការក្នុងភាពជាដៃគូរជាមួយរដ្ឋាភិបាល។ ដូចគ្នានេះដែរ សេវាសុខភាពពាហនៈអាចពង្រីកបន្ថែមទៀតយ៉ាងលឿន ប្រសិនបើគំរូនៃអ្នកផ្គត់ផ្គង់ឯកជនត្រូវបានអនុវត្តទោះបី ជាសំរាប់យុទ្ធនាការចាក់វ៉ាកសាំងជាសាធារណៈប្រឆាំងជម្ងឺឆ្លងដល់ពាហនៈ ធនធានសាធារណៈផ្តល់កិច្ចសន្យា សេវាទាំងនេះសំរាប់ផ្តល់ដល់កសិករតូចតាច។

១៩៤. *ក្នុងការខិតខំប្រឹងប្រែងជំរុញការធ្វើពិពិធកម្មដាំដុះ និងទីផ្សារ ដែលជាអ្នកដឹកនាំនៃកំណើនចំណូលជនបទ រដ្ឋាភិបាលនឹងត្រូវការចាំបាច់ផ្តល់ការយកចិត្តទុកដាក់ដល់គុណភាពផលិតផល និងបញ្ហាស្តង់ដារ។* តួនាទី របស់ផ្នែកសាធារណៈកំពុងផ្លាស់ប្តូរក្នុងវិស័យនេះ ដែលជាពិសេសទីផ្សារនាំចេញ ឬខ្សែសង្វាក់ផ្គត់ផ្គង់ដែល ផ្អែកលើផ្សារទំនើបកំពុងតែទទួលបាននូវសារៈសំខាន់ដ៏ខ្លាំង។ នៅក្នុងទីផ្សារកំណើនទាំងពីរនេះ និយាមគុណភាព និងស្តង់ដារកំពុងកាន់តែត្រូវបានកំណត់ដោយបណ្តាញលទ្ធកម្មឯកជន ដោយលក្ខណៈបច្ចេកទេសច្រើនតែមិនដូចនិយាមសាធារណៈ។ នៅពេលទីផ្សារវិវត្តនៅក្នុងទិសដៅនេះ រដ្ឋាភិបាលនឹងមិនសូវមានប្រសិទ្ធភាពក្នុងការប្រមូលផ្តុំការកំណត់និយាមសាធារណៈ និងកាន់តែប្រឈមមុខក្នុងការ

ធានាឱ្យមានលទ្ធផលសង្គមសមស្របដោយធ្វើការជាមួយកសិករតូចតាច និងសមាគមរបស់ពួកគេដើម្បីផ្ដល់ពត៌មានអំពីទីផ្សារ និងបច្ចេកទេសផលិតកម្មដែលអនុញ្ញាតិឱ្យពួកគាត់បំពេញបាននូវលក្ខខណ្ឌនៃកាលានុវត្តភាពទីផ្សា ដែលកំពុងតែកើតមានទាំងនេះ។

១៩៥. *រដ្ឋាភិបាលជួបប្រទះនូវការប្រឈមជាច្រើនតែនៅក្នុងតួនាទីដែលខ្លួនអាចអនុវត្តបាន គឺការបង្កើតនូវសមាសធាតុផ្សេងៗដែលមានទំនាក់ទំនងគ្នា ដែលចាំបាច់ដើម្បីជួយដល់ការបែងចែកអត្ថប្រយោជន៍សង្គមនៃធនធានធម្មជាតិដែលបច្ចុប្បន្នស្ថិតក្នុងសិទ្ធិអំណាចរដ្ឋ។* ដូចដែលបានរៀបរាប់ខាងលើ ការសំរេចបាននូវភាពជឿនលឿនក្នុងវិស័យនេះគឺជាការប្រឈមមុខមួយក្នុងចំណោមការប្រឈមមុខនានាដ៏សំខាន់ដើម្បីទទួលបាននូវកំណើនជនបទដែលគ្រប់គ្រាន់សំរាប់កាត់បន្ថយភាពក្រីក្រជនបទ។ ភាពសកម្មនិយមរបស់រដ្ឋាភិបាល នឹងជាធាតុមួយដ៏សំខាន់នៅក្នុងសមាសភាគស្ទើរតែទាំងអស់នៃប្រព័ន្ធដែលចាំបាច់ត្រូវកសាងឡើង រួមមាន: ការកំណត់នូវព្រំដែនបច្ចេកទេសនិងសង្គមចំពោះវិសាលភាពនិងទីតាំងនៃការបែងចែកឡើងវិញ ការបង្កើតលក្ខណៈវិនិច្ឆ័យសំរាប់អត្ថប្រយោជន៍ស្របច្បាប់ ការធានានូវវិធានការទ្រទ្រង់ដែលបំពេញឱ្យគ្នាទៅវិញទៅមក ការកសាងនូវការឯកភាពជាសាធារណៈដែលនៅពីក្រោយកញ្ចប់នៃជំរើសនានា និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃការដាក់ទណ្ឌកម្ម នៅពេលដែលឯកត្តជនណាមួយធ្វើឱ្យខូចដល់ការអនុវត្តន៍នៃជំរើសសាធារណៈទាំងនេះ។

១៩៦. *ជាចុងក្រោយ ក្នុងតួនាទីដោះស្រាយនូវភាពបរាជ័យនៃទីផ្សារ វិស័យមួយដែលរដ្ឋាភិបាលអាចយកមកពិចារណាវាយតំលៃវិធីសាស្ត្របច្ចុប្បន្ន គឺការកែលំអនូវលទ្ធភាពទទួលបានឥណទានហិរញ្ញវត្ថុ និងសេវាសន្សំ ដោយផលិតករជនបទ ឬមួយកសិករឬមួយសហគ្រិនតូចៗ។* ការផ្ដល់មូលធនតាមរយៈកម្មវិធីឥណទានរបស់ រដ្ឋាភិបាលសំដៅដល់អ្នកទទួលផលនៅជនបទ គួរតែត្រូវបានជៀសវាង ដោយសារវារួមចំណែកតិចតួចដល់ ការកសាងស្ថាប័នប្រកបដោយចេរភាព ដែលមានសមត្ថភាពពង្រីកលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុដល់ ប្រជាជនជនបទដែលបច្ចុប្បន្នពុំដែលទទួលសេវានានា។ ការប្រើប្រាស់នូវធនធានដ៏មានកំរិតរបស់រដ្ឋាភិបាល ទំនងជាមិនកើតមានក្នុងពេលណាមួយដ៏ឆាប់ដែលជាដំណោះស្រាយមួយដ៏សមស្រប ដើម្បីដោះស្រាយនូវតំរូវ ការដែលមិនបានបំពេញនៅជនបទសំរាប់សេវាហិរញ្ញវត្ថុ។ ការបង្កើតបរិស្ថានអំណោយផលដែលជំរុញការ អភិវឌ្ឍន៍ស្ថាប័នហិរញ្ញវត្ថុដែលមានលក្ខណៈល្អប្រសើរ ហើយអន្តរការីហិរញ្ញវត្ថុនៃការសន្សំជនបទទៅជាការ វិនិយោគជនបទគឺការផ្តោតទៅលើផ្នែកសាធារណៈដែលអាចទទួលយកបាន។

## *តំរូវការសំរបសំរួល រួមមានការគាំទ្រពីអ្នកផ្តល់ជំនួយ*

១៩៧. *បញ្ហាពហុភ្នាក់ងារ*។ ភ្នាក់ងារជាច្រើនត្រូវបានជាប់ពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ជនបទនិងកសិកម្ម។ ការទទួលខុសត្រូវនិងធនធានសំរាប់កសិកម្មនិងអភិវឌ្ឍន៍ជនបទ គឺរាលដាលនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបណ្តាលឱ្យមានរដ្ឋបាលសាធារណៈលើសលុបសំរាប់កសិកម្ម និងអភិវឌ្ឍន៍ជនបទ។ អាណត្តិត្រួតគ្នា និងការសំរបសំរួលទុនខ្សោយជះឥទ្ធិពលដល់ការអនុវត្តន៍ការងាររបស់ស្ថាប័ន ទាំងនោះ ដែលនៅតែពឹង ផ្អែកទៅលើការគាំទ្រពីអ្នកផ្តល់ជំនួយ។ ភ្នាក់ងារផ្សេងទៀតដូចជា ក្រសួងបរិស្ថាន ក្រសួងកិច្ចការនារីនិង អតីតយុទ្ធជន ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ក៏ដើរ តួនាទីតិចជាងមុនក្នុងផ្នែក កសិកម្មនិងអភិវឌ្ឍន៍ជនបទ។ ការកែលំអសមត្ថភាពដើម្បីសំរបសំរួលយុទ្ធសាស្ត្រ និងសកម្មភាពសំរាប់ កសិកម្មនិងអភិវឌ្ឍន៍ជនបទ គឺមានសារៈសំខាន់ និងគួរតែទទួលបានការយកចិត្ត ទុកដាក់។ ជាផ្លូវការ ក្រុមប្រឹក្សាអន្តរក្រសួងសំរាប់កសិកម្មនិងអភិវឌ្ឍន៍ជនបទដែលមាននាយករដ្ឋមន្ត្រី ជាប្រធាន គឺជាមធ្យោបាយមួយសំរាប់ការសំរបសំរួល ប៉ុន្តែក្រុមប្រឹក្សានោះមានអត្ថិភាពភាគច្រើន នៅលើ តែក្រដាសប៉ុណ្ណោះ កំរជួបប្រជុំ និងមិនទាន់មានប្រសិទ្ធិភាពនៅឡើយ។

១៩៨. *ការសំរបសំរួលរបស់អ្នកផ្តល់ជំនួយក្នុងការងារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ គឺជាបញ្ហាមួយដ៏សំខាន់ សំរាប់ប្រសិទ្ធិភាពជំនួយ ប៉ុន្តែនៅមានកំរិតនៅឡើយ*។ ជំនួយបរទេសក្នុងកំរិតខ្ពស់ចំពោះផ្នែកជនបទក្នុង ទសវត្សរ៍កន្លងមកមានការផ្ទុយគ្នាយ៉ាងខ្លាំងជាមួយនឹងការខ្វះខាតនូវភាពជឿនលឿន ក្នុងការកាត់បន្ថយភាព ក្រីក្រជនបទ និងការអនុវត្តន៍ការងារកំរិតមធ្យមនៃសេដ្ឋកិច្ចជនបទ ដែលនាំឱ្យមានភាពងឿងឆ្ងល់អំពីប្រសិទ្ធិ ភាពទូទៅនៃកិច្ចខិតខំប្រឹងប្រែងកន្លងមក។ ជំនួយបរទេសដ៏ច្រើនដែលជួយដល់ផ្នែកកសិកម្មនិងអភិវឌ្ឍន៍ជន បទ[៩៤] ពហុភាពនៃប្រភព និងចំណែកដ៏សំខាន់នៃមូលនិធិជំនួយឥតសំណងក្រៅថវិកា (ប្រហែល ៤៥%នៃ

---

[94] ទិន្នន័យអំពីលំហូរជំនួយអភិវឌ្ឍន៍ផ្លូវការគឺបានមកពី CDC និងត្រូវបានប្រើប្រាស់ដោយមានការព្រមានជាមុនថាទិន្នន័យទាំងនេះចាំ បាច់ត្រូវកែលំអឡើងវិញ ឧទាហរណ៍ ដើម្បីដោះស្រាយនូវបញ្ហាចំណាត់ថ្នាក់ដូចជាគំរោងផ្លូវថ្នល់ដោយមានសមាសភាពជនបទដែល គេចផុតពីអត្តសញ្ញាណ និងការដាក់បញ្ចូល។ ទិន្នន័យ CDC បង្ហាញថាអ្នកផ្តល់ជំនួយផ្តល់ប្រហែល ៦៦លានដុល្លាសំរាប់កសិកម្មនិង អភិវឌ្ឍន៍ជនបទក្នុងឆ្នាំ២០០២។ ការផ្តល់ពីថវិការដ្ឋាភិបាលមានប្រហែល ២៣លានដុល្លាក្នុងឆ្នាំ ២០០១។ ក្នុងជំនួយអភិវឌ្ឍន៍ផ្លូវការ ឆ្នាំ ២០០២ ជំនួយទ្វេភាគីរួមមានការគាំទ្រពីជប៉ុន (១៦% នៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការទាំងអស់) ពីអូស្ត្រាលី ដាណឺម៉ាក

ជំនួយបរទេសទៅដល់ផ្នែកនេះ យោងទៅតាមតួលេខរបស់ CDC) មានន័យថា ការខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងនៃការធ្វើឱ្យថវិកាស៊ីសង្វាក់ស្របគ្នានឹងអាទិភាពគោលនយោបាយនឹងផ្អែកទៅលើការកែលំអការសំរបសំរួលអ្នកផ្តល់ជំនួយ ។

១៩៩. *អន្តរសកម្មភាពដ៏មានប្រសិទ្ធិភាពក្នុងចំណោមអ្នកផ្តល់ជំនួយ និងរវាងអ្នកផ្តល់ជំនួយនិងរាជរដ្ឋាភិបាល នឹងមានសារៈសំខាន់សំរាប់ការឆ្លើយតបប្រកបដោយលក្ខណៈយុទ្ធសាស្ត្រ និងសំរបសំរួលទៅនឹងភាពប្រឈមជាច្រើននៃផ្នែកនេះ*។ ការពិនិត្យឡើងវិញថ្មីៗនេះរកឃើញថាគំរោងជាច្រើនហាក់បីដូចជា ត្រូវបានអនុវត្ត ដោយពុំមានការសំរបសំរួលគ្រប់គ្រាន់ឬមួយជាមួយគ្នាទៅវិញទៅមក ឬមួយជាមួយសកម្មភាពរបស់កម្ពុជាគ្នាឯង ។ ការកើនឡើងនៃគំរោងនិងយុទ្ធសាស្ត្រកើតមានឡើងជាមួយនឹងសកម្មភាពដែលផ្តល់ដោយអ្នកផ្តល់ ជំនួយដែលមានលក្ខណៈមិនសំរបសំរួល ខ្វះនូវភាពជាម្ចាស់របស់ជាតិ និងដាក់នូវនីតិវិធីនិងទិសដៅផ្សេងៗទៅ លើរដ្ឋាភិបាល ។ មានការចែករំលែកពតិមានតិចតួចណាស់ ដែលនាំមកនូវជំនួយអភិវឌ្ឍន៍នៅតំបន់ជនបទត្រូវ បានបង្ហាញពីពហុភាពទាំងអ្នកផ្តល់ជំនួយនិងវិធីសាស្ត្ររបស់ខ្លួន ។ គុណភាពនៃធាតុចូលរបស់អ្នកផ្តល់ជំនួយ ទៅក្នុងដំណើរការរៀបចំគោលនយោបាយគឺមិនដូចគ្នាទេ ។ ភស្តុតាងជាក់ស្តែងដ៏តិចតួចដែលផ្អែកលើ បទពិសោធន៍នៅទីកន្លែង ឬការស្រាវជ្រាវត្រូវបានលើកយកមកពិចារណាក្នុងការរៀបចំគោលនយោបាយ ហើយមានការខ្វះខាតនូវការវាយតំលៃប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ស៊ីសង្វាក់និងរឹងមាំនៃផលប៉ះពាល់ របស់គំរោង ។ ប៉ុន្តែមានបទពិសោធន៍ជោគជ័យមួយចំនួនដែលអាចត្រូវបានពង្រីកថែមទៀត ( សូមអាន ប្រអប់ទី ៧) ។

### ប្រអប់ទី ៨: មេរៀនបទពិសោធន៍ខ្លះដែលបានមកពីការពិនិត្យឡើងវិញនាពេលថ្មីៗនៃជំនួយបរទេស

*ធ្វើការតាមរយៈនីតិវិធីរដ្ឋាភិបាល*។ ដើម្បីបានប្រសិទ្ធិភាពអតិបរមា ការអនុវត្តន៍គំរោងគួរតែធ្វើតាមនីតិវិធីដែលមានស្រាប់ដែលអាចធ្វើបានជាជាងការបង្កើតប្រព័ន្ធស្របគ្នាថែមទៀត ។ នៅក្នុងករណីណាមួយដែលអាចធ្វើបាន អ្នកផ្តល់ជំនួយគួរតែអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុថ្មីរបស់រដ្ឋាភិបាលនិងនីតិវិធីនៃការអនុវត្តន៍គំរោងដែលបានផ្តួចផ្តើមឡើងបន្ទាប់ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ និងការបង្កើតមូលនិធិឃុំសង្កាត់ (C/SF) ។

*បំពេញឱ្យគ្នាទៅវិញទៅមកជាមួយដៃគូរផ្សេងៗទៀត*។ កម្ពុជានៅតែត្រូវការការធ្វើអន្តរាគមន៍ពហុផ្នែកដើម្បីដោះស្រាយនូវមូលហេតុនៃការរីករាលដាលភាពក្រីក្រជនបទ និងដើម្បីធ្វើឱ្យប្រសើរឡើងសន្តិសុខ

---

អាល្លឺម៉ង់ និងបារាំង ។ ភ្នាក់ងារពហុភាគីគាំទ្រដល់ កសិកម្មនិងអភិវឌ្ឍន៍ជនបទរួមមានធនាគារពិភពលោក ( ប្រហែល ២២% នៃការផ្តល់ឆ្នាំ ២០០២) ADB (១៤%) សហគមន៍អឺរ៉ុប (១៣%) IFAD (៥%) និងភ្នាក់ងារ UN (៤%) (IFAPER, 2003) ។

ស្បៀងនិងចំណូលរបស់គ្រួសារ ។ ដើម្បីជ្រើសរើសគំរោងស្មុគស្មាញ ដែលមានការលំបាកក្នុងការអនុវត្តន៏ដោយមានសមត្ថភាពស្ថាប័នខ្សោយ អ្នកផ្តល់ជំនួយគួរតែចូលរួមជាដៃគូរជាមួយកម្មវិធីនិងគំរោងផ្សេងៗទៀតដើម្បីផ្តល់នូវសេវាដែលបំពេញឱ្យគ្នាទៅវិញទៅមកដល់អ្នកក្រីក្រជនបទដើម្បីសំរេចនូវទិសដៅរួម ។ *ភាពដែលអាចបត់បែនបាននិងការអនុវត្តន៏ជាជំហានៗ*។ ការរៀបចំគំរោងនិងកម្មវិធីគួរតែអាចបត់បែនបានដើម្បីគិតបញ្ចូលនូវភាពមិនប្រាកដប្រជានិងហានិភ័យក្នុងអំឡុងពេលអនុវត្តគំរោង និងអនុញ្ញាតឱ្យមានការកែសំរួលនៅពេលដែលទទួលបានបទពិសោធន៏បន្ថែម ។

*ស្ថាប័នមូលដ្ឋាន*។ សព្វថ្ងៃនេះ ក្រសួង មន្ទីរតាមខេត្តនានា មន្ត្រីស្រុក និងក្រុមប្រឹក្សាឃុំ មានសមត្ថភាពនៅមានក៏រិត ។ ដោយមានការខ្វះខាតការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងស្មារតីទាបរបស់មន្ត្រី ការផ្តល់នូវប្រាក់ឧបត្ថម្ភដល់មន្ត្រីគឺជាការចាំបាច់ដើម្បីធានាការបំពេញការងារពេញម៉ោង ប៉ុន្តែទាំងនេះគួរតែផ្សារភ្ជាប់គ្នាជាមួយការទទួលខុសត្រូវនិងគណនេយ្យភាពសំរាប់លទ្ធផលការងាររបស់មន្ត្រីដែលពាក់ព័ន្ធ ។ សំរាប់វិធីសាស្រ្តអភិវឌ្ឍន៏រលូនមួយ គណៈកម្មាធិការអភិវឌ្ឍន៏ជនបទខេត្ត ១ភគ្រជសច ឬ អ្នកនៅក្រោមឱវាទខ្លួនគួរតែសំរបសំរួលសកម្មភាពគំរោងនៅថ្នាក់ខេត្តដែលជាផ្នែកមួយនៃតួនាទីដ៏ធំនៃការសំរបសំរួលរាល់សកម្មភាពអភិវឌ្ឍន៏ជនបទនៅក្នុងខេត្ត ។

*ការចូលរួម និងនិរន្តរភាព*។ សមាជិកសហគមន៏ជនបទគួរតែចូលរួមឱ្យបានពេញលេញក្នុងការរៀបចំផែនការនិងការអនុវត្តន៏សកម្មភាពរបស់កម្មវិធីដើម្បីធានានូវនិរន្តរភាព និងភាពជាម្ចាស់ ។ គណៈកម្មាធិការជនបទនិងក្រុមប្រឹក្សាឃុំគួរតែរួមចំណែកដល់ការចំណាយវិនិយោគ និងទទួលការទទួលខុសត្រូវសំរាប់ប្រតិបត្តិការនិងការថែទាំនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចរបស់ឃុំ ។

*វិធីសាស្រ្តអភិវឌ្ឍន៏ ។* បទពិសោធន៏បានបង្ហាញថាជីវភាពរស់នៅរបស់អ្នកក្រីក្រអាចត្រូវបានធ្វើឱ្យប្រសើរឡើងច្រើនដោយផ្តល់ (i) ជំនួយហិរញ្ញវត្ថុផ្ទាល់ (ii) លទ្ធភាពទទួលបានបច្ចេកវិជ្ជា សេវាហិរញ្ញវត្ថុ និង ទីផ្សារ និង (iii) ការកសាងសមត្ថភាពដ៏ម៉ត់ចត់ ។
*បញ្ជាក់ច្បាស់លាស់នៃបច្ចេកវិជ្ជា*។ ការបញ្ជាក់ច្បាស់លាស់នៃបច្ចេកវិជ្ជាដំណាំនិងបសុសត្វ និងវិធីសាស្រ្តផ្សព្វផ្សាយសមស្របគឺមាននៅក្នុងគោលការណ៏ណែនាំជាតិនៃការផ្សព្វផ្សាយ និងជាទូទៅសមស្របទៅនឹងលក្ខខណមូលដ្ឋាននិងភាពជាក់លាក់នៃឧបសគ្គផ្នែកបច្ចេកទេសដែលនឹងត្រូវដោះស្រាយ ។

*ភាពទទួលបានផលចំណេញផ្នែកសេដ្ឋកិច្ចនៃប្រព័ន្ធធារាសាស្ត្រ។* គំរោងនានាបង្ហាញពីភាពមិនច្បាស់លាស់នៃផលចំណេញផ្នែកសេដ្ឋកិច្ច និងនិរន្តរភាពហិរញ្ញវត្ថុនៃគំរោងធារាសាស្ត្រខ្នាតធំនិងមធ្យមនៅកម្ពុជា។ អ្នកផ្តល់ជំនួយគួរតែយកនូវវិធីប្រុងប្រយ័ត្នដើម្បីវិនិយោគក្នុងគំរោងទាំងនេះ។

២០០. *មានការបើកចំហថ្មីៗនេះ សំរាប់ការចែករំលែកនូវបទពិសោធន៍នានានិងការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធិភាពជំនួយបរទេសសំរាប់ការអភិវឌ្ឍន៍កសិកម្មនិងជនបទ។* នៅឆ្នាំ២០០៣ គំនិតផ្តួចផ្តើមមួយដើម្បីសំរបសំរួលគោលនយោបាយនិងការគាំទ្ររបស់អ្នកផ្តល់ជំនួយ បាននាំមកនូវការបង្កើតក្រុមការងារបច្ចេកទេសរួមគ្នារវាងរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ - វេទិកាសំរាប់រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអ្នកផ្សេងៗទៀតដើម្បីធ្វើការជាមួយគ្នាក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍន៍កសិកម្មនិងជនបទ និងសំរាប់ (i) គោលនយោបាយតាមផ្នែកដែលទ្រទ្រង់ដល់អ្នកក្រីក្រ (ii) សំរបសំរួលនិងចែករំលែកពត៌មាន និង (iii) តម្លាភាពក្នុងការប្រើប្រាស់និងគ្រឿងគរធនធានដែលមានតិចតួច។ ទន្ទឹមនឹងការនេះជាការអភិវឌ្ឍន៍ជាវិជ្ជមានបញ្ហាបន្ថែមមួយទៀតគឺជំនួយដែលត្រូវរំលែកទុកសំរាប់ស្ថាប័ន។ ដើម្បីធានាថាគោលនយោបាយតាមផ្នែកនិងយុទ្ធសាស្ត្រអនុវត្ត មានលក្ខណៈគ្រប់ជ្រុងជ្រោយសមរម្យ ការពិនិត្យឡើងវិញថ្មីៗនៃជំនួយបច្ចេកទេសបានផ្តល់អនុសាសន៍ថា អ្នកផ្តល់ជំនួយគាំទ្រការផ្លាស់ប្តូរពី "ការរៀបចំថវិកាសំរាប់ស្ថាប័ន" មក "ការរៀបចំថវិកាសំរាប់កម្មវិធី "ហើយក្រុមការងារទាំងនោះអាចវាយតំលៃថាតើនេះគឺជារបៀបវារៈមួយទាន់ពេលវេលា សំរាប់ភាពជាដៃគូកម្ពុជា-អ្នកផ្តល់ជំនួយឬយ៉ាងណា។

២០១. *កិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្ននេះសំរាប់ការសំរបសំរួលកសិកម្មនិងអភិវឌ្ឍន៍ជនបទនឹងមានប្រសិទ្ធិភាពខ្ពស់ប្រសិនបើអបទៅដោយភាពជាអ្នកដឹកនាំខ្លាំងរបស់រដ្ឋាភិបាល។* ក្រុមប្រឹក្សាសកម្មស្តីពីការអភិវឌ្ឍន៍ កសិកម្មនិងជនបទអាចជាជំរើសមួយសំរាប់កិច្ចការនេះ ប្រហែលដោយមានការគាំទ្រពីលេខាធិការដ្ឋានតូច ប៉ុន្តែអចិន្ត្រៃយ៍ ក៏នឹងត្រូវបានដឹកនាំផងដែរដោយរាជរដ្ឋាភិបាល ប្រហែលដោយមានការគាំទ្រការផ្តល់ជំនួយ ឥតសំណងរួមរបស់អ្នកផ្តល់ជំនួយដើម្បីបំពេញថវិកាប្រចាំថ្ងៃតិចតួច និងកម្មវិធីការងារដែលសំដៅកែលំអ នីតិវិធីនិងខ្លឹមសារនៃការពិគ្រោះយោបល់និងសំរបសំរួល។ បទពិសោធន៍ក្នុងផ្នែកជីធ្លីបង្ហាញពីភាពជឿន លឿនដែលអាចសំរេចបាននៅពេលមានក្របខ័ណ្ឌយុទ្ធសាស្រឯកភាពមួយ និងភាពជាអ្នកដឹកនាំខ្លាំងរបស់ រដ្ឋាភិបាលដែលជំរុញឱ្យមានការសំរបសំរួលវិស័យទាំងមូលនិងប្រកបដោយប្រសិទ្ធិភាព។

## ជំហានបន្ទាប់

២០២. *ការទទួលបានការឯកភាពក្នុងចំណោមដៃគូរអភិវឌ្ឍន៍និងការកំណត់នូវអាទិភាពនានា។* ចេញពីសមាសធាតុនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទក្នុកំណត់សំគាល់នេះ ឆ្ពោះទៅរបៀបវារៈមួយដែលមានលក្ខណៈសមាហរណកម្មនិងដែលបានកំណត់អាទិភាព ច្បាស់ណាស់នឹងមានការងារនិងការពិភាក្សាបន្ថែមទៀត។ កំរិតនៃការងារនិងការពិភាក្សាដែលគួរតែត្រូវបានអនុវត្ត អាស្រ័យទៅលើកំរិតធនធាន - រដ្ឋាភិបាល អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន- ដែលមានសំរាប់ការអភិវឌ្ឍន៍កសិកម្មនិងជនបទ។ ការពិភាក្សាបន្ថែមទៀតនិងការពិនិត្យឡើងវិញនូវធនធានដែលមានបច្ចុប្បន្ននិងអនាគតគឺត្រូវការជាចាំបាច់ ដើម្បីវាយតំលៃគំលាតធនធាន ហើយក្នុងវិស័យមួយៗ កំណត់នូវចំណុចដៅនានា។ របៀបវារៈកំណែទំរង់ចុងក្រោយបំផុតនឹងសំខាន់បំផុតមានមូលដ្ឋានទូលំទូលាយ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ របៀបវារៈនេះអាចរួមមានសំណុំសកម្មភាពនិងកំណែទំរង់ដែលសំដៅដើម្បីជួយជំរុញការកែលំអជាចាំបាច់ក្នុងផលិតកម្ម និងផលិតភាពជនបទទូទៅ បង្កើតការងារដែលមានចំនួនកាន់តែកើនឡើងនៃប្រជាពលរដ្ឋក្រីក្រនៅជនបទ រួមមានស្ត្រីនិងជំនួសការ ធ្វើអាជីវកម្មហួសហេតុនៃធនធានធម្មជាតិ របស់ប្រទេស ជាមួយនឹងកាការប្រើប្រាស់ផ្អែកលើសហគមន៍ដែលមាននិរន្តរភាព ។

២០៣. សំរាប់ផ្នែកភាគច្រើន សកម្មភាពទាំងនេះនឹងផ្តល់ផ្លែផ្កានៅក្នុងរយៈពេលមធ្យម ទោះបីជាខ្លះ នឹងមានឥទ្ធិពលជាផ្លែផ្កាក្នុងរយៈពេលខ្លី ទៅលើចំណូលជនបទ និងការកាត់បន្ថយភាពក្រីក្រជនបទ។ ប៉ុន្តែដើម្បីឱ្យផលប្រយោជន៍ទាំងនោះកើតមានឡើង ជំហាននានាក្នុងការរៀបចំនិងអនុវត្តរបៀបវារៈ គួរតែចាប់ផ្តើមនាពេលឥឡូវនេះ មុនពេលជំរើសសេដ្ឋកិច្ចជនបទរបស់កម្ពុជាក្លាយជាចំណាប់ខ្មាំងទាំងស្រុងចំពោះផលប៉ះពាល់ដែលពុំមានប្រសិទ្ធិភាពនៃថាមភាពប្រជាជនជនបទ។ គ្រោងសំខាន់ៗធំៗនៃកំណែទំរង់ដែលបានស្នើឡើងភាគច្រើនត្រូវបានដឹងឮរួចហើយ ហើយការចំណាយនៃការពន្យាពេលបន្ថែមទៀតអាចមានទំហំធំជាពិសេសសំរាប់អ្នកក្រីក្រជនបទ។ នេះគឺជាកាតព្វកិច្ចដែលទាំងរដ្ឋាភិបាលនិងសហគមន៍អ្នកផ្តល់ជំនួយជំពាក់ដល់អ្នករស់នៅជនបទរបស់កម្ពុជាដែលបន្តរស់នៅយ៉ាងកៀកនឹងជីវភាពជីវព្រឹត្ត។

២០៤. ឯកសារនេះនឹងរួមវិភាគទាន ចំពោះកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកំណត់របៀបវារៈសំរាប់អភិវឌ្ឍន៍តំបន់ជនបទក្នុងរយៈពេលខ្លីទៅមធ្យមរបស់ខ្លួន ដោយសហការជាមួយដៃគូដទៃ ។ ឯកសារនេះពុំមានបំណងបង្ហាញយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនាពេលនេះទេ ដោយហេតុថា កង្វះពតិមានសំខាន់ៗ

នៃរបាយការណ៏ និង ការចូលរួមតិចតួចជាមួយរដ្ឋាភិបាលនៅក្នុងដំណើរកសាងឯកសារនេះ ដោយបន្សល់ទុកការងារជាច្រើនសំរាប់ដំណាក់កាលជាបន្តបន្ទាប់ ។ ការពិគ្រោះជាបន្ត នៅក្នុងអំឡុងពេលរៀបចំផែនការជាតិអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រ ២០០៦-២០១០ ក្នុងរយៈពេលខ្លី និង តាមរយៈការពិភាក្សាដែលកំពុងប្រព្រឹត្តទៅនៅក្នុង TWG រវាងរដ្ឋាភិបាល និង ម្ចាស់ជំនួយ ក្នុងរយៈពេលមធ្យមមានគោលដៅបញ្ជាក់ទិសដៅយុទ្ធសាស្ត្ររស់រដ្ឋាភិបាល អាទិវិស័យជាអាទិភាពសំរាប់ផ្តោតការយកចិត្តទុកដាក់ ទំនាក់ទំនង និងតំលាតពតិមាន ទាមទារអោយមានការកែលំអជាបន្តទៀត និង ផ្នែកជាក់លាក់ដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់អនុវត្តរបៀបវារៈជាក់ស្តែង ។ ធនាគារពិភពលោកមានជំហត្រៀមលក្ខណៈ នៅក្នុងការគាំទ្រដំណាក់កាលការងារជាបន្តបន្ទាប់នេះ កិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល ។

# ឯកសារយោងសំខាន់ៗ


Agrifood Consulting International, *ការសិក្សាខ្សែចង្វាក់តំលៃស្រូវៈកម្ពុជា* (*Rice Value Chain Study: Cambodia*) របាយការណ៍រៀបចំដោយធនាគាពិភពលោក 2002.

Asian Development Bank, *កម្មវិធីអភិវឌ្ឍន៍ផ្នែកកសិកម្ម* (*Agriculture Sector Development Program*) TA-3695 CAM, របាយការណ៍ព្រាងចុងក្រោយ ខែកញ្ញា 2002, Manila.

Asian Development Bank, *ការវាយតំលៃភាពក្រីក្រដោយមានការចូលរួមៈកម្ពុជា* (*Participatory Poverty Assessment: Cambodia*) ខែធ្នូ 2001, Manila.

Auffret, P., World Bank, *ភាពក្រីក្រជនបទនៅកម្ពុជាៈ ផលប៉ះពាល់នៃការបែងចែកដីធ្លី និងជំរើសគោលនយោបាយនានា* (*Rural Poverty in Cambodia: Impact of Land Distribution and Alternative Policies*) សេចក្តីព្រាង ខែវិច្ឆិការ 2003, Washington DC.

Boreak, Sik, and Desbarats, Jacqueline, *ប្រជាជននិងដីនៅជនបទកម្ពុជា* (*People and Land in Rural Cambodia*) Cambodia Development Review, Volume 4 Issue 3, September 2000, Phnom Penh.

Burger, Kees, and Smit, Hidde P., *កំណើនសេដ្ឋកិច្ចនិងអនាគតនៃកៅស៊ូធម្មជាតិ* (*Economic Growth and the Future of Natural Rubber*) ខែវិច្ឆិការ 2001, Yamoussoukro.

Cambodia Development Resource Institute (CDRI), *សិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជា* (*Land Tenure in Cambodia*) *– A Data Update*, Working Paper 19, November 2001, Phnom Penh.

Castellanet, C., *ការពិនិត្យឡើងវិញនៃសេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា* (*A review of agricultural extension services in Cambodia*) World Bank, ខែតុលា 2003, Washington DC.

Chea, Yim and McKenney, Bruce, *ការនាំត្រីចេញពីបឹងទន្លេសាបៈ ការវិភាគអំពីប្រព័ន្ធបង់ថ្លៃ* (*Great Lake Fish Exports: An Analysis of the Fee System*) Cambodia Development Review, Volume 7 Issue 3, ខែកក្កដា-កញ្ញា 2003, Phnom Penh.

Deger, P., Van Acker, F., Van Zalinge, N., Thuok, N., and Vuthy, L., *Taken for Granted: វិវាទលើធនធានត្រីទឹកសាបរបស់កម្ពុជា (Conflicts over Cambodia's Freshwater Fish Resources)* គណៈកម្មការទន្លេមេគង្គ/សកលវិទ្យាល័យ Antwerp ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ខែមិថុនា 2000, Phnom Penh.

FAO, Investment Center Division, *ការវិភាគប្រភពនៃកំណើននៅតំបន់ជនបទ (Analysis of Sources of Growth in Rural Areas)* សេចក្តីព្រាង ខែកក្កដា 2003, Rome.

GRET, IRAM, CEDAC, *ស្ថានភាពតំបន់ជនបទនៅកម្ពុជា និងប្រព័ន្ធអប់រំផ្នែកកសិកម្ម ក្រសួងកសិកម្ម (scenario for the rural sector of Cambodia and the agricultural education system)* ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ APIP, ខែធ្នូ 2000, Phnom Penh.

Gummert, M., PRASAC II, ការវាយតំលៃនៃស្ថានភាពកសិឧស្សាហកម្មនៅកម្ពុជា (*Assessment of the Agro-Industrial Situation in Cambodia*) ខែកុម្ភៈ 2003, គណៈកម្មការសហគមន៍អឺរ៉ុប Phnom Penh.

Helmers, K., Gibson., J., and Wallgren, P., *ការសិក្សាពីប្រភពចំណូលជនបទនិងយុទ្ធសាស្រ្តនៃជីវភាពរស់នៅ (Rural Sources of Income and Livelihood Strategies Study)* របាយការណ៏ចុងក្រោយ ខែធ្នូ 2003, Washington DC.

International Monetary Fund, IMF របាយការណ៏ប្រទេស 03/59 – កម្ពុជា: *បញ្ហាជ្រើសរើស និងឧបសម្ព័ន្ធស្ថិតិ (Cambodia: Selected Issues and Statistical Appendix)* ខែមិនា 2003, http://www.imf.org/external/pubs/ft/scr/2003/cr0359.pdf

Kingdom of Cambodia, Council for Social Development, *យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ (National Poverty Reduction Strategy) 2003-2005*, ខែធ្នូ 2002, Phnom Penh.

Millington, Peter, *កម្ពុជា-ការសិក្សាប្រវត្តិអំពីការគ្រប់គ្រងធនធានទឹកនិងការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្ត (Cambodia - Background Study on Water Resources Management and Irrigation/Drainage Development)* រៀបចំសំរាប់ធនាគារពិភពលោក 2003.

Ministry of Agriculture, Forestry and Fisheries, *សន្និសិទ្ធប្រចាំឆ្នាំស្តីពីកសិកម្ម ២០០៣-២០០៤* (*Annual Conference on Agriculture, 2003-2004*) បកប្រែក្រៅផ្លូវការ Phnom Penh.

Ministry of Agriculture, Forestry and Fisheries, GRET, *ស្ថានភាពបច្ចុប្បន្ននៅកម្ពុជា និងប្រព័ន្ធអប់រំផ្នែកសិកម្ម* (*Scenarios for the Rural Sector of Cambodia and the Agricultural Education System*) គំរោងកែលំអផលិតភាពកសិកម្ម ខែធ្នូ 2000, Phnom Penh.

Ministry of Commerce, សមាហរណកម្មនិងការសិក្សាអំពីភាពប្រកួតប្រជែង (*Integration and Competitiveness Study*) ខែវិច្ឆិកា 2001, Phnom Penh.

Ministry of Planning, National Institute of Statistics, *អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ១៩៩៩* (*Cambodia Socio-Economic Survey 1999*) Phnom Penh.

National Institute of Statistics, ជំរឿនទូទៅនៃប្រជាជនកម្ពុជា ១៩៩៨ (*General Population Census of Cambodia*, 1998) Phnom Penh, អាចរកបានតាម http://www.nis.gov.kh/Statistics.htm.

National Institute of Statistics, *Yearbook 2001*, Phnom Penh, អាចរកបានតាម http://www.nis.gov.kh/Statistics.htm.

Oxfam, *របាយការណ៍បឋមអំពីលទ្ធផលនៃ ការអត់ដីធ្លី និងឧបករណ៍ពត៌មានអភិវឌ្ឍន៍* (*Interim Report on Findings of Landlessness and Development Information Tool (LADIT)*) 2000, Phnom Penh.

Royal Government of Cambodia, *ផែនការសេដ្ឋកិច្ចសង្គមកិច្ច* (Second Socioeconomic Development Plan)

Sophal, Chan and Sarthi Acharya, *ការប្រឈមការលំបាកជីវភាពជនបទ: ទិដ្ឋភាពមួយនៃភូមិចំនួន ៩នៅកម្ពុជា* (*Facing the Challenge of Rural Livelihoods: A Perspective from Nine Villages in Cambodia*) Working Paper 25, Cambodia Development Resource Institute (CDRI), Phnom Penh.

Torres, Olga, *ហិរញ្ញវត្ថុជនបទ និងផ្នែកមីក្រូហិរញ្ញវត្ថុនៅកម្ពុជា* (Rural *finance and the Micro-finance Sector in Cambodia*) ខែមករា 2004, Phnom Penh.

Umali-Deininger, Dina, *ការផ្សព្វផ្សាយកសិកម្មសាធារណៈនិងឯកជនៈ ដៃគូរឬប្រឆាំង* (*Public and Private Agricultural Extension: Partners or Rivals?*) The World Bank Research Observer, Volume 12, Number 2, ខែសីហា 1997, Washington DC.

Vindel, Bruno, *ការសិក្សាវិភាគនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្តមួយចំនួន* (*Diagnostic Study of Selected Provincial Departments of Agriculture, Forestry and Fisheries*) រៀបចំសំរាប់ធនាគារពិភពលោក ខែតុលា 2003, Phnom Penh.

World Bank, *សៀវភៅវិនិយោគកសិកម្ម* (*Agriculture Investment Sourcebook*) អាចរកបានតាម http://www-esd.worldbank.org/ais

World Bank, *កម្ពុជា-ការវាយតំលៃយេនឌ័រទូទាំងប្រទេស* (*Cambodia – Country Gender Assessment*) 2003.

World Bank and Asian Development Bank, *កម្ពុជាៈ លើកកំពស់ការចែកចាយសេវាតាមរយៈ ការកែលំអការបែងចែកធនធាននិងកំណែទំរង់ស្ថាប័ន. ការវាយតំលៃភាពត្រឹមត្រូវ និងការពិនិត្យឡើងវិញ ការចំណាយសាធារណៈ (IFAPER)* (*Cambodia: Enhancing Service Delivery through Improved Resource Allocation and Institutional Reform, Integrated Fiduciary Assessment and Public Expenditure Review (IFAPER)*) ខែកញ្ញា 2003, Washington DC.

World Bank, *កម្ពុជាៈ ការឆ្លៀតយកកាលានុវត្តភាពពិភពលោក — ការវាយតំលៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកំណែទំរង់* (*Cambodia: Seizing the Global Opportunity - Investment Climate Assessment and Reform Strategy*) 2004, Washington DC.

World Bank, *ការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិនៅកម្ពុជា-កាត់បន្ថយភាពងាយរងគ្រោះ* (*Natural Disaster Risk Management in Cambodia – Reducing Vulnerability*) សេចក្តីព្រាងចំលងសំរាប់ពិភាក្សា, 2003.

World Bank, PPIAF, MPDF, IFC, *ឆ្ពោះទៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកឯកជនសំរាប់កម្ពុជា* (*Towards a Private Sector Development Strategy for Cambodia*) upcoming draft, 2004.

# ឧបសម្ព័ន្ធ ១: គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា

| សូចនាការជ្រើសរើស | ឆ្នាំគោល | ២០១៥ |
|---|---|---|
| **MDG1: ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន** | **លុបបំបាត់ពាក់កណ្តាលសមាមាត្រប្រជាជនដែលទទួលរងដោយការអត់ឃ្លាន** | |
| សមាមាត្រប្រជាជនដែលមានចំណូលទាបជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | 39 (1993) | 19.5 |
| សមាមាត្រនៃបញ្ចូភាគក្របំផុតក្នុងចំណាយថ្នាក់ជាតិ | 7.4 (1993) | 11 |
| អត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទំងន់អាយុក្រោម ៥ឆ្នាំ | 45.2 (2000) | 22.6 |
| អត្រាប្រេវ៉ាឡង់នៃកុមារស្គមអាយុក្រោម ៥ឆ្នាំ | 15 (2000) | 9 |
| **MDG 2: សំរេចបានជាសកលការអប់រំមូលដ្ឋាន ៩ឆ្នាំ** | **ធានាឱ្យកុមារទាំងអស់បញ្ចប់ការសិក្សាមូលដ្ឋាននៅឆ្នាំ ២០១៥** | |
| អត្រាពិតចូលរៀនថ្មី | 59 (1997) | 100 |
| អត្រាពិតនៃការសិក្សាក្នុងការអប់រំបឋមសិក្សា | 78 (1997) | 100 |
| អត្រាពិតនៃការសិក្សាក្នុងមធ្យមសិក្សា | 14 (1997) | 75 |
| **MDG 3: លើកកំពស់សមភាពយេនឌ័រ និងផ្តល់អំណាចដល់ ស្ត្រី** | កាត់បន្ថយភាពខុសគ្នានៃយេនឌ័រនៅគ្រប់កំរិតសិក្សាទាំងអស់ | |
| អត្រាសិស្សស្ត្រីធៀបនឹងសិស្សប្រុសនៅមធ្យមសិក្សាទុតិយភូមិ | 47 (2002) | 100 |
| អត្រាសិស្សស្ត្រីធៀបនឹងសិស្សប្រុសក្រោយមធ្យមសិក្សា | 19 (1997) | 85 |
| សមាមាត្រនៃអសនៈរបស់ស្ត្រីនៅរដ្ឋសភា | 6 (1993) | 30 |
| **MDG4: កាត់បន្ថយអត្រាមរណៈភាពកុមារ** | កាត់បន្ថយអត្រាមរណៈភាពកុមារអាយុក្រោម ៥ឆ្នាំ | |
| អត្រាមរណៈភាពអាយុក្រោម ៥ឆ្នាំ (ក្នុង១000 កំណើតរស់) | 124 (2000) | 65 |
| អត្រាមរណៈភាពទារក (ក្នុង១000 កំណើតរស់) | 95 (1997) | 50 |
| សមាមាត្រកុមារអាយុក្រោមមួយឆ្នាំដែលបានចាក់ថ្នាំការពារជំងឺកញ្ជ្រឹល | 41 (2000) | 90 |
| MDG5: លើកកំពស់សុខភាពមាតា | កាត់បន្ថយអត្រាមរណៈភាពមាតា | |

| | | |
|---|---|---|
| អត្រាមរណៈភាពមាតា (ក្នុង១០០ ០០០ កំណើតរស់)<br>សមាមាត្រនៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ | 437 (2000)<br>32 (2000) | 140<br>80 |
| **MDG6: ប្រយុទ្ធប្រឆាំងនឹងមេរោគ HIV/AIDS, គ្រុនចាញ់ និង ជំងឺផ្សេងៗ** | បន្ថយការរាលដាលនៃជំងឺ HIV/AIDS, គ្រុនចាញ់ គ្រុនឈាម និងរបេង | |
| អត្រាប្រេវ៉ាឡង់នៃមេរោគ HIV ក្នុងចំណោមមនុស្សពេញវ័យ អាយុពី ១៥-៤៩ ឆ្នាំ<br>អត្រាស្លាប់ដោយគ្រុនចាញ់រាយការណ៍ដោយផ្នែកសុខាភិបាលសាធារណៈ | 2.6 (2002)<br>0.4 (2000) | 1.8<br>0.1 |
| **MDG7: ធានាចិរភាពបរិស្ថាន** | **សំរេចចំណុចដៅស្ដង់ដារផ្សេងៗដើម្បីធានាចិរភាពបរិស្ថាន** | |
| ទំហំព្រៃឈើជាភាគរយនៃផ្ទៃដីសរុប<br>សមាមាត្រនៃប្រជាជនជនបទដែលមានលទ្ធភាពទទួលបានប្រភពទឹកស្អាត<br>សមាមាត្រនៃប្រជាជនជនបទដែលមានលទ្ធភាពទទួលបានអនាម័យល្អ | 61 (2002)<br>24 (1998)<br>8.6 (1998) | 60<br>50<br>30 |
| **MDG8: បង្កើតភាពជាដៃគូជាសកលសំរាប់ការអភិវឌ្ឍន៍**<br>ចំណុចដៅដែលបានធ្វើមូលដ្ឋានីយកម្មនឹងត្រូវបញ្ចប់ | | |
| **MDG9: ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងជំនួយដល់អ្នករងគ្រោះ**<br>ចំណុចដៅ: ឆ្ពោះទៅគ្មានផលប៉ះពាល់ពីគ្រាប់មីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ នៅឆ្នាំ ២០១២<br>ចំណុចដៅ: លុបបំបាត់ផលប៉ះពាល់អវិជ្ជមាននៃគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទៅលើមនុស្សជាតិនិងសេដ្ឋកិច្ចសង្គមកិច្ចនៅឆ្នាំ ២០២៥ | | |

ប្រភព: UNDP

# ឧបសម្ព័ន្ធទី ២: ប្រព័ន្ធដាំដុះ

១- **កម្ពុជាគឺជាប្រទេសដែលមានប្រព័ន្ធដាំដុះច្រើនប្រភេទ** ដែលអាចបែងចែកជា ៧ក្រុមសំខាន់ៗ[៩៥]: ប្រព័ន្ធដាំដុះស្រូវ ៤ប្រភេទ ប្រព័ន្ធដាំដុះដំណាំចំការ ២ប្រភេទ និងប្រព័ន្ធផលិតកម្មឧស្សាហកម្មដែលនៅមានកំរិតនៅឡើយមួយប្រភេទ។ ប្រព័ន្ធទាំងនេះខុសៗគ្នាទៅតាមសក្តានុពលរៀងៗខ្លួនក្នុងការធ្វើប្រពលវប្បកម្ម ការធ្វើពិពិធកម្ម និងការធ្វើពាណិជ្ជកម្ម។ ប៉ុន្តែ ប្រព័ន្ធដាំដុះស្រូវដែលផ្អែកលើទឹកភ្លៀងត្រូវបានបង្ហាញដោយផលិតភាពទាប ប្រមូលផ្តុំប្រហែល ៧០%នៃប្រជាជនជនបទ តំណាងឱ្យ ៨០%នៃតំបន់ដាំដុះស្រូវ និង៧០%នៃការផលិតស្រូវដែលពន្យល់អំពីការអនុវត្តន៍នៅមានកំរិតទាបបើពិនិត្យក្នុងកំរិតរួម។

២- **ប្រភេទបួនយ៉ាងសំខាន់ៗនៃប្រព័ន្ធដាំដុះស្រូវរួមមាន** (1) មួយប្រភេទដែលបានរកឃើញនៅតំបន់ទំនាបគ្មានប្រព័ន្ធធារាសាស្ត្រ ដែលបង្ហាញពីលក្ខណៈដាំដុះស្រូវដែលមានផលិតភាពទាបនិងផ្អែកតាមទឹកភ្លៀងជាញឹកញាប់មានពាក់ព័ន្ធជាមួយដើមត្នោត។ ប្រព័ន្ធនេះឃើញមានអនុវត្តក្នុងចំណោមកសិករ (សូមអានតារាង xx)។ ការប្រែប្រួលថ្មីៗនេះរួមមានការណែនាំឱ្យមានការដាំដុះពីរដង។ (2) តំបន់សំរកទឹកជំនន់ដែលការត្រួតពិនិត្យទឹកអនុញ្ញាតិឱ្យមានការដាំស្រូវប្រពលវប្បកម្ម ដោយមានការត្រួតពិនិត្យបាននូវទឹកល្អនិងដីមានជីជាតិ ការវិវត្តន៍អាចធ្វើបានលឿនឬមួយឆ្ពោះទៅការធ្វើឯកទេសកម្មក្នុងការដាំដុះស្រូវប្រពលវប្បកម្ម ដោយមានការប្រមូលផ្តុំលើផ្ទៃដីនិងការបង្កើតកំលាំងពលកម្មដែលផ្តល់បៀវត្សរ៍ ឬមួយឆ្ពោះទៅការធ្វើពិពិធកម្មនៃផលិតកម្ម។ (3) ស្រូវឡើងទឹក នៅក្នុងវាលស្រែលិចទឹកដីធំ ដែលនៅទីនោះលក្ខណៈដីធំធេងនៃការអនុវត្តន៍ការដាំដុះអនុញ្ញាតិឱ្យមានផលិតភាពពលកម្មល្អ ប៉ុន្តែក្នុងនោះហានិភ័យជំនន់ខ្ពស់។ ប្រព័ន្ធទាំងនេះគឺអវឌ្ឍនៈ និងវិវត្តន៍ឬមួយទៅជាការដាំស្រូវពេលទឹកជំនន់ស្រកចុះ ឬមួយទៅជាការដាំដុះពីរដងដោយមានប្រព័ន្ធស្រោចស្រព និង (4) ប្រព័ន្ធដាំដុះស្រូវតំបន់ខ្ពង់រាប ពាក់ព័ន្ធនឹងការរៀបចំដីបែបពនេចរដែលភាគច្រើនស្ថិតនៅតំបន់ដែលមានដង់ស៊ីតេប្រជាជនតិចនៃខេត្តភាគឦសាន្ត។ ប្រព័ន្ធទាំងនេះផ្អែកតិចតួចណាស់លើការដាំដុះស្រូវ ដោយមានកំណើនប្រជាជនហូរចូល និងមានការអភិវឌ្ឍន៍ការដាំដំណាំសំរាប់លក់ដោយអ្នកចំណាកស្រុក។

៣- ការដាំដំណាំចំការសំដៅទៅប្រព័ន្ធដាំដុះពហុភាពដ៏ទូលំទូលាយដែលក្នុងនោះ គេច្រើនដាំស្រូវាគច្រើន ប៉ុន្តែការដាំដុះភាគច្រើនមិនស្រោចទឹកទេ។ ការដាំដុះចំការអាចបែងចែកជា ក្រុម (1) ប្រព័ន្ធដាំដុះតាមឆ្នេរទន្លេ គ្របដណ្តប់ភាគច្រើនដោយប្រព័ន្ធដាំដុះដែលមានលក្ខណៈពិពិធកម្មទៅ តាមខួបទឹកជំនន់

[95] APIP/GRET-IRAM-CEDAC, 2001

ប្រចាំឆ្នាំ ដោយមានសក្តានុពលអភិវឌ្ឍន៍ខ្ពស់។ តំលៃដីមានកំរិតខ្ពស់ និងការប្រមូលផ្តុំដីនាំ ឱ្យការកើតមាននូវចំការធំៗដោយមានការប្រើគ្រឿងយន្តនិងការប្រើប្រាស់នូវកំលាំងពលកម្មតិចតួច។ (2) ប្រព័ន្ធដាំដុះតំបន់ខ្ពង់រាប ដីក្រហមនិងខ្មៅដែលការដាំដំណាំកៅស៊ូត្រូវបានប្រមូលផ្តុំនៅទីនោះ ហើយដំណាំ សំរាប់លក់ផ្សេងទៀតមានការអភិវឌ្ឍន៍លឿន។ អនាគតនៃប្រព័ន្ធទាំងនេះអាស្រ័យលើការរៀបចំរចនាសម្ព័ន្ធ ឡើងវិញនៃឧស្សាហកម្មកៅស៊ូ និងការអភិវឌ្ឍន៍ដំណាំប្រចាំឆ្នាំ ជាពិសេស ពោត សណ្តែកសៀង និងដំណាំដីទៃទៀតដូចជា ស្វាយចន្ទី ឬចេក។

៤- ប្រព័ន្ធចុងក្រោយគេគឺបែបទំនើប អតិមូលធនដែលគេឃើញភាគច្រើននៅក្បែរទីក្រុងនានា ឬមួយនៅតំបន់ឆ្នេរមាត់ទន្លេ (ក្បែរទីក្រុងភ្នំពេញ) ឬក៏លាយឡំឆ្នេរមាត់ទន្លេ និងទំនាប (បាត់ដំបង សៀមរាប) ដំណាំដាំដុះជាសួនបែបប្រពលវប្បកម្មសំរាប់លក់នៅទីផ្សារ ការចិញ្ចឹមមាន់ជាលក្ខណៈឧស្សាហកម្ម ដីចំការឈើហូបផ្លែ ។ល។ ការវិវត្តន៍នៃប្រព័ន្ធនេះនឹងពឹងផ្អែកទៅលើការពង្រីកទីផ្សារតំបន់ទីប្រជុំជន ថ្លៃពលកម្ម និងការអភិវឌ្ឍន៍នៃការប្រើប្រាស់មូលធនក្នុងជំរើសផ្សេងទៀតនៅក្នុងផ្នែកសេដ្ឋកិច្ចផ្សេងទៀត ក៏ដូចជាពឹងផ្អែកទៅលើការវិវត្តន៍នៃទីផ្សារខាងក្រៅសំរាប់ការនាំចេញនូវទំនិញសំខាន់ៗ (ប្រេងដូង សណ្តែកសៀង ស្វាយចន្ទី ។ល ។)

***សារៈសំខាន់នៃប្រព័ន្ធដាំដុះសំខាន់ៗ ឆ្នាំ២000 (ប្រភពៈការសិក្សារបស់អង្គការ ហ្គ៉េត,អាវ៉ូន)***

| | ទំនាប (ស្រូវ) | ស្រូវប្រដេញទឹក | ស្រូវឡើងទឹក | ស្រូវតាមឆ្នេរមាត់ទន្លេ | ដីក្រហម | ពនេរចរ | ទំនើប/អតិមូលធន | សរុប |
|---|---|---|---|---|---|---|---|---|
| ប្រជាជនជនបទ (លាន) | 7.5 | 0.75 | 0.125 | 1.5 | 0.8 | 0.07 | - | 10.75 |
| គ្រួសារ (ពាន់ដង) | 1,500 (70%) | 150 (7%) | 25 (1%) | 300 (14%) | 160 (7%) | 14 (0.6%) | 5 (0.2%) | 2,149 |
| ផ្ទៃដីដាំ ស្រូវ (ពាន់ហិកតា) | 1,500 (81%) | 150 (8%) | 56 (3%) | 100 (5%) | 24 | 14 | 0 | 1,844 |
| ទិន្នផល/ហិកតា[ក] | 1.75 | 3.5 | 2.0 | 3.5 | 2.3 | 1.5 | - | 2.0 |
| %នៃផលិតកម្មស្រូវ | 71% | 14 % | 3% | 9% | 1.5% | 0.5% | 0 | 3,688 លានតោន |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ការប៉ាន់ប្រមាណកំណើនប្រជាជននៅឆ្នាំ ២០២០ (លាន) | 4.03 | 0.40 | 0.67 | 0.80 | 0.43 | 0.38 | 0.003 | 5.73 |

ក/មធ្យមភាគបីឆ្នាំ ជាតោន/ហិកតា

**៥. ជំរើសក្នុងការធ្វើប្រពលវប្បកម្ម និងពិពិធកម្មក្នុងតំបន់ទំនាបដែលពឹងផ្អែកលើទឹកភ្លៀង។** ការដាំដុះស្រូវ ដែលពឹងផ្អែកលើទឹកភ្លៀងគឺមានសារៈសំខាន់ជាពិសេសក្នុងតំបន់ពីដែលមានប្រជាជនរស់នៅច្រើន-ខេត្តតំបន់ ទំនាបក្នុងភាគអាគ្នេយ៏ (ព្រៃវែង ស្វាយរៀង តាកែវ កំពត និងភាគខាងជើងកំពង់ចាម) និងខេត្តភាគនិរតី នៃតំបន់បឹងទន្លេសាប (បាត់ដំបង សៀមរាប បន្ទាយមានជ័យ)។ ការដាំដុះពីរដងដោយមានប្រព័ន្ធស្រោចស្រព បានអភិវឌ្ឍជាសំខាន់នៅខេត្តភាគអាគ្នេយ៏ដែលនៅជុំវិញទីក្រុងភ្នំពេញ (កណ្តាល តាកែវ ព្រៃវែង កំពង់ចាម កំពង់ស្ពឺ កំពត)។

**៦.** ការខ្វះខាតទឹកនិងដីដែលមានជីជាតិទាបគឺជាឧបសគ្គដ៏សំខាន់ដល់ការធ្វើប្រពលវប្បកម្មនៃប្រព័ន្ធដាំដុះ និងការបញ្ចូលគ្នានៃប្រព័ន្ធធារាសាស្ត្រនិងការប្រើប្រាស់នូវប្រភេទស្រូវប្រាំងផ្សេងៗដែលល្អ ជាជំរើសដ៏សំខាន់នៃការធ្វើប្រពលវប្បកម្ម ផ្តល់នូវអត្រាថ្លៃស្រូវធៀបនឹងថ្លៃវត្ថុធាតុដើម (ធាតុចូល) វិវត្តន៏ទៅដោយសមស្រប (រួមមានថ្លៃប្រេងឥន្ទនៈសំរាប់បូមទឹក) ហើយការគាំទ្រដ៏សំខាន់ត្រូវបានផ្តល់ក្នុងលក្ខណៈជាការស្រាវជ្រាវនិងផ្សព្វផ្សាយដែលមានលក្ខណៈវិមជ្ឈការ ការបណ្តុះបណ្តាលកសិករ និងភាពដែលអាចទទួលបាននៃឥណទាន និងគុណភាពធាតុចូល។ ក្នុងចំណោមកាលានុវត្តភាពដែលអាចមាន ការអភិវឌ្ឍន៏នៃការចិញ្ចឹមត្រីខ្នាតតូចគឺជាក្តីសង្ឃឹមមួយដ៏ធំ ឬក៏ការអភិវឌ្ឍន៏ការដាំដុះបន្លែនារដូវក្តៅ នៅពេលទីផ្សារកើតមាន។ ប៉ុន្តែ សមត្ថភាពនៃប្រព័ន្ធទាំងនេះដើម្បីស្រូបយកប្រជាជនបន្ថែមទៀតនៅក្នុងឆ្នាំខាងមុខនេះ គឺនៅមានកំរិត ដូចដែលបានចង្អុលបង្ហាញដោយផ្ទៃដីដាំដុះទាបដែលមានក្នុងមួយគ្រួសារ (តិចជាង ១ហិកតានៅភាគអាគ្នេយ៏[៩៦] ដែលពុំមានដីទំនេឡើយ ហើយតិចជាង ១,៥ហិកតានៅភាគនិរតី)។ តុល្យភាពនៃប្រព័ន្ធទាំងនេះគឺពឹងផ្អែកយ៉ាងខ្លាំងផងដែរទៅលើការអភិវឌ្ឍន៏កាលានុវត្តភាពចំណូលពីការងារក្រៅពីស្រែចំការ (ដោយដឹងពីទិន្នផលបច្ចុប្បន្ន ត្រូវយក ០,៩ហិកតានៃការដាំស្រូវ ដើម្បីបំពេញតំរូវការម្ហូបអាហារនៃគ្រួសារដែលមានប្រាំនាក់) ហើយកសិករភាគច្រើនពឹងផ្អែកលើចំណូលមិនមែនបានមកពីការធ្វើស្រែចំការ

[96] ៣០ឆ្នាំមុនផ្ទៃដីជាមធ្យមមានពីរដងធំជាង។

សកម្មភាពដាំដុះក្រៅពីស្រូវ (នេសាទ ផលិតស្ករត្នោត អារឈើ ធ្វើត្បូង និងចំណាកស្រុកតាមរដូវមកទីក្រុង) បានជាង ៥០%នៃចំណូលរបស់ពួកគាត់។

**៧.** ការពង្រីកប្រព័ន្ធដាំដុះស្រូវប្រដេញទឹក។ប្រព័ន្ធដាំដុះស្រូវប្រដេញទឹកបានពង្រីកយ៉ាងលឿន (ទោះបីជាពីមូលដ្ឋានផ្ទៃដីតូចក៏ដោយ) ទាំងតាមរយៈការកាប់ព្រៃលិចទឹកនិងដោយការបំលែងប្រព័ន្ធដាំដុះស្រូវឡើងទឹក ដោយមានការអភិវឌ្ឍន៍តាមរយៈការវិនិយោគប្រព័ន្ធគ្រប់គ្រងទឹក ការទទួលយកពូជស្រូវស្រាល និងការបង្កើនការប្រើប្រាស់ជី[៩៧]។ ប្រព័ន្ធដាំដុះស្រូវប្រដេញ ទឹក គឺជាការដាំដុះមានលក្ខណៈអតិពលកម្ម និងប្រើធាតុចូលច្រើន និងមានទិន្នផលដល់ ៣តោន/ហិកតាដែលអាចទទួលបានដោយមិនបាច់ ប្រើជីបន្ថែម។ ប្រសិនបើប្រព័ន្ធធារាសាស្រ្តអាចគ្រប់គ្រងបាននិងដោយមានការ ត្រួតពិនិត្យគ្រប់គ្រាន់ចំពោះសត្វល្អិតចង្រៃនិងការគ្រប់គ្រងជី អាចទទួលបានទិន្នផលដល់ ៦-៧តោនក្នុងមួយ ហិកតា។ ប្រព័ន្ធទាំងនេះពឹងផ្អែកតិចតួចលើចំណូលមិនមែនស្រែចំការ ហើយចំណែកដីធំនៃផលិតកម្ម ដាំដុះ ត្រូវបានលក់ទៅទីផ្សារ។ ថ្លៃដីកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងតំបន់ទាំងនោះ ហើយការប្រមូលផ្តុំដីផ្តល់ផល ប្រយោជន៍ ដល់អ្នកមានទ្រព្យសម្បត្តិច្រើនឬ កសិករដែលមានទព្វសំភារៈគ្រប់គ្រាន់ត្រូវបានគេសង្កេតឃើញ។ កត្តាកំណត់ដ៏សំខាន់ៗសំរាប់ប្រពលវប្បកម្មនាពេលអនាគត និងការអភិវឌ្ឍន៍ប្រព័ន្ធទាំងនេះរួមមាន ការវិវត្តន៍នៃអត្រាថ្លៃស្រូវ/ធាតុចូល[៩៨] លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្មដែលដោះស្រាយនូវ ឧបសគ្គជាក់លាក់នៃបរិយាកាសសង្គម លទ្ធភាពទទួលបានកំលាំងពលកម្ម (ឬការទទួលយកពូជផ្សេងៗគ្នា-ព្រោះពូជដោយផ្ទាល់-មិនសូវពឹងផ្អែកលើកំលាំងពលកម្ម) និងសកម្មភាពរបស់រដ្ឋាភិបាលដើម្បីរក្សាព្រៃលិច ទឹកដែលនៅសល់។ ប្រព័ន្ធដាំដុះស្រូវឡើងទឹក ដែលងាយទទួលរងគ្រោះខ្លាំងដោយទឹកជំនន់ ត្រូវបានបំលែងបន្តិចម្តងៗ ទៅជាប្រព័ន្ធដាំដុះស្រូវប្រដេញទឹកដោយមានការវិនិយោគក្នុងការកែលំអពូជស្រូវផ្សេងៗ និងក្នុងធារាសាស្រ្តធុនតូច (ម៉ាស៊ីនបូមទឹក អណ្តូងស្នប់)។ ប្រព័ន្ធដាំដុះស្រូវតាមឆ្នេរមាត់ទន្លេ រួមមាន ប្រពលវប្បកម្មពហុវប្បកម្មដំណាំ ដាំដុះ និងការចិញ្ចឹមសត្វ) ឬប្រព័ន្ធដាំដុះ-ចិញ្ចឹមត្រី និងដាំដុះ-ចិញ្ចឹមសត្វ-ចិញ្ចឹមត្រី ហើយគ្រួសារជាធម្មតា ចូលរួមពាក់ព័ន្ធនឹងសកម្មភាពជាច្រើនអាស្រ័យទៅតាមកាលានុវត្តភាព មូលដ្ឋាន (នេសាទ លក់អុស អាជីវកម្មតូច ការងារបណ្តោះអាសន្នឬអចិន្ត្រៃនៅភ្នំពេញនៃសមាជិកគ្រួសារម្នាក់ ។ល។)។ នៅក្រោមសម្ពាធ ប្រជាជនដែលចេះតែកើនឡើង ការកាប់ឆ្ការព្រៃលិចទឹកដែលជា

---

[97] នេះជាប្រព័ន្ធមួយដែលត្រូវបានផ្តល់អនុសាសន៍ឱ្យប្រើដោយការស្រាវជ្រាវជាតិនិងសេវាផ្សព្វផ្សាយសមនឹងយុទ្ធសាស្រ្តនិងឧបសគ្គរបស់កសិករ។

[98] និន្នាការបច្ចុប្បន្នគឺការធ្វើពិពិធកម្មការដាំដុះផ្សេងៗគ្នា (ឧទាហរណ៍ mung bean )

ដីបំរុងដែលនៅសល់កំពុងតែកើតមានឡើង  ក៏ដូចជាការប្រមូលផ្តុំដីដែលផ្តល់ផលប្រយោជន៏ដល់កសិករដែលប្រឹងប្រែងបូកបន្ថែមនូវទ្រព្យរបស់ខ្លួន (ម៉ាស៊ីនបូមទឹក ត្រាក់ទ័រ មធ្យោបាយដឹកជញ្ជូន ។ល។) ។ ការវិវត្តន៏នៃប្រព័ន្ធដាំដុះតាមឆ្នេរមាត់ទន្លេដែល មានទិសដៅពាណិជ្ជកម្មជាយូរមកហើយដោយសារភាពងាយស្រួលទៅដល់ទីប្រជុំជននឹងត្រូវបានផ្សារភ្ជាប់ ទៅនឹងការអភិវឌ្ឍន៏នៃវិស័យឧស្សាហកម្មនិងសេវាកម្មនិងការពង្រីកទីផ្សារម្ហូបអាហារនៅទីប្រជុំជន ។

៨- **ពិពិធកម្មនិងការអភិវឌ្ឍន៏ប្រព័ន្ធដាំដុះចំការ** ។ ប្រព័ន្ធដាំដុះពនេរចរ និងដីក្រហមដីខ្មៅតំបន់ខ្ពង់រាបពង្រីកទៅដល់តំបន់រួមមាន រតនៈគីរីនិងមណ្ឌលគីរី និងផ្នែកនៃខេត្តកំពង់ចាម ក្រចេះ និងកំពង់ធំ ។ កសិកម្មពនេចរគឺត្រូវបានអនុវត្តដោយក្រុមជនជាតិ (ប្រហែល ១៤.000គ្រួសារ) រស់នៅតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប ហើយការប្រមូលផលព្រៃឈើគឺជាប្រភពចំណូលដ៏សំខាន់សំរាប់គ្រួសារបន្ថែមទៅលើផលិតកម្មកសិកម្ម (ស្រូវ បន្លែ ក្តួច ចេក រុក្ខជាតិជាគ្រឿងផ្សំ បន្លែ) ។ និន្នាការថ្មីៗរួមមានការអភិវឌ្ឍន៏ការដាំស្វាយចន្ទី និងការងាររកស៊ីដែលអង្គុយច្រើន នៅជិតផ្លូវសំខាន់ៗ ។ ការធ្វើចំណូលស្រុកគឺសំខាន់ក្នុងតំបន់ទាំងនេះ[៩៩] ហើយនាំឱ្យមានការចាប់ផ្តើមផលិតកាហ្វេ កៅស៊ូ ដើមស្វាយចន្ទី និងសណ្តែកសៀងដែលតំរង់ទិសខាងពាណិជ្ជកម្ម ។ ការអភិវឌ្ឍន៏កសិកម្មនាពេលអនាគត នឹងពឹងផ្អែកលើគោលនយោបាយរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៏មូលដ្ឋាន ជាពិសេសជំរើសដែលនឹងត្រូវបានជ្រើសរើសសំរាប់ការបែងចែកដីធ្លីដែលផ្តល់នូវសក្តានុពលដ៏ធំធេង (តំបន់ខ្ពង់រាបដីក្រហមសំរាប់ការអភិវឌ្ឍន៏ការដាំដំណាំសំរាប់លក់ ឬតំបន់ទឹករាក់សំរាប់ការដាំស្រូវ) ក៏ដូចជាលទ្ធភាពទទួលបាននូវសេវាគាំទ្រកសិកម្មដែលអាចជំរុញការអភិវឌ្ឍន៏ប្រព័ន្ធដាំដុះប្រកបដោយចិរភាព នៅក្រោមកំណើនប្រជាជនបច្ចុប្បន្ន ។ ពិពិធកម្មបន្តទៅទៀតដល់ការដាំកៅស៊ូទ្រង់ទ្រាយតូច និងការដាំដំណាំអចិន្ត្រៃយ៏ផ្សេងទៀត (ស្វាយចន្ទី ចេក ។ល ។) នឹងពឹងផ្អែកលើការកែលំអសន្តិសុខនៃការកាន់កាប់ដីធ្លី ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ ឥណទាននិងសេវាផ្សព្វផ្សាយ ហើយក្នុងករណីកៅស៊ូគឺការរៀបចំរចនាសម្ព័ន្ធឡើងវិញនៃផ្នែកនេះ និងការកែលំអបរិស្ថានទីផ្សារ ។

៩- **សន្និដ្ឋាន:** កត្តាកំណត់ដ៏សំខាន់ៗនៃការវិវត្តន៏ប្រព័ន្ធដាំដុះទៅអនាគត ហើយបន្ទាប់មក ការកសាងសមត្ថភាពដើម្បីផ្តល់នូវការងារដែលទទួលបានប្រាក់កំរៃសំរាប់កំណើនដ៏លឿននៃប្រជាជន ពឹងផ្អែកទៅលើកត្តាមួយចំនួន កត្តាខ្លះនៅក្រៅក្របខ័ណ្ឌជនបទ ជាពិសេសការអភិវឌ្ឍន៏កាលានុវត្តភាពការងារនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មនៅតំបន់ទីប្រជុំជន ។ ប៉ុន្តែនិន្នាការទៅអនាគតនឹងអាស្រ័យនៅក្នុងក៏រិតមួយដ៏ធំ

[99] យោងតាមជំរឿនឆ្នាំ ១៩៩៨ ប្រជាជន២៥%នៃខេត្តរតនគីរីគឺជាជនចំណូលស្រុកមកពីខេត្តផ្សេងៗ និងប្រទេសជិតខាង ។

ទៅលើជំរើសគោលនយោបាយរបស់រដ្ឋាភិបាលសំរាប់តំបន់ជនបទ ដូចជាៈ (i) ការគ្រប់គ្រងដីធ្លី និងសន្តិសុខកម្មសិទ្ធិកាន់កាប់ ជាពិសេសនៅតំបន់ខ្ពង់រាប និងតំបន់ដែលមានដង់ស៊ីតេប្រជាជនតិចនៃភាគនីរតី ១៨ អាទិភាពសំរាប់ការវិនិយោគក្នុងប្រព័ន្ធធារាសាស្ត្រនិងការគ្រប់គ្រងទឹក ១៨ ដោះស្រាយឧបសគ្គម៉ាឃិតធីងនិងពាណិជ្ជកម្មសំរាប់ទំនិញសំខាន់ៗមួយចំនួន ( ស្រូវ ត្រី បសុសត្វ កៅស៊ូ ។ល ។) (iv) តំរង់ទិសឡើងវិញនៃប្រព័ន្ធស្រាវជ្រាវនិងផ្សព្វផ្សាយ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃប្រព័ន្ធដាំដុះពិពិធកម្ម (v) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសនៅតំបន់ដាច់ស្រយាលដែលមិនភ្ជាប់ទៅនឹងទីផ្សារនិងទីប្រជុំជន ។

# ឧបសម្ព័ន្ធទី ៣៖ ផែនទី